# ព្រះ
# ត្រៃបិដកបាលី
នឹង
សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
## អង្គុត្តរនិកាយ អដ្ឋកនិបាត
## សត្តមភាគ
# ៤៦

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ
ព.ស ២៤៩៧

សុត្តន្តបិដក
អង្គុត្តរនិកាយ អដ្ឋកនិបាត
សត្តមភាគ
៤៦
ព.ស. ២៤៩៧

# សុត្តន្តបិដកេ

## អង្គុត្តរនិកាយស្ស សត្តកនិបាតោ

## សត្តមោ ភាគោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

### បឋមបណ្ណាសកោ

### អាហុនេយ្យវគ្គោ

(១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សត្តហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។

# សុត្តន្តបិដក

## អង្គុត្តរនិកាយ សត្តកនិបាត

## សត្តមភាគ

*សូមនមស្ការចំពោះព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ*

### បឋមបណ្ណាសក

### អាហុនេយ្យវគ្គ

*(១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុដែលនៅក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលស្តាប់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលវត្ថុដែលគេរៀបចំដើម្បីភ្ញៀវ គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។*

កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ វិហរតិ សតោ សម្បជានោ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ នេវ សុមនោ ហោតិ ន ទុម្មនោ ឧបេក្ខកោ វិហរតិ សតោ សម្បជានោ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ ឥទមវោច ភគវា ។ អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុំ ។

(២) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ ឆហិ ។



ប្រកបដោយធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែក ជាអ្នកមិនត្រេកអរ មិនតាក់អន់ ជាអ្នកព្រងើយកន្តើយ ប្រកបដោយសតិសម្បជញ្ញៈ ឮសំឡេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ ... ទទួលរសដោយអណ្តាត ... ពាល់ត្រូវផ្សព្វៈដោយកាយ...ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ជាអ្នកមិនត្រេកអរ មិនតាក់អន់ ជាអ្នកព្រងើយកន្តើយ ប្រកបដោយសតិសម្បជញ្ញៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលនូវវត្ថុដែលគេរៀបចំទុកសម្រាប់ភ្ញៀវ គួរទទួលទក្ខិណាទាន គួរដល់អញ្ជលីកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។ លុះព្រះដ៏មានព្រះភាគ សំដែងសូត្រនេះចប់ហើយ ។ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយចំពោះភាសិត នៃព្រះដ៏មានព្រះភាគ ។

(២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។ ប្រកបដោយធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។

ឥធ ភិក្ខវេ ភិក្ខុ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆតិ សេយ្យថាបិ អាកាសេ បឋវិយាបិ ឧម្មុជ្ជនិមុជ្ជំ ករោតិ សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ គច្ឆតិ សេយ្យថាបិ បឋវិយំ អាកាសេបិ បល្លង្កេន កមតិ សេយ្យថាបិ បក្ខី សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរិមសតិ បរិមជ្ជតិ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។ ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណាតិ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ច ។ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានាតិ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ វីតរាគំ វា ចិត្តំ... សទោសំ វា ចិត្តំ... វីតទោសំ វា ចិត្តំ... សមោហំ វា ចិត្តំ...



ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងបាននូវការតាក់តែង ឬ សំដែងឫទ្ធិច្រើនប្រការបាន គឺមនុស្សម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន មនុស្សច្រើននាក់ ធ្វើឲ្យទៅជាម្នាក់ក៏បាន ធ្វើទីកំបាំងឲ្យទៅជាទីវាលក៏បាន ធ្វើទីវាលឲ្យទៅជាទីកំបាំងក៏បាន ដើរ(ចូល)ទៅក្រៅជញ្ជាំង ក្រៅកំពែង ក្រៅភ្នំ ឥតទើសទាល់ ដូចដើរទៅក្នុងអាកាសក៏បាន ធ្វើនូវការមុជងើបក្នុងផែនដី ដូចមុជងើបក្នុងទឹកក៏បាន ដើរទៅលើទឹក ឥតបែកធ្លាយទឹក ដូចជាដើរលើផែនដីក៏បាន អង្គុយទៅឯអាកាសទាំងពែនភ្នែន ដូចជាសត្វស្លាបក៏បាន ចាប់ស្ទាបអង្អែលព្រះចន្ទនិងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ដោយដៃក៏បាន ញុំាងអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយរហូតដល់ព្រហ្មលោកក៏បាន ។ ភិក្ខុមានសោតធាតុជាទិព្វដ៏បរិសុទ្ធ កន្លងសោតធាតុរបស់មនុស្សធម្មតា រមែងស្តាប់សំឡេងពីរប្រការ គឺសំឡេងទិព្វនិងសំឡេងមនុស្ស ក្នុងទីឆ្ងាយក៏បាន ជិតក៏បាន ។ ភិក្ខុរមែងកំណត់ដឹងច្បាស់នូវចិត្តរបស់សត្វដទៃ បុគ្គលដទៃដោយចិត្តរបស់ខ្លួន គឺចិត្តដែលប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈក្តី... ចិត្តដែលប្រកបដោយទោសៈក្តី... ចិត្តដែលប្រាសចាកទោសៈក្តី... ចិត្តដែលប្រកបដោយមោហៈក្តី ...

វីតមោហំ វា ចិត្តំ... សង្ខិត្តំ វា ចិត្តំ... វិក្ខិត្តំ វា ចិត្តំ... មហគ្គតំ វា ចិត្តំ... អមហគ្គតំ វា ចិត្តំ...សឧត្តរំ វា ចិត្តំ... អនុត្តរំ វា ចិត្តំ... សមាហិតំ វា ចិត្តំ... អសមាហិតំ វា ចិត្តំ... វិមុត្តំ វា ចិត្តំ... អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ ។ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាលីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្តកប្បេ អនេកេបិ វិវដ្តកប្បេ អនេកេបិ សំវដ្តវិវដ្តកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី



ចិត្តដែលប្រាសចាកមោហៈក្តី... ចិត្តដែលរួញរាក្តី... ចិត្តដែលរាយមាយក្តី... ចិត្តដែលជាមហគ្គតៈក្តី... ចិត្តដែលមិនមែនជាមហគ្គតៈក្តី... ចិត្តដែលជាសឧត្តរៈក្តី ចិត្តដែលជាអនុត្តរៈក្តី ចិត្តដែលតាំងមាំក្តី... ចិត្តដែលមិនតាំងមាំក្តី... ចិត្តដែលរួចចាកកិលេសក្តី... ចិត្តមិនរួចចាកកិលេសក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចចាកកិលេស ១ ។ តែងរលឹកឃើញខន្ធជាតិដែលខ្លួនធ្លាប់នៅអាស្រ័យ ក្នុងកាលមុនជាច្រើនជាតិ គឺរលឹកឃើញបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ មួយពាន់ជាតិ មួយសែនជាតិក៏បានខ្លះ រលឹកឃើញបានច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្តវិវដ្តកប្បក៏បាន ដូច្នេះថា អញបានកើត ក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ លុះអញច្យុតចាកភពនោះហើយ បានទៅកើត ក្នុងភពឯណោះ ដែលអញបានទៅកើត ក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ

ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ
ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ
អនុស្សរាមិ ។ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្ត-
មានុសកេន សត្តេ បស្សាមិ ចវមានេ ឧបបជ្ជមានេ
ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ
យថាកម្មូបគេ សត្តេ បជានាមិ ឥមេ វត ភោន្តោ
សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន
សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ
ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា
តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ
វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ
សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន
សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ
អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា
តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ
ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្ត-
មានុសកេន សត្តេ បស្សាមិ ចវមានេ ឧបបជ្ជមានេ



មានកំណត់អាយុប៉ុណ្ណេះ លុះអញច្យុតចាកភពនោះហើយក៏បានមកកើត
ក្នុងភពនេះ ភិក្ខុរលឹកឃើញនូវជាតិដែលខ្លួនធ្លាប់នៅអាស្រ័យ ក្នុងកាល
មុនបានច្រើនជាតិ ព្រមទាំងអាការទាំងឧទ្ទេស ដោយប្រការផ្សេងៗ ។
ភិក្ខុមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា ឃើញ
នូវសត្វទាំងឡាយដែលកំពុងច្យុតនិងកំពុងកើត មានសភាពថោកទាបនិង
ឧត្តម មានសម្បុរល្អ និងសម្បុរអាក្រក់ មានគតិល្អនិងគតិអាក្រក់ ដឹង
ច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វទាំងនេះ
ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត
ជាអ្នកតិះដៀលនូវព្រះអរិយៈទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់ខ្ជាប់នូវអំពើជា
មិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើត
ឯអបាយ ទុគ្គតិ វិនិបាត នរក អើហ្ន៎ ចំណែកឯសត្វទាំងនេះ ប្រកបដោយ
កាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិតជាអ្នកមិន
តិះដៀលនូវព្រះអរិយៈទាំងឡាយ ជាសម្មាទិដ្ឋិ ប្រកាន់ខ្ជាប់នូវអំពើជាសម្មា-
ទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតឯសុគតិ-
សួគ៌ទេវលោក ភិក្ខុមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់
មនុស្សធម្មតា បានឃើញនូវសត្វទាំងឡាយដែលច្យុត ដែលចាប់បដិសន្ធិ

ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។បេ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

(៣) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។បេ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ ឆហិ ។ សទ្ធិន្ទ្រិយេន វីរិយិន្ទ្រិយេន សតិន្ទ្រិយេន សមាធិន្ទ្រិយេន បញ្ញិន្ទ្រិយេន អាសវានញ្ច ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។



មានសភាពថោកទាប និងឧត្តម មានសម្បុរល្អនិងសម្បុរអាក្រក់ មានគតិល្អនិងគតិអាក្រក់ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មរបស់ខ្លួនដោយប្រការដូច្នេះ ១ ។ ភិក្ខុបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ទើបគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

(៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។ ប្រកបដោយធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុប្រកបដោយសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ទើបគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលវត្ថុដែលគេរៀបចំទទួលភ្ញៀវ គួរទទួលទក្ខិណាទាន គួរដល់អញ្ជលីកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

( ៦ ) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។បេ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ ឆហិ ។ សទ្ធាពលេន វីរិយពលេន សតិពលេន សមាធិពលេន បញ្ញាពលេន អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។បេ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

( ៧ ) ឆហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ រញ្ញោ ភទ្រោ អស្សាជានីយោ ខមោ ហោតិ រូបានំ ខមោ សទ្ទានំ ខមោ គន្ធានំ ខមោ រសានំ ខមោ ផោដ្ឋព្វានំ វណ្ណសម្បន្នោ ច ហោតិ ។



( ៦ ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។ ប្រកបដោយធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុប្រកបដោយសទ្ធាពលៈ ១ វីរិយពលៈ ១ សតិពលៈ ១ សមាធិពលៈ ១ បញ្ញាពលៈ ១ ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ទើបគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

( ៧ ) ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៦ យ៉ាង ជាសត្វគួរដល់ព្រះរាជា គួរជារាជបម្រើ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។ ប្រកបដោយអង្គ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ជាសត្វអត់ធន់នឹងរូប ១ អត់ធន់នឹងសំឡេង ១ អត់ធន់នឹងក្លិន ១ អត់ធន់នឹងរស ១ អត់ធន់នឹងការពាល់ត្រូវ ១ បរិបូណ៌ដោយសម្បុរ ១ ។

ឥមេហិ ខោ ភិក្ខវេ ឆហិ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។បេ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ ខមោ ហោតិ រូបានំ ខមោ សទ្ទានំ ខមោ គន្ធានំ ខមោ រសានំ ខមោ ផោដ្ឋព្វានំ ខមោ ធម្មានំ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។បេ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

(២) ឆហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ រញ្ញោ ភទ្រោ អស្សាជានីយោ ខមោ ហោតិ រូបានំ ខមោ សទ្ទានំ ខមោ គន្ធានំ ខមោ រសានំ ខមោ ផោដ្ឋព្វានំ វណ្ណសម្បន្នោ ច ហោតិ ។



ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៦ យ៉ាងនេះឯង ទើបជាសត្វគួរដល់ព្រះរាជា គួរជាគ្រឿងបម្រើ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ទើបគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកអត់ធន់នឹងរូប ១ អត់ធន់នឹងសំឡេង ១ អត់ធន់នឹងក្លិន ១ អត់ធន់នឹងរស ១ អត់ធន់នឹងការពាល់ត្រូវ ១ អត់ធន់នឹងធម្មារម្មណ៍ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ទើបគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

(២) ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៦ យ៉ាង ជាសត្វគួរដល់ព្រះរាជា គួរជាគ្រឿងបម្រើ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។ ប្រកបដោយអង្គ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ជាសត្វអត់ធន់នឹងរូប ១ អត់ធន់នឹងសំឡេង ១ អត់ធន់នឹងក្លិន ១ អត់ធន់នឹងរស ១ អត់ធន់នឹងការពាល់ត្រូវ ១ បរិបូណ៌ដោយសម្បុរ ១ ។

ឥមេហិ ខោ ភិក្ខវេ ឆហិ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ ឯវមេវ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។បេ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ ខមោ ហោតិ រូបានំ ខមោ សទ្ទានំ ខមោ គន្ធានំ ខមោ រសានំ ខមោ ផោដ្ឋព្វានំ ខមោ ធម្មានំ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។បេ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

[៥] ឆហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ រញ្ញោ ភទ្រោ អស្សាជានីយោ ខមោ ហោតិ រូបានំ ខមោ សទ្ទានំ ខមោ គន្ធានំ ខមោ រសានំ ខមោ ផោដ្ឋព្វានំ វណ្ណសម្បន្នោ ច ហោតិ ។



ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើរ របស់ស្តេចប្រកបដោយអង្គ ៦ យ៉ាងនេះឯង ជាសត្វគួរដល់ព្រះរាជា គួរជាគ្រឿងប្រើ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូច ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ទើបជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកអត់ធន់នឹងរូប ១ អត់ធន់នឹងសំឡេង ១ អត់ធន់នឹងក្លិន ១ អត់ធន់នឹងរស ១ អត់ធន់នឹងការពាល់ត្រូវ ១ អត់ធន់នឹងធម្មារម្មណ៍ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ទើបជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

(៥) ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើរ របស់ស្តេចប្រកបដោយអង្គ ៦ យ៉ាង ជាសត្វគួរដល់ព្រះរាជា គួរជាគ្រឿងប្រើ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។ ប្រកបដោយអង្គ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ស្តេចក្នុងលោកនេះជាសត្វអត់ធន់នឹងរូប ១ អត់ធន់នឹងសំឡេង ១ អត់ធន់នឹងក្លិន ១ អត់ធន់នឹងរស ១ អត់ធន់នឹងការពាល់ត្រូវ ១ បរិបូណ៌ដោយសម្បុរ ១ ។

ឥមេហិ ខោ ភិក្ខវេ ឆហិ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ ខមោ ហោតិ រូបានំ ។ បេ ។ ខមោ ធម្មានំ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

(៨) ឆយិមានិ ភិក្ខវេ អនុត្តរិយានិ ។ កតមានិ ឆ ។ ទស្សនានុត្តរិយំ សវនានុត្តរិយំ លាភានុត្តរិយំ សិក្ខានុត្តរិយំ បារិចរិយានុត្តរិយំ អនុស្សតានុត្តរិយំ ។ ឥមានិ ខោ ភិក្ខវេ ឆ អនុត្តរិយានីតិ ។



ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើរ របស់ស្តេច ប្រកបដោយអង្គ ៦ យ៉ាងនេះឯង ជាសត្វគួរដល់ព្រះរាជា គួរជាគ្រឿងប្រើ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចភិក្ខុ ប្រកបដោយធម៌ ៦ យ៉ាង ទើបជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វ-លោក ។ ប្រកបដោយធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកអត់ធន់នឹងរូប ១ ។បេ។ អត់ធន់នឹងធម្មារម្មណ៍ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

(៨) ម្នាលភិក្ខុទាំងឡាយ អនុត្តរិយៈ (ធម្មជាតដ៏ប្រសើរ) នេះមាន ៦ យ៉ាង ។ អនុត្តរិយៈ ៦ យ៉ាង តើដូចម្តេចខ្លះ ។ គឺទស្សនា-នុត្តរិយៈ ១ សវនានុត្តរិយៈ ១ លាភានុត្តរិយៈ ១ សិក្ខានុត្តរិយៈ ១ បារិ-ចរិយានុត្តរិយៈ ១ អនុស្សតានុត្តរិយៈ ១ ។ ម្នាលភិក្ខុទាំងឡាយ អនុត្តរិយៈ មាន ៦ យ៉ាងនេះឯង ។

(៩) ឆយិមានិ ភិក្ខវេ អនុស្សតិដ្ឋានានិ ។ កតមានិ ឆ ។ ពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ សីលានុស្សតិ ចាគានុស្សតិ ទេវតានុស្សតិ ។ ឥមានិ ខោ ភិក្ខវេ ឆ អនុស្សតិដ្ឋានានីតិ ។

(១០) ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថខោ មហានាមោ សក្កោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហានាមោ សក្កោ ភគវន្តំ ឯតទវោច យោ សោ ភន្តេ អរិយសាវកោ អាគតផលោ វិញ្ញាតសាសនោ សោ កតមេន វិហារេន ពហុលំ វិហរតីតិ ។ យោ សោ មហានាម អរិយសាវកោ អាគតផលោ វិញ្ញាតសាសនោ សោ ឥមិនា វិហារេន ពហុលំ វិហរតិ ។ ឥធ មហានាម អរិយសាវកោ តថាគតំ អនុស្សរតិ



(៩) ម្នាលភិក្ខុទាំងឡាយ អនុស្សតិដ្ឋាន (ហេតុជាទីតាំងនៃសេចក្ដីរលឹក) នេះមាន ៦ យ៉ាង ។ អនុស្សតិដ្ឋាន ៦ យ៉ាង តើដូចម្ដេចខ្លះ ។ គឺពុទ្ធានុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ សីលានុស្សតិ ១ ចាគានុស្សតិ ១ ទេវតានុស្សតិ ១ ។ ម្នាលភិក្ខុទាំងឡាយ អនុស្សតិដ្ឋាន មាន ៦ យ៉ាងនេះឯង ។

(១០) សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលវត្ថុ ក្នុងសក្កជនបទ ។ គ្រានោះ មហានាមសក្កៈ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយប្រថាប់ក្នុងទីដ៏សមគួរ ។ លុះមហានាមសក្កៈ ប្រថាប់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន អរិយសាវកណា បានសម្រេចអរិយផល ដឹងច្បាស់នូវសាសនានៃព្រះសាស្ដាហើយ អរិយសាវកនោះ ច្រើនតែនៅដោយវិហារធម៌ដូចម្ដេច ។ ម្នាលមហានាម អរិយសាវកណា បានសម្រេចអរិយផល ដឹងច្បាស់នូវសាសនាហើយ អរិយសាវកនោះ ច្រើនតែនៅដោយវិហារធម៌នេះ ។ បពិត្រមហានាម អរិយសាវកក្នុងសាសនានេះ រលឹករឿយៗ នូវព្រះតថាគត

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ យស្មឹ មហានាម សមយេ អរិយសាវកោ តថាគតំ អនុស្សរតិ នេវស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ តថាគតំ អារព្ភ ។ ឧជុគតចិត្តោ ខោ បន មហានាម អរិយសាវកោ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទយតិ សុខិនោ ចិត្តំ សមាធិយតិ ។ អយំ វុច្ចតិ មហានាម អរិយសាវកោ វិសមគតាយ បជាយ សមប្បត្តោ(១) វិហរតិ

១ ម. សម្បត្តោ ។



ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកកិលេស ត្រាស់ដឹងនូវញេយ្យធម៌ដោយប្រពៃចំពោះព្រះអង្គឯង ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ ព្រះអង្គមានដំណើរល្អ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គជាបុគ្គលប្រសើរដោយសីលាទិគុណ ព្រះអង្គជាអ្នកទូន្មាននូវបុរស ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ដោយហេតុនេះ ៗ ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវក រលឹករឿយៗ នូវគុណនៃព្រះតថាគត ក្នុងសម័យនោះ អរិយសាវកនោះ រមែងមិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ ក៏រមែងជាចិត្តត្រង់បាន ព្រោះប្រារព្ធនូវគុណនៃព្រះតថាគត ។ បពិត្រមហានាម លុះអរិយសាវក មានចិត្តត្រង់ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលនូវសេចក្តីសុខ លុះប្រកបដោយសេចក្តីសុខហើយ ចិត្តក៏រមែងដំកល់មាំ ។ បពិត្រមហានាម អរិយសាវកនេះ ហៅថាជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់

សព្យាបជ្ជាយ បជាយ អព្យាបជ្ជោ វិហរតិ ធម្មសោតំ
សមាបន្នោ ពុទ្ធានុស្សតឹ ភាវេតិ ។ បុន ចបរំ
មហានាម អរិយសាវកោ ធម្មំ អនុស្សរតិ ស្វាក្ខាតោ
ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ
ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ យស្មឹ
មហានាម សមយេ អរិយសាវកោ ធម្មំ អនុស្សរតិ
នេវស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ
ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ
ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ
ហោតិ ធម្មំ អារព្ភ ។ ឧជុគតចិត្តោ ខោ បន
មហានាម អរិយសាវកោ លភតិ អត្ថវេទំ លភតិ
ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ បមុទិតស្ស
បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ
បស្សទ្ធកាយោ សុខំ វេទយតិ សុខិនោ ចិត្តំ
សមាធិយតិ ។ អយំ វុច្ចតិ មហានាម អរិយសាវកោ



ជាអ្នកមិនចង្អៀតចង្អល់ ក្នុងពួកសត្វដែលប្រកបដោយសេចក្ដីចង្អៀត
ចង្អល់ ជាអ្នកសម្រេចនូវធម្មសោតៈហើយស្រួល ចំរើននូវពុទ្ធានុស្សតិកម្ម-
ដ្ឋាន ។ បពិត្រមហានាម មួយទៀត អរិយសាវករលឹករឿយៗ នូវគុណ
ព្រះធម៌ថា ព្រះធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយ
ដោយប្រពៃ ព្រះធម្មគុណគឺធម៌ដែលបុគ្គលគប្បីឃើញដោយខ្លួនឯង
ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សិកៈ ជាធម៌គួរបង្អោន
ចូលមកទុកក្នុងខ្លួន ជាធម៌ដែលអ្នកវិញ្ញូជន គប្បីដឹងច្បាស់ចំពោះខ្លួន ។
បពិត្រមហានាម ក្នុងសម័យណា អរិយសាវករលឹករឿយៗ នូវព្រះធម៌
ក្នុងសម័យនោះ អរិយសាវកនោះ រមែងមិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវ
ទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្ត
របស់អរិយសាវកនោះ រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវគុណព្រះធម៌ ។
បពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ហើយ រមែងបាននូវការ
ដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្ដីរីករាយប្រកបដោយធម៌
កាលបើមានសេចក្ដីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកប
ដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់
ហើយ រមែងទទួលនូវសេចក្ដីសុខ កាលបើមានសេចក្ដីសុខ ចិត្ត
ក៏រមែងដំកល់មាំ ។ បពិត្រមហានាម អរិយសាវកនេះ លោកថា

វិសមគតាយ បជាយ សមប្បត្តោ វិហរតិ សព្យាបជ្ជាយ បជាយ អព្យាបជ្ជោ វិហរតិ ធម្មសោតំ សមាបន្នោ ធម្មានុស្សតិំ ភាវេតិ ។ បុន ចបរំ មហានាម អរិយសាវកោ សង្ឃំ អនុស្សរតិ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ យស្មិំ មហានាម សមយេ អរិយសាវកោ សង្ឃំ អនុស្សរតិ នេវស្ស តស្មិំ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មិំ សមយេ ចិត្តំ ហោតិ សង្ឃំ អារព្ភ ។



ជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នកមិនបៀតបៀនគេ ក្នុងពួកសត្វដែលមានសេចក្តីបៀតបៀនគេ ជាអ្នកសម្រេចនូវធម្មសោតៈ គឺវិបស្សនា ចំរើននូវធម្មានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយទៀត អរិយសាវករលឹករឿយ ៗ នូវគុណនៃព្រះសង្ឃថា ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិល្អហើយ ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិត្រង់ហើយ ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិដើម្បីត្រាស់ដឹងព្រះនិព្វាន ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិគួរដល់សាមីចិកម្ម បើរាប់ជាគូនៃបុរសបាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលបាន ៨ ព្រះសង្ឃទាំងនុ៎ះជាសង្ឃសាវកនៃព្រះដ៏មានព្រះភាគ គួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលនូវវត្ថុដែលគេរៀបចំដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលីកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវករលឹករឿយ ៗ នូវគុណព្រះសង្ឃ ក្នុងសម័យនោះ អរិយសាវកនោះ ក៏មិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវគុណព្រះសង្ឃ ។

ឧជុគតចិត្តោ ខោ បន មហានាម អរិយសាវកោ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទយតិ សុខិនោ ចិត្តំ សមាធិយតិ ។ អយំ វុច្ចតិ មហានាម អរិយសាវកោ វិសមគតាយ បជាយ សមប្បត្តោ វិហរតិ សព្យាបជ្ជាយ បជាយ អព្យាបជ្ជោ វិហរតិ ធម្មសោតំ សមាបន្នោ សង្ឃានុស្សតឹ ភាវេតិ ។ បុន ចបរំ មហានាម អរិយសាវកោ អត្តនោ សីលានិ អនុស្សរតិ អខណ្ឌានិ អច្ឆិទ្ទានិ អសពលានិ អកម្មាសានិ ភុជិស្សានិ វិញ្ញុប្បសត្ថានិ អបរាមដ្ឋានិ សមាធិសំវត្តនិកានិ ។ យស្មិំ មហា-នាម សមយេ អរិយសាវកោ អត្តនោ សីលានិ អនុស្សរតិ នេវស្ស តស្មិំ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មិំ សមយេ ចិត្តំ ហោតិ សីលំ អារព្ភ ។



បពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ហើយ រមែងទទួលនូវសេចក្តីសុខ កាលបើមានសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវកនេះ ហៅថាជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នកមិនបៀតបៀន ក្នុងពួកសត្វដែលមានសេចក្តីបៀតបៀន ជាអ្នកសម្រេចនូវធម្មសោតៈនិងសង្ឃ ចំរើនសង្ឃានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយទៀត អរិយសាវក រលឹករឿយៗ នូវសីលរបស់ខ្លួន ដែលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលរួចខ្លួន គឺមិនជាខ្ញុំតណ្ហា ដែលវិញ្ញូជនសរសើរហើយ មិនមានតណ្ហានិងទិដ្ឋិ ប៉ះពាល់បាន ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវករលឹករឿយៗ នូវសីលរបស់ខ្លួន ក្នុងសម័យនោះ អរិយសាវកនោះ រមែងមិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវសីល ។

ឧជុគតចិត្តោ ខោ បន មហានាម អរិយសាវកោ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទយតិ សុខិនោ ចិត្តំ សមាធិយតិ ។ អយំ វុច្ចតិ មហានាម អរិយសាវកោ វិសមគតាយ បជាយ សមប្បត្តោ វិហរតិ សព្យាបជ្ឈាយ បជាយ អព្យាបជ្ឈោ វិហរតិ ធម្មសោតំ សមាបន្នោ សីលានុស្សតឹ ភាវេតិ ។ បុន ចបរំ មហានាម អរិយសាវកោ អត្តនោ ចាគំ អនុស្សរតិ លាភា វត មេ សុលទ្ធំ វត មេ យោហំ មច្ឆេរមលបរិយុដ្ឋិតាយ បជាយ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសាមិ មុត្តចាគោ បយតបាណិ វោស្សគ្គរតោ យាចយោគោ ទានសំវិភាគរតោ ។ យស្មឹ មហានាម សមយេ អរិយសាវកោ ចាគំ អនុស្សរតិ នេវស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ



បពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលនូវសេចក្តីសុខ កាលបើមានសេចក្តីសុខហើយ ចិត្តក៏រមែងដំកល់មាំ ។ បពិត្រមហានាម អរិយសាវកនេះ ហៅថាជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នកមិនបៀតបៀនបន្ទល់ ក្នុងពួកសត្វដែលមានសេចក្តីបៀតបៀនបន្ទល់ ជាអ្នកសម្រេចនូវធម្មសោតៈ រមែងចំរើននូវសីលានុស្សតិកម្មដ្ឋាន បពិត្រមហានាម មួយទៀត អរិយសាវករលឹករឿយ ៗ នូវចាគៈរបស់ខ្លួនថា ឱហ្ន៎ អាត្មាអញបានលាភហើយ ឱហ្ន៎ អត្តភាពជាមនុស្សអាត្មាអញបានបានល្អហើយ ព្រោះកាលពួកសត្វមានសេចក្តីកំណាញ់ជាមន្ទិលកំពុងរួបរឹត អាត្មាអញមានចិត្តប្រាសចាកសេចក្តីកំណាញ់ជាមន្ទិល ជាអ្នកមានការលះបង់ហើយ មានដៃលាងស្អាតហើយ ត្រេកអរក្នុងការលះបង់ ជាបុគ្គលគួរគេសូម ត្រេកអរក្នុងការចែកដាយទាន នៅគ្រប់គ្រងផ្ទះ ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវករលឹករឿយ ៗ នូវចាគៈ ក្នុងសម័យនោះ អរិយសាវកនោះ រមែងមិនត្រូវរាគៈរួបរឹតចិត្ត

ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ ចាគំ អារព្ភ ។ ឧជុគតចិត្តោ ខោ បន មហានាម អរិយសាវកោ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទយតិ សុខិនោ ចិត្តំ សមាធិយតិ ។ អយំ វុច្ចតិ មហានាម អរិយសាវកោ វិសមគតាយ បជាយ សមប្បត្តោ វិហរតិ សព្យាបជ្ឈាយ បជាយ អព្យាបជ្ជោ វិហរតិ ធម្មសោតំ សមាបន្នោ ចាគានុស្សតឹ ភាវេតិ ។ បុន ចបរំ មហានាម អរិយសាវកោ ទេវតានុស្សតឹ ភាវេតិ សន្តិ ទេវា ចាតុម្មហារាជិកា សន្តិ ទេវា តាវតឹសា សន្តិ ទេវា យាមា សន្តិ ទេវា តុសិតា សន្តិ ទេវា និម្មានរតិនោ សន្តិ ទេវា បរនិម្មិតវសវត្តិនោ សន្តិ ទេវា ព្រហ្មកាយិកា សន្តិ ទេវា តតុត្តរិ



មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ ក៏រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវចាគៈ ។ បពិត្រមហានាម លុះអរិយសាវក មានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលនូវសេចក្តីសុខ កាលបើមានសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវកនេះ លោកហៅថាជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នកមិនបៀតបៀន ក្នុងពួកសត្វដែលមានសេចក្តីបៀតបៀន ជាអ្នកសម្រេចនូវធម្មសោតៈហើយសាង ចំរើននូវចាគានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយវិញទៀត អរិយសាវក ចំរើននូវទេវតានុស្សតិថា ទេវតាទាំងឡាយជាន់ចាតុម្មហារាជិកៈក៏មាន ទេវតាទាំងឡាយជាន់តាវត្តិង្សក៏មាន ទេវតាទាំងឡាយជាន់យាមៈក៏មាន ទេវតាទាំងឡាយជាន់តុសិតក៏មាន ទេវតាទាំងឡាយជាន់និម្មានរតីក៏មាន ទេវតាទាំងឡាយជាន់បរនិម្មិតវសវត្តីក៏មាន ទេវតាទាំងឡាយជាន់ព្រហ្មកាយិកៈក៏មាន ទេវតាទាំងឡាយខ្ពស់លើសជាងនោះក៏មាន

យថារូបាយ សទ្ធាយ សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថូបបន្នា មយ្ហំបិ តថារូបា សទ្ធា សំវិជ្ជតិ យថារូបេន សីលេន សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថូបបន្នា មយ្ហំបិ តថារូបំ សីលំ សំវិជ្ជតិ យថារូបេន សុតេន សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថូបបន្នា មយ្ហំបិ តថារូបំ សុតំ សំវិជ្ជតិ យថារូបេន ចាគេន សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថូបបន្នា មយ្ហំបិ តថារូបោ ចាគោ សំវិជ្ជតិ យថារូបាយ បញ្ញាយ សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថូបបន្នា មយ្ហំបិ តថារូបា បញ្ញា សំវិជ្ជតីតិ ។ យស្មឹ មហានាម សមយេ អរិយសាវកោ អត្តនោ ច តាសញ្ច ទេវតានំ សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរតិ នេវស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ ទេវតា អារព្ភ ។



ទេវតាពួកនោះ ប្រកបដោយសទ្ធា មានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ សទ្ធារបស់អញដែលមានសភាពយ៉ាងនោះក៏មាន ទេវតាពួកនោះ ប្រកបដោយសីល មានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ សីលរបស់អញដែលមានសភាពយ៉ាងនោះក៏មាន ពួកទេវតាពួកនោះ ប្រកបដោយសុតៈមានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ សុតៈរបស់អញដែលមានសភាពយ៉ាងនោះ មានទេវតាពួកនោះ ប្រកបដោយចាគៈមានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ ចាគៈរបស់អញដែលមានសភាពដូច្នោះក៏មាន ទេវតាពួកនោះ ប្រកបដោយបញ្ញាមានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ បញ្ញារបស់អញដែលមានសភាពដូច្នោះក៏មាន ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវក រលឹករឿយៗ នូវសទ្ធា សីល សុតៈ ចាគៈ និងបញ្ញា របស់ខ្លួនផង របស់ទេវតាពួកនោះផង ក្នុងសម័យនោះ អរិយសាវកនោះ រមែងមិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវពួកទេវតា ។

ឧជុគតចិត្តោ ហោតិ មហានាម អរិយសាវកោ លភតិ អត្ថវេទំ លភតិ ធម្មវេទំ លភតិ ធម្មូបសញ្ហិតំ បាមុជ្ជំ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទយតិ សុខិនោ ចិត្តំ សមាធិយតិ ។ អយំ វុច្ចតិ មហានាម អរិយសាវកោ វិសមគតាយ បជាយ សមប្បត្តោ វិហរតិ សព្យាបជ្ឈាយ បជាយ អព្យាបជ្ឈោ វិហរតិ ធម្មសោតំ សមាបន្នោ ទេវតានុស្សតឹ ភាវេតិ ។ យោ សោ មហានាម អរិយសាវកោ អាគតផលោ វិញ្ញាតសាសនោ សោ ឥមិនា វិហារេន ពហុលំ វិហរតីតិ ។

អាហុនេយ្យវគ្គោ បឋមោ ។

### តស្សុទ្ទានំ

ទ្វេ អាហុនេយ្យា ឥន្ទ្រិយ-
ពលានិ តយោ អាជានិយា
អនុត្តរិយអនុស្សតា
មហានាមេន តេ ទសាតិ ។



បពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយ ដែលប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ ក៏រមែងទទួលនូវសេចក្តីសុខ កាលបើមានសេចក្តីសុខហើយ ចិត្តក៏រមែងដម្កល់មាំ ។ បពិត្រមហានាម អរិយសាវកនេះ ហៅថាជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នកមិនបៀតបៀន ក្នុងពួកសត្វដែលមានសេចក្តីបៀតបៀន ជាអ្នកសម្រេចនូវធម្មសោតៈគឺ [illegible] ចំរើននូវទេវតានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម អរិយសាវកណា បានសម្រេចអរិយផល ដឹងច្បាស់នូវសាសនាហើយ អរិយសាវកនោះ ច្រើនតែនៅដោយវិហារធម៌នេះ ។

ចប់ អាហុនេយ្យវគ្គ ទី ១ ។

### ឧទ្ទាននៃអាហុនេយ្យវគ្គនោះគឺ

និយាយអំពីអាហុនេយ្យបុគ្គល ២ លើក គឺពី
ឥន្ទ្រិយ ១ ពលៈ ១ សេះអាជានេយ្យ ៣ លើក អនុត្តរិយៈ ១
អនុស្សតិ ១ មហានាមសក្កៈ ១ រួមជា ១០ ។

## សារាណីយាទិវគ្គោ

(១១) ឆយិមេ ភិក្ខវេ ធម្មា សារាណីយា ។ កតមេ ឆ ។ ឥធ ភិក្ខវេ ភិក្ខុនោ មេត្តំ កាយកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវិ ចេវ រហោ ច អយម្បិ ធម្មោ សារាណីយោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ មេត្តំ វចីកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវិ ចេវ រហោ ច អយម្បិ ធម្មោ សារាណីយោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុនោ មេត្តំ មនោកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវិ ចេវ រហោ ច អយម្បិ ធម្មោ សារាណីយោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ យេ តេ លាភា ធម្មិកា ធម្មលទ្ធា អន្តមសោ បត្តបរិយាបន្នមត្តម្បិ តថារូបេហិ លាភេហិ អប្បដិវិភត្តភោគី ហោតិ សីលវន្តេហិ សព្រហ្មចារីហិ សាធារណភោគី អយម្បិ ធម្មោ សារាណីយោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ យានិ តានិ សីលានិ អខណ្ឌានិ អច្ឆិទ្ទានិ អសពលានិ អកម្មាសានិ ភុជិស្សានិ

## សារាណីយាទិវគ្គ

(១១) ម្នាលភិក្ខុទាំងឡាយ សារាណីយធម៌ (ធម៌គួររលឹក) នេះ មាន ៦ យ៉ាង ។ សារាណីយធម៌ ៦ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដំកល់នូវកាយកម្មប្រកបដោយមេត្តា ចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាសារាណីយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុដំកល់នូវវចីកម្មប្រកបដោយមេត្តាចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាសារាណីយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុដំកល់នូវមនោកម្មប្រកបដោយមេត្តាចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាសារាណីយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកបរិភោគ មិនញែកចេញដោយលាភទាំងឡាយ ដែលប្រកបដោយធម៌ បានមកដោយធម៌ ដោយហោចទៅ សូម្បីលាភត្រឹមតែរបស់ដែលមានក្នុងបាត្រ ជាអ្នកបរិភោគជាសាធារណៈ ដោយសព្រហ្មចារីទាំងឡាយដែលមានសីល នេះជាសារាណីយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានសីលស្មើគ្នានឹងសព្រហ្មចារីទាំងឡាយ ក្នុងសីលទាំងឡាយ ដែលជាសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលរួចខ្លួន គឺមិនជាខ្ញុំតណ្ហា

វិញ្ញុប្បសត្ថានិ អបរាមដ្ឋានិ សមាធិសំវត្តនិកានិ តថារូបេសុ សីលេសុ សីលសាមញ្ញគតោ វិហរតិ សព្រហ្មចារីហិ អាវិ ចេវ រហោ ច អយម្បិ ធម្មោ សារាណីយោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ យាយំ ទិដ្ឋិ អរិយា និយ្យានិកា និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយ តថារូបាយ ទិដ្ឋិយា ទិដ្ឋិសាមញ្ញគតោ វិហរតិ សព្រហ្មចារីហិ អាវិ ចេវ រហោ ច អយម្បិ ធម្មោ សារាណីយោ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មា សារាណីយាតិ ។

(១៦) ឆយិមេ ភិក្ខវេ ធម្មា សារាណីយា បិយករណា គរុករណា សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តន្តិ ។ កតមេ ឆ ។ ឥធ ភិក្ខវេ ភិក្ខុនោ មេត្តំ កាយកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវិ ចេវ រហោ ច អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។



ដែលវិញ្ញូជនសរសើរហើយ មិនមានតណ្ហានិងទិដ្ឋិប៉ះពាល់បាន ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ទាំងចំពោះមុខ ទាំងកំបាំងមុខ នេះជាសារាណីយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុមានសេចក្ដីយល់ឃើញស្មើគ្នា នឹងសព្រហ្មចារីទាំងឡាយ ក្នុងទិដ្ឋិដ៏ប្រសើរ ជាទីស្រោចស្រង់សត្វ ប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃកងទុក្ខដោយប្រពៃ ដល់អ្នកធ្វើតាមទិដ្ឋិនោះ ទាំងចំពោះមុខ ទាំងកំបាំងមុខ នេះជាសារាណីយធម៌ ។ ម្នាលភិក្ខុទាំងឡាយ សារាណីយធម៌ ៦ យ៉ាងនេះឯង ។

(១៦) ម្នាលភិក្ខុទាំងឡាយ សារាណីយធម៌ ៦ យ៉ាងនេះ ជាធម៌ធ្វើសេចក្ដីស្រឡាញ់ ធ្វើសេចក្ដីគោរព ប្រព្រឹត្តទៅ ដើម្បីសេចក្ដីសង្គ្រោះ ដើម្បីមិនទាស់គ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីរួបរួមគ្នា ។ សារាណីយធម៌ ៦ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដំកល់កាយកម្មប្រកបដោយមេត្តា ចំពោះសព្រហ្មចារីទាំងឡាយ ទាំងចំពោះមុខ ទាំងកំបាំងមុខ នេះជាសារាណីយធម៌ ជាធម៌ធ្វើសេចក្ដីស្រឡាញ់ ធ្វើសេចក្ដីគោរព ប្រព្រឹត្តទៅ ដើម្បីសេចក្ដីសង្គ្រោះ ដើម្បីមិនទាស់គ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីរួបរួមគ្នា ។

បុន ចបរំ ភិក្ខវេ ភិក្ខុនោ មេត្តំ វចីកម្មំ បច្ចុបដ្ឋិតំ ហោតិ ។បេ។ មេត្តំ មនោកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវិ ចេវ រហោ ច អយម្បិ ធម្មោ សារណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ យេ តេ លាភា ធម្មិកា ធម្មលទ្ធា អន្តមសោ បត្តបរិយាបន្នមត្តម្បិ តថារូបេហិ លាភេហិ អប្បដិវិភត្តភោគី ហោតិ សីលវន្តេហិ សព្រហ្មចារីហិ សាធារណភោគី អយម្បិ ធម្មោ សារណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ យានិ តានិ សីលានិ អខណ្ឌានិ អច្ឆិទ្ទានិ អសពលានិ អកម្មាសានិ ភុជិស្សានិ វិញ្ញុប្បសត្ថានិ អបរាមដ្ឋានិ សមាធិសំវត្តនិកានិ តថារូបេសុ សីលេសុ សីលសាមញ្ញគតោ វិហរតិ សព្រហ្មចារីហិ អាវិ ចេវ រហោ ច



ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុតំកល់វចីកម្មប្រកបដោយមេត្តា ។បេ។ តំកល់មនោកម្មប្រកបដោយមេត្តា ចំពោះសព្រហ្មចារីទាំងឡាយ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាសារណីយធម៌ ជាធម៌ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅ ដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់គ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីមូលមិត្រគ្នា ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកបរិភោគ មិនញែកមុខ ដោយលាភទាំងឡាយដែលប្រកបដោយធម៌ បានមកដោយធម៌ ដោយហោចទៅ សូម្បីលាភត្រឹមតែរបស់ដែលមានក្នុងបាត្រ ជាអ្នកបរិភោគជាសាធារណៈ ដោយសព្រហ្មចារីទាំង-ឡាយ ដែលមានសីលនោះ ជាសារណីយធម៌ ជាធម៌ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរពប្រព្រឹត្តទៅ ដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់គ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីមូលមិត្រគ្នា ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានសីលស្មើគ្នា នឹងសព្រហ្មចារីទាំងឡាយ ក្នុងសីលទាំងឡាយ ដែលជាសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលរួចខ្លួន គឺមិនជាទុំតណ្ហា ដែលវិញ្ញូជនសរសើរហើយ មិនមានតណ្ហានិងទិដ្ឋិប៉ះពាល់បាន ជាសីលប្រព្រឹត្តទៅ ដើម្បីសមាធិ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ

អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ យាយំ ទិដ្ឋិ អរិយា និយ្យានិកា និយ្យាតិ តក្ករស្ស សម្មា-ទុក្ខក្ខយាយ តថារូបាយ ទិដ្ឋិយា ទិដ្ឋិសាមញ្ញគតោ វិហរតិ សព្រហ្មចារីហិ អាវិ ចេវ រហោ ច អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មា សារាណីយា បិយករណា គរុករណា សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តន្តីតិ ។

(១៣) ឆយិមេ ភិក្ខវេ និស្សារណីយា ធាតុយោ ។ កតមា ឆ ។ ឥធ ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ មេត្តា ហិ ខោ មេ ចេតោវិមុត្តិ ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា



នេះជាសារាណីយធម៌ ជាធម៌ធ្វើសេចក្ដីស្រឡាញ់ ធ្វើសេចក្ដីគោរព ប្រព្រឹត្តទៅ ដើម្បីសេចក្ដីសង្គ្រោះ ដើម្បីមិនទាស់គ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីរួបរួមគ្នា ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុមានសេចក្ដីយល់ឃើញស្មើគ្នា នឹងសព្រហ្មចារីទាំងឡាយ ក្នុងទិដ្ឋិដ៏ប្រសើរជាគ្រឿងស្រោចស្រង់សត្វ ប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃកងទុក្ខដោយប្រពៃ ដល់អ្នកធ្វើតាមទិដ្ឋិនោះ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាសារាណីយធម៌ ជាធម៌ដែលធ្វើសេចក្ដីស្រឡាញ់ ធ្វើសេចក្ដីគោរព ប្រព្រឹត្តទៅ ដើម្បីសេចក្ដីសង្គ្រោះ ដើម្បីមិនទាស់គ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីរួបរួមគ្នា ។ ម្នាលភិក្ខុទាំងឡាយ សារាណីយធម៌ ៦ យ៉ាងនេះឯង ជាធម៌ធ្វើសេចក្ដីស្រឡាញ់ ធ្វើសេចក្ដីគោរព ប្រព្រឹត្តទៅ ដើម្បីសេចក្ដីសង្គ្រោះ ដើម្បីមិនទាស់គ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីរួបរួមគ្នា ។

(១៣) ម្នាលភិក្ខុទាំងឡាយ និស្សារណីយធាតុនេះ មាន ៦ យ៉ាង ។ និស្សារណីយធាតុ ៦ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ និយាយយ៉ាងនេះថា ចេតោវិមុត្តិប្រកបដោយមេត្តា ខ្ញុំបានចម្រើនច្រើនហើយ បានធ្វើឲ្យដូចជាយាន បានដំកល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំ បានប្រារព្ធល្អហើយ

អថ ច បន មេ ព្យាបាទោ ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។ សោ មា ហេវន្តិស្ស វចនីយោ មា អាយស្មា ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អដ្ឋានមេតំ អាវុសោ អនវកាសោ យំ មេត្តាយ ចេតោវិមុត្តិយា ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ អថ ច បនស្ស ព្យាបាទោ ចិត្តំ បរិយាទាយ ឋស្សតីតិ នេតំ ឋានំ វិជ្ជតិ និស្សរណាហេតំ អាវុសោ ព្យាបាទស្ស យទិទំ មេត្តា ចេតោវិមុត្តិ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ ករុណា ហិ ខោ មេ ចេតោវិមុត្តិ ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អថ ច បន មេ វិហេសា ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។



តែបើទុកជាដូច្នោះក៏ដោយ ព្យាបាទក៏គង់តែគ្របសង្កត់ចិត្តរបស់ខ្ញុំបាន ។ ភិក្ខុនោះ គប្បីនិយាយឃាត់ថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះដ៏មានព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ តាមដែលពិតនោះ ព្រះដ៏មានព្រះភាគ មិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា ចេតោវិមុត្តិប្រកបដោយមេត្តា ដែលគេបានអប់រំធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានដំកល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ ព្យាបាទក៏គង់នៅគ្របសង្កត់ចិត្តរបស់គេបាន ដូច្នេះ ហេតុនុ៎ះ មិនដែលមានឡើយ ម្នាលអាវុសោ តាមដែលគំនុំ គឺចេតោវិមុត្តិដែលប្រកបដោយមេត្តាហ្នឹងឯង ជាធម៌សម្រាប់រលាស់ចោលនូវព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ពោលយ៉ាងនេះថា ចេតោវិមុត្តិប្រកបដោយករុណា ខ្ញុំបានអប់រំធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានដំកល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាដូច្នោះក៏ដោយ វិហេសា (សេចក្ដីបៀតបៀន) ក៏គង់តែគ្របសង្កត់ចិត្តរបស់ខ្ញុំបាន ។

សោ ឯវមស្ស វចនីយោ មា អាយស្មា ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អដ្ឋានមេតំ អាវុសោ អនវកាសោ យំ ករុណាយ ចេតោវិមុត្តិយា ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ អថ ច បនស្ស វិហេសា ចិត្តំ បរិយាទាយ ឋស្សតីតិ នេតំ ឋានំ វិជ្ជតិ និស្សរណំ ហេតំ អាវុសោ វិហេសាយ យទិទំ ករុណា ចេតោវិមុត្តិ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ មុទិតា ហិ ខោ មេ ចេតោវិមុត្តិ ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អថ ច បន មេ អរតិ ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។ សោ ឯវមស្ស វចនីយោ



អ្នកនោះ គប្បីនិយាយហាមភិក្ខុនោះថា លោក កុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះដ៏មានព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ តាមដែលពិតនោះ ព្រះដ៏មានព្រះភាគ មិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ហេតុនេះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា ចេតោវិមុត្តិប្រកបដោយករុណា ដែលគេបានអប់រំបង្កើនច្រើនហើយ បានធ្វើឲ្យដូចជាយាន បានដំកល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ វិហេសា គឺគង់នៅតែគ្របសង្កត់ចិត្តរបស់គេបាន ដូច្នេះ ហេតុនុ៎ះ មិនដែលមានឡើយ ម្នាលអាវុសោ តាមដែលពិតនុ៎ះ គឺចេតោវិមុត្តិ ដែលប្រកបដោយករុណា នេះឯង ជាធម៌សម្រាប់លាស់ចេញនូវវិហេសា ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ពោលយ៉ាងនេះថា ចេតោវិមុត្តិ ប្រកបដោយមុទិតា ខ្ញុំបានអប់រំបង្កើនច្រើនហើយ បានធ្វើឲ្យដូចជាយាន បានដំកល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ អរតិ (សេចក្តីមិនត្រេកអរ) គឺគង់នៅតែគ្របសង្កត់ចិត្តរបស់ខ្ញុំបាន ។ អ្នកនោះ គប្បីនិយាយហាមភិក្ខុនោះថា លោក កុំនិយាយយ៉ាងនេះឡើយ

មា អាយស្មា ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អដ្ឋានមេតំ អាវុសោ អនវកាសោ យំ មុទិតាយ ចេតោវិមុត្តិយា ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ អថ ច បនស្ស អរតិ ចិត្តំ បរិយាទាយ ឋស្សតីតិ នេតំ ឋានំ វិជ្ជតិ និស្សរណញ្ហេតំ អាវុសោ អរតិយា យទិទំ មុទិតា ចេតោវិមុត្តិ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ ឧបេក្ខា ហិ ខោ មេ ចេតោវិមុត្តិ ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អថ ច បន មេ រាគោ ចិត្តំ បរិយា-ទាយ តិដ្ឋតីតិ ។ សោ មា ហេវន្តិស្ស វចនីយោ មា អាយស្មា ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ



លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះដ៏មានព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះដ៏មានព្រះភាគ មិនល្អទេ តាមដែលពិតនោះ ព្រះដ៏មានព្រះភាគ មិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះ មិនមែនជាហេតុ មិនមែនជាបច្ច័យ គឺពាក្យដែលថា ចេតោវិមុត្តិ ប្រកបដោយមុទិតា ដែលគេបានអប់រំបំប៉នឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានដំកល់ស៊ប់ បានប្រព្រឹត្តរឿយ ៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះហើយ អរតិគឺនឹងគ្របសង្កត់ចិត្តរបស់គេបាន ដូច្នេះ ហេតុនុ៎ះ មិនដែលមានឡើយ ម្នាលអាវុសោ តាមដែលពិតនោះ ចេតោវិមុត្តិ ដែលប្រកបដោយមុទិតានុ៎ះឯង ជាគ្រឿងរលាស់ចោលនូវអរតិ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ពោលយ៉ាងនេះថា ចេតោវិមុត្តិប្រកបដោយឧបេក្ខា ខ្ញុំបានអប់រំបំប៉នឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានដំកល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះហើយ រាគៈគឺនឹងគ្របសង្កត់ចិត្តរបស់ខ្ញុំបាន ។ អ្នកដទៃ ត្រូវនិយាយហាមភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះដ៏មានព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះដ៏មានព្រះភាគ មិនល្អទេ តាមដែលពិតនោះ ព្រះដ៏មានព្រះភាគ មិនបានត្រាស់យ៉ាងនេះទេ

អដ្ឋានមេតំ អាវុសោ អនវកាសោ យំ ឧបេក្ខាយ ចេតោវិមុត្តិយា ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ អថ ច បនស្ស រាគោ ចិត្តំ បរិយាទាយ ឋស្សតីតិ នេតំ ឋានំ វិជ្ជតិ និស្សរណញ្ហេតំ អាវុសោ រាគស្ស យទិទំ ឧបេក្ខា ចេតោវិមុត្តិ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ អនិមិត្តា ហិ ខោ មេ ចេតោវិមុត្តិ ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អថ ច បន មេ និមិត្តានុសារី វិញ្ញាណំ ហោតីតិ ។ សោ មា ហេវន្តិស្ស វចនីយោ មា អាយស្មា ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អដ្ឋានមេតំ អាវុសោ អនវកាសោ



ម្នាលអាវុសោ ដំណើរនេះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា ចេតោវិមុត្តិប្រកបដោយឧបេក្ខា ដែលគេបានចំរើនធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានដំកល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ បើទុកជាធ្វើដូច្នោះក៏ដោយ រាគៈក៏គង់នៅតែគ្របសង្កត់ចិត្តរបស់គេបាន ដូច្នោះ ហេតុនុ៎ះ មិនដែលមានឡើយ ម្នាលអាវុសោ តាមដែលពិតនោះ គឺចេតោវិមុត្តិដែលប្រកបដោយឧបេក្ខានុ៎ះឯង ជាធម៌សម្រាប់រលាស់ចោលនូវរាគៈ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ពោលយ៉ាងនេះថា ចេតោវិមុត្តិ ប្រកបដោយអនិមិត្ត ខ្ញុំបានចំរើនធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានដំកល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ និមិត្តានុសារីវិញ្ញាណ គឺវិញ្ញាណដែលរលឹកឃើញនូវនិមិត្តរបស់ខ្ញុំនៅតែមាន ។ ភិក្ខុដទៃ គប្បីនិយាយហាមភិក្ខុនោះថា លោក កុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះដ៏មានព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះដ៏មានព្រះភាគ មិនល្អទេ តាមដែលពិតនោះ ព្រះដ៏មានព្រះភាគ មិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះមិនមែនជាហេតុ មិនមែនជាបច្ច័យ

យំ អនិមិត្តាយ ចេតោវិមុត្តិយា ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ អថ ច បនស្ស និមិត្តានុសារិ វិញ្ញាណំ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ និស្សរណញ្ហេតំ អាវុសោ សព្វនិមិត្តានំ យទិទំ អនិមិត្តា ចេតោវិមុត្តិ ។ ឥធ បន ភិក្ខវេ ភិក្ខុ ឯវំ វទេយ្យ អស្មីតិ ខោ មេ វិគតេ(១) អយមហមស្មីតិ ច ន សមនុបស្សាមិ អថ ច បន មេ វិចិកិច្ឆាកថំកថាសល្លំ ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។ សោ មា ហេវន្តិស្ស វចនីយោ មា អាយស្មា ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អដ្ឋានមេតំ អាវុសោ អនវកាសោ យំ អស្មីតិ វិគតេ អយមហមស្មីតិ ច អសមនុបស្សតោ

១ ម. ឆ. វិគតំ ។



គ្រង់ពាក្យដែលថា ចេតោវិមុត្តិប្រកបដោយអនិមិត្ត ដែលភិក្ខុបានអប់រំ ធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានដំកល់ស៊ប់ បានប្រព្រឹត្ត រឿយៗ បានសន្សំ បានប្រារព្ធល្អហើយ បើទុកជាដូច្នោះគង់ដោយ និមិត្តានុសារីវិញ្ញាណ របស់ភិក្ខុនោះនៅតែនៅមាន ដូច្នេះ ហេតុនុ៎ះ មិនដែល មានឡើយ ម្នាលអាវុសោ តាមដែលពិតនោះ ចេតោវិមុត្តិ ដែលប្រកប ដោយអនិមិត្តហ្នឹងឯង ជាគ្រឿងសម្រាប់លាស់ចាកនូវនិមិត្តទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ ពោលយ៉ាង នេះថា អស្មិមានះរបស់ខ្ញុំនេះទៅប្រាសអស់ហើយ ខ្ញុំពិចារណាមិនឃើញ ថា អាត្មាអញមានអស្មិមានះដូច្នេះឡើយ តែបើទុកជាដូច្នោះគង់ដោយ សរគឺសេចក្តីសង្ស័យនឹងសេចក្តីងឿងឆ្ងល់ ក៏នៅតែគ្របសង្កត់ចិត្តរបស់ ខ្ញុំបាន ។ ភិក្ខុដទៃ គប្បីនិយាយហាមភិក្ខុនោះយ៉ាងនេះថា លោកកុំ និយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ លោក កុំនិយាយបង្កាច់ព្រះដ៏មានព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះដ៏មាន ព្រះភាគ មិនល្អទេ តាមដែលពិតនោះ ព្រះដ៏មានព្រះភាគ មិនបានត្រាស់ យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជា បច្ច័យ គ្រង់ពាក្យដែលថា អស្មិមានះ របស់គេនោះទៅប្រាសអស់ ហើយ គេពិចារណាមិនឃើញថា អាត្មាអញមានអស្មិមានះដូច្នេះឡើយ

អថ ច បនស្ស វិចិកិច្ឆាកថំកថាសល្លំ ចិត្តំ បរិយាទាយ ឋស្សតីតិ នេតំ ឋានំ វិជ្ជតិ និស្សរណញ្ហេតំ អាវុសោ វិចិកិច្ឆាកថំកថាសល្លស្ស យទិទំ អស្មីតិ មានសមុគ្ឃាតោ ។ ឥមា ខោ ភិក្ខវេ ឆ និស្សារណីយា ធាតុយោតិ ។

(១៤) តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវេតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច តថា តថា អាវុសោ ភិក្ខុ វិហារំ កប្បេតិ យថា យថាស្ស វិហារំ កប្បយតោ ន ភទ្ទកំ មរណំ ហោតិ ន ភទ្ទិកា កាលកិរិយា ។ កថញ្ចាវុសោ ភិក្ខុ តថា តថា វិហារំ កប្បេតិ យថា យថាស្ស វិហារំ កប្បយតោ ន ភទ្ទកំ មរណំ ហោតិ ន ភទ្ទិកា កាលកិរិយា ។ ឥធាវុសោ ភិក្ខុ កម្មារាមោ ហោតិ



តែបើទុកជាដូច្នោះ សរគឺសេចក្តីសង្ស័យ នឹងសេចក្តីងឿងឆ្ងល់ ក៏គង់តែគ្របសង្កត់ចិត្តរបស់គេបាន ដូច្នេះ ហេតុនុ៎ះ មិនមែនមានឡើយ ម្នាលអាវុសោ តាមដែលពិតនោះ ការដកឡើងនូវអស្មិមានះបានហើយឯង ជាធម៌សម្រាប់រលាស់ចេញនូវសរគឺសេចក្តីសង្ស័យ នឹងសេចក្តីងឿងឆ្ងល់ ។ ម្នាលភិក្ខុទាំងឡាយ និស្សារណីយធាតុមាន ៦ យ៉ាងនេះឯង ។

(១៤) ព្រះសារីបុត្តដ៏មានអាយុ ហៅពួកភិក្ខុក្នុងទីនោះថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលស្តាប់ថេរវាចា ព្រះសារីបុត្តដ៏មានអាយុថា ករុណាអាវុសោ ។ ព្រះសារីបុត្តដ៏មានអាយុបានពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុរមែងសម្រេចនូវការនៅយ៉ាងណា ៗ មរណៈមិនល្អ(១) កាលកិរិយាក៏មិនល្អ(២) ភិក្ខុរមែងសម្រេចការនៅយ៉ាងនោះ ៗ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុរមែងសម្រេចការនៅយ៉ាងណា ៗ មរណៈមិនល្អ កាលកិរិយាក៏មិនល្អ ភិក្ខុរមែងសម្រេចការនៅយ៉ាងនោះ ៗ តើដោយប្រការដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីត្រេកអរក្នុងការងារ(៣)

១ បុគ្គលដែលស្លាប់ទាំងសេចក្តីធ្លាក់ស្លុតភិតភ័យ ឈ្មោះថាមរណៈមិនល្អ ។
២ បុគ្គលដែលស្លាប់ហើយ ទៅកើតក្នុងអបាយ ឈ្មោះថាកាលកិរិយាមិនល្អ ។ អដ្ឋកថា ។
៣ ការងារមានធ្វើវិហារជាដើម ។

កម្មរតោ កម្មារាមតំ អនុយុត្តោ ភស្សារាមោ ហោតិ ភស្សរតោ ភស្សារាមតំ អនុយុត្តោ និទ្ទារាមោ ហោតិ និទ្ទារតោ និទ្ទារាមតំ អនុយុត្តោ សង្គណិការាមោ ហោតិ សង្គណិការតោ សង្គណិការាមតំ អនុយុត្តោ សំសគ្គារាមោ ហោតិ សំសគ្គរតោ សំសគ្គារាមតំ អនុយុត្តោ បបញ្ចារាមោ ហោតិ បបញ្ចរតោ បបញ្ចារាមតំ អនុយុត្តោ ។ ឯវំ ខោ អាវុសោ ភិក្ខុ តថា តថា វិហារំ កប្បេតិ យថា យថាស្ស វិហារំ កប្បយតោ ន ភទ្ទកំ មរណំ ហោតិ ន ភទ្ទិកា កាលកិរិយា ។ អយំ វុច្ចតាវុសោ ភិក្ខុ សក្កាយាភិរតោ ន បហាសិ សក្កាយំ សម្មា ទុក្ខស្ស អន្តកិរិយាយ ។



ត្រេកអរ ក្នុងការងារ ប្រកបរឿយៗ នូវសេចក្តីរីករាយ ក្នុងការងារ ជាអ្នកមានសេចក្តីរីករាយ ក្នុងការនិយាយ ត្រេកអរក្នុងការនិយាយ ប្រកបរឿយៗ នូវសេចក្តីរីករាយ ក្នុងការនិយាយ រមែងជាអ្នកមានសេចក្តីរីករាយនឹងការដេកលក់ ត្រេកអរ ក្នុងការដេកលក់ ប្រកបរឿយៗ នូវសេចក្តីរីករាយនឹងការដេកលក់ ជាអ្នកមានសេចក្តីរីករាយ ក្នុងពួកគណៈ ត្រេកអរ ក្នុងពួកគណៈ ប្រកបរឿយៗ នូវសេចក្តីរីករាយនឹងពួកគណៈ ជាអ្នកមានសេចក្តីរីករាយ ក្នុងការច្រឡូកច្រឡំ ត្រេកអរ ក្នុងការច្រឡូកច្រឡំ ប្រកបរឿយៗ នូវសេចក្តីរីករាយនឹងការច្រឡូកច្រឡំ ជាអ្នកមានសេចក្តីរីករាយ ក្នុងបបញ្ចធម៌គឺតណ្ហា ទិដ្ឋិ មានះ ត្រេកអរ ក្នុងបបញ្ចធម៌ ប្រកបរឿយៗ នូវសេចក្តីរីករាយនឹងបបញ្ចធម៌ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុ សម្រេចការនៅយ៉ាងណាៗ មរណៈមិនល្អ កាលកិរិយា ក៏មិនល្អ ភិក្ខុ រមែងសម្រេចការនៅយ៉ាងនោះៗ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ នេះហៅថា ភិក្ខុអ្នកត្រេកអរ ចំពោះសក្កាយគឺវដ្តៈក្នុងត្រៃភូមិ មិនលះបង់សក្កាយ ដើម្បីធ្វើនូវទីបំផុតនៃទុក្ខ ដោយប្រពៃឡើយ ។

តថា តថា អាវុសោ ភិក្ខុ វិហារំ កប្បេតិ យថា យថាស្ស វិហារំ កប្បយតោ ភទ្ទកំ មរណំ ហោតិ ភទ្ទិកា កាលកិរិយា ។ កថញ្ចាវុសោ ភិក្ខុ តថា តថា វិហារំ កប្បេតិ យថា យថាស្ស វិហារំ កប្បយតោ ភទ្ទកំ មរណំ ហោតិ ភទ្ទិកា កាលកិរិយា ។ ឥធាវុសោ ភិក្ខុ ន កម្មារាមោ ហោតិ ន កម្មរតោ ន កម្មារាមតំ អនុយុត្តោ ន ភស្សារាមោ ហោតិ ន ភស្សរតោ ន ភស្សារាមតំ អនុយុត្តោ ន និទ្ទារាមោ ហោតិ ន និទ្ទារតោ ន និទ្ទារាមតំ អនុយុត្តោ ន សង្គណិការាមោ ហោតិ ន សង្គណិការតោ ន សង្គណិការាមតំ អនុយុត្តោ ន សំសគ្គារាមោ ហោតិ ន សំសគ្គរតោ ន សំសគ្គារាមតំ អនុយុត្តោ ន បបញ្ចារាមោ ហោតិ ន បបញ្ចរតោ ន បបញ្ចារាមតំ អនុយុត្តោ ។



ម្នាលអាវុសោទាំងឡាយ កាលសម្រេចការនៅយ៉ាងណា ៗ មរណៈល្អ កាលកិរិយាក៏ល្អ ភិក្ខុតែងសម្រេចការនៅយ៉ាងនោះ ៗ ។ ម្នាលអាវុសោ កាលសម្រេចការនៅយ៉ាងណា ៗ មរណៈល្អ កាលកិរិយាក៏ល្អ ភិក្ខុតែងសម្រេចការនៅយ៉ាងនោះ ៗ តើដោយប្រការដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនមានសេចក្តីរីករាយក្នុងការងារ មិនត្រេកអរក្នុងការងារ មិនប្រកបរឿយ ៗ នូវសេចក្តីរីករាយក្នុងការងារ ជាអ្នកមិនមានសេចក្តីរីករាយ ក្នុងការពោល មិនត្រេកអរ ក្នុងការពោល មិនប្រកបរឿយ ៗ នូវសេចក្តីរីករាយ ក្នុងការពោល ជាអ្នកមិនមានសេចក្តីរីករាយ ក្នុងការដេកលក់ មិនត្រេកអរក្នុងការដេកលក់ មិនប្រកបរឿយ ៗ នូវសេចក្តីរីករាយ ក្នុងការដេកលក់ ជាអ្នកមិនរីករាយ ក្នុងពួកគណៈ មិនត្រេកអរ ក្នុងពួកគណៈ មិនប្រកបរឿយ ៗ នូវសេចក្តីរីករាយ ក្នុងពួកគណៈ ជាអ្នកមិនរីករាយ ក្នុងការច្រឡូកច្រឡំ មិនត្រេកអរ ក្នុងការច្រឡូកច្រឡំ មិនប្រកបរឿយ ៗ នូវសេចក្តីរីករាយ ក្នុងការច្រឡូកច្រឡំ ជាអ្នកមិនមានសេចក្តីរីករាយ ក្នុងបបញ្ចធម៌ មិនត្រេកអរ ក្នុងបបញ្ចធម៌ មិនប្រកបរឿយ ៗ នូវសេចក្តីរីករាយ ក្នុងបបញ្ចធម៌ ។

ឯវំ ខោ អាវុសោ ភិក្ខុ តថា តថា វិហារំ កប្បេតិ យថា យថាស្ស វិហារំ កប្បយតោ ភទ្ទកំ មរណំ ហោតិ ភទ្ទិកា កាលកិរិយា ។ អយំ វុច្ចតាវុសោ ភិក្ខុ និព្វានាភិរតោ បហាសិ សក្កាយំ សម្មា ទុក្ខស្ស អន្តកិរិយាយាតិ ។

យោ បបញ្ចំ អនុយុត្តោ បបញ្ចាភិរតោ មគោ
វិរាធយី សោ និព្វានំ យោគក្ខេមំ អនុត្តរំ ។
យោ ច បបញ្ចំ ហិត្វាន និប្បបញ្ចបថេ រតោ
អារាធយី សោ និព្វានំ យោគក្ខេមំ អនុត្តរន្តិ ។

[១៥] តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ តថា តថាវុសោ ភិក្ខុ វិហារំ កប្បេតិ យថា យថាស្ស វិហារំ កប្បយតោ កាលកិរិយា អនុតប្បា ហោតិ ។ កថញ្ចាវុសោ ភិក្ខុ តថា តថា វិហារំ កប្បេតិ យថា យថាស្ស វិហារំ កប្បយតោ កាលកិរិយា អនុតប្បា ហោតិ ។



ម្នាលអាវុសោទាំងឡាយ ភិក្ខុសម្រេចការនៅយ៉ាងណាៗ មរណៈល្អ កាលកិរិយាក៏ល្អ ភិក្ខុតែងសម្រេចការនៅយ៉ាងនោះៗ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ នេះហៅថា ភិក្ខុអ្នកត្រេកអរចំពោះព្រះនិព្វាន លះបង់ហើយនូវសក្កាយ ដើម្បីធ្វើនូវទីបំផុតនៃទុក្ខដោយប្រពៃ ។

បុគ្គលណា ប្រកបរឿយៗ នូវបបញ្ចធម៌ ត្រេកអរក្នុង
បបញ្ចធម៌ដូចជាម្រឹគ បុគ្គលនោះ ឈ្មោះថា រៀរនូវ
ព្រះនិព្វាន ជាទីក្សេមចាកយោគៈដ៏ប្រសើរ ។ លុះតែបុគ្គល
ណាលះបង់នូវបបញ្ចធម៌ ត្រេកអរក្នុងព្រះនិព្វាន ដែល
មិនមានបបញ្ចធម៌ បុគ្គលនោះ ឈ្មោះថា ញ៉ាំងព្រះនិព្វាន
ជាទីក្សេមចាកយោគៈ ដ៏ប្រសើរឲ្យសម្រេចបាន ។

(១៥) ព្រះសារីបុត្រដ៏មានអាយុ មានថេរដីកានឹងពួកភិក្ខុក្នុងទីនោះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុសម្រេចការនៅយ៉ាងណាៗ កាលកិរិយាក៏តែងក្តៅក្រហាយរឿយៗ ភិក្ខុតែងសម្រេចការនៅយ៉ាងនោះ ៗ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុសម្រេចការនៅយ៉ាងណាៗ កាលកិរិយា ក៏តែងក្តៅក្រហាយរឿយៗ ភិក្ខុតែងសម្រេចការនៅយ៉ាងនោះៗ តើដូចម្តេច ។

ឥធាវុសោ ភិក្ខុ កម្មារាមោ ហោតិ កម្មរតោ កម្មារាមតំ អនុយុត្តោ ភស្សារាមោ ហោតិ... និទ្ទារាមោ ហោតិ... សង្គណិការាមោ ហោតិ... សំសគ្គារាមោ ហោតិ... បបញ្ចារាមោ ហោតិ បបញ្ចរតោ បបញ្ចារាមតំ អនុយុត្តោ ។ យំ ខោ អាវុសោ ភិក្ខុ តថា តថា វិហារំ កប្បេតិ យថា យថាស្ស វិហារំ កប្បយតោ កាលកិរិយា អនុតប្បា ហោតិ ។ អយំ វុច្ចតាវុសោ ភិក្ខុ សក្កាយាភិរតោ ន បហាសិ(*) សក្កាយំ សម្មា ទុក្ខស្ស អន្តកិរិយាយ ។ តថា តថា អាវុសោ ភិក្ខុ វិហារំ កប្បេតិ យថា យថាស្ស វិហារំ កប្បយតោ កាលកិរិយា អននុតប្បា ហោតិ ។ កថញ្ចាវុសោ ភិក្ខុ តថា តថា វិហារំ កប្បេតិ យថា យថាស្ស វិហារំ កប្បយតោ កាលកិរិយា អននុតប្បា ហោតិ ។

* ម. ន បជហាសិ ។



ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះជាអ្នកមានសេចក្តីត្រេកអរក្នុងការងារ ត្រេកអរក្នុងការងារ ប្រកបរឿយៗ នូវសេចក្តីត្រេកអរក្នុងការងារ ជាអ្នកមានសេចក្តីត្រេកអរក្នុងការរបោ ... ជាអ្នកមានសេចក្តីត្រេកអរក្នុងការដេកលក់... ជាអ្នកមានសេចក្តីត្រេកអរក្នុងពួកគណៈ... ជាអ្នកមានសេចក្តីត្រេកអរក្នុងការច្រឡូកច្រឡំ... ជាអ្នកមានសេចក្តីត្រេកអរក្នុងបបញ្ចធម៌ ត្រេកអរក្នុងបបញ្ចធម៌ ប្រកបរឿយៗ នូវសេចក្តីត្រេកអរក្នុងបបញ្ចធម៌ ។ ម្នាលអាវុសោទាំងឡាយ គេកាលសម្រេចការនៅយ៉ាងណាៗ កាលកិរិយាក៏ក្តៅក្រហាយរឿយៗ ភិក្ខុសម្រេចការនៅយ៉ាងនោះៗ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ នេះហៅថា ភិក្ខុអ្នកត្រេកអរចំពោះសក្កាយ មិនលះបង់សក្កាយ ដើម្បីធ្វើនូវទីបំផុតនៃទុក្ខដោយប្រពៃឡើយ ។ ម្នាលអាវុសោទាំងឡាយ គេកាលសម្រេចការនៅយ៉ាងណាៗ កាលកិរិយាក៏មិនក្តៅក្រហាយរឿយៗ ភិក្ខុតែងសម្រេចការនៅយ៉ាងនោះៗ ។ ម្នាលអាវុសោទាំងឡាយ ចុះគេកាលសម្រេចការនៅយ៉ាងណាៗ កាលកិរិយាក៏មិនក្តៅក្រហាយរឿយៗ ភិក្ខុតែងសម្រេចការនៅយ៉ាងនោះៗ តើដូចម្តេច ។

ឥធាវុសោ ភិក្ខុ ន កម្មារាមោ ហោតិ ន កម្មរតោ ន កម្មារាមតំ អនុយុត្តោ ន ភស្សារាមោ ហោតិ ។បេ។ ន និទ្ទារាមោ ហោតិ ន សង្គណិការាមោ ហោតិ ន សំសគ្គារាមោ ហោតិ ។ បេ ។ ន បបញ្ចារាមោ ហោតិ ន បបញ្ចរតោ ន បបញ្ចារាមតំ អនុយុត្តោ ។ ឯវំ ខោ អាវុសោ ភិក្ខុ តថា តថា វិហារំ កប្បេតិ យថា យថាស្ស វិហារំ កប្បយតោ កាលកិរិយា អននុតប្បា ហោតិ ។ អយំ វុច្ចតាវុសោ ភិក្ខុ និព្វានាភិរតោ បហាសិ សក្កាយំ សម្មា ទុក្ខស្ស អន្តកិរិយាយាតិ ។

យោ បបញ្ចំ អនុយុត្តោ បបញ្ចាភិរតោ មគោ
វិរាធយិ សោ និព្វានំ យោគក្ខេមំ អនុត្តរំ ។
យោ ច បបញ្ចំ ហិត្វាន និប្បបញ្ចបថេ រតោ
អារាធយិ សោ និព្វានំ យោគក្ខេមំ អនុត្តរន្តិ ។



ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនមានសេចក្តីត្រេកអរក្នុងការងារ មិនត្រេកអរក្នុងការងារ មិនប្រកបរឿយៗ នូវសេចក្តីត្រេកអរក្នុងការងារ ជាអ្នកមិនមានសេចក្តីត្រេកអរក្នុងការនិយាយ ។ បេ ។ ជាអ្នកមិនមានសេចក្តីត្រេកអរក្នុងការដេកលក់ ជាអ្នកមិនមានសេចក្តីត្រេកអរក្នុងពួកគណៈ ជាអ្នកមិនមានសេចក្តីត្រេកអរក្នុងការច្រឡូកច្រឡំ ។ បេ ។ ជាអ្នកមិនមានសេចក្តីត្រេកអរក្នុងបបញ្ចធម៌ មិនត្រេកអរក្នុងបបញ្ចធម៌ មិនប្រកបរឿយៗ នូវសេចក្តីត្រេកអរក្នុងបបញ្ចធម៌ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុសម្រេចការនៅយ៉ាងណា ៗ កាលកិរិយា ក៏មិនក្តៅក្រហាយឡើយ ។ ភិក្ខុតែងសម្រេចការនៅយ៉ាងនោះ ៗ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ នេះហៅថា ភិក្ខុអ្នកត្រេកអរចំពោះព្រះនិព្វាន លះបង់នូវសក្កាយ ដើម្បីធ្វើនូវទីបំផុតនៃទុក្ខដោយប្រពៃបាន ។

បុគ្គលណា ប្រកបរឿយៗ នូវបបញ្ចធម៌ ត្រេកអរក្នុង
បបញ្ចធម៌ ប្រាកដដូចជាម្រឹគ បុគ្គលនោះ ឈ្មោះថា វៀរ
នូវព្រះនិព្វាន ជាទីក្សេមចាកយោគៈដ៏ប្រសើរ ។ លុះតែ
បុគ្គលណា លះបង់នូវបបញ្ចធម៌ ត្រេកអរក្នុងព្រះនិព្វាន
ដែលមិនមានបបញ្ចធម៌ បុគ្គលនោះ ទើបឈ្មោះថា
ញុំាងព្រះនិព្វានជាទីក្សេមចាកយោគៈ ដ៏ប្រសើរឲ្យសម្រេចបាន ។

(១៦) ឯកំ សមយំ ភគវា ភគ្គេសុ វិហរតិ សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ ។ តេន ខោ បន សមយេន នកុលបិតា គហបតិ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ ។ អថខោ នកុលមាតា គហបតានី នកុលបិតរំ គហបតឹ ឯតទវោច មា ខោ ត្វំ គហបតិ សាបេក្ខោ កាលមកាសិ ទុក្ខា គហបតិ សាបេក្ខស្ស កាលកិរិយា គរហិតា ច ភគវតា សាបេក្ខស្ស កាលកិរិយា សិយា ខោ បន តេ គហបតិ ឯវមស្ស នកុលមាតា គហបតានី មមច្ចយេន ន សក្ខិស្សតិ(១) ទារកេ បោសេតុំ ឃរាវាសំ សណ្ឋាបេតុំ ន ខោ បនេតំ គហបតិ ឯវំ ទដ្ឋព្វំ កុសលាហំ គហបតិ កប្បាសំ កន្តិតុំ(២) វេណឹ ឱលិខិតុំ សក្កោមហំ គហបតិ តវច្ចយេន ទារកេ បោសេតុំ ឃរាវាសំ សណ្ឋាបេតុំ តស្មាតិហ ត្វំ គហបតិ មា សាបេក្ខោ កាលមកាសិ

១ ម. ន សក្ខតិ ។ ឱ. សក្ខតិ ។ ២ ឱ. កន្តុំ ។



(១៦) សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅ ក្នុងភេសកឡាវន ជាទីឲ្យភ័យដល់ម្រឹគ ជិតក្រុងឈ្មោះសុំសុមារគិរៈ ក្នុងភគ្គជនបទ ។ សម័យនោះឯង នកុលបិតាគហបតី មានអាពាធ ដល់នូវទុក្ខ ឈឺធ្ងន់ ។ គ្រានោះ នកុលមាតាគហបតានី បាននិយាយនឹងនកុលបិតាគហបតីដូច្នេះថា បពិត្រគហបតី អ្នកកុំធ្វើមរណកាលទាំងសេចក្តីអាល័យឡើយ បពិត្រគហបតី (ព្រោះ) កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ រមែងនាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលផង បពិត្រគហបតី អ្នកប្រហែលជាមានសេចក្តីត្រិះរិះយ៉ាងនេះថា កំណើតអំពីអញទៅ នកុលមាតាគហបតានី នឹងមិនអាចដើម្បីចិញ្ចឹមនូវទារកទាំងឡាយ ដំកល់គ្រប់គ្រងនូវឃរាវាសបានឡើយ បពិត្រគហបតី ដំណើរនុះ អ្នកមិនត្រូវយល់ឃើញយ៉ាងនុះឡើយ បពិត្រគហបតី ខ្ញុំជាស្ត្រីប្រសប់រវៃកប្បាស ទៀតក្រាសបួងក្តងសក់ បពិត្រគហបតី កំណើតអំពីអ្នកទៅ ខ្ញុំអាចដើម្បីចិញ្ចឹមនូវទារកទាំងឡាយ ដំកល់គ្រប់គ្រងនូវឃរាវាសបាន បពិត្រគហបតី ព្រោះហេតុដូច្នោះ អ្នកកុំធ្វើមរណកាលទាំងសេចក្តីអាល័យឡើយ

ទុក្ខា គហបតិ សាបេក្ខស្ស កាលកិរិយា គរហិតា ច ភគវតា សាបេក្ខស្ស កាលកិរិយា ។ សិយា ខោ បន តេ គហបតិ ឯវមស្ស នកុលមាតា គហបតានី មមច្ចយេន អញ្ញំ(១) ភត្តារំ គមិស្សតីតិ ន ខោ បនេតំ គហបតិ ឯវំ ទដ្ឋព្វំ ត្វញ្ចេវ ខោ គហបតិ ជានាសិ អហញ្ច យថា(២) នោ សោឡសវស្សានិ គហដ្ឋព្រហ្មចរិយំ(៣) សមាចិណ្ណំ តស្មាតិហ ត្វំ គហបតិ មា សាបេក្ខោ កាលមកាសិ ទុក្ខា គហបតិ សាបេក្ខស្ស កាលកិរិយា គរហិតា ច ភគវតា សាបេក្ខស្ស កាលកិរិយា ។ សិយា ខោ បន តេ គហបតិ ឯវមស្ស នកុលមាតា គហបតានី មមច្ចយេន ន ទស្សនកាមា ភវិស្សតិ ភគវតោ ន ទស្សនកាមា ភិក្ខុសង្ឃស្សាតិ ន ខោ បនេតំ គហបតិ ឯវំ ទដ្ឋព្វំ អហំ ហិ គហបតិ(៤) ទស្សនកាមតរា ច ភវិស្សាមិ ភគវតោ ទស្សនកាមតរា ច ភិក្ខុសង្ឃស្ស

១ ម. អញ្ញំ ឃរំ ។ ឱ. អញ្ញំ គន្តំ ។ ២ ម. យថា នោ ។ ឱ. យំ នោ ។ ៣ ម. ឱ. គហដ្ឋកំ ព្រហ្មចរិយំ ។ ៤ ម. ឱ. [illegible] ។



បពិត្រគហបតី កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ នាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលផង ។ បពិត្រគហបតី អ្នកប្រហែលជាមានសេចក្តីត្រិះរិះយ៉ាងនេះថា កំណត់អំពីអញទៅ នកុល-មាតាគហបតានី ចប់តែយកប្តីទៀត បពិត្រគហបតី ដំណើរនុ៎ះ អ្នកមិនគួរយល់ឃើញយ៉ាងនុ៎ះឡើយ បពិត្រគហបតី អ្នកក្តី ខ្ញុំក្តី ក៏ដឹងថា ព្រហ្ម-ចរិយធម៌របស់គ្រហស្ថ យើងធ្លាប់សន្សំមកអស់ ១៦ ឆ្នាំហើយ បពិត្រគហបតី ព្រោះហេតុនោះ អ្នកកុំធ្វើមរណកាលទាំងសេចក្តីអាល័យឡើយ បពិត្រគហបតី (ព្រោះ) កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ រមែងនាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលផង ។ បពិត្រគហបតី អ្នកប្រហែលជាមានសេចក្តីត្រិះរិះយ៉ាងនេះថា កំណត់អំពីអញទៅ នកុលមាតាគហបតានី ចប់តែមិនចង់ឃើញព្រះដ៏មានព្រះភាគ មិនចង់ឃើញព្រះភិក្ខុសង្ឃ បពិត្រគហបតី ដំណើរនុ៎ះ អ្នកមិនគួរយល់ឃើញយ៉ាងនុ៎ះឡើយ បពិត្រគហបតី ជៀសអំណាចអំពីអ្នកទៅ ខ្ញុំនឹងរឹតតែចង់ឃើញព្រះដ៏មានព្រះភាគផង នឹងរឹតតែចង់ឃើញព្រះភិក្ខុសង្ឃផង

តស្មាតិហ ត្វំ គហបតិ មា សាបេក្ខោ កាលមកាសិ ទុក្ខា គហបតិ សាបេក្ខស្ស កាលកិរិយា គរហិតា ច ភគវតា សាបេក្ខស្ស កាលកិរិយា ។ សិយា ខោ បន តេ គហបតិ ឯវមស្ស ន នកុលមាតា គហបតានី មមច្ចយេន សីលេសុ បរិបូរការិនី ន ខោ បនេតំ គហបតិ ឯវំ ទដ្ឋព្វំ យាវតា ខោ គហបតិ តស្ស ភគវតោ សាវិកា គិហី ឱទាតវសនា សីលេសុ បរិបូរការិនិយោ អហន្តាសំ អញ្ញតរា យស្ស ខោ បនស្ស កង្ខា វា វិមតិ វា អយំ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ភគ្គេសុ វិហរតិ សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ តំ ភគវន្តំ ឧបសង្កមិត្វា បុច្ឆតុ តស្មាតិហ ត្វំ គហបតិ មា សាបេក្ខោ កាលមកាសិ ទុក្ខា គហបតិ សាបេក្ខស្ស កាលកិរិយា



ម្នាលគហបតី ព្រោះហេតុនោះ អ្នកកុំធ្វើមរណកាលទាំងសេចក្តីអាល័យឡើយ ម្នាលគហបតី (ព្រោះ) កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ នាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលផង ។ ម្នាលគហបតី អ្នកប្រហែលជាមានសេចក្តីត្រិះរិះយ៉ាងនេះថា តំណពីអញទៅ នកុលមាតាគហបតានី នឹងលែងបំពេញសីលទាំងឡាយ ម្នាលគហបតី អំណើះនុ៎ះ អ្នកមិនត្រូវយល់ឃើញយ៉ាងនុ៎ះឡើយ ម្នាលគហបតី ពួកស្រីគ្រហស្ថជាសាវិការបស់ព្រះដ៏មានព្រះភាគអង្គនោះ ទាំងប៉ុន្មាននាក់ ជាស្រីស្លៀកដណ្តប់សំពត់ស បំពេញសីលទាំងឡាយ បណ្តាពួកសាវិកាទាំងនោះ ខ្ញុំជាសាវិកាមួយដែរ (រឿងនេះ) បើបុគ្គលណាមានសេចក្តីសង្ស័យក្តី មានសេចក្តីងឿងឆ្ងល់ក្តី ព្រះដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ទ្រង់គង់នៅភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់ម្រឹគ ជិតភ្នំសុំសុមារគីរៈ ក្នុងភគ្គជនបទ បុគ្គលនោះចូរចូលទៅគាល់ព្រះដ៏មានព្រះភាគនោះហើយសួរចុះ ម្នាលគហបតី ព្រោះហេតុនោះ អ្នកកុំធ្វើមរណកាលទាំងសេចក្តីអាល័យឡើយ ម្នាលគហបតី (ព្រោះ) កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ នាំមកនូវទុក្ខផង

គរហិតា ច ភគវតា សាបេក្ខស្ស កាលកិរិយា ។ សិយា ខោ បន តេ គហបតិ ឯវមស្ស ន នកុលមាតា គហបតានី លាភិនី អជ្ឈត្តំ ចេតោសមថស្សាតិ ន ខោ បនេតំ គហបតិ ឯវំ ទដ្ឋព្វំ យាវតា ខោ គហបតិ តស្ស ភគវតោ សាវិកា គិហី ឱទាតវសនា លាភិនិយោ អជ្ឈត្តំ ចេតោសមថស្ស អហំ តាសំ អញ្ញតរា យស្ស ខោ បនស្ស កង្ខា វា វិមតិ វា អយំ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ភគ្គេសុ វិហរតិ សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ តំ ភគវន្តំ ឧបសង្កមិត្វា បុច្ឆតុ តស្មាតិហ ត្វំ គហបតិ មា សាបេក្ខោ កាលមកាសិ ទុក្ខា គហបតិ សាបេក្ខស្ស កាលកិរិយា គរហិតា ច ភគវតា សាបេក្ខស្ស កាលកិរិយា ។



កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលផង ។ បពិត្រគហបតី អ្នកប្រហែលជាមានសេចក្តីត្រិះរិះយ៉ាងនេះថា នកុលមាតាគហបតានី ជាស្ត្រីមិនបាននូវចេតោសមថៈក្នុងសន្តាន បពិត្រគហបតី ដំណើរនុ៎ះ អ្នកមិនត្រូវយល់ឃើញយ៉ាងនី នុ៎ះឡើយ បពិត្រគហបតី ពួកស្ត្រីគ្រហស្ថ ជាសាវិកា របស់ព្រះដ៏មានព្រះភាគទាំងប៉ុន្មាននាក់ ជាស្ត្រីស្លៀកសំពត់ស បាននូវចេតោសមថៈក្នុងសន្តាន បណ្តាពួកសាវិកាទាំងនុ៎ះ ខ្ញុំក៏ជាសាវិកាមួយដែរ (ក្បឿងនេះ) បើបុគ្គលណាមានសេចក្តីសង្ស័យក្តី មានសេចក្តីងឿងឆ្ងល់ក្តី ព្រះដ៏មានព្រះភាគជាព្រះអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ទ្រង់គង់នៅក្នុងភេសកឡាវ័ន ជាទីឲ្យអភ័យដល់ម្រឹគ ជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ បុគ្គលនោះ គួរចូលទៅគាល់ព្រះដ៏មានព្រះភាគនោះ ហើយសួរល្បងចុះ បពិត្រគហបតី ព្រោះហេតុនោះ អ្នកកុំធ្វើមរណកាលទាំងសេចក្តីអាល័យឡើយ បពិត្រគហបតី (ព្រោះ) កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ នាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលផង ។

សិយា ខោ បន តេ គហបតិ ឯវមស្ស ន នកុលមាតា គហបតានី ឥមស្មឹ ធម្មវិនយេ ឱគាធប្បត្តា បដិគាធប្បត្តា អស្សាសប្បត្តា តិណ្ណវិចិកិច្ឆា វិគតកថំកថា វេសារជ្ជប្បត្តា អបរប្បច្ចយា សត្ថុ សាសនេ វិហរតីតិ ន ខោ បនេតំ គហបតិ ឯវំ ទដ្ឋព្វំ យាវតា ខោ គហបតិ តស្ស ភគវតោ សាវិកា គិហី ឱទាតវសនា ឥមស្មឹ ធម្មវិនយេ ឱគាធប្បត្តា បដិគាធប្បត្តា អស្សាសប្បត្តា តិណ្ណវិចិកិច្ឆា វិគតកថំកថា វេសារជ្ជប្បត្តា អបរប្បច្ចយា សត្ថុ សាសនេ វិហរន្តិ អហន្តាសំ អញ្ញតរា យស្ស ខោ បនស្ស កង្ខា វា វិមតិ វា អយំ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ភគ្គេសុ វិហរតិ សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ តំ ភគវន្តំ ឧបសង្កមិត្វា បុច្ឆតុ



បពិត្រគហបតី ប្រហែលជាអ្នកមានសេចក្តីត្រិះរិះយ៉ាងនេះថា នកុលមាតាគហបតានី មិនទាន់ដល់នូវការចុះចិត្តស៊ប់ មិនទាន់ដល់នូវទីពឹង មិនទាន់ដល់នូវការកក់ក្តៅ មិនទាន់ឆ្លងផុតសេចក្តីសង្ស័យ មិនទាន់ប្រាសចាកសេចក្តីងឿងឆ្ងល់ មិនទាន់ដល់នូវសេចក្តីក្លៀវក្លា ក្នុងធម្មវិន័យនេះ មិនទាន់លែងជឿតាមបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា បពិត្រគហបតី ដំណើរនុ៎ះ អ្នកមិនត្រូវយល់ឃើញយ៉ាងនុ៎ះឡើយ បពិត្រគហបតី ពួកស្ត្រីគ្រហស្ថជាសាវិកា របស់ព្រះដ៏មានព្រះភាគទាំងប៉ុន្មាននាក់ ជាស្ត្រីស្លៀកសំពត់ស ដល់នូវការចុះចិត្តស៊ប់ ដល់នូវទីពឹង ដល់នូវការកក់ក្តៅ មានសេចក្តីសង្ស័យឆ្លងផុតហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លា ក្នុងធម្មវិន័យនេះ មិនជឿតាមបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា បណ្តាសាវិកាទាំងនុ៎ះ ខ្ញុំជាសាវិកាមួយដែរ (រឿងនេះ) បើបុគ្គលណា មានសេចក្តីសង្ស័យក្តី មានសេចក្តីងឿងឆ្ងល់ក្តី ព្រះដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់គង់នៅក្នុងភេសកឡាវន ជាទីឲ្យនូវអភ័យដល់ម្រឹគ ជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ បុគ្គលនោះ ចូរចូលទៅគាល់ព្រះដ៏មានព្រះភាគអង្គនោះ ហើយសួរប្រស្នាចុះ ។

តស្មាតិហ ត្វំ គហបតិ មា សាបេក្ខោ កាលមកាសិ ទុក្ខា គហបតិ សាបេក្ខស្ស កាលកិរិយា គរហិតា ច ភគវតា សាបេក្ខស្ស កាលកិរិយាតិ ។ អថខោ នកុលបិតុនោ គហបតិស្ស នកុលមាតាយ គហបតានិយា ឥមិនា ឱវាទេន ឱវទិយមានស្ស សោ អាពាធោ ឋានសោ បដិប្បស្សម្ភិ វុដ្ឋហិ ច នកុលបិតា គហបតិ តម្ហា អាពាធា ។ តថា បហីនោ ច បន នកុលបិតុនោ គហបតិស្ស សោ អាពាធោ អហោសិ ។ អថខោ នកុលបិតា គហបតិ គិលានា វុដ្ឋិតោ អចិរវុដ្ឋិតោ គេលញ្ញា ទណ្ឌមោលុព្ភ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ នកុលបិតរំ គហបតឹ ភគវា ឯតទវោច លាភា តេ គហបតិ សុលទ្ធំ តេ គហបតិ យស្ស តេ នកុលមាតា គហបតានី អនុកម្បិកា អត្ថកាមា ឱវាទិកា អនុសាសិកា





បពិត្រគហបតី ព្រោះហេតុនោះ អ្នកកុំធ្វើមរណកាលទាំងសេចក្តីអាល័យឡើយ បពិត្រគហបតី (ព្រោះ) កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ នាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលផង ។ លំដាប់នោះ នកុលបិតាគហបតី ដែលនកុលមាតាគហបតានីទូន្មានដោយឱវាទនេះ អាពាធនោះក៏ស្ងប់រម្ងាប់ ដោយឋានៈ ទាំងនកុលបិតាគហបតី ក៏សះស្បើយចាកអាពាធនោះ ។ អាពាធនោះជាស្រឡះអំពីនកុលបិតាគហបតីហើយ ។ លុះនកុលបិតាគហបតី ស្បើយចាកជម្ងឺ ក្រោកចាកជម្ងឺមិនយូរប៉ុន្មាន ក៏ច្រត់ឈើច្រត់ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះនកុលបិតាគហបតី អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី អ្នកពេញជាមានលាភហើយ ម្នាលគហបតី អត្តភាពជាមនុស្ស អ្នកពេញជាបានល្អហើយ ត្រង់ដែលអ្នកបាននកុលមាតាគហបតានី មកជាអ្នកអនុគ្រោះ ប្រាថ្នានូវប្រយោជន៍ ជាអ្នកទូន្មានប្រៀនប្រដៅ

យាវតា តេ គហបតិ មម សាវិកា គិហី ឱទាតវសនា សីលេសុ បរិបូរការិនិយោ នកុល-មាតា គហបតានី តាសំ អញ្ញតរា យាវតា តេ គហបតិ មម សាវិកា គិហី ឱទាតវសនា លាភិនិយោ អជ្ឈត្តំចេតោសមថស្ស នកុលមាតា គហបតានី តាសំ អញ្ញតរា យាវតា តេ គហបតិ មម សាវិកា គិហី ឱទាតវសនា ឥមស្មឹ ធម្មវិនយេ ឱគាធប្បត្តា បដិគាធប្បត្តា អស្សាសប្បត្តា តិណ្ណវិចិកិច្ឆា វិគតកថំកថា វេសារជ្ជប្បត្តា អបរប្បច្ចយា សត្ថុ សាសនេ វិហរន្តិយោ នកុល-មាតា គហបតានី តាសំ អញ្ញតរា លាភា តេ គហបតិ សុលទ្ធំ តេ គហបតិ យស្ស តេ នកុលមាតា គហបតានី អនុកម្បិកា អត្ថកាមា ឱវាទិកា អនុសាសិកាតិ ។



ម្នាលគហបតី ពួកស្រ្តីគ្រហស្ថជាសាវិកា របស់តថាគតទាំងប៉ុន្មាននាក់ ជាអ្នកស្លៀកដណ្តប់សំពត់ស បំពេញសីលទាំងឡាយ បណ្តាពួកសាវិកាទាំងនោះ នកុលមាតាគហបតានី ជាសាវិកាមួយដែរ ម្នាលគហបតី ពួកស្រ្តីគ្រហស្ថជាសាវិកា របស់តថាគតទាំងប៉ុន្មាននាក់ ជាអ្នកស្លៀកដណ្តប់សំពត់ស បាននូវចេតោសមថៈក្នុងសន្តាន បណ្តាពួកសាវិកាទាំងនោះ នកុលមាតាគហបតានី ជាសាវិកាមួយដែរ ម្នាលគហបតី ពួកស្រ្តីគ្រហស្ថជាសាវិកា របស់តថាគតទាំងប៉ុន្មាននាក់ ជាអ្នកស្លៀកដណ្តប់សំពត់ស ដល់នូវការចុះចិត្តស៊ប់ ដល់នូវទីពឹងមាំ ដល់នូវការកក់ក្តៅ មានសេចក្តីសង្ស័យឆ្លងផុតហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លាក្នុងធម្មវិន័យនេះ មិនជឿតាមបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា បណ្តាពួកសាវិកាទាំងនោះ នកុលមាតាគហបតានី ជាសាវិកាមួយដែរ ម្នាលគហបតី អ្នកពេញជាមានលាភហើយ ម្នាលគហបតី អត្តភាពជាមនុស្ស អ្នកពេញជាបានល្អហើយ ត្រង់ដែលអ្នកបាន នកុលមាតាគហ-បតានី មកជាអ្នកអនុគ្រោះ ប្រាថ្នានូវប្រយោជន៍ ទូន្មានប្រៀនប្រដៅ ។

(១៧) ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនុបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អាយស្មាបិ ខោ សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនុបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ អាយស្មាបិ ខោ មហាមោគ្គល្លានោ អាយស្មាបិ ខោ មហាកស្សបោ អាយស្មាបិ ខោ មហាកច្ចានោ អាយស្មាបិ ខោ មហាកោដ្ឋិកោ អាយស្មាបិ ខោ មហាចុន្ទោ អាយស្មាបិ ខោ មហាកប្បិនោ អាយស្មាបិ ខោ អនុរុទ្ធោ អាយស្មាបិ ខោ រេវតោ អាយស្មាបិ ខោ អានន្ទោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនុបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ អថខោ ភគវា



(១៧) សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ចូលទៅឯឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ ចំណែកព្រះសារីបុត្រដ៏មានអាយុ ក៏ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅឯឧបដ្ឋានសាលាដែរ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ចំណែកព្រះមោគ្គល្លានដ៏មានអាយុ ព្រះមហាកស្សបដ៏មានអាយុ ព្រះមហាកច្ចានៈដ៏មានអាយុ ព្រះមហាកោដ្ឋិកៈដ៏មានអាយុ ព្រះមហាចុន្ទដ៏មានអាយុ ព្រះមហាកប្បិនដ៏មានអាយុ ព្រះអនុរុទ្ធដ៏មានអាយុ ព្រះរេវតៈដ៏មានអាយុ ព្រះអានន្ទដ៏មានអាយុ ក៏ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ហើយចូលទៅឯឧបដ្ឋានសាលាដែរ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ

ពហុទេវ រត្តឹ និសជ្ជាយ វីតិនាមេត្វា ឧដ្ឋាយាសនា
វិហារំ បាវិសិ ។ តេបិ ខោ អាយស្មន្តោ
អចិរបក្កន្តស្ស ភគវតោ ឧដ្ឋាយាសនា យថាវិហារំ
អគមំសុ ។ យេ បន តត្ថ ភិក្ខូ នវា
អចិរបព្វជិតា អធុនាគតា ឥមំ ធម្មវិនយំ តេ
យាវ សុរិយស្សុគ្គមនា កាកច្ឆមានា សុបិំសុ ។
អទ្ទសា ខោ ភគវា ទិព្វេន ចក្ខុនា វិសុទ្ធេន
អតិក្កន្តមានុសកេន តេ ភិក្ខូ យាវ សុរិយស្សុគ្គមនា
កាកច្ឆមានេ សុបន្តេ ទិស្វា យេនុបដ្ឋានសាលា
តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ
និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ
កហំ នុ ខោ ភិក្ខវេ សារីបុត្តោ កហំ មោគ្គល្លានោ
កហំ មហាកស្សបោ កហំ មហាកច្ចានោ កហំ
មហាកោដ្ឋិកោ កហំ មហាចុន្ទោ កហំ មហាកប្បិនោ
កហំ អនុរុទ្ធោ កហំ រេវតោ កហំ អានន្ទោ កហំ
នុ ខោ តេ ភិក្ខវេ ថេរា សាវកា គតា ។



ទ្រង់គង់កន្លងវេលា រហូតយប់ជ្រៅ ហើយក៏ទ្រង់ក្រោកចាកអាសនៈ
ស្តេចទៅកាន់វិហារ ។ ពួកព្រះថេរៈដ៏មានអាយុទាំងនោះ កាលដែលព្រះ
ដ៏មានព្រះភាគ ស្តេចចេញទៅមិនយូរប៉ុន្មាន ក៏ក្រោកចាកអាសនៈ
ទៅកាន់លំនៅរៀងខ្លួន ៗ ។ ចំណែកពួកភិក្ខុណា ដែលនៅក្នុងឧបដ្ឋាន-
សាលានោះ ជាភិក្ខុថ្មី បួសមិនទាន់អស់កាលយូរប៉ុន្មាន ទើបនឹងមកកាន់
ធម្មវិន័យនេះ ពួកភិក្ខុទាំងនុ៎ះ ក៏សឹងស្រមុកលន់លក់ ដរាបដល់ព្រះអាទិត្យ
រះឡើង ។ ព្រះដ៏មានព្រះភាគបានឃើញ ពួកភិក្ខុទាំងនុ៎ះ កំពុងដេក
ស្រមុកលន់លក់ ដរាបដល់ព្រះអាទិត្យរះឡើង ដោយទិព្វចក្ខុដ៏បរិសុទ្ធ
កន្លងបង់ចក្ខុរបស់មនុស្សសាមញ្ញ លុះឃើញហើយ ក៏យាងចូលទៅ
ឯឧបដ្ឋានសាលា លុះយាងចូលទៅដល់ហើយ ក៏គង់លើអាសនៈដែល
គេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគ ទ្រង់គង់ស្រេចហើយ ក៏ត្រាស់
សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ សារីបុត្រទៅក្នុងទីណា មោគ្គល្លាន
ទៅក្នុងទីណា មហាកស្សបទៅក្នុងទីណា មហាកច្ចានៈទៅក្នុងទីណា
មហាកោដ្ឋិតៈទៅក្នុងទីណា មហាចុន្ទទៅក្នុងទីណា មហាកប្បិនទៅក្នុងទី
ណា អនុរុទ្ធទៅក្នុងទីណា រេវតៈទៅក្នុងទីណា អានន្ទទៅក្នុងទីណា ម្នាល
ភិក្ខុទាំងឡាយ ពួកសាវកជាថេរៈទាំងនោះ ទៅក្នុងទីណាបាត់អស់នេះ ។

តេបិ ខោ ភន្តេ អាយស្មន្តោ អចិរប្បក្កន្តស្ស ភគវតោ ឧដ្ឋាយាសនា យថាវិហារំ អគមំសូតិ ។ កេន នោ តុម្ហេ ភិក្ខវេ ថេរា ភិក្ខូ នវា យាវ សុរិយស្សុគ្គមនា កាកច្ឆមានា សុបថ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ តុម្ហេហិ ទិដ្ឋំ វា សុតំ វា រាជា ខត្តិយោ មុទ្ធាវសិត្តោ យាវជីវំ សេយ្យសុខំ បស្សសុខំ មិទ្ធសុខំ អនុយុត្តោ វិហរន្តោ យាវជីវំ រជ្ជំ ការេន្តោ ជនបទស្ស វា បិយោ មនាបោតិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ មយាបិ ខោ ឯតំ ភិក្ខវេ នេវ ទិដ្ឋំ ន សុតំ រាជា ខត្តិយោ មុទ្ធាវសិត្តោ យាវជីវំ សេយ្យសុខំ បស្សសុខំ មិទ្ធសុខំ អនុយុត្តោ វិហរន្តោ យាវជីវំ រជ្ជំ ការេន្តោ ជនបទស្ស វា បិយោ មនាបោតិ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ តុម្ហេហិ ទិដ្ឋំ វា សុតំ វា រដ្ឋិកោ បេត្តនិកោ (១)

---
១ ឱ. និទ្ធុប បេតណិកោ អត្ថិ ។



ពួកភិក្ខុទាំងនោះ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលព្រះអង្គស្ដេចចេញទៅមិនយូរប៉ុន្មាន ពួកលោកទាំងនោះ ក៏ក្រោកចាកអាសនៈ ហើយទៅកាន់លំនៅនៃខ្លួនៗ ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយ ជាថេរៈ ឬជាភិក្ខុថ្មី សុទ្ធតែដេកស្រមុកលង់លក់ ដរាបដល់ព្រះអាទិត្យរះឡើង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ យល់នូវហេតុនោះដូចម្ដេច អ្នកទាំងឡាយធ្លាប់ឃើញ ឬធ្លាប់ឮថា ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ ទ្រង់សព្វព្រះរាជហឫទ័យ នឹងតែសុខអំពីការផ្ទំ សុខអំពីការផ្អែក សុខអំពីងុយលក់ទាល់តែស្លាប់ស្អុល សោយរាជ្យដរាបដល់អស់ព្រះជន្មហើយ បានជាទីស្រឡាញ់ពេញចិត្ត នៃអ្នកជនបទផងដែរឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន មិនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ តំណើរនុ៎ះ សូម្បីតថាគត ក៏មិនដែលឃើញ មិនដែលឮថា ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ ទ្រង់សព្វព្រះរាជហឫទ័យនឹងតែសុខអំពីការផ្ទំ សុខអំពីការផ្អែក សុខអំពីងុយលក់ទាល់តែស្លាប់ស្អុល សោយរាជ្យដរាបដល់អស់ព្រះជន្ម ហើយបានជាទីស្រឡាញ់ពេញចិត្ត នៃអ្នកជនបទផងដែរ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ យល់នូវហេតុនោះ ដូចម្ដេច អ្នកទាំងឡាយធ្លាប់ឃើញ ឬធ្លាប់ឮថា អ្នកធំក្នុងដែន អ្នកប្រើប្រាស់ទ្រព្យជាដំណែលបិតា

សេនាបតិកោ គាមគាមណិកោ បូគគាមណិកោ យាវតត្ថំ សេយ្យសុខំ បស្សសុខំ មិទ្ធសុខំ អនុយុត្តោ វិហរន្តា យាវជីវំ បូគគាមណិកត្តំ កាហេន្តា បូគស្ស ច បិយោ មនាបោតិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ មយាបិ ខោ ឯតំ ភិក្ខវេ នេវ ទិដ្ឋំ ន សុតំ បូគគាមណិកោ យាវតត្ថំ សេយ្យសុខំ បស្សសុខំ មិទ្ធសុខំ អនុយុត្តោ វិហរន្តា យាវជីវំ បូគគាមណិកត្តំ កាហេន្តោ បូគស្ស ច បិយោ មនាបោតិ ។ តំ កិំ មញ្ញថ ភិក្ខវេ អបិ នុ តុម្ហេហិ ទិដ្ឋំ វា សុតំ វា សមណោ វា ព្រាហ្មណោ វា យាវតត្ថំ សេយ្យសុខំ បស្សសុខំ មិទ្ធសុខំ អនុយុត្តោ ឥន្ទ្រិយេសុ អគុត្តទ្វារោ ភោជនេ អមត្តញ្ញូ ជាគរិយំ អននុយុត្តោ អវិបស្សកោ កុសលានំ ធម្មានំ បុព្វរត្តាបរត្តំ ពោធិបក្ខិយានំ ធម្មានំ ភាវនានុយោគំ អននុយុត្តោ



ជាសេនាបតី ជាចៅហ្វាយស្រុក អ្នកជាធំលើប្រជាជន ចូលចិត្តនៃតាងនី សុខអំពីការដេក សុខអំពីការផ្អែក សុខអំពីការដេកលក់តាមតែស្កប់ស្កល់ គ្រាន់តែទទួលដំណែង ជាចៅហ្វាយស្រុកនៃប្រជាជន ដរាបដល់អស់ជីវិត ហើយបានជាទីស្រឡាញ់ពេញចិត្តនៃប្រជាជនផងដែរ ។ បពិត្រព្រះអង្គដ៏ចំរើន មិនធ្លាប់ទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ សូម្បីតថាគត ក៏មិនដែលឃើញ មិនដែលឮថា អ្នកជាធំលើប្រជាជន ចូលចិត្តនៃតាងនីសុខអំពីការដេក សុខអំពីការផ្អែក សុខអំពីការដេកលក់តាមតែស្កប់ស្កល់ ទទួលដំណែងជាចៅហ្វាយស្រុកនៃប្រជាជន ដរាបដល់អស់ជីវិត ហើយបានជាទីស្រឡាញ់ ជាទីពេញចិត្តនៃប្រជាជនផងដែរ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ យល់នូវហេតុនោះដូចម្តេច អ្នកទាំងឡាយធ្លាប់ឃើញ ឬធ្លាប់ឮថា សមណៈក្តី ព្រាហ្មណ៍ក្តី ខ្វល់ខ្វាយនៃតាងនីសុខអំពីការដេក សុខអំពីការផ្អែក សុខអំពីដេកលក់តាមតែស្កប់ស្កល់ ជាអ្នកមិនគ្រប់គ្រងទ្វារ គឺឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន មិនប្រកបនូវការភ្ញាក់រលឹក មិនពិចារណាកុសលធម៌ទាំងឡាយ ក្នុងកាលជាខាងដើមរាត្រី និងកាលជាខាងចុងរាត្រី មិនខ្វល់ខ្វាយនូវការព្យាយាមចំរើននូវពោធិបក្ខិយធម៌ទាំងឡាយទេ

អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ មយាបិ ខោ ឯតំ ភិក្ខវេ នេវ ទិដ្ឋំ ន សុតំ សមណោ វា ព្រាហ្មណោ វា យាវទត្ថំ សេយ្យសុខំ បស្សសុខំ មិទ្ធសុខំ អនុយុត្តោ ឥន្ទ្រិយេសុ អគុត្តទ្វារោ ភោជនេ អមត្តញ្ញូ ជាគរិយំ អននុយុត្តោ អវិបស្សកោ កុសលានំ ធម្មានំ បុព្វរត្តាបររត្តំ ពោធិបក្ខិយានំ ធម្មានំ ភាវនានុយោគំ អននុយុត្តោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ ឥន្ទ្រិយេសុ គុត្តទ្វារា ភវិស្សាម ភោជនេ មត្តញ្ញុនោ ជាគរិយំ អនុយុត្តា



ហើយការធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនឯង ដូច្នេះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន មិនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះសូម្បីតថាគត ក៏មិនដែលឃើញ មិនដែលឮថា សមណៈក្ដី ព្រាហ្មណ៍ក្ដី ខ្វល់ខ្វាយតែនឹងសុខអំពីការដេក សុខអំពីការផ្អែក សុខអំពីការដេកលក់តាមតែស្កប់ស្កល់ ជាអ្នកមិនគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ មិនស្គាល់ប្រមាណក្នុងភោជន មិនប្រកបរឿយៗ នូវការភ្ញាក់រលឹក មិនពិចារណាកុសលធម៌ទាំងឡាយ ក្នុងកាលជាខាងដើមរាត្រី និងកាលខាងចុងរាត្រី មិនខ្វល់ខ្វាយនូវការព្យាយាមចំរើនពោធិបក្ខិយធម៌ទាំងឡាយទេ ហើយការធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនឯង ដូច្នេះដែរ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះថា យើងនឹងជាអ្នកគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ស្គាល់ប្រមាណក្នុងភោជន ប្រកបរឿយៗ នូវការភ្ញាក់រលឹក

វិបស្សកា កុសលានំ ធម្មានំ បុព្វរត្តាបរត្តំ ពោធិបក្ខិយានំ ធម្មានំ ភាវនានុយោគមនុយុត្តា វិហរិស្សាមាតិ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

(១៨) ឯកំ សមយំ ភគវា កោសលេសុ ចារិកំ ចរតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ ។ អទ្ទសា ខោ ភគវា អទ្ធានមគ្គំ បដិបន្នោ អញ្ញតរស្មឹ បទេសេ មច្ឆិកំ មច្ឆឃាតកំ មច្ឆេ វធិត្វា វធិត្វា វិក្កិណមានំ ទិស្វា មគ្គា ឱក្កម្ម អញ្ញតរស្មឹ រុក្ខមូលេ បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ បស្សថ នោ តុម្ហេ ភិក្ខវេ អមុំ(១) មច្ឆិកំ មច្ឆឃាតកំ មច្ឆេ វធិត្វា វធិត្វា វិក្កិណមានន្តិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ តុម្ហេហិ ទិដ្ឋំ វា សុតំ វា មច្ឆិកោ មច្ឆឃាតកោ មច្ឆេ វធិត្វា វធិត្វា វិក្កិណមានោ តេន កម្មេន តេន អាជីវេន ហត្ថិយាយី វា អស្សយាយី វា រថយាយី វា យានយាយី វា ភោគភោគី វា មហន្តំ វា ភោគក្ខន្ធំ អជ្ឈាវសន្តោតិ ។ នោ ហេតំ ភន្តេ ។

១ ម. ឱ. អមុំ ។



ជាអ្នកពិចារណានូវកុសលធម៌ទាំងឡាយ ក្នុងកាលជាខាងដើមរាត្រីនិងកាលខាងចុងរាត្រី នូវខ្វល់ខ្វាយនូវការព្យាយាមចំរើនពោធិបក្ខិយធម៌ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះឯង ។

(១៨) សម័យមួយ ព្រះដ៏មានព្រះភាគ ស្តេចទៅកាន់ចារិក ក្នុងដែនកោសល មួយអន្លើដោយភិក្ខុសង្ឃច្រើនរូប ។ កាលព្រះដ៏មានព្រះភាគ ស្តេចទៅកាន់ផ្លូវឆ្ងាយ បានឃើញព្រានត្រី អ្នកសម្លាប់ត្រី កំពុងតែកាប់សំឡាប់ត្រីលក់ ក្នុងប្រទេសមួយ លុះទតឃើញហើយ ស្តេចចេញអំពីផ្លូវ ទៅគង់លើអាសនៈដែលគេក្រាលទុក ទៀបគល់ឈើមួយដើម ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់ហើយ បានត្រាស់នឹងពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញព្រានត្រី អ្នកសម្លាប់ត្រីឯណោះ កំពុងកាប់សំឡាប់ត្រីលក់ដែរឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ យល់នូវហេតុនោះដូចម្តេច អ្នកទាំងឡាយធ្លាប់ឃើញ ឬធ្លាប់ឮថា បុគ្គលជាព្រានត្រី អ្នកសម្លាប់ត្រី សំឡាប់ត្រីលក់ បានជាអ្នកទៅដោយដំរី ទៅដោយសេះ ទៅដោយរថ ទៅដោយយាន ឬបានជាអ្នកបរិភោគនូវភោគសម្បត្តិ ឬនៅគ្រប់គ្រងនូវគំនរភោគសម្បត្តិដ៏ច្រើន ព្រោះអំពើបែបនោះ ព្រោះការចិញ្ចឹមជីវិតបែបនោះដូច្នោះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន មិនដូច្នោះទេ ។

សាធុ ភិក្ខវេ មយាបិ ខោ ឯតំ ភិក្ខវេ នេវ ទិដ្ឋំ ន សុតំ មច្ឆិកំ មច្ឆឃាតំ មច្ឆេ វធិត្វា វធិត្វា វិក្កិណមានំ តេន កម្មេន តេន អាជីវេន ហត្ថិយាយឹ វា អស្សយាយឹ វា រថយាយឹ វា យានយាយឹ វា ភោគភោគឹ វា មហន្តំ វា ភោគក្ខន្ធំ អជ្ឈាវសន្តំ ។ តំ កិស្ស ហេតុ ។ តេ ហិ សោ ភិក្ខវេ មច្ឆេ វជ្ឈេ វធាយនីតេ បាបកេន មនសា អនុបេក្ខតិ តស្មា សោ នេវ ហត្ថិយាយី ហោតិ ន អស្សយាយី ន រថយាយី ន យានយាយី ន ភោគភោគី ន មហន្តំ ភោគក្ខន្ធំ អជ្ឈាវសតិ ។ តំ កិំ មញ្ញថ ភិក្ខវេ អបិ នុ តុម្ហេហិ ទិដ្ឋំ វា សុតំ វា គោឃាតកោ គាវេ វធិត្វា វធិត្វា វិក្កិណមានោ តេន កម្មេន តេន អាជីវេន ហត្ថិយាយី វា អស្សយាយី វា រថយាយី វា យានយាយី វា ភោគភោគី វា មហន្តំ វា ភោគក្ខន្ធំ អជ្ឈាវសន្តោ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ មយាបិ ខោ ឯតំ ភិក្ខវេ នេវ ទិដ្ឋំ



ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ សូម្បីតថាគត ក៏មិនធ្លាប់ឃើញមិនធ្លាប់ឮថា បុគ្គលជាព្រានត្រី អ្នកចាប់ត្រី សំឡាប់ត្រីលក់ បានជាអ្នកទៅដោយដំរី ទៅដោយសេះ ទៅដោយរថ ទៅដោយយាន ឬបានជាអ្នកបរិភោគនូវភោគសម្បត្តិ នៅគ្រប់គ្រងនូវគំនរភោគសម្បត្តិដ៏ច្រើន ព្រោះអំពើនោះ ព្រោះការចិញ្ចឹមជីវិតនោះ ដូច្នេះ ។ ពាក្យនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ព្រានត្រីនោះតែងរំពៃគិតត្រី ដែលខ្លួនត្រូវសំឡាប់ នាំមកដើម្បីសំឡាប់នោះ ដោយចិត្តអាក្រក់ ព្រោះហេតុនោះ ព្រាននោះ ទើបជាអ្នកមិនបានទៅដោយដំរី មិនបានទៅដោយសេះ មិនបានទៅដោយរថ មិនបានទៅដោយយាន មិនបានជាអ្នកបរិភោគនូវភោគសម្បត្តិ មិនបានគ្រប់គ្រងនូវគំនរភោគសម្បត្តិដ៏ច្រើនឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ យល់ហេតុនោះ ដូចម្តេច អ្នកទាំងឡាយ ធ្លាប់ឃើញ ឬធ្លាប់ឮថា អ្នកពិឃាតគោ សំឡាប់គោលក់ បានជាអ្នកទៅដោយដំរី ទៅដោយសេះ ទៅដោយរថ ទៅដោយយាន ឬបានជាអ្នកបរិភោគនូវភោគសម្បត្តិ នៅគ្រប់គ្រងនូវគំនរភោគសម្បត្តិដ៏ច្រើន ព្រោះអំពើនោះ ព្រោះការចិញ្ចឹមជីវិតនោះ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន មិនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ សូម្បីតថាគត ក៏មិនធ្លាប់ឃើញ មិនធ្លាប់ឮថា

ន សុតំ គោឃាតកោ គាវេ វធិត្វា វធិត្វា វិក្កិណមានោ តេន កម្មេន តេន អាជីវេន ហត្ថិយាយី វា អស្សយាយី វា រថយាយី វា យានយាយី វា ភោគភោគី វា មហន្តំ វា ភោគក្ខន្ធំ អជ្ឈាវសន្តោតិ ។ តំ កិស្ស ហេតុ ។ តេ ហិ សោ ភិក្ខវេ គាវេ វជ្ឈត្ថាយ នីតេ ពាធកេន មនសា អនុបេក្ខតិ តស្មា សោ នេវ ហត្ថិយាយី ហោតិ ន អស្សយាយី ន រថយាយី ន យានយាយី ន ភោគភោគី ន មហន្តំ ភោគក្ខន្ធំ អជ្ឈាវសតិ ។ តំ កិំ មញ្ញថ ភិក្ខវេ អបិ នុ តុម្ហេហិ ទិដ្ឋំ វា សុតំ វា ឱរព្ភិកោ ។បេ។ សូករិកោ សាកុណិកោ មាគវិកោ មិគេ វធិត្វា វធិត្វា វិក្កិណមានោ តេន កម្មេន តេន អាជីវេន ហត្ថិយាយី វា អស្សយាយី វា រថយាយី វា យានយាយី វា ភោគភោគី វា មហន្តំ វា ភោគក្ខន្ធំ អជ្ឈាវសន្តោតិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ មយាបិ ខោ ឯតំ ភិក្ខវេ នេវ ទិដ្ឋំ ន សុតំ



អ្នកពិឃាតគោ សំឡាប់គោលក់ បានជាអ្នកទៅដោយដំរី ទៅដោយសេះ ទៅដោយរថ ទៅដោយយាន ឬបានជាអ្នកបរិភោគនូវភោគសម្បត្តិ នៅគ្រប់គ្រងនូវភោគសម្បត្តិដ៏ច្រើនដូច្នេះដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា អ្នកពិឃាតគោនោះ រមែងពិចារណាគោ ដែលខ្លួនត្រូវសំឡាប់ ដែលខ្លួននាំមកដើម្បីសំឡាប់នោះ ដោយចិត្តអាក្រក់ ព្រោះហេតុនោះ អ្នកពិឃាតគោនោះ ទើបមិនបានជាអ្នកទៅដោយដំរី មិនបានទៅដោយសេះ មិនបានទៅដោយរថ មិនបានទៅដោយយាន មិនបានជាអ្នកបរិភោគនូវភោគសម្បត្តិ មិននៅគ្រប់គ្រងនូវភោគសម្បត្តិ ដ៏ច្រើន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់ហេតុនោះដូចម្តេច អ្នកទាំងឡាយ ធ្លាប់ឃើញ ឬធ្លាប់ឮថា អ្នកសំឡាប់ចៀម ។បេ។ អ្នកសំឡាប់ជ្រូក អ្នកសំឡាប់សត្វស្លាប អ្នកសំឡាប់ម្រឹគ ដែលសំឡាប់ម្រឹគលក់ បានជាអ្នកទៅដោយដំរី ទៅដោយសេះ ទៅដោយរថ ទៅដោយយាន ឬជាអ្នកបរិភោគនូវភោគសម្បត្តិ នៅគ្រប់គ្រងនូវភោគសម្បត្តិ ដ៏ច្រើន ដោយអំពើនោះ ដោយការចិញ្ចឹមជីវិតនោះ ដូច្នេះដែរ ឬ ។ បពិត្រព្រះអង្គដ៏ចំរើន មិនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ហេតុនុ៎ះ សូម្បីតថាគត ក៏មិនដែលឃើញ មិនដែលឮថា

មាគវិកោ មិគេ វធិត្វា វធិត្វា វិក្កិណមានោ តេន កម្មេន តេន អាជីវេន ហត្ថិយាយី វា អស្សយាយី វា រថយាយី វា យានយាយី វា ភោគភោគី វា មហន្តំ វា ភោគក្ខន្ធំ អជ្ឈាវសន្តោតិ ។ តំ កិស្ស ហេតុ ។ តថា ហិ សោ ភិក្ខវេ មិគេ វធាយុបនីតេ បាបកេន មនសានុបេក្ខតិ តស្មា សោ នេវ ហត្ថិយាយី ហោតិ ន អស្សយាយី ន រថយាយី ន យានយាយី ន ភោគភោគី ន មហន្តំ ភោគក្ខន្ធំ អជ្ឈាវសតិ ។ យោ ហិ សោ ភិក្ខវេ តិរច្ឆានគតេ បាណេ មិគេ វធាយុបនីតេ បាបកេន មនសានុបេក្ខតិ តស្មា សោ នេវ ហត្ថិយាយី ហោតិ ន អស្សយាយី ន រថយាយី ន យានយាយី ន ភោគភោគី ន មហន្តំ ភោគក្ខន្ធំ អជ្ឈាវសតិ ។ កោ បន វាទោ យំ មនុស្សភូតំ វជ្ឈំ វធាយុបនីតំ បាបកេន មនសានុបេក្ខតិ



អ្នកសំឡាប់ម្រឹគ ដែលសំឡាប់ម្រឹគលក់ បានជាអ្នកទៅដោយដំរី ទៅដោយសេះ ទៅដោយរថ ទៅដោយយាន ឬ ជាអ្នកបរិភោគនូវភោគសម្បត្តិ នៅគ្រប់គ្រងនូវគំនរភោគសម្បត្តិ ដ៏ច្រើនដូច្នេះដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ព្រានម្រឹគនោះ រមែងរំពៃរកម្រឹគ ដែលខ្លួនត្រូវសំឡាប់ ដែលខ្លួននាំមក ដើម្បីសំឡាប់នោះ ដោយចិត្តអាក្រក់ ព្រោះហេតុនោះ ព្រានម្រឹគនោះ មិនបានជាអ្នកទៅដោយដំរី មិនបានទៅដោយសេះ មិនបានទៅដោយរថ មិនបានទៅដោយយាន មិនបានជាអ្នកបរិភោគនូវភោគសម្បត្តិ មិនបាននៅគ្រប់គ្រងនូវគំនរភោគសម្បត្តិ ដ៏ច្រើន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះ ព្រាននោះ រមែងរំពៃរកសត្វតិរច្ឆានទាំងនោះ ដែលខ្លួនត្រូវសំឡាប់ ដែលខ្លួននាំមកដើម្បីសំឡាប់ ដោយចិត្តអាក្រក់ ព្រោះហេតុនោះ បានជាព្រានម្រឹគនោះ មិនបានជាអ្នកទៅដោយដំរី មិនបានទៅដោយសេះ មិនបានទៅដោយរថ មិនបានទៅដោយយាន មិនបានជាអ្នកបរិភោគនូវភោគសម្បត្តិ មិនបាននៅគ្រប់គ្រងនូវគំនរភោគសម្បត្តិ ដ៏ច្រើន ចាំបាច់និយាយថ្វីដល់បុគ្គល ដែលសំឡឹងរកមនុស្សដែលខ្លួនត្រូវសំឡាប់ ដែលខ្លួននាំមកដើម្បីសំឡាប់ ដោយចិត្តអាក្រក់

តំ ហិ តស្ស ភិក្ខវេ ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយ ។ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតីតិ ។

(១៩) ឯកំ សមយំ ភគវា នាតិកេ វិហរតិ គិញ្ជកាវសថេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច មរណស្សតិ ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា អមតោគធា អមតបរិយោសានា ភាវេថ នោ តុម្ហេ ភិក្ខវេ មរណស្សតិន្តិ ។ ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច អហំ ខោ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ យថាកថំ បន ត្វំ ភិក្ខុ ភាវេសិ មរណស្សតិន្តិ ។ ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ



ម្នាលភិក្ខុទាំងឡាយ ព្រោះការសំឡឹងបែបនោះ រមែងប្រព្រឹត្តទៅ មិនជាប្រយោជន៍ ជាទុក្ខអស់កាលយូរអង្វែងដល់បុគ្គលនោះ លុះបុគ្គលនោះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតឯអបាយទុគ្គតិ វិនិបាត នរក ។

(១៩) សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទឥដ្ឋ ទៀបនាតិកគ្រាម ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ និមន្តភិក្ខុដែលនៅក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលតបព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ មរណស្សតិ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងជាគុណជាតិ មានផលច្រើន មានអានិសង្សច្រើន ជាគុណជាតិ ឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយ ចំរើននូវមរណស្សតិដែរឬ ។ កាលព្រះដ៏មានព្រះភាគ ត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូប ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណា ចំរើននូវមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចំរើនមរណស្សតិបែបណា ។ បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គបានគិតទុកយ៉ាងនេះថា

អហោ វតាហំ រត្តិន្ទិវំ ជីវេយ្យំ ភគវតោ សាសនំ មនសិ ករេយ្យំ ពហុ វត មេ កតំ អស្សាតិ ឥមំ ខោ អហំ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ អញ្ញតរោបិ ខោ ភិក្ខុ ភគវន្តំ ឯតទវោច អហំបិ ខោ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ យថាកថំ បន ត្វំ ភិក្ខុ ភាវេសិ មរណស្សតិន្តិ ។ ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ អហោ វតាហំ ទិវសំ ជីវេយ្យំ ភគវតោ សាសនំ មនសិ ករេយ្យំ ពហុ វត មេ កតំ អស្សាតិ ឥមំ ខោ អហំ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ អញ្ញតរោបិ ខោ ភិក្ខុ ភគវន្តំ ឯតទវោច អហំបិ ខោ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ យថាកថំ បន ត្វំ ភិក្ខុ ភាវេសិ មរណស្សតិន្តិ ។ ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ឯកំ បិណ្ឌបាតំ ភុញ្ជាមិ ភគវតោ សាសនំ មនសិ



ឱហ្ន៎ អញមុខជានឹងរស់នៅ តែត្រឹមមួយយប់មួយថ្ងៃ ( ដូច្នេះ ) អញគប្បីយកចិត្តទុកដាក់នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើនូវកិច្ច ( គឺសាសនារបស់ព្រះដ៏មានព្រះភាគ ) ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិ យ៉ាងនេះឯង ។ ភិក្ខុមួយរូបទៀត ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចំរើនមរណស្សតិបែបណា ។ បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គបានតាំងចិត្តទុកយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែត្រឹមមួយថ្ងៃ ( ដូច្នេះ ) អញគប្បីយកចិត្តទុកដាក់នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើនូវកិច្ច ( គឺសាសនារបស់ព្រះដ៏មានព្រះភាគ ) ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិយ៉ាងនេះឯង ។ ភិក្ខុមួយរូបទៀត ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចំរើនមរណស្សតិបែបណា ។ បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គបានតាំងចិត្តទុកយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែក្នុងខណៈ ដែលអញបរិភោគបិណ្ឌបាតមួយ ( ដូច្នេះ ) អញគប្បីយកចិត្តទុកដាក់នូវសាសនារបស់ព្រះដ៏មានព្រះភាគ

ករេយ្យំ ពហុ វត មេ កតំ អស្សាតិ ឯវំ ខោ អហំ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ អញ្ញតរោបិ ខោ ភិក្ខុ ភគវន្តំ ឯតទវោច អហំបិ ខោ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ យថាកថំ បន ត្វំ ភិក្ខុ ភាវេសិ មរណស្សតិន្តិ ។ ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ចត្តារោ អាលោបេ(១) សង្ខាទិត្វា អជ្ឈោហរាមិ ភគវតោ សាសនំ មនសិ ករេយ្យំ ពហុ វត មេ កតំ អស្សាតិ ឯវំបិ ខោ អហំ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ អញ្ញតរោបិ ខោ ភិក្ខុ ភគវន្តំ ឯតទវោច អហំបិ ខោ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ យថាកថំ បន ត្វំ ភិក្ខុ ភាវេសិ មរណស្សតិន្តិ ។ ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ឯកំ អាលោបំ សង្ខាទិត្វា អជ្ឈោហរាមិ ភគវតោ សាសនំ មនសិ ករេយ្យំ ពហុ វត មេ កតំ អស្សាតិ ឯវំបិ ខោ អហំ ភន្តេ ភាវេមិ មរណស្សតិន្តិ ។

១ ម. ឆ. ចត្តារោ បញ្ច អាលោបេ ។



អញគប្បីធ្វើកិច្ច (គឺសាសនារបស់ព្រះដ៏មានព្រះភាគ) ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិយ៉ាងនេះឯង ។ ភិក្ខុមួយរូបទៀត ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចំរើនមរណស្សតិដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីឯណេះ ខ្ញុំព្រះអង្គបានតាំងចិត្តទុកយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ ត្រឹមតែខណៈ ដែលអញទំពាលេបពំនូតបាយ ៤ ពំនូត (ដូច្នេះ) អញគប្បីយកចិត្តទុកដាក់នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច (គឺសាសនារបស់ព្រះដ៏មានព្រះភាគ) ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិយ៉ាងនេះឯង ។ ភិក្ខុមួយរូបទៀត ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចំរើនមរណស្សតិដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីឯណេះ ខ្ញុំព្រះអង្គបានតាំងចិត្តទុកយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ ត្រឹមតែខណៈ ដែលអញទំពាលេបពំនូតបាយមួយពំនូត (ដូច្នេះ) អញគប្បីយកចិត្តទុកដាក់នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច (គឺសាសនារបស់ព្រះដ៏មានព្រះភាគ) ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិយ៉ាងនេះឯង ។

អញ្ញតរោបិ ខោ ភិក្ខុ ភគវន្តំ ឯតទវោច អហម្បិ ខោ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ យថាកថំ បន ត្វំ ភិក្ខុ ភាវេសិ មរណស្សតិន្តិ ។ ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ អស្សសិត្វា វា បស្សសាមិ បស្សសិត្វា វា អស្សសាមិ ភគវតោ សាសនំ មនសិ ករេយ្យំ ពហុ វត មេ កតំ អស្សាតិ ឯវំ ខោ អហំ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ ឯវំ វុត្តេ ភគវា ភិក្ខូ ឯតទវោច យោយំ ភិក្ខវេ ភិក្ខុ ឯវំ មរណស្សតឹ ភាវេតិ អហោ វតាហំ រត្តិន្ទិវំ ជីវេយ្យំ ភគវតោ សាសនំ មនសិ ករេយ្យំ ពហុ វត មេ កតំ អស្សាតិ យោ ចាយំ ភិក្ខវេ ភិក្ខុ ឯវំ មរណស្សតឹ ភាវេតិ អហោ វតាហំ ទិវសំ ជីវេយ្យំ ភគវតោ សាសនំ មនសិ ករេយ្យំ ពហុ វត មេ កតំ អស្សាតិ



ភិក្ខុមួយរូបទៀត ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចំរើនមរណស្សតិដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គបានតាំងចិត្តទុកយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែក្នុងខណៈ ដែលអញដកដង្ហើមចេញ ហើយដកដង្ហើមចូលវិញ ឬដកដង្ហើមចូល ហើយដកដង្ហើមចេញវិញ (ដូច្នេះ) អញគប្បីយកចិត្តទុកដាក់នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច (ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ) ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិយ៉ាងនេះឯង ។ កាលដែលភិក្ខុនោះក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគ បានត្រាស់នឹងពួកភិក្ខុដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចំរើនមរណស្សតិយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែត្រឹមមួយយប់មួយថ្ងៃ (ដូច្នេះ) អញគប្បីយកចិត្តទុកដាក់នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច (ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ) ឲ្យបានច្រើនក្តី ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចំរើនមរណស្សតិយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែត្រឹមមួយថ្ងៃ (ដូច្នេះ) អញគប្បីយកចិត្តទុកដាក់ នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច (ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ) ឲ្យបានច្រើនក្តី

យោចាយំ ភិក្ខវេ ភិក្ខុ ឯវំ មរណស្សតឹ ភាវេតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ឯកំ បិណ្ឌបាតំ ភុញ្ជាមិ ភគវតោ សាសនំ មនសិ ករេយ្យំ ពហុ វត មេ កតំ អស្សាតិ យោចាយំ ភិក្ខវេ ភិក្ខុ ឯវំ មរណស្សតឹ ភាវេតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ចត្តារោ បញ្ច អាលោបេ សង្ខាទិត្វា អជ្ឈោហរាមិ ភគវតោ សាសនំ មនសិ ករេយ្យំ ពហុ វត មេ កតំ អស្សាតិ ឥមេ វុច្ចន្តិ ភិក្ខវេ ភិក្ខូ បមត្តា វិហរន្តិ ទន្ធំ មរណស្សតឹ ភាវេន្តិ អាសវានំ ខយាយ ។ យោចាយំ ភិក្ខវេ ភិក្ខុ ឯវំ មរណស្សតឹ ភាវេតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ឯកំ អាលោបំ សង្ខាទិត្វា អជ្ឈោហរាមិ ភគវតោ សាសនំ មនសិ ករេយ្យំ ពហុ វត មេ កតំ អស្សាតិ យោចាយំ ភិក្ខវេ ភិក្ខុ ឯវំ មរណស្សតឹ ភាវេតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ អស្សសិត្វា វា បស្សសាមិ បស្សសិត្វា វា អស្សសាមិ



ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចំរើនមរណស្សតិយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែក្នុងខណៈដែលអញបរិភោគបិណ្ឌបាតមួយ (ដូច្នេះ) អញគប្បីយកចិត្តទុកដាក់នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច (ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ) ឲ្យបានច្រើនក្តី ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចំរើនមរណស្សតិយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែក្នុងខណៈដែលអញទំពាលេបពំនូតបាយបួន ឬប្រាំពំនូត (ដូច្នេះ) អញគប្បីយកចិត្តទុកដាក់នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច (ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ) ឲ្យបានច្រើនក្តី ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុទាំងនេះ ហៅថាជាអ្នកប្រមាទ ចំរើនមរណស្សតិយ៉ាងទន់ខ្សោយ ដើម្បីឲ្យអស់អាសវៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចំរើនមរណស្សតិយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែក្នុងខណៈដែលអញទំពាលេបពំនូតបាយមួយពំនូត (ដូច្នេះ) អញគប្បីយកចិត្តទុកដាក់នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច (ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ) ឲ្យបានច្រើនក្តី ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចំរើនមរណស្សតិយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែក្នុងខណៈដែលអញដកដង្ហើមចេញ ហើយដកដង្ហើមចូលវិញ ឬ ដកដង្ហើមចូល ហើយដកដង្ហើមចេញវិញដូច្នេះ

ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតំ អស្សាតិ ឥមេ វុច្ចន្តិ ភិក្ខវេ ភិក្ខូ អប្បមត្តា វិហរន្តិ តិក្ខំ មរណស្សតឹ ភាវេន្តិ អាសវានំ ខយាយ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ អប្បមត្តា វិហរិស្សាម តិក្ខំ មរណស្សតឹ ភាវេស្សាម អាសវានំ ខយាយាតិ ។ ឯវំ ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

(៦០) ឯកំ សមយំ ភគវា នាតិកេ វិហរតិ គិញ្ជកាវសថេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ មរណស្សតិ ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា អមតោគធា អមតបរិយោសានា ។ កថំ ភាវិតា ច ភិក្ខវេ មរណស្សតិ កថំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា អមតោគធា អមតបរិយោសានា ។ ឥធ ភិក្ខវេ ភិក្ខុ ទិវសេ និក្ខន្តេ រត្តិយា បដិហិតាយ(១) ឥតិ បដិសញ្ចិក្ខតិ

១ ម. បតិតាយ ។



អាត្មាអញគប្បីយកចិត្តទុកដាក់នូវសាសនារបស់ព្រះដ៏មានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ច (ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ) ឲ្យបានច្រើនហ្ន៎ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុទាំងនេះ ទើបហៅថាជាអ្នកមិនប្រមាទ ចំរើននូវមរណស្សតិយ៉ាងក្លៀវក្លា ដើម្បីឲ្យអស់អាសវៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយ នឹងជាអ្នកមិនប្រមាទ នឹងចំរើនមរណស្សតិយ៉ាងក្លៀវក្លា ដើម្បីឲ្យអស់អាសវៈ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសិក្សាយ៉ាងនេះឯង ។

(៦០) សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទឥដ្ឋ ទៀបនាតិកគ្រាម ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងពួកភិក្ខុ ដែលនៅក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ មរណស្សតិដែលភិក្ខុចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងជាគុណជាតិ មានផលច្រើន មានអានិសង្សច្រើន ជាគុណជាតិ ឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ ចុះមរណស្សតិ ដែលភិក្ខុចំរើនហើយ ដោយប្រការដូចម្តេច ធ្វើឲ្យច្រើនហើយ ដោយប្រការដូចម្តេច ទើបជាគុណជាតិ មានផលច្រើន មានអានិសង្សច្រើន ជាគុណជាតិ ឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ កាលបើថ្ងៃអស្តង្គតហើយ រាត្រីកំពុងមក ភិក្ខុក្នុងសាសនានេះ ពិចារណាដូច្នេះថា

ពហុកា ខោ មេ បច្ចយា មរណស្ស អហិ វា មំ ឌំសេយ្យ វិច្ឆិកោ វា មំ ឌំសេយ្យ សតបទី វា មំ ឌំសេយ្យ តេន មេ អស្ស កាលកិរិយា សោ មមស្ស អន្តរាយោ ឧបក្ខលិត្វា វា បបតេយ្យំ ភត្តំ វា មេ ភុត្តំ ព្យាបជ្ជេយ្យ បិត្តំ វា មេ កុប្បេយ្យ សេម្ហំ វា មេ កុប្បេយ្យ សត្ថកា វា មេ វាតា កុប្បេយ្យុំ តេន មេ អស្ស កាលកិរិយា សោ មមស្ស អន្តរាយោតិ ។ តេន ភិក្ខវេ ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ អត្ថិ នុ ខោ មេ បាបកា អកុសលា ធម្មា អប្បហីនា យេ មេ អស្សុ រត្តឹ កាលំ ករោន្តស្ស អន្តរាយាយាតិ ។ សចេ ភិក្ខវេ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អត្ថិ មេ បាបកា អកុសលា ធម្មា អប្បហីនា យេ មេ អស្សុ រត្តឹ កាលំ ករោន្តស្ស អន្តរាយាយាតិ



បច្ច័យនៃសេចក្ដីស្លាប់របស់អាត្មា មានច្រើនណាស់ គឺពស់នឹងចឹកអាត្មា ឬខ្ទួយនឹងទិចអាត្មា ខ្អែបនឹងខាំអាត្មា អាត្មាគប្បីធ្វើមរណកាល ដោយហេតុនោះ សេចក្ដីអន្តរាយនោះ នឹងមានដល់អាត្មា អាត្មានឹងភ្លាត់ជើងដួល ឬបាយដែលអាត្មាបរិភោគហើយនឹងឲ្យទោស ប្រមាត់របស់អាត្មា នឹងកម្រើក ស្លេស្មរបស់អាត្មានឹងកម្រើក ខ្យល់មានអាការដូចកាំបិតកោររបស់អាត្មានឹងកម្រើក អាត្មាគប្បីធ្វើមរណកាល ដោយហេតុនោះ សេចក្ដីអន្តរាយនោះនឹងមានដល់អាត្មា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគួរពិចារណាដូច្នេះថា អកុសលធម៌ដ៏លាមកទាំងឡាយ ដែលអាត្មាមិនទាន់លះបង់ ជាធម៌ដែលនឹងធ្វើឲ្យអន្តរាយដល់អាត្មា កាលធ្វើមរណកាលក្នុងវេលាយប់ តើមានឬទេ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ភិក្ខុកាលពិចារណាទៅ ដឹងយ៉ាងនេះថា អកុសលធម៌ដ៏លាមកទាំងឡាយ ដែលអាត្មាមិនទាន់លះបង់ ជាធម៌ដែលនឹងធ្វើឲ្យអន្តរាយដល់អាត្មា កាលធ្វើមរណកាល ក្នុងវេលាយប់

តេន ភិក្ខវេ ភិក្ខុនា តេសំ យេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ ។ សេយ្យថាបិ ភិក្ខវេ អាទិត្តចេលោ វា អាទិត្តសីសោ វា តស្សេវ ចេលស្ស វា សីសស្ស វា និព្វាបនាយ អធិមត្តំ ឆន្ទញ្ច វាយាមញ្ច ឧស្សាហញ្ច ឧស្សោឡ្ហិញ្ច អប្បដិវានិញ្ច សតិញ្ច សម្បជញ្ញញ្ច ករេយ្យ ឯវមេវ ខោ ភិក្ខវេ តេន ភិក្ខុនា តេសំ យេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ ។ សចេ បន ភិក្ខវេ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ នត្ថិ មេ បាបកា អកុសលា ធម្មា អប្បហីនា យេ មេ អស្សុ រត្តឹ កាលំ ករោន្តស្ស អន្តរាយាយាតិ



ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីធ្វើនូវសេចក្តីពេញចិត្តផង សេចក្តីព្យាយាមផង សេចក្តីខ្មីឃ្មាតផង សេចក្តីប្រឹងប្រែងផង ការប្រព្រឹត្តមិនថយក្រោយផង សតិផង សម្បជញ្ញៈផង ឲ្យមាំមួន ដើម្បីលះបង់នូវអកុសល-ធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលត្រូវភ្លើងឆេះសំពត់ក្តី ឆេះក្បាលក្តី ធ្វើនូវសេចក្តីពេញចិត្តផង សេចក្តីព្យាយាមផង សេចក្តីខ្មីឃ្មាតផង សេចក្តីប្រឹងប្រែងផង ការប្រព្រឹត្តមិនថយក្រោយផង សតិផង សម្បជញ្ញៈផង ឲ្យមាំមួន ដើម្បីរលត់ភ្លើង (ដែលឆេះ) សំពត់ ឬក្បាលនោះចេញ សេចក្តីនេះ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីធ្វើនូវសេចក្តីពេញចិត្តផង សេចក្តីព្យាយាមផង សេចក្តីខ្មីឃ្មាតផង សេចក្តីប្រឹងប្រែងផង ការប្រព្រឹត្តមិនថយក្រោយផង សតិផង សម្បជញ្ញៈផង ឲ្យមាំមួន ដើម្បីលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ មានឧបមេយ្យយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ តែបើ ភិក្ខុកាលពិចារណាទៅដឹងយ៉ាងនេះវិញថា អកុសល-ធម៌ដ៏លាមកទាំងឡាយ ដែលអញមិនទាន់លះបង់ ជាធម៌ដែលនឹងនាំឲ្យអន្តរាយដល់អញ កាលធ្វើមរណកាល ក្នុងវេលារាត្រីមិនមានទេ

តេន ភិក្ខវេ ភិក្ខុនា តេនេវ ចិត្តេនបោដ្ឋេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ ឥធ បន ភិក្ខវេ ភិក្ខុ រត្តិយា និក្ខន្តាយ ទិវសេ បដិហិតេ ឥតិ បដិសញ្ចិក្ខតិ ពហុកា ខោ មេ បច្ចយា មរណស្ស អហិ វា មំ ឌំសេយ្យ វិច្ឆិកោ វា មំ ឌំសេយ្យ សតបទី វា មំ ឌំសេយ្យ តេន មេ អស្ស កាលកិរិយា សោ មមស្ស អន្តរាយោ ឧបក្ខលិត្វា វា បបតេយ្យំ ភត្តំ វា មេ ភុត្តំ ព្យាបជ្ជេយ្យ បិត្តំ វា មេ កុប្បេយ្យ សេម្ហំ វា មេ កុប្បេយ្យ សត្ថកា វា មេ វាតា កុប្បេយ្យុំ តេន មេ អស្ស កាលកិរិយា សោ មមស្ស អន្តរាយោតិ ។ តេន ភិក្ខវេ ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ អត្ថិ នុ ខោ មេ បាបកា អកុសលា ធម្មា អប្បហីនា យេ មេ អស្សុ ទិវា(១) កាលំ ករោន្តស្ស អន្តរាយាយាតិ ។

១ ម. រត្តិំ ។



ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីជាអ្នកសិក្សារឿយ ៗ ក្នុងកុសលធម៌ទាំងឡាយ ទាំងវេលាថ្ងៃ ទាំងវេលាយប់ ដោយចិត្តនឹងចិត្តប្រាថ្នានោះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលបើវេលាយប់កន្លងផុតទៅ វេលាថ្ងៃគឺដើមកដល់ ភិក្ខុក្នុងសាសនានេះ រមែងពិចារណាដូច្នេះថា បច្ច័យនៃសេចក្តីស្លាប់របស់អញ មានច្រើនណាស់ ពស់នឹងចឹកអញ ឬ ខ្ទួយនឹងទិចអញ ក្អែបនឹងខាំអញ អញគប្បីធ្វើមរណកាល ដោយហេតុនោះ សេចក្តីអន្តរាយនោះនឹងមានដល់អញ អញនឹងភ្លាត់ជើង ឬ បាយដែលអញបរិភោគហើយនឹងឲ្យទោស ប្រមាត់របស់អញនឹងកម្រើក ស្លេស្មរបស់អញនឹងកម្រើក ខ្យល់មានអាការដូចកាំបិតកាត់របស់អញនឹងកម្រើក អញគប្បីធ្វើមរណកាល ដោយហេតុនោះ សេចក្តីអន្តរាយនោះ នឹងមានដល់អញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីពិចារណាដូច្នេះថា អកុសលធម៌ដ៏លាមកទាំងឡាយ ដែលអញមិនទាន់លះបង់ ជាធម៌ដែលនឹងធ្វើអន្តរាយដល់អញ កាលធ្វើមរណកាល ក្នុងវេលាថ្ងៃ តើមានឬទេ

សចេ បន ភិក្ខវេ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អត្ថិ មេ បាបកា អកុសលា ធម្មា អប្បហីនា យេ មេ អស្សុ ធិភ កាលំ ករោន្តស្ស អន្តរាយាយាតិ តេន ភិក្ខវេ ភិក្ខុនា តេសំ យេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ ។ សេយ្យថាបិ ភិក្ខវេ អាទិត្តចេលោ វា អាទិត្តសីសោ វា តស្សេវ ចេលស្ស វា សីសស្ស វា និព្វាបនាយ អធិមត្តំ ឆន្ទញ្ច វាយាមញ្ច ឧស្សាហញ្ច ឧស្សោឡ្ហិញ្ច អប្បដិវានិញ្ច សតិញ្ច សម្បជញ្ញញ្ច ករេយ្យ ឯវមេវ ខោ ភិក្ខវេ តេន ភិក្ខុនា តេសំ យេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ ។



ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ភិក្ខុកាលពិចារណា ទៅដឹងយ៉ាងនេះថា អកុសលធម៌ដ៏លាមកទាំងឡាយ ដែលអញមិនទាន់លះបង់ ជាធម៌ដែលនឹងធ្វើអន្តរាយដល់អញ កាលធ្វើមរណកាល ក្នុងវេលាថ្ងៃខាង ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង សេចក្តីព្យាយាមផង សេចក្តីខ្មីឃ្មាតផង សេចក្តីប្រឹងប្រែងផង ការប្រព្រឹត្តមិនថយក្រោយផង សតិផង សម្បជញ្ញៈផង ឲ្យមាំមួន ដើម្បីលះបង់អកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលត្រូវភ្លើងឆេះសំពត់ក្តី ឆេះក្បាលក្តី គប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង សេចក្តីព្យាយាមផង សេចក្តីខ្មីឃ្មាតផង សេចក្តីប្រឹងប្រែងផង ការប្រព្រឹត្តមិនថយក្រោយផង សតិផង សម្បជញ្ញៈផង ឲ្យមាំមួន ដើម្បីលត់ភ្លើងដែលឆេះសំពត់ ឬក្បាលនោះចេញ សេចក្តីនេះ មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង សេចក្តីព្យាយាមផង សេចក្តីខ្មីឃ្មាតផង សេចក្តីប្រឹងប្រែងផង ការប្រព្រឹត្តមិនថយក្រោយផង សតិផង សម្បជញ្ញៈផង ឲ្យមាំមួន ដើម្បីលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ មានឧបមេយ្យយ៉ាងនោះឯង ។

សចេ បន ភិក្ខវេ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ នត្ថិ មេ បាបកា អកុសលា ធម្មា អប្បហីនា យេ មេ អស្សុ ទិវា កាលំ ករោន្តស្ស អន្តរាយាយាតិ តេន ភិក្ខវេ ភិក្ខុនា តេនេវ បីតិបាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ ឯវំ ភាវិតា ខោ ភិក្ខវេ មរណស្សតិ ឯវំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា អមតោគធា អមតបរិយោសានាតិ ។

សារណីយវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

ទ្វេ សារណីយា មេត្តំ
ភទ្ទកំ អនុតប្បិយំ
នកុលកុសលា មច្ឆិ
ទ្វេ ច ហោន្តិ មរណស្សតិកា ទសាតិ ។



ម្នាលភិក្ខុទាំងឡាយ តែបើ ភិក្ខុកាលពិចារណា នៅដឹងយ៉ាងនេះវិញថា អកុសលធម៌ដ៏លាមកទាំងឡាយ ដែលអាត្មាអញមិនទាន់លះបង់ ជាធម៌ដែលនឹងនាំឲ្យមានអន្តរាយដល់អាត្មាអញ កាលធ្វើមរណកាល ក្នុងវេលាថ្ងៃ មិនមានទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីជាអ្នកសិក្សារឿយៗ ក្នុងកុសលធម៌ទាំងឡាយ ទាំងវេលាថ្ងៃ ទាំងវេលាយប់ ដោយបីតិនិងបាមោជ្ជៈនោះឯង ។ ម្នាលភិក្ខុទាំងឡាយ មរណស្សតិដែលបុគ្គលចំរើនយ៉ាងនេះ ធ្វើឲ្យច្រើនយ៉ាងនេះ រមែងជាគុណជាតិ មានផលច្រើន មានអានិសង្សច្រើន ជាគុណជាតិ ឈមទៅកាន់ព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ។

ចប់ សារណីយវគ្គ ទី២ ។

## ឧទ្ទាននៃសារណីយវគ្គនោះគឺ

និយាយអំពីសារណីយធម៌ពីរលើក អំពីមេត្តា ១ អំពីកាលកិរិយាល្អ ១ អំពីកាលកិរិយាក្តៅក្រហាយ ១ អំពីរឿងនកុលបិតា ១ អំពីការមិនពិចារណានូវកុសលធម៌ ១ អំពីអ្នកសម្លាប់ត្រី ១ អំពីមរណស្សតិពីរលើក ត្រូវជា ១០ រឿង ។

[៤១] ឯកំ សមយំ ភគវា សក្កេសុ វិហរតិ សាមគាមកេ បោក្ខរណិយាយំ ។ អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ បោក្ខរណិយំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ ឯតទវោច តយោមេ ភន្តេ ធម្មា ភិក្ខុនោ បរិហានាយ សំវត្តន្តិ ។ កតមេ តយោ ។ កម្មារាមតា ភស្សារាមតា និទ្ទារាមតា ។ ឥមេ ខោ ភន្តេ តយោ ធម្មា ភិក្ខុនោ បរិហានាយ សំវត្តន្តីតិ ។ ឥទមវោច សា ទេវតា ។ សមនុញ្ញោ សត្ថា អហោសិ ។ អថខោ សា ទេវតា សមនុញ្ញោ មេ សត្ថាតិ ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយិ ។ អថខោ ភគវា តស្សា រត្តិយា អច្ចយេន ភិក្ខូ អាមន្តេសិ



[៤០] សម័យមួយ ព្រះដ៏មានព្រះភាគ ប្រថាប់នៅក្នុងវិហារឈ្មោះបោក្ខរណិយា ជិតសាមគ្រាម ក្នុងដែនសក្កៈ ។ គ្រានោះ ទេវតាមួយអង្គ មានរស្មីដ៏រុងរឿង កាលរាត្រីបឋមយាមកន្លងហើយ បណ្តាលវិហារឈ្មោះបោក្ខរណិយាទាំងមូលឲ្យភ្លឺច្រាល ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឈរនៅក្នុងទីដ៏សមគួរ ។ លុះទេវតានោះ ឈរនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៣ យ៉ាងនេះ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុ ។ ធម៌ ៣ យ៉ាង តើដូចម្តេច ។ គឺសេចក្តីត្រេកអរក្នុងការងារ ១ សេចក្តីត្រេកអរក្នុងការពោល ១ សេចក្តីត្រេកអរក្នុងការដេកលក់ ១ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៣ យ៉ាងនេះឯង តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុ ។ លុះទេវតានោះ ក្រាបបង្គំទូលដូច្នេះហើយ ។ ព្រះសាស្តាក៏ទ្រង់ពេញព្រះហឫទ័យ ។ ទើបទេវតានោះ ដឹងថា ព្រះសាស្តារបស់អញ ទ្រង់ពេញព្រះហឫទ័យហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ បាត់ទៅក្នុងទីនោះឯង ។ លុះកន្លងរាត្រីនោះទៅហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា

ឥមំ ភិក្ខវេ រត្តឹ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ឯកមន្តំ ឋិតា ខោ ភិក្ខវេ សា ទេវតា មំ ឯតទវោច តយោមេ ភន្តេ ធម្មា ភិក្ខុនោ បរិហានាយ សំវត្តន្តិ ។ កតមេ តយោ ។ កម្មារាមតា ភស្សារាមតា និទ្ទារាមតា ។ ឥមេ ខោ ភន្តេ តយោ ធម្មា ភិក្ខុនោ បរិហានាយ សំវត្តន្តីតិ ។ ឥទមវោច ភិក្ខវេ សា ទេវតា ឥទំ វត្វា មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយិ ។ តេសំ តេ ភិក្ខវេ អលាភា តេសំ ទុល្លទ្ធំ យេ តេ ទេវតាបិ ជានន្តិ កុសលេហិ ធម្មេហិ បរិហាយមានេ(*) ។ អបរេបិ ភិក្ខវេ តយោ បរិហានិយេ ធម្មេ ទេសេស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។

(*) ម. បរិហាយមានំ ។



ម្នាលភិក្ខុទាំងឡាយ កាលរាត្រីបឋមយាមយប់មិញ កន្លងទៅហើយទេវតាមួយអង្គ មានរស្មីដ៏រុងរឿង បណ្ដាលវិហារឈ្មោះ ជេតពនទាំងមូលឲ្យភ្លឺច្រាល ហើយចូលមកកាន់សំណាក់តថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត ហើយឈរនៅក្នុងទីដ៏សមគួរ ម្នាលភិក្ខុទាំងឡាយ លុះទេវតានោះ ឈរនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៣ យ៉ាងនេះ តែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យដល់ភិក្ខុ ។ ៣ យ៉ាង តើដូចម្ដេច ។ គឺសេចក្ដីត្រេកអរក្នុងការងារ ១ សេចក្ដីត្រេកអរក្នុងការនិយាយ ១ សេចក្ដីត្រេកអរក្នុងការដេកលក់ ១ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៣ យ៉ាងនេះឯង តែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យដល់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ទេវតានោះបាននិយាយយ៉ាងនេះ លុះនិយាយយ៉ាងនេះហើយ ក៏ថ្វាយបង្គំតថាគត ធ្វើប្រទក្សិណហើយបាត់ទៅក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតា ដឹងលោកទាំងឡាយណាដែលកើតក្ដីសាបសូន្យចាកកុសលធម៌ទាំងឡាយ លោកទាំងនោះឈ្មោះថាឥតលាភ លោកទាំងនោះឈ្មោះថាបានដោយក្រក់ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវបរិហានិយធម៌ (ធម៌ជាគ្រឿងសាបសូន្យ) ៣ ដទៃទៀត អ្នកទាំងឡាយចូរស្ដាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យស្រួលបួល តថាគតនឹងសំដែងប្រាប់ ។

វំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ។ កតមេ ច ភិក្ខវេ តយោ បរិហានិយា ធម្មា ។ សង្គណិការាមតា ទោវចស្សតា បាបមិត្តតា ។ ឥមេ ខោ ភិក្ខវេ តយោ បរិហានិយា ធម្មា ។ យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ បរិហាយឹសុ កុសលេហិ ធម្មេហិ សព្វេ តេ ឥមេហេវ ឆហិ ធម្មេហិ បរិហាយឹសុ កុសលេហិ ធម្មេហិ ។ យេ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ បរិហាយិស្សន្តិ កុសលេហិ ធម្មេហិ សព្វេ តេ ឥមេហេវ ឆហិ ធម្មេហិ បរិហាយិស្សន្តិ កុសលេហិ ធម្មេហិ ។ យេ ហិ កេចិ ភិក្ខវេ ឯតរហិ បរិហាយន្តិ កុសលេហិ ធម្មេហិ សព្វេ តេ ឥមេហេវ ឆហិ ធម្មេហិ បរិហាយន្តិ កុសលេហិ ធម្មេហីតិ ។

(៦២) តយោមេ ភិក្ខវេ អបរិហានិយេ ធម្មេ ទេសេស្សាមិ តំ សុណាថ ។ បេ ។ កតមេ ច ភិក្ខវេ ឆ អបរិហានិយា ធម្មា ។



ភិក្ខុទាំងនោះ បានទទួលស្ដាប់ព្រះតម្រាស់នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគ បានត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ បរិហានិយធម៌ ៣ យ៉ាង តើដូចម្ដេច ។ គឺសេចក្ដីត្រេកអរនឹងការរីករាយដោយគ្នីគ្នា ១ ភាពជាអ្នកដែលគេប្រដៅបានដោយក្រ ១ ភាពជាអ្នកមានមិត្រអាក្រក់ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងបរិហានិយធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ពួកបុគ្គលណាមួយ សាបសូន្យហើយចាកកុសលធម៌ទាំងឡាយ ក្នុងអតីតកាល បុគ្គលទាំងអស់នោះ សាបសូន្យហើយចាកកុសលធម៌ទាំង ៦ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកបុគ្គលណាមួយ នឹងសាបសូន្យចាកកុសលធម៌ទាំងឡាយ ក្នុងអនាគតកាល បុគ្គលទាំងអស់នោះ គង់នឹងសាបសូន្យចាកកុសលធម៌ទាំង ៦ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកបុគ្គលណាមួយ កំពុងសាបសូន្យចាកកុសលធម៌ទាំងឡាយ ក្នុងកាលឥឡូវនេះ បុគ្គលទាំងអស់នោះ គង់សាបសូន្យចាកកុសលធម៌ទាំង ៦ នេះឯង ។

(៦៦) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែង អបរិហានិយធម៌ (ធម៌ដែលមិនសាបសូន្យ) ៦ យ៉ាងនេះ អ្នកទាំងឡាយ ចូរស្ដាប់ធម៌នោះចុះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អបរិហានិយធម៌ ៦ យ៉ាង តើដូចម្ដេច ។

ន កម្មារាមតា ន ភស្សារាមតា ន និទ្ទារាមតា ន សង្គណិការាមតា សោវចស្សតា កល្យាណមិត្តតា ។ ឥមេ ខោ ភិក្ខវេ ឆ អបរិហានិយា ធម្មា ។ យេ ហិ កេចិ ភិក្ខវេ អតីតមទ្ធានំ ន បរិហាយឹសុ កុសលេហិ ធម្មេហិ សព្វេ តេ ឥមេហេវ ឆហិ ធម្មេហិ ន បរិហាយឹសុ កុសលេហិ ធម្មេហិ ។ យេ ហិ កេចិ ភិក្ខវេ អនាគតមទ្ធានំ ន បរិហាយិស្សន្តិ កុសលេហិ ធម្មេហិ សព្វេ តេ ឥមេហេវ ឆហិ ធម្មេហិ ន បរិហាយិស្សន្តិ កុសលេហិ ធម្មេហិ ។ យេ ហិ កេចិ ភិក្ខវេ ឯតរហិ ន បរិហាយន្តិ កុសលេហិ ធម្មេហិ សព្វេ តេ ឥមេហេវ ឆហិ ធម្មេហិ ន បរិហាយន្តិ កុសលេហិ ធម្មេហីតិ ។

(៦៣) ភយន្តិ ភិក្ខវេ កាមានមេតំ អធិវចនំ ទុក្ខន្តិ ភិក្ខវេ កាមានមេតំ អធិវចនំ រោគោតិ ភិក្ខវេ កាមានមេតំ អធិវចនំ គណ្ឌោតិ ភិក្ខវេ កាមានមេតំ អធិវចនំ



គឺសេចក្តីមិនត្រេកអរក្នុងការងារ ១ សេចក្តីមិនត្រេកអរក្នុងការចរចា ១ សេចក្តីមិនត្រេកអរក្នុងការដេកលក់ ១ សេចក្តីមិនត្រេកអរក្នុងការរឹករវដោយគ្នា ១ ភាពជាអ្នកដែលគេប្រដៅងាយ ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងអបរិហានិយធម៌ទាំង ៦ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ពួកបុគ្គលណាមួយ មិនសាបសូន្យហើយចាកកុសលធម៌ទាំងឡាយ ក្នុងអតីតកាល បុគ្គលទាំងអស់នោះ មិនសាបសូន្យហើយចាកធម៌ទាំង ៦ នេះឯង ដែលជាកុសលធម៌ ។ ម្នាលភិក្ខុទាំងឡាយ ពួកបុគ្គលណាមួយ នឹងមិនសាបសូន្យចាកកុសលធម៌ទាំងឡាយ ក្នុងអនាគតកាល បុគ្គលទាំងអស់នោះនឹងមិនសាបសូន្យចាកធម៌ទាំង ៦ នេះឯង ដែលជាកុសលធម៌ ។ ម្នាលភិក្ខុទាំងឡាយ ពួកបុគ្គលណាមួយ មិនសាបសូន្យចាកកុសលធម៌ទាំងឡាយ ក្នុងកាលឥឡូវនេះ បុគ្គលទាំងអស់នោះ មិនសាបសូន្យចាកធម៌ទាំង ៦ នេះឯង ដែលជាកុសលធម៌ ។

(៦៣) ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា ភ័យនុ៎ះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ទុក្ខនុ៎ះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា រោគនុ៎ះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា គណ្ឌៈ (ពក) នុ៎ះជាឈ្មោះនៃកាមទាំងឡាយ

សង្គោតិ ភិក្ខវេ កាមានមេតំ អធិវចនំ បង្កោតិ ភិក្ខវេ កាមានមេតំ អធិវចនំ ។ កស្មា ច ភិក្ខវេ ភយន្តិ កាមានមេតំ អធិវចនំ កាមរាគរត្តាយំ ភិក្ខវេ ឆន្ទរាគវិនិពទ្ធោ ទិដ្ឋធម្មិកាបិ ភយា ន បរិមុច្ចតិ សម្បរាយិកាបិ ភយា ន បរិមុច្ចតិ តស្មា ភយន្តិ កាមានមេតំ អធិវចនំ ។ កស្មា ច ភិក្ខវេ ទុក្ខន្តិ... រោគោតិ... គណ្ឌោតិ... សល្លន្តិ... សង្គោតិ... បង្កោតិ កាមានមេតំ អធិវចនំ កាមរាគរត្តាយំ ភិក្ខវេ ឆន្ទរាគវិនិពទ្ធោ ទិដ្ឋធម្មិកាបិ បង្កា ន បរិមុច្ចតិ សម្បរាយិកាបិ បង្កា ន បរិមុច្ចតិ តស្មា បង្កោតិ កាមានមេតំ អធិវចនន្តិ ។

ភយំ ទុក្ខញ្ច រោគោ ច សង្គោ បង្កោ ច ឧភយំ
ឯតេ កាមា បវុច្ចន្តិ យត្ថ សត្តោ បុថុជ្ជនោ ។



ម្នាលភិក្ខុទាំងឡាយ ពាក្យថា សង្គៈ (ការជាប់ចំពាក់ចិត្ត) នុ៎ះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បង្កៈ (ភក់) នុ៎ះ ជាឈ្មោះនៃកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យនុ៎ះ ជាឈ្មោះនៃកាមទាំងឡាយ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ (ព្រោះថា) បុគ្គលដែលត្រេកអរដោយកាមរាគនេះ ហើយជាប់ចំពាក់ដោយឆន្ទរាគ មិនរួចអំពីភ័យក្នុងបច្ចុប្បន្នផង មិនរួចអំពីភ័យក្នុងបរលោកផង ព្រោះហេតុនោះបានជា ពាក្យថា ភ័យនុ៎ះ ជាឈ្មោះនៃកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ទុក្ខ... រោគ... គណ្ឌៈ... សល្លៈ... បង្កៈ នុ៎ះ ជាឈ្មោះនៃកាមទាំងឡាយ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ (ព្រោះថា) បុគ្គលដែលត្រេកអរដោយកាមនេះ ហើយជាប់ចំពាក់ដោយឆន្ទរាគ មិនរួចអំពីបង្កៈក្នុងបច្ចុប្បន្នផង មិនរួចអំពីបង្កៈក្នុងបរលោកផង ហេតុនោះបានជា ពាក្យថា បង្កៈនុ៎ះ ទើបជាឈ្មោះនៃកាមទាំងឡាយ ។

កាមទាំងឡាយ ដែលជាទីជាប់នៅរបស់បុថុជ្ជននុ៎ះ លោកតែងហៅថា
ភ័យផង ទុក្ខផង រោគផង និងធម្មជាតទាំង២ គឺសង្គៈផង បង្កៈផង ។

ឧបាទានេ ភយំ ទិស្វា   ជាតិមរណសម្ភវេ
អនុបាទា វិមុច្ចន្តិ   ជាតិមរណសង្ខយេ ។
តេ ខេមប្បត្តា សុខិតា   ទិដ្ឋធម្មាភិនិព្វុតា
សព្វេ វេរភយាតីតា   សព្វទុក្ខំ ឧបច្ចគុន្តិ ។

(២៤) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ហិមវន្តំ បព្វតរាជំ បទាលេយ្យ កោ បន វាទោ ឆវាយ អវិជ្ជាយ ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ សមាធិស្ស សមាបត្តិកុសលោ ហោតិ សមាធិស្ស ឋិតិកុសលោ ហោតិ សមាធិស្ស វុដ្ឋានកុសលោ ហោតិ សមាធិស្ស កល្លតាកុសលោ ហោតិ សមាធិស្ស គោចរកុសលោ ហោតិ សមាធិស្ស អភិនីហារកុសលោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ហិមវន្តំ បព្វតរាជំ បទាលេយ្យ កោ បន វាទោ ឆវាយ អវិជ្ជាយាតិ ។



អរិយសាវកទាំងឡាយ ឃើញភ័យ ក្នុងឧបាទានដែលជាហេតុឲ្យកើតជាតិនិងមរណៈ លុះមិនប្រកាន់ហើយ រមែងរួចស្រឡះ ព្រោះការអស់ជាតិនិងមរណៈ ។ អរិយសាវកទាំងនោះ ដល់នូវសេចក្តីក្សេមក្សាន្ត មានសេចក្តីសុខ រលត់កិលេសក្នុងអត្តភាពនេះ ប្រព្រឹត្តកន្លងនូវពៀរនិងភ័យទាំងអស់ ហើយលះបង់នូវទុក្ខទាំងអស់បាន ។

(២៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង គប្បីទំលាយភ្នំហិមពាន្តជាស្តេចភ្នំបាន មិនបាច់និយាយ (ដល់ការទំលាយ) អវិជ្ជាដែលលាមកទេ ។ ធម៌ ៦ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឈ្លាសក្នុងការចូលសមាធិ ១ ឈ្លាសក្នុងការធ្វើសមាធិឲ្យតាំងនៅតាមកំណត់ ១ ឈ្លាសក្នុងការចេញចាកសមាធិ ១ ឈ្លាសក្នុងការថែងចំណែកសមាធិ ១ ឈ្លាសក្នុងគោចររបស់សមាធិ ១ ឈ្លាសក្នុងការសោងសង្ស៊ូវសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៦ នេះឯង គប្បីទំលាយភ្នំហិមពាន្តជាស្តេចភ្នំបាន មិនបាច់និយាយដល់អវិជ្ជាដែលលាមកទេ ។

[២៥] ឆយិមានិ ភិក្ខវេ អនុស្សតិដ្ឋានានិ ។ កតមានិ ឆ ។ ឥធ ភិក្ខវេ អរិយសាវកោ តថាគតំ អនុស្សរតិ ឥតិបិ សោ ភគវា ។បេ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ យស្មឹ ភិក្ខវេ សមយេ អរិយសាវកោ តថាគតំ អនុស្សរតិ នេវស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ និក្ខន្តំ មុត្តំ វុដ្ឋិតំ គេធម្ហា គេធោតិ ខោ ភិក្ខវេ បញ្ចន្នេតំ(១) កាមគុណានំ អធិវចនំ ។ ឥទម្បិ ខោ ភិក្ខវេ អារម្មណំ ករិត្វា ឯវមិធេកច្ចេ សត្តា វិសុជ្ឈន្តិ ។ បុន ចបរំ ភិក្ខវេ អរិយសាវកោ ធម្មំ អនុស្សរតិ ស្វាក្ខាតោ ភគវតា ធម្មោ ។បេ។ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ យស្មឹ ភិក្ខវេ សមយេ អរិយសាវកោ ធម្មំ អនុស្សរតិ

(១) បញ្ចន្នេតំ យុត្តតរំ ។



(២៥) ម្នាលភិក្ខុទាំងឡាយ អនុស្សតិដ្ឋាន (ហេតុជាទីតាំងនៃសេចក្តីរឭក) នេះមាន ៦ យ៉ាង ។ ៦ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ រឭកនូវព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ដោយប្រការដូច្នេះ ។បេ។ ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ត្រាស់ប្រាប់នូវសច្ចៈទាំង ៤ ដែលនឹងត្រូវចែក កាន់តែថ្មីទៀត ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវក កំពុងរឭកព្រះតថាគត សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញស្រឡះ អំពីគេធៈបាន ម្នាលភិក្ខុទាំងឡាយ ពាក្យថា គេធៈ នេះជាឈ្មោះនៃកាមគុណទាំង ៥ ។ ម្នាលភិក្ខុទាំងឡាយ សត្វពួកខ្លះ ក្នុងសាសនានេះ តែងបរិសុទ្ធបានយ៉ាងនេះ ព្រោះធ្វើនូវពុទ្ធានុស្សតិកម្មដ្ឋាននេះ ឲ្យជាអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវករឭកនូវព្រះធម៌ថា ព្រះធម៌ដែលព្រះដ៏មានព្រះភាគសំដែងល្អហើយ ។បេ។ ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយគប្បីដឹងច្បាស់ចំពោះខ្លួន ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវក កំពុងរឭកនូវព្រះធម៌

នេវស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ និក្ខន្តំ មុត្តំ វុដ្ឋិតំ គេធម្ហា គេធោតិ ខោ ភិក្ខវេ បញ្ចន្នេតំ កាមគុណានំ អធិវចនំ ។ ឥទម្បិ ខោ ភិក្ខវេ អារម្មណំ ករិត្វា ឯវមិធេកច្ចេ សត្តា វិសុជ្ឈន្តិ ។ បុន ចបរំ ភិក្ខវេ អរិយសាវកោ សង្ឃំ អនុស្សរតិ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។បេ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ យស្មឹ ភិក្ខវេ សមយេ អរិយសាវកោ សង្ឃំ អនុស្សរតិ នេវស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ និក្ខន្តំ មុត្តំ វុដ្ឋិតំ គេធម្ហា គេធោតិ ខោ ភិក្ខវេ បញ្ចន្នេតំ កាមគុណានំ អធិវចនំ ។ ឥទម្បិ ខោ ភិក្ខវេ អារម្មណំ ករិត្វា ឯវមិធេកច្ចេ សត្តា វិសុជ្ឈន្តិ ។



សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតអំពីគេធៈបាន ម្នាលភិក្ខុទាំងឡាយ ពាក្យថាគេធៈនេះជាឈ្មោះនៃកាមគុណទាំង ៥ ។ ម្នាលភិក្ខុទាំងឡាយ សត្វពួកខ្លះក្នុងសាសនានេះ តែងបរិសុទ្ធបានយ៉ាងនេះ ព្រោះធ្វើនូវធម្មានុស្សតិកម្មដ្ឋាននេះឲ្យជាអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវករឭកនូវព្រះសង្ឃថា ព្រះសង្ឃជាសាវករបស់ព្រះដ៏មានព្រះភាគ ប្រតិបត្តិដោយប្រពៃ ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវកកំពុងរឭកព្រះសង្ឃ សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតអំពីគេធៈបាន ម្នាលភិក្ខុទាំងឡាយ ពាក្យថា គេធៈនេះ ជាឈ្មោះនៃកាមគុណ៥ ។ ម្នាលភិក្ខុទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ តែងបរិសុទ្ធបានយ៉ាងនេះ ព្រោះធ្វើនូវសង្ឃានុស្សតិកម្មដ្ឋាននេះ ឲ្យជាអារម្មណ៍ ។

បុន ចបរំ ភិក្ខវេ អរិយសាវកោ អត្តនោ សីលានិ អនុស្សរតិ អខណ្ឌានិ ។បេ។ សមាធិសំវត្តនិកានិ ។ យស្មឹ ភិក្ខវេ សមយេ អរិយសាវកោ សីលំ អនុស្សរតិ នេវស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ និក្ខន្តំ មុត្តំ វុដ្ឋិតំ គេធម្ហា គេធោតិ ខោ ភិក្ខវេ បញ្ចន្នេតំ កាមគុណានំ អធិវចនំ ។ ឥទម្បិ ខោ ភិក្ខវេ អារម្មណំ ករិត្វា ឯវមិធេកច្ចេ សត្តា វិសុជ្ឈន្តិ ។ បុន ចបរំ ភិក្ខវេ អរិយសាវកោ អត្តនោ ចាគំ អនុស្សរតិ លាភា វត មេ សុលទ្ធំ វត មេ យោហំ ។បេ។ យាចយោគោ ទានសំវិភាគរតោតិ ។ យស្មឹ ភិក្ខវេ សមយេ អរិយសាវកោ ចាគំ អនុស្សរតិ នេវស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ



ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវករឭកនូវសីលទាំងឡាយ របស់ខ្លួនជាសីលមិនដាច់ ។បេ។ ប្រព្រឹត្តទៅដើម្បីសមាធិ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវក កំពុងរឭកនូវសីល សម័យនោះ អរិយសាវក មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះអរិយសាវក នោះ មានចិត្តប្រព្រឹត្តទៅត្រង់តែម្យ៉ាងគឺ ជាចិត្តចេញរួចឃ្លាតចាកគេធៈ ផុត ម្នាលភិក្ខុទាំងឡាយ ពាក្យថា គេធៈនេះ ជាឈ្មោះនៃកាមគុណ៥ ។ ម្នាលភិក្ខុទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ តែងបរិសុទ្ធបានយ៉ាងនេះ ព្រោះធ្វើសីលានុស្សតិកម្មដ្ឋាននេះ ឲ្យជាអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវក រឭកនូវចាគៈរបស់ខ្លួនថា ជាលាភរបស់អញ ហើយ អញឈ្មោះថាបានស្រួលហើយ ព្រោះអាត្មាអញ ។បេ។ គួរគេសូមបាន ត្រេកអរក្នុងការឲ្យ និងការចែករំលែក ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវក កំពុងរឭកនូវចាគៈ សម័យនោះ អរិយសាវក នោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់

ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ និក្ខន្តំ មុត្តំ វុដ្ឋិតំ គេធម្ហា គេធោតិ ខោ ភិក្ខវេ បញ្ចន្នេតំ កាមគុណានំ អធិវចនំ ។ ឥទម្បិ ខោ ភិក្ខវេ អារម្មណំ ករិត្វា ឯវមិធេកច្ចេ សត្តា វិសុជ្ឈន្តិ ។ បុន ចបរំ ភិក្ខវេ អរិយសាវកោ ទេវតា អនុស្សរតិ សន្តិ ទេវា ចាតុម្មហារាជិកា សន្តិ ទេវា តាវតឹសា សន្តិ ទេវា យាមា សន្តិ ទេវា តុសិតា សន្តិ ទេវា និម្មានរតិនោ សន្តិ ទេវា បរនិម្មិតវសវត្តិនោ សន្តិ ទេវា ព្រហ្មកាយិកា សន្តិ ទេវា តតុត្តរិ យថារូបាយ សទ្ធាយ សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថ ឧបបន្នា មយ្ហម្បិ តថារូបា សទ្ធា សំវិជ្ជតិ យថារូបេន សីលេន សុតេន ចាគេន បញ្ញាយ សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថ ឧបបន្នា មយ្ហម្បិ តថារូបា បញ្ញា សំវិជ្ជតីតិ ។ យស្មឹ ភិក្ខវេ សមយេ អរិយសាវកោ អត្តនោ ច តាសញ្ច ទេវតានំ សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរតិ នេវស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ



*មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតអំពីគេធៈបាន ម្នាលភិក្ខុទាំងឡាយ ពាក្យថា គេធៈនេះ ជាឈ្មោះនៃកាមគុណ ៥ ។ ម្នាលភិក្ខុទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ តែងបរិសុទ្ធបាន យ៉ាងនេះ ព្រោះធ្វើនូវចាគានុស្សតិកម្មដ្ឋាន ឲ្យជាអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវក រឮកនូវពួកទេវតាថា មានពួកទេវតាជាន់ចាតុម្មហារាជិកៈ ទេវតាជាន់តាវត្តិង្ស ទេវតាជាន់យាមៈ ទេវតាជាន់តុសិតៈ ទេវតាជាន់និម្មានរតី ទេវតាជាន់បរនិម្មិតវសវត្តី មានទេវតាជាពួករបស់ព្រហ្ម មានទេវតាជាន់ខ្ពស់ជាងនោះទៀត ទេវតាទាំងនោះ ដែលប្រកបដោយសទ្ធាយ៉ាងណា ច្យុតអំពីទីនេះហើយ ទៅកើតក្នុងទីនោះ យើងសោតក៏មានសទ្ធាដូច្នោះដែរ ទេវតាទាំងនោះ ប្រកបដោយសីលៈ សុតៈ ចាគៈ បញ្ញា យ៉ាងណា ច្យុតអំពីទីនេះហើយ ទៅកើតក្នុងទីនោះ យើងសោតក៏មានបញ្ញាដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវក កំពុងរឮកនូវសទ្ធា សីលៈ សុតៈ ចាគៈនិងបញ្ញារបស់ខ្លួនផង របស់ទេវតាទាំងនោះផង សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈ គ្របសង្កត់*

ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ និក្ខន្តំ មុត្តំ វុដ្ឋិតំ គេធម្ហា គេធោតិ ខោ ភិក្ខវេ បញ្ចន្នេតំ កាមគុណានំ អធិវចនំ ។ ឥទម្បិ ខោ ភិក្ខវេ អារម្មណំ ករិត្វា ឯវមិធេកច្ចេ សត្តា វិសុជ្ឈន្តិ ។ ឥមានិ ខោ ភិក្ខវេ ឆ អនុស្សតិដ្ឋានានីតិ ។

[៦៦] តត្រ ខោ អាយស្មា មហាកច្ចានោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវេតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ មហាកច្ចានស្ស បច្ចស្សោសុំ ។ អាយស្មា មហាកច្ចានោ ឯតទវោច អច្ឆរិយំ អាវុសោ អព្ភុតំ អាវុសោ យាវញ្ចិទំ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សម្ពាធេ ឱកាសាធិគមោ អនុពុទ្ធោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ ឆ អនុស្សតិដ្ឋានានិ ។



មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតចាកគេធៈបាន ម្នាលភិក្ខុទាំងឡាយ ពាក្យថាគេធៈនេះ ជាឈ្មោះរបស់កាមគុណ ៥ ។ ម្នាលភិក្ខុទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ តែងបរិសុទ្ធបានយ៉ាងនេះ ព្រោះធ្វើនូវទេវតានុស្សតិកម្មដ្ឋាននេះឲ្យជាអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងអនុស្សតិដ្ឋានទាំង ៦ ។

(៦៦) គ្រានោះឯង ព្រះមហាកច្ចានៈដ៏មានអាយុ បានហៅពួកភិក្ខុថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលស្តាប់ព្រះមហាកច្ចានៈដ៏មានអាយុថា អាវុសោដូច្នេះ ។ ទើបព្រះមហាកច្ចានៈដ៏មានអាយុ បាននិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ហេតុគួរឲ្យអស្ចារ្យ ម្នាលអាវុសោទាំងឡាយ ហេតុមិនធ្លាប់កើត ក៏កើតឡើងបាន ព្រោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ ទ្រង់ជ្រាប ទ្រង់ឃើញ បានត្រាស់ដឹងនូវការបាននូវឱកាសក្នុងទីចង្អៀត ដើម្បីសេចក្តីបរិសុទ្ធិដល់សត្វ ដើម្បីប្រព្រឹត្តកន្លងនូវសេចក្តីសោកនិងខ្សឹកខ្សួល ដើម្បីរលត់ទៅនៃទុក្ខនិងទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ការត្រាស់ដឹងនេះ គឺអនុស្សតិដ្ឋានទាំង ៦ ។

កតមានិ ឆ ។ ឥធាវុសោ អរិយសាវកោ តថាគតំ អនុស្សរតិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ យស្មឹ អាវុសោ សមយេ អរិយសាវកោ តថាគតំ អនុស្សរតិ នេវស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ និក្ខន្តំ មុត្តំ វុដ្ឋិតំ គេធម្ហា គេធោតិ ខោ អាវុសោ បញ្ចន្នេតំ កាមគុណានំ អធិវចនំ ។ សោ ខោ អាវុសោ អរិយសាវកោ សព្វសោ អាកាសសមេន ចេតសា វិហរតិ វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ។ ឥទម្បិ ខោ អាវុសោ អារម្មណំ ករិត្វា ឯវមិធេកច្ចេ សត្តា វិសុទ្ធិធម្មា ភវន្តិ ។ បុន ចបរំ អាវុសោ អរិយសាវកោ ធម្មំ អនុស្សរតិ ស្វាក្ខាតោ ភគវតា ធម្មោ ។ បេ ។ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។



អនុស្សតិដ្ឋានទាំង៦ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ អរិយសាវក ក្នុងសាសនានេះ រឭកនូវព្រះតថាគតថា ព្រោះហេតុនេះ ព្រះដ៏មានព្រះភាគអង្គនោះ ដោយប្រការដូច្នេះ ។បេ។ ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវសច្ចៈទាំង៤ ទ្រង់លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ ម្នាលអាវុសោទាំងឡាយ សម័យណា អរិយសាវក កំពុងរឭកនូវព្រះតថាគត សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតចាកគេធៈបាន ម្នាលអាវុសោទាំងឡាយ ពាក្យថា គេធៈនេះ ជាឈ្មោះនៃកាមគុណ៥ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកនោះ មានចិត្តស្មើដោយអាកាសទាំងមូល ជាចិត្តដ៏ទូលាយធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ។ ម្នាលអាវុសោទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ មានសេចក្តីបរិសុទ្ធិជាធម្មតាបានយ៉ាងនេះ ព្រោះធ្វើនូវពុទ្ធានុស្សតិកម្មដ្ឋាននេះ ឲ្យជាអារម្មណ៍ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត អរិយសាវក រឭកនូវព្រះធម៌ថា ព្រះធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយដោយល្អ ។បេ។ ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងចំពោះខ្លួន ។

យស្មឹ អាវុសោ សមយេ អរិយសាវកោ ធម្មំ អនុស្សរតិ នេវស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ និក្ខន្តំ មុត្តំ វុដ្ឋិតំ គេធម្ហា គេធោតិ ខោ អាវុសោ បញ្ចន្នេតំ កាមគុណានំ អធិវចនំ ។ សោ ខោ សោ អាវុសោ អរិយសាវកោ សព្វសោ អាកាសសមេន ចេតសា វិហរតិ វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ។ ឥទម្បិ ខោ អាវុសោ អារម្មណំ ករិត្វា ឯវមិធេកច្ចេ សត្តា វិសុទ្ធិធម្មា ភវន្តិ ។ បុន ចបរំ អាវុសោ អរិយសាវកោ សង្ឃំ អនុស្សរតិ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។បេ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ យស្មឹ អាវុសោ សមយេ អរិយសាវកោ សង្ឃំ អនុស្សរតិ នេវស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ



ម្នាលអាវុសោទាំងឡាយ សម័យណា អរិយសាវក កំពុងរឭកឃើញព្រះធម៌ សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតអំពីគេធៈបាន ម្នាលអាវុសោទាំងឡាយ ពាក្យថា គេធៈនេះ ជាឈ្មោះនៃកាមគុណ ៥ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកនោះ មានចិត្តស្មើដោយអាកាសទាំងមូល ជាចិត្តដ៏ទូលាយ ធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ។ ម្នាលអាវុសោទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ មានសេចក្តីបរិសុទ្ធិជាធម្មតាបានយ៉ាងនេះ ព្រោះធ្វើនូវធម្មានុស្សតិកម្មដ្ឋាននេះ ឲ្យជាអារម្មណ៍ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត អរិយសាវក រឭកឃើញព្រះសង្ឃថា ព្រះសង្ឃជាសាវករបស់ព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយល្អ ។បេ។ លោកជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ។ ម្នាលអាវុសោទាំងឡាយ សម័យណា អរិយសាវក កំពុងរឭកឃើញព្រះសង្ឃ សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ

ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ និក្ខន្តំ មុត្តំ វុដ្ឋិតំ គេធម្ហា គេធោតិ ខោ អាវុសោ បញ្ចន្នេតំ កាមគុណានំ អធិវចនំ ។ សព្វសោ អាវុសោ អរិយសាវកោ សព្វសោ អាកាសសមេន ចេតសា វិហរតិ វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ។ ឥទម្បិ ខោ អាវុសោ អារម្មណំ ករិត្វា ឯវមិធេកច្ចេ សត្តា វិសុទ្ធិធម្មា ភវន្តិ ។ បុន ចបរំ អាវុសោ អរិយសាវកោ អត្តនោ សីលានិ អនុស្សរតិ អខណ្ឌានិ ។ បេ ។ សមាធិសំវត្តនិកានិ ។ យស្មឹ អាវុសោ សមយេ អរិយសាវកោ សីលំ អនុស្សរតិ នេវស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ និក្ខន្តំ មុត្តំ វុដ្ឋិតំ គេធម្ហា គេធោតិ ខោ អាវុសោ បញ្ចន្នេតំ កាមគុណានំ អធិវចនំ ។



សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតចាកគេធៈបាន ម្នាលអាវុសោទាំងឡាយ ពាក្យថាគេធៈនេះ ជាឈ្មោះនៃកាមគុណ ៥ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកនោះ មានចិត្តស្មើដោយអាកាសទាំងពួង ជាចិត្តដ៏ទូលាយ ធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ។ ម្នាលអាវុសោទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ មានសេចក្ដីបរិសុទ្ធិជាធម្មតាបានយ៉ាងនេះ ព្រោះធ្វើឲ្យសង្ឃានុស្សតិកម្មដ្ឋាននេះ ឲ្យជាអារម្មណ៍ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត អរិយសាវក រឭកនូវសីលរបស់ខ្លួន ជាសីលមិនដាច់ ។បេ។ ប្រព្រឹត្តទៅដើម្បីបាននូវសមាធិ ។ ម្នាលអាវុសោទាំងឡាយ សម័យណា អរិយសាវក កំពុងរឭកនូវសីល សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតចាកគេធៈបាន ម្នាលអាវុសោទាំងឡាយ ពាក្យថា គេធៈនេះ ជាឈ្មោះនៃកាមគុណ ៥ ។

ស ខោ សោ អាវុសោ អរិយសាវកោ សព្វសោ អាកាសសមេន ចេតសា វិហរតិ វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ។ ឥទម្បិ ខោ អាវុសោ អារម្មណំ ករិត្វា ឯវមិធេកច្ចេ សត្តា វិសុទ្ធិធម្មា ភវន្តិ ។ ផុន ចបរំ អាវុសោ អរិយសាវកោ អត្តនោ ចាគំ អនុស្សរតិ លាភា វត មេ សុលទ្ធំ វត មេ យោហំ ។បេ។ យាចយោគោ ទានសំវិភាគរតោតិ ។ យស្មិំ អាវុសោ សមយេ អរិយសាវកោ ចាគំ អនុស្សរតិ នេវស្ស តស្មិំ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មិំ សមយេ ចិត្តំ ហោតិ និក្ខន្តំ មុត្តំ វុដ្ឋិតំ គេធម្ហា គេធោតិ ខោ អាវុសោ បញ្ចន្នេតំ កាមគុណានំ អធិវចនំ ស ខោ សោ អាវុសោ អរិយសាវកោ សព្វសោ អាកាសសមេន ចេតសា វិហរតិ វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ។ ឥទម្បិ ខោ អាវុសោ អារម្មណំ ករិត្វា ឯវមិធេកច្ចេ សត្តា វិសុទ្ធិធម្មា ភវន្តិ ។



ម្នាលអាវុសោទាំងឡាយ អរិយសាវកនោះ មានចិត្តស្មើដោយអាកាសទាំងមូល ជាចិត្តដ៏ទូលាយ ធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ។ ម្នាលអាវុសោទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ មានសេចក្តីបរិសុទ្ធិជាធម្មតាបានយ៉ាងនេះ ព្រោះធ្វើនូវសីលានុស្សតិកម្មដ្ឋាននេះឲ្យជាអារម្មណ៍ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត អរិយសាវករឭកនូវចាគៈរបស់ខ្លួនថា ជាលាភរបស់អញហើយ អញឈ្មោះថាបានស្រួលហើយ ព្រោះថាអញ ។បេ។ គួរគេសូមបាន ត្រេកអរក្នុងការឲ្យនឹងការចែករំលែក ។ ម្នាលអាវុសោទាំងឡាយ សម័យណា អរិយសាវករឭកនូវចាគៈ សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ឡើយ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែម្យ៉ាងគឺ ជាចិត្តចេញរួចឃ្លាតអំពីគេធៈបាន ម្នាលអាវុសោទាំងឡាយ ពាក្យថាគេធៈនេះ ជាឈ្មោះនៃកាមគុណ៥ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកនោះ មានចិត្តស្មើដោយអាកាសទាំងមូល ជាចិត្តដ៏ទូលាយ ធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ។ ម្នាលអាវុសោទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ មានសេចក្តីបរិសុទ្ធិជាធម្មតាបានយ៉ាងនេះ ព្រោះធ្វើនូវចាគានុស្សតិកម្មដ្ឋាននេះ ឲ្យជាអារម្មណ៍ ។

បុន ចបរំ អាវុសោ អរិយសាវកោ ទេវតា អនុស្សរតិ សន្តិ ទេវា ចាតុម្មហារាជិកា ។បេ។ សន្តិ ទេវា តទុត្តរិ យថារូបាយ សទ្ធាយ សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថ ឧបបន្នា មយ្ហម្បិ តថារូបា សទ្ធា សំវិជ្ជតិ យថារូបេន សីលេន ។បេ។ សុតេន ចាគេន បញ្ញាយ សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថ ឧបបន្នា មយ្ហម្បិ តថារូបា បញ្ញា សំវិជ្ជតីតិ ។ យស្មឹ អាវុសោ សមយេ អរិយសាវកោ អត្តនោ ច តាសញ្ច ទេវតានំ សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរតិ នេវស្ស តស្មឹ សមយេ រាគបរិយុដ្ឋិតំ ចិត្តំ ហោតិ ន ទោសបរិយុដ្ឋិតំ ចិត្តំ ហោតិ ន មោហបរិយុដ្ឋិតំ ចិត្តំ ហោតិ ឧជុគតមេវស្ស តស្មឹ សមយេ ចិត្តំ ហោតិ និក្ខន្តំ មុត្តំ វុដ្ឋិតំ គេធម្ហា គេធោតិ ខោ អាវុសោ បញ្ចន្នេតំ កាមគុណានំ អធិវចនំ ។ សោ ខោ អាវុសោ អរិយសាវកោ សព្វសោ អាកាសសមេន ចេតសា វិហរតិ វិបុលេន មហគ្គតេន អប្បមាណេន



ម្នាលអាវុសោទាំងឡាយ មួយទៀត អរិយសាវក រឭកនូវពួកទេវតាថា ទេវតាជាន់ចាតុម្មហារាជិកៈក៏មាន ។បេ។ ទេវតាជាន់ខ្ពស់ជាងនោះទៀតក៏មាន ទេវតាទាំងនោះប្រកបដោយសទ្ធាយ៉ាងណា ច្យុតអំពីទីនេះហើយ ទៅកើតក្នុងទីនោះ អាត្មាអញក៏មានសទ្ធាដូច្នោះដែរ ទេវតាទាំងនោះប្រកបដោយសីលយ៉ាងណា ។បេ។ ដោយសុតៈ ចាគៈ បញ្ញា ច្យុតអំពីទីនេះហើយ ទៅកើតក្នុងទីនោះ អាត្មាអញក៏មានបញ្ញាដូច្នោះដែរ ។ ម្នាលអាវុសោទាំងឡាយ សម័យណា អរិយសាវក ក៏រឭកនូវគុណគឺសទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា របស់ខ្លួនផង របស់ទេវតាទាំងនោះផង សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតអំពីគេធៈបាន ម្នាលអាវុសោទាំងឡាយ ពាក្យថា គេធៈនេះ ជាឈ្មោះនៃកាមគុណ៥ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកនោះមានចិត្តស្មើដោយអាកាសទាំងមូល ជាចិត្តដ៏ទូលាយ ធំ ប្រមាណមិនបាន

អវេរេន អព្យាបជ្ជេន ។ ឥទម្បិ ខោ អាវុសោ អារម្មណំ ករិត្វា ឯវមិធេកច្ចេ សត្តា វិសុទ្ធិធម្មា ភវន្តិ ។ អច្ឆរិយំ អាវុសោ អព្ភុតំ អាវុសោ យាវញ្ចិទំ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សម្ពាធេ ឱកាសាធិគមោ អនុពុទ្ធោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ ឥមានិ ឆ អនុស្សតិដ្ឋានានីតិ ។

(៦៧) អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កតិ នុ ខោ ភន្តេ សមយា មនោភាវនីយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុន្តិ ។ ឆយិមេ ភិក្ខុ សមយា មនោភាវនីយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុំ ។



មិនមានពៀរ មិនមានព្យាបាទ ។ ម្នាលអាវុសោទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ មានសេចក្តីបរិសុទ្ធិជាធម្មតាបានយ៉ាងនេះ ព្រោះធ្វើនូវអនុស្សតិដ្ឋាននេះ ឲ្យជាអារម្មណ៍ ។ ម្នាលអាវុសោទាំងឡាយ ហេតុនេះគួរឲ្យអស្ចារ្យ ម្នាលអាវុសោទាំងឡាយ ហេតុមិនធ្លាប់កើត ក៏កើតឡើងបាន ត្រង់ដែលព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ ទ្រង់ជ្រាប ទ្រង់ឃើញ បានត្រាស់ដឹងនូវការបាននូវឱកាស ក្នុងទីចង្អៀតនេះ ដើម្បីសេចក្តីបរិសុទ្ធិដល់ពួកសត្វ ដើម្បីប្រព្រឹត្តកន្លងនូវសេចក្តីសោកនិងខ្សឹកខ្សួលទាំងឡាយ ដើម្បីឲ្យអស់ទៅនៃទុក្ខនិងទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ការត្រាស់ដឹងនេះ គឺអនុស្សតិដ្ឋានទាំង ៦ នេះ ។

(៦៧) គ្រានោះ ភិក្ខុ ១ រូប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សម័យដែលគួរចូលទៅឃើញ ភិក្ខុជាអ្នកមានចិត្តចំរើនហើយ តើមានប៉ុន្មាន ។ ម្នាលភិក្ខុ សម័យដែលគួរចូលទៅឃើញ ភិក្ខុមានចិត្តចំរើនហើយ នេះមាន ៦ យ៉ាងគឺ

កតមេ ឆ ។ ឥធ ភិក្ខុ យស្មឹ សមយេ ភិក្ខុ កាមរាគបរិយុដ្ឋិតេន ចេតសា វិហរតិ កាមរាគបរេតេន ឧប្បន្នស្ស ច កាមរាគស្ស និស្សរណំ យថាភូតំ នប្បជានាតិ តស្មឹ សមយេ មនោភាវនិយោ ភិក្ខុ ឧបសង្កមិត្វា ឯវមស្ស វចនីយោ អហំ ខោ អាវុសោ កាមរាគបរិយុដ្ឋិតេន ចេតសា វិហរាមិ កាមរាគបរេតេន ឧប្បន្នស្ស ច កាមរាគស្ស និស្សរណំ យថាភូតំ នប្បជានាមិ សាធុ វត មេ អាយស្មា កាមរាគស្ស បហានាយ ធម្មំ ទេសេតូតិ តស្ស មនោភាវនិយោ ភិក្ខុ កាមរាគស្ស បហានាយ ធម្មំ ទេសេតិ ។ អយំ ភិក្ខុ បឋមោ សមយោ មនោភាវនិយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុំ ។ បុន ចបរំ ភិក្ខុ យស្មឹ សមយេ ភិក្ខុ ព្យាបាទបរិយុដ្ឋិតេន ចេតសា វិហរតិ ព្យាបាទបរេតេន ឧប្បន្នស្ស ច ព្យាបាទស្ស និស្សរណំ យថាភូតំ នប្បជានាតិ តស្មឹ សមយេ មនោភាវនិយោ ភិក្ខុ ឧបសង្កមិត្វា ឯវមស្ស វចនីយោ



៦ តើអ្វីខ្លះ ។ ម្នាលភិក្ខុ សម័យណា ភិក្ខុក្នុងសាសនានេះ មានចិត្តដែលកាមរាគគ្របសង្កត់ហើយ រើករាយ ដោយកាមរាគ ទាំងមិនដឹងនូវការលះកាមរាគ ដែលកើតឡើងហើយ ឲ្យពិតប្រាកដបាន សម័យនោះត្រូវចូលទៅរកភិក្ខុជាអ្នកមានចិត្តចំរើនហើយ និយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមានចិត្តត្រូវកាមរាគគ្របសង្កត់ហើយ រើករាយដោយកាម-រាគ ទាំងមិនដឹងនូវការលះកាមរាគ ដែលកើតឡើងហើយ ឲ្យពិតប្រាកដបានទេ សូមលោកដ៏មានអាយុ អាណិតសំដែងធម៌ ដើម្បីលះកាមរាគដល់ខ្ញុំ ភិក្ខុដែលមានចិត្តចំរើន តែងតែសំដែងធម៌ ដើម្បីលះកាមរាគដល់ភិក្ខុនោះ ។ ម្នាលភិក្ខុ នេះជាសម័យដែលគួរចូលទៅ ឃើញភិក្ខុដែលមានចិត្តចំរើនទី ១ ។ ម្នាលភិក្ខុ មួយទៀត សម័យណា បើភិក្ខុមានចិត្ត ត្រូវព្យាបាទគ្របសង្កត់ហើយ រើករាយ ដោយព្យាបាទ ទាំងមិនដឹងនូវការលះព្យាបាទ ដែលកើតឡើងហើយ ឲ្យពិតប្រាកដ សម័យនោះទើបត្រូវចូលទៅរកភិក្ខុ ដែលមានចិត្តចំរើនហើយ និយាយយ៉ាងនេះថា

អហំ ខោ អាវុសោ ព្យាបាទបរិយុដ្ឋិតេន ចេតសា វិហរាមិ ព្យាបាទបរេតេន ឧប្បន្នស្ស ច ព្យាបាទស្ស និស្សរណំ យថាភូតំ នប្បជានាមិ សាធុ វត មេ អាយស្មា ព្យាបាទស្ស បហានាយ ធម្មំ ទេសេតូតិ តស្ស មនោភាវនិយោ ភិក្ខុ ព្យាបាទស្ស បហានាយ ធម្មំ ទេសេតិ ។ អយំ ភិក្ខុ ទុតិយោ សមយោ មនោភាវនិយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុំ ។ បុន ចបរំ ភិក្ខុ យស្មឹ សមយេ ភិក្ខុ ថីនមិទ្ធបរិយុដ្ឋិតេន ចេតសា វិហរតិ ថីនមិទ្ធបរេតេន ឧប្បន្នស្ស ច ថីនមិទ្ធស្ស និស្សរណំ យថាភូតំ នប្បជានាតិ តស្មឹ សមយេ មនោភាវនិយោ ភិក្ខុ ឧបសង្កមិត្វា ឯវមស្ស វចនីយោ អហំ ខោ អាវុសោ ថីនមិទ្ធបរិយុដ្ឋិតេន ចេតសា វិហរាមិ ថីនមិទ្ធបរេតេន ឧប្បន្នស្ស ច ថីនមិទ្ធស្ស និស្សរណំ យថាភូតំ នប្បជានាមិ សាធុ វត មេ អាយស្មា ថីនមិទ្ធស្ស បហានាយ ធម្មំ ទេសេតូតិ តស្ស មនោភាវនិយោ ភិក្ខុ ថីនមិទ្ធស្ស បហានាយ ធម្មំ ទេសេតិ ។



ថា ម្នាលអាវុសោ ខ្ញុំមានចិត្តត្រូវព្យាបាទគ្របសង្កត់ហើយ រវើរវាយដោយព្យាបាទ តាំងមិនដឹងនូវការលះព្យាបាទ ដែលកើតឡើងហើយ ឲ្យពិតប្រាកដទេ សូមលោកដ៏មានអាយុ អាណិតសំដែងធម៌ ដើម្បីលះព្យាបាទដល់ខ្ញុំ ។ ភិក្ខុដែលមានចិត្តចំរើន គង់នឹងសំដែងធម៌ ដើម្បីលះព្យាបាទដល់ភិក្ខុនោះ ។ ម្នាលភិក្ខុ នេះជាសម័យ ដែលគួរចូលទៅឃើញភិក្ខុដែលមានចិត្តចំរើនទី ២ ។ ម្នាលភិក្ខុ មួយទៀត សម័យណា ភិក្ខុមានចិត្តត្រូវថីនមិទ្ធៈគ្របសង្កត់ រវើរវាយដោយថីនមិទ្ធៈ តាំងមិនដឹងនូវការលះថីនមិទ្ធៈ ដែលកើតឡើងឲ្យពិតប្រាកដ សម័យនោះ ត្រូវចូលទៅរកភិក្ខុដែលមានចិត្តចំរើន ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមានចិត្តត្រូវថីនមិទ្ធៈគ្របសង្កត់ ហើយរវើរវាយដោយថីនមិទ្ធៈ តាំងមិនដឹងនូវការលះថីនមិទ្ធៈដែលកើតឡើងហើយ ឲ្យពិតប្រាកដទេ សូមលោកដ៏មានអាយុ អាណិតសំដែងធម៌ ដើម្បីលះថីនមិទ្ធៈដល់ខ្ញុំ ភិក្ខុដែលមានចិត្តចំរើន គង់នឹងសំដែងធម៌ ដើម្បីលះថីនមិទ្ធៈដល់ភិក្ខុនោះ ។

អយំ ភិក្ខវេ តតិយោ សមយោ មនោភាវនិយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុំ ។ បុន ចបរំ ភិក្ខវេ យស្មឹ សមយេ ភិក្ខុ ឧទ្ធច្ចកុក្កុច្ចបរិយុដ្ឋិតេន ចេតសា វិហរតិ ឧទ្ធច្ចកុក្កុច្ចបរេតេន ឧប្បន្នស្ស ច ឧទ្ធច្ចកុក្កុច្ចស្ស និស្សរណំ យថាភូតំ នប្បជានាតិ តស្មឹ សមយេ មនោភាវនិយោ ភិក្ខុ ឧបសង្កមិត្វា ឯវមស្ស វចនីយោ អហំ ខោ អាវុសោ ឧទ្ធច្ចកុក្កុច្ចបរិយុដ្ឋិតេន ចេតសា វិហរាមិ ឧទ្ធច្ចកុក្កុច្ចបរេតេន ឧប្បន្នស្ស ច ឧទ្ធច្ចកុក្កុច្ចស្ស និស្សរណំ យថាភូតំ នប្បជានាមិ សាធុ វត មេ អាយស្មា ឧទ្ធច្ចកុក្កុច្ចស្ស បហានាយ ធម្មំ ទេសេតូតិ តស្ស មនោភាវនិយោ ភិក្ខុ ឧទ្ធច្ចកុក្កុច្ចស្ស បហានាយ ធម្មំ ទេសេតិ ។ អយំ ភិក្ខវេ ចតុត្ថោ សមយោ មនោភាវនិយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុំ ។ បុន ចបរំ ភិក្ខវេ យស្មឹ សមយេ ភិក្ខុ វិចិកិច្ឆាបរិយុដ្ឋិតេន ចេតសា វិហរតិ វិចិកិច្ឆាបរេតេន ឧប្បន្នាយ ច វិចិកិច្ឆាយ និស្សរណំ យថាភូតំ នប្បជានាតិ-



ម្នាលភិក្ខុ នេះជាសម័យ ដែលគួរចូលទៅឃើញ ភិក្ខុដែលមានចិត្តចំរើន ទី ៣ ។ ម្នាលភិក្ខុ មួយទៀត សម័យណា ភិក្ខុមានចិត្តត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ រឿករាយដោយឧទ្ធច្ចកុក្កុច្ចៈ ទាំងមិនដឹងនូវការលះឧទ្ធច្ចកុក្កុច្ចៈ ដែលកើតឡើងហើយឲ្យពិតប្រាកដទេ សម័យនោះ ត្រូវចូលទៅរកភិក្ខុមានចិត្តចំរើន ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមានចិត្តត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ហើយ រឿករាយដោយឧទ្ធច្ចកុក្កុច្ចៈ ទាំងមិនដឹងនូវការលះឧទ្ធច្ចកុក្កុច្ចៈ ដែលកើតឡើងហើយឲ្យពិតប្រាកដទេ សូមលោកដ៏មានអាយុ ករុណាសំដែងធម៌ដល់ខ្ញុំ ដើម្បីលះនូវឧទ្ធច្ចកុក្កុច្ចៈ ភិក្ខុជាអ្នកមានចិត្តចំរើន តែងសំដែងធម៌ដល់ភិក្ខុនោះ ដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ ។ ម្នាលភិក្ខុ នេះជាសម័យ ដែលគួរចូលទៅឃើញ ភិក្ខុដែលមានចិត្តចំរើនទី ៤ ។ ម្នាលភិក្ខុ មួយទៀត សម័យណា ភិក្ខុមានចិត្ត ត្រូវវិចិកិច្ឆាគ្របសង្កត់ រឿករាយដោយវិចិកិច្ឆា ទាំងមិនដឹងនូវការលះវិចិកិច្ឆា ដែលកើតឡើងហើយ ឲ្យពិតប្រាកដទេ

តស្មឹ សមយេ មនោភាវនិយោ ភិក្ខុ ឧបសង្កមិត្វា ឯវមស្ស វចនីយោ អហំ ខោ អាវុសោ វិចិកិច្ឆាប-រិយុដ្ឋិតេន ចេតសា វិហរាមិ វិចិកិច្ឆាបរេតេន ឧប្បន្នាយ ច វិចិកិច្ឆាយ និស្សរណំ យថាភូតំ នប្បជានាមិ សាធុ វត មេ អាយស្មា វិចិកិច្ឆាយ បហានាយ ធម្មំ ទេសេតូតិ តស្ស មនោភាវនិយោ ភិក្ខុ វិចិកិច្ឆាយ បហានាយ ធម្មំ ទេសេតិ ។ អយំ ភិក្ខុ បញ្ចមោ សមយោ មនោភាវនិយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុំ ។ បុន ចបរំ ភិក្ខុ យស្មឹ សមយេ ភិក្ខុ យំ និមិត្តំ អាគម្ម យំ និមិត្តំ មនសិករោតោ អនន្តរា អាសវានំ ខយោ ហោតិ តំ និមិត្តំ ន ជានាតិ ន បស្សតិ តស្មឹ សមយេ មនោភាវនិយោ ភិក្ខុ ឧបសង្ក-មិត្វា ឯវមស្ស វចនីយោ អហំ ខោ អាវុសោ យំ និមិត្តំ អាគម្ម យំ និមិត្តំ មនសិករោតោ អនន្តរា អាសវានំ ខយោ ហោតិ តំ និមិត្តំ ន ជានាមិ ន បស្សាមិ សាធុ វត មេ អាយស្មា អាសវានំ ខយាយ ធម្មំ ទេសេតូតិ តស្ស មនោភាវនិយោ ភិក្ខុ អាសវានំ ខយាយ ធម្មំ ទេសេតិ ។



សម័យនោះ ត្រូវចូលទៅរកភិក្ខុដែលមានចិត្តចំរើន ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមានចិត្តត្រូវវិចិកិច្ឆាគ្របសង្កត់ហើយ រវើរវាយដោយវិចិកិច្ឆា ទាំងមិនដឹងនូវការលះវិចិកិច្ឆា ដែលកើតឡើង ហើយឲ្យពិតប្រាកដផង សូមលោកដ៏មានអាយុ ករុណាកសំដែងធម៌ដល់ខ្ញុំ ដើម្បីលះវិចិកិច្ឆា ភិក្ខុដែលមានចិត្តចំរើន ក៏នឹងសំដែងធម៌ដល់ភិក្ខុនោះ ដើម្បីលះនូវវិចិកិច្ឆា ។ ម្នាលភិក្ខុ នេះជាសម័យដែលគួរចូលទៅឃើញភិក្ខុដែលមានចិត្តចំរើនទី៥ ។ ម្នាលភិក្ខុ មួយទៀត សម័យណា ភិក្ខុមិនដឹង មិនឃើញនូវនិមិត្ត ដែលខ្លួនអាស្រ័យនិមិត្តណា ធ្វើទុកក្នុងចិត្តនូវនិមិត្តណា ហើយអស់អាសវៈទាំងឡាយ ដោយឥតអន្តរាយនោះ សម័យនោះ ត្រូវចូលទៅរកភិក្ខុដែលមានចិត្តចំរើន ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនដឹង មិនឃើញនូវនិមិត្ត (ដែលខ្ញុំ) អាស្រ័យនិមិត្តណា ធ្វើទុកក្នុងចិត្តនូវនិមិត្តណា ហើយអស់អាសវៈទាំងឡាយ ដោយឥតអន្តរាយនោះ សូមលោកដ៏មានអាយុ ករុណាកសំដែងធម៌ដល់ខ្ញុំ ដើម្បីឲ្យអស់អាសវៈទាំងឡាយ ភិក្ខុដែលមានចិត្តចំរើន ក៏នឹងសំដែងធម៌ដល់ភិក្ខុនោះ ដើម្បីឲ្យអស់អាសវៈទាំងឡាយ ។

អយំ ភិក្ខុ ឆដ្ឋោ សមយោ មនោភាវនិយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុំ ។ ឥមេ ខោ ភិក្ខុ ឆ សមយា មនោភាវនិយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុន្តិ ។

(២៨) ឯកំ សមយំ សម្ពហុលា ថេរា ភិក្ខូ ពារាណសិយំ វិហរន្តិ ឥសិបតនេ មិគទាយេ ។ អថខោ ថេរានំ ភិក្ខូនំ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តានំ មណ្ឌលមាឡេ សន្និសិន្នានំ សន្និបតិតានំ អយមន្តរា កថា ឧទបាទិ កោ នុ ខោ អាវុសោ សមយោ មនោភាវនិយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុន្តិ ។ ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ថេរេ ភិក្ខូ ឯតទវោច យស្មឹ អាវុសោ សមយេ មនោភាវនិយោ ភិក្ខុ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ បាទេ បក្ខាលេត្វា និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា សោ សមយោ មនោភាវនិយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុន្តិ ។ ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ តំ ភិក្ខុំ ឯតទវោច



ម្នាលភិក្ខុ នេះជាសម័យ ដែលគួរចូលទៅឃើញនូវភិក្ខុដែលមានចិត្តចំរើនទី ៦ ។ ម្នាលភិក្ខុ នេះឯងជាសម័យទាំង ៦ ដែលគួរចូលទៅឃើញភិក្ខុមានចិត្តចំរើន ។

(២៨) សម័យមួយ ភិក្ខុជាថេរៈច្រើនអង្គ នៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ គ្រានោះ ភិក្ខុជាថេរៈទាំងឡាយនោះ ផុតកិច្ចដោយបិណ្ឌបាត ក្នុងកាលជាខាងក្រោយពេលបាយហើយ បានអង្គុយប្រជុំគ្នា ក្នុងរោងនៅក្នុងមណ្ឌលទី (រោងឧសាលា) ហើយនិយាយឡើងក្នុងចន្លោះយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ សម័យដែលគួរចូលទៅឃើញ ភិក្ខុដែលមានចិត្តចំរើន តើសម័យណា ។ កាលបើពួកព្រះថេរៈនិយាយយ៉ាងនេះហើយ ភិក្ខុ១រូប បាននិយាយនឹងពួកភិក្ខុជាថេរៈយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ សម័យណា ភិក្ខុដែលមានចិត្តចំរើន ផុតកិច្ចដោយបិណ្ឌបាត ក្នុងកាលជាខាងក្រោយពេលបាយ លោកលាងជើងហើយអង្គុយផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងសតិចំពោះមុខ សម័យនោះ ទើបគួរចូលទៅឃើញភិក្ខុដែលមានចិត្តចំរើន ។ កាលបើភិក្ខុនោះនិយាយយ៉ាងនេះហើយ ភិក្ខុ១រូបទៀត និយាយនឹងភិក្ខុនោះយ៉ាងនេះថា

ន សោ អាវុសោ សមយោ មនោភាវនិយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុំ ។ យស្មិំ អាវុសោ សមយេ មនោភាវនិយោ ភិក្ខុ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ បាទេ បក្ខាលេត្វា និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ចារិត្តកិលមថោបិស្ស តស្មិំ សមយេ អប្បដិប្បស្សទ្ធោ ហោតិ ភត្តកិលមថោបិស្ស តស្មិំ សមយេ អប្បដិប្បស្សទ្ធោ ហោតិ តស្មា សោ អសមយោ មនោភាវនិយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុំ ។ យស្មិំ អាវុសោ សមយេ មនោភាវនិយោ ភិក្ខុ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ វិហារបច្ឆាយាយំ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា សោ សមយោ មនោភាវនិយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុន្តិ ។ ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ តំ ភិក្ខុំ ឯតទវោច ន សោ អាវុសោ សមយោ មនោភាវនិយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុំ ។



ម្នាលអាវុសោ មិនមែនជាសម័យ គួរចូលទៅឃើញភិក្ខុដែលមានចិត្តចំរើនទេ ។ ម្នាលអាវុសោ ព្រោះថា សម័យណា ភិក្ខុដែលមានចិត្តចំរើន ផុតកិច្ចដោយបិណ្ឌបាត ក្នុងកាលក្រោយពេលឆាន់ លោកលាងជើង ហើយអង្គុយផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងសតិចំពោះមុខ លោកកំពុងមានសេចក្តីលំបាកនឹងការត្រាច់ទៅ (បិណ្ឌបាត) មិនទាន់ស្ងប់រម្ងាប់ ក្នុងសម័យនោះនៅឡើយ សូម្បីសេចក្តីលំបាកព្រោះភត្ត ក៏មិនទាន់ស្ងប់រម្ងាប់ ក្នុងសម័យនោះនៅឡើយដែរ ហេតុនោះ បានជាសម័យនោះ មិនមែនជាសម័យ គួរចូលទៅឃើញភិក្ខុដែលមានចិត្តចំរើនទេ ។ ម្នាលអាវុសោ សម័យណា ភិក្ខុដែលមានចិត្តចំរើន ចេញអំពីទីស្ងាត់ ក្នុងសាយណ្ហសម័យ ហើយអង្គុយក្នុងម្លប់ខាងក្រោយវិហារ ផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងសតិចំពោះមុខ សម័យនោះ ទើបជាសម័យ គួរចូលទៅឃើញភិក្ខុ ដែលមានចិត្តចំរើនបាន ។ កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ភិក្ខុដទៃទៀត និយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ មិនមែនជាសម័យ ដែលគួរចូលទៅឃើញភិក្ខុដែលមានចិត្តចំរើន (នោះទេ) ។

យស្មឹ អាវុសោ សមយេ មនោភាវនីយោ ភិក្ខុ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ វិហារបច្ឆាយាយំ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា យមស្ស ទិវា សមាធិនិមិត្តំ មនសិកតំ ហោតិ តមស្ស តស្មឹ សមយេ សមុទាចរតិ ។ តស្មា សោ អសមយោ មនោភាវនីយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុំ ។ យស្មឹ អាវុសោ សមយេ មនោភាវនីយោ ភិក្ខុ រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា សោ សមយោ មនោភាវនីយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុន្តិ ។ ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ តំ ភិក្ខុំ ឯតទវោច ន ខោ អាវុសោ សមយោ មនោភាវនីយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុំ ។ យស្មឹ អាវុសោ សមយេ មនោភាវនីយោ ភិក្ខុ រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ និសិន្នោ ហោតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ



ម្នាលអាវុសោ ព្រោះថា សម័យណា ភិក្ខុមានចិត្តចំរើនចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ អង្គុយក្នុងម្លប់ខាងក្រោយវិហារ ផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងសតិចំពោះមុខ ហើយធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្តណាក្នុងវេលាថ្ងៃ សមាធិនិមិត្តរបស់លោកនោះឯង រមែងកើតឡើង (ក្នុងខាងក្នុង) ក្នុងសម័យនោះ ។ ហេតុនោះ បានជាសម័យនោះ មិនមែនជាសម័យ ដែលគួរចូលទៅឃើញភិក្ខុដែលមានចិត្តចំរើនទេ ។ ម្នាលអាវុសោ លុះតែសម័យណា ភិក្ខុដែលមានចិត្តចំរើន ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយអង្គុយផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងសតិចំពោះមុខ សម័យនោះ ទើបគួរចូលទៅឃើញភិក្ខុដែលមានចិត្តចំរើន ។ កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ភិក្ខុឯទៀត និយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ មិនមែនជាសម័យ ដែលគួរចូលទៅឃើញភិក្ខុដែលមានចិត្តចំរើនទេ ។ ម្នាលអាវុសោ លុះតែសម័យណា ភិក្ខុដែលមានចិត្តចំរើនក្រោកឡើងក្នុងបច្ចូស សម័យនៃរាត្រី ហើយអង្គុយ ផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់

បរិមុខំ សតិំ ឧបដ្ឋបេត្វា ឆជ្ជាយិស្ស តស្មិំ សមយេ កាយោ ហោតិ ផាសុកស្ស ហោតិ ពុទ្ធានំ សាសនំ មនសិកាតុំ ។ តស្មា សោ សមយោ មនោភាវនិយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុន្តិ ។ ឯវំ វុត្តេ អាយស្មា មហាកច្ចានោ ថេរេ ភិក្ខូ ឯតទវោច សម្មុខា មេ តំ អាវុសោ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ ឆយិមេ ភិក្ខុ សមយា មនោភាវនិយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុំ ។ កតមេ ឆ ។ ឥធ ភិក្ខុ យស្មិំ សមយេ ភិក្ខុ កាមរាគបរិយុដ្ឋិតេន ចេតសា វិហរតិ កាមរាគបរេតេន ឧប្បន្នស្ស ច កាមរាគស្ស និស្សរណំ យថាភូតំ នប្បជានាតិ តស្មិំ សមយេ មនោភាវនិយោ ភិក្ខុ ឧបសង្កមិត្វា ឯវមស្ស វចនីយោ អហំ ខោ អាវុសោ កាមរាគបរិយុដ្ឋិតេន ចេតសា វិហរាមិ កាមរាគបរេតេន ឧប្បន្នស្ស ច កាម-រាគស្ស និស្សរណំ យថាភូតំ នប្បជានាមិ សាធុ វត មេ អាយស្មា កាមរាគស្ស បហានាយ ធម្មំ ទេសេតូតិ



តាំងសតិចំពោះមុខ សម័យនោះ កាយរបស់លោក កំពុងតាំងនៅក្នុងផាសុក (ការស្រួល) លោកកំពុងសប្បាយនឹងធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ ព្រោះហេតុនោះ សម័យនោះ ទើបជាសម័យគួរចូលទៅឃើញភិក្ខុដែលមានចិត្តចំរើន ។ កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ទើបព្រះមហាកច្ចានៈដ៏មានអាយុ បាននិយាយនឹងពួកភិក្ខុជាថេរៈយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ការនោះ ខ្ញុំបានស្តាប់ចំពោះព្រះភក្រ្ត ខ្ញុំបានរៀនចំពោះព្រះភក្រ្ត នៃព្រះដ៏មានព្រះភាគយ៉ាងនេះថា ម្នាលភិក្ខុ សម័យដែលគួរចូលទៅឃើញភិក្ខុដែលមានចិត្តចំរើននេះមាន ៦ ។ ៦ តើដូចម្តេច ។ ម្នាលភិក្ខុ សម័យណា ភិក្ខុក្នុងសាសនានេះ មានចិត្តត្រូវកាមរាគគ្របសង្កត់ហើយ រងរាំងដោយកាមរាគ មិនដឹងនូវការលះកាមរាគដែលកើតឡើងហើយឲ្យពិតប្រាកដទេ សម័យនោះ ត្រូវចូលទៅរកភិក្ខុដែលមានចិត្តចំរើន ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមានចិត្តត្រូវកាមរាគគ្របសង្កត់ហើយ រងរាំង ដោយកាម-រាគ មិនដឹងនូវការលះកាមរាគដែលកើតឡើងហើយឲ្យពិតប្រាកដទេ សូមលោកដ៏មានអាយុ ករុណាសំដែងធម៌ដល់ខ្ញុំ ដើម្បីលះកាមរាគ

តស្ស មនោភាវនិយោ ភិក្ខុ កាមរាគស្ស បហានាយ ធម្មំ ទេសេតិ ។ អយំ ភិក្ខុ បឋមោ សមយោ មនោភាវនិយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុំ ។ បុន ចបរំ ភិក្ខុ យស្មឹ សមយេ ភិក្ខុ ព្យាបាទបរិយុដ្ឋិតេន ចេតសា វិហរតិ ។បេ។ ថីនមិទ្ធបរិយុដ្ឋិតេន ចេតសា វិហរតិ ឧទ្ធច្ចកុក្កុច្ចបរិយុដ្ឋិតេន ចេតសា វិហរតិ វិចិកិច្ឆាបរិយុដ្ឋិតេន ចេតសា វិហរតិ ។បេ។ យំ និមិត្តំ អាគម្ម យំ និមិត្តំ មនសិការោតោ អនន្តរា អាសវានំ ខយោ ហោតិ តំ និមិត្តំ ន ជានាតិ ន បស្សតិ តស្មឹ សមយេ មនោភាវនិយោ ភិក្ខុ ឧបសង្កមិត្វា ឯវមស្ស វចនីយោ អហំ ខោ អាវុសោ យំ និមិត្តំ អាគម្ម យំ និមិត្តំ មនសិការោតោ អនន្តរា អាសវានំ ខយោ ហោតិ តំ និមិត្តំ ន ជានាមិ ន បស្សាមិ សាធុ វត មេ អាយស្មា អាសវានំ ខយាយ ធម្មំ ទេសេតូតិ តស្ស មនោភាវនិយោ ភិក្ខុ អាសវានំ ខយាយ ធម្មំ ទេសេតិ ។



ភិក្ខុដែលមានចិត្តចំរើន តែងតែសំដែងធម៌ដល់ភិក្ខុនោះ ដើម្បីលះកាមរាគ ។ ម្នាលភិក្ខុ នេះជាសម័យ ដែលគួរចូលទៅឃើញភិក្ខុដែលមានចិត្តចំរើន ទី ១ ។ ម្នាលភិក្ខុ មួយទៀត សម័យណា ភិក្ខុមានចិត្តត្រូវព្យាបាទគ្របសង្កត់ ។បេ។ មានចិត្តត្រូវថីនមិទ្ធគ្របសង្កត់ មានចិត្តត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ មានចិត្តត្រូវវិចិកិច្ឆាគ្របសង្កត់ ។បេ។ មិនដឹង មិនឃើញនូវនិមិត្តដែលខ្លួនអាស្រ័យនិមិត្តណា ធ្វើទុកក្នុងចិត្តនូវនិមិត្តណា ហើយអស់អាសវៈទាំងឡាយ ដោយឥតអន្តរាយនោះ សម័យនោះ ទើបជាសម័យគួរចូលទៅរកភិក្ខុដែលមានចិត្តចំរើន ហើយនិយាយយ៉ាងនេះនឹងភិក្ខុនោះថា ម្នាលអាវុសោ ខ្ញុំមិនដឹង មិនឃើញនិមិត្ត (ដែលខ្ញុំ) អាស្រ័យនិមិត្តណា ធ្វើទុកក្នុងចិត្តនូវនិមិត្តណា ហើយអស់អាសវៈទាំងឡាយ ដោយឥតអន្តរាយនោះ សូមលោកដ៏មានអាយុ អាណិតសំដែងធម៌ដល់ខ្ញុំ ដើម្បីឲ្យអស់អាសវៈទាំងឡាយ ភិក្ខុដែលមានចិត្តចំរើន តែងតែសំដែងធម៌ដល់ភិក្ខុនោះ ដើម្បីធ្វើឲ្យអស់អាសវៈទាំងឡាយ ។

អយំ ភិក្ខុ ឆដ្ឋោ សមយោ មនោភាវនីយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុំ ។ សម្មុខា មេ តំ អាវុសោ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ ឥមេ ខោ ភិក្ខុ ឆ សមយា មនោភាវនីយស្ស ភិក្ខុនោ ទស្សនាយ ឧបសង្កមិតុន្តិ ។

(២៩) អថខោ ភគវា អាយស្មន្តំ ឧទាយឹ អាមន្តេសិ កតិ នុ ខោ ឧទាយិ អនុស្សតិដ្ឋានានីតិ ។ ឯវំ វុត្តេ អាយស្មា ឧទាយិ តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ ភគវា អាយស្មន្តំ ឧទាយឹ អាមន្តេសិ កតិ នុ ខោ ឧទាយិ អនុស្សតិដ្ឋានានីតិ ។ ឯវំ វុត្តេ អាយស្មា ឧទាយិ តុណ្ហី អហោសិ ។ តតិយម្បិ ខោ ភគវា អាយស្មន្តំ ឧទាយឹ អាមន្តេសិ កតិ នុ ខោ ឧទាយិ អនុស្សតិដ្ឋានានីតិ ។ តតិយម្បិ ខោ អាយស្មា ឧទាយិ តុណ្ហី អហោសិ ។ អថខោ អាយស្មា អានន្ទោ អាយស្មន្តំ ឧទាយឹ ឯតទវោច សត្ថា តំ អាវុសោ ឧទាយិ អាមន្តេតីតិ ។ សុណោមហំ អាវុសោ អានន្ទ



ម្នាលភិក្ខុ នេះជាសម័យ ដែលគួរចូលទៅឃើញភិក្ខុដែលមានចិត្តចំរើន ទី ៦ ។ ម្នាលអាវុសោទាំងឡាយ ការនោះ ខ្ញុំបានស្ដាប់ចំពោះព្រះភក្រ្ត ខ្ញុំបានរៀនហើយចំពោះព្រះភក្រ្តព្រះដ៏មានព្រះភាគថា ម្នាលភិក្ខុ នេះឯងជាសម័យទាំង ៦ នេះ ដែលគួរចូលទៅឃើញភិក្ខុដែលមានចិត្តចំរើន ។

(២៩) គ្រានោះ ព្រះដ៏មានព្រះភាគត្រាស់ហៅព្រះឧទាយិដ៏មានអាយុថា ម្នាលឧទាយិ អនុស្សតិដ្ឋាន តើមានប៉ុន្មានយ៉ាង ។ កាលបើព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ ព្រះឧទាយិដ៏មានអាយុ ក៏នៅស្ងៀម ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងព្រះឧទាយិដ៏មានអាយុ អស់វារៈពីរដងថា ម្នាលឧទាយិ អនុស្សតិដ្ឋាន តើមានប៉ុន្មានយ៉ាង ។ កាលបើព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ ព្រះឧទាយិដ៏មានអាយុ ក៏នៅស្ងៀមទៀត ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងព្រះឧទាយិដ៏មានអាយុ ជាគំរប់បីដងថា ម្នាលឧទាយិ អនុស្សតិដ្ឋាន តើមានប៉ុន្មានយ៉ាង ។ ព្រះឧទាយិដ៏មានអាយុ ក៏នៅស្ងៀមអស់វារៈបីដងទៀត ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ បាននិយាយនឹងព្រះឧទាយិដ៏មានអាយុយ៉ាងនេះថា ម្នាលអាវុសោឧទាយិ ព្រះសាស្ដាទ្រង់ត្រាស់ហៅលោក ។ ម្នាលអាវុសោ អានន្ទ ខ្ញុំបានឮ ព្រះដ៏មានព្រះភាគហើយ

ភគវតោ ឥធ ភន្តេ ភិក្ខុ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ឥទំ ភន្តេ អនុស្សតិដ្ឋានន្តិ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ អញ្ញាសិំ ខោ អហំ អានន្ទ នេវាយំ ឧទាយី មោឃបុរិសោ អធិចិត្តមនុយុត្តោ វិហរតីតិ ។ កតិ នុ ខោ អានន្ទ អនុស្សតិដ្ឋានានីតិ ។ បញ្ច ភន្តេ អនុស្សតិដ្ឋានានិ ។ កតមានិ បញ្ច ។ ឥធ ភន្តេ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥទំ ភន្តេ អនុស្សតិដ្ឋានំ ឯវំ ភាវិតំ ឯវំ ពហុលីកតំ ទិដ្ឋធម្មសុខវិហារាយ សំវត្តតិ ។ បុន ចបរំ ភន្តេ ភិក្ខុ អាលោកសញ្ញំ មនសិករោតិ ទិវាសញ្ញំ អធិដ្ឋាតិ យថា ទិវា តថា រត្តឹ យថា រត្តឹ តថា ទិវា ឥតិ វិវដេន ចេតសា អបរិយោនទ្ធេន សប្បភាសំ ចិត្តំ ភាវេតិ ។



បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុក្នុងសាសនានេះ រឭកឃើញនូវបុព្វេនិវាសបានច្រើនប្រការគឺ ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ រឭកឃើញនូវបុព្វេនិវាសបានច្រើនប្រការព្រមទាំងអាការៈ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ បពិត្រព្រះអង្គដ៏ចំរើន ការរឭកឃើញជាតិនេះឈ្មោះថា អនុស្សតិដ្ឋាន ។ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ តថាគតដឹងច្បាស់ថា ឧទាយីនេះ ជាមោឃបុរស មិនមែនជាប្រកបរឿយ ៗ នូវអធិចិត្ត (សមាធិវិបស្សនា) ទេ ។ ម្នាលអានន្ទ អនុស្សតិដ្ឋាន តើមានប៉ុន្មានយ៉ាង ។ បពិត្រព្រះអង្គដ៏ចំរើន អនុស្សតិដ្ឋានមាន ៥ ។ ៥ យ៉ាង តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុក្នុងសាសនានេះ ស្ងាត់ស្រឡះចាកកាមទាំងឡាយ ។ បេ ។ ចូលតតិយជ្ឈាន ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាអនុស្សតិដ្ឋាន ដែលភិក្ខុចំរើនយ៉ាងនេះហើយ បានធ្វើរឿយ ៗ យ៉ាងនេះហើយ តែងប្រព្រឹត្តទៅ ដើម្បីជាសុខក្នុងបច្ចុប្បន្ន ។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត ភិក្ខុធ្វើទុកក្នុងចិត្តនូវសេចក្តីសំគាល់នូវពន្លឺ តម្កល់ទុកនូវសេចក្តីសំគាល់ថាថ្ងៃ គឺតាំងចិត្តក្នុងវេលាថ្ងៃយ៉ាងណា ក្នុងវេលាយប់ក៏យ៉ាងនោះ ក្នុងវេលាយប់យ៉ាងណា ក្នុងវេលាថ្ងៃក៏យ៉ាងនោះ ជាបុគ្គលមានចិត្តជាប្រក្រតី ដែលនីវរណៈរួបរឹតមិនបាន តែងចំរើនចិត្តប្រកបដោយពន្លឺ (ដើម្បីបានទិព្វចក្ខុ) ។

ឥទំ ភន្តេ អនុស្សតិដ្ឋានំ ឯវំ ភាវិតំ ឯវំ ពហុលីកតំ ញាណទស្សនប្បដិលាភាយ សំវត្តតិ ។ បុន ចបរំ ភន្តេ ភិក្ខុ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរន្នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ កេសា លោមា នខា ទន្តា តចោ មំសំ នហារូ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តន្តិ ។ ឥទំ ភន្តេ អនុស្សតិដ្ឋានំ ឯវំ ភាវិតំ ឯវំ ពហុលីកតំ កាមរាគស្ស បហានាយ សំវត្តតិ ។ បុន ចបរំ ភន្តេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ ឯកាហមតំ វា ទ្វីហមតំ វា តីហមតំ វា ឧទ្ធុមាតកំ វិនីលកំ វិបុព្វកជាតំ សោ ឥមមេវ កាយំ ឯវំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំអនតីតោតិ ។



បពិត្រព្រះអង្គដ៏ចំរើន នេះជាអនុស្សតិដ្ឋាន ដែលភិក្ខុបានចំរើនយ៉ាងនេះហើយ បានធ្វើរឿយ ៗ យ៉ាងនេះហើយ តែងប្រព្រឹត្តទៅ ដើម្បីបាននូវញាណទស្សនៈ ។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះ ខាងលើតាំងពីបាតជើង ខាងក្រោមតាំងពីចុងសក់ ទីបំផុតត្រឹមស្បែក ដែលពេញដោយគ្រឿងមិនស្អាត មានប្រការផ្សេង ៗ ថា ក្នុងកាយនេះមានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងនោម បេះដូង ថ្លើម វាវ ក្រពះ(១) សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករអិល ទឹកមូត្រ ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាអនុស្សតិដ្ឋាន ដែលភិក្ខុបានចំរើនយ៉ាងនេះហើយ បានធ្វើរឿយ ៗ យ៉ាងនេះហើយ តែងប្រព្រឹត្តទៅ ដើម្បីលះនូវកាមរាគៈ ។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត ដូចភិក្ខុណា ឃើញនូវសរីរៈ ដែលគេបោះចោលទៅក្នុងព្រៃស្មសាន ទោះស្លាប់១ថ្ងៃ ស្លាប់២ថ្ងៃ ស្លាប់៣ថ្ងៃ ជាសាកសពហើមប៉ោងមានសម្បុរខៀវដោយច្រើន មានខ្ទុះហូរចេញតាមទ្វារផ្សេង ៗ ភិក្ខុនោះប្រៀបធៀបនឹងកាយ (ខ្លួន) នេះ យ៉ាងនេះថា សូម្បីកាយនេះសោត ក៏មានសភាពដូច្នោះ គង់នឹងក្លាយទៅដូច្នោះ គង់មិនផុតដូច្នោះដែរ ។

១. ប្រែថា គម្រងទងស្លះ ២ ជា សន្លុះល្វាស ។

សេយ្យថា វា បន បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ កាកេហិ វា ខជ្ជមានំ កុលលេហិ វា ខជ្ជមានំ គិជ្ឈេហិ វា ខជ្ជមានំ សុវាណេហិ វា ខជ្ជមានំ សិង្គាលេហិ វា ខជ្ជមានំ វិវិធេហិ វា បាណកជាតេហិ ខជ្ជមានំ សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំអនតីតោតិ ។ សេយ្យថា វា បន បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ អដ្ឋិកសង្ខលិកំ សមំសលោហិតំ ន្ហារុសម្ពន្ធំ អដ្ឋិកសង្ខលិកំ និម្មំសលោហិតមក្ខិតំ ន្ហារុសម្ពន្ធំ អដ្ឋិកសង្ខលិកំ អបគតមំសលោហិតំ ន្ហារុសម្ពន្ធំ អដ្ឋិកានិ អបគតសម្ពន្ធានិ ទិសា វិទិសា វិក្ខិត្តានិ អញ្ញេន ហត្ថដ្ឋិកំ អញ្ញេន បាទដ្ឋិកំ អញ្ញេន ជង្ឃដ្ឋិកំ អញ្ញេន ឩរុដ្ឋិកំ អញ្ញេន កដិដ្ឋិកំ អញ្ញេន បិដ្ឋិកណ្ដកដ្ឋិកំ អញ្ញេន សីសកដាហំ សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំអនតីតោតិ



ពុំនោះសោត ដូចភិក្ខុណា ឃើញសរីរៈដែលគេបោះចោលក្នុងព្រៃស្មសាន ត្រូវពួកក្អែកជញ្ជីកស៊ី ពួកក្រសាក់ត្រសង់ជញ្ជីកស៊ី ពួកត្មាតជញ្ជីកស៊ី ពួកស្វានជញ្ជីកស៊ី ពួកចចកកញ្ជ្រោងស៊ី បាណកជាតិ (ពួកដង្កូវ) ផ្សេងៗ ត្រូវជញ្ជីកស៊ី ភិក្ខុនោះ ប្រៀបផ្ទឹមនឹងកាយនេះយ៉ាងនេះថា នេះកាយនេះសោត ក៏មានសភាពដូច្នោះ នឹងនឹងក្លាយទៅដូច្នោះ មិនកន្លងនូវយ៉ាងនោះទៅបានឡើយ ។ ឬថា ដូចភិក្ខុឃើញសរីរៈ ដែលគេបោះចោលក្នុងព្រៃស្មសានជាគ្រោងឆ្អឹង ប្រកបដោយសាច់នឹងឈាម មានសរសៃជាគ្រឿងចងភ្ជាប់ ឆ្អឹងឥតមានសាច់ គ្រាន់តែនៅប្រឡាក់ដោយឈាម ដែលជាប់គ្នាដោយសរសៃ ក៏ឆ្អឹងឥតមានសាច់នឹងឈាមជាប់គ្នា ដោយសរសៃជាគ្រឿងចងឆ្អឹងដែលដាច់ចេញហើយ ខ្ចាត់ខ្ចាយពាសពាយ ទៅក្នុងទិសតូចនឹងទិសធំ ឆ្អឹងដៃទៅដោយឡែក ឆ្អឹងជើងទៅដោយឡែក ឆ្អឹងស្មងទៅដោយឡែក ឆ្អឹងភ្លៅទៅដោយឡែក ឆ្អឹងចង្កេះទៅដោយឡែក ឆ្អឹងត្រកឆ្អឹងខ្នងទៅដោយឡែក លលាដ៍ក្បាលទៅដោយឡែក ភិក្ខុនោះ ប្រៀបផ្ទឹមនឹងកាយនេះយ៉ាងនេះថា កាយនេះសោត ក៏មានសភាពដូច្នោះ នឹងនឹងក្លាយទៅដូច្នោះ មិនកន្លងនូវភាពដូច្នោះក៏បានឡើយ

សេយ្យថាបិ បន បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ អដ្ឋិកានិ សេតានិ សង្ខវណ្ណូបនិភានិ អដ្ឋិកានិ បុញ្ជកិតានិ តេរោវស្សិកានិ បូតីនិ ចុណ្ណកជាតានិ សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំអនតីតោតិ ។ ឥទំ ភន្តេ អនុស្សតិដ្ឋានំ ឯវំ ភាវិតំ ឯវំ ពហុលីកតំ អស្មិមានសមុគ្ឃាតាយ សំវត្តតិ ។ បុន ចបរំ ភន្តេ ភិក្ខុ សុខស្ស ច បហានា ។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥទំ ភន្តេ អនុស្សតិដ្ឋានំ ឯវំ ភាវិតំ ឯវំ ពហុលីកតំ អនេកធាតុបដិវេធាយ សំវត្តតិ ។ ឥមានិ ខោ ភន្តេ បញ្ច អនុស្សតិដ្ឋានានីតិ ។ សាធុ សាធុ អានន្ទ តេនហិ ត្វំ អានន្ទ ឥមម្បិ ឆដ្ឋំ អនុស្សតិដ្ឋានំ ធារេហិ ឥធានន្ទ ភិក្ខុ សតោវ អភិក្កមតិ សតោវ បដិក្កមតិ សតោវ តិដ្ឋតិ សតោវ និសីទតិ សតោវ សេយ្យំ កប្បេតិ សតោវ កម្មំ អធិដ្ឋាតិ ។ ឥទំ អានន្ទ អនុស្សតិដ្ឋានំ ឯវំ ភាវិតំ ឯវំ ពហុលីកតំ សតិសម្បជញ្ញាយ សំវត្តតីតិ ។



មួយទៀត ម្យ៉ាង ដូចភិក្ខុឃើញឆ្អឹងសរីរៈដែលគេបោះចោលក្នុងព្រៃស្មសាន សល់នៅតែឆ្អឹងទទេ មានសម្បុរសដូចស័ង្ខ ពពូនឆ្អឹងដែលគេដាក់ពំនូក ឆ្អឹងហួស ១ ឆ្នាំ ហើយ ពុកផុយខ្ទេចខ្ទីជាកំទេច ភិក្ខុនោះ ប្រៀបធៀបនឹងកាយនេះយ៉ាងនេះថា ទោះជាកាយនេះក៏ដោយ ក៏មានសភាពយ៉ាងដូច្នោះ គង់នឹងក្លាយទៅដូច្នោះ នឹងកន្លងនូវភាពដូច្នោះពុំបានឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាអនុស្សតិដ្ឋាន ដែលភិក្ខុបានចំរើនយ៉ាងនេះ បានធ្វើឲ្យច្រើនយ៉ាងនេះហើយ តែងប្រព្រឹត្តទៅ ដើម្បីដកចោលនូវអស្មិមានះ ។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត ភិក្ខុលះបង់សេចក្ដីសុខផង ។បេ។ ចូលចតុត្ថជ្ឈាន ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាអនុស្សតិដ្ឋាន ដែលភិក្ខុបានចំរើនយ៉ាងនេះ បានធ្វើឲ្យច្រើនយ៉ាងនេះហើយ តែងប្រព្រឹត្តទៅដើម្បីត្រាស់ដឹងនូវធាតុច្រើនប្រការ ។ បពិត្រព្រះអង្គដ៏ចំរើន នេះឯងជាអនុស្សតិដ្ឋានទាំង ៥ ។ ម្នាលអានន្ទ ល្អហើយៗ ម្នាលអានន្ទ បើដូច្នោះ អ្នកចូរចាំទុកនូវអនុស្សតិដ្ឋានទី ៦ នេះថែមទៀតចុះ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ប្រុងស្មារតីឈានដើរទៅមុខ ប្រុងស្មារតីត្រឡប់មកវិញ ប្រុងស្មារតីឈរ ប្រុងស្មារតីដេក ប្រុងស្មារតីអធិដ្ឋានការងារ ។ ម្នាលអានន្ទ នេះជាអនុស្សតិដ្ឋាន ដែលភិក្ខុបានចំរើនយ៉ាងនេះ បានធ្វើឲ្យច្រើនយ៉ាងនេះ តែងប្រព្រឹត្តទៅ ដើម្បីបាននូវសតិសម្បជញ្ញៈ ។

(៣០) ឆយិមានិ ភិក្ខវេ អនុត្តរិយានិ ។ កតមានិ ឆ ។ ទស្សនានុត្តរិយំ សវនានុត្តរិយំ លាភានុត្តរិយំ សិក្ខានុត្តរិយំ បារិចរិយានុត្តរិយំ អនុស្សតានុត្តរិយំ ។ កតមញ្ច ភិក្ខវេ ទស្សនានុត្តរិយំ ។ ឥធ ភិក្ខវេ ឯកច្ចោ ហត្ថិរតនម្បិ ទស្សនាយ គច្ឆតិ អស្សរតនម្បិ ទស្សនាយ គច្ឆតិ មណិរតនម្បិ ទស្សនាយ គច្ឆតិ ឧច្ចាវចំ វា បន ទស្សនាយ គច្ឆតិ សមណំ វា ព្រាហ្មណំ វា មិច្ឆាទិដ្ឋិកំ មិច្ឆាបដិបន្នំ ទស្សនាយ គច្ឆតិ អត្ថេតំ ភិក្ខវេ ទស្សនំ នេតំ នត្ថីតិ វទាមិ តញ្ច ខោ ឯតំ ភិក្ខវេ ទស្សនំ ហីនំ គម្មំ បោថុជ្ជនិកំ អនរិយំ អនត្ថសញ្ហិតំ ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ ។ យោ ច ខោ ភិក្ខវេ តថាគតំ វា តថាគតសាវកំ វា ទស្សនាយ គច្ឆតិ





[៣០] ម្នាលភិក្ខុទាំងឡាយ អនុត្តរិយៈ (ធម៌ជាតប្រសើរបំផុត) នេះមាន ៦ ។ ៦ តើដូចម្តេច ។ គឺទស្សនានុត្តរិយៈ (ការឃើញដ៏ប្រសើរបំផុត) ១ សវនានុត្តរិយៈ (ការស្តាប់ប្រសើរបំផុត) ១ លាភានុត្តរិយៈ (ការបានប្រសើរបំផុត) ១ សិក្ខានុត្តរិយៈ (ការសិក្សាប្រសើរបំផុត) ១ បារិចរិយានុត្តរិយៈ (ការបម្រើប្រសើរបំផុត) ១ អនុស្សតានុត្តរិយៈ (ការរឭកប្រសើរបំផុត) ១ ។ ម្នាលភិក្ខុទាំងឡាយ ទស្សនានុត្តរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ទៅមើលដំរីកែវក្តី ទៅមើលសេះកែវក្តី ទៅមើលមណីកែវក្តី ឬក៏ទៅមើលរបស់ធំ តូចណាមួយក្តី ទៅមើលសមណៈ ឬព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិ អ្នកប្រតិបត្តិខុសក្តី ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការឃើញនុ៎ះ ឈ្មោះថាឃើញ ហើយ ការឃើញនុ៎ះមិនមែនជាមិនឃើញទេ ម្នាលភិក្ខុទាំងឡាយ តែថា ការឃើញនុ៎ះ ជារបស់ថោក សម្រាប់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរ ឥតប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីនឿយណាយទេ ដើម្បីប្រាសចាកតម្រេកទេ ដើម្បីរលត់កិលេសទេ ដើម្បីស្ងប់ទុក្ខទេ ដើម្បីដឹងប្រសើរទេ ដើម្បីត្រាស់ដឹងទេ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា ទៅឃើញតថាគត ឬសាវកនៃតថាគត

និវិដ្ឋសទ្ធោ និវិដ្ឋបេមោ ឯកន្តគតោ អភិប្បសន្នោ ឯតទានុត្តរិយំ ភិក្ខវេ ទស្សនានំ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ តថាគតំ វា តថាគតសាវកំ វា ទស្សនាយ គច្ឆតិ និវិដ្ឋសទ្ធោ និវិដ្ឋបេមោ ឯកន្តគតោ អភិប្បសន្នោ ឥទំ វុច្ចតិ ភិក្ខវេ ទស្សនានុត្តរិយំ ។ ឥតិ ទស្សនានុត្តរិយំ ។ សវនានុត្តរិយញ្ច កថំ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ ភេរិសទ្ទម្បិ សវនាយ គច្ឆតិ វីណាសទ្ទម្បិ សវនាយ គច្ឆតិ គីតសទ្ទម្បិ សវនាយ គច្ឆតិ ឧច្ចាវចំ វា បន សវនាយ គច្ឆតិ សមណស្ស វា ព្រាហ្មណស្ស វា មិច្ឆាទិដ្ឋិកស្ស មិច្ឆាបដិបន្នស្ស ធម្មស្សវនាយ គច្ឆតិ អត្ថេតំ ភិក្ខវេ សវនំ នេតំ នត្ថីតិ វទាមិ តញ្ច ខោ ឯតំ ភិក្ខវេ សវនំ ហីនំ គម្មំ បោថុជ្ជនិកំ អនរិយំ អនត្ថសញ្ហិតំ



ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ជ្រះថ្លាពិត ម្នាលភិក្ខុទាំងឡាយ ការឃើញនុ៎ះ ទើបប្រសើរបំផុតជាងការឃើញទាំងឡាយ (ក្រៅពីនេះទៅ) ដើម្បីសេចក្តីបរិសុទ្ធិរបស់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោកនឹងខ្សឹកខ្សួល ដើម្បីវិនាសទៅនៃទុក្ខនឹងទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺនៅត្រង់បុគ្គលទៅឃើញតថាគត ឬសាវ័កនៃតថាគត ហើយជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ជ្រះថ្លាពិត ម្នាលភិក្ខុទាំងឡាយ ការឃើញនេះ ទើបតថាគតឲ្យឈ្មោះថា ការឃើញប្រសើរបំផុត ។ ទស្សនានុត្តរិយៈ ដូច្នេះឯង ។ ចុះសវនានុត្តរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ទៅស្តាប់សំឡេងស្គរក្តី ទៅស្តាប់សំឡេងពិណក្តី ទៅស្តាប់សំឡេងចម្រៀងក្តី ឬក៏ទៅស្តាប់សំឡេងធំតូចណាមួយក្តី ទៅស្តាប់ធម៌របស់សមណៈឬព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិ អ្នកប្រតិបត្តិខុសក្តី ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការស្តាប់នុ៎ះ ក៏ឈ្មោះថាស្តាប់ដែរ ការស្តាប់នុ៎ះ មិនមែនជាមិនស្តាប់ទេ ម្នាលភិក្ខុទាំងឡាយ តែថាការស្តាប់នុ៎ះ ជារបស់ថោក សម្រាប់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរ ឥតប្រយោជន៍

ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ ។ យោ ច ខោ ភិក្ខវេ តថាគតស្ស វា តថាគតសាវកស្ស វា ធម្មស្សវនាយ គច្ឆតិ និវិដ្ឋសទ្ធោ និវិដ្ឋបេមោ ឯកន្តគតោ អភិប្បសន្នោ ឯតទានុត្តរិយំ ភិក្ខវេ សវនានំ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ តថាគតស្ស វា តថាគតសាវកស្ស វា ធម្មស្សវនាយ គច្ឆតិ និវិដ្ឋសទ្ធោ និវិដ្ឋបេមោ ឯកន្តគតោ អភិប្បសន្នោ ឥទំ វុច្ចតិ ភិក្ខវេ សវនានុត្តរិយំ ។ ឥតិ ទស្សនានុត្តរិយំ សវនានុត្តរិយំ ។ លាភានុត្តរិយញ្ច កថំ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុត្តលាភម្បិ លភតិ ទារលាភម្បិ លភតិ ធនលាភម្បិ លភតិ ឧច្ចាវចំ វា បន លាភំ លភតិ សមណេ វា ព្រាហ្មណេ វា មិច្ឆាទិដ្ឋិកេ មិច្ឆាបដិបន្នេ សទ្ធំ បដិលភតិ



មិនប្រព្រឹត្តទៅដើម្បីនឿយណាយទេ ដើម្បីប្រាសចាកតម្រេកទេ ដើម្បីរលត់កិលេសទេ ដើម្បីស្ងប់ទុក្ខទេ ដើម្បីដឹងប្រសើរទេ ដើម្បីត្រាស់ដឹងទេ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណាទៅស្តាប់ធម៌តថាគត ឬសាវ័កនៃតថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការស្តាប់នុ៎ះ ទើបប្រសើរបំផុតជាងការស្តាប់ទាំងឡាយ ប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធិដល់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសោកនិងខ្សឹកខ្សួល ដើម្បីអស់ទៅនៃទុក្ខនិងទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យច្បាស់នូវព្រះនិព្វាន គឺទៅក្រែងបុគ្គលទៅស្តាប់ធម៌តថាគត ឬសាវ័កនៃតថាគត ហើយជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការស្តាប់នេះ តថាគតហៅថា ការស្តាប់ប្រសើរបំផុត ។ ទស្សនានុត្តរិយៈ សវនានុត្តរិយៈ ដូច្នេះឯង ។ ចុះលាភានុត្តរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ បានលាភគឺកូនក្តី បានលាភគឺប្រពន្ធក្តី បានលាភគឺទ្រព្យក្តី ឬក៏បានលាភធំតូចណាមួយក្តី បានសេចក្តីជឿក្នុងសមណៈឬព្រាហ្មណ៍ជាមិច្ឆាទិដ្ឋិ អ្នកប្រតិបត្តិខុសក្តី

អត្ថេសោ ភិក្ខវេ លាភោ នេសោ នត្ថីតិ វទាមិ សោ ច ខោ ឯសោ ភិក្ខវេ លាភោ ហីនោ គម្មោ ពោថុជ្ជនិកោ អនរិយោ អនត្ថសញ្ហិតោ ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ ។ យោ ច ខោ ភិក្ខវេ តថាគតេ វា តថាគតសាវកេ វា សទ្ធំ បដិលភតិ និវិដ្ឋសទ្ធោ និវិដ្ឋបេមោ ឯកន្តគតោ អភិប្បសន្នោ ឯតទានុត្តរិយំ ភិក្ខវេ លាភានំ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ តថាគតេ វា តថាគតសាវកេ វា សទ្ធំ បដិលភតិ និវិដ្ឋសទ្ធោ និវិដ្ឋបេមោ ឯកន្តគតោ អភិប្បសន្នោ ឥទំ វុច្ចតិ ភិក្ខវេ លាភានុត្តរិយំ ។ ឥតិ ទស្សនានុត្តរិយំ សវនានុត្តរិយំ លាភានុត្តរិយំ ។



ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា លាភនុ៎ះ ក៏ជាលាភដែរហើយ មិនមែនជាលាភទេ ម្នាលភិក្ខុទាំងឡាយ តែថាលាភនុ៎ះ ជារបស់ថោក សម្រាប់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរ ឥតប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីនឿយណាយទេ ដើម្បីប្រាសចាកតម្រេកទេ ដើម្បីរលត់កិលេសទេ ដើម្បីស្ងប់ទុក្ខទេ ដើម្បីដឹងប្រសើរទេ ដើម្បីត្រាស់ដឹងទេ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណាបានសេចក្ដីជឿក្នុងតថាគត ឬក្នុងសាវករបស់តថាគត ហើយជាអ្នកមានសទ្ធាតាំងមាំ មានចិត្តស្រឡាញ់តាំងមាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការបាននុ៎ះប្រសើរបំផុតជាងលាភទាំងឡាយ ព្រោះប្រព្រឹត្តទៅ ដើម្បីសេចក្ដីបរិសុទ្ធិដល់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសោកនឹងខ្សឹកខ្សួល ដើម្បីរំលត់ទៅនៃទុក្ខនឹងទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺនៅត្រង់បុគ្គលបានសេចក្ដីជឿក្នុងតថាគត ឬក្នុងសាវករបស់តថាគត ហើយជាអ្នកមានសទ្ធាតាំងមាំ មានចិត្តស្រឡាញ់មាំ ជឿស៊ប់ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការបាននេះ ទើបតថាគតហៅថា ជាលាភប្រសើរបំផុត ។ ទស្សនានុត្តរិយៈ សវនានុត្តរិយៈ លាភានុត្តរិយៈដូច្នេះឯង ។

សិក្ខានុត្តរិយញ្ច កថំ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ ហត្ថិស្មិម្បិ សិក្ខតិ អស្សស្មិម្បិ សិក្ខតិ រថស្មិម្បិ សិក្ខតិ ធនុស្មិម្បិ សិក្ខតិ ថរុស្មិម្បិ សិក្ខតិ ឧច្ចាវចំ វា បន សិក្ខតិ សមណស្ស វា ព្រាហ្មណស្ស វា មិច្ឆាទិដ្ឋិកស្ស មិច្ឆាបដិបន្នស្ស សិក្ខតិ អត្ថេសា ភិក្ខវេ សិក្ខា នេសា នត្ថីតិ វទាមិ សា ច ខោ ឯសា ភិក្ខវេ សិក្ខា ហីនា គម្មា បោថុជ្ជនិកា អនរិយា អនត្ថសញ្ហិតា ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ ។ យោ ច ខោ ភិក្ខវេ តថាគតប្បវេទិតេ ធម្មវិនយេ អធិសីលម្បិ សិក្ខតិ អធិចិត្តម្បិ សិក្ខតិ អធិបញ្ញម្បិ សិក្ខតិ និវិដ្ឋសទ្ធោ និវិដ្ឋបេមោ ឯកន្តគតោ អភិប្បសន្នោ ឯតទានុត្តរិយំ ភិក្ខវេ សិក្ខានំ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ



ចំណែកខាងសិក្ខានុត្តរិយៈ តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ សិក្សាវិជ្ជាដំរីខ្លះ សិក្សាវិជ្ជាសេះខ្លះ សិក្សាវិជ្ជារថខ្លះ សិក្សាវិជ្ជាធ្នូខ្លះ សិក្សាវិជ្ជាដាវខ្លីខ្លះ ឬក៏សិក្សាវិជ្ជាខ្ពស់ទាបខ្លះ សិក្សា (វិជ្ជា) របស់សមណៈ ឬព្រាហ្មណ៍ជាមិច្ឆាទិដ្ឋិ អ្នកប្រតិបត្តិខុសខ្លះ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការសិក្សានុ៎ះ ក៏ជាការសិក្សាហើយ មិនមែនមិនសិក្សាទេ ម្នាលភិក្ខុទាំងឡាយ តែថា ការសិក្សានុ៎ះ ជារបស់ថោក សម្រាប់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរ ឥតប្រយោជន៍ មិនប្រព្រឹត្តទៅដើម្បីនឿយណាយទេ ដើម្បីប្រាសចាកតម្រេកទេ ដើម្បីរលត់កិលេសទេ ដើម្បីរម្ងាប់ទុក្ខទេ ដើម្បីដឹងប្រសើរទេ ដើម្បីត្រាស់ដឹងទេ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា សិក្សានូវអធិសីល សិក្សានូវអធិចិត្ត សិក្សានូវអធិបញ្ញា ក្នុងធម្មវិន័យ ដែលតថាគតសំដែងហើយ ជាអ្នកមានសទ្ធាតាំងខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការសិក្សានុ៎ះ ប្រសើរបំផុតជាងការសិក្សាទាំងឡាយ ព្រោះប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធិ ដល់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសោកនិងខ្សឹកខ្សួល ដើម្បីរលត់ទៅនៃទុក្ខនិងទោមនស្ស

ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ តថាគតប្បវេទិតេ ធម្មវិនយេ អធិសីលស្មឹ សិក្ខតិ អធិចិត្តស្មឹ សិក្ខតិ អធិបញ្ញាស្មឹ សិក្ខតិ និវិដ្ឋសទ្ធោ និវិដ្ឋប្បេមោ ឯកន្តគតោ អភិប្បសន្នោ ឥទំ វុច្ចតិ ភិក្ខវេ សិក្ខានុត្តរិយំ ។ ឥតិ ទស្សនានុត្តរិយំ សវនានុត្តរិយំ លាភានុត្តរិយំ សិក្ខានុត្តរិយំ ។ បារិចរិយានុត្តរិយញ្ច កថំ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ ខត្តិយម្បិ បរិចរតិ ព្រាហ្មណម្បិ បរិចរតិ គហបតិម្បិ បរិចរតិ ឧច្ចាវចំ វា បន បរិចរតិ សមណំ វា ព្រាហ្មណំ វា មិច្ឆាបដិបន្នំ បរិចរតិ អត្ថេសា ភិក្ខវេ បារិចរិយា នេសា នត្ថីតិ វទាមិ សា ច ខោ ឯសា ភិក្ខវេ បារិចរិយា ហីនា គម្មា បោថុជ្ជនិកា អនរិយា អនត្ថសញ្ហិតា ន និព្វិទាយ ។បេ។ ន និព្វានាយ សំវត្តតិ ។ យោ ច ខោ ភិក្ខវេ តថាគតំ វា តថាគតសាវកំ វា បរិចរតិ និវិដ្ឋសទ្ធោ និវិដ្ឋប្បេមោ ឯកន្តគតោ អភិប្បសន្នោ



ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺនៅត្រង់បុគ្គលសិក្សានូវអធិសីលក្តី សិក្សានូវអធិចិត្តក្តី សិក្សានូវអធិបញ្ញាក្តី ក្នុងធម្មវិន័យ ដែលតថាគតសំដែងហើយ ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការសិក្សានេះ តថាគតហៅថា សិក្ខាប្រសើរបំផុត ។ ទស្សនានុត្តរិយៈ សវនានុត្តរិយៈ លាភានុត្តរិយៈ សិក្ខានុត្តរិយៈ ដូច្នេះឯង ។ ចុះបារិចរិយានុត្តរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ បម្រើក្សត្រិយ៍ក្តី បម្រើព្រាហ្មណ៍ក្តី បម្រើគហបតីក្តី ឬបម្រើបុគ្គលធំតូចណាមួយក្តី បម្រើសមណៈ ឬព្រាហ្មណ៍ជាមិច្ឆាទិដ្ឋិ អ្នកប្រតិបត្តិខុសក្តី ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការបម្រើនុ៎ះ ក៏ជាការបម្រើហើយ មិនមែនមិនបម្រើទេ ម្នាលភិក្ខុទាំងឡាយ តែថា ការបម្រើនុ៎ះ ជារបស់ថោក សម្រាប់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរ ឥតប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីនឿយណាយទេ ។បេ។ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា បម្រើតថាគត ឬសាវ័ករបស់តថាគត ហើយជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង

ឯតទានុត្តរិយំ ភិក្ខវេ បារិចរិយានំ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ តថាគតំ វា តថាគតសាវកំ វា បរិចរតិ និវិដ្ឋសទ្ធោ និវិដ្ឋប្បេមោ ឯកន្តគតោ អភិប្បសន្នោ ឥទំ វុច្ចតិ ភិក្ខវេ បារិចរិយានុត្តរិយំ ។ ឥតិ ទស្សនានុត្តរិយំ សវនានុត្តរិយំ លាភានុត្តរិយំ សិក្ខានុត្តរិយំ បារិចរិយានុត្តរិយំ ។ អនុស្សតានុត្តរិយញ្ច កថំ ហោតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុត្តលាភម្បិ អនុស្សរតិ ទារលាភម្បិ អនុស្សរតិ ធនលាភម្បិ អនុស្សរតិ ឧច្ចាវចំ វា បន លាភំ អនុស្សរតិ សមណំ វា ព្រាហ្មណំ វា មិច្ឆាទិដ្ឋិកំ មិច្ឆាបដិបន្នំ អនុស្សរតិ អត្ថេសា ភិក្ខវេ អនុស្សតិ នេសា នត្ថីតិ វទាមិ សា ច ខោ ឯសា ភិក្ខវេ អនុស្សតិ ហីនា គម្មា បោថុជ្ជនិកា អនរិយា



ម្នាលភិក្ខុទាំងឡាយ ការបម្រើនុ៎ះ ប្រសើរបំផុតជាងការបម្រើទាំងឡាយ ព្រោះប្រព្រឹត្តទៅ ដើម្បីសេចក្ដីបរិសុទ្ធ ដល់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសោកនិងខ្សឹកខ្សួល ដើម្បីរំលត់ទៅនៃទុក្ខនិងទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺនៅត្រង់បុគ្គលបម្រើតថាគត ឬសាវករបស់តថាគត ហើយជាអ្នកមានសទ្ធាតាំងមាំ មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការបម្រើនេះ តថាគតហៅថា ការបម្រើប្រសើរបំផុត ។ ម្នាលភិក្ខុទាំងឡាយ ទស្សនានុត្តរិយៈ សវនានុត្តរិយៈ លាភានុត្តរិយៈ សិក្ខានុត្តរិយៈ បារិចរិយានុត្តរិយៈ ដូច្នេះឯង ។ ចំណែកអនុស្សតានុត្តរិយៈ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ រឭកនូវការបាននូវបុត្ត រឭកនូវការបាននូវប្រពន្ធ រឭកនូវការបាននូវទ្រព្យ ឬរឭកនូវការបានរបស់តូចធំ រឭកនូវសមណៈ ឬព្រាហ្មណ៍ជាមិច្ឆាទិដ្ឋិ អ្នកប្រតិបត្តិខុសក្ដី ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការរឭកនុ៎ះ ក៏ឈ្មោះថា រឭកដែរ មិនមែនមិនរឭកទេ ម្នាលភិក្ខុទាំងឡាយ តែថាការរឭកនុ៎ះ ជារបស់ថោក សម្រាប់អ្នកស្រុកជារបស់បុថុជ្ជន មិនប្រសើរ

អនត្តសញ្ញិតា ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ ។ យោ ច ខោ ភិក្ខវេ តថាគតំ វា តថាគតសាវកំ វា អនុស្សរតិ និវិដ្ឋសទ្ធោ និវិដ្ឋបេមោ ឯកន្តគតោ អភិប្បសន្នោ ឯតទានុត្តរិយំ ភិក្ខវេ អនុស្សតីនំ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ តថាគតំ វា តថាគតសាវកំ វា អនុស្សរតិ និវិដ្ឋសទ្ធោ និវិដ្ឋបេមោ ឯកន្តគតោ អភិប្បសន្នោ ឥទំ វុច្ចតិ ភិក្ខវេ អនុស្សតានុត្តរិយំ ។ ឥមានិ ខោ ភិក្ខវេ ឆ អនុត្តរិយានីតិ ។

ទស្សនានុត្តរិយំ លទ្ធា សវនញ្ច អនុត្តរំ
លាភានុត្តរិយំ លទ្ធា សិក្ខានុត្តរិយេ រតា



ឥតប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីនឿយណាយទេ ដើម្បីប្រាសចាកតម្រេកទេ ដើម្បីរលត់កិលេសទេ ដើម្បីស្ងប់ទុក្ខទេ ដើម្បីដឹងប្រសើរទេ ដើម្បីត្រាស់ដឹងទេ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា រឭកនូវតថាគត ឬសាវ័ករបស់តថាគត ហើយជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាពិត ម្នាលភិក្ខុទាំងឡាយ សេចក្ដីរឭកនុ៎ះ ប្រសើរបំផុតជាងសេចក្ដីរលឹកទាំងឡាយក្រៅប្រព្រឹត្តទៅ ដើម្បីសេចក្ដីបរិសុទ្ធ ដល់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសោកនិងខ្សឹកខ្សួល ដើម្បីរំលត់ទៅនៃទុក្ខនិងទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវនិព្វាន គឺនៅត្រង់បុគ្គលរឭកនូវតថាគត ឬសាវ័ករបស់តថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាពិត ម្នាលភិក្ខុទាំងឡាយ ការរឭកនេះ ទើបតថាគតហៅថា ការរឭកប្រសើរបំផុត ។ ម្នាលភិក្ខុទាំងឡាយ នេះឯងអនុត្តរិយៈទាំង ៦ យ៉ាង ។

បុគ្គលណាបាន នូវទស្សនានុត្តរិយៈផង នូវសវនានុត្តរិយៈ
ផង បាននូវលាភានុត្តរិយៈផង ត្រេកអរក្នុងសិក្ខានុត្តរិយៈផង

ឧបដ្ឋិតា បារិចរិយេ ភាវយន្តិ អនុស្សតិំ
វិវេកបដិសញ្ញុត្តំ ខេមំ អមតគាមិនិំ
អប្បមាទេ បមុទិតា និបកា សីលសំវុតា
តេ វេ កាលេន បច្ចន្តិ យត្ថ ទុក្ខំ និរុជ្ឈតីតិ ។

អនុត្តរិយវគ្គោ តតិយោ ។

## តស្សុទ្ទានំ

សាមកោ អបរិហានិយោ
ភយំ ហិមវំ អនុស្សតិ(១)
កច្ចានោ ទ្វេ ច សមយា
ឧទាយិ អនុត្តរិយានិ ។

---
១ ម. ឧ. ហេមវានុស្សតិ ។



តាំងនៅក្នុងបារិចរិយានុត្តរិយៈ ចំរើននូវអនុស្សតានុត្តរិយៈ ដែលប្រកបដោយវិវេក ជាក្សេមជាគ្រឿងដល់នូវនិព្វាន ដឹង ក្នុងខណៈនោះ រីករាយក្នុងសេចក្តីមិនប្រមាទ មានបញ្ញាចាស់ ស្រួមហើយក្នុងសីល រមែងដឹងនូវអមតនិព្វាន ដែលជាទីរលត់ទុក្ខ តាមកាលដ៏គួរ ។

ចប់ អនុត្តរិយវគ្គ ទី ៣ ។

## ឧទ្ទាននៃអនុត្តរិយវគ្គនោះគឺ

ព្រះដ៏មានព្រះភាគទ្រង់សំដែងសាមកសូត្រ ១ សូត្រ អបរិហានិយធម៌ ១ សូត្រ ភ័យជាឈ្មោះរបស់កាមជាដើម ១សូត្រ ភិក្ខុតាំងនៅលើភ្នំហិមពាន្ត ១ សូត្រ ភិក្ខុរមែងរលឹក ១ សូត្រ ព្រះមហាកច្ចានៈ ១ សូត្រ សម័យ ២ សូត្រ ឧទាយិត្ថេរ ១ សូត្រ អនុត្តរិយៈ ១ សូត្រ ។

## សេក្ខបរិហានិយវគ្គោ

(៣១) ឆយិមេ ភិក្ខវេ ធម្មា សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ ។ កតមេ ឆ ។ កម្មារាមតា ភស្សារាមតា និទ្ទារាមតា សង្គណិការាមតា ឥន្ទ្រិយេសុ អគុត្តទ្វារតា ភោជនេ អមត្តញ្ញុតា ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មា សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ ។ ឆយិមេ ភិក្ខវេ ធម្មា សេក្ខស្ស ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ ឆ ។ ន កម្មារាមតា ន ភស្សារាមតា ន និទ្ទារាមតា ន សង្គណិការាមតា ឥន្ទ្រិយេសុ គុត្តទ្វារតា ភោជនេ មត្តញ្ញុតា ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មា សេក្ខស្ស ភិក្ខុនោ អបរិហានាយ សំវត្តន្តីតិ ។

(៣២) អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា

## សេក្ខបរិហានិយវគ្គ

(៣១) ម្នាលភិក្ខុទាំងឡាយ ធម៌ ៦ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បី សេចក្តីសាបសូន្យ (តាមគុណធម៌ជាន់លើ) ដល់ភិក្ខុជាសេក្ខៈ (ទាំងពួក) ។ ធម៌ ៦ យ៉ាង ដូចម្តេចខ្លះ ។ គឺសេចក្តីត្រេកអរក្នុងការងារ ១ សេចក្តីត្រេកអរក្នុងការពោល ១ សេចក្តីត្រេកអរក្នុងការដេក ១ សេចក្តីត្រេកអរក្នុងពួកគណៈ ១ មិនមានសេចក្តីគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ១ មិនដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៦ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ ដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៦ យ៉ាងនេះប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យ ដល់ភិក្ខុជាសេក្ខៈ ។ ធម៌ ៦ យ៉ាងដូចម្តេចខ្លះ ។ គឺ សេចក្តីមិនត្រេកអរក្នុងការងារ ១ សេចក្តីមិនត្រេកអរក្នុងការពោល ១ សេចក្តីមិនត្រេកអរក្នុងការដេក ១ សេចក្តីមិនត្រេកអរក្នុងពួកគណៈ ១ គ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ ដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៦ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យ ដល់ភិក្ខុជាសេក្ខៈ ។

(៣២) គ្រានោះ មានទេវតា ១ អង្គ កាលរាត្រីបឋមយាមកន្លងហើយ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនទាំងអស់ឲ្យភ្លឺស្វាង

យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ ឯតទវោច ឆយិមេ ភន្តេ ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ ឆ ។ សត្ថុគារវតា ធម្មគារវតា សង្ឃគារវតា សិក្ខាគារវតា អប្បមាទគារវតា បដិសន្ថារគារវតា ។ ឥមេ ខោ ភន្តេ ឆ ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តីតិ ។ ឥទមវោច សា ទេវតា ។ សមនុញ្ញោ សត្ថា អហោសិ ។ អថខោ សា ទេវតា សមនុញ្ញោ មេ សត្ថាតិ ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយិ ។ អថខោ ភគវា តស្សា រត្តិយា អច្ចយេន ភិក្ខូ អាមន្តេសិ ឥមំ ភិក្ខវេ រត្តឹ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។



ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះទេវតានោះ ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៦ យ៉ាងនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៦ យ៉ាងដូចម្តេចខ្លះ ។ គឺសេចក្តីគោរពក្នុងព្រះសាស្តា ១ សេចក្តីគោរពក្នុងព្រះធម៌ ១ សេចក្តីគោរពក្នុងព្រះសង្ឃ ១ សេចក្តីគោរពក្នុងសិក្ខា ១ សេចក្តីគោរពក្នុងអប្បមាទធម៌ ១ សេចក្តីគោរពក្នុងបដិសន្ថារៈ ១ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៦ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុ ។ ទេវតានោះ បានក្រាបទូលដូច្នេះហើយ ។ ព្រះសាស្តាក៏មានព្រះហឫទ័យរីករាយ ។ លុះទេវតានោះដឹងថា ព្រះសាស្តាមានព្រះហឫទ័យរីករាយនឹងអាត្មាហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគធ្វើប្រទក្សិណ ហើយក៏បាត់ក្នុងទីនោះឯង ។ លុះដល់រាត្រី បឋមយាមនោះ កន្លងហើយ ព្រះដ៏មានព្រះភាគ ក៏ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ យប់មិញនេះ មានទេវតា ១ រូប កាលរាត្រី បឋមយាមកន្លងហើយ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនទាំងអស់ឲ្យភ្លឺស្វាង ចូលមករកតថាគត លុះចូលមកដល់ថ្វាយបង្គំតថាគត ហើយឋិតនៅ ក្នុងទីដ៏សមគួរ ។

ឯកមន្តំ ឋិតា ខោ ភិក្ខវេ សា ទេវតា មំ ឯតទវោច ឆយិមេ ភន្តេ ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ ឆ ។ សត្ថុគារវតា ធម្មគារវតា សង្ឃគារវតា សិក្ខាគារវតា អប្បមាទគារវតា បដិសន្ថារគារវតា ។ ឥមេ ខោ ភន្តេ ឆ ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តីតិ ។ ឥទមវោច ភិក្ខវេ សា ទេវតា ឥទំ វត្វា មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

សត្ថុគរុ ធម្មគរុ សង្ឃេ ច តិព្វគារវោ
អប្បមាទគរុ ភិក្ខុ បដិសន្ថារគារវោ
អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេតិ ។

(៣៣) ឥមំ ភិក្ខវេ រត្តឹ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ



ម្នាលភិក្ខុទាំងឡាយ លុះទេវតានោះ ឋិតនៅក្នុងទីសមគួរហើយ បាននិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៦ យ៉ាងនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៦ យ៉ាងដូចម្តេចខ្លះ ។ គឺសេចក្តីគោរពក្នុងព្រះសាស្តា ១ សេចក្តីគោរពក្នុងព្រះធម៌ ១ សេចក្តីគោរពក្នុងព្រះសង្ឃ ១ សេចក្តីគោរពក្នុងសិក្ខា ១ សេចក្តីគោរពក្នុងអប្បមាទធម៌ ១ សេចក្តីគោរពក្នុងបដិសន្ថារៈ ១ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៦ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ទេវតានោះបាននិយាយដូច្នេះ លុះនិយាយដូច្នេះហើយ ក៏ថ្វាយបង្គំតថាគតធ្វើប្រទក្សិណ ហើយបាត់ក្នុងទីនោះឯង ។

ភិក្ខុអ្នកគោរពក្នុងព្រះសាស្តា គោរពក្នុងព្រះធម៌ គោរព
ដ៏ក្លៀវក្លាក្នុងព្រះសង្ឃ (គោរពក្នុងសិក្ខា) គោរពក្នុងសេចក្តី
មិនប្រមាទ គោរពក្នុងបដិសន្ថារៈហើយ មិនគួរ ដើម្បី
សាបសូន្យ រមែងតាំងនៅ ក្នុងទីជិតនៃព្រះនិព្វាន ។

(៣៣) ម្នាលភិក្ខុទាំងឡាយ យប់មិញនេះ មានទេវតា ១ រូប កាលរាត្រីបឋមយាមកន្លងហើយ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនទាំងអស់ឲ្យភ្លឺស្វាង ចូលមករកតថាគត លុះចូលមកដល់ថ្វាយបង្គំតថាគត

អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ ភិក្ខវេ សា ទេវតា មំ ឯតទវោច ឆយិមេ ភន្តេ ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ ឆ ។ សត្ថុគារវតា ធម្មគារវតា សង្ឃគារវតា សិក្ខាគារវតា ហិរិគារវតា ឱត្តប្ប-គារវតា ។ ឥមេ ខោ ភន្តេ ឆ ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តីតិ ។ ឥទមវោច ភិក្ខវេ សា ទេវតា ឥទំ វត្វា មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

សត្ថុគរុ ធម្មគរុ សង្ឃេ ច តិព្វគារវោ
ហិរិឱត្តប្បសម្បន្នោ សប្បតិស្សោ សគារវោ
អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេតិ ។

(៣៤) ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មតោ មហាមោគ្គល្លានស្ស រហោគតស្ស បដិសល្លីនស្ស



ហើយឋិតក្នុងទីសមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះទេវតានោះ ឋិតក្នុងទីសមគួរហើយ បាននិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៦ យ៉ាងនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៦ យ៉ាងដូចម្តេចខ្លះ ។ គឺសេចក្តីគោរពក្នុងព្រះសាស្តា ១ សេចក្តីគោរពក្នុងព្រះធម៌ ១ សេចក្តីគោរពក្នុងព្រះសង្ឃ ១ សេចក្តីគោរពក្នុងសិក្ខា ១ សេចក្តីគោរពក្នុងការខ្មាសបាប ១ សេចក្តីគោរពក្នុងការខ្លាចបាប ១ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៦ យ៉ាងនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ទេវតានោះ បាននិយាយដូច្នេះ លុះបាននិយាយដូច្នេះហើយ ក៏ថ្វាយបង្គំតថាគត ធ្វើបទក្សិណ ហើយបាត់ក្នុងទីនោះឯង ។

ភិក្ខុអ្នកគោរពក្នុងព្រះសាស្តា គោរពក្នុងព្រះធម៌ គោរពដ៏
ក្រៃក្នុងព្រះសង្ឃ (គោរពក្នុងសិក្ខា) បរិបូណ៌ដោយហិរិ
និងឱត្តប្បៈប្រកបដោយសេចក្តីកោតក្រែងមានសេចក្តីគោរព មិនគួរ
ដើម្បីសាបសូន្យ រមែងតាំងនៅ ក្នុងទីជិតនៃព្រះនិព្វាន ។

(៣៤) សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ចូលទៅកាន់ទីស្ងាត់ គួរសម្ង៍

ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ កតមេសានំ ទេវានំ ឯវំ ញាណំ ហោតិ សោតាបន្នត្ត(១) អវិនិបាត-ធម្មា និយតា សម្ពោធិបរាយនាតិ ។ តេន ខោ បន សមយេន តិស្សោ នាម ភិក្ខុ អចិរំ កាលកតោ អញ្ញតរំ ព្រហ្មលោកំ ឧបបន្នោ ហោតិ ។ តត្រាបិ នំ ឯវំ ជានន្តិ តិស្សោ ព្រហ្មា មហិទ្ធិកោ មហានុ-ភាវោតិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ សេយ្យថាបិ នាម ពលវា បុរិសោ សមិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សមិញ្ជេយ្យ ឯវមេវ ជេតវនេ អន្តរហិតោ តស្មិំ ព្រហ្មលោកេ បាតុរហោសិ ។ អទ្ទសា ខោ តិស្សោ ព្រហ្មា អាយស្មន្តំ មហាមោគ្គល្លានំ ទូរតោវ អាគច្ឆន្តំ ទិស្វាន អាយស្មន្តំ មហាមោគ្គល្លានំ ឯតទ-វោច ឯហិ ខោ មារិស មោគ្គល្លាន ស្វាគតំ មារិស មោគ្គល្លាន ចិរស្សំ ខោ មារិស មោគ្គល្លាន ឥមំ បរិយាយមកាសិ យទិទំ ឥធាគមនាយ និសីទ មារិស មោគ្គល្លាន ឥទមាសនំ បញ្ញត្តំ ។

១ ម. ឆ. សោតាបន្នោ ។



ហើយមានសេចក្តីត្រិះរិះក្នុងចិត្ត កើតឡើងយ៉ាងនេះថា ពួកទេវតាណា មានសេចក្តីដឹងថា យើងទាំងឡាយ ជាអ្នកដល់នូវសោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង បានត្រាស់ដឹងនៅខាងមុខ យ៉ាងនេះដែរឬទេ ។ សម័យនោះ មានភិក្ខុឈ្មោះតិស្សៈ ធ្វើមរណកាលថ្មីៗ បានទៅកើតក្នុងព្រហ្មលោកណាមួយ ។ ឯពួកព្រហ្ម ក្នុងព្រហ្មលោកនោះ ក៏ស្គាល់ព្រហ្មនោះ យ៉ាងនេះថា នេះជាព្រហ្មឈ្មោះតិស្សៈ មានឫទ្ធិច្រើន មានអានុភាពច្រើន ។ គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ បាត់អំពីវត្តជេតពន ទៅប្រាកដ ឯព្រហ្មលោកនោះ ដូចជាបុរសដ៏មានកំឡាំង លាដៃដែលខ្លួនបត់ ឬបត់ដៃដែលខ្លួនលា ដូច្នោះឯង ។ តិស្សព្រហ្ម បានឃើញព្រះមហាមោគ្គល្លានដ៏មានអាយុ កំពុងនិមន្តមកអំពីចម្ងាយ លុះឃើញហើយ ក៏បាននិយាយ នឹងព្រះមហាមោគ្គល្លានដ៏មានអាយុយ៉ាងនេះថា បពិត្រព្រះមោគ្គល្លានដ៏ម្ចាស់ សូមលោកនិមន្តចូលមកចុះ បពិត្រព្រះមោគ្គល្លានដ៏ម្ចាស់ លោកនិមន្តមកស្រួលហើយ បពិត្រព្រះមោគ្គល្លានដ៏ម្ចាស់ លោកបានធ្វើបរិយាយនេះ ដើម្បីមកក្នុងទីនេះ អស់កាលយូរណាស់ហើយហ្ន៎ បពិត្រព្រះមោគ្គល្លានដ៏ម្ចាស់ សូមលោកគង់ចុះ នេះជាអាសនៈដែលខ្ញុំក្រាលប្រគេន ។

និសីទិ ខោ អាយស្មា មហាមោគ្គល្លានោ បញ្ញត្តេ អាសនេ ។ តិស្សោបិ ព្រហ្មា អាយស្មន្តំ មហា-មោគ្គល្លានំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ តិស្សំ ព្រហ្មានំ អាយស្មា មហាមោគ្គល្លានោ ឯតទវោច កតមេសានំ ខោ តិស្ស ទេវានំ ឯវំ ញាណំ ហោតិ សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយនាតិ ។ ចាតុម្មហារាជិកានំ ខោ មារិស មោគ្គល្លាន ទេវានំ ឯវំ ញាណំ ហោតិ សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយនាតិ ។ សព្វេសញ្ញេវ នុ ខោ តិស្ស ចាតុម្មហារាជិកានំ ទេវានំ ឯវំ ញាណំ ហោតិ សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិ-បរាយនាតិ ។ ន ខោ មារិស មោគ្គល្លាន សព្វេសំ ចាតុម្មហារាជិកានំ ទេវានំ ឯវំ ញាណំ ហោតិ សោតា-បន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយនាតិ ។



*ព្រះមហាមោគ្គល្លានដ៏មានអាយុ គង់លើអាសនៈ ដែលតិស្សព្រហ្ម ក្រាលប្រគេន ។ ឯតិស្សព្រហ្ម ថ្វាយបង្គំព្រះមហាមោគ្គល្លានដ៏មានអាយុហើយ អង្គុយក្នុងទីសមគួរ លុះតិស្សព្រហ្ម អង្គុយក្នុងទីសមគួរហើយ ព្រះមហា-មោគ្គល្លានដ៏មានអាយុ មានថេរដីកាយ៉ាងនេះថា ម្នាលតិស្សៈ ពួកទេវតាណាខ្លះ មានសេចក្តីដឹងថា យើងជាអ្នកដល់សោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង បានត្រាស់ដឹងទៅខាងមុខ យ៉ាងនេះ ។ តិស្សទេវ បពិត្រព្រះមោគ្គល្លានដ៏ចំរើន ពួកទេវតា ជាន់ចាតុម្មហារាជិកៈ មានសេចក្តីដឹងថា យើងជាអ្នកដល់សោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង នឹងបានត្រាស់ដឹងទៅខាងមុខ យ៉ាងនេះដែរ ។ ម្នាលតិស្សៈ ពួកទេវតា ជាន់ចាតុម្មហារាជិកៈទាំងអស់ មានសេចក្តីដឹងថា យើងជាអ្នកដល់សោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង នឹងមានសេចក្តីត្រាស់ដឹងទៅខាងមុខ យ៉ាងនេះដែរ ឬដូចម្តេច ។ បពិត្រព្រះមោគ្គល្លានដ៏ចំរើន ពួកទេវតា ជាន់ចាតុម្មហារាជិកៈ មិនមានសេចក្តីដឹងថា យើងជាអ្នកដល់សោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង នឹងមានសេចក្តីត្រាស់ដឹងទៅខាងមុខយ៉ាងនេះ ទាំងអស់គ្នាទេ ។*

យេ ខោ តេ មារិស មោគ្គល្លាន ចាតុម្មហារាជិកា ទេវា ពុទ្ធេ អវេច្ចប្បសាទេន អសមន្នាគតា ធម្មេ អវេច្ចប្បសាទេន អសមន្នាគតា សង្ឃេ អវេច្ចប្បសាទេន អសមន្នាគតា អរិយកន្តេហិ សីលេហិ អសមន្នាគតា តេសំ ន ឯវំ ញាណំ ហោតិ សោតាបន្នាម្ហ អវិនិបាតធម្មា និយតា សម្ពោធិបរាយណាតិ ។ យេ ច ខោ តេ មារិស មោគ្គល្លាន ចាតុម្មហារាជិកា ទេវា ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតា ធម្មេ អវេច្ចប្បសាទេន សមន្នាគតា សង្ឃេ អវេច្ចប្បសាទេន សមន្នាគតា អរិយកន្តេហិ សីលេហិ សមន្នាគតា តេសំ ឯវំ ញាណំ ហោតិ សោតាបន្នាម្ហ អវិនិបាតធម្មា និយតា សម្ពោធិបរាយណាតិ ។ ចាតុម្មហារាជិកានញ្ញេវ ខោ តិស្ស ទេវានំ ឯវំ ញាណំ ហោតិ សោតាបន្នាម្ហ អវិនិបាតធម្មា និយតា សម្ពោធិបរាយណាតិ ឧទាហុ តាវត្តឹសានម្បិ ទេវានំ ។ បេ ។ យាមានម្បិ ទេវានំ តុសិតានម្បិ ទេវានំ និម្មានរតីនម្បិ ទេវានំ បរនិម្មិតវសវត្តីនម្បិ ទេវានំ ឯវំ ញាណំ ហោតិ



បពិត្រព្រះមោគ្គល្លានដ៏ម្ចាស់ ពួកចាតុម្មហារាជិកទេវតាណា មិនប្រកបដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុងព្រះពុទ្ធ មិនប្រកបដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុងព្រះធម៌ មិនប្រកបដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុងព្រះសង្ឃ មិនប្រកបដោយសីលទាំងឡាយ ដែលព្រះអរិយៈត្រេកអរហើយ ពួកចាតុម្មហារាជិកទេវតានោះ មិនមានសេចក្តីដឹងថា យើងជាអ្នកដល់នូវសោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង នឹងមានសេចក្តីត្រាស់ដឹងទៅខាងមុខ យ៉ាងនេះទេ ។ បពិត្រព្រះមោគ្គល្លានដ៏ម្ចាស់ ពួកចាតុម្មហារាជិកទេវតាណា ប្រកបដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុងព្រះពុទ្ធ ប្រកបដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុងព្រះធម៌ ប្រកបដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុងព្រះសង្ឃ ប្រកបដោយសីលទាំងឡាយ ដែលព្រះអរិយៈត្រេកអរហើយ ទើបពួកចាតុម្មហារាជិកទេវតានោះ មានសេចក្តីដឹងថា យើងជាអ្នកដល់នូវសោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង នឹងមានសេចក្តីត្រាស់ដឹងទៅខាងមុខ យ៉ាងនេះបាន ។ ម្នាលតិស្សៈ ចុះមានតែពួកចាតុម្មហារាជិកទេវតា មានសេចក្តីដឹងថា យើងជាអ្នកដល់នូវសោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង នឹងមានសេចក្តីត្រាស់ដឹងទៅខាងមុខប៉ុណ្ណោះឬ ឬក៏ពួកតាវត្តិង្សទេវតាក្តី ។ បេ ។ ពួកយាមទេវតាក្តី ពួកតុសិតទេវតាក្តី ពួកនិម្មានរតីទេវតាក្តី ពួកបរនិម្មិតវសវត្តីទេវតាក្តី មានសេចក្តីដឹងថា

សោតាបន្នម្ហា អវិនិបាតធម្មា និយតា សម្ពោធិ-
បរាយណាតិ ។ បរនិម្មិតវសវត្តីនម្បិ ខោ មារិស
មោគ្គល្លាន ទេវានំ ឯវំ ញាណំ ហោតិ សោតាបន្នម្ហា
អវិនិបាតធម្មា និយតា សម្ពោធិបរាយណាតិ ។
សព្វេសញ្ញេវ នុ ខោ តិស្ស បរនិម្មិតវសវត្តីនំ
ទេវានំ ឯវំ ញាណំ ហោតិ សោតាបន្នម្ហា អវិនិបាត-
ធម្មា និយតា សម្ពោធិបរាយណាតិ ។ ន ខោ
មារិស មោគ្គល្លាន សព្វេសញ្ញេវ បរនិម្មិតវសវត្តីនំ
ទេវានំ ឯវំ ញាណំ ហោតិ សោតាបន្នម្ហា
អវិនិបាតធម្មា និយតា សម្ពោធិបរាយណាតិ ។
យេ ខោ តេ មារិស មោគ្គល្លាន បរនិម្មិតវសវត្តិនោ
ទេវា ពុទ្ធេ អវេច្ចប្បសាទេន អសមន្នាគតា ធម្មេ
អវេច្ចប្បសាទេន អសមន្នាគតា សង្ឃេ អវេច្ចប្បសាទេន
អសមន្នាគតា អរិយកន្តេហិ សីលេហិ អសមន្នាគតា
ន តេសំ ទេវានំ ឯវំ ញាណំ ហោតិ សោតាបន្នម្ហា
អវិនិបាតធម្មា និយតា សម្ពោធិបរាយណាតិ ។



យើងជាអ្នកដល់ស្រោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង
នឹងមានសេចក្តីត្រាស់ដឹងនៅខាងមុខ យ៉ាងនេះដែរ ។ បពិត្រព្រះមោគ្គ-
ល្លានដ៏ម្ចាស់ ពួកបរនិម្មិតវសវត្តីទេវតា មានសេចក្តីដឹងថា យើងជាអ្នក
ដល់ស្រោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង នឹងមាន
សេចក្តីត្រាស់ដឹងនៅខាងមុខយ៉ាងនេះបាន ។ ម្នាលតិស្សៈ ពួកបរនិម្មិត-
វសវត្តីទេវតា មានសេចក្តីដឹងថា យើងជាអ្នកដល់ស្រោតៈ មាន
សភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង នឹងមានសេចក្តីត្រាស់ដឹងនៅ
ខាងមុខយ៉ាងនេះ ទាំងអស់គ្នា ឬដូចម្តេច ។ បពិត្រព្រះមោគ្គល្លានដ៏ម្ចាស់
ពួកបរនិម្មិតវសវត្តីទេវតា មិនមានសេចក្តីដឹងថា យើងជាអ្នកដល់ស្រោតៈ
មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង នឹងមានសេចក្តីត្រាស់ដឹង
នៅខាងមុខយ៉ាងនេះ ទាំងអស់គ្នាទេ ។ បពិត្រព្រះមោគ្គល្លានដ៏ម្ចាស់
ពួកបរនិម្មិតវសវត្តីទេវតាណា មិនប្រកបដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុង
ព្រះពុទ្ធ មិនប្រកបដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុងព្រះធម៌ មិនប្រកប
ដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុងព្រះសង្ឃ មិនប្រកបដោយសីលទាំងឡាយ
ដែលព្រះអរិយៈត្រេកអរហើយ ពួកបរនិម្មិតវសវត្តីទេវតាទាំងនោះ មិនមាន
សេចក្តីដឹងថា យើងជាអ្នកដល់ស្រោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា
ជាបុគ្គលទៀង នឹងមានសេចក្តីត្រាស់ដឹង នៅខាងមុខយ៉ាងនេះទេ ។

យេ ច ខោ តេ មារិស មោគ្គល្លាន អនិមិត្តសមាធិតោ ឥតោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតា ធម្មេ អវេច្ចប្បសាទេន សមន្នាគតា សង្ឃេ អវេច្ចប្បសាទេន សមន្នាគតា អរិយកន្តេហិ សីលេហិ សមន្នាគតា តេសំ ឯវំ ញាណំ ហោតិ សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយណាតិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ តិស្សស្ស ព្រហ្មុនោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ព្រហ្មលោកេ អន្តរហិតោ គិជ្ឈកូដេ បាតុរហោសីតិ ។

(៣៩) ឆយិមេ ភិក្ខវេ ធម្មា វិជ្ជាភាគិយា ។ កតមេ ឆ ។ អនិច្ចសញ្ញា អនិច្ចេ ទុក្ខសញ្ញា ទុក្ខេ អនត្តសញ្ញា បហានសញ្ញា វិរាគសញ្ញា



បពិត្រព្រះមោគ្គល្លានដ៏ម្ចាស់ លុះតែពួកបានអនិមិត្តចេតោសមាធិណា ប្រកបដោយសេចក្តីជ្រះថ្លាមាំមាំ ក្នុងព្រះពុទ្ធ ប្រកបដោយសេចក្តីជ្រះថ្លាមាំមាំ ក្នុងព្រះធម៌ ប្រកបដោយសេចក្តីជ្រះថ្លាមាំមាំ ក្នុងព្រះសង្ឃ ប្រកបដោយសីលទាំងឡាយ ដែលព្រះអរិយៈត្រេកអរហើយ ទើបពួកបានអនិមិត្តចេតោសមាធិនោះ មានសេចក្តីដឹងថា យើងជាអ្នកដល់សោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង នឹងមានសេចក្តីត្រាស់ដឹង ទៅខាងមុខយ៉ាងនេះបាន ។ គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ត្រេកអរអនុមោទនាភាសិត របស់តិស្សព្រហ្ម ហើយក៏បាត់ពីព្រហ្មលោក មកប្រាកដនៅភ្នំគិជ្ឈកូដវិញ ដូចជាបុរសមានកំឡាំងលាតដៃដែលបត់ ឬបត់ដៃដែលលាត ដូច្នោះឯង ។

(៣៩) ម្នាលភិក្ខុទាំងឡាយ ពួកធម៌ ជាចំណែកនៃវិជ្ជានេះ មាន ៦ យ៉ាង ។ ធម៌ ៦ យ៉ាង តើដូចម្តេច ។ គឺសេចក្តីសំគាល់
(ដែលកើតឡើង) ក្នុងអនិច្ចានុបស្សនាញាណ ១ សេចក្តីសំគាល់
(ដែលកើតឡើង) ក្នុងទុក្ខានុបស្សនាញាណ ១ សេចក្តីសំគាល់
(ដែលកើតឡើង) ក្នុងអនត្តានុបស្សនាញាណ ១ សេចក្តីសំគាល់
(ដែលកើតឡើង) ក្នុងបហានានុបស្សនាញាណ ១ សេចក្តីសំគាល់
(ដែលកើតឡើង) ក្នុងវិរាគានុបស្សនាញាណ ១

វិវេកសញ្ញា ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មា វិជ្ជាភាគិយាតិ ។

[៣៦] ឆយិមានិ ភិក្ខវេ វិវាទមូលានិ ។ កតមានិ ឆ ។ ឥធ ភិក្ខវេ ភិក្ខុ កោធនោ ហោតិ ឧបនាហី ។ យោ សោ ភិក្ខវេ ភិក្ខុ កោធនោ ហោតិ ឧបនាហី សោ សត្ថរិបិ អគារវោ វិហរតិ អប្បតិស្សោ ធម្មេបិ អគារវោ វិហរតិ អប្បតិស្សោ សង្ឃេបិ អគារវោ វិហរតិ អប្បតិស្សោ សិក្ខាយបិ ន បរិបូរការី ហោតិ ។ យោ សោ ភិក្ខវេ ភិក្ខុ សត្ថរិ អគារវោ វិហរតិ អប្បតិស្សោ ធម្មេ អគារវោ វិហរតិ អប្បតិស្សោ សង្ឃេ អគារវោ វិហរតិ អប្បតិស្សោ សិក្ខាយ ន បរិបូរការី សោ សង្ឃេ វិវាទំ ជនេតិ យោ ហោតិ វិវាទោ ពហុជនាហិតាយ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។



សេចក្ដីសំគាល់ (ដែលកើតឡើង) ក្នុងនិរោធ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ ដែលជាចំណែកនៃវិជ្ជា ៦ យ៉ាង ។

[៣៦] ម្នាលភិក្ខុទាំងឡាយ មូលហេតុនៃសេចក្ដីវិវាទនេះ មាន ៦ យ៉ាង ។ ៦ យ៉ាង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានសេចក្ដីក្រោធ ចងសេចក្ដីក្រោធទុក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មានសេចក្ដីក្រោធ ចងសេចក្ដីក្រោធទុក ភិក្ខុនោះ មិនមានសេចក្ដីគោរព មិនមានសេចក្ដីកោតក្រែង ក្នុងព្រះសាស្ដាផង មិនមានសេចក្ដីគោរព មិនមានសេចក្ដីកោតក្រែង ក្នុងព្រះធម៌ផង មិនមានសេចក្ដីគោរព មិនមានសេចក្ដីកោតក្រែង ក្នុងព្រះសង្ឃផង ជាអ្នកមិនធ្វើឲ្យបរិបូណ៌ ក្នុងសិក្ខាផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មិនមានសេចក្ដីគោរព មិនមានសេចក្ដីកោតក្រែងក្នុងព្រះសាស្ដា មិនមានសេចក្ដីគោរព មិនមានសេចក្ដីកោតក្រែង ក្នុងព្រះធម៌ មិនមានសេចក្ដីគោរព មិនមានសេចក្ដីកោតក្រែង ក្នុងព្រះសង្ឃ ជាអ្នកមិនធ្វើឲ្យបរិបូណ៌ ក្នុងសិក្ខាទេ ភិក្ខុនោះ រមែងញុំាងសេចក្ដីវិវាទឲ្យកើតក្នុងសង្ឃ ដែលជាវិវាទប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដល់ជនច្រើន ដើម្បីមិនជាសុខ ដល់ជនច្រើន មិនចំរើនដល់ជនច្រើន មិនជាប្រយោជន៍ ជាទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ។

ឯវរូបញ្ចេ តុម្ហេ ភិក្ខវេ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា សមនុបស្សេយ្យាថ តត្រ តុម្ហេ ភិក្ខវេ តស្សេវ បាបកស្ស វិវាទមូលស្ស បហានាយ វាយមេយ្យាថ ។ ឯវរូបញ្ចេ តុម្ហេ ភិក្ខវេ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ន សមនុបស្សេយ្យាថ តត្រ តុម្ហេ ភិក្ខវេ តស្សេវ បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវាយ បដិបជ្ជេយ្យាថ ។ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស បហានំ ហោតិ ។ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវោ ហោតិ ។ បុន ចបរំ ភិក្ខវេ ភិក្ខុ មក្ខី ហោតិ បឡាសី ។បេ។ ឥស្សុកី ហោតិ មច្ឆរី សឋោ ហោតិ មាយាវី បាបិច្ឆោ ហោតិ មិច្ឆាទិដ្ឋិ សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី ។ យោ សោ ភិក្ខវេ ភិក្ខុ សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី សោ សត្ថរិបិ អគារវោ វិហរតិ អប្បតិស្សោ ធម្មេបិ អគារវោ វិហរតិ អប្បតិស្សោ សង្ឃេបិ អគារវោ វិហរតិ អប្បតិស្សោ សិក្ខាយបិ ន បរិបូរការី ហោតិ ។



ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ បានឃើញមូលហេតុនៃវិវាទ មានសភាពយ៉ាងនេះ ជាខាងក្នុង ឬជាខាងក្រៅហើយ ម្នាលភិក្ខុទាំងឡាយ ក្នុងរឿងនោះ អ្នកទាំងឡាយ ត្រូវព្យាយាម ដើម្បីលះមូលហេតុ នៃវិវាទដ៏លាមកនោះចេញ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ មិនឃើញមូលហេតុនៃវិវាទ មានសភាពយ៉ាងនេះ ជាខាងក្នុង ឬជាខាងក្រៅទេ ម្នាលភិក្ខុទាំងឡាយ ក្នុងរឿងនោះ អ្នកទាំងឡាយ ត្រូវប្រតិបត្តិ ដើម្បីមិនឲ្យមូលហេតុ នៃវិវាទដ៏លាមកនោះ ជាប់តាមតទៅទៀតបាន ។ យ៉ាងនេះ ឈ្មោះថា ការលះមូលហេតុ នៃវិវាទដ៏លាមកនុ៎ះចេញ ។ យ៉ាងនេះ ឈ្មោះថា មិនមានមូលហេតុ នៃវិវាទដ៏លាមកនុ៎ះ ជាប់តាមតទៅទៀតទេ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកលុបគុណ នឹងឲ្យតួស្មើ ។បេ។ ជាអ្នកមានសេចក្តីឫស្យា មានសេចក្តីកំណាញ់ ជាអ្នកអួតអាង មានពុតត្បុត ជាអ្នកមានសេចក្តីប្រាថ្នាដ៏លាមក មានសេចក្តីយល់ខុស ជាអ្នកស្ទាបអង្អែល តាមសេចក្តីយល់របស់ខ្លួន ប្រកាន់មាំ លះបង់បានដោយក្រ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ស្ទាបអង្អែល តាមសេចក្តីយល់របស់ខ្លួន ប្រកាន់មាំ លះបង់បានដោយក្រ ភិក្ខុនោះមិនគោរព មិនកោតក្រែង ក្នុងព្រះសាស្តាផង មិនគោរពមិនកោតក្រែង ក្នុងព្រះធម៌ផង មិនគោរពមិនកោតក្រែង ក្នុងព្រះសង្ឃផង មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាផង។

យោ សោ ភិក្ខវេ ភិក្ខុ សត្ថរិ អគារវោ វិហរតិ អប្បតិស្សោ ។បេ។ សិក្ខាយ ន បរិបូរការី សោ សង្ឃេ វិវាទំ ជនេតិ យោ ហោតិ វិវាទោ ពហុជនាហិតាយ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ ឯវរូបញ្ចេ តុម្ហេ ភិក្ខវេ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា សមនុបស្សេយ្យាថ តត្រ តុម្ហេ ភិក្ខវេ តស្សេវ បាបកស្ស វិវាទមូលស្ស បហានាយ វាយមេយ្យាថ ។ ឯវរូបញ្ចេ តុម្ហេ ភិក្ខវេ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ន សមនុបស្សេយ្យាថ តត្រ តុម្ហេ ភិក្ខវេ តស្សេវ បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវាយ បដិបជ្ជេយ្យាថ ។ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស បហានំ ហោតិ ។ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវោ ហោតិ ។ ឥមានិ ខោ ភិក្ខវេ ឆ វិវាទមូលានីតិ ។



ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មិនគោរព មិនកោតក្រែង ក្នុងព្រះសាស្តា ។ល។ មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាទេ ភិក្ខុនោះរមែងបង្កវិវាទ ឲ្យកើតឡើងក្នុងព្រះសង្ឃ ដែលជាវិវាទប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនចំរើនដល់ជនច្រើន មិនជាប្រយោជន៍ ជាទុក្ខ ដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ ពិចារណាឃើញមូលហេតុនៃវិវាទ មានសភាពយ៉ាងនេះ ជាខាងក្នុង ឬជាខាងក្រៅហើយ ម្នាលភិក្ខុទាំងឡាយ ក្នុងរឿងនោះ អ្នកទាំងឡាយត្រូវព្យាយាម ដើម្បីលះបង់នូវវិវាទមូលដ៏លាមកនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ មិនពិចារណាឃើញនូវវិវាទមូល មានសភាពយ៉ាងនេះ ទាំងខាងក្នុង ទាំងខាងក្រៅទេ ម្នាលភិក្ខុទាំងឡាយ ក្នុងរឿងនោះ អ្នកទាំងឡាយ ត្រូវប្រតិបត្តិ ដើម្បីមិនឲ្យវិវាទមូលដ៏លាមកនុ៎ះជាប់តាម តទៅទៀតបាន ។ យ៉ាងនេះ ឈ្មោះថា ការលះបង់នូវវិវាទមូល ដ៏លាមកនោះ ។ យ៉ាងនេះ ឈ្មោះថា មិនមានវិវាទមូល ដ៏លាមកនុ៎ះ ជាប់តាម តទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះហើយ ជាវិវាទមូល ៦ យ៉ាង ។

(៣៧) ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន វេឡុកណ្ដកី នន្ទមាតា ឧបាសិកា សារីបុត្តមោគ្គល្លានប្បមុខេ ភិក្ខុសង្ឃេ ឆឡង្គសមន្នាគតំ ទក្ខិណំ បតិដ្ឋាបេតិ ។ អទ្ទសា ខោ ភគវា ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន វេឡុកណ្ដកឹ នន្ទមាតរំ ឧបាសិកំ សារីបុត្តមោគ្គល្លានប្បមុខេ ភិក្ខុសង្ឃេ ឆឡង្គសមន្នាគតំ ទក្ខិណំ បតិដ្ឋាបេន្តឹ ទិស្វាន ភិក្ខូ អាមន្តេសិ ឯសា ភិក្ខវេ វេឡុកណ្ដកី នន្ទមាតា ឧបាសិកា សារីបុត្តមោគ្គល្លានប្បមុខេ ភិក្ខុសង្ឃេ ឆឡង្គសមន្នាគតំ ទក្ខិណំ បតិដ្ឋាបេតិ ។ កថញ្ច ភិក្ខវេ ឆឡង្គសមន្នាគតា ទក្ខិណា ហោតិ ។ ឥធ ភិក្ខវេ ទាយកស្ស តីណង្គានិ ហោន្តិ បដិគ្គាហកានំ តីណង្គានិ ។



(៣៧) សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឧបាសិកា ជាមាតាព្រះនន្ទ អ្នកនៅក្នុងក្រុងវេឡុកណ្ដកៈ ដំកល់ទាន ប្រកបដោយអង្គ ៦ ចំពោះភិក្ខុសង្ឃ មានព្រះសារីបុត្រនិងព្រះមោគ្គល្លាន ជាប្រធាន ។ ព្រះដ៏មានព្រះភាគ បានទតឃើញនន្ទមាតា ឧបាសិកា អ្នកនៅក្នុងក្រុងវេឡុកណ្ដកៈ ដោយទិព្វចក្ខុ ដ៏បរិសុទ្ធ កន្លងចក្ខុរបស់មនុស្សធម្មតា ដែលកំពុងដំកល់ទាន ប្រកបដោយអង្គ ៦ ចំពោះភិក្ខុសង្ឃ មានព្រះសារីបុត្រនិងព្រះមោគ្គល្លាន ជាប្រធាន លុះទតឃើញហើយ ក៏ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ នន្ទមាតា ឧបាសិកា អ្នកនៅក្នុងក្រុងវេឡុកណ្ដកៈនោះ កំពុងដំកល់ទាន ប្រកបដោយអង្គ ៦ ចំពោះភិក្ខុសង្ឃ មានព្រះសារីបុត្រនិងព្រះមោគ្គល្លាន ជាប្រធាន ។ ម្នាលភិក្ខុទាំងឡាយ ចុះទាន ប្រកបដោយអង្គ ៦ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ អង្គរបស់ទាយកមាន ៣ អង្គរបស់បដិគ្គាហកៈទាំងឡាយ មាន ៣ ។

កតមានិ ទាយកស្ស តីណង្គានិ ។ ឥធ ភិក្ខវេ ទាយកោ បុព្វេវ ទានា សុមនោ ហោតិ ទទំ ចិត្តំ បសាទេតិ ទត្វា អត្តមនោ ហោតិ ។ ឥមានិ ទាយកស្ស តីណង្គានិ ។ កតមានិ បដិគ្គាហកានំ តីណង្គានិ ។ ឥធ ភិក្ខវេ បដិគ្គាហកា វីតរាគា វា ហោន្តិ រាគវិនយាយ វា បដិបន្នា វីតទោសា វា ហោន្តិ ទោសវិនយាយ វា បដិបន្នា វីតមោហា វា ហោន្តិ មោហវិនយាយ វា បដិបន្នា ។ ឥមានិ បដិគ្គាហកានំ តីណង្គានិ ។ ឥតិ ទាយកស្ស តីណង្គានិ បដិគ្គាហកានំ តីណង្គានិ ។ ឯវំ ខោ ភិក្ខវេ ឆឡង្គសមន្នាគតា ទក្ខិណា ហោតិ ។ ឯវំ ឆឡង្គសមន្នាគតាយ ភិក្ខវេ ទក្ខិណាយ ន សុករំ បុញ្ញស្ស បមាណំ គហេតុំ(១) ឯត្តកោ បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខវិ-បាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតីតិ ។ អថខោ អសង្ខេយ្យោ អប្បមេយ្យោ មហាបុញ្ញក្ខន្ធោត្វេវ សង្ខំ គច្ឆតិ ។

---
១ ម. គាហុំ ។



ចុះអង្គរបស់ទាយក ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ទាយកជាអ្នកមានចិត្តត្រេកអរមុន អំពីកាលឲ្យ ១ កំពុងតែឲ្យ ធ្វើចិត្តឲ្យជ្រះថ្លា ១ លុះឲ្យហើយ មានចិត្តរីករាយ ១ ។ នេះជាអង្គទាយកមាន ៣ ។ អង្គរបស់បដិគ្គាហកៈទាំងឡាយ មាន ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ពួកបដិគ្គាហកៈ ជាអ្នកប្រាសចាករាគៈឬប្រតិបត្តិ ដើម្បីបន្ទោបង់រាគៈ ១ ប្រាសចាកទោសៈ ឬប្រតិបត្តិ ដើម្បីបន្ទោបង់ទោសៈ ១ ប្រាសចាកមោហៈឬប្រតិបត្តិ ដើម្បីបន្ទោបង់មោហៈ ១ ។ នេះជាអង្គបដិគ្គាហកៈមាន ៣ ។ អង្គរបស់ទាយកមាន ៣ អង្គរបស់បដិគ្គាហកៈមាន ៣ ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ជាទានប្រកបដោយអង្គ ៦ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនងាយកំណត់ នូវប្រមាណនៃបុណ្យ របស់ទាន ដែលប្រកបដោយអង្គ ៦ យ៉ាងនេះថា ផលបុណ្យ ផលកុសល ជាគ្រឿងនាំមកនូវសេចក្តីសុខ ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក ប្រព្រឹត្តទៅ ដើម្បីស្ថានសួគ៌ប៉ុណ្ណេះ ប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នា ត្រេកអរ គាប់ចិត្ត ជាប្រយោជន៍ ជាសុខប៉ុណ្ណេះឡើយ ។ ដោយពិតនោះ រាប់មិនបាន ប្រមាណមិនកើត ត្រាន់តែរាប់ថា ជាគំនរបុណ្យច្រើនប៉ុណ្ណេះបាន ។

សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទេ ន សុករំ ឧទកស្ស បមាណំ គហេតុំ ឯត្តកានិ ឧទកាឡ្ហកានីតិ វា ឯត្តកានិ ឧទកាឡ្ហកសតានីតិ វា ឯត្តកានិ ឧទកាឡ្ហកសហស្សានីតិ វា ឯត្តកានិ ឧទកាឡ្ហកសតសហស្សានីតិ វា ។ អថខោ អសង្ខេយ្យោ អប្បមេយ្យោ មហាឧទកក្ខន្ធោត្វេវ សង្ខំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ ឯវំ ឆឡង្គសមន្នាគតាយ ទក្ខិណាយ ន សុករំ បុញ្ញស្ស បមាណំ គហេតុំ ឯត្តកោ បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខវិបាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតីតិ ។ អថខោ អសង្ខេយ្យោ អប្បមេយ្យោ មហាបុញ្ញក្ខន្ធោត្វេវ សង្ខំ គច្ឆតីតិ ។

បុព្វេវ ទានា សុមនោ ទទំ ចិត្តំ បសាទយេ
ទត្វា អត្តមនោ ហោតិ ឯសា យញ្ញស្ស សម្បទា ។



ម្នាលភិក្ខុទាំងឡាយ ដូចបុគ្គលដែលមិនងាយកំណត់ ប្រមាណនូវទឹកក្នុងមហាសមុទ្រថា ទឹកប៉ុណ្ណេះអាឡ្ហកៈ ទឹកប៉ុណ្ណេះរយអាឡ្ហកៈ ទឹកប៉ុណ្ណេះពាន់អាឡ្ហកៈ ទឹកប៉ុណ្ណេះសែនអាឡ្ហកៈ បានឡើយ ។ ដោយពិតនោះថា រាប់មិនបានប្រមាណមិនកើត គ្រាន់តែរាប់ថា គំនរទឹកដ៏ច្រើនប៉ុណ្ណោះបាន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនងាយកំណត់ប្រមាណនូវបុណ្យនៃទានប្រកបដោយអង្គ ៦ យ៉ាង យ៉ាងនេះថា គំនរបុណ្យ គំនរកុសល ជាគ្រឿងនាំមកនូវសុខឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក ប្រព្រឹត្តទៅ ដើម្បីស្ថានសួគ៌ប៉ុណ្ណេះ ប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នា ត្រេកអរ គាប់ចិត្ត ជាប្រយោជន៍ ជាសុខបានឡើយ ។ ដោយពិតនោះថា រាប់មិនបានប្រមាណមិនកើត គ្រាន់តែរាប់ថា ជាគំនរបុណ្យដ៏ច្រើនប៉ុណ្ណោះបាន គឺយ៉ាងនោះឯង ។

ទាយកមានចិត្តរីករាយ ក្នុងវេលាមុនអំពីកាលឲ្យ កំពុង
ឲ្យ ធ្វើចិត្តឲ្យជ្រះថ្លា លុះឲ្យហើយក៏មានចិត្តត្រេកអរ
( ខាងក្រោយ ) នេះជាសេចក្តីបរិបូណ៌របស់ទាន ។

វីតរាគោ វីតទោសោ វីតមោហោ អនាសវោ
ខេត្តំ យញ្ញស្ស សម្បន្នំ សញ្ញតា ព្រហ្មចារយោ ។
សយំ អាចមយិត្វាន ទត្វា សកេហិ បាណិភិ
អត្តនោ បរតោ ចេសោ យញ្ញោ ហោតិ មហប្ផលោ ។
ឯវំ យជិត្វា មេធាវី សទ្ធោ មុត្តេន ចេតសា
អព្យាបជ្ឈំ សុខំ លោកំ បណ្ឌិតោ ឧបបជ្ជតីតិ ។

(៣៨) អថខោ អញ្ញតរោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធិំ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អហញ្ហិ ភោ គោតម ឯវំវាទី ឯវំទិដ្ឋិ នត្ថិ អត្តការោ នត្ថិ បរការោតិ ។ មាហំ ព្រាហ្មណ ឯវំវាទឹ ឯវំទិដ្ឋិំ(១) អទ្ទសំ វា អស្សោសឹ វា កថំ ហិ នាម សយំ អភិក្កមន្តោ សយំ បដិក្កមន្តោ

១ ម. ឯវំវាទី ឯវំទិដ្ឋី ។



បុគ្គលអ្នកប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាក
មោហៈ មិនមានអាសវៈជាព្រហ្មចារី មានសេចក្តីសង្រួម
ឈ្មោះថាជាខេត្តនៃទានដ៏បរិបូណ៌ (ដោយគុណ) ។
បុគ្គលខ្ពុល់ខ្ពុរដោយខ្លួនឯង ឲ្យទានដោយដៃរបស់ខ្លួន ។
ទាននុ៎ះ ជាទានមានផលច្រើន ព្រោះខ្លួនឯង ព្រោះបុគ្គល
ដទៃផង ។ អ្នកប្រាជ្ញជាបណ្ឌិតអ្នកមានសទ្ធា មានចិត្តផុត
ស្រឡះ (ចាកសេចក្តីកំណាញ់) លុះឲ្យទានយ៉ាងនេះហើយ
គឺរមែងទៅកើត ក្នុងទេវលោកជាសុខ ឥតមានទុក្ខ ។

(៣៨) គ្រានោះ មានព្រាហ្មណ៍ម្នាក់ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលសួរសាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យសួរសាយ នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រាហ្មណ៍នោះ អង្គុយក្នុងទីដ៏សមគួរហើយ ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គប្រាប់និយាយយ៉ាងនេះ គ្រាប់យល់យ៉ាងនេះថា មិនមានការធ្វើ (កម្ម) ដើម្បីខ្លួន មិនមានការធ្វើ (កម្ម) ដើម្បីបុគ្គលដទៃ បានឡើយ ។ ម្នាលព្រាហ្មណ៍ តថាគតមិនដែលឃើញ មិនដែលឮ មនុស្សនិយាយយ៉ាងនេះ យល់យ៉ាងនេះឡើយ ហេតុអ្វីបានជាមនុស្សឈានដើរទៅមុខ ខ្លួនឯង ឈានដើរត្រឡប់មកខ្លួនឯង

ឯវំ វក្ខតិ នត្ថិ អត្តការោ នត្ថិ បរការោតិ ។ តំ កិម្មញ្ញសិ ព្រាហ្មណ អត្ថិ អារព្ភធាតូតិ ។ ឯវំ ភោ ។ អារព្ភធាតុយា សតិ អារព្ភវន្តោ សត្តា បញ្ញាយន្តីតិ ។ ឯវំ ភោ ។ យំ ខោ ព្រាហ្មណ អារព្ភធាតុយា សតិ អារព្ភវន្តោ សត្តា បញ្ញាយន្តិ អយំ សត្តានំ អត្តការោ អយំ បរការោតិ ។ តំ កិម្មញ្ញសិ ព្រាហ្មណ អត្ថិ និក្កមធាតូតិ ។ បេ ។ អត្ថិ បរក្កមធាតុ អត្ថិ ថាមធាតុ អត្ថិ ឋិតិធាតុ អត្ថិ ឧបក្កមធាតូតិ ។ ឯវំ ភោ ។ ឧបក្កមធាតុយា សតិ ឧបក្កមវន្តោ សត្តា បញ្ញាយន្តីតិ ។ ឯវំ ភោ ។ យំ ខោ ព្រាហ្មណ ឧបក្កមធាតុយា សតិ ឧបក្កមវន្តោ សត្តា បញ្ញាយន្តិ អយំ សត្តានំ អត្តការោ អយំ បរការោតិ



និយាយយ៉ាងនេះថា មិនមានការធ្វើ(កម្ម)ដើម្បីខ្លួន មិនមានការធ្វើ (កម្ម) ដើម្បីបុគ្គលដទៃ ដូច្នេះបាន ។ ម្នាលព្រាហ្មណ៍ អ្នកសំគាល់ហេតុនោះដូចម្តេច ការផ្តើមនូវសេចក្តីព្យាយាម មានដែរឬទេ ។ មានដែរព្រះអង្គ ។ កាលបើមានការផ្តើមនូវសេចក្តីព្យាយាមហើយ សត្វទាំងឡាយ មានសេចក្តីប្រារព្ធ រមែងប្រាកដឡើងដែរឬទេ ។ មានដែរព្រះអង្គ ។ ម្នាលព្រាហ្មណ៍ កាលបើមានការផ្តើមនូវសេចក្តីព្យាយាមហើយ សត្វទាំងឡាយ មានសេចក្តីប្រារព្ធ ប្រាកដដោយហេតុណា ហេតុនេះហើយ ជាការធ្វើ (កម្ម) ដើម្បីខ្លួន ជាការធ្វើ (កម្ម) ដើម្បីបុគ្គលដទៃ របស់សត្វទាំងឡាយ ។ ម្នាលព្រាហ្មណ៍ អ្នកសំគាល់ហេតុនោះដូចម្តេច សេចក្តីព្យាយាម មានសភាពចេញចាកការខ្ជិលច្រអូស មានដែរឬទេ ។ បេ ។ សេចក្តីប្រឹងប្រែងមានដែរឬទេ សេចក្តីនឹងធឹងមានដែរឬទេ សេចក្តីតាំងមាំមានដែរឬទេ សេចក្តីខ្វល់ខ្វាយមានដែរឬទេ ។ មានដែរព្រះអង្គ ។ កាលបើមានសេចក្តីខ្វល់ខ្វាយហើយ សត្វទាំងឡាយ មានសេចក្តីខ្វល់ខ្វាយ ក៏រមែងប្រាកដឡើងដែរឬទេ ។ មានប្រាកដដែរព្រះអង្គ ។ ម្នាលព្រាហ្មណ៍ កាលបើសេចក្តីខ្វល់ខ្វាយមានហើយ សត្វទាំងឡាយ មានសេចក្តីខ្វល់ខ្វាយ ប្រាកដឡើងដោយហេតុណា ហេតុនេះជាការធ្វើ (កម្ម) ដើម្បីខ្លួន ជាការធ្វើ (កម្ម) ដើម្បីបុគ្គលដទៃ របស់សត្វទាំងឡាយ

នាហំ ព្រាហ្មណ ឯវំវាទឹ ឯវំទិដ្ឋឹ អទ្ទសំ វា អស្សោសឹ វា កថញ្ហិ នាម សយំ អភិក្កមន្តោ សយំ បដិក្កមន្តោ ឯវំ វក្ខតិ នត្ថិ អត្តការោ នត្ថិ បរការោតិ ។ អភិក្កន្តំ ភោ គោតម ។បេ។ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

(៣៩) តីណីមានិ ភិក្ខវេ និទានានិ កម្មានំ សមុទយាយ ។ កតមានិ តីណិ ។ លោភោ និទានំ កម្មានំ សមុទយាយ ទោសោ និទានំ កម្មានំ សមុទយាយ មោហោ និទានំ កម្មានំ សមុទយាយ ។ ន ភិក្ខវេ លោភា អលោភោ សមុទេតិ អថខោ ភិក្ខវេ លោភា លោភោវ សមុទេតិ ។ ន ភិក្ខវេ ទោសា អទោសោ សមុទេតិ អថខោ ភិក្ខវេ ទោសា ទោសោវ សមុទេតិ ។ ន ភិក្ខវេ មោហា អមោហោ សមុទេតិ អថខោ ភិក្ខវេ



ម្នាលព្រាហ្មណ៍ តថាគតមិនដែលឃើញ មិនដែលឮ មនុស្សនិយាយពាក្យនេះ យល់ពាក្យនេះឡើយ ដូចម្តេចក៏មនុស្សណាដើរទៅមុខខ្លួនឯង ឈានដើរត្រឡប់មកខ្លួនឯង មកនិយាយពាក្យនេះថា មិនមានការធ្វើ (កម្ម) ដើម្បីខ្លួន មិនមានការធ្វើ (កម្ម) ដើម្បីបុគ្គលដទៃសោះឡើយ ។ បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ ។បេ។ ចាប់ដើមតាំងពីថ្ងៃនេះទៅ ជាអ្នកដល់នូវព្រះរតនត្រ័យជាទីពឹងស្មើដោយជីវិត ។

(៣៩) ម្នាលភិក្ខុទាំងឡាយ ហេតុទាំងឡាយ ៣ យ៉ាងនេះ ដែលផ្តួចផ្តើមឲ្យកើត អកុសលកម្មទាំងឡាយ ។ ហេតុ ៣ យ៉ាង តើដូចម្តេច ។ គឺលោភៈ ជាហេតុផ្តួចផ្តើមឲ្យកើតអកុសលកម្មទាំងឡាយ ១ ទោសៈ ជាហេតុផ្តួចផ្តើមឲ្យកើតអកុសលកម្មទាំងឡាយ ១ មោហៈ ជាហេតុផ្តួចផ្តើមឲ្យកើតអកុសលកម្មទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ អលោភៈ មិនកើតមកអំពីលោភៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ លោភៈប្រាកដជាកើតមកអំពីលោភៈដដែល ។ ម្នាលភិក្ខុទាំងឡាយ អទោសៈ មិនកើតមកអំពីទោសៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ ទោសៈប្រាកដជាកើតមកអំពីទោសៈដដែល ។ ម្នាលភិក្ខុទាំងឡាយ អមោហៈ មិនកើតមកអំពីមោហៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ

មោហា មោហោវ សមុទេតិ ។ ន ភិក្ខវេ លោភជេន កម្មេន ទោសជេន កម្មេន មោហជេន កម្មេន ទេវា បញ្ញាយន្តិ មនុស្សា បញ្ញាយន្តិ យា វា បនញ្ញាបិ កាចិ សុគតិ(១) អថខោ ភិក្ខវេ លោភជេន កម្មេន ទោសជេន កម្មេន មោហជេន កម្មេន និរយោ បញ្ញាយតិ តិរច្ឆានយោនិ បញ្ញាយតិ បិត្តិវិសយោ បញ្ញាយតិ យា វា បនញ្ញាបិ កាចិ ទុគ្គតិ(២) ។ ឥមានិ ខោ ភិក្ខវេ តីណិ និទានានិ កម្មានំ សមុទយាយ ។ តីណីមានិ ភិក្ខវេ និទានានិ កម្មានំ សមុទយាយ ។ កតមានិ តីណិ ។ អលោភោ និទានំ កម្មានំ សមុទយាយ អទោសោ និទានំ កម្មានំ សមុទយាយ អមោហោ និទានំ កម្មានំ សមុទយាយ ។ ន ភិក្ខវេ អលោភា លោភោ សមុទេតិ អថខោ ភិក្ខវេ អលោភា អលោភោវ សមុទេតិ ។ ន ភិក្ខវេ អទោសា ទោសោ សមុទេតិ អថខោ ភិក្ខវេ អទោសា អទោសោវ សមុទេតិ ។ ន ភិក្ខវេ អមោហា មោហោ សមុទេតិ

១ ម. ឆ. សុគតិយោ ។ ២ ម. ឆ. ទុគ្គតិយោ ។



មោហៈប្រាកដជាកើតមកអំពីមោហៈវិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតាក្តី ពួកមនុស្សក្តី ឬសុគតិណាមួយឯទៀត មិនមែនបានប្រាកដមកអំពីកម្មដែលកើតអំពីលោភៈ កម្មដែលកើតអំពីទោសៈ កម្មដែលកើតអំពីមោហៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ នរកក្តី កំណើតតិរច្ឆានក្តី ប្រេតវិស័យក្តី ឬទុគ្គតិណាមួយឯទៀត រមែងកើតប្រាកដមកអំពីកម្ម ដែលកើតអំពីលោភៈ កម្មដែលកើតអំពីទោសៈ កម្មដែលកើតអំពីមោហៈជាប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះហើយ ដែលផ្តួចផ្តើមឲ្យកើតអកុសលកម្មទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង ៣ យ៉ាងនេះ ដែលផ្តួចផ្តើមឲ្យកើតកុសលកម្មទាំងឡាយ ។ ចុះហេតុ ៣ យ៉ាង តើដូចម្តេច ។ គឺអលោភៈជាហេតុផ្តួចផ្តើមឲ្យកើតកុសលកម្មទាំងឡាយ ១ អទោសៈជាហេតុផ្តួចផ្តើមឲ្យកើតកុសលកម្មទាំងឡាយ ១ អមោហៈជាហេតុផ្តួចផ្តើមឲ្យកើតកុសលកម្មទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ លោភៈមិនមែនកើតមកអំពីអលោភៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ អលោភៈប្រាកដជាកើតមកអំពីអលោភៈវិញ ។ ម្នាលភិក្ខុទាំងឡាយ ទោសៈមិនមែនកើតមកអំពីអទោសៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ អទោសៈប្រាកដជាកើតមកអំពីអទោសៈវិញ ។ ម្នាលភិក្ខុទាំងឡាយ មោហៈមិនមែនកើតមកអំពីអមោហៈទេ

អថ ខោ ភិក្ខវេ អមោហា អមោហោវ សមុទេតិ ។ ន ភិក្ខវេ អលោភជេន កម្មេន អទោសជេន កម្មេន អមោហជេន កម្មេន និរយោ បញ្ញាយតិ តិរច្ឆានយោនិ បញ្ញាយតិ បិត្តិវិសយោ បញ្ញាយតិ យា វា បនញ្ញាបិ កាចិ ទុគ្គតិយោ ។ អថ ខោ ភិក្ខវេ អលោភជេន កម្មេន អទោសជេន កម្មេន អមោហជេន កម្មេន ទេវា បញ្ញាយន្តិ មនុស្សា បញ្ញាយន្តិ យា វា បនញ្ញាបិ កាចិ សុគតិយោ ។ ឥមានិ ខោ ភិក្ខវេ តីណិ និទានានិ កម្មានំ សមុទយាយាតិ ។

(៤០) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កិមិលាយំ(១) វិហរតិ វេឡុវនេ ។ អថ ខោ អាយស្មា កិមិលោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា កិមិលោ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន តថាគតេ បរិនិព្វុតេ សទ្ធម្មោ ន ចិរដ្ឋិតិកោ ហោតីតិ ។

១. កិម្ពិលាយំ ។



ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ អមោហៈប្រាកដជាកើតមកអំពីអមោហៈដដែល ។ ម្នាលភិក្ខុទាំងឡាយ នរកក្តី កំណើតតិរច្ឆានក្តី ប្រេត-វិស័យក្តី ឬក៏ទុគ្គតិណាមួយដទៃទៀត មិនកើតប្រាកដមកអំពីកម្មដែលកើតពីអលោភៈ កម្មដែលកើតអំពីអទោសៈ កម្មដែលកើតអំពីអមោហៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ ពួកទេវតាក្តី ពួកមនុស្សក្តី ឬក៏សុគតិណាមួយដទៃទៀត តែងកើតប្រាកដមកអំពីកម្មដែលកើតអំពីអលោភៈ កម្មដែលកើតមកអំពីអទោសៈ កម្មដែលកើតមកអំពីអមោហៈជាប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង ៣ យ៉ាងនេះហើយ ដែលផ្តួចផ្តើមឲ្យកើតកុសលកម្មទាំងឡាយ ។

(៤០) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវន ទៀបក្រុងកិមិលា ។ គ្រានោះ ព្រះកិមិលៈដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះកិមិលៈ ដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលសួរព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ហេតុដូចម្តេច បច្ច័យដូចម្តេចនេះ កាលបើព្រះតថាគត បរិនិព្វានហើយ ព្រះសទ្ធម្មមិនឋិតនៅអស់កាលយូរបាន ។

ឥធ កិមិល តថាគតេ បរិនិព្វុតេ ភិក្ខូ ភិក្ខុនិយោ
ឧបាសកា ឧបាសិកាយោ សត្ថរិ អគារវា វិហរន្តិ
អប្បតិស្សា ធម្មេ អគារវា វិហរន្តិ អប្បតិស្សា សង្ឃេ
អគារវា វិហរន្តិ អប្បតិស្សា សិក្ខាយ អគារវា
វិហរន្តិ អប្បតិស្សា អប្បមាទេ អគារវា វិហរន្តិ
អប្បតិស្សា បដិសន្ថារេ អគារវា វិហរន្តិ អប្បតិស្សា ។
អយំ ខោ កិមិល ហេតុ អយំ បច្ចយោ យេន
តថាគតេ បរិនិព្វុតេ សទ្ធម្មោ ន ចិរដ្ឋិតិកោ ហោតីតិ ។
កោ បន ភន្តេ ហេតុ កោ បច្ចយោ យេន
តថាគតេ បរិនិព្វុតេ សទ្ធម្មោ ចិរដ្ឋិតិកោ ហោតីតិ ។
ឥធ កិមិល តថាគតេ បរិនិព្វុតេ ភិក្ខូ ភិក្ខុនិយោ
ឧបាសកា ឧបាសិកាយោ សត្ថរិ សគារវា វិហរន្តិ
សប្បតិស្សា ធម្មេ សគារវា វិហរន្តិ សប្បតិស្សា សង្ឃេ
សគារវា វិហរន្តិ សប្បតិស្សា សិក្ខាយ សគារវា
វិហរន្តិ សប្បតិស្សា អប្បមាទេ សគារវា វិហរន្តិ
សប្បតិស្សា បដិសន្ថារេ សគារវា វិហរន្តិ សប្បតិស្សា ។



ម្នាលកិមិលៈ ក្នុងសាសនានេះ កាលតថាគត បរិនិព្វានហើយ ពួកភិក្ខុ
ភិក្ខុនី ឧបាសកឧបាសិកា ជាអ្នកមិនគោរព មិនកោតក្រែង ក្នុងព្រះសាស្តា
មិនគោរព មិនកោតក្រែង ក្នុងព្រះធម៌ មិនគោរព មិនកោតក្រែង
ក្នុងសង្ឃ មិនគោរព មិនកោតក្រែង ក្នុងសិក្ខា មិនគោរព មិនកោតក្រែង
ក្នុងអប្បមាទ មិនគោរព មិនកោតក្រែងក្នុងបដិសន្ថារៈ ។ ម្នាលកិមិលៈ
នេះជាហេតុ នេះជាបច្ច័យ កាលបើព្រះតថាគត បរិនិព្វានហើយ ព្រះ
សទ្ធម្មមិនឋិតនៅអស់កាលយូរបាន ។ បពិត្រព្រះអង្គដ៏ចំរើន ចុះ
ហេតុដូចម្តេច បច្ច័យដូចម្តេចនែ កាលព្រះតថាគត បរិនិព្វានហើយ
ព្រះសទ្ធម្មឋិតនៅអស់កាលយូរបាន ។ ម្នាលកិមិលៈ ក្នុងសាសនា
នេះ កាលបើព្រះតថាគត បរិនិព្វានហើយ ពួកភិក្ខុ ភិក្ខុនី ឧបាសក
ឧបាសិកា ជាអ្នកគោរព កោតក្រែង ក្នុងព្រះសាស្តា គោរព កោតក្រែង
ក្នុងព្រះធម៌ គោរព កោតក្រែង ក្នុងសង្ឃ គោរព កោតក្រែង ក្នុងសិក្ខា
គោរព កោតក្រែង ក្នុងអប្បមាទ គោរព កោតក្រែង ក្នុងបដិសន្ថារៈ ។

អយំ ខោ កាបិល ហេតុ អយំ បច្ចយោ យេន តថាគតេ បរិនិព្វុតេ សទ្ធម្មោ ចិរដ្ឋិតិកោ ហោតីតិ ។

(៦១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ អថខោ អាយស្មា សារីបុត្តោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សម្ពហុលេហិ ភិក្ខូហិ សទ្ធិំ គិជ្ឈកូដា បព្វតា ឱរោហន្តោ(១) អញ្ញតរស្មឹ បទេសេ មហន្តំ ទារុក្ខន្ធំ ទិស្វា ភិក្ខូ អាមន្តេសិ បស្សថ នោ អាវុសោ តុម្ហេ អមុំ មហន្តំ ទារុក្ខន្ធន្តិ ។ ឯវមាវុសោតិ ។ អាកង្ខមានោ អាវុសោ ភិក្ខុ ឥទ្ធិមា ចេតោវសិប្បត្តោ អមុំ ទារុក្ខន្ធំ បឋវីត្វេវ អធិមុច្ចេយ្យ ។ តំ កិស្ស ហេតុ ។ អត្ថិ អាវុសោ អមុស្មឹ ទារុក្ខន្ធេ បឋវីធាតុ យំ និស្សាយ ភិក្ខុ ឥទ្ធិមា ចេតោវសិប្បត្តោ អមុំ ទារុក្ខន្ធំ បឋវីត្វេវ អធិមុច្ចេយ្យ ។ អាកង្ខមានោ អាវុសោ ភិក្ខុ ឥទ្ធិមា ចេតោវសិប្បត្តោ អមុំ ទារុក្ខន្ធំ អាបោត្វេវ អធិមុច្ចេយ្យ ។ បេ ។ តេជោត្វេវ អធិមុច្ចេយ្យ

១ ឱ. ម. [illegible] ។



ម្នាលកបិលៈ នេះជាហេតុ នេះជាបច្ច័យ កាលបើព្រះតថាគត បរិនិព្វានហើយ ព្រះសទ្ធម្មឋិតនៅអស់កាលយូរបាន ។

(៦១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចុះអំពីភ្នំគិជ្ឈកូដជាមួយនឹងពួកភិក្ខុដ៏ច្រើន បានឃើញគំនរឈើដ៏ធំ ក្នុងប្រទេសមួយ ហើយប្រាប់នឹងភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយ ឃើញគំនរឈើដ៏ធំឯណោះដែរឬទេ ។ ឃើញដែរអាវុសោ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុមានឫទ្ធិ ប្រាថ្នាដល់នូវសេចក្តីស្ទាត់ជំនាញក្នុងចិត្ត គប្បីកំណត់នូវគំនរឈើឯណោះ ថាជាបឋវីធាតុ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ ព្រោះថា ភិក្ខុមានឫទ្ធិ ដល់នូវសេចក្តីស្ទាត់ជំនាញក្នុងចិត្ត អាស្រ័យ បឋវីធាតុ ក្នុងគំនរឈើឯណោះ ហើយគប្បីកំណត់នូវគំនរឈើឯណោះ ថាជាបឋវីធាតុ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុមានឫទ្ធិ ប្រាថ្នាដល់នូវសេចក្តីស្ទាត់ជំនាញក្នុងចិត្ត គប្បីកំណត់នូវគំនរឈើឯណោះ ថាជាអាបោធាតុ ។ បេ ។ គប្បីកំណត់ថាជាតេជោធាតុ

វាយោត្វេវ អធិមុច្ចេយ្យ សុភន្តេ្វវ អធិមុច្ចេយ្យ អសុភន្តេ្វវ អធិមុច្ចេយ្យ ។ តំ កិស្ស ហេតុ ។ អត្ថិ អាវុសោ ឥមស្មឹ ទារុក្ខន្ធេ អសុភធាតុ យំ និស្សាយ ភិក្ខុ ឥទ្ធិមា ចេតោវសិប្បត្តោ អមុំ ទារុក្ខន្ធំ អសុភន្តេ្វវ អធិមុច្ចេយ្យាតិ ។

[៤២] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសលេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន ឥច្ឆានង្គលំ នាម កោសលានំ ព្រាហ្មណគាមោ តទវសរិ ។ តត្រ សុទំ ភគវា ឥច្ឆានង្គលេ វិហរតិ ឥច្ឆានង្គលវនសណ្ឌេ ។ អស្សោសុំ ខោ ឥច្ឆានង្គលកា ព្រាហ្មណគហបតិកា សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ ឥច្ឆានង្គលំ អនុប្បត្តោ ឥច្ឆានង្គលេ វិហរតិ ឥច្ឆានង្គលវនសណ្ឌេ ។ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ



គប្បីកំណត់ថាជាវាយោធាតុ គប្បីកំណត់ថាជាសុភធាតុ(១) គប្បីកំណត់ថាជាអសុភធាតុ(២) ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ ព្រោះភិក្ខុមានឫទ្ធិ ដល់នូវសេចក្តីស្ទាត់ជំនាញ ក្នុងចិត្ត អាស្រ័យអសុភធាតុ ក្នុងគំនរឈើឯណោះ គប្បីកំណត់នូវគំនរឈើឯណោះថាជាអសុភធាតុ ។

(៤២) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់ក្នុងដំណើរទៅកាន់ចារិក ក្នុងដែនកោសល ជាមួយនឹងភិក្ខុសង្ឃជាច្រើន ស្តេចទៅដល់ព្រាហ្មណគ្រាមឈ្មោះឥច្ឆានង្គលៈ របស់អ្នកដែនកោសលទាំងឡាយ ។ បានសេចក្តីថាក្នុងកាលនោះ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវនព្រៃឥច្ឆានង្គលៈ ទៀបព្រាហ្មណគ្រាម ឈ្មោះឥច្ឆានង្គលៈនោះ ។ ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកឥច្ឆានង្គលៈបានឮថា ព្រះសមណគោតមដ៏ចំរើន ជាសក្យបុត្រចេញចាកសក្យត្រកូលទៅទ្រង់ព្រះផ្នួស ស្តេចមកដល់ស្រុកឥច្ឆានង្គលៈ ហើយគង់ក្នុងវនព្រៃឥច្ឆានង្គលៈ ទៀបស្រុកឥច្ឆានង្គលៈ ។ ឯព្រះគោតមដ៏ចំរើននោះ មានកិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅយ៉ាងនេះថា ព្រះដ៏មានព្រះភាគនោះ ព្រះអង្គឆ្ងាយចាកសឹកសត្រូវគឺកិលេស

១ ធាតុល្អក្នុងស្រះមានពណ៌ក្រហម ហៅថា សុភធាតុ ។ ២ ចំណែកខ្លឹមឈើ ស្រាយនឹងព្រលាំងក្រោយនឹងស្លឹកឈើ ដែលមានពណ៌មិនជាទីគាប់ចិត្ត ហៅថា អសុភធាតុ ។ អដ្ឋកថា ។

សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ ។ បេ ។ ពុទ្ធោ ភគវាតិ ។ សោ ឥមំ លោកំ សទេវកំ សមារកំ ។បេ។ អរហតំ ទស្សនំ ហោតីតិ ។ អថខោ ឥច្ឆានង្គលកា ព្រាហ្មណគហបតិកា តស្សា រត្តិយា អច្ចយេន បហូតំ ខាទនីយំ ភោជនីយំ អាទាយ យេន ឥច្ឆានង្គលវនសណ្ឌោ តេនុបសង្កមឹសុ ឧបសង្កមិត្វា ពហិទ្វារកោដ្ឋកេ អដ្ឋំសុ ឧច្ចាសទ្ទា មហាសទ្ទា ។ តេន ខោ បន សមយេន អាយស្មា នាគិតោ ភគវតោ ឧបដ្ឋាកោ ហោតិ ។ អថខោ ភគវា អាយស្មន្តំ នាគិតំ អាមន្តេសិ កេ បន តេ នាគិត ឧច្ចាសទ្ទា មហាសទ្ទា កេវដ្ដា មញ្ញេ មច្ឆេ វិលោបេន្តីតិ ។ ឯតេ ភន្តេ ឥច្ឆានង្គលកា ព្រាហ្មណគហបតិកា បហូតំ ខាទនីយំ ភោជនីយំ អាទាយ ពហិទ្វារកោដ្ឋកេ ឋិតា ភគវន្តញ្ញេវ ឧទ្ទិស្ស ភិក្ខុសង្ឃញ្ចាតិ ។



ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ដោយព្រះអង្គឯង បរិបូណ៌ដោយវិជ្ជានឹងចរណៈ ។ បេ ។ ត្រាស់ដឹងនូវអរិយសច្ចធម៌ ៤ ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ។ ព្រះដ៏មានព្រះភាគនោះ ទ្រង់ញុំាងលោកនេះ ព្រមទាំងទេវលោក មារលោក ។ បេ ។ ការបានជួបប្រទះព្រះអរហន្តទាំងឡាយ ។ គ្រាកាលរាត្រីនោះ កន្លងទៅហើយ ពួកព្រាហ្មណ៍និងគហបតី អ្នកស្រុកឥច្ឆានង្គលៈ កាន់ខាទនីយភោជនីយាហារដ៏ច្រើន ចូលទៅកាន់ដងព្រៃឥច្ឆានង្គលៈ លុះចូលទៅដល់ហើយ ឋិតនៅខាងក្រៅក្លោងទ្វារ រួមមានសំឡេងឹកកងយ៉ាងខ្លាំង ។ សម័យនោះ ព្រះនាគិតៈដ៏មានអាយុ ជាអ្នកបម្រើនៃព្រះដ៏មានព្រះភាគ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរព្រះនាគិតៈដ៏មានអាយុថា ម្នាលនាគិតៈ ពួកជនណា ស្រែកហ៊ោឹកកង ដូចជាពួកអ្នកសំណាញ់ ដណ្តើមត្រី ។ បពិត្រព្រះអង្គដ៏ចំរើន ពួកព្រាហ្មណ៍គហបតី អ្នកស្រុកឥច្ឆានង្គលៈនុ៎ះ នាំយកខាទនីយភោជនីយាហារដ៏ច្រើនមក ហើយឈរនៅខាងក្រៅក្លោងទ្វារ ចង់ឧទ្ទិសចំពោះព្រះដ៏មានព្រះភាគផង ភិក្ខុសង្ឃផង ។

មាហំ នាគិត យសេន សមាគមំ មា ច មយា យសោ ។ យោ ខោ នាគិត ឥមស្ស នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភី អស្ស អកិច្ឆលាភី អកសិរលាភី យស្សាហំ នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភី អស្សំ អកិច្ឆលាភី អកសិរលាភី សោ តំ មិឡ្ហសុខំ មិទ្ធសុខំ លាភសក្ការសិលោកសុខំ សាទិយេយ្យាតិ ។ អធិវាសេតុទានិ ភន្តេ ភគវា អធិវាសេតុ សុគតោ អធិវាសនកាលោទានិ ភន្តេ ភគវតោ អធិវាសនកាលោទានិ ភន្តេ ភគវតោ ។ យេន យេនេវទានិ ភន្តេ ភគវា គមិស្សតិ តំនិន្នាវ ភវិស្សន្តិ ព្រាហ្មណគហបតិកា នេគមា ចេវ ជានបទា ច ។



ម្នាលនាគិតៈ តថាគតសុំកុំជួបប្រសប់នឹងយសឡើយ ឯយសក៏កុំជួបប្រសប់នឹងតថាគតយ៉ាងនេះឡើយ ។ ម្នាលនាគិតៈ តថាគតជាអ្នកបានសមតាមប្រាថ្នា បានដោយ បានស្រួល នូវនេក្ខម្មសុខ (សុខកើតអំពីកិរិយាចេញបួស) បវិវេកសុខ (សុខកើតអំពីសេចក្តីស្ងប់ស្ងាត់) ឧបសមសុខ (សុខកើតអំពីសេចក្តីស្ងប់រម្ងាប់) សម្ពោធសុខ (សុខកើតអំពីសេចក្តីត្រាស់ដឹង) បុគ្គលណា ជាអ្នកមិនបានសមតាមប្រាថ្នា មិនបានដោយ មិនបានស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខនេះ បុគ្គលនោះ គប្បីត្រេកអរនឹងសុខកខ្វក់ សុខដោយដេក សុខប្រកបដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទ្រង់ទទួលនិមន្ត សូមព្រះសុគត ទ្រង់ទទួលនិមន្តឥឡូវ បពិត្រព្រះអង្គដ៏ចំរើន កាលនេះគួរព្រះដ៏មានព្រះភាគទទួលនិមន្តណាស់ បពិត្រព្រះអង្គដ៏ចំរើន កាលនេះគួរព្រះដ៏មានព្រះភាគទទួលនិមន្តណាស់ ។ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ព្រះដ៏មានព្រះភាគ ស្តេចនឹងយាងទៅកាន់ទីណា ៗ ពួកព្រាហ្មណ៍គហបតីអ្នកនិគម ជនបទ នឹងបាក់បបទៅតាមព្រះដ៏មានព្រះភាគក្នុងទីនោះៗ ដែរ ។

សេយ្យថាបិ ភន្តេ ថុល្លផុសិតកេ ទេវេ វស្សន្តេ យថានិន្នំ ឧទកានិ បវត្តន្តិ ។ ឯវមេវ ខោ ភន្តេ យេន យេនេវ ភគវា គមិស្សតិ តំនិន្នាវ ភវិស្សន្តិ ព្រាហ្មណគហបតិកា នេគមា ចេវ ជានបទា ច ។ តំ កិស្ស ហេតុ ។ តថា ហិ ភន្តេ ភគវតោ សីលបញ្ញាណន្តិ ។ មាហំ នាគិត យសេន សមាគច្ឆំ មា ច មយា យសោ ។ យោ ខោ នាគិត នយិមស្ស នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភី អស្ស អកិច្ឆលាភី អកសិរលាភី យស្សាហំ នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភី អស្សំ អកិច្ឆលាភី អកសិរលាភី សោ តំ មិឡ្ហសុខំ មិទ្ធសុខំ លាភសក្ការសិលោកសុខំ សាទិយេយ្យ ។ ឥធាហំ នាគិត ភិក្ខុំ បស្សាមិ គាមន្តវិហារំ សមាហិតំ និសិន្នំ តស្ស មយ្ហំ នាគិត ឯវំ ហោតិ ឥទានិ មំ អាយស្មន្តំ អារាមិកោ វា ឃដេស្សតិ សមណុទ្ទេសោ វា សមាធិម្ហា តំ ចាវេស្សតីតិ ។



បពិត្រព្រះអង្គដ៏ចំរើន ដូចជាភ្លៀងមានដំណក់ទឹកធំ ៗ បង្អុរចុះ ទឹករមែងហូរទៅកាន់ទីទំនាប យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ព្រះមានព្រះភាគ នឹងស្តេចទៅកាន់ទីណា ៗ ពួកព្រាហ្មណ៍គហបតី អ្នកនិគម ជនបទ នឹងបង្អោនទៅតាមព្រះមានព្រះភាគ ក្នុងទីនោះ ៗ ក៏យ៉ាងនោះដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចំរើន ព្រោះថាព្រះមានព្រះភាគ មានសីលនឹងបញ្ញា ។ ម្នាលនាគិតៈ តថាគតសុំកុំជួបនឹងយសបរិវារ ឯយសក៏កុំជួបប្រសព្វនឹងតថាគត ( យ៉ាងនេះ ) ឡើយ ។ ម្នាលនាគិតៈ តថាគតជាអ្នកបានសមតាមប្រាថ្នា បានងាយ បានស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ បុគ្គលណាមិនបានសមតាមប្រាថ្នា មិនបានងាយ មិនបានស្រួលនូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខនេះទេ បុគ្គលនោះ គប្បីត្រេកអរនឹងសុខកខ្វក់ សុខងុយដេក សុខប្រកបដោយលាភសក្ការៈ នឹងសេចក្តីសរសើរនោះ ។ ម្នាលនាគិតៈក្នុងទីឯណោះ តថាគតឃើញភិក្ខុ នៅក្នុងសេនាសនៈ ជាប់ក្បែរស្រុក កំពុងអង្គុយចំរើនសមាធិ ម្នាលនាគិតៈ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ជនជាខ្ញុំរបស់អារាម នឹងបៀតបៀនលោកដ៏មានអាយុនេះ ឬក៏សាមណេរ មុខជាញុំាងភិក្ខុនោះឲ្យឃ្លាតចាកសមាធិដែលថ្កើងទេ ។

តេនាហំ នាគិត តស្ស ភិក្ខុនោ ន អត្តមនោ ហោមិ គាមន្តវិហារេន ។ ឥធ បនាហំ នាគិត ភិក្ខុំ បស្សាមិ អារញ្ញិកំ អរញ្ញេ បចលាយមានំ និសិន្នំ តស្ស មយ្ហំ នាគិត ឯវំ ហោតិ ឥទានិ អយមាយស្មា ឥមំ និទ្ទាកិលមថំ បដិវិនោទេត្វា អរញ្ញសញ្ញំ យេវ មនសិករិស្សតិ ឯកត្តន្តិ ។ តេនាហំ នាគិត តស្ស ភិក្ខុនោ អត្តមនោ ហោមិ អរញ្ញវិហារេន ។ ឥធ បនាហំ នាគិត ភិក្ខុំ បស្សាមិ អារញ្ញិកំ អរញ្ញេ អសមាហិតំ និសិន្នំ តស្ស មយ្ហំ នាគិត ឯវំ ហោតិ ឥទានិ អយមាយស្មា អសមាហិតំ វា ចិត្តំ សមាទហិស្សតិ សមាហិតំ វា ចិត្តំ អនុរក្ខិស្សតីតិ ។ តេនាហំ នាគិត តស្ស ភិក្ខុនោ អត្តមនោ ហោមិ អរញ្ញវិហារេន ។ ឥធ បនាហំ នាគិត ភិក្ខុំ បស្សាមិ អារញ្ញិកំ អរញ្ញេ សមាហិតំ និសិន្នំ តស្ស មយ្ហំ នាគិត ឯវំ ហោតិ ឥទានិ អយមាយស្មា អវិមុត្តំ វា ចិត្តំ វិមោចេស្សតិ វិមុត្តំ វា ចិត្តំ អនុរក្ខិស្សតីតិ ។



ម្នាលនាគិតៈ ហេតុនោះ តថាគតមិនពេញចិត្តនឹងភិក្ខុនោះ ព្រោះតែនៅក្នុងសេនាសនៈជាយស្រុក ។ ម្នាលនាគិតៈ មួយទៀត ក្នុងទីឯណោះ តថាគតឃើញភិក្ខុអ្នកនៅក្នុងព្រៃ កំពុងអង្គុយលក់ក្នុងព្រៃ ម្នាលនាគិតៈ តថាគតនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ លោកនេះបន្ទោបង់នូវសេចក្ដីលំបាក ក្នុងកិរិយាងោកលក់នេះ ហើយធ្វើមនសិការៈនូវអរញ្ញសញ្ញាឲ្យប្រសើរឯក ។ ម្នាលនាគិតៈ ហេតុនោះបានជាតថាគតពេញចិត្តនឹងភិក្ខុនោះ ព្រោះតែនៅក្នុងព្រៃ ។ ម្នាលនាគិតៈ មួយទៀត ក្នុងទីឯណោះ តថាគតឃើញភិក្ខុ អ្នកនៅក្នុងព្រៃ មិនអង្គុយចំរើនសមាធិក្នុងព្រៃទេ ម្នាលនាគិតៈ តថាគតនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ លោកនេះនឹងតាំងចិត្ត ដែលមិនទាន់ដល់សមាធិផង រក្សាចិត្តដែលបានដល់សមាធិហើយផង ។ ម្នាលនាគិតៈ ហេតុនេះ បានជាតថាគតពេញចិត្តនឹងភិក្ខុនោះ ព្រោះតែនៅក្នុងព្រៃ ។ ម្នាលនាគិតៈ មួយទៀត ក្នុងទីឯណោះ តថាគតឃើញ ភិក្ខុអ្នកនៅក្នុងព្រៃ បានដល់សមាធិ ហើយអង្គុយនៅក្នុងព្រៃ ម្នាលនាគិតៈ តថាគតនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ លោកនេះ ញុំាងចិត្តដែលមិនទាន់រួចស្រឡះ ឲ្យរួចស្រឡះផង រក្សាទុកនូវចិត្តដែលរួចស្រឡះហើយផង ។

តេនាហំ នាគិត តស្ស ភិក្ខុនោ អត្តមនោ ហោមិ អរញ្ញវិហារេន ។ ឥធ បនាហំ នាគិត ភិក្ខុំ បស្សាមិ គាមន្តវិហារិំ លាភិំ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ សោ តំ លាភសក្ការសិលោកំ និកាមយមានោ រិញ្ចតិ បដិសល្លានំ រិញ្ចតិ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ គាមនិគមរាជធានឹ ឱសរិត្វា វាសំ កប្បេតិ ។ តេនាហំ នាគិត តស្ស ភិក្ខុនោ ន អត្តមនោ ហោមិ គាមន្តវិហារេន ។ ឥធ បនាហំ នាគិត ភិក្ខុំ បស្សាមិ អារញ្ញិកំ លាភិំ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ សោ តំ លាភសក្ការសិលោកំ បដិប្បណាមេត្វា ន រិញ្ចតិ បដិសល្លានំ ន រិញ្ចតិ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ ។ តេនាហំ នាគិត តស្ស ភិក្ខុនោ អត្តមនោ ហោមិ អរញ្ញវិហារេន ។ យស្មាហំ នាគិត



ម្នាលនាគិតៈ ហេតុនោះបានជាតថាគតពេញចិត្តនឹងភិក្ខុនោះ ព្រោះតែនៅក្នុងព្រៃ ។ ម្នាលនាគិតៈ មួយទៀត ក្នុងទីឯណានេះ តថាគតឃើញភិក្ខុអ្នកនៅក្នុងសេនាសនៈ ជាប់ផ្លោះស្រុក ធ្លាប់បានចីវរបិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ កាលបើភិក្ខុនោះបានលាភសក្ការៈ សេចក្តីសរសើរនោះហើយ រមែងលះបង់នូវទីសម្ងំ លះបង់នូវសេនាសនៈដ៏ស្ងាត់ គឺព្រៃទីដងព្រៃ ក៏ជ្រកនៅតែក្នុងស្រុក និគម រាជធានី ។ ម្នាលនាគិតៈ ហេតុនោះបានជាតថាគតមិនពេញចិត្តនឹងភិក្ខុនោះ ព្រោះតែនៅក្នុងសេនាសនៈ ជាប់ផ្លោះស្រុក ។ ម្នាលនាគិតៈ មួយទៀត ក្នុងទីឯណានេះ តថាគតឃើញភិក្ខុអ្នកនៅក្នុងព្រៃ ធ្លាប់បានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ភិក្ខុនោះបន្ទោបង់នូវលាភសក្ការៈ សេចក្តីសរសើរនោះ ហើយមិនលះបង់ទីសេនាសនៈដ៏ស្ងាត់ គឺព្រៃ ទីដងព្រៃ ។ ម្នាលនាគិតៈ ហេតុនោះ បានជាតថាគតពេញចិត្តនឹងភិក្ខុនោះ ព្រោះតែនៅក្នុងព្រៃ ។ ម្នាលនាគិតៈ ពេលណា

សមយេ អទ្ធានមគ្គប្បដិបន្នោ ន កញ្ចិ បស្សាមិ បុរតោ វា បច្ឆតោ វា ផាសុ យេវ តស្មឹ សមយេ ហោតិ អន្តមសោ ឧច្ចារបស្សាវកម្មាយាតិ ។

សេយ្យបរិហានិយវគ្គោ ចតុត្ថោ ។

តស្សុទ្ទានំ

សេក្ខា ទ្វេ អបរិហានិ
មោគ្គល្លានវិជ្ជាភាគិយា
វិវាទជាតក្ខការី និទានំ
កិមិលនាគុទ្ទេន ជាតកោតិ ។



តថាគតដើរទៅកាន់ផ្លូវឆ្ងាយ មិនបានឃើញបុគ្គលណាមួយ ខាងមុខឬខាងក្រោយ ម្នាលនាគិតៈ ពេលនោះ តថាគតមានសេចក្តីសុខសប្បាយ ដោយហោចទៅ (សូម្បីត្រឹមតែ) ធ្វើឧច្ចារៈបស្សាវៈក៏ស្រួលដែរ ។

ចប់ សេយ្យបរិហានិយវគ្គ ទី ៤ ។

## ឧទ្ទាននៃសេយ្យបរិហានិយវគ្គនោះគឺ

និយាយអំពីសេក្ខបរិហានិយធម៌ ១ សេក្ខអបរិហានិយធម៌ ២ លើក សេចក្តីត្រិះរិះនៃព្រះមហាមោគ្គល្លាន ១ ធម៌ជាចំណែកនៃវិជ្ជា ១ មូលហេតុនៃវិវាទ ១ ការឡើពាន ១ មិនមានការធ្វើ (កម្ម) ដើម្បីខ្លួន ១ ហេតុឲ្យកើតកម្មទាំងឡាយ ១ ព្រះកិមិលៈទូលសួរព្រះដ៏មានព្រះភាគ ១ ព្រះសារីបុត្រចង្អុលបង្ហាញគំនរឈើដល់ភិក្ខុទាំងឡាយ ១ នាគិតត្ថេរក្រាបបង្គំព្រះដ៏មានព្រះភាគ ១ ។

## ធម្មិកវគ្គោ

(៦៣) ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថិយំ បិណ្ឌាយ បាវិសិ ។ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន បុព្វារាមោ មិគារមាតុបាសាទោ តេនុបសង្កមិស្សាម ទិវាវិហារាយាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា អាយស្មតា អានន្ទេន សទ្ធឹ យេន បុព្វារាមោ មិគារមាតុបាសាទោ តេនុបសង្កមិ ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ អាយស្មន្តំ អានន្ទំ អាមន្តេសិ អាយាមានន្ទ យេន បុព្វកោដ្ឋកោ តេនុបសង្កមិស្សាម គត្តានិ បរិសិញ្ចិតុន្តិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា អាយស្មតា អានន្ទេន សទ្ធឹ យេន បុព្វកោដ្ឋកោ តេនុបសង្កមិ គត្តានិ បរិសិញ្ចិតុំ ។ បុព្វកោដ្ឋកេ គត្តានិ បរិសិញ្ចិត្វា

## ធម្មិកវគ្គ

(៦៣) សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ។ លុះព្រះអង្គចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថីរួចហើយត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយនៃភត្ត ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ មកយើងនឹងចូលទៅបុព្វារាម ជាមិគារមាតុប្រាសាទ ដើម្បីសម្រាកក្នុងវេលាថ្ងៃ ។ ព្រះអានន្ទដ៏មានអាយុទទួល ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ចូលទៅបុព្វារាមជាមិគារមាតុប្រាសាទ ជាមួយនឹងព្រះអានន្ទដ៏មានអាយុ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ទ្រង់មានព្រះបន្ទូលនឹងអានន្ទដ៏មានអាយុថា ម្នាលអានន្ទ មកយើងនឹងចូលទៅឯស្រះឈ្មោះបុព្វកោដ្ឋកៈ ដើម្បីស្រោចស្រង់ខ្លួន ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ វេលានោះ ព្រះដ៏មានព្រះភាគទ្រង់ចូលទៅឯស្រះបុព្វកោដ្ឋកៈ ជាមួយនឹងព្រះអានន្ទដ៏មានអាយុ ដើម្បីស្រោចស្រង់ព្រះអង្គ ។ លុះព្រះដ៏មានព្រះភាគ ស្រោចស្រង់ព្រះអង្គក្នុងស្រះបុព្វកោដ្ឋកៈរួចហើយ

បច្ចុត្តរិត្វា ឯកចីវរោ អដ្ឋាសិ គត្តានិ បុព្វសមិសានិ ក្បុមានោ(១)។ តេន ខោ បន សមយេន រញ្ញោ បសេនទិស្ស កោសលស្ស សេតោ នាម នាគោ មហាតុរិយតាឡិតវាទិតេន បុព្វកោដ្ឋកា បច្ចុត្តរតិ ។ អបិស្សុ តំ ជនោ ទិស្វា ឯវមាហ អភិរូបោ វត ភោ រញ្ញោ នាគោ ទស្សនីយោ វត ភោ រញ្ញោ នាគោ បាសាទិកោ វត ភោ រញ្ញោ នាគោ កាយុបបន្នោ វត ភោ រញ្ញោ(២) នាគោ នាគោតិ។ ឯវំ វុត្តេ អាយស្មា ឧទាយិ ភគវន្តំ ឯតទវោច ហត្ថិមេវ នុ ខោ ភន្តេ មហន្តំ ព្រហន្តំ(៣) កាយុបបន្នំ ជនោ ទិស្វា ឯវមាហ នាគោ វត ភោ នាគោ ឧទាហុ អញ្ញម្បិ កញ្ចិ មហន្តំ ព្រហន្តំ កាយុបបន្នំ ជនោ ទិស្វា ឯវមាហ នាគោ វត ភោ នាគោតិ ។ ហត្ថិម្បិ ខោ ឧទាយិ មហន្តំ ព្រហន្តំ កាយុបបន្នំ ជនោ ទិស្វា ឯវមាហ នាគោ វត ភោ នាគោតិ ។ អស្សម្បិ ខោ ឧទាយិ មហន្តំ ព្រហន្តំ គោណម្បិ ខោ ឧទាយិ មហន្តំ ព្រហន្តំ

១ ម. បុព្វាបយមានោ ។ ២ ម. ឯត្ថន្តរេ នាគោ នាគោ វត ហោតិ ទិស្សតិ ។ ៣ ម. មហន្តំ ព្រហ្មន្តំ ។



ទ្រង់ត្រឡប់ឡើងមក មានចីវរតែមួយ ទ្រង់ឈរហាលព្រះអង្គឲ្យប្រាកដដូចជាកាលមុន ។ សម័យនោះឯង ដំរីឈ្មោះសេតៈរបស់ព្រះបាទបសេនទិកោសល ត្រូវគេវាយប្រគំតូរ្យតន្ត្រីដ៏ប្រសើរ ក៏ឡើងមកអំពីស្រះបុព្វកោដ្ឋកៈដែរ ។ មហាជនបានឃើញដំរីនោះហើយ ក៏និយាយយ៉ាងនេះថា យីអើ ដំរីរបស់ស្ដេច មានរូបល្អណាស់តើ យីអើ ដំរីរបស់ស្ដេច គួរជាទីរមិលមើលណាស់តើ យីអើ ដំរីរបស់ស្ដេច គួរជាទីជ្រះថ្លាណាស់តើ យីអើ ដំរីរបស់ស្ដេចមានកាយសមរម្យល្អណាស់តើ ។ កាលបើមហាជន និយាយយ៉ាងនេះហើយ ព្រះឧទាយិដ៏មានអាយុ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន មហាជនបានឃើញនូវដំរីធំប្រសើរ មានកាយសមរម្យប៉ុណ្ណោះ ក៏និយាយយ៉ាងនេះថា យីអើ ប្រសើរណាស់តើ ប្រសើរណាស់តើ ឬហ្ន៎ ឬថាមហាជន បានឃើញនូវវត្ថុឯទៀតណាមួយ ធំប្រសើរ មានកាយសមរម្យ ក៏និយាយយ៉ាងនេះថា យីអើ ប្រសើរណាស់តើ ប្រសើរណាស់តើ ។ ម្នាលឧទាយិ មហាជនបានឃើញដំរីធំ ប្រសើរមានកាយសមរម្យក្តី ក៏និយាយយ៉ាងនេះថា យីអើ ប្រសើរណាស់តើ ប្រសើរណាស់តើ ។ ម្នាលឧទាយិ មហាជនបានឃើញសេះធំប្រសើរក្តី ម្នាលឧទាយិ មហាជនបានឃើញគោធំប្រសើរក្តី

ឧរគម្បិ ខោ ឧទាយិ មហន្តំ ព្រហន្តំ រុក្ខម្បិ ខោ ឧទាយិ មហន្តំ ព្រហន្តំ មនុស្សម្បិ ខោ ឧទាយិ មហន្តំ ព្រហន្តំ កាយុបបន្នំ ជនោ ទិស្វា ឯវមាហ នាគោ វត ភោ នាគោតិ ។ អបិ ចុទាយិ យោ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណ-ព្រាហ្មណិយា បជាយ សទេវមនុស្សាយ អាគុំ ន ករោតិ កាយេន វាចាយ មនសា តមហំ នាគោតិ ព្រូមីតិ ។ អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ សុភាសិតមិទំ ភន្តេ ភគវតា ។ អបិ ចុទាយិ យោ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណ-ព្រាហ្មណិយា បជាយ សទេវមនុស្សាយ អាគុំ ន ករោតិ កាយេន វាចាយ មនសា តមហំ នាគោតិ ព្រូមីតិ ។ ឥទញ្ច បនាហំ ភន្តេ ភគវតា សុភាសិតំ ឥមាហិ គាថាហិ អនុមោទាមិ



ម្នាលឧទាយិ មហាជនបានឃើញពស់ធំប្រសើរក្តី ម្នាលឧទាយិ មហាជនបានឃើញដើមឈើធំប្រសើរក្តី ម្នាលឧទាយិ មហាជនបានឃើញមនុស្សធំប្រសើរមានកាយសមរម្យក្តី ហើយក៏និយាយថានាគនេះជា យីអើ ប្រសើរណាស់តើ ប្រសើរណាស់តើ ។ ម្នាលឧទាយិ មួយទៀត បុគ្គលណា ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស មិនធ្វើនូវអំពើអាក្រក់ ដោយកាយ ដោយវាចា ដោយចិត្ត តថាគតហៅបុគ្គលនោះថា នាគៈ គឺបុគ្គលប្រសើរ ដូច្នេះ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះអស្ចារ្យពេកណាស់ បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះចំឡែកពេកណាស់ បពិត្រព្រះអង្គដ៏ចំរើន ព្រោះពាក្យនេះ ព្រះដ៏មានព្រះភាគ ទ្រង់បានពោលហើយដោយប្រពៃ ។ ម្នាលឧទាយិ មួយទៀត បុគ្គលណាក្នុងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្ស ជាសម្មតិទេពនិងមនុស្សដ៏សេស មិនធ្វើនូវអំពើអាក្រក់ដោយកាយ ដោយវាចា ដោយចិត្ត តថាគតហៅបុគ្គលនោះថា នាគៈ ដូច្នេះផង ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យដែលព្រះដ៏មានព្រះភាគទ្រង់សំដែងដោយប្រពៃហើយនេះ ខ្ញុំព្រះអង្គសូមអនុមោទនា ដោយគាថាទាំងនេះថា

មនុស្សភូតំ សម្ពុទ្ធំ អត្តទន្តំ សមាហិតំ

ឥរិយមានំ ព្រហ្មបថេ ចិត្តស្សូបសមេ រតំ

យំ មនុស្សា នមស្សន្តិ សព្វធម្មាន បារគុំ

ទេវាបិ តំ នមស្សន្តិ ឥតិ មេ អរហតោ សុតំ

សព្វសញ្ញោជនាតីតំ វនា និព្វានមាគតំ

កាមេហិ នេក្ខម្មរតំ មុត្តំ សេលាវ កញ្ចនំ

សព្វេ អច្ចរុចី នាគោ ហិមវាញ្ញេ សិលុច្ចយេ

សព្វេសំ នាគនាមានំ សច្ចនាមោ អនុត្តរោ ។

នាគំ វោ កិត្តយិស្សាមិ ន ហិ អាគុំ ករោតិ សោ

សោរច្ចំ អវិហឹសា ច បាទា នាគស្ស តេ ទុវេ



មនុស្សទាំងឡាយ តែងនមស្ការ ព្រះសម្ពុទ្ធអង្គណា ដែលជាមនុស្សជាតិ មានព្រះអង្គទូន្មាន មានព្រះទ័យដំកល់មាំ តាំងនៅក្នុងផ្លូវដ៏ប្រសើរ ត្រេកត្រអាល ក្នុងព្រះនិព្វាន ជាទីរម្ងាប់នូវចិត្ត ដល់នូវត្រើយនៃធម៌ទាំងពួង ពួកទេវតាផង: អាត្មាខ្ញុំបានឮអំពីសំណាក់ នៃព្រះអរហន្តថា សូម្បីពួកទេវតា ក៏តែងនមស្ការ ចំពោះព្រះសម្ពុទ្ធអង្គនោះ ដែលកន្លងផុតនូវសំយោជនៈទាំងអស់ ចេញចាកព្រៃ គឺកិលេស ហើយបានដល់ព្រះនិព្វាន ត្រេកត្រអាលក្នុងការចេញចាកកាមទាំងឡាយ ដូចជាមាស ដែលផុតចាកថ្ម ព្រះពុទ្ធជាបុគ្គលប្រសើរ រុងរឿងកន្លងនូវសត្វទាំងពួង ដូចភ្នំហិមពាន្តដែលរុងរឿងជាងភ្នំដទៃ (ព្រះសម្ពុទ្ធអង្គនោះ) មាននាមប្រាកដប្រសើរជាងនាគនាមទាំងអស់ ។ តថាគតនឹងសំដែងនូវពុទ្ធនាគដល់អ្នកទាំងឡាយ ព្រោះថាពុទ្ធនាគនោះ រមែងមិនធ្វើអំពើអាក្រក់ សេចក្ដីស្ងប់ស្ងៀមនឹងសេចក្ដីមិនបៀតបៀនទាំងពីរនោះ ទុកជាជើងទាំងពីររបស់ពុទ្ធនាគ

តបោ ច ព្រហ្មចរិយំ    ចរណា នាគស្ស ត្យាបរេ

សទ្ធាហត្ថោ មហានាគោ    ឧបេក្ខាសេតទន្តវា

សតិ គីវា សិរោ បញ្ញា    វីមំសា ធម្មចិន្តនា

ធម្មកុច្ឆិសមាវាសោ    វិវេកោ តស្ស វាលធិ ។

សោ ឈាយី អស្សាសរតោ    អជ្ឈត្តសុសមាហិតោ

គច្ឆំ សមាហិតោ នាគោ    ឋិតោ នាគោ សមាហិតោ

សេយ្យំ សមាហិតោ នាគោ    និសិន្នោ ច សមាហិតោ

សព្វត្ថ សំវុតោ នាគោ    ឯសា នាគស្ស សម្បទា ។

ភុញ្ជតិ អនវជ្ជានិ    សាវជ្ជានិ ន ភុញ្ជតិ

ឃាសមច្ឆាទនំ លទ្ធា    សន្និធឹ បរិវជ្ជយេ



តបៈគឺការសមាទានធុតង្គ ព្រហ្មចរិយៈ គឺសីលប្រកប ដោយអរិយមគ្គនោះជាជើងទាំងក្រោយរបស់ពុទ្ធនាគ មហានាគ (នោះ) មានសទ្ធាជាប្រមោយ មានឧបេក្ខាជាភ្លុកស មានសតិជាក មានបញ្ញាជាក្បាល ការគិតនូវធម៌ទុកជាចុង (ប្រមោយ) មានធម៌ គឺចតុត្ថជ្ឈាន-សមាធិ ជាពោះសម្រាប់ទំនុកអាហារ មានសេចក្ដីស្ងប់ស្ងាត់ ជាកន្ទុយរបស់ពុទ្ធនាគនោះ ពុទ្ធនាគនោះមានឈាន មានសេចក្ដីត្រេកអរ ក្នុងការដកដង្ហើមចេញ មានចិត្តដំកល់ខ្ជាប់ក្នុងសន្តាន កាលពុទ្ធនាគដើរក៏មានចិត្តដំកល់ខ្ជាប់ កាលពុទ្ធនាគឈរ ក៏មានចិត្តដំកល់ខ្ជាប់ កាលពុទ្ធនាគសឹង ក៏មានចិត្តដំកល់ខ្ជាប់សូម្បីអង្គុយ ក៏មានចិត្តដំកល់ខ្ជាប់ ពុទ្ធនាគបានសង្រួមក្នុងទ្វារទាំងអស់ នេះជាសម្បទានៃពុទ្ធនាគ ពុទ្ធនាគនោះតែងឆាន់នូវភោជនដែលមិនមានទោស មិនបរិភោគភោជនដែលមានទោស    លុះបានគ្រឿងបរិភោគនិងគ្រឿងស្លៀកដណ្ដប់ ក៏ចៀសវៀងនូវការសន្សំទុកដាក់

សញ្ញោជនំ អណុំ ថូលំ សព្វំ ឆេត្វាន ពន្ធនំ

យេន យេនេវ គច្ឆតិ អនបេក្ខោវ គច្ឆតិ ។

យថាបិ ឧទកេ ជាតំ បុណ្ឌរីកំ បវឌ្ឍតិ

ន ឧបលិប្បតិ តោយេន សុចិគន្ធំ មនោរមំ

តថេវ លោកេ សុជាតោ ពុទ្ធោ លោកេ វិហរតិ

ន ឧបលិប្បតិ លោកេន តោយេន បទុមំ យថា ។

មហាគ្គិនិ បជ្ជលិតោ អនាហារូបសម្មតិ

សង្ខារេសូបសន្តេសុ និព្វុតោតិ បវុច្ចតិ ។

អត្ថស្សាយំ វិញ្ញាបនី ឧបមា វិញ្ញូហិ ទេសិតា ។

វិញ្ញាយន្តិ មហានាគា នាគំ នាគេន ទេសិតំ ។

វីតរាគោ វីតទោសោ វីតមោហោ អនាសវោ

សរីរំ វិជហំ នាគោ បរិនិព្វិស្សតិ អនាសវោតិ ។



ផ្តាច់បង់នូវចំណង គឺសំយោជនៈតូចនិងធំ ទាំងអស់ ហើយទៅក្នុងទីណាៗ មិនអាឡោះអាល័យនូវទីនោះៗ ។ ឈូកសដែលដុះឡើង ចំរើនឡើងក្នុងទឹក មានក្លិនល្អជាទីត្រេកអរនៃចិត្ត មិនជាប់ដោយទឹក ដូចម្តេចមិញ ព្រះពុទ្ធទ្រង់កើតឡើងក្នុងលោក ទ្រង់គង់នៅក្នុងលោក ក៏មិនជាប់ដោយលោកឡើយ ដូចជាផ្កាឈូកមិនជាប់ដោយទឹកដូច្នោះដែរ ។ គំនរភ្លើងធំឆេះឡើង រមែងរលត់ទៅដោយមិនមានអាហារភ្លើង សង្ខារទាំងឡាយស្ងប់រម្ងាប់ទៅ ហៅថា រលត់ដូច្នេះ នេះជាសេចក្តីឧបមាជាគ្រឿងពន្យល់ នូវសេចក្តីនោះ ដែលវិញ្ញូជនទាំងឡាយ បានសំដែងហើយ ។ ពួកមហានាគរមែងដឹងច្បាស់នូវក្តីប្រសើរ ដែលពុទ្ធនាគ បានសំដែងហើយ ពុទ្ធនាគដែលប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មិនមានអាសវៈលះបង់នូវសរីរៈ ជាបុគ្គលមិនមានអាសវៈ នឹងបរិនិព្វាន ។

(៤៤) អថខោ អាយស្មា អានន្ទោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន មិគសាលាយ ឧបាសិកាយ និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ មិគសាលា ឧបាសិកា យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នា ខោ មិគសាលា ឧបាសិកា អាយស្មន្តំ អានន្ទំ ឯតទវោច កថំ កថំ នាមាយំ ភន្តេ អានន្ទ ភគវតា ធម្មោ ទេសិតោ អញ្ញេយ្យោ យត្រ ហិ នាម ព្រហ្មចារី ច អព្រហ្មចារី ច ឧភោ សមសមគតិកា ភវិស្សន្តិ អភិសម្បរាយំ ។ បិតា មេ ភន្តេ បុរាណោ ព្រហ្មចារី អហោសិ អារាចារី វិរតោ មេថុនា គាមធម្មា សោ កាលកតោ ភគវតា ព្យាកតោ សកទាគាមី សត្តោ តុសិតំ កាយំ ឧបបន្នោតិ ។ បិតុ(*) បិយោ មេ ភន្តេ ឥសិទត្តោ អព្រហ្មចារី អហោសិ សទារសន្តុដ្ឋោ

* ១- ម. បេត្តេយ្យោ ។



(៤៤) លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់លំនៅនៃមិគសាលាឧបាសិកា លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលទុក ។ វេលានោះ មិគសាលាឧបាសិកា ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ បានថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះមិគសាលាឧបាសិកា អង្គុយក្នុងទីសមគួរហើយ បាននិយាយនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចំរើន ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយនេះ គួរឲ្យអ្នកផងដឹងបាន ដោយហេតុដូចម្តេច ដូចជាបុគ្គលពីរពួក គឺព្រហ្មចារីបុគ្គល ១ អព្រហ្មចារីបុគ្គល ១ មានគតិស្មើៗ គ្នាក្នុងបរលោក ។ បពិត្រលោកម្ចាស់ដ៏ចំរើន បិតារបស់ខ្ញុំឈ្មោះបុរាណៈ ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ប្រព្រឹត្តឆ្ងាយ វៀរចាកមេថុនជាធម៌របស់អ្នកស្រុក កាលធ្វើមរណកាលទៅ ព្រះដ៏មានព្រះភាគទ្រង់ព្យាករថា ជាសកទាគាមិបុគ្គល បានទៅកើតក្នុងពួកទេវតា ក្នុងស្ថានតុសិត បពិត្រលោកម្ចាស់ដ៏ចំរើន ចំណែកឥសិទត្ត ជាទីស្រឡាញ់នៃបិតារបស់ខ្ញុំ ជាអ្នកមិនប្រព្រឹត្តនូវធម៌ដ៏ប្រសើរទេ ជាអ្នកត្រេកអរតែក្នុងប្រពន្ធរបស់ខ្លួន

សោបិ កាលកតោ ភគវតា ព្យាកតោ សកទាគាមី សត្តោ តុសិតំ កាយំ ឧបបន្នោតិ កថំកថំ នាមាយំ ភន្តេ អានន្ទ ភគវតា ធម្មោ ទេសិតោ អញ្ញេយ្យោ យត្រ ហិ នាម ព្រហ្មចារី ច អព្រហ្មចារី ច ឧភោ សមសមគតិកា ភវិស្សន្តិ អភិសម្បរាយន្តិ ។ ឯវំ ខោ បនេតំ ភគិនិ ភគវតា ព្យាកតន្តិ ។ អថខោ អាយស្មា អានន្ទោ មិគសាលាយ ឧបាសិកាយ និវេសនេ បិណ្ឌបាតំ គហេត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ អាយស្មា អានន្ទោ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន មិគសាលាយ ឧបាសិកាយ និវេសនំ តេនុបសង្កមឹ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទឹ ។



កាលធ្វើមរណកាលទៅ ព្រះដ៏មានព្រះភាគទ្រង់ព្យាករថា ជាសកទាគាមិបុគ្គល បានទៅកើតក្នុងពួកទេវតា ក្នុងស្ថានតុសិតដែរ បពិត្រព្រះអានន្ទដ៏ចំរើន ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយនេះ គួរឲ្យស្គាល់ដឹងបាន ដោយហេតុដូចម្ដេច ដូចយ៉ាងបុគ្គលពីរពួក គឺ ព្រហ្មចារីបុគ្គល ១ អព្រហ្មចារីបុគ្គល ១ មានគតិស្មើ ៗ ក្នុងបរលោក ។ ម្នាលនាង រឿងនុ៎ះ ព្រះដ៏មានព្រះភាគទ្រង់ព្យាករយ៉ាងនឹងហើយ ។ លំដាប់នោះព្រះអានន្ទដ៏មានអាយុ ទទួលយកចង្ហាន់បិណ្ឌបាតក្នុងលំនៅនៃមិគសាលាឧបាសិការួចហើយ ក៏ក្រោកចាកអាសនៈ ចៀសចេញទៅ ។ លុះព្រះអានន្ទដ៏មានអាយុ ត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយនៃភត្តហើយ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់លំនៅនៃមិគសាលាឧបាសិកា លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។

ឥធ ភន្តេ មិគសាលា ឧបាសិកា យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នា ខោ ភន្តេ មិគសាលា ឧបាសិកា មំ ឯតទវោច កថំកថំ នាមាយំ ភន្តេ អានន្ទ ភគវតា ធម្មោ ទេសិតោ អញ្ញេយ្យោ យត្រ ហិ នាម ព្រហ្មចារី ច អព្រហ្មចារី ច ឧភោ សមសមគតិកា ភវិស្សន្តិ អភិសម្បរាយំ ។ បិតា មេ ភន្តេ បុរាណោ ព្រហ្មចារី អហោសិ អារាចារី វិរតោ មេថុនា គាមធម្មា សោ កាលកតោ ភគវតា ព្យាកតោ សកទាគាមី សត្តោ តុសិតំ កាយំ ឧបបន្នោតិ បិតុ បិយោ មេ ភន្តេ ឥសិទត្តោ អព្រហ្មចារី អហោសិ សទារសន្តុដ្ឋោ សោបិ កាលកតោ ភគវតា ព្យាកតោ សកទាគាមី សត្តោ តុសិតំ កាយំ ឧបបន្នោតិ ។ កថំកថំ នាមាយំ ភន្តេ អានន្ទ ភគវតា ធម្មោ ទេសិតោ អញ្ញេយ្យោ យត្រ ហិ នាម ព្រហ្មចារី ច អព្រហ្មចារី ច ឧភោ សមសមគតិកា ភវិស្សន្តិ អភិសម្បរាយន្តិ ។



បពិត្រព្រះអង្គដ៏ចំរើន គ្រានោះ មិគសាលាឧបាសិកា ចូលមករកខ្ញុំព្រះអង្គ លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំខ្ញុំព្រះអង្គ ហើយអង្គុយក្នុងទីដ៏សមគួរ ។ បពិត្រព្រះអង្គដ៏ចំរើន លុះមិគសាលាឧបាសិកាអង្គុយក្នុងទីដ៏សមគួរហើយ ក៏បាននិយាយនឹងខ្ញុំព្រះអង្គដូច្នេះថា បពិត្រព្រះអានន្ទដ៏ចំរើន ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងហើយនេះ គួរឲ្យអ្នកផងដឹងបាន ដោយហេតុដូចម្តេច ដូចយ៉ាងបុគ្គលពីរពួកគឺ ព្រហ្មចារីបុគ្គល ១ អព្រហ្មចារីបុគ្គល ១ មានគតិស្មើៗគ្នា ក្នុងបរលោក ។ បពិត្រលោកម្ចាស់ដ៏ចំរើន បិតារបស់ខ្ញុំ ឈ្មោះបុរាណៈ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ប្រព្រឹត្តឆ្ងាយស្រឡះចាកមេថុន ជាធម៌របស់អ្នកស្រុក កាលគាត់ធ្វើមរណកាលទៅ ព្រះដ៏មានព្រះភាគទ្រង់ព្យាករថា ជាសកទាគាមិសត្វ បានទៅកើតក្នុងពួកទេវតា ក្នុងស្ថានតុសិត បពិត្រលោកម្ចាស់ដ៏ចំរើន ឥសិទត្តៈជាទីស្រឡាញ់នៃបិតារបស់ខ្ញុំ ជាអ្នកមិនប្រព្រឹត្តធម៌ដ៏ប្រសើរទេ ជាអ្នកត្រេកអរតែក្នុងប្រពន្ធរបស់ខ្លួន កាលគាត់ធ្វើមរណកាលទៅ ព្រះដ៏មានព្រះភាគទ្រង់ព្យាករថា ជាសកទាគាមិសត្វ បានទៅកើតក្នុងពួកទេវតា ក្នុងស្ថានតុសិតដែរ ។ បពិត្រព្រះអានន្ទដ៏ចំរើន ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយនេះ គួរឲ្យអ្នកផងដឹងបាន ដោយហេតុដូចម្តេច ដូចយ៉ាងបុគ្គលពីរពួកគឺ ព្រហ្មចារីបុគ្គល ១ អព្រហ្មចារីបុគ្គល ១ មានគតិស្មើៗគ្នា ក្នុងបរលោក ។

យំ វុត្ត អហំ ភន្តេ មិគសាលំ ឧបាសិកំ ឯវមវោចំ យំ ខោ បនេតំ គតិំ គតាកា ព្យាករោន្តិ ។ កា ចានន្ទ មិគសាលា ឧបាសិកា ពាលា អព្យត្តា អម្មកា អម្មកសញ្ញា កេ ច បុរិសបុគ្គលបរោបរិយញ្ញាណេ ឆយិមេ អានន្ទ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ ឆ ។ ឥធានន្ទ ឯកច្ចោ បុគ្គលោ សោរតោ ហោតិ សុខសំវាសោ អភិនន្ទន្តិ សព្រហ្មចារី ឯកត្តវាសេន ។ តស្ស សវនេនបិ អកតំ ហោតិ ពាហុសច្ចេនបិ អកតំ ហោតិ ទិដ្ឋិយាបិ អប្បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តឹ ន លភតិ ។ សោ កាយស្ស ភេទា បរម្មរណា ហានាយ បរេតិ នោ វិសេសាយ ហានគាមីយេវ ហោតិ នោ វិសេសគាមី ។ ឥធ បនានន្ទ ឯកច្ចោ បុគ្គលោ



បពិត្រព្រះអង្គដ៏ចំរើន ការដែលមិគសាលាឧបាសិកា និយាយយ៉ាងនេះ ហើយខ្ញុំព្រះអង្គបាននិយាយនឹងមិគសាលាឧបាសិកាដូច្នេះថា ម្នាលនាង រឿងនុ៎ះ ព្រះដ៏មានព្រះភាគព្យាករយ៉ាងហ្នឹងនែងហើយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ មិគសាលាឧបាសិកាណា ជាស្ត្រីល្ងង់ មិនឈ្លាស មានសភាពជាស្ត្រី មានសញ្ញាជាស្ត្រី ព្រះសម្មាសម្ពុទ្ធទាំង ញាណណា មានវិស័យមិនបានទៅសពាល់ គឺសេចក្តីដឹងនូវសេចក្តីចំរើនឹងថយនៃបុរសបុគ្គលទាំងពីរនោះ ឆ្ងាយអំពីញាណណាស់ ។ ម្នាលអានន្ទ បុគ្គល ៦ ពួកនេះ មានប្រាកដក្នុងលោក ។ បុគ្គលទាំង ៦ ពួកគឺដូចម្តេច ។ ម្នាលអានន្ទ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកស្លូត ជាអ្នកមានសំវាសជាសុខ ពួកសព្រហ្មចារី រមែងត្រេកអរដោយការនៅជាមួយ (នឹងបុគ្គលនោះ) ។ បុគ្គលនោះ មិនបានធ្វើដោយការស្តាប់ផង មិនបានធ្វើដោយសេចក្តីព្យាយាមផង មិនចាក់ធ្លុះដោយទិដ្ឋិផង មិនបាននូវវិមុត្តិ ក៏ បំពេញនិងបាតុភ: ដែលអាស្រ័យនូវការស្តាប់ធម៌សព្វកាលផង ។ លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ មិនប្រព្រឹត្តទៅដើម្បីគុណវិសេស ជាអ្នកដល់នូវការសាបសូន្យមិនដល់នូវគុណវិសេស ។ ម្នាលអានន្ទ បុគ្គលពួកខ្លះ ក្នុងលោកនេះ

សោរតោ ហោតិ សុខសំវាសោ អភិនន្ទន្តិ សព្រហ្មចារី ឯកត្តវាសេន ។ តស្ស សវនេនបិ កតំ ហោតិ ពាហុសច្ចេនបិ កតំ ហោតិ ទិដ្ឋិយាបិ បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តិំ លភតិ ។ សោ កាយស្ស ភេទា បរម្មរណា វិសេសាយ បរេតិ នោ ហានាយ វិសេសគាមីយេវ ហោតិ នោ ហានគាមី ។ តត្រានន្ទ បមាណិកា បមិណន្តិ ឥមស្សបិ តេវ ធម្មា អបរស្សបិ តេវ ធម្មា កស្មា តេសំ ឯកោ ហីនោ ឯកោ បណីតោតិ ។ តញ្ហិ តេសំ អានន្ទ ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយ ។ តត្រានន្ទ យ្វាយំ បុគ្គលោ សោរតោ ហោតិ សុខសំវាសោ អភិនន្ទន្តិ សព្រហ្មចារី ឯកត្តវាសេន ។ តស្ស សវនេនបិ កតំ ហោតិ ពាហុសច្ចេនបិ កតំ ហោតិ ទិដ្ឋិយាបិ បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តិំ លភតិ ។



ជាអ្នកស្លូត មានសំវាសជាសុខ ពួកសព្រហ្មចារី រមែងត្រេកអរដោយការនៅជាមួយនឹងបុគ្គលនោះ ។ បុគ្គលនោះ បានធ្វើដោយការស្តាប់ផង បានធ្វើដោយសេចក្តីព្យាយាមផង បានចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិ គឺបីតិនិងបាមោជ្ជៈ ដែលអាស្រ័យនូវការស្តាប់ធម៌តាមកាលផង ។ លុះបុគ្គលនោះបែកធ្លាយចាកកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីគុណវិសេស មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ ជាអ្នកដល់នូវគុណវិសេស មិនដល់នូវសេចក្តីសាបសូន្យ ។ ម្នាលអានន្ទ បុគ្គលអ្នកកាន់យកប្រមាណក្នុងធម៌នោះ រមែងនឹងប្រមាណថា នេះជាធម៌របស់អ្នកនេះ នោះជាធម៌របស់អ្នកឯទៀត ហេតុដូចម្តេចបានជាអ្នកទាំងនោះ មានធម៌មួយថោកទាប មានធម៌មួយខ្ពស់ ។ ម្នាលអានន្ទ ព្រោះថា ដំណើរនោះប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាស ដើម្បីសេចក្តីទុក្ខ អស់កាលជាយូរអង្វែងដល់បុគ្គលទាំងនោះ ។ ម្នាលអានន្ទ ក្នុងរឿងនោះ បុគ្គលណាជាអ្នកស្លូត មានសំវាសជាសុខ ពួកសព្រហ្មចារី រមែងត្រេកអរដោយការនៅជាមួយនឹងបុគ្គលនោះ ។ បុគ្គលនោះ បានធ្វើដោយការស្តាប់ផង បានធ្វើដោយសេចក្តីព្យាយាមផង បានចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិ គឺបីតិនិងបាមោជ្ជៈ ដែលអាស្រ័យនូវការស្តាប់ធម៌តាមកាលផង ។

អយំ អានន្ទ បុគ្គលោ អមុនា បុរិមេន បុគ្គលេន អភិក្កន្តតរោ ច បណីតតរោ ច ។ តំ កិស្ស ហេតុ ។ ឥមញ្ហានន្ទ បុគ្គលំ ធម្មសោតោ និព្ពហតិ ។ តទនន្តរំ កោ ជានេយ្យ អញ្ញត្រ តថាគតេន ។ តស្មាតិហានន្ទ មា បុគ្គលេសុ បមាណិកា អហុវត្ថ មា បុគ្គលេសុ ច បមាណំ គណ្ហិត្ថ ។ ខញ្ញតិ ហានន្ទ បុគ្គលេសុ បមាណំ គណ្ហន្តោ ។ អហំ វា អានន្ទ បុគ្គលេសុ បមាណំ គណ្ហេយ្យំ យោ វា បនស្ស មាទិសោ ។ ឥធ បនានន្ទ ឯកច្ចស្ស បុគ្គលស្ស កោធមានោ អធិគតោ ហោតិ សមយេន សមយញ្ចស្ស លោភធម្មា ឧប្បជ្ជន្តិ ។ តស្ស សវនេនបិ អកតំ ហោតិ ពាហុសច្ចេនបិ អកតំ ហោតិ ទិដ្ឋិយាបិ អប្បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តឹ ន លភតិ ។



ម្នាលអានន្ទ បុគ្គលនេះ ប្រសើរជាង ទាំងឧត្តមជាងបុគ្គលជាន់មុនឯណោះ ៗ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលអានន្ទ ព្រោះធម្មសោតៈគឺវិបស្សនាញាណ រមែងដឹកនាំនូវបុគ្គលនេះ (ឲ្យបានសម្រេចអរិយភូមិ) ។ លំដាប់តពីនោះមក អ្នកណាហ្ន៎នឹងដឹងបាននូវហេតុនោះកើត លើកលែងតែព្រះតថាគតចេញ ។ ម្នាលអានន្ទ ព្រោះហេតុនោះ បុគ្គលក្នុងលោកនេះ កុំប្រកបដោយប្រមាណ ក្នុងបុគ្គលទាំងឡាយផង កុំប្រកាន់យកនូវប្រមាណក្នុងបុគ្គលទាំងឡាយផង ។ ម្នាលអានន្ទ ព្រោះថា បុគ្គលកាន់យកនូវប្រមាណក្នុងបុគ្គលទាំងឡាយហើយ ទៅជា ជីករំលើងនូវគុណ ។ ម្នាលអានន្ទ តថាគតគប្បីកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយបាន ឬបុគ្គលណាប្រហែលនឹងតថាគត (គឺគប្បីកាន់យកនូវប្រមាណក្នុងបុគ្គលទាំងឡាយបានដែរ) ។ ម្នាលអានន្ទ បុគ្គលពួកខ្លះ ក្នុងលោកនេះ មានសេចក្តីក្រោធ នឹងមានះ ត្រួតសង្កត់ហើយ លោភធម៌ រមែងកើតឡើងដល់បុគ្គលនោះ សព្វ ៗ កាល ។ បុគ្គលនោះ មិនបានធ្វើដោយការស្តាប់ផង មិនបានធ្វើដោយសេចក្តីព្យាយាមផង មិនបានចាក់ធ្លុះដោយទិដ្ឋិផង មិនបាននូវវិមុត្តិ ដែលអាស្រ័យនូវការស្តាប់ធម៌សព្វកាលផង ។

សោ កាយស្ស ភេទា បរម្មរណា ហានាយ បរេតិ នោ វិសេសាយ ហានគាមីយេវ ហោតិ នោ វិសេសគាមី ។ ឥធ បនានន្ទ ឯកច្ចស្ស បុគ្គលស្ស កោធមានោ អធិគតោ ហោតិ សមយេន សមយញ្ចស្ស លោភធម្មា ឧប្បជ្ជន្តិ ។ តស្ស សវនេនបិ កតំ ហោតិ ។បេ។ ឥធ បនានន្ទ ឯកច្ចស្ស បុគ្គលស្ស កោធមានោ អធិគតោ ហោតិ សមយេន សមយញ្ចស្ស វចីសង្ខារា ឧប្បជ្ជន្តិ ។ តស្ស សវនេនបិ អកតំ ហោតិ ពាហុសច្ចេនបិ អកតំ ហោតិ ទិដ្ឋិយាបិ អប្បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តិំ ន លភតិ ។ សោ កាយស្ស ភេទា បរម្មរណា ហានាយ បរេតិ នោ វិសេសាយ ហានគាមីយេវ ហោតិ នោ វិសេសគាមី ។ ឥធ បនានន្ទ ឯកច្ចស្ស បុគ្គលស្ស កោធមានោ អធិគតោ ហោតិ សមយេន សមយញ្ចស្ស វចីសង្ខារា ឧប្បជ្ជន្តិ ។ តស្ស សវនេនបិ កតំ ហោតិ ពាហុសច្ចេនបិ កតំ ហោតិ ទិដ្ឋិយាបិ បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តិំ លភតិ ។



លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ មិនប្រព្រឹត្តទៅ ដើម្បីគុណវិសេស ជាបុគ្គលដល់នូវសេចក្តីសាបសូន្យ មិនដល់នូវគុណវិសេសឡើយ ។ ម្នាលអានន្ទ បុគ្គលពួកខ្លះ ក្នុងលោកនេះ មានសេចក្តីក្រោធ នឹងមានះគ្របសង្កត់ហើយ លោភធម៌ រមែងកើតឡើងដល់បុគ្គលនោះសព្វ ៗ កាល ។ បុគ្គលនោះ បានធ្វើដោយការស្តាប់ផង ។បេ។ ម្នាលអានន្ទ បុគ្គលពួកខ្លះ ក្នុងលោកនេះ មានសេចក្តីក្រោធ នឹងមានះគ្របសង្កត់ហើយ វចីសង្ខារ រមែងកើតឡើង ដល់បុគ្គលនោះ សព្វ ៗ កាល ។ បុគ្គលនោះមិនបានធ្វើដោយការស្តាប់ផង មិនបានធ្វើដោយសេចក្តីព្យាយាមផង មិនបានចាក់ធ្លុះដោយទិដ្ឋិផង មិនបាននូវវិមុត្តិ ដែលអាស្រ័យនូវការស្តាប់ធម៌សព្វកាលផង ។ លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ មិនប្រព្រឹត្តទៅ ដើម្បី គុណវិសេស ជាបុគ្គលដល់នូវការសាបសូន្យ មិនដល់នូវគុណវិសេស ។ ម្នាលអានន្ទ បុគ្គលពួកខ្លះ ក្នុងលោកនេះ មានសេចក្តីក្រោធ នឹងមានះ គ្របសង្កត់ហើយ វចីសង្ខារ រមែងកើតឡើង ដល់បុគ្គលនោះសព្វ ៗ កាល ។ បុគ្គលនោះ បានធ្វើដោយការស្តាប់ផង បានធ្វើដោយសេចក្តីព្យាយាមផង បានចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិ ដែលអាស្រ័យនូវការស្តាប់ធម៌ សព្វកាលផង ។

សោ កាយស្ស ភេទា បរម្មរណា វិសេសាយ បរេតិ នោ ហានាយ វិសេសគាមីយេវ ហោតិ នោ ហានគាមី ។ តត្រានន្ទ បមាណិកា បមិណន្តិ ឥមស្សបិ តេវ ធម្មា អបរស្សបិ តេវ ធម្មា កស្មា តេសំ ឯកោ ហីនោ ឯកោ បណីតោតិ ។ តញ្ហិ តេសំ អានន្ទ ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយ ។ តត្រានន្ទ យស្ស បុគ្គលស្ស កោធមានោ អធិគតោ ហោតិ សមយេន សមយញ្ចស្ស វចីសង្ខារា ឧប្បជ្ជន្តិ ។ តស្ស សវនេនបិ កតំ ហោតិ ពាហុសច្ចេនបិ កតំ ហោតិ ទិដ្ឋិយាបិ បដិវិទ្ធំ ហោតិ សាមាយិកម្បិ វិមុត្តិំ លភតិ ។ អយំ អានន្ទ បុគ្គលោ អមុនា បុរិមេន បុគ្គលេន អភិក្កន្តតរោ ច បណីតតរោ ច ។ តំ កិស្ស ហេតុ ។ ឥមញ្ហានន្ទ បុគ្គលំ ធម្មសោតោ និព្វហតិ ។ តទន្តរំ កោ ជានេយ្យ អញ្ញត្រ តថាគតេន ។ តស្មាតិហានន្ទ មា បុគ្គលេសុ បមាណិកា អហុវត្ថ



លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីគុណវិសេស មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ ជាបុគ្គលដល់នូវគុណវិសេស មិនដល់នូវសេចក្តីសាបសូន្យ ។ ម្នាលអានន្ទ បុគ្គលអ្នកកាន់យកនូវប្រមាណ រមែងថ្លឹងប្រមាណក្នុងធម៌នោះថា នេះជាធម៌របស់អ្នកនេះ នេះជាធម៌របស់អ្នកឯទៀត ព្រោះហេតុអ្វី បានជាបុគ្គលទាំងនោះ មានធម៌មួយថោកទាប មានធម៌មួយឧត្តម ។ ម្នាលអានន្ទ ព្រោះថា ដំណើរនោះប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលជាយូរអង្វែង ដល់បុគ្គលទាំងនោះ ។ ត្រង់នោះ បុគ្គលណា មានសេចក្តីក្រោធ នឹងមានះគ្របសង្កត់ហើយ វចីសង្ខារ រមែងកើតឡើង ដល់បុគ្គលនោះជួនកាល ។ បុគ្គលនោះ បានធ្វើដោយការស្តាប់ផង បានធ្វើដោយសេចក្តីព្យាយាមផង បានចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិដែលអាស្រ័យនូវការស្តាប់តាមសម័យកាលផង ។ ម្នាលអានន្ទ បុគ្គលនេះប្រសើរជាង ឧត្តមជាងបុគ្គលជាខាងមុខឯណោះ ។ រឿងនោះព្រោះហេតុអ្វី ។ ម្នាលអានន្ទ ព្រោះធម្មសោតៈគឺវិបស្សនាញាណ ដឹកនាំនូវបុគ្គលនេះ (ឲ្យបានសម្រេចអរិយភូមិ) ។ លំដាប់តពីនោះមក អ្នកណានឹងដឹងបាននូវហេតុនោះកើត លើកលែងតែព្រះតថាគតចេញ ។ ម្នាលអានន្ទ ព្រោះហេតុនោះ បុគ្គលក្នុងលោកនេះ កុំប្រកបដោយប្រមាណ ក្នុងបុគ្គលទាំងឡាយផង

មា បុគ្គលេសុ ច បមាណំ គណ្ហិត្ថ ។ ខញ្ញតិ ហានន្ទ បុគ្គលេសុ បមាណំ គណ្ហន្តោ ។ អហំ វា អានន្ទ បុគ្គលេសុ បមាណំ គណ្ហេយ្យំ យោ វា បនស្ស មាទិសោ ។ កា ចានន្ទ មិគសាលា ឧបាសិកា ពាលា អព្យត្តា អម្ពកា អម្ពកសញ្ញា កេ ច បុរិស-បុគ្គលបរោបរិយញ្ញាណេ ។ ទ្វេមេ ខោ អានន្ទ ឧ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ យថារូបេន អានន្ទ សីលេន បុរាណោ សមន្នាគតោ អហោសិ តថារូបេន សីលេន ឥសិទត្តោ សមន្នាគតោ អភវិស្ស នយិធ បុរាណោ ឥសិទត្តស្ស គតិម្បិ អញ្ញស្ស ។ យថារូបាយ ច អានន្ទ បញ្ញាយ ឥសិទត្តោ សមន្នាគតោ អហោសិ តថារូបាយ បញ្ញាយ បុរាណោ សមន្នាគតោ អភវិស្ស នយិធ ឥសិទត្តោ បុរាណស្ស គតិម្បិ អញ្ញស្ស ។ ឥតិ ខោ អានន្ទ ឥមេ បុគ្គលា ឧភោ ឯកង្គហីនាតិ ។



កុំប្រកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយឡើយ ។ ម្នាលអានន្ទ ព្រោះថា កាលបុគ្គលកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយ ហៅថា ជីករំលើងនូវគុណ ។ ម្នាលអានន្ទ តថាគតកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយបាន ឬបុគ្គលណាប្រាកដដូចតថាគត (គឺគប្បីកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយបានដែរ) ។ ម្នាលអានន្ទ មិគសាលាឧបាសិកាណាក្តី ជាស្ត្រីល្ងង់ មិនឈ្លាស មានសភាពជាស្ត្រី មានសញ្ញាជាស្ត្រី ព្រះសម្មាសម្ពុទ្ធទាំងឡាយណាក្តី មានវិស័យមិនបានទើសទាល់ ក្នុងសេចក្តីដឹងនូវឥន្ទ្រិយរឹងនឹងទន់ របស់បុរសបុគ្គល បុគ្គលទាំងពីរនោះ ខុសអំពីគ្នាណាស់ ។ ម្នាលអានន្ទ បុគ្គល ២ ពួកនេះឯង មានប្រាកដក្នុងលោក ។ ម្នាលអានន្ទ បុរាណឧបាសកប្រកបដោយសីល មានសភាពយ៉ាងណា ឥសិទត្ត ក៏ប្រកបដោយសីល មានសភាពយ៉ាងនោះដែរ តែបុរាណឧបាសក មិនបានដឹងនូវគតិរបស់ឥសិទត្តក្នុងលោកនេះឡើយ ។ ម្នាលអានន្ទ ឥសិទត្តប្រកបដោយបញ្ញា មានសភាពយ៉ាងណា បុរាណឧបាសក ក៏ប្រកបដោយបញ្ញា មានសភាពយ៉ាងនោះដែរ តែឥសិទត្ត មិនបានដឹងនូវគតិរបស់បុរាណឧបាសក ក្នុងលោកនេះឡើយ ។ ម្នាលអានន្ទ បុគ្គលទាំងពីរនាក់នេះ មានសេចក្តីសាបសូន្យដោយអង្គ ១ ដូច្នេះឯង ។

(៤៥) ទាលិទ្ទិយំ ភិក្ខវេ ទុក្ខំ លោកស្មឹ កាមភោគិ-នោតិ ។ ឯវំ ភន្តេ ។ យម្បិ ភិក្ខវេ ទលិទ្ទោ អស្សកោ អនាឡ្ហិកោ ឥណំ អាទិយតិ ឥណាទានម្បិ ភិក្ខវេ ទុក្ខំ លោកស្មឹ កាមភោគិនោតិ ។ ឯវំ ភន្តេ ។ យម្បិ ភិក្ខវេ ទលិទ្ទោ អស្សកោ អនាឡ្ហិកោ ឥណំ អាទិយិត្វា វឌ្ឍឹ បដិស្សុណាតិ វឌ្ឍិបិ ភិក្ខវេ ទុក្ខា លោកស្មឹ កាមភោគិនោតិ ។ ឯវំ ភន្តេ ។ យម្បិ ភិក្ខវេ ទលិទ្ទោ អស្សកោ អនាឡ្ហិកោ វឌ្ឍឹ បដិស្សុណិត្វា កាលាភតំ វឌ្ឍឹ ន ទេតិ ចោទេន្តិបិ នំ ចោទនាបិ ភិក្ខវេ ទុក្ខា លោកស្មឹ កាមភោគិនោតិ ។ ឯវំ ភន្តេ ។ យម្បិ ភិក្ខវេ ទលិទ្ទោ អស្សកោ អនាឡ្ហិកោ ចោទិយមានោ ន ទេតិ អនុចរន្តិបិ នំ អនុចរិយាបិ ភិក្ខវេ ទុក្ខា លោកស្មឹ កាមភោគិនោតិ ។



(៤៥) ម្នាលភិក្ខុទាំងឡាយ សេចក្តីកំសត់ក្រ ជាទុក្ខនៃកាមភោគី-បុគ្គល (បុគ្គលអ្នកបរិភោគកាម) ក្នុងលោកដែរឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកំសត់ក្រ មិនមានទ្រព្យជារបស់ខ្លួន មិនបានជាបុគ្គលស្តុកស្តម្ភ កាន់យកខ្ចីបំណុលណា ម្នាលភិក្ខុទាំងឡាយ ការកាន់យកខ្ចីបំណុលនោះ ជាទុក្ខនៃកាមភោគីបុគ្គលក្នុងលោកដែរឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកំសត់ក្រ មិនមានទ្រព្យជារបស់ខ្លួន មិនបានជាបុគ្គលស្តុកស្តម្ភ កាន់យកខ្ចីបំណុលហើយ ប្តេជ្ញានូវកើនចំណីការណា ម្នាលភិក្ខុទាំងឡាយ កំណើនចំណីការនោះ ជាទុក្ខនៃកាមភោគី-បុគ្គលក្នុងលោកដែរឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកំសត់ក្រ មិនមានទ្រព្យជារបស់ខ្លួន មិនបានជាបុគ្គលស្តុកស្តម្ភ ប្តេជ្ញានូវកើនចំណីការហើយ មិនឲ្យការដែលគេឲ្យនាំមកតាមកំណត់កាល ម្ចាស់បំណុលទាំងឡាយ តែងតឹងទារនូវបុគ្គលនោះ ដោយការតឹងទារណា ម្នាលភិក្ខុទាំងឡាយ ការតឹងទារនោះ ជាទុក្ខនៃកាមភោគីបុគ្គលក្នុងលោកដែរឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកំសត់ក្រ មិនមានទ្រព្យជារបស់ខ្លួន មិនបានជាបុគ្គលស្តុកស្តម្ភ កាលបើគេតឹងទារហើយមិនបានឲ្យគេ តែងដេញតាមនូវបុគ្គលនោះ ដោយការដេញតាមការណា ម្នាលភិក្ខុទាំងឡាយ ការដេញតាមនោះ ជាទុក្ខនៃកាមភោគីបុគ្គលក្នុងលោកដែរឬ ។

ឯវំ ភន្តេ ។ យម្បិ ភិក្ខវេ ទលិទ្ទោ អស្សកោ អនឡ្ហិកោ អនុចរិយមានោ ន ទេតិ ពន្ធន្តិបិ នំ ពន្ធនម្បិ ភិក្ខវេ ទុក្ខំ លោកស្មិំ កាមភោគិនោតិ ។ ឯវំ ភន្តេ ។ ឥតិ ខោ ភិក្ខវេ ទាលិទ្ទិយម្បិ ទុក្ខំ លោកស្មិំ កាមភោគិនោ ឥណាទានម្បិ ទុក្ខំ លោកស្មិំ កាមភោគិនោ វឌ្ឍិបិ ទុក្ខា លោកស្មិំ កាមភោគិនោ ចោទនាបិ ទុក្ខា លោកស្មិំ កាមភោគិនោ អនុចរិយាបិ ទុក្ខា លោកស្មិំ កាមភោគិនោ ពន្ធនម្បិ ទុក្ខំ លោកស្មិំ កាមភោគិនោ ។ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ សទ្ធា នត្ថិ កុសលេសុ ធម្មេសុ ហិរី នត្ថិ កុសលេសុ ធម្មេសុ ឱត្តប្បំ នត្ថិ កុសលេសុ ធម្មេសុ វិរិយំ នត្ថិ កុសលេសុ ធម្មេសុ បញ្ញា នត្ថិ កុសលេសុ ធម្មេសុ ។ អយំ វុច្ចតិ ភិក្ខវេ អរិយស្ស វិនយេ ទលិទ្ទោ អស្សកោ អនឡ្ហិកោ ។ ស ខោ សោ ភិក្ខវេ ទលិទ្ទោ អស្សកោ



ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទ័លក្រ មិនមានទ្រព្យជារបស់ខ្លួន មិនបានជាបុគ្គលស្តុកស្តម្ភ កាលបើគេដេញតាមទារ ក៏មិនបានឲ្យគេ គេរមែងចងនូវបុគ្គលនោះដោយចំណងណា ម្នាលភិក្ខុទាំងឡាយ ចំណងនោះជាទុក្ខនៃកាមភោគីបុគ្គលក្នុងលោកដែរឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីទ័លក្រក្តី ក៏ជាទុក្ខនៃកាមភោគីបុគ្គលក្នុងលោក ការខ្ចីយកនូវបំណុលក្តី ក៏ជាទុក្ខនៃកាមភោគីបុគ្គលក្នុងលោក ការពិពង់ការក្តី ក៏ជាទុក្ខនៃកាមភោគីបុគ្គលក្នុងលោក ការតឹងទារក្តី ក៏ជាទុក្ខនៃកាមភោគីបុគ្គលក្នុងលោក ការដេញតាមទារក្តី ក៏ជាទុក្ខនៃកាមភោគីបុគ្គល ក្នុងលោក ការចងក្តី ក៏សុទ្ធតែជាទុក្ខនៃកាមភោគីបុគ្គល ក្នុងលោកដោយពិត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ មិនមានសទ្ធា ក្នុងកុសលធម៌ មិនមានហិរិ ក្នុងកុសលធម៌ មិនមានឱត្តប្បៈ ក្នុងកុសលធម៌ មិនមានវីរិយៈ ក្នុងកុសលធម៌ មិនមានបញ្ញា ក្នុងកុសលធម៌ ក៏យ៉ាងដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ គេហៅថា បុគ្គលទ័លក្រ មិនមានទ្រព្យជារបស់ខ្លួន មិនបានជាបុគ្គលស្តុកស្តម្ភ ក្នុងអរិយវិន័យ ម្នាលភិក្ខុទាំងឡាយ បុគ្គលទ័លក្រនោះឯង មិនមានទ្រព្យជារបស់ខ្លួន

អនាឡ្ហិកោ សទ្ធាយ អសតិ កុសលេសុ ធម្មេសុ ហិរិយា អសតិ កុសលេសុ ធម្មេសុ ឱត្តប្បេ អសតិ កុសលេសុ ធម្មេសុ វិរិយេ អសតិ កុសលេសុ ធម្មេសុ បញ្ញាយ អសតិ កុសលេសុ ធម្មេសុ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ ។ ឥទមស្ស ឥណាទានស្មិំ វទាមិ ។ សោ តស្ស កាយទុច្ចរិតស្ស បដិច្ឆាទនហេតុ បាបិកំ ឥច្ឆំ បណិទហតិ មា មំ ជញ្ញូតិ ឥច្ឆតិ មា មំ ជញ្ញូតិ សង្កប្បេតិ មា មំ ជញ្ញូតិ វាចំ ភាសតិ មា មំ ជញ្ញូតិ កាយេន បរក្កមតិ ។ សោ តស្ស វចីទុច្ចរិតស្ស បដិច្ឆាទនហេតុ ។ បេ ។ សោ តស្ស មនោទុច្ចរិតស្ស បដិច្ឆាទនហេតុ បាបិកំ ឥច្ឆំ បណិទហតិ មា មំ ជញ្ញូតិ ឥច្ឆតិ មា មំ ជញ្ញូតិ សង្កប្បេតិ មា មំ ជញ្ញូតិ វាចំ ភាសតិ មា មំ ជញ្ញូតិ កាយេន បរក្កមតិ ។ ឥទមស្ស វឌ្ឍិយា វទាមិ ។



មិនមានទ្រព្យជាបុគ្គលស្ដុកស្ដម្ភ កាលបើមិនមានសទ្ធា ក្នុងកុសលធម៌ មិនមានហិរិ ក្នុងកុសលធម៌ មិនមានឱត្តប្បៈ ក្នុងកុសលធម៌ មិនមានវីរិយៈ ក្នុងកុសលធម៌ មិនមានបញ្ញា ក្នុងកុសលធម៌ហើយ រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ តថាគតពោលនូវអំពើនេះថាជា ការកាន់យកនូវបំណុលរបស់បុគ្គលនោះ ។ បុគ្គលនោះ រមែងដំកល់ទុកនូវសេចក្ដីប្រាថ្នាដ៏លាមក ព្រោះហេតុតែការបិទបាំងនូវកាយទុច្ចរិតនោះ ប្រាថ្នាមិនឲ្យជនណាស្គាល់ខ្លួន ត្រិះរិះមិនឲ្យជនណាស្គាល់ខ្លួន ពោលនូវវាចាមិនឲ្យជនណាស្គាល់ខ្លួន ប្រឹងប្រែងដោយកាយ មិនឲ្យជនណាស្គាល់ខ្លួនឡើយ ។ បុគ្គលនោះ ព្រោះហេតុតែការបិទបាំងនូវវចីទុច្ចរិតនោះ ។ បេ ។ បុគ្គលនោះ រមែងដំកល់នូវសេចក្ដីប្រាថ្នាដ៏លាមក ព្រោះហេតុតែការបិទបាំងនូវមនោទុច្ចរិតនោះ ប្រាថ្នាមិនឲ្យជនណាស្គាល់ខ្លួន ត្រិះរិះមិនឲ្យជនណាស្គាល់ខ្លួន ពោលនូវវាចាមិនឲ្យជនណាស្គាល់ខ្លួន ប្រឹងប្រែងដោយកាយ មិនឲ្យជនណាស្គាល់ខ្លួនឡើយ ។ តថាគតពោលនូវអំពើនេះថាជាអំពើចងការរបស់បុគ្គលនោះ ។

តមេនំ បេសលា សព្រហ្មចារី បរិវាហន្តិ អយញ្ច សោ អាយស្មា ឯវំការី ឯវំសមាចារោតិ ។ ឯវមស្ស ហានាយ ហោតិ ។ តមេនំ អរញ្ញគតំ វា រុក្ខមូល-គតំ វា សុញ្ញាគារគតំ វា វិប្បដិសារសហគតា បាបកា អកុសលវិតក្កា សមុទាចរន្តិ ។ ឯវមស្ស អនុចរិយាយ ហោតិ ។ សចេ សោ ភិក្ខុ ធជ្ជិត្តោ អស្សុតោ អហិរិកោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា និរយគមនេ វា តព្វតិ តិរច្ឆានយោនិគមនេ វា ។ នាហំ ភិក្ខវេ អញ្ញំ ឯកំ ធម្មំ សមនុបស្សាមិ ឯវំ ឥទ្ធំ ឯវំ កដុកំ[១] ឯវំ អន្តរាយករំ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយ យថយិទំ ភិក្ខវេ និរយគមនំ វា តិរច្ឆានយោនិគមនំ វាតិ ។

ឆញ្ចិត្តិយំ ទុក្ខំ លោកោ ឥណាទានញ្ច វុច្ចតិ
ឆញ្ចិត្តោ ឥណមាទាយ ភុញ្ជមានោ វិហញ្ញតិ

១. ឱកាសុរំ ។



ពួកសព្រហ្មចារី បុគ្គលអ្នកមានសីលជាទីស្រឡាញ់ និយាយពោលបុគ្គលនោះយ៉ាងនេះថា លោកដ៏មានអាយុនោះ ជាអ្នកធ្វើយ៉ាងនេះ មានសមាចារៈយ៉ាងនេះ ។ នេះជាការពោលឡើងអំពីនេះថាជា ការតិះដៀលរបស់បុគ្គលនោះ ។ អកុសលវិតក្កៈដ៏លាមកដែលប្រកបដោយសេចក្តីក្តៅក្រហាយ រមែងផុសផុលឡើងចំពោះបុគ្គលនោះ ដែលនៅក្នុងព្រៃក្តី នៅក្រោមម្លប់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី នេះជាការពោលឡើងអំពីនេះថា ជាការវេញតាមរបស់បុគ្គលនោះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទំលក្រនោះឯង មិនមានវត្តជារបស់ខ្លួន មិនបានជាបុគ្គលសុភស្ពុ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងធ្លាក់ទៅក្នុងចំណាតគឺនរក ឬ ក្នុងចំណាតគឺកំណើតតិរច្ឆាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលឃើញនូវចំណាតដទៃណាមួយអាក្រក់យ៉ាងនេះ ទាំងកន្លងនូវសេចក្តីទុក្ខយ៉ាងនេះ ធ្វើនូវសេចក្តីអន្តរាយយ៉ាងនេះ ដល់ការបាននូវព្រះនិព្វានជាទីក្សេមចាកយោគៈដ៏ប្រសើរទេ ម្នាលភិក្ខុទាំងឡាយ ដូចជាចំណាតគឺ នរក ឬ ចំណាត គឺកំណើតតិរច្ឆាននេះឡើយ ។

សេចក្តីទំលក្រក៏ ការកាន់យកនូវចំណុះលក្ខ ហៅថាជាទុក្ខក្នុងលោក
បុគ្គលទំលក្រ កាន់យកនូវចំណុះលមកចរិកោរ រមែងលំបាក

តតោ អនុចរន្តិ នំ ពន្ធនម្បិ និគច្ឆតិ
ឯតញ្ហិ ពន្ធនំ ទុក្ខំ កាមលាភាភិជប្បិនំ ។
តថេវ អរិយវិនយេ សទ្ធា យស្ស ន វិជ្ជតិ
អហិរិកោ អនោត្តប្បី បាបកម្មំ វិនិព្ពយោ(១)
កាយទុច្ចរិតំ កត្វា វចីទុច្ចរិតានិ ច
មនោទុច្ចរិតំ កត្វា មា មំ ជញ្ញូតិ ឥច្ឆតិ ។
សោ សំសប្បតិ កាយេន វាចាយ ឧទ ចេតសា
បាបកម្មំ បវឌ្ឍេន្តោ តត្ថ តត្ថ បុនប្បុនំ ។
សោ បាបកម្មោ ទុម្មេធោ ជានំ ទុក្កដមត្តនោ
ទលិទ្ទោ ឥណមាទាយ ភុញ្ជមានោ វិហញ្ញតិ ។
តតោ អនុចរន្តិ នំ សង្កប្បា មានសា ទុខា
គាមេ វា យទិ វារញ្ញេ យស្ស វិប្បដិសារជា ។
សោ បាបកម្មោ ទុម្មេធោ ជានំ ទុក្កដមត្តនោ
យោនិមញ្ញតរំ គន្ត្វា និរយេ វាបិ ពជ្ឈតិ

១ ម. វិនិព្ពយោ ។



ព្រោះហេតុនោះ ពួកឥណជាម្ចាស់ រមែងដេញតាមបុគ្គលនោះ បុគ្គលនោះ រមែងដល់នូវចំណង ចំណងនេះឯង ជាទុក្ខនៃបុគ្គលអ្នកប្រាថ្នានូវកាមនិងលាភទាំងឡាយ ។ ក្នុងអរិយ-វិន័យដូច្នោះដែរ បុគ្គលណា មិនមានសទ្ធា មិនមានហិរិ មិនមានឱត្តប្បៈ ជាអ្នកបំប៉ននូវបាបកម្ម ធ្វើនូវកាយទុច្ចរិតផង វចីទុច្ចរិតផង មនោទុច្ចរិតផង ហើយប្រាថ្នាមិនឲ្យជនដទៃស្គាល់ខ្លួនឡើយ ។ បុគ្គលនោះ រមែងញាប់ញ័រដោយកាយ ដោយវាចា ឬដោយចិត្ត ឈ្មោះថា បំប៉ននូវបាបកម្មរឿយ ៗ ក្នុងទីនោះ ៗ ។ បុគ្គលនោះ មានអំពើអា-ក្រក់ឥតប្រាជ្ញា កាលដឹងនូវអំពើអាក្រក់របស់ខ្លួន រមែងលំ-បាកដូចអ្នកទ័លក្រ កាន់យកនូវបំណុលហើយបរិភោគ ។ សេចក្តីត្រិះរិះ ដោយចិត្តកើតឡើង គំនិតសេចក្តីក្តៅក្រហាយរបស់បុគ្គលដែលនៅក្នុងស្រុក ឬនៅក្នុងព្រៃជាទុក្ខ ដូចកូនបំណុល ដែលត្រូវម្ចាស់បំណុលដេញតាមទារ ។ បុគ្គលនោះមានអំពើអាក្រក់ ឥតប្រាជ្ញា កាលដឹងនូវអំពើអាក្រក់របស់ខ្លួន រមែងទៅកាន់កំណើតណាមួយ ឬជាប់នៅក្នុងនរក

ឯតញ្ហិ ពន្ធនំ មុញ្ចំ   យញ្ញា ជនេ បមុច្ចតិ ។
ពន្ធូលទ្វេហិ ភោគេហិ   ធនំ ចិត្តំ បសាទយំ
ទុតិយញ្ច តាដក្ខាហោ   សទ្ធស្ស យសមេសិនោ
និដ្ឋូបន្ទហិតក្ខាយ   សម្បាកយ សុខាយ ច
ឯវមេតំ តហាដ្ឋានំ   ញាតោ បុញ្ញំ បវឌ្ឍតិ ។
តស្មា អរិយវិនយេ   សទ្ធា យស្ស បតិដ្ឋិតា
ហិរិមនោ ច ឱត្តប្បី   បញ្ញវា សីលសំវុតោ
ឋិតោ សោ អរិយវិនយេ   សុខំ ជីវតិ វុច្ចតិ ។
និរាមិសំ សុខំ លទ្ធា   ឧបេក្ខំ អធិតិដ្ឋតិ
បញ្ច នីវរណេ ហិត្វា   និច្ចំ អារទ្ធវីរិយោ
ឈានានិ ឧបសម្បជ្ជ   ឯកោទិ និបកោ សតោ
ឯវំ ញត្វា យថាភូតំ   សព្វសញ្ញោជនក្ខយេ
សព្វសោ អនុបាទាយ   សម្មា ចិត្តំ វិមុច្ចតិ ។



អ្នកមានប្រាជ្ញា រមែងផុតស្រឡះចាកចំណងនេះ ដែលជាធ្ងន់ ។ បុគ្គលញុំាងចិត្តឲ្យជ្រះថ្លាហើយឲ្យទានដោយភោគៈ ដែលបានមកដោយធម៌ ការកាន់យកជំនោរកើតមិនតាំងពីនោះ រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្ននេះ ដើម្បីសេចក្ដីសុខក្នុងបរលោកនេះ របស់បុគ្គលអ្នកមានសទ្ធា ជាអ្នកស្វែងរកយស បុណ្យតែការបរិច្ចាគនុ៎ះ រមែងចំរើនដល់ព្រមទាំងញាតិទាំងឡាយ យ៉ាងនេះឯង ។ ក្នុងអរិយវិន័យ បុគ្គលណា មានសទ្ធាតាំងនៅ មានហិរិ មានឱត្តប្បៈ មានបញ្ញា សង្រួមក្នុងសីល បុគ្គលនុ៎ះឯង ទើបហៅថា រស់នៅជាសុខក្នុងអរិយវិន័យ ។ បុគ្គលបាននូវសេចក្ដីសុខ ប្រាសចាកអាមិសៈ រមែងដំកល់ចិត្តជាឧបេក្ខា លះបង់នូវនីវរណៈទាំង ៥ ហើយប្រារព្ធសេចក្ដីព្យាយាមជានិច្ច បានដល់នូវឈានទាំងឡាយ ជាបុគ្គលមានចិត្តខ្ពស់ឯក មានបញ្ញា មានស្មារតី ចិត្តក៏ផុតស្រឡះដោយប្រពៃ ព្រោះដឹងនូវហេតុនុ៎ះតាមពិត ព្រោះមិនបានប្រកាន់យក ដោយប្រការទាំងពួង ក្នុងការអស់ទៅ នៃសំយោជនៈទាំងពួង ។

តស្ស សម្មាវិមុត្តស្ស ញាណំ ចេ ហោតិ តាទិនោ
អកុប្បា មេ វិមុត្តីតិ ភវសញ្ញោជនក្ខយេ ។
ឯតំ ខោ បរមំ ញាណំ ឯតំ សុខមនុត្តរំ
អសោកំ វិរជំ ខេមំ ឯតំ អានណ្យមុត្តមន្តិ(១) ។

(៦២) ឯកំ សមយំ អាយស្មា មហាចុន្ទោ ចេតីសុ វិហរតិ សញ្ជាតិយំ ។ តត្រ ខោ អាយស្មា មហាចុន្ទោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវេតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ មហាចុន្ទស្ស បច្ចស្សោសុំ ។ អាយស្មា មហាចុន្ទោ ឯតទវោច ឥធ អាវុសោ ធម្មយោគា ភិក្ខូ ឈាយី ភិក្ខូ អបសាទេន្តិ

១ អដ្ឋកថាយំ អានណ្យមុត្តមន្តិ ទិស្សតិ ។



បុគ្គលនោះ លុះមានចិត្តផុតស្រឡះ ដោយប្រពៃហើយជាបុគ្គលមិនកក្រើកដោយលោកធម៌ រមែងមានបច្ចវេក្ខណញ្ញាណថា វិមុត្តិរបស់អាត្មាអញមិនងាកក្រើកឡើយ ព្រោះ កើតឡើងក្នុងកិរិយាអស់ទៅនៃភវសំយោជនៈ ។ ញាណនុ៎ះឯងជាញាណដ៏ឧត្តម សេចក្តីសុខក្នុងអរហត្តផលនុ៎ះ ជាសុខរកសេចក្តីសុខដទៃក្រៃលែងជាងគ្មាន ឥតមានសេចក្តីសោក ប្រាសចាកធូលី គឺកិលេស ជាទីក្សេម អរហត្តផលនុ៎ះជាគុណជាតដ៏ខ្ពង់ខ្ពស់ជាភាវៈនៃបុគ្គលមិនមានបំណុល ។

(៦២) សម័យមួយ ព្រះមហាចុន្ទមានអាយុ នៅក្នុងនិគមឈ្មោះសញ្ជាតិ ជិតដែនឈ្មោះចេតី ។ ក្នុងទីនោះ ព្រះមហាចុន្ទមានអាយុ មានថេរដីកាហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលស្តាប់ថេរដីកា ព្រះមហាចុន្ទមានអាយុថា អាវុសោដូច្នេះ ។ ព្រះមហាចុន្ទមានអាយុ មានថេរដីកាដូច្នេះថា ម្នាលអាវុសោទាំងឡាយ ពួកធម្មយោគភិក្ខុ (ភិក្ខុអ្នកព្យាយាមក្នុងធម៌)(១) ក្នុងសាសនានេះ បន្តុះបង្អាប់ពួកឈានភិក្ខុ (ភិក្ខុអ្នកមានឈាន) ថា

១ សំដៅយកពួកធម្មកថិក ។ អដ្ឋកថា ។

ឥមេ បន ឈាយិនោម្ហា ឈាយិនោម្ហាតិ ឈាយន្តិ បជ្ឈាយន្តិ កិញ្ហិមេ ឈាយន្តិ កិន្តិមេ ឈាយន្តិ កថញ្ហិមេ ឈាយន្តីតិ ។ តត្ថ ធម្មយោគា ច ភិក្ខូ នប្បសីទន្តិ ឈាយី ច ភិក្ខូ នប្បសីទន្តិ ន ច ពហុជន-ហិតាយ បដិបន្នា ហោន្តិ ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ ឥធ បនាវុសោ ឈាយី ភិក្ខូ ធម្មយោគេ ភិក្ខូ អបសាទេន្តិ ឥមេ បន ធម្មយោគម្ហា ធម្មយោគម្ហាតិ ឧទ្ធតា ឧន្នឡា ចបលា មុខរា វិកិណ្ណវាចា មុដ្ឋស្ស-តិនោ អសម្បជានា អសមាហិតា វិព្ភន្តចិត្តា បាកតិ-ន្ទ្រិយា កិញ្ហិមេ ធម្មយោគា កិន្តិមេ ធម្មយោគា កថញ្ហិមេ ធម្មយោគាតិ តត្ថ ឈាយី ច ភិក្ខូ នប្បសីទន្តិ ធម្មយោគា ច ភិក្ខូ នប្បសីទន្តិ ន ច ពហុជនហិតាយ បដិបន្នា ហោន្តិ ពហុជន-សុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ



ភិក្ខុទាំងនេះរមែងគិតថា យើងជាអ្នកមានឈាន យើងជាអ្នកមានឈាន ចុះភិក្ខុទាំងនេះ គិតអ្វី ភិក្ខុទាំងនេះ គិតដើម្បីអ្វី ភិក្ខុទាំងនេះ គិតដោយហេតុអ្វី ។ បណ្តាភិក្ខុទាំងនោះ ឯពួកធម្មយោគភិក្ខុ ក៏មិនជ្រះថ្លា ពួកឈាយីភិក្ខុក៏មិនជ្រះថ្លា ទាំងមិនបានប្រតិបត្តិ ដើម្បីជាប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើន ដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ឯពួកឈាយីភិក្ខុ ក្នុងសាសនានេះ រមែងបន្តុះបង្អាប់ធម្មយោគភិក្ខុថា ភិក្ខុទាំងនេះ ជាអ្នកមានចិត្តរាយមាយ មានចិត្តខ្ពស់ឡើង មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានពាក្យរាយប៉ាយ មានសតិភ្លេចភ្លាំង មិនបានដឹងព្រម មានចិត្តមិនដំកល់មាំ មានចិត្តរវើរវាយ មានឥន្ទ្រិយទាំងនៅ ជាប្រក្រតី គិតថា យើងជាអ្នកមានព្យាយាមក្នុងធម៌ យើងជាអ្នកមានព្យាយាមក្នុងធម៌ ភិក្ខុទាំងនេះ ជាធម្មយោគអ្វី ភិក្ខុទាំងនេះ ជាធម្មយោគដើម្បីអ្វី ភិក្ខុទាំងនេះ ជាធម្មយោគដោយហេតុអ្វី បណ្តាភិក្ខុទាំងនោះ ឯពួកឈាយីភិក្ខុ ក៏មិនជ្រះថ្លា ពួកធម្មយោគភិក្ខុ ក៏មិនជ្រះថ្លា ទាំងមិនបានប្រតិបត្តិ ដើម្បីជាប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍

សុខាយ ទេវមនុស្សានំ ។ ឥធ បនាវុសោ ធម្មយោគា ភិក្ខូ ធម្មយោគានញ្ចេវ ភិក្ខូនំ វណ្ណំ ភាសន្តិ នោ ឈាយីនំ ភិក្ខូនំ វណ្ណំ ភាសន្តិ ។ ឥត្ថ ធម្មយោគា ច ភិក្ខូ នប្បសីទន្តិ ឈាយី ច ភិក្ខូ នប្បសីទន្តិ ន ច ពហុជនហិតាយ បដិបន្នា ហោន្តិ ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ ឥធ បនាវុសោ ឈាយី ភិក្ខូ ឈាយីនញ្ចេវ ភិក្ខូនំ វណ្ណំ ភាសន្តិ នោ ធម្មយោគានំ ភិក្ខូនំ វណ្ណំ ភាសន្តិ ។ ឥត្ថ ឈាយី ច ភិក្ខូ នប្បសីទន្តិ ធម្មយោគា ច ភិក្ខូ នប្បសីទន្តិ ន ច ពហុជនហិតាយ បដិបន្នា ហោន្តិ ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ តស្មាតិហាវុសោ ឯវំ សិក្ខិតព្វំ ធម្មយោគា សមានា ឈាយីនំ ភិក្ខូនំ វណ្ណំ ភាសិស្សាមាតិ ។ ឯវញ្ហិ វោ អាវុសោ សិក្ខិតព្វំ ។



ដើម្បីសេចក្ដីសុខដល់ជនច្រើន ដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ពួកធម្មយោគភិក្ខុ ក្នុងសាសនានេះ រមែងនិយាយសរសើរ តែពួកភិក្ខុជាធម្មយោគៈដូចគ្នា មិននិយាយសរសើរពួកឈាយីភិក្ខុឡើយ ។ បណ្ដាភិក្ខុទាំងនោះ ឯពួកធម្មយោគភិក្ខុ ក៏មិនជ្រះថ្លា ពួកឈាយីភិក្ខុ ក៏មិនជ្រះថ្លា ទាំងមិនបានប្រតិបត្តិ ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខ ដល់ជនច្រើន ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ជនច្រើន ដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ឯពួកឈាយីភិក្ខុ ក្នុងសាសនានេះ រមែងនិយាយសរសើរតែពួកឈាយីភិក្ខុដូចគ្នា មិននិយាយសរសើរពួកធម្មយោគភិក្ខុឡើយ ។ បណ្ដាភិក្ខុទាំងនោះ ឯពួកឈាយីភិក្ខុក៏មិនជ្រះថ្លា ពួកធម្មយោគភិក្ខុក៏មិនជ្រះថ្លា ទាំងមិនបានប្រតិបត្តិ ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ជនច្រើន ដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គប្បីសិក្សាយ៉ាងនេះថា យើងជាធម្មយោគភិក្ខុ នឹងនិយាយសរសើរពួកឈាយីភិក្ខុ ។ ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

តំ កិស្ស ហេតុ ។ អច្ឆរិយា ហេតេ អាវុសោ បុគ្គលា ទុល្លភា លោកស្មឹ យេ អមតំ ធាតុំ កាយេន ផុសិត្វា វិហរន្តិ ។ តស្មាតិហាវុសោ ឯវំ សិក្ខិតព្វំ ឈាយី សមានា ធម្មយោគានំ ភិក្ខូនំ វណ្ណំ ភាសិស្សាមាតិ ។ ឯវញ្ហិ វោ អាវុសោ សិក្ខិតព្វំ ។ តំ កិស្ស ហេតុ ។ អច្ឆរិយា ហេតេ អាវុសោ បុគ្គលា ទុល្លភា លោកស្មឹ យេ គម្ភីរំ អត្ថបទំ បញ្ញាយ អតិវិជ្ឈ បស្សន្តីតិ ។

(៤៧) អថខោ មោលិយសិវកោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធិំ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មោលិយសិវកោ បរិព្វាជកោ ភគវន្តំ ឯតទវោច សន្ទិដ្ឋិកោ ធម្មោ សន្ទិដ្ឋិកោ ធម្មោតិ ភន្តេ វុច្ចតិ កិត្តាវតា នុខោ ភន្តេ សន្ទិដ្ឋិកោ ធម្មោ ហោតិ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ តេនហិ សិវក



រឿងនោះព្រោះហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ ព្រោះថា បុគ្គលណា ដែលពាល់ត្រូវនូវធាតុ ឈ្មោះអមតៈ ដោយនាមកាយហើយ បុគ្គលនុ៎ះជាបុគ្គលអស្ចារ្យ រកបានដោយក្រក្នុងលោក ។ ម្នាលអាវុសោទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរសិក្សាយ៉ាងនេះថា យើងជាអ្នកឈាយីភិក្ខុ នឹងនិយាយសរសើរពួកធម្មយោគភិក្ខុ ។ ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ ព្រោះថា បុគ្គលណាត្រាស់ដឹង ឃើញនូវចំណែកនៃអត្ថដ៏ជ្រាលជ្រៅ ដោយប្រាជ្ញាហើយ បុគ្គលនុ៎ះជាបុគ្គលអស្ចារ្យ រកបានដោយក្រក្នុងលោក ។

(៤៧) គ្រានោះ មោឡិយសិវកបរិព្វាជក (បរិព្វាជកឈ្មោះមោឡិយ-សិវកៈ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររលឹក ហើយក៏អង្គុយក្នុងទីសមគួរ ។ លុះមោឡិយ-សិវកបរិព្វាជកអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ដែលហៅថា សន្ទិដ្ឋិកធម៌ សន្ទិដ្ឋិកធម៌ បពិត្រព្រះអង្គដ៏ចំរើន ចុះសន្ទិដ្ឋិកធម៌ អកាលិកធម៌ ឯហិបស្សិកធម៌ ឱបនយិកធម៌ បច្ចត្តំ វេទិតព្វោ វិញ្ញូហិធម៌ កើតបានដូចម្ដេច ។ ម្នាលសិវកៈ បើដូច្នោះ

តញ្ញេវេត្ថ បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ ។ តំ កឹ មញ្ញសិ សីវក សន្តំ វា អជ្ឈត្តំ លោភំ អត្ថិ មេ អជ្ឈត្តំ លោភោតិ បជានាសិ អសន្តំ វា អជ្ឈត្តំ លោភំ នត្ថិ មេ អជ្ឈត្តំ លោភោតិ បជានាសីតិ ។ ឯវំ ភន្តេ ។ យំ ខោ ត្វំ សីវក សន្តំ វា អជ្ឈត្តំ លោភំ អត្ថិ មេ អជ្ឈត្តំ លោភោតិ បជានាសិ អសន្តំ វា អជ្ឈត្តំ លោភំ នត្ថិ មេ អជ្ឈត្តំ លោភោតិ បជានាសិ ឯវម្បិ ខោ សីវក សន្ទិដ្ឋិកោ ធម្មោ ហោតិ ។បេ។ តំ កឹ មញ្ញសិ សីវក សន្តំ វា អជ្ឈត្តំ ទោសំ ។បេ។ សន្តំ វា អជ្ឈត្តំ មោហំ សន្តំ វា អជ្ឈត្តំ លោភធម្មំ សន្តំ វា អជ្ឈត្តំ ទោសធម្មំ សន្តំ វា អជ្ឈត្តំ មោហធម្មំ អត្ថិ មេ អជ្ឈត្តំ មោហធម្មោតិ បជានាសិ អសន្តំ វា អជ្ឈត្តំ មោហធម្មំ នត្ថិ មេ អជ្ឈត្តំ មោហធម្មោតិ បជានាសីតិ ។



តថាគតនឹងសួរតបទៅអ្នកវិញ ក្នុងហេតុនុ៎ះ អ្នកគាប់ចិត្តយ៉ាងណា អ្នកគប្បីដោះស្រាយសេចក្តីនោះ យ៉ាងនោះចុះ ។ ម្នាលសីវកៈ អ្នកសំគាល់នូវហេតុនោះដូចម្តេច កាលលោភៈមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា លោភៈមានក្នុងសន្តានរបស់អាត្មាអញ កាលលោភៈមិនមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា លោភៈមិនមានក្នុងសន្តានរបស់អាត្មាអញដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលសីវកៈ កាលលោភៈ មានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា លោភៈមានក្នុងសន្តានរបស់អាត្មាអញ កាលលោភៈមិនមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា លោភៈមិនមានក្នុងសន្តានរបស់អាត្មាអញ ដោយហេតុណា ម្នាលសីវកៈ យ៉ាងនេះឯងហៅថា សន្ទិដ្ឋិកធម៌ ។បេ។ ម្នាលសីវកៈ អ្នកសំគាល់នូវហេតុនោះដូចម្តេច កាលទោសៈមានក្នុងសន្តានក្តី ។បេ។ កាលមោហៈមានក្នុងសន្តានក្តី កាលលោភធម៌មានក្នុងសន្តានក្តី ទោសធម៌មានក្នុងសន្តានក្តី មោហធម៌មានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា មោហធម៌មានក្នុងសន្តានរបស់អាត្មាអញ កាលមោហធម៌ មិនមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា មោហធម៌ មិនមានក្នុងសន្តានរបស់អាត្មាអញដែរឬ ។

ឯវំ ភន្តេ ។ យំ ខោ ត្វំ សីវក សន្តំ វា អជ្ឈត្តំ មោហធម្មំ អត្ថិ មេ អជ្ឈត្តំ មោហធម្មោតិ បជានាសិ អសន្តំ វា អជ្ឈត្តំ មោហធម្មំ នត្ថិ មេ អជ្ឈត្តំ មោហធម្មោតិ បជានាសិ ឯវម្បិ ខោ សីវក សន្ទិដ្ឋិកោ ធម្មោ ហោតិ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ អភិក្កន្តំ ភន្តេ ។បេ។ ឧបាសកំ មំ ភន្តេ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

(៤៨) អថខោ អញ្ញតរោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ព្រាហ្មណោ ភគវន្តំ ឯតទវោច សន្ទិដ្ឋិកោ ធម្មោ សន្ទិដ្ឋិកោ ធម្មោតិ ភោ គោតម វុច្ចតិ កិត្តាវតា នុ ខោ ភោ គោតម សន្ទិដ្ឋិកោ ធម្មោ ហោតិ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ តេនហិ ព្រាហ្មណ តញ្ញេវេត្ថ

១៥៧

អង្គុត្តរនិកាយ ឆក្កនិបាត

ព្រះករុណាព្រះអង្គ ។ ម្នាលសីវកៈ កាលមោហធម៌មានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា មោហធម៌មានក្នុងសន្តានរបស់អាត្មាអញ កាលមោហធម៌មិនមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា មោហធម៌មិនមានក្នុងសន្តានរបស់អាត្មាអញ ដោយហេតុណា ម្នាលសីវកៈយ៉ាងនេះឯង ហៅថា សន្ទិដ្ឋិកធម៌ អកាលិកធម៌ ឯហិបស្សិកធម៌ ឱបនយិកធម៌ បច្ចត្តំ វេទិតព្វោ វិញ្ញូហិធម៌ ។ បពិត្រព្រះអង្គដ៏ចំរើន ច្បាស់លាស់ពេកណាស់ ។បេ។ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ សំគាល់ខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់នូវសរណៈ ស្មើដោយជីវិតចាប់ដើមអំពីថ្ងៃនេះទៅ ។

(៤៨) លំដាប់នោះ មានព្រាហ្មណ៍ម្នាក់ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យ ដែលគួររីករាយនឹងពាក្យដែលគួររលឹក ហើយក៏អង្គុយក្នុងទីសមគួរ ។ លុះព្រាហ្មណ៍នោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ដែលហៅថា សន្ទិដ្ឋិកធម៌ សន្ទិដ្ឋិកធម៌ បពិត្រព្រះគោតមដ៏ចំរើន ចុះសន្ទិដ្ឋិកធម៌ អកាលិកធម៌ ឯហិបស្សិកធម៌ ឱបនយិកធម៌ បច្ចត្តំ វេទិតព្វោ វិញ្ញូហិធម៌ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បើដូច្នោះ តថាគតនឹងសួរតបទៅអ្នកវិញក្នុងហេតុនុ៎ះ

បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ តំ កឹ មញ្ញសិ ព្រាហ្មណ សន្តំ វា អជ្ឈត្តំ រាគំ អត្ថិ មេ អជ្ឈត្តំ រាគោតិ បជានាសិ អសន្តំ វា អជ្ឈត្តំ រាគំ នត្ថិ មេ អជ្ឈត្តំ រាគោតិ បជានាសីតិ ។ ឯវំ ភោ ។ យំ ខោ ត្វំ ព្រាហ្មណ សន្តំ វា អជ្ឈត្តំ រាគំ អត្ថិ មេ អជ្ឈត្តំ រាគោតិ បជានាសិ អសន្តំ វា អជ្ឈត្តំ រាគំ នត្ថិ មេ អជ្ឈត្តំ រាគោតិ បជានាសិ ឯវម្បិ ខោ ព្រាហ្មណ សន្ទិដ្ឋិកោ ធម្មោ ហោតិ ។បេ។ តំ កឹ មញ្ញសិ ព្រាហ្មណ សន្តំ វា អជ្ឈត្តំ ទោសំ សន្តំ វា អជ្ឈត្តំ មោហំ សន្តំ វា អជ្ឈត្តំ កាយសន្ទោសំ សន្តំ វា អជ្ឈត្តំ វចីសន្ទោសំ ។បេ។ សន្តំ វា អជ្ឈត្តំ មនោសន្ទោសំ អត្ថិ មេ អជ្ឈត្តំ មនោសន្ទោសោតិ បជានាសិ អសន្តំ វា អជ្ឈត្តំ មនោសន្ទោសំ នត្ថិ មេ អជ្ឈត្តំ មនោសន្ទោសោតិ បជានាសីតិ ។ ឯវំ ភោ ។



អ្នកគាប់ចិត្តយ៉ាងណា គប្បីដោះស្រាយនូវហេតុនោះយ៉ាងនោះចុះ ។ ម្នាលព្រាហ្មណ៍ អ្នកសំគាល់នូវហេតុនោះដូចម្តេច កាលរាគៈមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា រាគៈមានក្នុងសន្តានរបស់អាត្មាអញ កាលរាគៈមិនមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា រាគៈមិនមានក្នុងសន្តានរបស់អាត្មាអញដែរឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលព្រាហ្មណ៍ កាលរាគៈមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា រាគៈមានក្នុងសន្តានរបស់អាត្មាអញ កាលរាគៈមិនមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា រាគៈមិនមានក្នុងសន្តានរបស់អាត្មាអញ ដោយហេតុណា ម្នាលព្រាហ្មណ៍ យ៉ាងនេះឯង ទើបថា សន្ទិដ្ឋិកធម៌ ។បេ។ ម្នាលព្រាហ្មណ៍ អ្នកសំគាល់នូវហេតុនោះដូចម្តេច កាលទោសៈមានក្នុងសន្តានក្តី កាលមោហៈមានក្នុងសន្តានក្តី កាលហេតុជាគ្រឿងប្រទូស្តនៃកាយទ្វារ មានក្នុងសន្តានក្តី កាលហេតុជាគ្រឿងប្រទូស្តនៃវចីទ្វារមានក្នុងសន្តានក្តី ។បេ។ កាលហេតុជាគ្រឿងប្រទូស្តនៃមនោទ្វារ មានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា ហេតុជាគ្រឿងប្រទូស្តនៃមនោទ្វារ មានក្នុងសន្តានរបស់អាត្មាអញ កាលហេតុជាគ្រឿងប្រទូស្តនៃមនោទ្វារ មិនមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា ហេតុជាគ្រឿងប្រទូស្តនៃមនោទ្វារ មិនមានក្នុងសន្តានរបស់អាត្មាអញដែរឬ ។ ព្រះករុណាព្រះអង្គ ។

យំ ខោ ត្វំ ព្រាហ្មណ សន្តំ ច អជ្ឈត្តំ មនោសន្ទោសំ អត្ថិ មេ អជ្ឈត្តំ មនោសន្ទោសោតិ បជានាសិ អសន្តំ ច អជ្ឈត្តំ មនោសន្ទោសំ នត្ថិ មេ អជ្ឈត្តំ មនោសន្ទោសោតិ បជានាសិ ឯវម្បិ ខោ ព្រាហ្មណ សន្ទិដ្ឋិកោ ធម្មោ ហោតិ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។បេ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

(៤៩) ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ច ខេមោ អាយស្មា ច សុមនោ សាវត្ថិយំ វិហរន្តិ អន្ធវនស្មឹ ។ អថខោ អាយស្មា ច ខេមោ អាយស្មា ច សុមនោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា ខេមោ



ម្នាលព្រាហ្មណ៍ កាលបើធាតុជាគ្រឿងប្រទូស្តនៃមនោទ្វារមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា ធាតុជាគ្រឿងប្រទូស្តនៃមនោទ្វារ មានក្នុងសន្តានរបស់អាត្មាអញ កាលបើធាតុជាគ្រឿងប្រទូស្តនៃមនោទ្វារមិនមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា ធាតុជាគ្រឿងប្រទូស្តនៃមនោទ្វារ មិនមានក្នុងសន្តានរបស់អាត្មាអញ ដោយហេតុណា ម្នាលព្រាហ្មណ៍ យ៉ាងនេះឯងហៅថា សន្ទិដ្ឋិកធម៌ អកាលិកធម៌ ឯហិបស្សិកធម៌ ឱបនយិកធម៌ បច្ចត្តំវេទិតព្វោវិញ្ញូហិធម៌ ។ បពិត្រព្រះគោតមដ៏ចំរើន ច្បាស់ណាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចំរើន ច្បាស់ណាស់ពេកណាស់ ។បេ។ សូមព្រះគោតមដ៏ចំរើន សំគាល់នូវខ្ញុំព្រះអង្គថាជាឧបាសកអ្នកដល់នូវសរណៈស្មើដោយជីវិតតាំងអំពីថ្ងៃនេះទៅ ។

(៤៩) សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី សម័យនោះ ព្រះខេមៈដ៏មានអាយុ នឹងព្រះសុមនៈដ៏មានអាយុ នៅក្នុងអន្ធវន ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះខេមៈដ៏មានអាយុ នឹងព្រះសុមនៈដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះខេមៈអង្គុយក្នុងទីសមគួរហើយ

ភគវន្តំ ឯតទវោច យោ សោ ភន្តេ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញា វិមុត្តោ តស្ស ន ឯវំ ហោតិ អត្ថិ មេ សេយ្យោតិ វា អត្ថិ មេ សទិសោតិ វា អត្ថិ មេ ហីនោតិ វាតិ ។ ឥទមវោច អាយស្មា ខេមោ ។ សមនុញ្ញោ សត្ថា អហោសិ ។ អថខោ អាយស្មា ខេមោ សមនុញ្ញោ មេ សត្ថាតិ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ អាយស្មា សុមនោ អចិរបក្កន្តេ អាយស្មន្តេ ខេមេ ភគវន្តំ ឯតទវោច យោ សោ ភន្តេ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញា វិមុត្តោ តស្ស ន ឯវំ ហោតិ នត្ថិ មេ សេយ្យោតិ វា



ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណាជាអរហន្តខីណាស្រព មានមគ្គព្រហ្មចរិយធម៌នៅរួចហើយ មានសោឡសកិច្ចធ្វើរួចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានភវសំយោជនៈអស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះមិនមានសេចក្តីត្រិះរិះថា បុគ្គលដ៏ប្រសើរជាងអាត្មាអញក្តី ប្រហែលអាត្មាអញក្តី ថោកទាបជាងអាត្មាអញក្តី យ៉ាងនេះទេ ព្រះខេមៈដ៏មានអាយុ បានក្រាបបង្គំទូលដូច្នេះហើយ ។ ព្រះសាស្តាក៏សព្វព្រះហឫទ័យ ។ លំដាប់នោះ ព្រះខេមៈដ៏មានអាយុគិតថា ព្រះសាស្តារបស់អាត្មាអញទ្រង់សព្វព្រះហឫទ័យហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ លំដាប់នោះ កាលព្រះខេមៈដ៏មានអាយុ ចៀសចេញទៅមិនយូរប៉ុន្មាន ព្រះសុមនៈដ៏មានអាយុ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណាជាអរហន្តខីណាស្រព មានមគ្គព្រហ្មចរិយនៅរួចហើយ មានសោឡសកិច្ចធ្វើរួចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានភវសំយោជនៈអស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះមិនមានសេចក្តីត្រិះរិះយ៉ាងនេះថា មិនមានបុគ្គលដ៏ប្រសើរជាងអាត្មាអញផង

នត្ថិ មេ សទិសោតិ ភ នត្ថិ មេ ហីនោតិ ភតិ ។ ឥធមេកេ អាយស្មា សុមនោ ។ សមនុញ្ញោ សត្ថា អហោសិ ។ អថខោ អាយស្មា សុមនោ សមនុញ្ញោ មេ សត្ថាតិ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា អចិរប្បក្កន្តេសុ អាយស្មន្តេ ច ទេវេ អាយស្មន្តេ ច សុមនេ ភិក្ខូ អាមន្តេសិ ឯវំ ខោ ភិក្ខវេ កុលបុត្តា អញ្ញំ ព្យាករោន្តិ អត្ថោ ច វុត្តោ អត្តា ច អនុបនីតោ អថ ច បន ឥធេកច្ចេ មោឃបុរិសា ហសមានកា មញ្ញេ អញ្ញំ ព្យាករោន្តិ តេ បច្ឆា វិឃាតំ អាបជ្ជន្តីតិ ។



មិនមានបុគ្គលដទៃប្រហែលនឹងខ្ញុំព្រះអង្គទេ មិនមានបុគ្គលដទៃថោកទាបជាងខ្ញុំព្រះអង្គទេ ។ ព្រះសុមនៈដ៏មានអាយុ បានក្រាបបង្គំទូលដូច្នេះរួចហើយ ។ ព្រះសាស្តា ក៏ទ្រង់សព្វព្រះហឫទ័យ ។ គ្រានោះ ព្រះសុមនៈដ៏មានអាយុគិតថា ព្រះសាស្តារបស់ខ្ញុំព្រះអង្គ ទ្រង់សព្វព្រះហឫទ័យ ហើយក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ លំដាប់នោះ កាលព្រះទេវៈដ៏មានអាយុនឹងព្រះសុមនៈដ៏មានអាយុ ចៀសចេញទៅ មិនយូរប៉ុន្មាន ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកកុលបុត្ត រមែងពោលនូវអរហត្តផលយ៉ាងនេះឯងទាំងសេចក្តី ក៏ពួកកុលបុត្តនោះបានពោលហើយ ទាំងខ្លួន ក៏ពួកកុលបុត្តនោះមិនបាននាំចូលទៅដោយមានះ ចំណែកមោឃបុរសពួកខ្លះ ក្នុងលោកនេះហាក់ដូចជាសើចលេង ពោលនូវអរហត្តផល ពួកមោឃបុរសទាំងនោះនឹងដល់នូវសេចក្តីទុក្ខ ក្នុងកាលជាខាងក្រោយ ។

ន ឧស្សេសុ ន ឱសេសុ(១)
សមត្តេ នោបនីយរេ
ខីណា សញ្ជាតិ វុសិតំ
ព្រហ្មចរិយំ ចរន្តិ
សញ្ញោជនវិប្បមុត្តាតិ ។

(៥០) ឥន្ទ្រិយសំវរេ ភិក្ខវេ អសតិ ឥន្ទ្រិយសំវរវិបន្នស្ស ហតូបនិសំ ហោតិ សីលំ សីលេ អសតិ សីលវិបន្នស្ស ហតូបនិសោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ អសតិ សម្មាសមាធិវិបន្នស្ស ហតូបនិសំ ហោតិ យថាភូតញាណទស្សនំ យថាភូតញាណទស្សនេ អសតិ យថាភូតញាណទស្សនវិបន្នស្ស ហតូបនិសោ ហោតិ និព្វិទាវិរាគោ និព្វិទាវិរាគេ អសតិ និព្វិទាវិរាគវិបន្នស្ស ហតូបនិសំ ហោតិ វិមុត្តិញាណទស្សនំ ។

១ ម. ឆ. ន ឱមេសុ ។



ព្រះខីណាស្រពទាំងឡាយ មិនបានបង្អោនខ្លួន
ទៅដោយមានះ ក្នុងពួកបុគ្គលខ្ពស់ មិនបានបង្អោនខ្លួន
ទៅដោយមានះ ក្នុងពួកបុគ្គលទាប មិនបានបង្អោនខ្លួន
ទៅដោយមានះ ក្នុងបុគ្គលស្មើនឹងខ្លួន ព្រោះមានជាតិ
អស់ហើយ មានមគ្គព្រហ្មចរិយធម៌ នៅរួចហើយ
មានចិត្តផុតស្រឡះចាកសំយោជនៈហើយ ។

(៥០) ម្នាលភិក្ខុទាំងឡាយ កាលបើឥន្ទ្រិយសំវរៈមិនមានហើយ សីលនៃបុគ្គលដែលវិបត្តិចាកឥន្ទ្រិយសំវរៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យហើយ កាលបើសីលមិនមានហើយ សម្មាសមាធិនៃបុគ្គលដែលវិបត្តិចាកសីល ឈ្មោះថា មានឧបនិស្ស័យសាបសូន្យហើយ កាលបើសម្មាសមាធិមិនមានហើយ យថាភូតញ្ញាណទស្សនៈ នៃបុគ្គលដែលវិបត្តិចាកសម្មាសមាធិ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យហើយ កាលបើយថាភូតញ្ញាណទស្សនៈមិនមានហើយ និព្វិទាវិរាគៈនៃបុគ្គលដែលវិបត្តិចាកយថាភូតញ្ញាណទស្សនៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យហើយ កាលបើនិព្វិទាវិរាគៈមិនមានហើយ វិមុត្តិញ្ញាណទស្សនៈនៃបុគ្គលដែលវិបត្តិចាកនិព្វិទាវិរាគៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យហើយ ។

សេយ្យថាបិ ភិក្ខវេ រុក្ខោ សាខាបលាសវិបន្នោ តស្ស បបដិកាបិ ន បារិបូរឹ គច្ឆតិ តចោបិ ន បារិបូរឹ គច្ឆតិ ផេគ្គុបិ ន បារិបូរឹ គច្ឆតិ សារោបិ ន បារិបូរឹ គច្ឆតិ ឯវមេវ ខោ ភិក្ខវេ ឥន្ទ្រិយសំវរេ អសតិ ឥន្ទ្រិយសំវរវិបន្នស្ស ហតូបនិសំ ហោតិ សីលំ ។បេ។ វិមុត្តិញាណទស្សនំ ឥន្ទ្រិយសំវរេ ភិក្ខវេ សតិ ឥន្ទ្រិយសំវរសម្បន្នស្ស ឧបនិស្សយសម្បន្នំ(១) ហោតិ សីលំ សីលេ សតិ សីលសម្បន្នស្ស ឧបនិស្សយសម្បន្នោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ សតិ សម្មាសមាធិសម្បន្នស្ស ឧបនិស្សយសម្បន្នំ ហោតិ យថាភូតញាណទស្សនំ យថាភូតញាណទស្សនេ សតិ យថាភូតញាណទស្សនសម្បន្នស្ស ឧបនិស្សយសម្បន្នោ ហោតិ និព្វិទាវិរាគោ និព្វិទាវិរាគេ សតិ និព្វិទាវិរាគសម្បន្នស្ស ឧបនិស្សយសម្បន្នំ ហោតិ វិមុត្តិញាណទស្សនំ ។

១ ម.ម. ឧបនិសសម្បន្នំ ។



ម្នាលភិក្ខុទាំងឡាយ ដូចដើមឈើដែលវិបត្តិចាកមែកនិងស្លឹក ក្រមរនៃដើមឈើនោះក្តី ក៏មិនដល់នូវការពេញលេញ សំបកក្តី ក៏មិនដល់នូវការពេញលេញ ស្រាយក្តី ក៏មិនដល់នូវការពេញលេញ ខ្លឹមក្តី ក៏មិនដល់នូវការពេញលេញយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើឥន្ទ្រិយសំវរៈមិនមានហើយ សីលនៃបុគ្គលដែលវិបត្តិចាកឥន្ទ្រិយសំវរៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យហើយ ។ បេ ។ វិមុត្តិញាណទស្សនៈក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលបើឥន្ទ្រិយសំវរៈមានហើយ សីលនៃបុគ្គលដែលបរិបូណ៌ ដោយឥន្ទ្រិយសំវរៈឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើសីលមានហើយ សម្មាសមាធិនៃបុគ្គលដែលបរិបូណ៌ដោយសីល ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើ សម្មាសមាធិមានហើយ យថាភូតញ្ញាណទស្សនៈនៃបុគ្គលដែលបរិបូណ៌ដោយសម្មាសមាធិ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើយថាភូតញ្ញាណទស្សនៈមានហើយ និព្វិទាវិរាគៈនៃបុគ្គលដែលបរិបូណ៌ដោយយថាភូតញ្ញាណទស្សនៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើ និព្វិទាវិរាគៈមានហើយ វិមុត្តិញ្ញាណទស្សនៈនៃបុគ្គលដែលបរិបូណ៌ដោយនិព្វិទាវិរាគៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ដែរ ។

សេយ្យថាបិ ភិក្ខវេ រុក្ខោ សាខាបលាសសម្បន្នោ តស្ស បបដិកាបិ បារិបូរឹ គច្ឆតិ តចោបិ បារិបូរឹ គច្ឆតិ ផេគ្គុបិ បារិបូរឹ គច្ឆតិ សារោបិ បារិបូរឹ គច្ឆតិ ឯវមេវ ខោ ភិក្ខវេ ឥន្ទ្រិយសំវរេ សតិ ឥន្ទ្រិយសំវរសម្បន្នស្ស ។ បេ ។ ឧបនិស្សយសម្បន្នំ ហោតិ វិមុត្តិញ្ញាណទស្សនន្តិ ។

[៥១] អថខោ អាយស្មា អានន្ទោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ អាយស្មន្តំ សារីបុត្តំ ឯតទវោច កិត្តាវតា នុ ខោ អាវុសោ សារីបុត្ត ភិក្ខុ អស្សុតញ្ចេវ ធម្មំ សុណាតិ សុតា ចស្ស ធម្មា ន សម្មោសំ គច្ឆន្តិ យេ ចស្ស ធម្មា បុព្វេ ចេតសា សម្ផុដ្ឋបុព្វា តេ ច សមុទាចរន្តិ អវិញ្ញាតញ្ច វិជានាតីតិ ។



ម្នាលភិក្ខុទាំងឡាយ ដូចដើមឈើដែលបរិបូណ៌ ដោយមែកនិងស្លឹក ក្រមរនៃដើមឈើនោះក្តី ក៏ដល់នូវការពេញលេញ សម្បកក្តី ក៏ដល់នូវការពេញលេញ ស្រាយក្តី ក៏ដល់នូវការពេញលេញ ខ្លឹមក្តី ក៏ដល់នូវការពេញលេញ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើឥន្ទ្រិយសំវរៈមានហើយ សីលនៃបុគ្គលដែលបរិបូណ៌ដោយឥន្ទ្រិយសំវរៈ ។ បេ ។ វិមុត្តិញ្ញាណទស្សនៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ ក៏យ៉ាងនោះដែរ ។

[៥១] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបនិយាយនឹងព្រះសារីបុត្តដ៏មានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត ភិក្ខុស្តាប់នូវធម៌ដែលខ្លួនមិនដែលស្តាប់ក្តី ធម៌ដែលភិក្ខុនោះស្តាប់ហើយ មិនដល់នូវសេចក្តីភ្លេចភ្លាំងទៅវិញក្តី ពួកធម៌ណាដែលភិក្ខុនោះធ្លាប់ប៉ះពាល់ដោយចិត្តក្នុងកាលមុន ធម៌ទាំងនោះក៏ផុសផុលឡើងក្តី ភិក្ខុនោះដឹងច្បាស់នូវធម៌ដែលខ្លួនមិនធ្លាប់ដឹងក្តី ដោយហេតុប៉ុន្មាន ។

អាយស្មា ខោ អានន្ទោ ពហុស្សុតោ បដិភាតុ អាយស្មន្តញ្ញេវ អានន្ទំ ។ តេនហាវុសោ សារីបុត្ត ធម្មំ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ អាវុសោតិ ខោ អាយស្មា សារីបុត្តោ អាយស្មតោ អានន្ទស្ស បច្ចស្សោសិ ។ អាយស្មា អានន្ទោ ឯតទវោច ឥធាវុសោ សារីបុត្ត ភិក្ខុ ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ ទេសេតិ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ វាចេតិ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន សជ្ឈាយំ ករោតិ យថាសុតំ យថាបរិយត្តំ ធម្មំ ចេតសា អនុវិតក្កេតិ អនុវិចារេតិ មនសានុបេក្ខតិ យស្មឹ អាវាសេ ថេរា ភិក្ខូ វិហរន្តិ ពហុស្សុតា អាគតាគមា ធម្មធរា វិនយធរា មាតិកាធរា តស្មឹ អាវាសេ វស្សំ ឧបេតិ



ព្រះសារីបុត្តនិយាយថា អានន្ទដ៏មានអាយុ ជាពហុស្សូតស្រាប់ហើយ សូមអានន្ទដ៏មានអាយុ សំដែងនូវធម៌នោះទៅ ។ ព្រះអានន្ទតបថា ម្នាលអាវុសោសារីបុត្ត បើដូច្នោះ សូមលោកចាំស្ដាប់នូវធម៌ ហើយធ្វើទុកក្នុងចិត្តឲ្យល្អចុះ ខ្ញុំនឹងសំដែង ។ ព្រះសារីបុត្តដ៏មានអាយុ បានទទួលពាក្យព្រះអានន្ទដ៏មានអាយុថា អើអាវុសោ ។ ព្រះអានន្ទដ៏មានអាយុ ក៏និយាយដូច្នេះថា ម្នាលអាវុសោសារីបុត្ត ភិក្ខុក្នុងសាសនានេះ រៀននូវធម៌គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ សំដែងនូវធម៌ តាមទំនងដែលខ្លួនបានឮ តាមទំនងដែលខ្លួន បានរៀនសូត្រ ដល់បុគ្គលដទៃដោយពិស្ដារ បង្រៀននូវធម៌ តាមទំនងដែលខ្លួនបានឮ តាមទំនងដែលខ្លួនបានរៀនសូត្រដោយពិស្ដារ ស្វាធ្យាយនូវធម៌ តាមទំនងដែលខ្លួនបានឮ តាមទំនងដែលខ្លួនបានរៀនសូត្រ ដោយពិស្ដារ ត្រិះរិះរឿយៗ ពិចារណារឿយៗ គិតរឿយៗ នូវធម៌តាមទំនងដែលខ្លួនបានឮ តាមទំនងដែលខ្លួនបានរៀនសូត្រដោយចិត្ត ពួកភិក្ខុជាថេរៈ ជាពហុស្សូត ជាអ្នកចេះចាំនូវនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា នៅក្នុងអាវាសណា ក៏ចូលទៅកាន់វស្សា ក្នុងអាវាសនោះ

តេ កាលេន កាលំ ឧបសង្កមិត្វា បរិបុច្ឆតិ បរិបញ្ហតិ ឥទំ ភន្តេ កថំ ឥមស្ស កោ អត្ថោតិ ។ តស្ស តេ អវិវដញ្ចេវ វិវរន្តិ អនុត្តានីកតញ្ច ឧត្តានីករោន្តិ អនេកវិហិតេសុ ច កង្ខាដ្ឋានិយេសុ ធម្មេសុ កង្ខំ បដិវិនោទេន្តិ ។ ឯត្តាវតា នុ ខោ អាវុសោ សារីបុត្ត ភិក្ខុ អស្សុតញ្ចេវ ធម្មំ សុណាតិ សុតា ចស្ស ធម្មា ន សម្មោសំ គច្ឆន្តិ យេ ចស្ស ធម្មា បុព្វេ ចេតសា សម្ផុដ្ឋបុព្វា តេ ច សមុទាចរន្តិ អវិញ្ញាតញ្ច វិជានាតីតិ ។ អច្ឆរិយំ អាវុសោ អព្ភុតំ អាវុសោ យាវ សុភាសិតញ្ចិទំ អាយស្មតា អានន្ទេន ។ ឥមេហិ ច មយំ ឆហិ ធម្មេហិ សមន្នាគតំ អាយស្មន្តំ អានន្ទំ ធារេម ។ អាយស្មា ហិ អានន្ទោ ធម្មំ បរិយាបុណាតិ សុត្តំ គេយ្យំ វេយ្យាករណំ គាថំ ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ



លុះចូលទៅរកភិក្ខុទាំងនោះ សព្វកាលហើយ ក៏សាកសួរដេញដោលថា បពិត្រព្រះករុណាដ៏ចំរើន ពាក្យនេះដូចម្ដេច អត្ថរបស់ពាក្យនេះដូចម្ដេច ។ ភិក្ខុទាំងនោះ រមែងបើកបង្ហាញនូវធម៌ដ៏កំបាំងផង ធ្វើនូវធម៌ដែលជ្រៅឲ្យទៅជារាក់ផង បន្ទោបង់នូវសេចក្ដីសង្ស័យ ក្នុងធម៌ដែលមានប្រការច្រើន ជាទីតាំងនៃសេចក្ដីសង្ស័យផង ដល់ភិក្ខុនោះ ។ ម្នាលអាវុសោសារីបុត្ត ភិក្ខុស្ដាប់នូវធម៌ដែលខ្លួនមិនដែលបានស្ដាប់ក្ដី ធម៌ដែលភិក្ខុនោះស្ដាប់ហើយ មិនដល់នូវសេចក្ដីភ្លេចភ្លាំងទៅវិញក្ដី ពួកធម៌ណាដែលភិក្ខុនោះ ធ្លាប់ពិចារណាហើយដោយចិត្តក្នុងកាលមុន ធម៌ទាំងនោះក៏ផុសផុលឡើងក្ដី ភិក្ខុនោះ រមែងដឹងច្បាស់នូវធម៌ដែលខ្លួនមិនធ្លាប់ដឹងក្ដី ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។ ម្នាលអាវុសោ អស្ចារ្យពេកណាស់ ម្នាលអាវុសោ ចំឡែកពេកណាស់ ព្រោះថា ពាក្យនេះព្រះអានន្ទដ៏មានអាយុ បានពោលហើយដោយប្រពៃ ។ យើងទាំងទុកនូវព្រះអានន្ទដ៏មានអាយុ ដែលប្រកបដោយធម៌ ៦ យ៉ាងនេះឯង ។ ព្រោះថា ព្រះអានន្ទដ៏មានអាយុ រៀនយកនូវធម៌គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ

អាយស្មា អានន្ទោ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ ទេសេតិ អាយស្មា អានន្ទោ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន បរេសំ វាចេតិ អាយស្មា អានន្ទោ យថាសុតំ យថាបរិយត្តំ ធម្មំ វិត្ថារេន សជ្ឈាយំ ករោតិ អាយស្មា អានន្ទោ យថាសុតំ យថាបរិយត្តំ ធម្មំ ចេតសា អនុវិតក្កេតិ អនុវិចារេតិ មនសានុបេក្ខតិ អាយស្មា អានន្ទោ យស្មឹ អាវាសេ ថេរា ភិក្ខូ វិហរន្តិ ពហុស្សុតា អាគតាគមា ធម្មធរា វិនយធរា មាតិកាធរា តស្មឹ អាវាសេ វស្សំ ឧបេតិ តេ អាយស្មា អានន្ទោ កាលេន កាលំ ឧបសង្កមិត្វា បរិបុច្ឆតិ បរិបញ្ហតិ ឥទំ ភន្តេ កថំ ឥមស្ស កោ អត្ថោតិ។ តេ អាយស្មតោ អានន្ទស្ស អវិវដញ្ចេវ វិវរន្តិ អនុត្តានីកតញ្ច ឧត្តានីករោន្តិ អនេកវិហិតេសុ ច កង្ខាដ្ឋានិយេសុ ធម្មេសុ កង្ខំ បដិវិនោទេន្តិ ។



ព្រះអានន្ទដ៏មានអាយុ រមែងសំដែងធម៌ តាមទំនងដែលខ្លួនចេះដឹង តាមទំនងដែលខ្លួនបានរៀនសូត្រ ដល់បុគ្គលដទៃដោយពិស្តារ ព្រះអានន្ទដ៏មានអាយុ បង្រៀនធម៌តាមទំនងដែលខ្លួនចេះដឹង តាមទំនងដែលខ្លួនបានរៀនសូត្រ ដល់បុគ្គលដទៃដោយពិស្តារ ព្រះអានន្ទដ៏មានអាយុ ស្វាធ្យាយនូវធម៌ តាមទំនងដែលខ្លួនចេះដឹង តាមទំនងដែលខ្លួនបានរៀនសូត្រដោយពិស្តារ ព្រះអានន្ទដ៏មានអាយុ ត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ គិតរឿយ ៗ នូវធម៌ តាមទំនងដែលខ្លួនចេះដឹង តាមទំនងដែលខ្លួនបានរៀនសូត្រដោយចិត្ត ពួកភិក្ខុជាថេរៈ ជាពហុស្សូត ជាអ្នកចេះចាំនូវនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា នៅក្នុងអាវាសណា ព្រះអានន្ទដ៏មានអាយុ ចូលទៅកាន់វស្សា ក្នុងអាវាសនោះ ព្រះអានន្ទដ៏មានអាយុ រមែងចូលទៅរកភិក្ខុទាំងនោះរឿយ ៗ តាមកាល ហើយសាកសួរដេញដោលថា បពិត្រលោកដ៏ចំរើន ពាក្យនេះដូចម្ដេច អត្ថរបស់ពាក្យនេះដូចម្ដេច ។ ភិក្ខុទាំងនោះ ក៏បង្ហាញនូវធម៌ដែលកំបាំងផង ធ្វើនូវធម៌ដែលក្រឡៅឲ្យទៅជាងាយផង បន្ទោបង់នូវសេចក្ដីសង្ស័យក្នុងធម៌ដែលមានប្រការច្រើន ជាទីតាំងនៃសេចក្ដីសង្ស័យផង ដល់ព្រះអានន្ទដ៏មានអាយុ ។

[៥២] អថខោ ជាណុស្សោណិ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ជាណុស្សោណិ ព្រាហ្មណោ ភគវន្តំ ឯតទវោច ខត្តិយា ភោ គោតម កិំអធិប្បាយា កិំឧបវិចារា កិំអធិដ្ឋានា កិំអភិនិវេសា កិំបរិយោសានាតិ ។ ខត្តិយា ខោ ព្រាហ្មណ ភោគាធិប្បាយា បញ្ញូបវិចារា ពលាធិដ្ឋានា បឋវីអភិនិវេសា ឥស្សរិយបរិយោសានាតិ ។ ព្រាហ្មណា បន ភោ គោតម កិំអធិប្បាយា កិំឧបវិចារា កិំអធិដ្ឋានា កិំអភិនិវេសា កិំបរិយោសានាតិ ។ ព្រាហ្មណា ខោ ព្រាហ្មណ ភោគាធិប្បាយា បញ្ញូបវិចារា មន្តាធិដ្ឋានា យញ្ញាភិនិវេសា ព្រហ្មលោកបរិយោសានាតិ ។ គហបតិកា បន ភោ គោតម កិំអធិប្បាយា កិំឧបវិចារា កិំអធិដ្ឋានា កិំអភិនិវេសា កិំបរិយោសានាតិ ។ គហបតិកា ខោ ព្រាហ្មណ ភោគាធិប្បាយា



(៥២) គ្រានោះ ជាណុស្សោណិព្រាហ្មណ៍ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះជាណុស្សោណិព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ពួកក្សត្រមានអ្វីជាទីប្រាថ្នា មានអ្វីជាទីពិចារណា មានអ្វីជាទីតាំងនៅ មានអ្វីជាទីប្រកាន់ មានអ្វីជាទីបំផុត ។ ម្នាលព្រាហ្មណ៍ ពួកក្សត្រមានភោគៈជាទីប្រាថ្នា មានបញ្ញាជាទីពិចារណា មានពួកពលជាទីតាំងនៅ មានប្រថពីជាទីប្រកាន់ មានឥស្សរិយៈជាទីបំផុត ។ បពិត្រព្រះគោតមដ៏ចំរើន ចុះពួកព្រាហ្មណ៍ មានអ្វីជាទីប្រាថ្នា មានអ្វីជាទីពិចារណា មានអ្វីជាទីតាំងនៅ មានអ្វីជាទីប្រកាន់ មានអ្វីជាទីបំផុត ។ ម្នាលព្រាហ្មណ៍ ពួកព្រាហ្មណ៍ មានភោគៈជាទីប្រាថ្នា មានបញ្ញាជាទីពិចារណា មានមន្តជាទីតាំងនៅ មានការបូជាជាទីប្រកាន់ មានព្រហ្មលោកជាទីបំផុត ។ បពិត្រព្រះគោតមដ៏ចំរើន ចុះពួកគហបតី មានអ្វីជាទីប្រាថ្នា មានអ្វីជាទីពិចារណា មានអ្វីជាទីតាំងនៅ មានអ្វីជាទីប្រកាន់ មានអ្វីជាទីបំផុត ។ ម្នាលព្រាហ្មណ៍ ពួកគហបតី មានភោគៈជាទីប្រាថ្នា

បញ្ញូបវិចារា សិប្បាធិដ្ឋានា កម្មន្តាភិនិវេសា និដ្ឋិត-កម្មន្តបរិយោសានាតិ ។ ឥត្ថី បន ភោ គោតម កិមធិប្បាយា កឹឧបវិចារា កឹអធិដ្ឋានា កឹអភិនិវេសា កឹបរិយោសានាតិ ។ ឥត្ថី ខោ ព្រាហ្មណ បុរិសាធិប្បាយា អលង្ការូបវិចារា បុត្តាធិដ្ឋានា អសបត្តិអភិនិវេសា ឥស្សរិយបរិយោសានាតិ ។ ចោរា បន ភោ គោតម កិមធិប្បាយា កឹឧបវិចារា កឹអធិដ្ឋានា កឹអភិនិវេសា កឹបរិយោសានាតិ ។ ចោរា ខោ ព្រាហ្មណ អាទានា-ធិប្បាយា គហណូបវិចារា សត្ថាធិដ្ឋានា អន្ធការា-ភិនិវេសា អទស្សនបរិយោសានាតិ ។ សមណា បន ភោ គោតម កិមធិប្បាយា កឹឧបវិចារា កឹអធិដ្ឋានា កឹអភិនិវេសា កឹបរិយោសានាតិ ។ សមណា ខោ ព្រាហ្មណ ខន្តិសោរច្ចាធិប្បាយា បញ្ញូបវិចារា សីលា-ធិដ្ឋានា អកិញ្ចញ្ញាភិនិវេសា និព្វានបរិយោសានាតិ ។



មានបញ្ញាជាទីពិចារណា មានសិល្បៈជាទីតាំងមាំ មានការងារជាទីប្រកាន់ មានការងារសម្រេចហើយជាទីបំផុត ។ បពិត្រព្រះគោតមដ៏ចំរើន ចុះពួកស្ត្រីមានអ្វីជាទីប្រាថ្នា មានអ្វីជាទីពិចារណា មានអ្វីជាទីតាំងមាំ មានអ្វីជាទីប្រកាន់ មានអ្វីជាទីបំផុត ។ ម្នាលព្រាហ្មណ៍ ពួកស្ត្រីមានបុរសជាទីប្រាថ្នា មានគ្រឿងអលង្ការជាទីពិចារណា មានបុត្រជាទីតាំងមាំ មិនមានស្ត្រីរួមស្វាមីជាទីប្រកាន់ មានឥស្សរិយៈជាទីបំផុត ។ បពិត្រព្រះគោតមដ៏ចំរើន ចុះពួកចោរមានអ្វីជាទីប្រាថ្នា មានអ្វីជាទីពិចារណា មានអ្វីជាទីតាំងមាំ មានអ្វីជាទីប្រកាន់ មានអ្វីជាទីបំផុត ។ ម្នាលព្រាហ្មណ៍ ពួកចោរ មានការលួចយកជាទីប្រាថ្នា មានព្រៃញាតស្បាតជាទីពិចារណា មានគ្រឿងសស្ត្រាជាទីតាំងមាំ មានទីងងឹតជាទីប្រកាន់ មានកិរិយាមិនឃើញ នីការរត់គេចជាទីបំផុត ។ បពិត្រព្រះគោតមដ៏ចំរើន ចុះពួកសមណៈ មានអ្វីជាទីប្រាថ្នា មានអ្វីជាទីពិចារណា មានអ្វីជាទីតាំងមាំ មានអ្វីជាទីប្រកាន់ មានអ្វីជាទីបំផុត ។ ម្នាលព្រាហ្មណ៍ ពួកសមណៈ មានខន្តិនិងការស្ងៀមជាទីប្រាថ្នា មានបញ្ញាជាទីពិចារណា មានសីលជាទីតាំងមាំ មានសេចក្តីមិនកង្វល់ជាទីប្រកាន់ មាននិព្វានជាទីបំផុត ។

អច្ឆរិយំ ភោ គោតម អព្ភុតំ ភោ គោតម ខត្តិយានញ្ចិ ភវំ គោតមោ ជានាតិ អធិប្បាយញ្ច ឧបវិចារញ្ច អធិដ្ឋានញ្ច អភិនិវេសញ្ច បរិយោសានញ្ច ព្រាហ្មណានញ្ចិ ភវំ គោតមោ ជានាតិ ។ បេ ។ គហបតិកានញ្ចិ ភវំ គោតមោ ជានាតិ ឥត្ថីនញ្ចិ ភវំ គោតមោ ជានាតិ ចោរានញ្ចិ ភវំ គោតមោ ជានាតិ សមណានញ្ចិ ភវំ គោតមោ ជានាតិ អធិប្បាយញ្ច ឧបវិចារញ្ច អធិដ្ឋានញ្ច អភិនិវេសញ្ច បរិយោសានញ្ច ។ អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

(៥៣) អថខោ អញ្ញតរោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ព្រាហ្មណោ



បពិត្រព្រះគោតមដ៏ចំរើន អស្ចារ្យពេកណាស់ បពិត្រព្រះគោតមដ៏ចំរើន ចំឡែកពេកណាស់ ព្រះគោតមដ៏ចំរើន ទ្រង់ជ្រាបនូវសេចក្តីប្រាថ្នា នូវកិរិយាពិចារណា នូវកិរិយាតាំងចិត្ត នូវសេចក្តីប្រកាន់ នូវទីបំផុត នៃក្សត្រទាំងឡាយផង ព្រះគោតមដ៏ចំរើន ទ្រង់ជ្រាប (នូវសេចក្តីប្រាថ្នាជាដើម) នៃព្រាហ្មណ៍ទាំងឡាយផង ។ បេ ។ ព្រះគោតមដ៏ចំរើន ទ្រង់ជ្រាប (នូវសេចក្តីប្រាថ្នាជាដើម) នៃគហបតីទាំងឡាយផង ព្រះគោតមដ៏ចំរើនទ្រង់ជ្រាប (នូវសេចក្តីប្រាថ្នាជាដើម) នៃស្ត្រីទាំងឡាយផង ព្រះគោតមដ៏ចំរើនទ្រង់ជ្រាប (នូវសេចក្តីប្រាថ្នាជាដើម) នៃចោរទាំងឡាយផង ព្រះគោតមដ៏ចំរើន ទ្រង់ជ្រាបនូវសេចក្តីប្រាថ្នា នូវកិរិយាពិចារណា នូវកិរិយាតាំងចិត្ត នូវកិរិយាប្រកាន់ នូវទីបំផុត នៃសមណៈទាំងឡាយផង ។ បពិត្រព្រះគោតមដ៏ចំរើន ច្បាស់លាស់ពេកណាស់ ។ បេ ។ សូមព្រះគោតមដ៏ចំរើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសកដល់នូវសរណៈស្មើដោយជីវិត តាំងអំពីថ្ងៃនេះតទៅ ។

(៥៣) គ្រានោះ មានព្រាហ្មណ៍ម្នាក់ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រាហ្មណ៍នោះ អង្គុយក្នុងទីសមគួរហើយ

ភគវន្តំ ឯតទវោច អត្ថិ នុ ខោ ភោ គោតម ឯកោ ធម្មោ ភាវិតោ ពហុលីកតោ យោ ឧភោ អត្ថេ សមធិគ្គយ្ហ តិដ្ឋតិ ទិដ្ឋធម្មិកញ្ចេវ អត្ថំ យោ ច អត្ថោ សម្បរាយិកោតិ ។ អត្ថិ ខោ ព្រាហ្មណ ឯកោ ធម្មោ ភាវិតោ ពហុលីកតោ យោ ឧភោ អត្ថេ សមធិគ្គយ្ហ តិដ្ឋតិ ទិដ្ឋធម្មិកញ្ចេវ អត្ថំ យោ ច អត្ថោ សម្បរាយិកោតិ ។ កតមោ បន ភោ គោតម ឯកោ ធម្មោ ភាវិតោ ពហុលីកតោ យោ ឧភោ អត្ថេ សមធិគ្គយ្ហ តិដ្ឋតិ ទិដ្ឋធម្មិកញ្ចេវ អត្ថំ យោ ច អត្ថោ សម្បរាយិកោតិ ។ អប្បមាទោ ខោ ព្រាហ្មណ ឯកោ ធម្មោ ភាវិតោ ពហុលីកតោ យោ ឧភោ អត្ថេ សមធិគ្គយ្ហ តិដ្ឋតិ ទិដ្ឋធម្មិកញ្ចេវ អត្ថំ យោ ច អត្ថោ សម្បរាយិកោ ។ សេយ្យថាបិ ព្រាហ្មណ យានិ កានិចិ ជង្គលានំ បាណានំ បទជាតានិ សព្វានិ តានិ ហត្ថិបទេ សមោធានំ គច្ឆន្តិ ហត្ថិបទំ តេសំ អគ្គមក្ខាយតិ យទិទំ មហន្តត្តេន



ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ធម៌តែមួយដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើន ៗ ហើយ រមែងបាននូវប្រយោជន៍ទាំងពីរ គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ មានដែរឬ ។ ម្នាលព្រាហ្មណ៍ ធម៌តែមួយដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើន ៗ ហើយ រមែងបាននូវប្រយោជន៍ទាំងពីរ គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ មានដែរ ។ បពិត្រព្រះគោតមដ៏ចំរើន ចុះធម៌តែមួយដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើន ៗ ហើយ រមែងបាននូវប្រយោជន៍ទាំងពីរ គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ ដូចម្តេច ។ ម្នាលព្រាហ្មណ៍ អប្បមាទធម៌ ជាធម៌តែមួយដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើន ៗ ហើយ រមែងបាននូវប្រយោជន៍ទាំងពីរ គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ ។ ម្នាលព្រាហ្មណ៍ ដូចស្នាមជើងណានីមួយ នៃសត្វទាំងឡាយ ដែលត្រាច់ទៅលើផែនដី ស្នាមជើងនៃសត្វទាំងអស់នោះ រមែងដល់នូវការប្រជុំចុះ ក្នុងស្នាមជើងនៃដំរី ស្នាមជើងនៃដំរីប្រាកដជាប្រសើរជាងស្នាមជើងនៃសត្វទាំងនោះ ព្រោះស្នាមជើងនៃដំរីធំ យ៉ាងណាមិញ

ឯវមេវ ខោ ព្រាហ្មណ អប្បមាទោ ឯកោ ធម្មោ ភាវិតោ ពហុលីកតោ យោ ឧភោ អត្ថេ សមធិគ្គយ្ហ តិដ្ឋតិ ទិដ្ឋធម្មិកញ្ចេវ អត្ថំ យោ ច អត្ថោ សម្ប-រាយិកោ សេយ្យថាបិ ព្រាហ្មណ កូដាគារស្ស យា កាចិ គោបានសិយោ សព្វា តា កូដង្គមា កូដនិន្នា កូដសមោសរណា កូដំ តាសំ អគ្គមក្ខាយតិ ឯវមេវ ខោ ព្រាហ្មណ ។បេ។ សេយ្យថាបិ ព្រាហ្មណ បព្វ-ជលាយកោ បព្វជំ លាយិត្វា អគ្គេ គហេត្វា ឱធុនាតិ និទ្ធុនាតិ និច្ឆាទេតិ ឯវមេវ ខោ ព្រាហ្មណ ។បេ។ សេយ្យថាបិ ព្រាហ្មណ អម្ពបិណ្ឌិយា វណ្ដច្ឆិន្នាយ យានិ កានិចិ អម្ពានិ វណ្ដូបនិពន្ធានិ(១) សព្វានិ តានិ តទន្វយានិ ភវន្តិ ឯវមេវ ខោ ព្រាហ្មណ ។បេ។ សេយ្យថាបិ ព្រាហ្មណ យេ កេចិ ខុទ្ទរាជានោ សព្វេ តេ រញ្ញោ ចក្កវត្តិស្ស អនុយុត្តា ភវន្តិ រាជា តេសំ ចក្កវត្តិ អគ្គមក្ខាយតិ ឯវមេវ ខោ ព្រាហ្មណ ។បេ។ សេយ្យថាបិ ព្រាហ្មណ យា កាចិ តារករូបានំ បភា

១. វណ្ដូបនិពន្ធានិ ។ ម. វណ្ដបដិពទ្ធានិ ។



ម្នាលព្រាហ្មណ៍ អប្បមាទធម៌ ជាធម៌តែមួយ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងបានខ្ជាប់នូវប្រយោជន៍ទាំងពីរ គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ គឺយ៉ាងនេះឯង ។ ម្នាលព្រាហ្មណ៍ ដូចបង្កង់ណានីមួយនៃផ្ទះកំពូល បង្កង់ទាំងអស់នោះ ប្រណមទៅកាន់កំពូល បង្អោនទៅកាន់កំពូល ប្រជុំចុះក្នុងកំពូល កំពូលប្រាកដជាប្រសើរជាងបង្កង់ទាំងនោះ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ (អប្ប-មាទធម៌) ក៏យ៉ាងនោះដែរ ។បេ។ ម្នាលព្រាហ្មណ៍ ដូចបុគ្គលជាអ្នកច្រូតនូវស្មៅជំរណោកឲ្យ បានច្រូតនូវស្មៅជំរណោកឲ្យ ចាប់យកត្រង់ចុងពុះរលាស់ហើយបោកនឹងដៃ ឬ ដើមឈើ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ (អប្បមាទធម៌) ក៏យ៉ាងនោះដែរ ។បេ។ ម្នាលព្រាហ្មណ៍ ដូចចង្កោមផ្លែស្វាយ ដែលផ្ដាច់ចាកទង ផ្លែស្វាយទាំងឡាយណានីមួយ ដែលជាប់នឹងទង ផ្លែស្វាយទាំងអស់នោះ រមែងប្រព្រឹត្តទៅតាមនូវទងនោះ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ (អប្បមាទធម៌) ក៏យ៉ាងនោះដែរ ។បេ។ ម្នាលព្រាហ្មណ៍ ដូចពួកស្ដេចតូចៗណានីមួយ ស្ដេចទាំងអស់នោះ រមែងប្រព្រឹត្តទៅតាមនូវស្ដេចចក្រពត្តិ ស្ដេចចក្រពត្តិប្រាកដជាប្រសើរជាងស្ដេចទាំងនោះ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ (អប្បមាទធម៌) ក៏យ៉ាងនោះដែរ ។បេ។ ម្នាលព្រាហ្មណ៍ ដូចពន្លឺណានីមួយនៃផ្កាយ

សព្វា តា ចន្ទស្ស បភាយ កលំ នាគ្ឃន្តិ សោឡសឹ ចន្ទប្បភា តាសំ អគ្គមក្ខាយតិ ឯវមេវ ខោ ព្រាហ្មណ អប្បមាទោ ឯកោ ធម្មោ ភាវិតោ ពហុលីកតោ យោ ឧភោ អត្ថេ សមធិគ្គយ្ហ តិដ្ឋតិ ទិដ្ឋធម្មិកញ្ចេវ អត្ថំ យោ ច អត្ថោ សម្បរាយិកោ ។ អយំ ខោ ព្រាហ្មណ ឯកោ ធម្មោ ភាវិតោ ពហុលីកតោ យោ ឧភោ អត្ថេ សមធិគ្គយ្ហ តិដ្ឋតិ ទិដ្ឋធម្មិកញ្ចេវ អត្ថំ យោ ច អត្ថោ សម្បរាយិកោតិ ។ អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។បេ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

[៥៤] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ តេន ខោ បន សមយេន អាយស្មា ធម្មិកោ ជាតិភូមិយំ អាវាសិកោ ហោតិ សព្វាសុ ជាតិភូមិយំ សត្តសុ អាវាសេសុ ។ តត្រ សុទំ អាយស្មា ធម្មិកោ អាគន្តុកេ ភិក្ខូ អក្កោសតិ បរិភាសតិ វិហឹសតិ វិតុទតិ រោសេតិ វាចាយ



ពន្លឺនៃផ្កាយទាំងអស់នោះ មិនដល់នូវចំណិតនៃចំណែក ១៦ នៃពន្លឺព្រះចន្ទឡើយ ពន្លឺនៃព្រះចន្ទប្រាកដជាប្រសើរជាងពន្លឺនៃផ្កាយទាំងនោះ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ អប្បមាទធម៌ ជាធម៌តែមួយដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងបាននូវប្រយោជន៍ទាំងពីរ គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ នេះឯងជាធម៌តែមួយ ដែលបុគ្គលបានចំរើន បានធ្វើឲ្យរឿយៗហើយ រមែងបាននូវប្រយោជន៍ទាំងពីរ គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ ។ បពិត្រព្រះគោតមដ៏ចំរើន ច្បាស់លាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចំរើន ច្បាស់លាស់ពេកណាស់ ។បេ។ សូមព្រះគោតមដ៏ចំរើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់នូវសរណៈស្មើដោយជីវិត តាំងអំពីថ្ងៃនេះតទៅ ។

[៥៤] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅភ្នំគិជ្ឈកូដ ក្បែរក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះធម្មិកៈដ៏មានអាយុ ជាចៅអាវាស ក្នុងជាតិភូមិ គឺនៅក្នុងអាវាសទាំង ៧ ក្នុងជាតិភូមិ ។ បានឮថា ក្នុងទីនោះ ព្រះធម្មិកៈដ៏មានអាយុ ជេរប្រទេច ចៀតចៀន ចាក់ដោតកោសរួសនូវពួកភិក្ខុជាអាគន្តុកៈ ដោយវាចា

តេ ច អាគន្តុកា ភិក្ខូ អាយស្មតា ធម្មិកេន អក្កោសិយមានា បរិភាសិយមានា វិហេសិយមានា វិតុទិយមានា រោសិយមានា វាចាយ បក្កមន្តិ ន សណ្ឋន្តិ រិញ្ចន្តិ អាវាសំ ។ អថខោ ជាតិភូមិកានំ ឧបាសកានំ ឯតទហោសិ មយំ ខោ ភិក្ខុសង្ឃំ បច្ចុបដ្ឋិតា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន អថ ច បន អាគន្តុកា ភិក្ខូ បក្កមន្តិ ន សណ្ឋន្តិ រិញ្ចន្តិ អាវាសំ កោ នុ ខោ ហេតុ កោ បច្ចយោ យេន អាគន្តុកា ភិក្ខូ បក្កមន្តិ ន សណ្ឋន្តិ រិញ្ចន្តិ អាវាសន្តិ ។ អថខោ ជាតិភូមិកានំ ឧបាសកានំ ឯតទហោសិ អយំ ខោ អាយស្មា ធម្មិកោ អាគន្តុកេ ភិក្ខូ អក្កោសតិ បរិភាសតិ វិហេសតិ វិតុទតិ រោសេតិ វាចាយ តេ ច អាគន្តុកា ភិក្ខូ អាយស្មតា ធម្មិកេន អក្កោសិយមានា បរិភាសិយមានា វិហេសិយមានា វិតុទិយមានា រោសិយមានា វាចាយ បក្កមន្តិ ន សណ្ឋន្តិ រិញ្ចន្តិ អាវាសំ ។ យន្នូន មយំ អាយស្មន្តំ ធម្មិកំ បព្វាជេយ្យាមាតិ ។



ឯអាគន្តុកភិក្ខុទាំងនោះ ត្រូវព្រះធម្មិកៈដ៏មានអាយុ ជេរប្រទេច បៀតបៀន ចាក់ដោត កោសរូស ដោយវាចាហើយ ក៏ចៀសចេញទៅ មិនបាននៅ លះបង់ទីអាវាសចោលអស់ ។ លំដាប់នោះ ពួកជាតិភូមិកឧបាសក មានសេចក្តីត្រិះរិះដូច្នេះថា យើងទាំងឡាយ ទំនុកបំរុងភិក្ខុសង្ឃដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ក៏ស្រាប់តែពួកអាគន្តុកភិក្ខុ ចៀសចេញទៅ មិនបាននៅ លះបង់ទីអាវាសចោលអស់ ចុះហេតុដូចម្តេច បច្ច័យដូចម្តេច បានជាពួកអាគន្តុកភិក្ខុ ចៀសចេញទៅ មិនបាននៅ លះបង់អាវាសចោលអស់ ។ លំដាប់នោះ ពួកជាតិភូមិកឧបាសក មានសេចក្តីត្រិះរិះដូច្នេះថា ច្បាស់ជាព្រះធម្មិកៈដ៏មានអាយុនេះឯង ជេរប្រទេច បៀតបៀន ចាក់ដោត កោសរូសនូវពួកអាគន្តុកភិក្ខុ ដោយវាចា បានជាអាគន្តុកភិក្ខុទាំងនោះ ត្រូវព្រះធម្មិកៈដ៏មានអាយុ ជេរប្រទេច បៀតបៀន ចាក់ដោត កោសរូស ដោយវាចា ហើយក៏ចៀសចេញទៅ មិនបាននៅ លះបង់ទីអាវាសចោលអស់ ។ បើដូច្នោះ យើងទាំងឡាយ ត្រូវបណ្តេញព្រះធម្មិកៈដ៏មានអាយុចេញ ។

អថខោ ជាតិភូមិកា ឧបាសកា យេន អាយស្មា ធម្មិកោ តេនុបសង្កមិំសុ ឧបសង្កមិត្វា អាយស្មន្តំ ធម្មិកំ ឯតទវោចុំ បក្កមតុ ភន្តេ អាយស្មា ធម្មិកោ ឥមម្ហា អាវាសា អលន្តេ ឥធ វាសេនាតិ ។ អថខោ អាយស្មា ធម្មិកោ តម្ហា អាវាសា អញ្ញំ អាវាសំ អគមាសិ ។ តត្របិ សុទំ អាយស្មា ធម្មិកោ អាគន្តុកេ ភិក្ខូ អក្កោសតិ បរិភាសតិ វិហេសតិ វិតុទតិ រោសេតិ វាចាយ តេ ច អាគន្តុកា ភិក្ខូ អាយស្មតា ធម្មិកេន អក្កោសិយមានា បរិភាសិយមានា វិហេសិយមានា វិតុទិយមានា រោសិយមានា វាចាយ បក្កមន្តិ ន សណ្ឋន្តិ វិជហន្តិ អាវាសំ ។ អថខោ ជាតិភូមិកានំ ឧបាសកានំ ឯតទហោសិ មយំ ខោ ភិក្ខុសង្ឃស្ស បច្ចុបដ្ឋិតា ចីវរបិណ្ឌបាតសេនាសនគិលានបច្ចយភេសជ្ជបរិក្ខារេន អថ ច បន អាគន្តុកា ភិក្ខូ បក្កមន្តិ ន សណ្ឋន្តិ វិជហន្តិ អាវាសំ កោ នុ ខោ ហេតុ កោ បច្ចយោ យេន អាគន្តុកា ភិក្ខូ បក្កមន្តិ ន សណ្ឋន្តិ វិជហន្តិ អាវាសន្តិ ។





លំដាប់នោះ ពួកជាតិភូមិកឧបាសក ចូលទៅរកព្រះធម្មិកៈដ៏មានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងព្រះធម្មិកៈដ៏មានអាយុដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមព្រះធម្មិកៈដ៏មានអាយុ ចៀសចេញចាកអាវាសនេះទៅ មិនគួរលោកនៅក្នុងអាវាសនេះទេ ។ វេលានោះ ព្រះធម្មិកៈដ៏មានអាយុ ក៏បានចេញអំពីអាវាសនោះ ទៅកាន់អាវាសដទៃវិញ ។ បានឮថា ក្នុងទីនោះ ព្រះធម្មិកៈដ៏មានអាយុ ជេរប្រទេច បៀតបៀន ចាក់ដោត រោសរួសពួកអាគន្តុកភិក្ខុដោយវាចា ឯពួកអាគន្តុកភិក្ខុទាំងនោះ ត្រូវព្រះធម្មិកៈ ដ៏មានអាយុ ជេរប្រទេច បៀតបៀន ចាក់ដោត រោសរួសដោយវាចាហើយ ក៏ចៀសចេញទៅ មិនឋិតនៅ លះបង់នូវអាវាសចោល ។ លំដាប់នោះ ពួកជាតិភូមិកឧបាសក មានសេចក្តីត្រិះរិះដូច្នេះថា យើងទាំងឡាយ ទំនុកបំរុងភិក្ខុសង្ឃដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ស្រាប់តែពួកអាគន្តុកភិក្ខុ ចៀសចេញទៅមិនឋិតនៅ លះបង់នូវអាវាសចោលអស់ ហេតុដូចម្ដេច បច្ច័យដូចម្ដេច បានជាពួកអាគន្តុកភិក្ខុ ចៀសចេញទៅ មិនឋិតនៅ លះបង់នូវអាវាសចោលអស់ ។

អថខោ ជាតិភូមិកានំ ឧបាសកានំ ឯតទហោសិ អយំ ខោ អាយស្មា ធម្មិកោ អាគន្តុកេ ភិក្ខូ អក្កោសតិ បរិភាសតិ វិហឹសតិ វិតុទតិ រោសេតិ វាចាយ តេ ច អាគន្តុកា ភិក្ខូ អាយស្មតា ធម្មិកេន អក្កោសិយមានា បរិភាសិយមានា វិហេសិយមានា វិតុទិយមានា រោសិយមានា វាចាយ បក្កមន្តិ ន សណ្ឋន្តិ រិញ្ចន្តិ អាវាសំ ។ យន្នូន មយំ អាយស្មន្តំ ធម្មិកំ បព្វាជេយ្យាមាតិ ។ អថខោ ជាតិភូមិកា ឧបាសកា យេន អាយស្មា ធម្មិកោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មន្តំ ធម្មិកំ ឯតទវោចុំ បក្កមតុ ភន្តេ អាយស្មា ធម្មិកោ ឥមម្ហា អាវាសា អលន្តេ ឥធ វាសេនាតិ ។ អថខោ អាយស្មា ធម្មិកោ តម្ហា អាវាសា អញ្ញំ អាវាសំ អគមាសិ ។ តត្របិ សុទំ អាយស្មា ធម្មិកោ អាគន្តុកេ ភិក្ខូ អក្កោសតិ បរិភាសតិ វិហឹសតិ វិតុទតិ រោសេតិ វាចាយ



វេលានោះ ពួកជាតិភូមិកឧបាសក មានសេចក្តីត្រិះរិះដូច្នេះថា ច្បាស់ជាព្រះធម្មិកៈដ៏មានអាយុនេះ ជេរប្រទេច បៀតបៀន ចាក់ដោត រោសរូសពួកអាគន្តុកភិក្ខុដោយវាចា ចុះជាអាគន្តុកភិក្ខុទាំងនោះ ត្រូវព្រះធម្មិកៈដ៏មានអាយុ ជេរប្រទេច បៀតបៀន ចាក់ដោត រោសរូស ដោយវាចាហើយ ក៏ចៀសចេញទៅ មិនឋិតនៅ លះបង់ទីអាវាសចោលអស់ បើដូច្នោះ យើងទាំងឡាយ ត្រូវតែបណ្តេញព្រះធម្មិកៈដ៏មានអាយុចេញ ។ លំដាប់នោះ ពួកជាតិភូមិកឧបាសក ចូលទៅរកព្រះធម្មិកៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះធម្មិកៈដ៏មានអាយុដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមព្រះធម្មិកៈដ៏មានអាយុចៀសចេញចាកអាវាសនេះទៅ លោកមិនគួរនៅក្នុងអាវាសនេះទេ ។ គ្រានោះ ព្រះធម្មិកៈដ៏មានអាយុ ក៏ចេញចាកអាវាសនោះ ទៅកាន់អាវាសដទៃវិញ ។ ចុះឮថា ក្នុងទីនោះ ព្រះធម្មិកៈដ៏មានអាយុ ជេរប្រទេច បៀតបៀន ចាក់ដោត រោសរូស ពួកអាគន្តុកភិក្ខុ ដោយវាចា

តេ ច អាគន្តុកា ភិក្ខូ អាយស្មតា ធម្មិកេន អក្កោសិយមានា បរិភាសិយមានា វិហេសិយមានា វិតុទិយមានា រោសិយមានា វាចាយ បក្កមន្តិ ន សណ្ឋន្តិ រិញ្ចន្តិ អាវាសំ ។ អថខោ ជាតិភូមកានំ ឧបាសកានំ ឯតទហោសិ មយំ ខោ ភិក្ខុសង្ឃំ បច្ចុ-បដ្ឋិតា ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជ-បរិក្ខារេន អថ ច បន អាគន្តុកា ភិក្ខូ បក្កមន្តិ ន សណ្ឋន្តិ រិញ្ចន្តិ អាវាសំ កោ នុ ខោ ហេតុ កោ បច្ចយោ យេន អាគន្តុកា ភិក្ខូ បក្កមន្តិ ន សណ្ឋន្តិ រិញ្ចន្តិ អាវាសន្តិ ។ អថខោ ជាតិភូមកានំ ឧបាសកានំ ឯតទហោសិ ។ បេ ។ យន្នូន មយំ អាយស្មន្តំ ធម្មិកំ បព្វាជេយ្យាម សព្វសោ ជាតិភូមិយំ សត្តហិ អាវាសេហីតិ ។ អថខោ ជាតិភូមកា ឧបាសកា យេន អាយស្មា ធម្មិកោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មន្តំ ធម្មិកំ ឯតទវោចុំ បក្កមតុ ភន្តេ អាយស្មា ធម្មិកោ សព្វសោ ជាតិភូមិយំ សត្តហិ អាវាសេហីតិ ។



*ឯអាគន្តុកភិក្ខុទាំងនោះ ត្រូវព្រះធម្មិកៈដ៏មានអាយុ ជេរប្រទេច បៀតបៀន ចាក់ដោត រោសរូស ដោយវាចាហើយ ក៏ចៀសចេញទៅ មិនឋិតនៅ លះបង់អាវាសចោលអស់ ។ លំដាប់នោះ ពួកជាតិភូមិកឧបាសក មានសេចក្តីត្រិះរិះដូច្នេះថា យើងទាំងឡាយ ទំនុកបំរុងព្រះភិក្ខុសង្ឃ ដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ប្រាកដតែពួកអាគន្តុកភិក្ខុ ចៀសចេញទៅ មិនឋិតនៅ លះបង់អាវាសចោលអស់ ចុះហេតុដូចម្តេច បច្ច័យដូចម្តេច បានជាពួកអាគន្តុកភិក្ខុ ចៀសចេញទៅ មិនឋិតនៅ លះបង់អាវាសចោលអស់ ។ វេលានោះ ពួកជាតិភូមិកឧបាសក មានសេចក្តីត្រិះរិះដូច្នេះថា ។ បេ ។ បើដូច្នោះ យើងទាំងឡាយ ត្រូវតែបណ្តេញព្រះធម្មិកៈដ៏មានអាយុ ឲ្យចេញចាកអា-វាសគ្រប់ទាំង ៧ ក្នុងជាតិភូមិ ។ លំដាប់នោះ ពួកជាតិភូមិកឧបាសក ចូលទៅរកព្រះធម្មិកៈដ៏មានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងព្រះធម្មិកៈដ៏មានអាយុដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមព្រះធម្មិកៈដ៏មានអាយុ ចៀសចេញចាកអាវាសគ្រប់ទាំង ៧ ក្នុងជាតិភូមិទៅ ។*

អថខោ អាយស្មតោ ធម្មិកស្ស ឯតទហោសិ បព្វាជិតោ ខោម្ហិ ជាតិភូមកេហិ ឧបាសកេហិ សព្វសោ ជាតិភូមិយំ សត្តហិ អាវាសេហិ កហំ នុ ខោ ទានិ គច្ឆាមីតិ ។ អថខោ អាយស្មតោ ធម្មិកស្ស ឯតទហោសិ យន្នូនាហំ យេន ភគវា តេនុបសង្កមេយ្យន្តិ ។ អថខោ អាយស្មា ធម្មិកោ បត្តចីវរមាទាយ យេន រាជគហំ តេន បក្កាមិ អនុបុព្វេន យេន រាជគហំ គិជ្ឈកូដោ បព្វតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ ធម្មិកំ ភគវា ឯតទវោច ហន្ទ កុតោ នុ ត្វំ ព្រាហ្មណ ធម្មិក អាគច្ឆសីតិ ។ បព្វាជិតោ អហំ ភន្តេ ជាតិភូមកេហិ ឧបាសកេហិ សព្វសោ ជាតិភូមិយំ សត្តហិ អាវាសេហីតិ ។ អលំ ព្រាហ្មណ ធម្មិក កិំ តេ ឥមិនា ។



គ្រានោះ ព្រះធម្មិកៈដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញត្រូវពួកជាតិភូមកៈ បណ្តេញចេញចាកអាវាសគ្រប់ទាំង ៧ ក្នុងជាតិភូមិហើយ ឥឡូវនេះ អាត្មាអញនឹងទៅក្នុងទីណាហ្ន៎ ។ លំដាប់នោះ ព្រះធម្មិកៈដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ គួរតែអាត្មាអញ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ សម័យនោះ ព្រះធម្មិកៈដ៏មានអាយុ ប្រដាប់បាត្រនិងចីវរ ដើរសំដៅទៅក្រុងរាជគ្រឹះ ហើយចូលទៅកាន់ភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ដោយលំដាប់ ដែលព្រះដ៏មានព្រះភាគគង់នៅ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះធម្មិកៈដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគត្រាស់ដូច្នេះថា ម្នាលព្រាហ្មណ៍ធម្មិកៈ អើ អ្នកមកពីណាហ្ន៎ ។ ព្រះធម្មិកៈក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គត្រូវពួកជាតិភូមកឧបាសក បណ្តេញអំពីអាវាសគ្រប់ទាំង ៧ ក្នុងជាតិភូមិ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ ល្មមហើយ ប្រយោជន៍អ្វីដោយអ្នកឯងនៅក្នុងអាវាសនេះ ។

យន្តំ គតោ គតោ បព្វាជេន្តិ សោ ត្វំ គតោ គតោ បព្វាជិតោ មមេវ សន្តិកេ អាគច្ឆសិ ។

ភូតបុព្វំ ព្រាហ្មណ ធម្មិក សាមុទ្ទិកា វាណិជា តីរទស្សឹ សកុណំ គហេត្វា នាវាយ សមុទ្ទំ អជ្ឈោគាហន្តិ ។ តេ អតីរទស្សនិយា(១) នាវាយ តីរទស្សឹ សកុណំ មុញ្ចន្តិ ។ សោ គច្ឆតេវ បុរត្ថិមំ ទិសំ គច្ឆតិ បច្ឆិមំ ទិសំ គច្ឆតិ ឧត្តរំ ទិសំ គច្ឆតិ ទក្ខិណំ ទិសំ គច្ឆតិ ឧទ្ធំ គច្ឆតិ អនុទិសំ ។ សចេ សោ សមន្តា តីរំ បស្សតិ តថាគតកោវ ហោតិ ។ សចេ បន សោ សមន្តា តីរំ ន បស្សតិ តមេវ នាវំ បច្ចាគច្ឆតិ ។ ឯវមេវ ខោ ព្រាហ្មណ ធម្មិក យន្តំ គតោ គតោ បព្វាជេន្តិ សោ ត្វំ គតោ គតោ បព្វាជិតោ មមេវ សន្តិកេ អាគច្ឆសិ ។

ភូតបុព្វំ ព្រាហ្មណ ធម្មិក រញ្ញោ កោរព្យស្ស សុប្បតិដ្ឋោ នាម និគ្រោធរាជា អហោសិ បញ្ចសាខោ សីតច្ឆាយោ មនោរមោ ។

១ ម. អតីរទស្សិណិយា ។



ពួកជាតិភូមិកទុកសក បណ្តេញអ្នកឯងអំពីទីនោះ ១ អ្នកឯងទាល់តែពួកជាតិភូមិកទុកសក បណ្តេញអំពីទីនោះ ១ ហើយ ទើបបានមកក្នុងសំណាក់តថាគតវិញ ។

ម្នាលព្រាហ្មណ៍ធម្មិកៈ តាំងពីព្រេងនាយមកមានពួកពាណិជអ្នកដើរក្នុងសមុទ្រ ចាប់សត្វស្លាបបក្សីឃើញត្រើយ ហើយចុះទៅកាន់សមុទ្រដោយសំពៅ ។ ពាណិជទាំងនោះ កាលបើសំពៅទៅមិនបានឃើញត្រើយ ក៏តែងលែងសត្វស្លាបបក្សីឃើញត្រើយទៅ ។ សត្វនោះ ក៏ហើរទៅទិសខាងកើត ហើរទៅទិសខាងលិច ហើរទៅទិសខាងជើង ហើរទៅទិសខាងត្បូង ហើរទៅទិសខាងលើ ហើរទៅទិសតូច បើសត្វនោះឃើញត្រើយដោយជុំវិញហើយ ក៏ហើរបាត់ទៅតែម្តង ។ បើសត្វនោះ មិនបានឃើញត្រើយដោយជុំវិញទេ ក៏ត្រឡប់មកកាន់សំពៅនោះវិញ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ធម្មិកៈ ពួកជាតិភូមិកទុកសក បណ្តេញអ្នកអំពីទីនោះ ១ អ្នកឯងទាល់តែគេបណ្តេញអំពីទីនោះ ១ ហើយ ទើបបានមកក្នុងសំណាក់តថាគតវិញ ក៏យ៉ាងនោះដែរ ។

ម្នាលព្រាហ្មណ៍ធម្មិកៈ តាំងពីព្រេងនាយមក មានស្តេចដើមជ្រៃឈ្មោះសុប្បតិដ្ឋៈរបស់ព្រះបាទកោរព្យៈ មានមែក៥ មានម្លប់ត្រជាក់ជាទីគាប់ចិត្ត

សុប្បតិដ្ឋស្ស ខោ បន ព្រាហ្មណ ធម្មិក និគ្រោធរាជស្ស ទ្វាទស យោជនានិ ឧព្វេធេន អហោសិ បញ្ច យោជនានិ មូលសន្តានកំ ។ សុប្បតិដ្ឋស្ស ខោ បន ព្រាហ្មណ ធម្មិក និគ្រោធរាជស្ស ឧឡារានិ ផលានិ អហេសុំ សេយ្យថាបិ នាម អាឡ្ហកថាលិកា ឯវមស្ស សាទូនិ ផលានិ អហេសុំ សេយ្យថាបិ នាម ខុទ្ទមធុំ អនេឡកំ ។ សុប្បតិដ្ឋស្ស ខោ បន ព្រាហ្មណ ធម្មិក និគ្រោធរាជស្ស ឯកំ ខន្ធំ រាជា បរិភុញ្ជតិ សទ្ធឹ ឥត្ថាគារេន ឯកំ ខន្ធំ ពលកាយោ បរិភុញ្ជតិ ឯកំ ខន្ធំ នេគមជានបទា បរិភុញ្ជន្តិ ឯកំ ខន្ធំ សមណព្រាហ្មណា បរិភុញ្ជន្តិ ឯកំ ខន្ធំ មិគបក្ខិនោ បរិភុញ្ជន្តិ ។ សុប្បតិដ្ឋស្ស ខោ បន ព្រាហ្មណ ធម្មិក និគ្រោធរាជស្ស ន កោចិ ផលានិ រក្ខតិ ។ ន ច សុទំ អញ្ញមញ្ញស្ស ផលានិ ហឹសន្តិ ។ អថខោ ព្រាហ្មណ ធម្មិក អញ្ញតរោ បុរិសោ សុប្បតិដ្ឋស្ស និគ្រោធរាជស្ស យាវទត្ថំ ផលានិ ភក្ខិត្វា សាខំ ភញ្ជិត្វា បក្កាមិ ។



ម្នាលព្រាហ្មណ៍ធម្មិកៈ សុប្បតិដ្ឋនិគ្រោធរាជ មានកំពស់ ១២ យោជន៍ មានបណ្ដាញឫស ៥ យោជន៍ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ សុប្បតិដ្ឋនិគ្រោធរាជ មានផ្លែធំប៉ុនភាជនៈ សម្រាប់ចំអិនអង្ករ ចំនួនមួយអាឡ្ហក ផ្លែជ្រៃនោះមានរសផ្អែមដូចទឹកឃ្មុំ គ្មានរេ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ ព្រះរាជាសោយមែកមួយរបស់សុប្បតិដ្ឋនិគ្រោធរាជ ជាមួយស្រីស្នំ ពួកពល បរិភោគមែកមួយ ពួកអ្នកនិគមជនបទ បរិភោគមែកមួយ ពួកសមណព្រាហ្មណ៍ បរិភោគមែកមួយ ពួកម្រឹគបក្សីបរិភោគមែកមួយ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ មិនមានបុគ្គលណា រក្សាផ្លែនៃសុប្បតិដ្ឋនិគ្រោធរាជទេ ។ សេចក្ដីដំណាលថា ពួកជនមិនបៀតបៀនផ្លែរបស់គ្នានឹងគ្នាឡើយ ។ ម្នាលព្រាហ្មណ៍ធម្មិកៈលំដាប់នោះ មានបុរសម្នាក់ ស៊ីផ្លែសុប្បតិដ្ឋនិគ្រោធរាជដរាប ដល់ឆ្អែត ហើយក៏កាច់យកមែកចៀសចេញទៅ ។

អថខោ ព្រាហ្មណ ធម្មិក សុប្បតិដ្ឋេ និគ្រោធរាជេ អធិវត្ថាយ ទេវតាយ ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ យាវ បាបមនុស្សោ យត្រ ហិ នាម សុប្បតិដ្ឋស្ស និគ្រោធរាជស្ស យាវតគ្គំ ផលានិ ភក្ខិត្វា សាខំ ភញ្ជិត្វា បក្កមិស្សតិ យន្នូន សុប្បតិដ្ឋោ និគ្រោធរាជា អាយតឹ ផលំ ន ទទេយ្យាតិ ។ អថខោ ព្រាហ្មណ ធម្មិក សុប្បតិដ្ឋោ និគ្រោធរាជា អាយតឹ ផលំ ន អទាសិ ។ អថខោ ព្រាហ្មណ ធម្មិក រាជា កោរព្យោ យេន សក្កោ ទេវានមិន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា សក្កំ ទេវានមិន្ទំ ឯតទវោច យគ្ឃេ មារិស ជានេយ្យាសិ សុប្បតិដ្ឋោ និគ្រោធរាជា ផលំ ន ទេតីតិ ។ អថខោ ព្រាហ្មណ ធម្មិក សក្កោ ទេវានមិន្ទោ តថារូបំ ឥទ្ធាភិសង្ខារំ អភិសង្ខាសិ យថា ពាឡ្ហា វាតវុដ្ឋិ អាគន្ត្វា សុប្បតិដ្ឋំ និគ្រោធរាជំ បវត្តេសិ(១) ឧម្មូលមកាសិ អថខោ ព្រាហ្មណ ធម្មិក សុប្បតិដ្ឋេ និគ្រោធរាជេ អធិវត្ថា ទេវតា ទុក្ខី ទុម្មនា អស្សុមុខី រុទមានា ឯកមន្តំ អដ្ឋាសិ ។

១ ម. ឃាតេសិ ។



ម្នាលព្រាហ្មណ៍ធម្មិកៈ វេលានោះ ទេវតាដែលនៅអាស្រ័យដើមសុប្បតិដ្ឋនិគ្រោធរាជ មានសេចក្តីត្រិះរិះដូច្នេះថា យីអើ អស្ចារ្យណាស់ហ្ន៎ យីអើ ចំឡែកណាស់ហ្ន៎ កោតតែមនុស្សបាប ហ៊ានស៊ីផ្លែសុប្បតិដ្ឋនិគ្រោធរាជ ដរាបដល់ផ្លែខ្ពស់ ហើយកាច់យកមែក ចៀសចេញទៅ បើដូច្នោះ សុប្បតិដ្ឋនិគ្រោធរាជ មិនគួរឲ្យផ្លែ តទៅទៀតទេ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ ដើមសុប្បតិដ្ឋនិគ្រោធរាជ ក៏មិនបានឲ្យផ្លែតទៅទៀតឡើយ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ លំដាប់នោះ ព្រះបាទកោរព្យៈ ចូលទៅរកសក្កទេវានមិន្ទ លុះចូលទៅដល់ហើយ ក៏ពោលទៅនឹងសក្កទេវានមិន្ទដូច្នេះថា បពិត្រលោកនិទ្ទុក្ខ ដែលគួរគេបូជា លោកគួរជ្រាប ឥឡូវនេះ សុប្បតិដ្ឋនិគ្រោធរាជ មិនឲ្យផ្លែទេ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ លំដាប់នោះ សក្កទេវានមិន្ទ បានតាក់តែងឥទ្ធាភិសង្ខារ គឺការតាក់តែង ដោយឫទ្ធិមានសភាពដូច្នោះឲ្យខ្យល់នឹងគ្រាប់ភ្លៀងដ៏មានកំឡាំង បក់បោកមកឲ្យសុប្បតិដ្ឋនិគ្រោធរាជរលំធ្វើឲ្យមានឫសឡើងលើ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ វេលានោះពួកទេវតាដែលអាស្រ័យនៅលើដើមសុប្បតិដ្ឋនិគ្រោធរាជ ក៏ដល់នូវសេចក្តីទុក្ខតូចចិត្ត មានមុខទទឹកដោយទឹកភ្នែក ទ្រហោយំឈរនៅក្នុងទីដ៏សមគួរ ។

អថខោ ព្រាហ្មណ ធម្មិក សក្កោ ទេវានមិន្ទោ យេន សុប្បតិដ្ឋេ និគ្រោធរាជេ អធិវត្ថា ទេវតា តេនុបសង្កមិ ឧបសង្កមិត្វា សុប្បតិដ្ឋេ និគ្រោធរាជេ អធិវត្ថំ ទេវតំ ឯតទវោច កឹ នុ ត្វំ ទេវតេ ទុម្មី ទុម្មនា អស្សុមុខី រុទមានា ឯកមន្តំ ឋិតាតិ ។ តថា ហិ បន មេ មារិស ឥភា ភិសុដ្ឋិ អាគន្ត្វា ករំ បរិក្កសិ ទុព្ពលមកាសីតិ ។ អបិ នុ ត្វំ ទេវតេ រុក្ខធម្មេ ឋិតា ឥភា ភិសុដ្ឋិ អាគន្ត្វា ករំ បរិក្កសិ ទុព្ពលមកាសីតិ ។ កថំ បន មារិស រុក្ខោ រុក្ខធម្មេ ឋិតោ ហោតីតិ ។ ឥធ ទេវតេ រុក្ខស្ស មូលំ មូលត្ថិកា ហរន្តិ តចំ តចត្ថិកា ហរន្តិ បត្តំ បត្តត្ថិកា ហរន្តិ បុប្ផំ បុប្ផត្ថិកា ហរន្តិ ផលំ ផលត្ថិកា ហរន្តិ ន ច តេន ទេវតាយ អនត្តមនតា វា អនភិរទ្ធិ វា ករណីយា ឯវំ ខោ ទេវតេ រុក្ខោ រុក្ខធម្មេ ឋិតោ ហោតីតិ ។ អដ្ឋិតាយេវ ខោ មេ មារិស រុក្ខធម្មេ ឥភា ភិសុដ្ឋិ អាគន្ត្វា ករំ បរិក្កសិ ទុព្ពលមកាសីតិ ។



ម្នាលព្រាហ្មណ៍ធម្មិកៈ លំដាប់នោះ សក្កទេវានមិន្ទ្រ ចូលទៅរកទេវតា ដែលនៅលើដើមសុប្បតិដ្ឋនិគ្រោធរាជ លុះចូលទៅដល់ហើយ បាននិយាយនឹងទេវតា ដែលនៅលើដើមសុប្បតិដ្ឋនិគ្រោធនោះថា នែទេវតា អ្នកដល់នូវសេចក្តីទុក្ខ ខូចចិត្ត មានមុខរងាក ដោយទឹកភ្នែក ខ្សឹកយំឈរនៅក្នុងទីសមគួរ ដោយហេតុដូចម្តេច ។ ម្នាលអ្នកនិទ្ទុក្ខ ដ្បិតខ្សែលនឹងកៀនដំរីទាំងនឹ បាក់ធ្លាក់កិតគលរបស់ខ្ញុំឲ្យរលីងទ្រលប់ ធ្វើឲ្យមានទុក្ខសោកទៀងហើយ ។ ម្នាលទេវតា អ្នកឋិតនៅក្នុងរុក្ខធម៌ហើយ ខ្សល់នឹងកៀនដំរីទាំងនឹ បាក់ធ្លាក់កិតគលឲ្យរលីងទ្រលប់ ធ្វើឲ្យមានទុក្ខទៀងលើដែរឬ ។ ម្នាលអ្នកនិទ្ទុក្ខ ចុះដើមឈើឋិតនៅក្នុងរុក្ខធម៌ដូចម្តេច ។ ម្នាលទេវតា ក្នុងលោកនេះ ពួកជនអ្នកត្រូវការដោយឫសឈើ តែងនាំយកឫសទៅ អ្នកត្រូវការដោយសម្បក តែងនាំយកសម្បកទៅ អ្នកត្រូវការដោយស្លឹក តែងនាំយកស្លឹកទៅ អ្នកត្រូវការដោយផ្កា តែងនាំយកផ្កាទៅ អ្នកត្រូវការដោយផ្លែ តែងនាំយកផ្លែទៅ ព្រោះហេតុនោះ ទេវតា មិនត្រូវធ្វើនូវសេចក្តីខូចចិត្តផង នូវសេចក្តីមិនត្រេកអរផងទេ ម្នាលទេវតា យ៉ាងនេះឯង ទើបថា ដើមឈើឋិតនៅក្នុងរុក្ខធម៌ ។ ម្នាលអ្នកនិទ្ទុក្ខ ខ្ញុំមិនបានឋិតនៅក្នុងរុក្ខធម៌ហើយ បានជាខ្សល់នឹងកៀនដំរីទាំងនឹបាក់ធ្លាក់កិតគលឲ្យរលីងទ្រលប់ ធ្វើឲ្យមានទុក្ខទៀងលើ ។

សចេ ខោ ត្វំ ទេវតេ ព្រាហ្មណស្ស ខមេយ្យាសិ សិយា តេ ភវនំ យថា បុរេតិ ។ ខមេយ្យាមហំ(១) មារិស ព្រាហ្មណស្ស ហោតុ មេ ភវនំ យថា បុរេតិ ។ អថ ខោ ព្រាហ្មណ ធម្មិក សក្កោ ទេវានមិន្ទោ តថារូបំ ឥទ្ធាភិសង្ខារំ អភិសង្ខារិ យថា ភុសា វាតវុដ្ឋិ អាគន្ត្វា សុប្បតិដ្ឋំ និគ្រោធរាជំ ឧស្សាបេតិ សញ្ឆវីនិ មូលានិ អហេសុំ ។ ឯវមេវ ខោ ព្រាហ្មណ ធម្មិក អបិនុ តំ សមណធម្មេ ឋិតំ ជាតិភូមិកា ឧបាសកា បព្វាជេសុំ(២) សព្វសោ ជាតិភូមិយំ សត្តហិ អាវាសេហីតិ ។ កថំ បន ភន្តេ សមណោ សមណធម្មេ ឋិតោ ហោតីតិ ។ ឥធ ព្រាហ្មណ ធម្មិក សមណោ អក្កោសន្តំ ន បច្ចក្កោសតិ រោសន្តំ ន បដិរោសតិ ភណ្ឌន្តំ ន បដិភណ្ឌតិ ឯវំ ខោ ព្រាហ្មណ ធម្មិក សមណោ សមណធម្មេ ឋិតោ ហោតីតិ ។ អដ្ឋិតញ្ញេវ ខោ មំ ភន្តេ សមណធម្មេ ជាតិភូមិកា ឧបាសកា បព្វាជេសុំ សព្វសោ ជាតិភូមិយំ សត្តហិ អាវាសេហីតិ ។

១ ម. ឧ. បស្សេមហំ ។ ២ ម. បព្វាជេយ្យុំ ។



ម្នាលទេវតា ប្រសិនបើ អ្នកឈប់ខឹងនឹងព្រាហ្មណ៍ហើយ ទើបភពន របស់អ្នកនឹងមានដូចកាលមុន ។ ម្នាលអ្នកនិទ្ទុក្ខ ខ្ញុំឈប់ខឹងនឹងព្រាហ្មណ៍ សូមឲ្យភពន របស់ខ្ញុំកើតឡើងដូចកាលមុន ។ ម្នាលព្រាហ្មណ៍ធម្មិក: វេលានោះសក្កទេវានមិន្ទ ក៏បានតាក់តែងឫទ្ធាភិសង្ខារ មានសភាពដូច្នោះ ឲ្យខ្យល់នឹងភ្លៀងដ៏ខ្លាំងបក់បោកមក ធ្វើឲ្យសុប្បតិដ្ឋនិគ្រោធរាជដុះឡើង មានឫសពេញដូចដែលវិញ ។ ម្នាលព្រាហ្មណ៍ធម្មិក:តើពួកជាតិភូមិកឧបាសក បានបណ្តេញអ្នកឯង ដែលឋិតនៅក្នុងសមណធម៌ ឲ្យចេញចាកអាវាសទាំង ៧ ក្នុងជាតិភូមិ ក៏យ៉ាងនោះដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ចុះសមណៈឋិតនៅក្នុងសមណធម៌ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ធម្មិក: សមណៈក្នុងសាសនានេះ មិនជេរតបបុគ្គលដែលជេរខ្លួន មិនរោសវិញនឹងបុគ្គល ដែលរោសខ្លួន មិនឈ្លោះតបបុគ្គលដែលឈ្លោះនឹងខ្លួនទេ ម្នាលព្រាហ្មណ៍ធម្មិក: យ៉ាងនេះឈ្មោះថាសមណៈឋិតនៅក្នុងសមណធម៌ ។ បពិត្រព្រះអង្គដ៏ចំរើន ពួកជាតិភូមិកឧបាសក បណ្តេញខ្ញុំព្រះអង្គដែលមិនបានឋិតនៅក្នុងសមណៈធម៌ អំពីអាវាសទាំង ៧ ក្នុងជាតិភូមិ ។

ភូតបុព្វំ ព្រាហ្មណា ធម្មិកា សុនេត្តោ នាម សត្ថា អហោសិ តិត្ថករោ កាមេសុ វីតរាគោ ។ សុនេត្តស្ស ខោ បន ព្រាហ្មណា ធម្មិកា សត្ថុនោ អនេកានិ សាវកសតានិ អហេសុំ ។ សុនេត្តោ សត្ថា សាវកានំ ព្រហ្មលោកសហព្យតាយ ធម្មំ ទេសេសិ ។ យេ ខោ បន ព្រាហ្មណា ធម្មិកា សុនេត្តស្ស សត្ថុនោ ព្រហ្មលោកសហព្យតាយ ធម្មំ ទេសេន្តស្ស ចិត្តានិ ន បសាទេសុំ តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជឹសុ ។ យេ ខោ បន ព្រាហ្មណា ធម្មិកា សុនេត្តស្ស សត្ថុនោ ព្រហ្មលោកសហព្យតាយ ធម្មំ ទេសេន្តស្ស ចិត្តានិ បសាទេសុំ តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជឹសុ ។

ភូតបុព្វំ ព្រាហ្មណា ធម្មិកា មូគបក្ខោ នាម សត្ថា អហោសិ ។បេ។ អរនេមិ នាម សត្ថា អហោសិ កុទ្ទាលកោ នាម សត្ថា អហោសិ ហត្ថិបាលោ នាម សត្ថា អហោសិ ។បេ។ ជោតិបាលោ នាម សត្ថា អហោសិ តិត្ថករោ កាមេសុ វីតរាគោ ។



ម្នាលព្រាហ្មណ៍ធម្មិកៈ ពីព្រេងនាយមក មានគ្រូឈ្មោះសុនេត្ត ជាអ្នកធ្វើនូវកំពង់ជាទីឆ្លងគឺលទ្ធិ ប្រាសចាកសេចក្តីត្រេកត្រអាល ក្នុងកាមទាំងឡាយ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ គ្រូសុនេត្តមានសាវកច្រើនរយ ។ គ្រូសុនេត្តបានសំដែងធម៌ ដើម្បីប្រព្រឹត្តទៅកាន់ព្រហ្មលោក ដល់ពួកសាវក ។ ម្នាលព្រាហ្មណ៍ធម្មិកៈ បើពួកជនណា មិនញុំាងចិត្តឲ្យជ្រះថ្លា ដល់គ្រូសុនេត្ត កំពុងសំដែងធម៌ ដើម្បីប្រព្រឹត្តទៅកាន់ព្រហ្មលោកទេ លុះជនទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលព្រាហ្មណ៍ធម្មិកៈ ពួកជនណា ញុំាងចិត្តឲ្យជ្រះថ្លាដល់គ្រូសុនេត្ត ដែលកំពុងសំដែងធម៌ ដើម្បីប្រព្រឹត្តទៅកាន់ព្រហ្មលោក ។ លុះជនទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ នឹងបានទៅកើត ក្នុងសុគតិសួគ៌ទេវលោក ។

ម្នាលព្រាហ្មណ៍ធម្មិកៈ ពីព្រេងនាយមក មានគ្រូឈ្មោះមូគបក្ខ ។បេ។ មានគ្រូឈ្មោះអរនេមិ មានគ្រូឈ្មោះកុទ្ទាលកៈ មានគ្រូឈ្មោះហត្ថិបាល ។បេ។ មានគ្រូឈ្មោះជោតិបាល ជាអ្នកធ្វើនូវកំពង់ ជាទីឆ្លង គឺលទ្ធិ ប្រាសចាកសេចក្តីត្រេកត្រអាល ក្នុងកាមទាំងឡាយ ។

ជោតិបាលស្ស ខោ បន ព្រាហ្មណ ធម្មិក សត្ថុនោ អនេកានិ សាវកសតានិ អហេសុំ ។ ជោតិបាលោ សត្ថា សាវកានំ ព្រហ្មលោកសហព្យតាយ ធម្មំ ទេសេសិ ។ យេ ខោ បន ព្រាហ្មណ ធម្មិក ជោតិបាលស្ស សត្ថុនោ ព្រហ្មលោកសហព្យតាយ ធម្មំ ទេសេន្តស្ស ចិត្តានិ ន បសាទេសុំ តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជឹសុ ។ យេ ខោ បន ព្រាហ្មណ ធម្មិក ជោតិបាលស្ស សត្ថុនោ ព្រហ្មលោកសហព្យតាយ ធម្មំ ទេសេន្តស្ស ចិត្តានិ បសាទេសុំ តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជឹសុ ។ តំ កឹ មញ្ញសិ ព្រាហ្មណ ធម្មិក យោ ឥមេ ឆ សត្ថារេ តិត្ថករេ កាមេសុ វីតរាគេ អនេកសត-បរិវារេ សសាវកសង្ឃេ បទុដ្ឋចិត្តោ អក្កោសេយ្យ បរិភាសេយ្យ ពហុំ សោ អបុញ្ញំ បសវេយ្យាតិ ។ ឯវំ ភន្តេ ។ យោ ខោ ព្រាហ្មណ ធម្មិក



ម្នាលព្រាហ្មណ៍ធម្មិកៈ ឯគ្រូឈ្មោះជោតិបាល មានសាវកច្រើនរយ ។ គ្រូជោតិបាល សំដែងធម៌ ដើម្បីប្រព្រឹត្តទៅកាន់ព្រហ្មលោក ដល់ពួកសាវក ។ ម្នាលព្រាហ្មណ៍ធម្មិកៈ ពួកជនណា មិនបានញុំាងចិត្តឲ្យជ្រះថ្លាដល់គ្រូជោតិបាល ដែលកំពុងសំដែងធម៌ ដើម្បីប្រព្រឹត្តទៅកាន់ព្រហ្មលោកទេ លុះជនទាំងនោះ បែកធ្លាយនៃកាយស្លាប់ទៅ ក៏នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលព្រាហ្មណ៍ធម្មិកៈ ពួកជនណា ញុំាងចិត្តឲ្យជ្រះថ្លាដល់គ្រូជោតិបាល ដែលកំពុងសំដែងធម៌ ដើម្បីប្រព្រឹត្តទៅកាន់ព្រហ្មលោកហើយ លុះជនទាំងនោះ បែកធ្លាយនៃកាយស្លាប់ទៅ ក៏នឹងទៅកើត ក្នុងសុគតិសួគ៌ទេវលោក ។ ម្នាលព្រាហ្មណ៍ធម្មិកៈ អ្នកសំគាល់នូវហេតុនោះដូចម្តេច បុគ្គលណា មានចិត្តប្រទូស្ត ជេរប្រទេចគ្រូទាំង ៦ នេះ ដែលជាអ្នកធ្វើនូវកំពង់ជាទីចុះ ដែលប្រាសចាកសេចក្តីត្រេកត្រអាល ក្នុងកាមទាំងឡាយ មានពួកសាវកច្រើនរយ ជាបរិវារហើយ បុគ្គលនោះ គប្បីបាននូវបាបដ៏ច្រើនដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ បុគ្គលណា

ឥមេ ច សត្ថារេ(១) តិត្ថករេ កាមេសុ វីតរាគេ អនេកសតបរិវារេ សសាវកសង្ឃេ បទុដ្ឋចិត្តោ អក្កោសេយ្យ បរិភាសេយ្យ ពហុំ សោ អបុញ្ញំ បសវេយ្យ ។ យោ ឯកំ ទិដ្ឋិសម្បន្នំ បុគ្គលំ បទុដ្ឋចិត្តោ អក្កោសតិ បរិភាសតិ អយំ តតោ ពហុតរំ អបុញ្ញំ បសវតិ ។ តំ កិស្ស ហេតុ ។ នាហំ ព្រាហ្មណ ធម្មិក ឥតោ ពហិទ្ធា ឯវរូបំ ខន្តិំ(២) វទាមិ យថាមំ សព្រហ្មចារីសុ ។ តស្មាតិហ ព្រាហ្មណ ធម្មិក ឯវំ សិក្ខិតព្វំ ន នោ អាមសព្រហ្មចារីសុ ចិត្តានិ បទុដ្ឋានិ ភវិស្សន្តីតិ ។ ឯវំ ហិ តេ ព្រាហ្មណ ធម្មិក សិក្ខិតព្វន្តិ ។

សុនេត្តោ មូគបក្ខោ ច អរនេមិ ច ព្រាហ្មណោ
កុទ្ទាលកោ អហុ សត្ថា ហត្ថិបាលោ ច មាណវោ

១ ឱ. ម. ឆ សត្ថារេ ។ ២ ឱ. ម. ឯវរូបិំ ខន្តិំ ។



មានចិត្តប្រទូស្តជេរប្រទេចគ្រូទាំង ៦ នេះ ដែលជាអ្នកធ្វើនូវកំពង់ជាទីឆ្លង ប្រាសចាកសេចក្តីត្រេកត្រអាលក្នុងកាមទាំងឡាយ មានពួកសាវ័កច្រើនរយ ជាបរិវារ បុគ្គលនោះ គប្បីបាននូវបាបដ៏ច្រើន ។ បុគ្គលណា មានចិត្តប្រទូស្តជេរប្រទេចបុគ្គលម្នាក់ ដែលបរិបូណ៌ដោយទិដ្ឋិ បុគ្គលនេះ រមែងបាននូវបាបដ៏ច្រើនជាងបុគ្គលទាំងនោះ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ធម្មិកៈ (ព្រោះ) តថាគតមិនសរសើរនូវការអត់រំលើងនូវគុណ មានសភាពដូច្នោះ ខាងក្រៅអំពីសាសនានេះ ដូចជាការជេរប្រទេចនេះ ក្នុងសព្រហ្មចារីបុគ្គលទាំងឡាយទេ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា ចិត្តដែលប្រទូស្ត ក្នុងពួកសព្រហ្មចារីបុគ្គលរបស់ខ្លួន នឹងមិនមានដល់យើងឡើយ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ អ្នកគប្បីសិក្សាយ៉ាងនេះចុះ ។

ក្នុងកាលកន្លងទៅហើយ មានគ្រូទាំង ៦ គឺ គ្រូឈ្មោះ
សុនេត្ត១ ឈ្មោះមូគបក្ខៈ១ ឈ្មោះអរនេមិ១ ព្រាហ្មណ៍
ឈ្មោះកុទ្ទាលកៈ ១ មាណព ឈ្មោះហត្ថិបាល ១

ជោតិបាលោ ច គោវិន្ទោ អហុ សត្ត បុរោហិតោ ។
អហិំសកា(១) អតីតំសេ ឆ សត្ថារោ យសស្សិនោ
និរាមគន្ធា ករុណេ វិមុត្តា កាមសញ្ញោជនាតិគា
កាមរាគំ វិរាជេត្វា ព្រហ្មលោកូបគា អហុ ។
អហេសុំ សាវកា តេសំ អនេកានិ សតានិបិ
និរាមគន្ធា ករុណេ វិមុត្តា កាមសញ្ញោជនាតិគា
កាមរាគំ វិរាជេត្វា ព្រហ្មលោកូបគា អហុ ។
យោ តេ ឥសី ពាហិរកេ វីតរាគេ សមាហិតេ
បទុដ្ឋមនសង្កប្បោ យោ នរោ បរិភាសតិ
ពហុញ្ច សោ បសវតិ អបុញ្ញំ តាទិសោ នរោ ។
យោ ចេតំ ទិដ្ឋិសម្បន្នំ ភិក្ខុំ ពុទ្ធស្ស សាវកំ
បទុដ្ឋមនសង្កប្បោ យោ នរោ បរិភាសតិ
អយំ តតោ ពហុតរំ អបុញ្ញំ បសវេ នរោ ។

១ ឱ. ម. អហិំសកា ។



គោវិន្ទព្រាហ្មណ៍ ឈ្មោះជោតិបាល ជាបុរោហិត នៃស្តេចទាំងប្រាំពីរ ១ ជាអ្នកមិនបៀតបៀន (អ្នកដទៃ) ជាអ្នកមានយស មិនមានក្លិនស្អុយ គឺក្រោធ មានចិត្តរួច គឺសេចក្តីករុណា កន្លងបង់នូវកាមសំយោជនៈ លះបង់នូវកាមរាគ ជាអ្នកចូលទៅកាន់ព្រហ្មលោក ។ ពួកសាវកជាច្រើនរយរបស់គ្រូទាំងនោះ ក៏មិនមានក្លិនស្អុយ មានចិត្តរួចផុត គឺសេចក្តីករុណា កន្លងបង់នូវកាមសញ្ញោជនៈ លះបង់នូវកាមរាគ ចូលទៅកាន់ព្រហ្មលោកដែរ ។ ជនណាមានចិត្តត្រិះរិះ ដើម្បីប្រទូស្ត ជេរប្រទេចពួកឥសីជាខាងក្រៅទាំងនោះ ដែលប្រាសចាកតម្រេក មានចិត្តតាំងខ្ជាប់ ជនបែបនោះ រមែងបាននូវបាបច្រើន ។ មួយទៀត ជនណាមានចិត្តត្រិះរិះ ដើម្បីប្រទូស្ត ជេរប្រទេច ភិក្ខុ ១ រូប ដែលបរិបូណ៌ ដោយទិដ្ឋិ ជាសាវករបស់ព្រះពុទ្ធ ជននេះ រមែងបាននូវបាបច្រើន ជាងជនដែលប្រទូស្តគ្រូទាំង ៦ នោះ ។

ន សាធុរូបំ អាសីទេ និដ្ឋិដ្ឋាឧប្បាទយិជំ ។
សត្តមោ បុគ្គលោ ឯសោ អរិយសង្ឃស្ស វុច្ចតិ
អវីតរាគោ កាមេសុ យស្ស បញ្ចិន្ទ្រិយា មុទូ
សទ្ធា សតិ ច វិរិយំ សមថោ ច វិបស្សនា
តាទិសំ ភិក្ខុំ អាសជ្ជ បុព្វេ ឧបហញ្ញតិ
អត្តានំ ឧបហន្ត្វាន បច្ឆា អញ្ញំ វិហឹសតិ ។
យោ ច រក្ខតិ អត្តានំ រក្ខិតោ តស្ស ពាហិរោ
តស្មា រក្ខេយ្យ អត្តានំ អក្ខតោ(១) បណ្ឌិតោ សទាតិ ។

ធម្មិកវគ្គោ បញ្ចមោ ។

## តស្សុទ្ទានំ

នាគមិគសាលា ឥណំ
ចុន្ទ ទ្វេ ច សន្ទិដ្ឋិកា
ខេមឥន្ទ្រិយា អានន្ទ
ខត្តិយា អប្បមាទេន ធម្មិកោតិ ។

បឋមបណ្ណាសកោ និដ្ឋិតោ ។

១ ម. អក្ខោ ។



តាំងមិនទាន់ជួបនូវបុគ្គលមានសភាពល្អ ជាអ្នកលះបង់នូវហេតុជាទីតាំងនៃទុក្ខ ។ បុគ្គលណាមានឥន្ទ្រិយទាំង ៥ គឺសទ្ធា ១ សតិ ១ វិរិយៈ ១ សមថៈ ១ វិបស្សនា ១ បុគ្គលនុ៎ះជាគំរប់ ៧ របស់អរិយសង្ឃ ហៅថា មិនទាន់ប្រាសចាកតម្រេក ក្នុងកាមទាំងឡាយ បុគ្គលនោះ ប្រទូស្តនូវភិក្ខុបែបនោះ ឈ្មោះថា បៀតបៀននូវខ្លួនមុន លុះបៀតបៀនខ្លួនហើយ ទើបបៀតបៀនបុគ្គលដទៃជាខាងក្រោយ ។ បុគ្គលណារក្សាខ្លួន បុគ្គលនោះ ឈ្មោះថា រក្សាហេតុខាងក្រៅ ព្រោះហេតុនោះ បណ្ឌិតដែលមិនមានសេចក្តីក្រោធ គប្បីរក្សាខ្លួនសព្វៗកាល ។

ចប់ ធម្មិកវគ្គទី ៥ ។

## ឧទ្ទាននៃធម្មិកវគ្គនោះ គឺ

និយាយអំពីនាគ ១ អំពីឧបាសិកាឈ្មោះមិគសាលា ១ អំពីបំណុល ១ អំពីមហាចុន្ទដ៏មានអាយុ ១ អំពីសន្ទិដ្ឋិកធម៌ ២ លើក អំពីព្រះខេមៈ ១ អំពីឥន្ទ្រិយ ១ អំពីព្រះអានន្ទ ១ អំពីពួកក្សត្រ ១ អំពីអប្បមាទធម៌ ១ អំពីធម្មិកត្ថេរ ១

ចប់ បឋមបណ្ណាសក ។

## ទុតិយបណ្ណាសកោ

## មហាវគ្គោ

(៥៥) ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ តេន ខោ បន សមយេន អាយស្មា សោណោ រាជគហេ វិហរតិ សីតវនេ ។

អថខោ អាយស្មតោ សោណស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ យេ ខោ កេចិ ភគវតោ សាវកា អារទ្ធវិរិយា វិហរន្តិ អហំ តេសំ អញ្ញតរោ អថ ច បន មេ ន អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចតិ សំវិជ្ជន្តិ ខោ បន មេ កុលេ ភោគា សក្កា ភោគេ ច ភុញ្ជិតុំ បុញ្ញានិ ច កាតុំ យន្នូនាហំ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិត្វា ភោគេ ច ភុញ្ជេយ្យំ បុញ្ញានិ ច ករេយ្យន្តិ ។ អថខោ ភគវា អាយស្មតោ សោណស្ស ចេតសា ចេតោ បរិវិតក្កមញ្ញាយ

## ទុតិយបណ្ណាសក

## មហាវគ្គ

(៥៥) សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះសោណៈដ៏មានអាយុ គង់នៅនាព្រៃសីតវ័ន ជិតក្រុងរាជគ្រឹះដែរ ។

លំដាប់នោះ ព្រះសោណៈដ៏មានអាយុ សម្ងំនៅក្នុងទីស្ងាត់ មានសេចក្តីត្រិះរិះក្នុងចិត្តកើតឡើងយ៉ាងនេះថា ពួកភិក្ខុណាមួយ ជាសាវករបស់ព្រះដ៏មានព្រះភាគ ជាអ្នកមានព្យាយាមដ៏ខ្លាំង បណ្តាភិក្ខុទាំងនោះ អញក៏រាប់ថា ជាសាវកដែលមានព្យាយាម ដ៏ខ្លាំងមួយដែរ តែថា ទុកជាដូច្នោះ ចិត្តរបស់អញ ក៏មិនរួចស្រឡះចាកអាសវៈ ព្រោះមិនប្រកាន់មាំបានឡើយ ហើយ ភោគសម្បត្តិក្នុងត្រកូលរបស់អញ ក៏មានគ្រប់គ្រាន់ អញក៏អាចប្រើប្រាស់ភោគសម្បត្តិ និងធ្វើនូវបុណ្យទាំងឡាយបានដែរ បើដូច្នោះគួរតែ អញលាខ្លួនសិក្ខា វិលត្រឡប់មកកាន់ហីនភេទ ប្រើប្រាស់នូវភោគសម្បត្តិ និងធ្វើបុណ្យទាំងឡាយវិញ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ បានជ្រាបច្បាស់នូវសេចក្តីត្រិះរិះក្នុងចិត្ត របស់ព្រះសោណៈដ៏មានអាយុ ដោយព្រះហឫទ័យព្រះអង្គ

សេយ្យថាបិ នាម ពលវា បុរិសោ សមិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សមិញ្ជេយ្យ ឯវមេវ ខោ គិជ្ឈកូដេ បព្វតេ អន្តរហិតោ សីតវនេ អាយស្មតោ សោណស្ស សម្មុខេ បាតុរហោសិ ។ និសីទិ ភគវា បញ្ញត្តេ អាសនេ ។ អាយស្មាបិ ខោ សោណោ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ សោណំ ភគវា ឯតទវោច ននុ តេ សោណ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ យេ ខោ កេចិ ភគវតោ សាវកា អារទ្ធវិរិយា វិហរន្តិ អហំ តេសំ អញ្ញតរោ អថ ច បន មេ ន អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចតិ សំវិជ្ជន្តិ ខោ បន មេ កុលេ ភោគា សក្កា ភោគេ ច ភុញ្ជិតុំ បុញ្ញានិ ច កាតុំ យន្នូនាហំ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិត្វា ភោគេ ច ភុញ្ជេយ្យំ បុញ្ញានិ ច ករេយ្យន្តិ ។



ក៏ស្រាប់តែបាត់ អំពីភ្នំគិជ្ឈកូដ មកប្រាកដ ក្នុងទីចំពោះមុខ នៃព្រះសោណៈដ៏មានអាយុ នាព្រៃសីតវន ដូចបុរសមានកំឡាំង លាតចេញនូវដៃដែលបត់ចូល ឬ បត់ចូលនូវដៃដែលលាតចេញ ។ ព្រះដ៏មានព្រះភាគ ទ្រង់គង់លើពុទ្ធាសនៈដែលគេក្រាលថ្វាយ ។ ឯព្រះសោណៈដ៏មានអាយុ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះសោណៈដ៏មានអាយុ គង់នៅក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគ ក៏ត្រាស់សួរយ៉ាងនេះថា នែសោណៈ ក្រែងអ្នកសម្ងំនៅ ក្នុងទីស្ងាត់ មានសេចក្តីត្រិះរិះក្នុងចិត្តកើតឡើងយ៉ាងនេះថា ពួកភិក្ខុណាមួយជាសាវករបស់ព្រះដ៏មានព្រះភាគ ជាអ្នកមានព្យាយាមតឹងតែង បណ្តាភិក្ខុទាំងនោះអញក៏រាប់ជា ជាសាវកដែលមានព្យាយាមតឹងតែង មួយដែរ តែបើទុកជាដូច្នោះ ចិត្តរបស់អញ ក៏មិនរួចស្រឡះចាកអាសវៈ ព្រោះមិនប្រកាន់មាំធួនឡើយ ណ្ហើយ ភោគសម្បត្តិក្នុងត្រកូលរបស់អញ ក៏មានគ្រប់គ្រាន់អញក៏អាចប្រើប្រាស់ភោគសម្បត្តិផង ធ្វើបុណ្យទាំងឡាយបានផង បើដូច្នោះ គួរតែអញលាចាកសិក្ខាវិលត្រឡប់មកកាន់ហីនភេទវិញ ហើយគប្បីប្រើប្រាស់នូវភោគសម្បត្តិផង ធ្វើនូវបុណ្យទាំងឡាយផង ដូច្នេះមែនឬ ។

ឯវំ ភន្តេ ។ តំ កឹ មញ្ញសិ សោណ កុសលោ ត្វំ បុព្វេ អាគារិកភូតោ វីណាយ តន្តិស្សរេតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញសិ សោណ យទា ច តេ វីណាយ តន្តិយោ អច្ចាយតា ហោន្តិ អបិនុ តេ វីណា តស្មឹ សមយេ សរវតី វា ហោតិ កម្មញ្ញា វាតិ ។ នោ ហេតំ ភន្តេ ។ តំ កឹ មញ្ញសិ សោណ យទា តេ វីណាយ តន្តិយោ អតិសិថិលា ហោន្តិ អបិនុ តេ វីណា តស្មឹ សមយេ សរវតី វា ហោតិ កម្មញ្ញា វាតិ ។ នោ ហេតំ ភន្តេ ។ យទា បន តេ សោណ វីណាយ តន្តិយោ ន អច្ចាយតា ហោន្តិ ន អតិសិថិលា សមេ គុណេ បតិដ្ឋិតា អបិនុ តេ វីណា តស្មឹ សមយេ សរវតី វា ហោតិ កម្មញ្ញា វាតិ ។ ឯវំ ភន្តេ ។ ឯវមេវ ខោ សោណ អច្ចារទ្ធំ វីរិយំ ឧទ្ធច្ចាយ សំវត្តតិ អតិលីនំ វីរិយំ(១) កោសជ្ជាយ សំវត្តតិ តស្មាតិហ ត្វំ សោណ វីរិយសមតំ អធិដ្ឋាហិ

១ ម. អតិសិថិលំ វីរិយំ ។



ព្រះសោណៈដ៏មានអាយុ ក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា នែសោណៈ អ្នកយល់នូវសេចក្តីនោះថា ដូចម្តេច ខ្លួនអ្នកកាលនៅជាគ្រហស្ថអំពីដើម ជាអ្នកឈ្លាសវៃក្នុងការដេញខ្សែពិណដែរឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលសោណៈ អ្នកយល់នូវសេចក្តីនោះថាដូចម្តេច សម័យណា ខ្សែពិណរបស់អ្នកតឹងពេក សម័យនោះ តើពិណរបស់អ្នក មានសំឡេងពីរោះ ឬគួរដល់ការដេញដែរឬ ។ មិនដូច្នោះទេព្រះអង្គ ។ ម្នាលសោណៈ អ្នកយល់នូវសេចក្តីនោះថាដូចម្តេច សម័យណា ខ្សែពិណរបស់អ្នកធូរពេក សម័យនោះ តើពិណរបស់អ្នក មានសំឡេងពីរោះ ឬ គួរដល់ការដេញដែរឬ ។ មិនដូច្នោះទេព្រះអង្គ ។ ម្នាលសោណៈ មួយទៀត សម័យណា ខ្សែពិណរបស់អ្នក មិនតឹងពេក មិនធូរពេកទេ តាំងនៅក្នុងគុណដ៏ស្មើល្មម គឺសំឡេងជាកណ្តាល សម័យនោះ តើពិណរបស់អ្នកមានសំឡេងពីរោះ ឬគួរដល់ការដេញដែរឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលសោណៈ ព្យាយាមដែលតឹងពេក រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីអណ្តែតអណ្តូងនៃចិត្ត ព្យាយាមដែលធូរពេក រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីខ្ជិលច្រអូស ក៏យ៉ាងនោះដែរ ម្នាលសោណៈ ព្រោះហេតុនោះ អ្នកចូរតាំងសេចក្តីព្យាយាមឲ្យស្មើល្មមផង(១)

១ ពាក្យនេះ ព្រះសម្ពុទ្ធទ្រង់ត្រាស់ដាស់តឿនព្រះសោណត្ថេរ ឲ្យតាំងសេចក្តីព្យាយាម ដំណើរសមចំពោះកុំឲ្យតឹងពេកធូរពេក ។ អដ្ឋកថា ។

ឥន្ទ្រិយានញ្ច សមតំ បដិវិជ្ឈ តត្ថ ច និមិត្តំ គណ្ហាហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា សោណោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា អាយស្មន្តំ សោណំ ឥមិនា ឱវាទេន ឱវទិត្វា សេយ្យថាបិ នាម ពលវា បុរិសោ សមិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សមិញ្ជេយ្យ ឯវមេវ ខោ សីតវនេ អន្តរហិតោ គិជ្ឈកូដេ បព្វតេ បាតុរហោសិ ។

អថខោ អាយស្មា សោណោ អបរេន សមយេន វីរិយសមតំ អធិដ្ឋាសិ ឥន្ទ្រិយានញ្ច សមតំ បដិវិជ្ឈិ តត្ថ ច និមិត្តំ អគ្គហេសិ ។ អថខោ អាយស្មា សោណោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ន ចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ



ចូរតាំងនូវឥន្ទ្រិយទាំងឡាយ (មានសទ្ធិន្ទ្រិយជាដើម) ឲ្យស្មើគ្នាផង ចូរកាន់យកនូវនិមិត្ត ក្នុងសេចក្តីព្យាយាមនិងឥន្ទ្រិយដែលស្មើល្មមនោះផង ។ ព្រះសោណៈដ៏មានអាយុ ក៏ទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ លុះព្រះដ៏មានព្រះភាគ ទ្រង់ទូន្មានព្រះសោណៈដ៏មានអាយុ ដោយឱវាទនេះហើយ ក៏ស្រាប់តែបាត់អំពីព្រៃសីតវ័ន ទៅប្រាកដលើភ្នំគិជ្ឈកូដ ដូចជាបុរសដ៏មានកំឡាំង លាចេញនូវដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។ គ្រាសម័យជាខាងក្រោយមក ព្រះសោណៈដ៏មានអាយុ ក៏បានតាំងនូវសេចក្តីព្យាយាមឲ្យស្មើល្មមផង តាំងនូវឥន្ទ្រិយទាំងឡាយឲ្យស្មើគ្នាផង បានកាន់យកនូវនិមិត្ត(១) ក្នុងសេចក្តីព្យាយាមនិងឥន្ទ្រិយដែលស្មើល្មមនោះផង ។ លំដាប់នោះ ព្រះសោណៈដ៏មានអាយុ គេចចេញចាកពួកទៅនៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានព្យាយាមដុតបំផ្លាញ (នូវកិលេស) មានចិត្តបញ្ជូនទៅ (កាន់ព្រះនិព្វាន) ពួកកុលបុត្តដែលចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា

(១) សំដៅយកលក្ខណនិមិត្ត និងវិបស្សនានិមិត្ត ។ អដ្ឋកថា ។

តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បន អាយស្មា សោណោ អរហតំ អហោសិ ។ អថខោ អាយស្មតោ សោណស្ស អរហត្តប្បត្តស្ស ឯតទហោសិ យន្នូនាហំ យេន ភគវា តេនុបសង្កមេយ្យំ ឧបសង្កមិត្វា ភគវតោ សន្តិកេ អញ្ញំ ព្យាករេយ្យន្តិ ។ អថខោ អាយស្មា សោណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សោណោ ភគវន្តំ ឯតទវោច យោ សោ ភន្តេ ភិក្ខុ អរហំ ខីណា-សវោ វុសិតវា កតករណីយោ ឱហិតភារោ



មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវអនុត្តរធម៌ ដែលមានព្រហ្មចរិយៈជាទីបំផុតនោះ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ហើយបានដឹងច្បាស់ថា ជាតិ (របស់អញ) អស់ហើយ ព្រហ្មចរិយធម៌ អញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ។ មានសេចក្ដីសរសើរថា បណ្ដាពួកព្រះអរហន្តទាំងឡាយ ព្រះសោណៈដ៏មានអាយុ ក៏បានជាអរហន្តមួយអង្គ ។ លំដាប់នោះ ព្រះសោណៈដ៏មានអាយុ កាលបានសម្រេចព្រះអរហត្តហើយ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអញចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ គួរក្រាបទូលនូវអរហត្តផល ក្នុងសំណាក់ព្រះដ៏មានព្រះភាគ ។ គ្រានោះឯង ព្រះសោណៈដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះព្រះសោណៈដ៏មានអាយុ គង់ក្នុងទីដ៏សមគួរស្រេចហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណា ជាអរហន្តខីណាស្រព បានប្រព្រឹត្តព្រហ្មចរិយធម៌រួចហើយ បានធ្វើសោឡសកិច្ចស្រេចហើយ បានដាក់ភារៈចុះហើយ

អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញា
វិមុត្តោ សោ ឆដ្ឋានានិ អធិមុត្តោ ហោតិ នេក្ខម្មាធិ-
មុត្តោ ហោតិ បវិវេកាធិមុត្តោ ហោតិ អព្យាបជ្ឈាធិ-
មុត្តោ ហោតិ តណ្ហក្ខយាធិមុត្តោ ហោតិ ឧបាទា-
នក្ខយាធិមុត្តោ ហោតិ អសម្មោហាធិមុត្តោ ហោតិ ។
សិយា ខោ បន ភន្តេ ឥធេកច្ចស្ស អាយស្មតោ
ឯវមស្ស កេវលំ សទ្ធាមត្តកំ នូន អយមាយស្មា
និស្សាយ នេក្ខម្មាធិមុត្តោតិ ។ ន ខោ បនេតំ
ភន្តេ ឯវំ ទដ្ឋព្វំ ។ ខីណាសវោ ភន្តេ ភិក្ខុ
វុសិតវា កតករណីយោ ករណីយំ អត្តនោ
អសមនុបស្សន្តោ កតស្ស វា បតិចយំ ខយា រាគស្ស
វីតរាគត្តា នេក្ខម្មាធិមុត្តោ ហោតិ ខយា ទោសស្ស
វីតទោសត្តា នេក្ខម្មាធិមុត្តោ ហោតិ ខយា
មោហស្ស វីតមោហត្តា នេក្ខម្មាធិមុត្តោ ហោតិ ។



មានប្រយោជន៍នៃខ្លួនសម្រេចហើយ មានកិលេសជាគ្រឿងប្រកបក្នុងភពអស់ហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះ ជាអ្នកមានចិត្តចុះស៊ប់កាន់ឋានៈ ៦ យ៉ាង គឺមានចិត្តចុះស៊ប់ ក្នុងនេក្ខម្ម (ការចេញចាកកាម) ១ ចុះស៊ប់ ក្នុងបវិវេក (ទីស្ងប់ស្ងាត់ចាកកិលេស) ១ ចុះស៊ប់ ក្នុងសេចក្តីមិនមានព្យាបាទ ១ ចុះស៊ប់ ក្នុងធម៌ជាទីអស់ទៅនៃតណ្ហា ១ ចុះស៊ប់ ក្នុងធម៌ជាទីអស់ទៅនៃឧបាទាន ១ ចុះស៊ប់ ក្នុងធម៌មិនមានសេចក្តីវង្វេង ១ ។ បពិត្រព្រះអង្គដ៏ចំរើន ពេលខ្លះ ក្នុងសាសនានេះ មានសេចក្តីត្រិះរិះយ៉ាងនេះថា លោកនេះ មានចិត្តចុះស៊ប់ ក្នុងនេក្ខម្មៈ ព្រោះអាស្រ័យនូវគុណធម៌ ត្រឹមតែសទ្ធាប៉ុណ្ណោះដោយពិត ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុនុ៎ះ បុគ្គលមិនត្រូវយល់ឃើញយ៉ាងនេះឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុជាខីណាស្រព បានប្រព្រឹត្តព្រហ្មចរិយធម៌ចប់ហើយ បានធ្វើសោឡសកិច្ចស្រេចហើយ បើទុកជាមិនបានពិចារណានូវសោ-ឡសកិច្ចរបស់ខ្លួន ឬការសន្សំរបស់ខ្លួនដែលបានធ្វើហើយទេ ក៏គង់មានចិត្តចុះស៊ប់ ក្នុងនេក្ខម្មៈ ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈ ក៏គង់មានចិត្តចុះស៊ប់ ក្នុងនេក្ខម្មៈ ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈ ក៏គង់មានចិត្តចុះស៊ប់ ក្នុងនេក្ខម្មៈ ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈ ។

សិយា នោ បន ភន្តេ ឯកច្ចស្ស អាយស្មតោ ថេរស្ស លាភសក្ការសិលោកំ ឱទ អយមាយស្មា និកាមយមានោ បរិយាទិន្នចិត្តោ(១) ។ ន ខោ បនេតំ ភន្តេ ឯវំ ទដ្ឋព្វំ ។ ខីណាសវោ ភន្តេ ភិក្ខុ វុសិតវា កតករណីយោ ករណីយំ អត្តនោ អសមនុ-បស្សន្តោ កតស្ស វា បតិចយំ ខយា រាគស្ស វីតរាគត្តា បរិយាទិន្នចិត្តោ ហោតិ ខយា ទោសស្ស វីតទោសត្តា បរិយាទិន្នចិត្តោ ហោតិ ខយា មោហស្ស វីតមោហត្តា បរិយាទិន្នចិត្តោ ហោតិ ។ សិយា នោ បន ភន្តេ ឯកច្ចស្ស អាយស្មតោ ថេរស្ស សីលព្វតបរាមាសំ ឱទ អយមាយស្មា សារតោ បច្ចាគច្ឆន្តោ អត្រូបញ្ញាចិត្តោតិ ។

---

● ម. បរិយាទិន្នចិត្តោ ហោតិ ។



បពិត្រព្រះអង្គដ៏ចំរើន លោកខ្លះ ក្នុងសាសនានេះ មានសេចក្តីត្រិះរិះយ៉ាងនេះថា លោកនេះ កាលប្រាថ្នាលាភសក្ការៈនិងសេចក្តីសរសើរហើយ ក៏គង់មានចិត្តចុះស៊ប់ ក្នុងសេចក្តីស្ងប់ស្ងាត់ ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុនុ៎ះ បុគ្គលមិនត្រូវយល់ឃើញយ៉ាងនេះឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុជាខីណាស្រព បានប្រព្រឹត្តព្រហ្មចរិយធម៌ចប់ហើយ បានធ្វើសោឡសកិច្ចស្រេចហើយ ទើបរកជាមិនបាន គិតរកការធ្វើសោឡសកិច្ចរបស់ខ្លួន ឬក្លាសន្សំរបស់ខ្លួនដែលបានធ្វើហើយទេ ក៏គង់មានចិត្តចុះស៊ប់ ក្នុងសេចក្តីស្ងប់ស្ងាត់ ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈ ក៏គង់មានចិត្តចុះស៊ប់ ក្នុងសេចក្តីស្ងប់ស្ងាត់ ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈ ក៏គង់មានចិត្តចុះស៊ប់ ក្នុងសេចក្តីស្ងប់ស្ងាត់ ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈ ។ បពិត្រព្រះអង្គដ៏ចំរើន លោកខ្លះ ក្នុងសាសនានេះ មានសេចក្តីត្រិះរិះយ៉ាងនេះថា លោកនេះ កាលត្រឡប់មកកាន់សីលព្វតបរាមាសៈ ថាជាធម៌មានខ្លឹមក៏ដោយ ក៏គង់ជាអ្នកមានចិត្តចុះស៊ប់ ក្នុងការមិនព្យាបាទ ។

ន ខោ បនេតំ ភន្តេ ឯវំ ទដ្ឋព្វំ ។ ខីណាសវោ ភន្តេ ភិក្ខុ វុសិតវា កតករណីយោ ករណីយំ អត្តនោ អសមនុបស្សន្តោ កតស្ស វា បតិចយំ ខយា រាគស្ស វីតរាគត្តា អព្យាបជ្ឈាធិមុត្តោ ហោតិ ខយា ទោសស្ស វីតទោសត្តា អព្យាបជ្ឈាធិមុត្តោ ហោតិ ខយា មោហស្ស វីតមោហត្តា អព្យាបជ្ឈាធិមុត្តោ ហោតិ ។ បេ ។ ខយា រាគស្ស វីតរាគត្តា តណ្ហាក្ខយាធិមុត្តោ ហោតិ ខយា ទោសស្ស វីតទោសត្តា តណ្ហាក្ខយា-ធិមុត្តោ ហោតិ ខយា មោហស្ស វីតមោហត្តា តណ្ហាក្ខយាធិមុត្តោ ហោតិ ខយា រាគស្ស វីតរាគត្តា ឧបាទានក្ខយាធិមុត្តោ ហោតិ ខយា ទោសស្ស វីតទោសត្តា ឧបាទានក្ខយាធិមុត្តោ ហោតិ ខយា មោហស្ស វីតមោហត្តា ឧបាទានក្ខយាធិមុត្តោ ហោតិ ខយា រាគស្ស វីតរាគត្តា អសម្មោហាធិមុត្តោ ហោតិ



បពិត្រព្រះអង្គដ៏ចំរើន ហេតុនុ៎ះ បុគ្គលមិនគួរយល់ឃើញយ៉ាងនេះឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុជាខីណាស្រព បានប្រព្រឹត្តព្រហ្មចរិយធម៌ចប់ហើយ បានធ្វើសោឡសកិច្ចស្រេចហើយ រមែងជាមិនបានពិចារណាឃើញសោឡសកិច្ចរបស់ខ្លួន ឬក៏ការសន្សំរបស់ខ្លួនដែលបានធ្វើហើយទេ ក៏តែងមានចិត្តចុះស៊ប់ ក្នុងការមិនព្យាបាទ ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈ ក៏តែងមានចិត្តចុះស៊ប់ ក្នុងការមិនព្យាបាទ ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈ ក៏តែងមានចិត្តចុះស៊ប់ ក្នុងការមិនព្យាបាទ ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈ ។ បេ ។ ក៏តែងមានចិត្តចុះស៊ប់ ក្នុងធម៌ជាទីអស់ទៅនៃតណ្ហា ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈ ក៏តែងមានចិត្តចុះស៊ប់ ក្នុងធម៌ជាទីអស់ទៅនៃតណ្ហា ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈ ក៏តែងមានចិត្តចុះស៊ប់ ក្នុងធម៌ជាទីអស់ទៅនៃតណ្ហា ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈ ក៏តែងមានចិត្តចុះស៊ប់ ក្នុងធម៌ជាទីអស់ទៅនៃឧបាទាន ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈ ក៏តែងមានចិត្តចុះស៊ប់ ក្នុងធម៌ជាទីអស់ទៅនៃឧបាទាន ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈ ក៏តែងមានចិត្តចុះស៊ប់ ក្នុងធម៌ជាទីអស់ទៅនៃឧបាទាន ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈ ក៏តែងមានចិត្តចុះស៊ប់ ក្នុងការមិនវង្វេង ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈ

ខយា ទោសស្ស វីតទោសត្តា អសម្មោហាធិមុត្តោ ហោតិ ខយា មោហស្ស វីតមោហត្តា អសម្មោហាធិមុត្តោ ហោតិ ។ ឯវំ សម្មាវិមុត្តចិត្តស្ស ភន្តេ ភិក្ខុនោ ភុសា ចេបិ ចក្ខុវិញ្ញេយ្យា រូបា ចក្ខុស្ស អាបាថំ អាគច្ឆន្តិ នេវស្ស ចិត្តំ បរិយាទិយន្តិ អមិស្សីកតមេវស្ស ចិត្តំ ហោតិ ឋិតំ អានេញ្ជប្បត្តំ វយញ្ចស្សានុបស្សតិ ។ ភុសា ចេបិ សោតវិញ្ញេយ្យា សទ្ទា ។បេ។ ឃានវិញ្ញេយ្យា គន្ធា ជិវ្ហាវិញ្ញេយ្យា រសា កាយវិញ្ញេយ្យា ផោដ្ឋព្វា មនោវិញ្ញេយ្យា ធម្មា មនស្ស អាបាថំ អាគច្ឆន្តិ នេវស្ស ចិត្តំ បរិយាទិយន្តិ អមិស្សីកតមេវស្ស ចិត្តំ ហោតិ ឋិតំ អានេញ្ជប្បត្តំ វយញ្ចស្សានុបស្សតិ ។



ក៏និងមានចិត្តចុះស៊ប់ ក្នុងការមិនវង្វេង ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈ ក៏និងមានចិត្តចុះស៊ប់ ក្នុងការមិនវង្វេង ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈ ។ បពិត្រព្រះអង្គដ៏ចំរើន កាលបើភិក្ខុ មានចិត្តផុតស្រឡះដោយប្រពៃ យ៉ាងនេះហើយ ទោះបើ រូបារម្មណ៍ យ៉ាងខ្លាំង ដែលគប្បីដឹងដោយភ្នែក មកកាន់ផ្លូវនៃចក្ខុទ្វារ ក៏គ្របសង្កត់ចិត្តរបស់ភិក្ខុនោះមិនបាន ចិត្តរបស់លោក ក៏មិនបានច្រឡំដោយអារម្មណ៍ ជាចិត្តនឹងនឹង ដល់នូវការមិនរំភើប ទាំងលោកក៏ពិចារណា ឃើញនូវការកើតឡើង និងរលត់ទៅនៃចិត្តនោះ ។ ទោះបើ សទ្ទារម្មណ៍ យ៉ាងខ្លាំង ដែលគប្បីដឹងដោយត្រចៀក ។បេ។ គន្ធារម្មណ៍ ដែលគប្បីដឹងដោយច្រមុះ រសារម្មណ៍ ដែលគប្បីដឹងដោយអណ្តាត ផោដ្ឋព្វារម្មណ៍ ដែលគប្បីដឹងដោយកាយ ធម្មារម្មណ៍ ដែលគប្បីដឹងដោយចិត្ត មកកាន់ផ្លូវនៃមនោទ្វារ ក៏គ្របសង្កត់ចិត្តរបស់ភិក្ខុនោះមិនបាន ចិត្តរបស់លោក មិនបានច្រឡំដោយអារម្មណ៍ ជាចិត្តនឹងនឹង ដល់នូវការមិនរំភើប ទាំងលោកក៏ឃើញនូវការកើតឡើង និងការរលត់ទៅនៃចិត្តនោះ ។

សេយ្យថាបិ ភន្តេ សេលោ បព្វតោ អច្ឆិទ្ទោ អសុសិរោ ឯកគ្ឃនោ អថ បុរត្ថិមាយ ចេបិ ទិសាយ អាគច្ឆេយ្យ ភុសា វាតវុដ្ឋិ នេវ នំ សង្កម្បេយ្យ ន សម្បកម្បេយ្យ ន សម្បវេធេយ្យ អថ បច្ឆិមាយ ចេបិ ទិសាយ អាគច្ឆេយ្យ ភុសា វាតវុដ្ឋិ ។បេ។ អថ ឧត្តរាយ ចេបិ ទិសាយ អាគច្ឆេយ្យ ភុសា វាតវុដ្ឋិ អថ ទក្ខិណាយ ចេបិ ទិសាយ អាគច្ឆេយ្យ ភុសា វាតវុដ្ឋិ នេវ នំ សង្កម្បេយ្យ ន សម្បកម្បេយ្យ ន សម្បវេធេយ្យ ឯវមេវ ខោ ភន្តេ ឯវំ សម្មាវិមុត្តចិត្តស្ស ភិក្ខុនោ ភុសា ចេបិ ចក្ខុវិញ្ញេយ្យា រូបា ចក្ខុស្ស អាបាថំ អាគច្ឆន្តិ នេវស្ស ចិត្តំ បរិយាទិយន្តិ អមិស្សីកតមេវស្ស ចិត្តំ ហោតិ ឋិតំ អានេញ្ជប្បត្តំ វយញ្ចស្សានុបស្សតិ ភុសា ចេបិ សោតវិញ្ញេយ្យា សទ្ទា ។បេ។ ឃានវិញ្ញេយ្យា គន្ធា ជិវ្ហាវិញ្ញេយ្យា រសា កាយវិញ្ញេយ្យា ផោដ្ឋព្វា មនោវិញ្ញេយ្យា ធម្មា មនស្ស អាបាថំ អាគច្ឆន្តិ



បពិត្រព្រះអង្គដ៏ចំរើន ភ្នំថ្មមិនមានធ្លុះ មិនមានប្រហោង ជាភ្នំតាន់ស៊ុប ទោះបើ គំនរខ្យល់ធំផងទឹក បក់បោកមកពីទិសខាងកើតក្តី ក៏ធ្វើភ្នំនោះឲ្យញាប់មិនបាន ឲ្យកម្រើកមិនបាន ឲ្យញាប់ញ័រមិនបាន ទោះបើ គំនរខ្យល់ធំផងទឹក បក់បោកមកអំពីទិសខាងលិចក្តី ។បេ។ ទោះបើ គំនរខ្យល់ធំផងទឹក បក់បោកមកអំពីទិសខាងជើងក្តី ទោះបើ គំនរខ្យល់ធំផងទឹក បក់បោកមកអំពីទិសខាងត្បូងក្តី ក៏ធ្វើភ្នំនោះឲ្យញាប់មិនបាន ឲ្យកម្រើកមិនបាន ឲ្យញាប់ញ័រមិនបាន មានឧបមាដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចំរើន មានឧបមេយ្យ ដូចភិក្ខុមានចិត្តផុតស្រឡះដោយប្រពៃ យ៉ាងនេះហើយ ទោះបើ រូបារម្មណ៍ដ៏ពន្លឹក ដែលគប្បីដឹងដោយភ្នែក មកកាន់ផ្លូវនៃចក្ខុទ្វារ ក៏គ្រប់សង្កត់ចិត្តរបស់ភិក្ខុនោះមិនបាន ចិត្តរបស់លោក ក៏មិនបានច្រឡំដោយអារម្មណ៍ ជាចិត្តនឹងធឹង ដល់នូវការមិនរំភើប ទាំងលោកក៏ពិចារណាឃើញនូវការកើតឡើង និងការវិនាសទៅនៃចិត្តនោះ ទោះបើសទ្ទារម្មណ៍ដ៏ពន្លឹក ដែលគប្បីដឹងដោយត្រចៀក ។បេ។ គន្ធារម្មណ៍ ដែលគប្បីដឹងដោយច្រមុះ រសារម្មណ៍ ដែលគប្បីដឹងដោយអណ្តាត ផោដ្ឋព្វារម្មណ៍ ដែលគប្បីដឹងដោយកាយ ធម្មារម្មណ៍ ដែលគប្បីដឹងដោយចិត្ត មកកាន់ផ្លូវនៃមនោទ្វារ

នេវស្ស ចិត្តំ បរិយាទិយន្តិ អមិស្សីកតមេវស្ស ចិត្តំ ហោតិ ឋិតំ អានេញ្ជប្បត្តំ វយញ្ចស្សានុបស្សតីតិ ។

នេក្ខម្មមធិមុត្តស្ស   បវិវេកញ្ច ចេតសោ
អព្យាបជ្ឈាធិមុត្តស្ស   ឧបាទានក្ខយស្ស ច
តណ្ហក្ខយាធិមុត្តស្ស   អសម្មោហញ្ច ចេតសោ
ទិស្វា អាយតនុប្បាទំ   សម្មា ចិត្តំ វិមុច្ចតិ
តស្ស សម្មាវិមុត្តស្ស   សន្តចិត្តស្ស ភិក្ខុនោ
កតស្ស បតិចយោ នត្ថិ   ករណីយំ ន វិជ្ជតិ ។
សេលោ យថា ឯកឃនោ   វាតេន ន សមីរតិ
ឯវំ រូបា រសា សទ្ទា   គន្ធា ផស្សា ច កេវលា
ឥដ្ឋា ធម្មា អនិដ្ឋា ច   នប្បវេធេន្តិ តាទិនោ
ឋិតំ ចិត្តំ វិប្បមុត្តំ   វយញ្ចស្សានុបស្សតីតិ ។



ក៏ស្រួបសង្កត់ចិត្តរបស់ភិក្ខុនោះមិនបាន ចិត្តរបស់លោក ក៏មិនបានច្រឡំដោយអារម្មណ៍ ជាចិត្តនឹងនឹង ដល់នូវការមិនញាប់ញ័រ ទាំងលោកក៏ពិចារណាឃើញនូវការកើតឡើង និងការរលត់ទៅនៃចិត្តនោះ ។

កាលបើ ភិក្ខុមានចិត្តចុះស៊ប់ចំពោះនេក្ខម្មៈ ចំពោះសេចក្តីស្ងប់ស្ងាត់
មានចិត្តចុះស៊ប់ចំពោះសេចក្តីមិនព្យាបាទ ចំពោះធម៌ជាទីអស់
ទៅនៃឧបាទាន មានចិត្តចុះស៊ប់ចំពោះធម៌ ជាទីអស់ទៅ
នៃតណ្ហា ចំពោះសេចក្តីមិនវង្វេង ចិត្តក៏រមែងផុតស្រឡះ
ដោយប្រពៃ ព្រោះឃើញនូវការកើត និងការរលត់ទៅនៃ
អាយតនៈ កាលបើភិក្ខុនោះ មានចិត្តផុតស្រឡះដោយ
ប្រពៃហើយ មានចិត្តស្ងប់រម្ងាប់ហើយ ការសន្សំនូវកិច្ច
ដែលលោកធ្វើហើយក៏មិនមាន កិច្ចដែលគួរធ្វើក៏មិនមាន ។
ភ្នំថ្មតាន់ស៊ុប រមែងមិនកម្រើក ដោយខ្យល់ យ៉ាងណា
អារម្មណ៍ទាំងឡាយគឺ រូប សំឡេង ក្លិន រស ផស្ស
ទាំងអស់ជាទីប្រាថ្នាក្តី មិនជាទីប្រាថ្នាក្តី ក៏ធ្វើចិត្តរបស់
អ្នកក្តាប់ខ្លួន ជាចិត្តនឹងនឹង រួចស្រឡះចាកកិលេស
ឲ្យញាប់ញ័រមិនបាន ទាំងលោកក៏ពិចារណាឃើញនូវការ
កើតឡើង និងការរលត់ទៅនៃចិត្តនោះ ក៏យ៉ាងនោះដែរ ។

[៥៦] តេន ខោ បន សមយេន អាយស្មា ផគ្គុណោ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហ-គិលានោ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អាយស្មា ភន្តេ ផគ្គុណោ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សាធុ ភន្តេ ភគវា យេនាយស្មា ផគ្គុណោ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា ផគ្គុណោ តេនុបសង្កមិ ។ អទ្ទសា ខោ អាយស្មា ផគ្គុណោ ភគវន្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន មញ្ចកេ សមធោសិ(១) ។ អថខោ ភគវា អាយស្មន្តំ ផគ្គុណំ ឯតទវោច អលំ ផគ្គុណ មា ត្វំ មញ្ចកេ សមធោសិ ។

១ ឱ. សមធោសិ ។



(៥៦) សម័យនោះ ព្រះផគ្គុណៈដ៏មានអាយុ មានអាពាធ ដល់នូវទុក្ខ ឈឺធ្ងន់ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះផគ្គុណៈដ៏មានអាយុ មានអាពាធ ដល់នូវទុក្ខ ឈឺធ្ងន់ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ស្តេចចូលទៅឯលំនៅនៃព្រះផគ្គុណៈដ៏មានអាយុ ដើម្បីអនុគ្រោះ ។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ទទួល ដោយតុណ្ហីភាព ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញចាកសម្ងំ ក្នុងសាយណ្ហសម័យហើយ ចូលទៅឯលំនៅនៃព្រះផគ្គុណៈដ៏មានអាយុ ។ ព្រះផគ្គុណៈដ៏មានអាយុ បានឃើញព្រះដ៏មានព្រះភាគ ស្តេចមកអំពីចម្ងាយលឹម ៗ លុះឃើញហើយ ក៏គ្រាន់តែសំដែងអាការជាទី ក្រោកឡើងលើគ្រែតូច ។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់ឃាត់ព្រះផគ្គុណៈដ៏មានអាយុយ៉ាងនេះថា កុំផគ្គុណៈ អ្នកកុំក្រោកអំពីគ្រែតូចឡើយ ។

សន្តិមានិ អាសនានិ បរេហិ(១) បញ្ញត្តានិ តត្ថាហំ និសីទិស្សាមីតិ និសីទិ ភគវា បញ្ញត្តេ អាសនេ និសជ្ជ ខោ ភគវា អាយស្មន្តំ ផគ្គុនំ ឯតទវោច កច្ចិ តេ ផគ្គុន ខមនីយំ កច្ចិ យាបនីយំ កច្ចិ ទុក្ខា វេទនា បដិក្កមន្តិ នោ អភិក្កមន្តិ បដិក្កមោសានំ បញ្ញាយតិ នោ អភិក្កមោតិ ។ ន មេ ភន្តេ ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោ ។ សេយ្យថាបិ ភន្តេ ពលវា បុរិសោ តិណ្ហេន សិខរេន មុទ្ធនិ(២) អភិមត្ថេយ្យ ឯវមេវ ខោ ភន្តេ អធិមត្តា វាតា មុទ្ធនិ ឩហនន្តិ ។ ន មេ ភន្តេ ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា

១ ឱ. បុរេ ។ ២ ឱ. មុទ្ធនំ ។



អាសនៈនេះដែលភិក្ខុឯទៀត ក្រាលបម្រុងទុកហើយ តថាគតនឹងអង្គុយលើអាសនៈនោះ ព្រះដ៏មានព្រះភាគក៏ទ្រង់គង់លើអាសនៈដែលភិក្ខុក្រាលថ្វាយ លុះព្រះដ៏មានព្រះភាគគង់ហើយ បានត្រាស់សួរព្រះផគ្គុណៈដ៏មានអាយុយ៉ាងនេះថា ម្នាលផគ្គុណៈ អ្នកល្មមអត់ធន់បានទេឬ អ្នកល្មមញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅបានទេឬ ទុក្ខវេទនា (របស់អ្នក) ធូរថយ មិនចំរើនឡើង សេចក្តីធូរថយ រមែងប្រាកដ ការចំរើនឡើងមិនប្រាកដទេឬ ។ ព្រះផគ្គុណៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនល្មមអត់ធន់បានទេ មិនល្មមញុំាងឥរិយាបថ ឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គខ្លាំងណាស់ រមែងចំរើនឡើង មិនធូរថយសោះ សេចក្តីចំរើនឡើង រមែងប្រាកដ សេចក្តីធូរថយ មិនប្រាកដទេ ។ បពិត្រព្រះអង្គដ៏ចំរើន បុរសមានកំឡាំង យកដែកស្រួចដ៏មុតមកចាក់ចំលុះក្បាល យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចំរើន ខ្យល់យ៉ាងខ្លាំងតែងចាក់ដោតក្នុងក្បាល (របស់ខ្ញុំព្រះអង្គ) ក៏យ៉ាងនោះដែរ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ មិនល្មមអត់ធន់បានទេ មិនល្មមញុំាងឥរិយាបថ ឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គខ្លាំងណាស់

អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោ ។ សេយ្យថាបិ ពលវា បុរិសោ ទឡ្ហេន វរត្តក្ខណ្ឌេន សីសេ សីសវេឋនំ ទទេយ្យ ឯវមេវ ខោ ភន្តេ អធិមត្តា សីសេ សីសវេទនា ន មេ ភន្តេ ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោ ។ សេយ្យថាបិ ភន្តេ ទក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា តិណ្ហេន គោវិកន្តនេន កុច្ឆឹ បរិកន្តេយ្យ ឯវមេវ ខោ មេ ភន្តេ អធិមត្តា វាតា កុច្ឆឹ បរិកន្តន្តិ ន មេ ភន្តេ ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោ ។ សេយ្យថាបិ ភន្តេ ទ្វេ ពលវន្តោ បុរិសា ទុព្ពលតរំ បុរិសំ នានាពាហាសុ គហេត្វា អង្គារកាសុយា សន្តាបេយ្យុំ(១) សម្បរិតាបេយ្យុំ ឯវមេវ ខោ ភន្តេ អធិមត្តោ កាយស្មឹ ទាហោ

១ ម. បរិតាបេយ្យុំ ។



រមែងតែចំរើនឡើង មិនធូរថយសោះ សេចក្តីចំរើនឡើង រមែងតែប្រាកដ សេចក្តីធូរថយមិនប្រាកដទេ ។ បុរសមានកំឡាំងយកព្រ័ត្រមាំមួយបង្វាយ មករឹតលើក្បាល យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចំរើន វេទនាក្នុងក្បាល (របស់ខ្ញុំព្រះអង្គ) ក៏ខ្លាំងយ៉ាងនោះដែរ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនល្មមអត់ធន់បានទេ មិនល្មមញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គខ្លាំងណាស់ រមែងតែចំរើនឡើង មិនធូរថយសោះ សេចក្តីចំរើនឡើង រមែងតែប្រាកដ សេចក្តីធូរថយមិនប្រាកដទេ ។ បពិត្រព្រះអង្គដ៏ចំរើន នាយគោឃាតក៏ ឬអ្នកជំនួយការនៃនាយគោឃាតក៏ ដែលឆ្លាស យកកាំបិតសម្រាប់វះគោដ៏មុត មកវះពោះ យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចំរើន ខ្យល់យ៉ាងខ្លាំង រែងកាត់ផ្ទៃរបស់ខ្ញុំព្រះអង្គ យ៉ាងនោះដែរ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនល្មមអត់ធន់បានទេ មិនល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គខ្លាំងណាស់ រមែងតែចំរើនឡើង មិនធូរថយសោះទេ សេចក្តីចំរើនឡើងរមែងតែប្រាកដ សេចក្តីធូរថយមិនប្រាកដទេ ។ បពិត្រព្រះអង្គដ៏ចំរើន បុរសមានកំឡាំងពីរនាក់ នាំគ្នាចាប់បុរសដែលមានកំឡាំងថយជាង ត្រង់ដើមដៃផ្សេងគ្នា មកដុតកលកាល លើរណ្តៅរងើកភ្លើង យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចំរើន សេចក្តីក្តៅក្រហាយយ៉ាងខ្លាំងក្នុងកាយ (របស់ខ្ញុំព្រះអង្គ) ក៏យ៉ាងនោះដែរ

ន មេ ភន្តេ ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។ អថខោ ភគវា អាយស្មន្តំ ផគ្គុណំ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ អាយស្មា ផគ្គុណោ អចិរបក្កន្តស្ស ភគវតោ កាលមកាសិ តម្ហិ ចស្ស សមយេ មរណកាលេ ឥន្ទ្រិយានិ វិប្បសីទិំសុ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អាយស្មា ភន្តេ ផគ្គុណោ អចិរបក្កន្តស្ស ភគវតោ កាលមកាសិ តម្ហិ ចស្ស សមយេ មរណកាលេ ឥន្ទ្រិយានិ វិប្បសីទិំសូតិ ។



បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនល្មមអត់ធន់បានទេ មិនល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គខ្លាំងណាស់ រមែងចំរើនឡើង មិនថយចុះសោះ សេចក្តីចំរើន រមែងប្រាកដ សេចក្តីថយចុះ មិនប្រាកដទេ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើព្រះផគ្គុណៈដ៏មានអាយុ ឲ្យយល់ឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈ ស្តេចចៀសចេញទៅ ។ កាលព្រះដ៏មានព្រះភាគ ទ្រង់ស្តេចចេញទៅមិនយូរប៉ុន្មាន ព្រះផគ្គុណៈដ៏មានអាយុ ក៏ធ្វើមរណភាព ក្នុងសម័យ ជាកាលជិតមរណៈនោះ ឥន្ទ្រិយទាំងឡាយ របស់លោក ក៏ជ្រះថ្លា ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន កាលព្រះអង្គទ្រង់ស្តេចចេញមក មិនយូរប៉ុន្មាន ព្រះផគ្គុណៈដ៏មានអាយុ ក៏ធ្វើមរណភាព ប៉ុន្តែសម័យ ជាកាលជិតមរណៈនោះ ឥន្ទ្រិយទាំងឡាយ របស់លោកក៏ជ្រះថ្លា ។

កឹ ចានន្ទ ផគ្គុណស្ស ភិក្ខុនោ ឥន្ទ្រិយានិ ន វិប្បសីទិស្សន្តិ ផគ្គុណស្ស អានន្ទ ភិក្ខុនោ បញ្ចហិ ឱរម្ភាគិយេហិ សញ្ញោជនេហិ ចិត្តំ អវិមុត្តំ អហោសិ តស្ស តំ ធម្មទេសនំ សុត្វា បញ្ចហិ ឱរម្ភាគិយេហិ សញ្ញោជនេហិ ចិត្តំ វិមុត្តំ ។ ឆយិមេ អានន្ទ អានិសំសា កាលេន ធម្មស្សវនេ កាលេន អត្ថុបបរិក្ខាយ ។ កតមេ ឆ ។ ឥធានន្ទ ភិក្ខុនោ បញ្ចហិ ឱរម្ភាគិយេហិ សញ្ញោជនេហិ ចិត្តំ អវិមុត្តំ ហោតិ សោ តម្ហិ សមយេ មរណកាលេ លភតិ តថាគតំ ទស្សនាយ តស្ស តថាគតោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ តស្ស តំ ធម្មទេសនំ សុត្វា បញ្ចហិ ឱរម្ភាគិយេហិ សញ្ញោជនេហិ ចិត្តំ វិមុច្ចតិ អយំ អានន្ទ បឋមោ អានិសំសោ កាលេន ធម្មស្សវនេ ។



ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអានន្ទ ឥន្ទ្រិយទាំងឡាយ របស់ផគ្គុណភិក្ខុ នឹងមិនជ្រះថ្លាដូចម្តេចបាន ម្នាលអានន្ទ ចិត្តរបស់ផគ្គុណ-ភិក្ខុ ជាចិត្តមិនទាន់ផុតស្រឡះ ចាកសំយោជនៈជាចំណែកខាងក្រោម ៥ យ៉ាងទេ ប៉ុន្តែចិត្តរបស់លោកផុតស្រឡះចាកសំយោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាងបានវិញ ព្រោះស្តាប់ធម្មទេសនានោះ ។ ម្នាលអានន្ទ អានិសង្សក្នុងការស្តាប់ធម៌ តាមកាលគួរ ក្នុងការពិចារណាសេចក្តីតាមកាលគួរ នេះមាន ៦ យ៉ាង ។ អានិសង្ស ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ មានចិត្តមិនទាន់ផុតស្រឡះ ចាកសំយោជនៈ ជាចំណែកខាងក្រោម៥យ៉ាងទេ ប៉ុន្តែក្នុងសម័យជាកាលជិតមរណៈនោះ ភិក្ខុនោះបានចួបប្រទះព្រះតថាគត ព្រះតថាគតសំដែងធម៌ដ៏ពីរោះបទដើម ពីរោះកណ្តាល ពីរោះចុង ប្រកបដោយអត្ថ ដោយព្យញ្ជនៈ ប្រកាសព្រហ្មចរិយធម៌ ដ៏បរិសុទ្ធពេញលេញទាំងអស់ ដល់ភិក្ខុនោះ ចិត្តរបស់ភិក្ខុនោះ ក៏ផុតស្រឡះចាកសំយោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាងបាន ព្រោះស្តាប់ធម្មទេសនានោះ ម្នាលអានន្ទ នេះជាអានិសង្សទី ១ ក្នុងការស្តាប់ធម៌ តាមកាលគួរ ។

បុន ចបរំ អានន្ទ ភិក្ខុនោ បញ្ចហិ ឱរម្ភាគិយេហិ សញ្ញោជនេហិ ចិត្តំ អវិមុត្តំ ហោតិ សោ តស្មិំ សមយេ មរណកាលេ នហេវ ខោ លភតិ តថាគតំ ទស្សនាយ អបិច ខោ តថាគតសាវកំ លភតិ ទស្សនាយ តស្ស តថាគតសាវកោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសាន-កល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ តស្ស តំ ធម្មទេសនំ សុត្វា បញ្ចហិ ឱរម្ភាគិយេហិ សញ្ញោជនេហិ ចិត្តំ វិមុច្ចតិ អយំ អានន្ទ ទុតិយោ អានិសំសោ កាលេន ធម្មស្សវនេ ។ បុន ចបរំ អានន្ទ ភិក្ខុនោ បញ្ចហិ ឱរម្ភាគិយេហិ សញ្ញោជនេហិ ចិត្តំ អវិមុត្តំ ហោតិ សោ តស្មិំ សមយេ មរណកាលេ នហេវ ខោ លភតិ តថាគតំ ទស្សនាយ នបិ តថាគតសាវកំ លភតិ ទស្សនាយ អបិច ខោ យថាសុតំ យថាបរិយត្តំ ធម្មំ ចេតសា អនុវិតក្កេតិ អនុវិចារេតិ មនសានុបេក្ខតិ



ម្នាលអានន្ទ មួយទៀត ភិក្ខុមានចិត្តមិនទាន់ផុតស្រឡះ ចាកសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាងទេ តែក្នុងសម័យកាលជិតមរណៈនោះ ភិក្ខុនោះ មិនបានជួបប្រទះព្រះតថាគតទេ ប៉ុន្តែបានជួបប្រទះនឹងសាវករបស់ព្រះតថាគត សាវករបស់ព្រះតថាគត ក៏សំដែងធម៌ មានពីរោះបទដើម បទកណ្ដាល បទចុង ប្រកបដោយអត្ថ ដោយព្យញ្ជនៈ ប្រកាសព្រហ្មចរិយធម៌ ដ៏បរិសុទ្ធពេញលេញឥតសល់ ដល់ភិក្ខុនោះ ចិត្តរបស់ភិក្ខុនោះ ក៏ផុតស្រឡះចាកសញ្ញោជនៈ ជាចំណែកខាងក្រោម៥យ៉ាងបាន ព្រោះស្ដាប់ធម្មទេសនានោះ នេះជាអានិសង្ស ទី ២ ក្នុងការស្ដាប់ធម៌តាមកាលគួរ ។ ម្នាលអានន្ទ មួយទៀត ចិត្តរបស់ភិក្ខុមិនទាន់ផុតស្រឡះចាកសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាងទេ តែក្នុងសម័យជាកាលជិតមរណៈ ភិក្ខុនោះ មិនបានជួបប្រទះព្រះតថាគត មិនបានជួបនឹងសាវករបស់ព្រះតថាគតទេ ប៉ុន្តែត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ ដោយចិត្ត ពិនិត្យរឿយ ៗ ក្នុងចិត្តចំពោះធម៌ តាមដែលខ្លួនបានស្ដាប់ បានរៀនមក

តស្ស យថាសុតំ យថាបរិយត្តំ ធម្មំ ចេតសា អនុវិតក្កយតោ អនុវិចារយតោ មនសានុបេក្ខតោ បញ្ចហិ ឱរម្ភាគិយេហិ សញ្ញោជនេហិ ចិត្តំ វិមុច្ចតិ អយំ អានន្ទ តតិយោ អានិសំសោ កាលេន អត្ថុបបរិក្ខាយ ។ ឥធានន្ទ ភិក្ខុនោ បញ្ចហិ ឱរម្ភាគិយេហិ សញ្ញោជនេហិ ចិត្តំ វិមុត្តំ ហោតិ អនុត្តរេ ច ខោ ឧបធិសង្ខយេ ចិត្តំ អវិមុត្តំ ហោតិ សោ តម្ហិ សមយេ មរណកាលេ លភតិ តថាគតំ ទស្សនាយ តស្ស តថាគតោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ ។បេ។ ព្រហ្មចរិយំ បកាសេតិ តស្ស តំ ធម្មទេសនំ សុត្វា អនុត្តរេ ឧបធិសង្ខយេ ចិត្តំ វិមុច្ចតិ អយំ អានន្ទ ចតុត្ថោ អានិសំសោ កាលេន ធម្មស្សវនេ ។ បុន ចបរំ អានន្ទ ភិក្ខុនោ បញ្ចហិ ឱរម្ភាគិយេហិ សញ្ញោជនេហិ ចិត្តំ វិមុត្តំ ហោតិ អនុត្តរេ ច ខោ ឧបធិសង្ខយេ ចិត្តំ អវិមុត្តំ ហោតិ



កាលភិក្ខុនោះ ត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ ដោយចិត្ត ពិនិត្យរឿយ ៗ នូវធម៌ ចំពោះធម៌ តាមដែលខ្លួនបានស្តាប់បានរៀនមក ចិត្តក៏ផុតស្រឡះចាកសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាងបាន ម្នាលអានន្ទ នេះជាអានិសង្សទី ៣ គឺការពិចារណាសេចក្តី តាមកាលគួរ ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ មានចិត្តផុតស្រឡះចាកសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាងស្រេចហើយ ប៉ុន្តែមានចិត្តមិនទាន់ផុតស៊ប់ក្នុងធម៌ដ៏ប្រសើរ គឺព្រះនិព្វានជាទីអស់ទៅនៃឧបធិទៅឡើយទេ លុះក្នុងសម័យជាកាលជិតមរណៈនោះ ភិក្ខុនោះ បានចួបប្រទះព្រះតថាគត ព្រះតថាគត ក៏សំដែងធម៌មានពីរោះបទដើម បទកណ្តាល ។បេ។ ប្រកាសព្រហ្មចរិយធម៌ដល់ភិក្ខុនោះ ចិត្តរបស់ភិក្ខុនោះ ក៏ផុតស៊ប់ក្នុងធម៌ដ៏ប្រសើរ គឺព្រះនិព្វានជាទីអស់ទៅនៃឧបធិបាន ព្រោះស្តាប់ធម្មទេសនានោះ ម្នាលអានន្ទ នេះជាអានិសង្សទី ៤ គឺការស្តាប់ធម៌តាមកាលគួរ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុមានចិត្តផុតស្រឡះ ចាកសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាងស្រេចហើយ ប៉ុន្តែមានចិត្តមិនទាន់ផុតស៊ប់ក្នុងធម៌ដ៏ប្រសើរ គឺព្រះនិព្វាន ជាទីអស់ទៅនៃឧបធិទៅឡើយទេ

សោ តស្មឹ សមយេ មរណកាលេ នហេវ ខោ លភតិ តថាគតំ ទស្សនាយ អបិច ខោ តថាគតសាវកំ លភតិ ទស្សនាយ តស្ស តថាគតសាវកោ ធម្មំ ទេសេតិ អាទិកល្យាណំ ។បេ។ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ តស្ស តំ ធម្មំ សុត្វា អនុត្តរេ ឧបធិសង្ខយេ ចិត្តំ វិមុច្ចតិ អយំ អានន្ទ បញ្ចមោ អានិសំសោ កាលេន ធម្មស្សវនេ ។ បុន ចបរំ អានន្ទ ភិក្ខុនោ បញ្ចហិ ឱរម្ភាគិយេហិ សញ្ញោជនេហិ ចិត្តំ វិមុត្តំ ហោតិ អនុត្តរេ ច ខោ ឧបធិសង្ខយេ ចិត្តំ អវិមុត្តំ ហោតិ សោ តស្មឹ សមយេ មរណកាលេ នហេវ ខោ លភតិ តថាគតំ ទស្សនាយ នបិ តថាគតសាវកំ លភតិ ទស្សនាយ អបិច ខោ យថាសុតំ យថាបរិយត្តំ ធម្មំ ចេតសា អនុវិតក្កេតិ អនុវិចារេតិ មនសានុបេក្ខតិ ។ តស្ស យថាសុតំ យថាបរិយត្តំ ធម្មំ ចេតសា អនុវិតក្កយតោ អនុវិចារយតោ មនសានុបេក្ខតោ អនុត្តរេ ឧបធិសង្ខយេ ចិត្តំ វិមុច្ចតិ



ក្នុងសម័យជាកាលជិតមរណៈនោះ ភិក្ខុនោះ មិនបានចួបប្រទះព្រះតថាគត ប៉ុន្តែបានចួបប្រទះនឹងសាវករបស់ព្រះតថាគត សាវករបស់ព្រះតថាគត ក៏សំដែងនូវធម៌ ពីរោះបទដើម ។ល។ ប្រកាសព្រហ្មចរិយធម៌ដ៏បរិសុទ្ធដល់ភិក្ខុនោះ ចិត្តរបស់ភិក្ខុនោះ ក៏ចុះស៊ប់ក្នុងធម៌ដ៏ប្រសើរ គឺព្រះនិព្វានជាទីអស់ទៅនៃឧបធិបាន ព្រោះស្តាប់ធម៌ទេសនានោះ ម្នាលអានន្ទ នេះជាអានិសង្សទី ៥ ក្នុងការស្តាប់ធម៌ តាមកាលគួរ ។ ម្នាលអានន្ទ មួយវិញទៀត ភិក្ខុមានចិត្តផុតស្រឡះចាកសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាង ស្រេចហើយ ប៉ុន្តែមានចិត្តមិនទាន់ចុះស៊ប់ក្នុងធម៌ដ៏ប្រសើរ គឺព្រះនិព្វានជាទីអស់ទៅនៃឧបធិនៅឡើយទេ លុះក្នុងសម័យជាកាលជិតមរណៈនោះ ភិក្ខុនោះ មិនបានចួបប្រទះព្រះតថាគត ទាំងមិនបានចួបប្រទះនឹងសាវករបស់ព្រះតថាគតទេ ប៉ុន្តែបានត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ ដោយចិត្តពិនិត្យរឿយ ៗ ក្នុងចិត្ត ចំពោះធម៌តាមដែលខ្លួនបានស្តាប់ បានរៀនមក កាលភិក្ខុនោះត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ ដោយចិត្តពិនិត្យរឿយ ៗ ក្នុងចិត្ត ចំពោះធម៌តាមដែលខ្លួនបានស្តាប់ បានរៀនមក ចិត្តក៏ចុះស៊ប់ ក្នុងធម៌ដ៏ប្រសើរគឺព្រះនិព្វាន ជាទីអស់ទៅនៃឧបធិបាន

អយំ អានន្ទ ឆដ្ឋោ អានិសំសោ កាលេន អត្ថុបបរិក្ខាយ ។ ឥមេ ខោ អានន្ទ ឆ អានិសំសា កាលេន ធម្មស្សវនេ កាលេន អត្ថុបបរិក្ខាយាតិ ។

(៥៧) ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច បូរណេន ភន្តេ កស្សបេន ឆឡាភិជាតិយោ បញ្ញត្តា កណ្ហាភិជាតិ បញ្ញត្តា នីលាភិជាតិ បញ្ញត្តា លោហិតាភិជាតិ បញ្ញត្តា ហលិទ្ទាភិជាតិ បញ្ញត្តា សុក្កាភិជាតិ បញ្ញត្តា បរមសុក្កាភិជាតិ បញ្ញត្តា ។ តត្រិទំ ភន្តេ បូរណេន កស្សបេន កណ្ហាភិជាតិ បញ្ញត្តា ឱរព្ភិកា សូករិកា សាកុណិកា មាគវិកា លុទ្ទា មច្ឆឃាតកា ចោរា ចោរឃាតកា ពន្ធនាគារិកា យេ វា បនញ្ញេបិ កេចិ កុរូរកម្មន្តា ។



ម្នាលអានន្ទ នេះជាអានិសង្សទី ៦ ក្នុងការពិចារណាសេចក្តី តាមកាលគួរ ។ ម្នាលអានន្ទ អានិសង្សក្នុងការស្តាប់ធម៌ តាមកាលគួរ ក្នុងការពិចារណាធម៌តាមកាលគួរ មាន ៦ យ៉ាងនេះឯង ។

(៥៧) សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ បានចូលទៅគាល់ ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន បូរណកស្សប បញ្ញត្តជាតិកំណើត ៦ យ៉ាង គឺបញ្ញត្តជាតិខ្មៅ ១ បញ្ញត្តជាតិខៀវ ១ បញ្ញត្តជាតិក្រហម ១ បញ្ញត្តជាតិលឿង ១ បញ្ញត្តជាតិស ១ បញ្ញត្តជាតិសសុទ្ធ ១ ។ បពិត្រព្រះអង្គដ៏ចំរើន ក្នុងជាតិ ៦ យ៉ាងនោះ បូរណកស្សប បញ្ញត្តពួកជនអ្នកសម្លាប់ពពែ អ្នកសម្លាប់ជ្រូក អ្នកសម្លាប់សត្វបក្សី អ្នកសម្លាប់ម្រឹគ ពួកព្រាន ពួកអ្នកសម្លាប់ត្រី ពួកចោរ ពួកអ្នកសម្លាប់ចោរ ពួកអ្នកជាប់គុក ឬក៏ពួកជនណាមួយក្រៅពីនេះ ដែលមានអំពើកាក្រក់ជាជាតិខ្មៅ ។

តត្រិទំ ភន្តេ បូរណេន កស្សបេន នីលាភិជាតិ បញ្ញត្តា ភិក្ខូ កណ្ដកវុត្តិកា(១) យេ វា បនញ្ញេ កេចិ កម្មវាទា កិរិយវាទា ។ តត្រិទំ ភន្តេ បូរណេន កស្សបេន លោហិតាភិជាតិ បញ្ញត្តា និគណ្ឋា ឯកសាដកា ។ តត្រិទំ ភន្តេ បូរណេន កស្សបេន ហលិទ្ទាភិជាតិ បញ្ញត្តា គិហី ឱទាតវសនា អចេលកសាវកា ។ តត្រិទំ ភន្តេ បូរណេន កស្សបេន សុក្កាភិជាតិ បញ្ញត្តា អាជីវកា អាជីវកិនិយោ ។ តត្រិទំ ភន្តេ បូរណេន កស្សបេន បរមសុក្កាភិជាតិ បញ្ញត្តា នន្ទោ វច្ឆោ កិច្ចោ(២) សង្កិច្ចោ មក្ខលិ គោសាលោ ។ បូរណេន ភន្តេ កស្សបេន ឥមា ឆឡាភិជាតិយោ បញ្ញត្តាតិ ។ កឹ បនានន្ទ បូរណស្ស កស្សបស្ស សព្វោ លោកោ ឯតទព្ភនុជានាតិ ឥមា ឆឡាភិជាតិយោ បញ្ញាបេតុន្តិ ។ នោ ហេតំ ភន្តេ ។

១ ម. ឧ. កណ្ហកវុត្តិកា ។ ២ ម. កិសោ ។ ឱ. កិញ្ចោ ។



បពិត្រព្រះអង្គដ៏ចំរើន អភិជាតិ ៦ យ៉ាងនោះ បូរណកស្សប បញ្ញត្តពួកភិក្ខុដែលមានអត្យាស្រ័យស្មៅ ឬក៏ពួកជនណាមួយ ក្រៅពីនេះ ដែលជាកម្មវាទ នឹងកិរិយវាទ ជាអភិជាតិ ខៀវ ។ បពិត្រព្រះអង្គដ៏ចំរើន អភិជាតិ ៦ យ៉ាងនោះ បូរណកស្សប បញ្ញត្តពួកនិគ្រន្ថដែលមានសាដកតែ ១ ជាអភិជាតិ ក្រហម ។ បពិត្រព្រះអង្គដ៏ចំរើន អភិជាតិ ៦ យ៉ាងនោះ បូរណកស្សប បញ្ញត្តពួកគ្រហស្ថ អ្នកស្លៀកដណ្ដប់សំពត់ស មានសាដកផ្ទួចជា សាវកអចេលកៈ ជាអភិជាតិ លឿង ។ បពិត្រព្រះអង្គដ៏ចំរើន អភិជាតិ ៦ យ៉ាងនោះ បូរណកស្សប បញ្ញត្តពួកអាជីវកៈ នឹងអាជីវិកា ជាអភិជាតិ ស ។ បពិត្រព្រះអង្គដ៏ចំរើន អភិជាតិ ៦ យ៉ាងនោះ បូរណកស្សប បញ្ញត្តជនឈ្មោះនន្ទវច្ឆៈ ឈ្មោះកិច្ចសង្កិច្ចៈ នឹងឈ្មោះមក្ខលិគោសាល ជាអភិជាតិ សសុទ្ធ ។ បពិត្រព្រះអង្គដ៏ចំរើន បូរណកស្សប បានបញ្ញត្តជាតិ ៦ យ៉ាងនេះឯង ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអានន្ទ ចុះសព្វលោកទាំងពួង យល់តាមពាក្យរបស់បូរណកស្សប ដែលបញ្ញត្តជាតិ ៦ យ៉ាងនេះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន មិនយល់តាមទេ ។

សេយ្យថាបិ អានន្ទ បុរិសោ ទលិទ្ទោ អស្សកោ អនាឡ្ហិយោ តស្ស អកាមកស្ស ពិលំ ឱលគ្គេយ្យុំ ឥទំ តេ អម្ភោ បុរិស មំសញ្ច ខាទិតព្វំ មូលញ្ច អនុប្បទាតព្វន្តិ ឯវមេវ ខោ អានន្ទ បូរណេន កស្សបេន អប្បដិញ្ញាយ ឯតេសំ សមណព្រាហ្មណានំ ឥមា ឆឡាភិជាតិយោ បញ្ញត្តា យថា តំ ពាលេន អព្យត្តេន អខេត្តញ្ញុនា អកុសលេន ។ អហំ ខោ បនានន្ទ ឆឡាភិជាតិយោ បញ្ញាបេមិ តំ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច កតមា ចានន្ទ ឆឡាភិជាតិយោ ។ ឥធានន្ទ ឯកច្ចោ កណ្ហាភិជាតិយោ សមានោ កណ្ហំ ធម្មំ អភិជាយតិ ឥធ បនានន្ទ ឯកច្ចោ កណ្ហាភិជាតិយោ សមានោ សុក្កំ ធម្មំ អភិជាយតិ ឥធ បនានន្ទ ឯកច្ចោ កណ្ហាភិជាតិយោ សមានោ អកណ្ហំ អសុក្កំ និព្វានំ អភិជាយតិ ឥធ បនានន្ទ ឯកច្ចោ សុក្កាភិជាតិយោ សមានោ កណ្ហំ ធម្មំ អភិជាយតិ



ម្នាលអានន្ទ ដូចជាបុរសកំសត់ក្រ មិនមានទ្រព្យរបស់ខ្លួន ជាអ្នកមិនស្តុកស្តម្ភ ពួកជនឯទៀត ជម្រុញព្យួរចំណែកសាច់ ដល់បុរសនោះ ដែលជាអ្នកមិនត្រូវការ ដោយពាក្យថា នែបុរសអើយ អ្នកត្រូវតែស៊ីសាច់នេះផង ត្រូវប្រគល់ថ្លៃឲ្យផង យ៉ាងណាមិញ ម្នាលអានន្ទ បូរណកស្សប ជាមនុស្សពាល មិនវាងវៃ មិនស្គាល់ខេត្ត (នៃការបញ្ញត្តិជាតិ) មិនឆ្លៀវឆ្លាស បានបញ្ញត្តជាតិ ៦ យ៉ាងនេះ របស់ពួកសមណព្រាហ្មណ៍ទាំងនុ៎ះ ដោយគេមិនបានយល់ព្រម ក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ ឥឡូវនេះ តថាគតនឹងបញ្ញត្តជាតិ ៦ យ៉ាង អ្នកចូរស្តាប់បញ្ញត្តិនោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អ តថាគតនឹងសំដែង ។ ព្រះអានន្ទដ៏មានអាយុ ក៏ទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអានន្ទ ចុះជាតិ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអានន្ទ បុគ្គលខ្លះ ក្នុងលោកនេះ មានជាតិ ខ្មៅ ប្រព្រឹត្តធម៌ខ្មៅ ១ ម្នាលអានន្ទ បុគ្គលខ្លះ ក្នុងលោកនេះ មានជាតិ ខ្មៅ ប្រព្រឹត្តធម៌ ស ១ ម្នាលអានន្ទ បុគ្គលខ្លះ ក្នុងលោកនេះ មានជាតិ ខ្មៅ ដល់នូវព្រះនិព្វាន ដែលជាធម៌មិនខ្មៅមិនស ១ ម្នាលអានន្ទ បុគ្គលខ្លះ ក្នុងលោកនេះ មានជាតិស ប្រព្រឹត្តធម៌ ខ្មៅ ១

ឥធ បនាវុសោ ឯកច្ចោ សុក្កាភិជាតិកោ សមានោ សុក្កំ ធម្មំ អភិជាយតិ ឥធ បនាវុសោ ឯកច្ចោ សុក្កាភិជាតិកោ សមានោ អកណ្ហំ អសុក្កំ និព្វានំ អភិជាយតិ ។ កតមញ្ចាវុសោ កណ្ហាភិជាតិកោ សមានោ កណ្ហំ ធម្មំ អភិជាយតិ ។ ឥធាវុសោ ឯកច្ចោ នីចេ កុលេ បច្ចាជាតោ ហោតិ ចណ្ឌាលកុលេ វា នេសាទកុលេ វា វេណកុលេ វា រថការកុលេ វា បុក្កុសកុលេ វា ទលិទ្ទេ អប្បន្នបានភោជនេ កសិរវុត្តិកេ យត្ថ កសិរេន ឃាសច្ឆាទោ លព្ភតិ សោ ច ហោតិ ទុព្វណ្ណោ ទុទ្ទសិកោ ឱកោដិមកោ ពវ្ហាពាធោ កាណោ វា កុណី វា ខញ្ជោ វា បក្ខហតោ វា ន លាភី អន្នស្ស បានស្ស វត្ថស្ស យានស្ស មាលាគន្ធវិលេបនស្ស សេយ្យាវសថបទីបេយ្យស្ស សោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ សោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។



ម្នាលអាវុសោ បុគ្គលខ្លះ ក្នុងលោកនេះ មានជាតិស ប្រព្រឹត្តធម៌ស ១ ម្នាលអាវុសោ បុគ្គលខ្លះ ក្នុងលោកនេះ មានជាតិស ដល់នូវព្រះនិព្វាន ដែលជាធម៌មិនខ្មៅមិនស ១ ។ ម្នាលអាវុសោ ចុះបុគ្គលមានជាតិខ្មៅ ប្រព្រឹត្តធម៌ខ្មៅ តើយ៉ាងដូចម្តេច ។ ម្នាលអាវុសោ បុគ្គលខ្លះ ក្នុងលោកនេះ មកកើតក្នុងត្រកូលថោកទាប គឺត្រកូលចណ្ឌាល ឬត្រកូលនេសាទ ត្រកូលជាងឬស្សី ត្រកូលជាងរថ ត្រកូលអ្នកយកសម្រាម ជាត្រកូលក្រីក្រ មិនមានបាយទឹក និងគ្រឿងប្រើប្រាស់ រស់នៅដោយលំបាក ដែលជាត្រកូលរកគ្រឿងបរិភោគនិងគ្រឿងស្លៀកពាក់បានដោយក្រ បុគ្គលនោះឯង ជាអ្នកមានសម្បុរអាក្រក់ លំបាកមើល ជាបុគ្គលតឿ មានអាពាធច្រើន ជាបុគ្គលខ្វាក់ ឬក្រិន ខ្វិន ស្លាប់ម្ខាង ជាអ្នកមិនសូវបានបាយទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅនិងគ្រឿងប្រទីប បុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ ក្រោយអំពីបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ។

ឯវំ ខោ អានន្ទ កណ្ហាភិជាតិយោ សមានោ កណ្ហំ ធម្មំ អភិជាយតិ ។ កថញ្ចានន្ទ កណ្ហាភិជាតិយោ សមានោ សុក្កំ ធម្មំ អភិជាយតិ ។ ឥធានន្ទ ឯកច្ចោ នីចេ កុលេ បច្ចាជាតោ ហោតិ ចណ្ឌាលកុលេ វា ។បេ។ សេយ្យាវសថប្បទីបេយ្យស្ស សោ កាយេន សុចរិតំ ចរតិ វាចាយ សុចរិតំ ចរតិ មនសា សុចរិតំ ចរតិ សោ កាយេន សុចរិតំ ចរិត្វា វាចាយ សុចរិតំ ចរិត្វា មនសា សុចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឯវំ ខោ អានន្ទ កណ្ហាភិជាតិយោ សមានោ សុក្កំ ធម្មំ អភិជាយតិ ។ កថញ្ចានន្ទ កណ្ហាភិជាតិយោ សមានោ អកណ្ហំ អសុក្កំ និព្វានំ អភិជាយតិ ។ ឥធានន្ទ ឯកច្ចោ នីចេ កុលេ បច្ចា-ជាតោ ហោតិ ចណ្ឌាលកុលេ វា ។បេ។ សោ ច ហោតិ ទុព្វណ្ណោ ទុទ្ទសិកោ ឱកោដិមកោ សោ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជតិ សោ ឯវំ បព្វជិតោ សមានោ



ម្នាលអានន្ទ បុគ្គលជាអ្នកមានជាតិខ្មៅ ប្រព្រឹត្តធម៌ខ្មៅ យ៉ាងនេះឯង ។ ម្នាលអានន្ទ ចុះបុគ្គលមានជាតិខ្មៅ ប្រព្រឹត្តធម៌ស តើដូចម្តេច ។ ម្នាលអានន្ទ បុគ្គលខ្លះ ក្នុងលោកនេះ មកកើតក្នុងត្រកូលទាប គឺត្រកូលចណ្ឌាល ។បេ។ ជាអ្នកមិនសូវបាននូវទីដេក ទីនៅ និងគ្រឿងប្រទីប បុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តហើយ ក្រោយបែកធ្លាយនៃកាយស្លាប់ទៅ ក៏ទៅកើត ឯសុគតិសួគ៌ទេវលោក ។ ម្នាលអានន្ទ បុគ្គលជាអ្នកមានជាតិខ្មៅ ប្រព្រឹត្តធម៌ស យ៉ាងនេះឯង ។ ម្នាលអានន្ទ ចុះបុគ្គលអ្នកមានជាតិខ្មៅ ដល់នូវព្រះនិព្វាន ដែលជាធម៌មិនខ្មៅមិនស តើដូចម្តេច ។ ម្នាលអានន្ទ បុគ្គលខ្លះ មកកើតក្នុងត្រកូលទាប គឺត្រកូលចណ្ឌាល ។បេ។ បុគ្គលនោះឯង ជាអ្នកមានសម្បុរអាក្រក់ លំបាកមើល ជាមនុស្សទាបតឿ បុគ្គលនោះកោរសក់ កោរពុកមាត់ពុកចង្កា ស្លៀកដណ្តប់នូវកាសាវព័ស្ត្រ ចេញចាកផ្ទះចូលកាន់ផ្នួស លុះបុគ្គលនោះបួស យ៉ាងនេះហើយ

បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ ចតូសុ សតិបដ្ឋានេសុ សុបដ្ឋិតចិត្តោ សត្ត ពោជ្ឈង្គេ យថាភូតំ ភាវេត្វា អកណ្ហំ អសុក្កំ និព្វានំ អភិជាយតិ ។ ឯវំ ខោ អានន្ទ កណ្ហាភិជាតិយោ សមានោ អកណ្ហំ អសុក្កំ និព្វានំ អភិជាយតិ ។ កថញ្ចានន្ទ សុក្កាភិជាតិយោ សមានោ កណ្ហំ ធម្មំ អភិជាយតិ ។ ឥធានន្ទ ឯកច្ចោ ឧច្ចេ កុលេ បច្ចាជាតោ ហោតិ ខត្តិយមហាសាលកុលេ វា ព្រាហ្មណ-មហាសាលកុលេ វា គហបតិមហាសាលកុលេ វា អឌ្ឍេ មហទ្ធនេ មហាភោគេ បហូតជាតរូបរជតេ បហូតវិត្តូបករណេ បហូតធនធញ្ញេ សោ ច ហោតិ អភិរូបោ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ លាភី អន្នស្ស បានស្ស វត្ថស្ស យានស្ស មាលាគន្ធវិលេបនស្ស សេយ្យាវសថបទីបេយ្យស្ស សោ កាយេន ទុច្ចរិតំ ចរតិ



ក៏ផុតលះនូវនីវរណធម៌ ៥ ប្រការ ដែលជាឧបក្កិលេសនៃចិត្តជាគ្រឿងធ្វើប្រាជ្ញាឲ្យថយកម្លាំង មានចិត្តតាំងខ្ជាប់ខ្ជួនក្នុងសតិប្បដ្ឋាន ៤ ចំរើនពោជ្ឈង្គ ៧ តាមសភាវៈ ហើយដល់នូវព្រះនិព្វានដែលជាធម៌មិនខ្មៅមិនស ។ ម្នាលអានន្ទ បុគ្គលអ្នកមានជាតិខ្មៅ ដល់នូវព្រះនិព្វាន ដែលជាធម៌មិនខ្មៅមិនស យ៉ាងនេះឯង ។ ម្នាលអានន្ទ ចុះបុគ្គលអ្នកមានជាតិស ប្រព្រឹត្តធម៌ខ្មៅ តើដូចម្តេច ។ ម្នាលអានន្ទ បុគ្គលខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយមហាសាល ឬត្រកូលព្រាហ្មណមហាសាល ត្រកូលគហបតិមហាសាល ជាត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ជាទីតាប់ចិត្តច្រើន មានធនធាននឹងធញ្ញាហារច្រើន បុគ្គលនោះ មានរូបល្អ គួរមើល គួរជ្រះថ្លា ប្រកបដោយសម្បុរដ៏ល្អក្រៃលែង ជាអ្នកស្ទាត់លាភ ចំពោះបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ នឹងគ្រឿងប្រទីប បុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ

វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ សោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ ឯវំ ខោ អានន្ទ សុក្កាភិជាតិយោ សមានោ កណ្ហំ ធម្មំ អភិជាយតិ ។ កថញ្ចានន្ទ សុក្កាភិជាតិយោ សមានោ សុក្កំ ធម្មំ អភិជាយតិ ។ ឥធានន្ទ ឯកច្ចោ ឧច្ចេ កុលេ បច្ចាជាតោ ហោតិ ខត្តិយមហាសាលកុលេ វា ។បេ។ សេយ្យាវសថបទីបេយ្យស្ស សោ កាយេន សុចរិតំ ចរតិ វាចាយ សុចរិតំ ចរតិ មនសា សុចរិតំ ចរតិ សោ កាយេន សុចរិតំ ចរិត្វា វាចាយ សុចរិតំ ចរិត្វា មនសា សុចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឯវំ ខោ អានន្ទ សុក្កាភិជាតិយោ សមានោ សុក្កំ ធម្មំ អភិជាយតិ ។ កថញ្ចានន្ទ សុក្កាភិជាតិយោ សមានោ អកណ្ហំ អសុក្កំ និព្វានំ អភិជាយតិ ។



ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ គ្រាបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលអានន្ទ បុគ្គលមានជាតិស ដែលប្រព្រឹត្តធម៌ខ្មៅ យ៉ាងនេះឯង ។ ម្នាលអានន្ទ ចុះបុគ្គលជាអ្នកមានជាតិស ប្រព្រឹត្តធម៌ស តើដូចម្តេច ។ ម្នាលអានន្ទ បុគ្គលពួកខ្លះក្នុងលោកនេះ មកកើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយមហាសាល ។បេ។ ជាអ្នកស្ទាត់លាភ ចំពោះទីដេក ទីនៅនិងគ្រឿងប្រទីប បុគ្គលនោះប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តហើយ គ្រាបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើត ក្នុងសុគតិសួគ៌ទេវលោក ។ ម្នាលអានន្ទ បុគ្គលអ្នកមានជាតិស ប្រព្រឹត្តធម៌ស យ៉ាងនេះឯង ។ ម្នាលអានន្ទ ចុះបុគ្គលមានជាតិស ដល់នូវព្រះនិព្វាន ដែលជាធម៌មិនខ្មៅមិនស តើយ៉ាងណា ។

ឥធានន្ទ ឯកច្ចោ ឧច្ចេ កុលេ បច្ចាជាតោ ហោតិ ខត្តិយមហាសាលកុលេ វា ព្រាហ្មណមហាសាលកុលេ វា គហបតិមហាសាលកុលេ វា អឌ្ឍេ មហទ្ធនេ មហាភោគេ បហូតជាតរូបរជតេ បហូតវិត្តូបករណេ បហូតធនធញ្ញេ សោ ច ហោតិ អភិរូបោ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណពោក្ខរតាយ សមន្នាគតោ លាភី អន្នស្ស បានស្ស វត្ថស្ស យានស្ស មាលាគន្ធវិលេបនស្ស សេយ្យាវសថបទីបេយ្យស្ស សោ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជតិ សោ ឯវំ បព្វជិតោ សមានោ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ ចតូសុ សតិបដ្ឋានេសុ សុប្បតិដ្ឋិតចិត្តោ សត្ត ពោជ្ឈង្គេ យថាភូតំ ភាវេត្វា អកណ្ហំ អសុក្កំ និព្វានំ អភិជាយតិ ។ ឯវំ ខោ អានន្ទ សុក្កាភិជាតិយោ សមានោ អកណ្ហំ អសុក្កំ និព្វានំ អភិជាយតិ ។ ឥមា ខោ អានន្ទ ឆឡាភិជាតិយោតិ ។



ម្នាលអានន្ទ បុគ្គលខ្លះ ក្នុងលោកនេះ មកកើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយមហាសាល ឬត្រកូលព្រាហ្មណមហាសាល ត្រកូលគហបតិមហាសាល ជាត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ជាទីតាប់ចិត្តច្រើន មានធនធាននិងធញ្ញជាតិច្រើន បុគ្គលនោះ ជាអ្នកមានរូបល្អ គួរមើល គួរជ្រះថ្លា ប្រកបដោយសម្បុរដ៏ល្អក្រៃលែង ជាអ្នកបានលាភចំពោះបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ និងគ្រឿងប្រទីប បុគ្គលនោះ បានកោរសក់ កោរពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាវព័ស្ត្រ ចេញចាកផ្ទះចូលកាន់ផ្នួស លុះបុគ្គលនោះបួស យ៉ាងនេះហើយ ក៏លះនូវនីវរណៈ ៥ ប្រការ ដែលជាឧបក្កិលេសនៃចិត្ត ជាគ្រឿងធ្វើប្រាជ្ញាឲ្យថយកំឡាំង មានចិត្តតាំងខ្ជាប់ក្នុងសតិប្បដ្ឋាន ៤ ចំរើនពោជ្ឈង្គ ៧ តាមសភាព ហើយដល់នូវព្រះនិព្វានដែលជាធម៌មិនខ្មៅមិនស ។ ម្នាលអានន្ទ បុគ្គលដែលមានជាតិ ស ដល់នូវព្រះនិព្វានដែលជាធម៌មិនខ្មៅមិនសយ៉ាងនេះឯង ។ ម្នាលអានន្ទ ជាតិ ៦ យ៉ាងនេះឯង ។

(៥៨) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុនោ យេ អាសវា សំវរា បហាតព្វា តេ សំវរេន បហីនា ហោន្តិ យេ អាសវា បដិសេវនា បហាតព្វា តេ បដិសេវនាយ បហីនា ហោន្តិ យេ អាសវា អធិវាសនា បហាតព្វា តេ អធិវាសនាយ បហីនា ហោន្តិ យេ អាសវា បរិវជ្ជនា បហាតព្វា តេ បរិវជ្ជនាយ បហីនា ហោន្តិ យេ អាសវា វិនោទនា បហាតព្វា តេ វិនោទនាយ បហីនា ហោន្តិ យេ អាសវា ភាវនា បហាតព្វា តេ ភាវនាយ បហីនា ហោន្តិ ។ កតមេ ច ភិក្ខវេ អាសវា សំវរា បហាតព្វា យេ សំវរេន បហីនា ហោន្តិ ។



(៥៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរទទួលនូវគ្រឿងដែលគេនាំមកបូជា គួរទទួលនូវគ្រឿងដែលគេរៀបចំទុកសំរាប់ភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរធ្វើអញ្ជលីកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយណា ដែលត្រូវលះបង់ ដោយការសង្រួម អាសវៈទាំងឡាយនោះ ភិក្ខុក្នុងសាសនានេះ បានលះបង់ហើយ ដោយការសង្រួម ១ អាសវៈទាំងឡាយណា ដែលត្រូវលះបង់ ដោយការសេព (នូវបច្ច័យ) អាសវៈទាំងឡាយនោះ ភិក្ខុបានលះបង់ហើយ ដោយការសេព ១ អាសវៈទាំងឡាយណា ដែលត្រូវលះបង់ ដោយការអត់ធន់ អាសវៈទាំងឡាយនោះ ភិក្ខុបានលះបង់ហើយ ដោយការអត់ធន់ ១ អាសវៈទាំងឡាយណា ដែលត្រូវលះបង់ ដោយការវៀរ អាសវៈទាំងឡាយនោះ ភិក្ខុបានលះបង់ហើយ ដោយការវៀរ ១ អាសវៈទាំងឡាយណា ដែលត្រូវលះបង់ ដោយការបន្ទោបង់ អាសវៈទាំងឡាយនោះ ភិក្ខុបានលះបង់ហើយដោយការបន្ទោបង់ ១ អាសវៈទាំងឡាយណា ដែលត្រូវលះបង់ ដោយការចំរើន អាសវៈទាំងឡាយនោះ ភិក្ខុបានលះបង់ហើយដោយការចំរើន ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះអាសវៈទាំងឡាយ ដូចម្តេច ដែលត្រូវលះបង់ ដោយការសង្រួម ភិក្ខុបានលះបង់ដោយការសង្រួម ។

ឥធ ភិក្ខវេ ភិក្ខុ បដិសង្ខា យោនិសោ ចក្ខុន្ទ្រិយសំវរសំវុតោ វិហរតិ ។ យំ ហិស្ស ភិក្ខវេ ចក្ខុន្ទ្រិយសំវរំ អសំវុតស្ស វិហរតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា ចក្ខុន្ទ្រិយសំវរំ សំវុតស្ស វិហរតោ ឯវំសុ តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ។ បដិសង្ខា យោនិសោ សោតិន្ទ្រិយ... ឃានិន្ទ្រិយ... ជិវ្ហិន្ទ្រិយ... កាយិន្ទ្រិយ... មនិន្ទ្រិយសំវរសំវុតោ វិហរតិ ។ យំ ហិស្ស ភិក្ខវេ មនិន្ទ្រិយសំវរំ អសំវុតស្ស វិហរតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា មនិន្ទ្រិយសំវរំ សំវុតស្ស វិហរតោ ឯវំសុ តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ។ យំ ហិស្ស ភិក្ខវេ សំវរំ អសំវុតស្ស វិហរតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា សំវរំ សំវុតស្ស វិហរតោ ឯវំសុ តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ។



ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយ ហើយសង្រួមនូវចក្ខុន្ទ្រិយសំវរៈ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មិនសង្រួមនូវចក្ខុន្ទ្រិយសំវរៈទេ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយ គប្បីកើតឡើងបាន បើភិក្ខុនោះ បានសង្រួមនូវចក្ខុន្ទ្រិយសំវរៈ អាសវៈ ដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយទាំងនោះ រមែងមិនមានដោយឧបាយយ៉ាងនេះ ។ ភិក្ខុពិចារណាដោយឧបាយហើយ សង្រួមនូវសោតិន្ទ្រិយ... ឃានិន្ទ្រិយ... ជិវ្ហិន្ទ្រិយ... កាយិន្ទ្រិយ... មនិន្ទ្រិយសំវរៈ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មិនសង្រួមនូវមនិន្ទ្រិយសំវរៈទេ អាសវៈទាំងឡាយ ដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយ គប្បីកើតឡើងបាន បើភិក្ខុនោះ បានសង្រួមនូវមនិន្ទ្រិយសំវរៈ អាសវៈដែលជាគ្រឿងចង្អៀតចង្អល់ក្តៅក្រហាយទាំងនោះ រមែងមិនមានដោយឧបាយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ភិក្ខុនោះមិនសង្រួមនូវសំវរៈទេ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយ គប្បីកើតឡើងបាន បើភិក្ខុនោះបានសង្រួមនូវសំវរៈ អាសវៈដែលជាគ្រឿងចង្អៀតចង្អល់ក្តៅក្រហាយទាំងនោះ រមែងមិនមានដោយឧបាយយ៉ាងនេះ ។

ឥមេ វុច្ចន្តិ ភិក្ខវេ អាសវា សំវរាបហាតព្វា យេ សំវរេន បហីនា ហោន្តិ ។ កតមេ ច ភិក្ខវេ អាសវា បដិសេវនាបហាតព្វា យេ បដិសេវនាយ បហីនា ហោន្តិ ។ ឥធ ភិក្ខវេ ភិក្ខុ បដិសង្ខា យោនិសោ ចីវរំ បដិសេវតិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរិំសប-សម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិន-បដិច្ឆាទនត្ថំ ។ បដិសង្ខា យោនិសោ បិណ្ឌបាតំ បដិសេវតិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច



ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាសវៈទាំងឡាយ ដែលត្រូវលះបង់ដោយការសង្រួម ភិក្ខុក៏បានលះបង់ ដោយការសង្រួម ។ ម្នាលភិក្ខុទាំងឡាយ ចុះអាសវៈទាំងឡាយដូចម្តេច ដែលត្រូវលះបង់ ដោយការសេព ភិក្ខុក៏បានលះបង់ដោយការសេព ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយហើយ ប្រើប្រាស់នូវចីវរ ដើម្បីការពារត្រជាក់ ដើម្បីការពារក្តៅ ដើម្បីការពារសម្ផស្សរបោម មូស ខ្យល់ កំដៅថ្ងៃ ពីងពស់តូច ពស់ធំទាំងឡាយដើម្បីបិទបាំងអវយវៈ ដែលធ្វើនូវសេចក្តីខ្មាសឲ្យកម្រើក ។ ពិចារណាដោយឧបាយហើយ បរិភោគនូវបិណ្ឌបាត មិនមែនដើម្បីលេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីឲ្យកើតបុរិសមានស្រវឹងដូចអ្នកប្រដាល់ក៏ទេ ដើម្បីប្រដាប់តាក់តែងកាយដូចស្រីគណិកាក៏ទេ ដើម្បីធ្វើឲ្យផូរផង់ពណ៌សម្បុរដូចអ្នករបាំក៏ទេ បរិភោគគ្រាន់តែដើម្បីឲ្យតាំងនៅនៃរាងកាយនេះ ដើម្បីញុំាងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចរិយធម៌ អាត្មានឹងកំចាត់បង់នូវវេទនាចាស់ គឺសេចក្តីស្រេកឃ្លាន ដែលមានហើយផង ញុំាងវេទនាថ្មីគឺឆ្អែតហួសប្រមាណមិនឲ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោស មានមិនប្រែប្រួលកាយ មិនប្រែប្រួលចិត្តជាដើមក្តី

ផាសុវិហារោ ចាតិ ។ បដិសង្ខា យោនិសោ សេនាសនំ បដិសេវតិ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសរីសប-សម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយ-វិនោទនំ បដិសល្លានារាមត្ថំ ។ បដិសង្ខា យោនិសោ គិលានប្បច្ចយភេសជ្ជបរិក្ខារំ បដិសេវតិ យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយ ។ យំ ហិស្ស ភិក្ខវេ អប្បដិសេវតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា បដិសេវតោ ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ។ ឥមេ វុច្ចន្តិ ភិក្ខវេ អាសវា បដិសេវនាបហាតព្វា យេ បដិសេវនាយ បហីនា ហោន្តិ ។ កតមេ ច ភិក្ខវេ អាសវា អធិវាសនាបហាតព្វា យេ អធិវាសនាយ បហីនា ហោន្តិ ។ ឥធ ភិក្ខវេ ភិក្ខុ បដិសង្ខា យោនិសោ ខមោ ហោតិ សីតស្ស ឧណ្ហស្ស ជិឃច្ឆាយ បិបាសាយ



កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមានដល់អញ ។ ពិចារណាដោយឧបាយហើយ ប្រើប្រាស់នូវសេនាសនៈ ដើម្បីការពារត្រជាក់ ដើម្បីការពារក្តៅ ដើម្បីការពារសម្ផស្ស របោម មូស ខ្យល់ កំដៅថ្ងៃ នឹងពស់តូចពស់ធំទាំងឡាយ ដើម្បីបន្ទោបង់នូវអន្តរាយ ដែលកើតអំពីរដូវ ហើយត្រេកអរសម្ងំនៅក្នុងទីព្រាត់ស្ងាត់ ។ ពិចារណាដោយឧបាយហើយ ប្រើប្រាស់នូវគ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកជម្ងឺ ដើម្បីការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខទាំងផង ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ មិនសេព ( នូវបច្ច័យណាមួយដោយឧបាយ ) ទេ អាសវៈទាំងឡាយ ដែលជាគ្រឿងបៀតបៀនផង ក្តៅក្រហាយ គប្បីកើតឡើងបាន បើភិក្ខុនោះបានសេព ( នូវបច្ច័យណាមួយដោយឧបាយ ) អាសវៈដែលជាគ្រឿងបៀតបៀនផង ក្តៅក្រហាយទាំងនោះ រមែងមិនមានដោយឧបាយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាសវៈទាំងឡាយ ដែលត្រូវលះបង់ដោយការសេព ភិក្ខុក៏បានលះបង់ដោយការសេព ។ ម្នាលភិក្ខុទាំងឡាយ ចុះអាសវៈទាំងឡាយដូចម្តេច ដែលត្រូវលះបង់ ដោយការអត់ធន់ ភិក្ខុក៏បានលះបង់ដោយការអត់ធន់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយហើយ អត់ធន់នូវត្រជាក់ក្តៅ ឃ្លាន ស្រេក

ទំសមកសវាតាតបសិរីសបសម្ផស្សានំ ទុរុត្តានំ ទុរា-
គតានំ វចនបថានំ ឧប្បន្នានំ សារីរិកានំ វេទនានំ
ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនា-
បានំ បាណហរានំ អធិវាសកជាតិកោ ហោតិ ។
យំ ហិស្ស ភិក្ខវេ អនធិវាសយតោ ឧប្បជ្ជេយ្យុំ អាសវា
វិឃាតបរិឡាហា អធិវាសយតោ ឯវំស តេ អាសវា
វិឃាតបរិឡាហា ន ហោន្តិ ។ ឥមេ វុច្ចន្តិ ភិក្ខវេ
អាសវា អធិវាសនាបហាតព្វា យេ អធិវាសនាយ
បហីនា ហោន្តិ ។ កតមេ ច ភិក្ខវេ អាសវា
បរិវជ្ជនាបហាតព្វា យេ បរិវជ្ជនាយ បហីនា ហោន្តិ ។
ឥធ ភិក្ខវេ ភិក្ខុ បដិសង្ខា យោនិសោ ចណ្ឌហត្ថឹ
បរិវជ្ជេតិ ចណ្ឌអស្សំ បរិវជ្ជេតិ ចណ្ឌគោណំ បរិវជ្ជេតិ
ចណ្ឌកុក្កុរំ បរិវជ្ជេតិ អហឹ ខាណុំ កណ្ដកដ្ឋានំ



ជាបុគ្គលអត់ធន់ចំពោះសម្ផស្ស របោម មូស ខ្យល់ កំដៅថ្ងៃនឹងសត្វលូន
ពស់ទាំងឡាយ នឹងពាក្យទ្រគោះ អាក្រក់ដែលគេស្រដីនូវសរីរៈជា
ទុក្ខក្លាខ្លាំងខ្លោចផ្សាមិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត ជាវេទនាអាច
នាំយកជីវិតទៅបានដែលកើតឡើងហើយ ។ ម្នាលភិក្ខុទាំងឡាយ កាល
បើភិក្ខុនោះ មិនអត់ធន់ (ចំពោះហេតុណាមួយទេ) អាសវៈទាំងឡាយ
ដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយ គប្បីកើតឡើងបាន បើភិក្ខុ
នោះបានអត់ធន់ (នូវហេតុណាមួយ) អាសវៈដែលជាគ្រឿងចង្អៀត
ចង្អល់ក្តៅក្រហាយទាំងនោះ រមែងមិនមានដល់ភិក្ខុយ៉ាងនេះ ។
ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាសវៈដែលត្រូវលះបង់ ដោយការ
អត់ធន់ ភិក្ខុក៏បានលះបង់ដោយការអត់ធន់ ។ ម្នាលភិក្ខុទាំងឡាយ
ចុះអាសវៈទាំងឡាយដូចម្តេច ដែលត្រូវលះបង់ ដោយការវៀរ ភិក្ខុបាន
លះបង់ ដោយការវៀរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ
ពិចារណាដោយឧបាយ ហើយចៀសវាងដំរីកាច ចៀសវាងសេះកាច
ចៀសវាងគោកាច ចៀសវាងឆ្កែកាច ពស់ គល់ឈើ ព្រៃបន្លា

សោព្ភំ បបាតំ ចន្ទនិកំ ឱឡិគល្លំ ។ យថារូបេ អនាសនេ និសិន្នំ យថារូបេ អគោចរេ ចរន្តំ យថារូបេ បាបកេ មិត្តេ ភជន្តំ វិញ្ញូ សព្រហ្មចារី បាបកេសុ ឋានេសុ ឱកប្បេយ្យុំ សោ តញ្ច អនាសនំ តញ្ច អគោចរំ តេ ច បាបកេ មិត្តេ បដិសង្ខា យោនិសោ បរិវជ្ជេតិ ។ យំ ហិស្ស ភិក្ខវេ អបរិវជ្ជយតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា បរិវជ្ជយតោ ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ។ ឥមេ វុច្ចន្តិ ភិក្ខវេ អាសវា បរិវជ្ជនាបហាតព្វា យេ បរិវជ្ជនាយ បហីនា ហោន្តិ ។ កតមេ ច ភិក្ខវេ អាសវា វិនោទនាបហាតព្វា យេ វិនោទនាយ បហីនា ហោន្តិ ។ ឥធ ភិក្ខវេ ភិក្ខុ បដិសង្ខា យោនិសោ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ បដិសង្ខា យោនិសោ ឧប្បន្នំ ព្យាបាទវិតក្កំ ។ បេ ។ ឧប្បន្នំ វិហឹសាវិតក្កំ...



អណ្ដូង ជ្រោះ រណ្ដៅទឹកសំអុយ ទីជ្រៅប្រឡាយទឹកសំអុយ ។ ពួកសព្រហ្មចារីទាំងឡាយជាអ្នកដឹង គប្បីកំណត់ទុកនូវបុគ្គលដែលអង្គុយលើអាសនៈមិនសមគួរ យ៉ាងណា ដែលត្រាច់ទៅក្នុងទីមិនសមគួរ យ៉ាងណា ដែលសេពគប់នូវពួកបាបមិត្រ យ៉ាងណា ថាដូចជាទីអាក្រក់ ភិក្ខុនោះពិចារណាដោយឧបាយ ហើយវៀរចាកនូវអាសនៈមិនសមគួរនោះផង ទីគោចរមិនសមគួរនោះផង ពួកបាបមិត្តនោះផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មិនវៀរចាក (នូវហេតុណាមួយ)ទេ អាសវៈទាំងឡាយ ដែលជាគ្រឿងចង្អៀតចង្អល់ ក្ដៅក្រហាយ គប្បីកើតឡើងបាន បើភិក្ខុនោះ បានវៀរចាក (នូវហេតុណាមួយ) អាសវៈដែលជាគ្រឿងចង្អៀតចង្អល់ក្ដៅក្រហាយទាំងនោះ រមែងមិនមានដោយឧបាយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាសវៈ ដែលត្រូវលះបង់ដោយការវៀរចាក ភិក្ខុក៏បានលះបង់ដោយការវៀរចាក ។ ម្នាលភិក្ខុទាំងឡាយ ចុះអាសវៈទាំងឡាយដូចម្ដេច ដែលត្រូវលះបង់ ដោយការបន្ទោបង់ ភិក្ខុក៏បានលះបង់ ដោយការបន្ទោបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយ ហើយអត់ធន់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យកើតមាននូវកាមវិតក្កៈដែលកើតឡើង នូវព្យាបាទវិតក្កៈដែលកើតឡើង ។បេ។ នូវវិហឹសាវិតក្កៈដែលកើតឡើង...

ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ ។ យំ ហិស្ស ភិក្ខវេ អវិនោទយតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា វិនោទយតោ ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ។ ឥមេ វុច្ចន្តិ ភិក្ខវេ អាសវា វិនោទនាបហាតព្វា យេ វិនោទនាយ បហីនា ហោន្តិ ។ កតមេ ច ភិក្ខវេ អាសវា ភាវនាបហាតព្វា យេ ភាវនាយ បហីនា ហោន្តិ ។ ឥធ ភិក្ខវេ ភិក្ខុ បដិសង្ខា យោនិសោ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ បដិសង្ខា យោនិសោ ធម្មវិចយសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។ វីរិយសម្ពោជ្ឈង្គំ ភាវេតិ បីតិសម្ពោជ្ឈង្គំ ភាវេតិ បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេតិ សមាធិសម្ពោជ្ឈង្គំ ភាវេតិ ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។



អត់ធន់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស បំផ្លាញនូវពួកអកុសលធម៌លាមកដែលកើតឡើងហើយៗ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះមិនបន្ទោបង់ (នូវវិតក្កៈណាមួយ) ទេ អាសវៈទាំងឡាយ ដែលជាគ្រឿងចង្អៀតចង្អល់ក្ដៅក្រហាយ គប្បីកើតឡើងបាន បើភិក្ខុនោះ បានបន្ទោបង់ (នូវវិតក្កៈណាមួយ) អាសវៈដែលជាគ្រឿងចង្អៀតចង្អល់ក្ដៅក្រហាយទាំងនោះ រមែងមិនមានដោយឧបាយយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាសវៈទាំងឡាយ ដែលត្រូវលះដោយការបន្ទោបង់ ភិក្ខុក៏បានលះដោយការបន្ទោបង់ ។ ម្នាលភិក្ខុទាំងឡាយ ចុះអាសវៈទាំងឡាយដូចម្ដេច ដែលត្រូវលះដោយការចំរើន ភិក្ខុក៏បានលះបង់ដោយការចំរើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយ ហើយចំរើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្ដីស្ងប់ស្ងាត់ អាស្រ័យនូវធម៌ជាគ្រឿងប្រាសចាករាគៈ អាស្រ័យធម៌ជាទីរលត់ទុក្ខ ជាធម៌បង្អោនទៅដើម្បីលះកិលេស ពិចារណាដោយឧបាយ ហើយចំរើនធម្មវិចយសម្ពោជ្ឈង្គ ។ បេ ។ ចំរើនវីរិយសម្ពោជ្ឈង្គ ចំរើនបីតិសម្ពោជ្ឈង្គ ចំរើនបស្សទ្ធិសម្ពោជ្ឈង្គ ចំរើនសមាធិសម្ពោជ្ឈង្គ ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្ដីស្ងប់ស្ងាត់ អាស្រ័យធម៌ជាទីប្រាសចាករាគៈ អាស្រ័យធម៌ជាទីរលត់ទុក្ខជាធម៌បង្អោនទៅ ដើម្បីលះកិលេស ។

យំ ហិស្ស ភិក្ខវេ អភាវយតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា ភាវយតោ ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ។ ឥមេ វុច្ចន្តិ ភិក្ខវេ អាសវា ភាវនាបហាតព្វា យេ ភាវនាយ បហីនា ហោន្តិ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

(៥៩) ឯកំ សមយំ ភគវា ញាតិកេ វិហរតិ គិញ្ជកាវសថេ ។ អថខោ ទារុកម្មិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ទារុកម្មិកំ គហបតិំ ភគវា ឯតទវោច អបិ នុ តេ គហបតិ កុលេ ទានំ ទីយតីតិ ។

៦៦៣
ទុតិយបណ្ណាសក មហាវគ្គ

ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មិនចំរើន (សមាធិឬបញ្ញាណាមួយ) ទេ អាសវៈទាំងឡាយ ដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយ គប្បីកើតឡើងបាន បើភិក្ខុនោះបានចំរើន (សមាធិឬបញ្ញាណាមួយ) អាសវៈ ដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយទាំងនោះ ក៏មិនមានដល់ភិក្ខុយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាសវៈទាំងឡាយ ដែលត្រូវលះដោយការចំរើន ភិក្ខុក៏បានលះបង់ដោយការចំរើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកគួរទទួលនូវវត្ថុដែលគេនាំមកបូជា គួរទទួលនូវវត្ថុដែលគេរៀបទទួលភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរធ្វើនូវអញ្ជលីកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

(៥៩) សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទ ដែលធ្វើអំពីឥដ្ឋ ក្នុងញាតិកគ្រាម ។ គ្រានោះឯង គហបតីឈ្មោះទារុកម្មិកៈ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះទារុកម្មិក-គហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរដូច្នេះថា ម្នាលគហបតី ចុះទានក្នុងត្រកូលអ្នកនៅតែឲ្យដែរឬ ។

ទីយតិ មេ ភន្តេ កុលេ ទានំ តញ្ច ខោ យេ តេ ភិក្ខូ អារញ្ញកា បិណ្ឌបាតិកា បំសុកូលិកា អរហន្តោ វា អរហត្តមគ្គំ វា សមាបន្នា តថារូបេសុ ភន្តេ ភិក្ខូសុ ទានំ ទីយតីតិ ។ ទុជ្ជានំ ខោ ឯតំ គហបតិ តយា គិហិនា កាមភោគិនា បុត្តសម្ពាធសយនំ អជ្ឈាវសន្តេន កាសិកចន្ទនំ បច្ចនុភោន្តេន មាលាគន្ធវិលេបនំ ធារយន្តេន ជាតរូបរជតំ សាទិយន្តេន ឥមេ វា អរហន្តោ ឥមេ វា អរហត្តមគ្គំ សមាបន្នាតិ ។ អារញ្ញកោ ចេបិ គហបតិ ភិក្ខុ ហោតិ ឧទ្ធតោ ឧន្នឡោ ចបលោ មុខរោ វិកិណ្ណវាចោ មុដ្ឋស្សតិ អសម្បជានោ អសមាហិតោ វិព្ភន្តចិត្តោ បាកតិន្ទ្រិយោ ឯវំ សោ តេនង្គេន គារយ្ហោ ។ អារញ្ញកោ ចេបិ គហបតិ ភិក្ខុ ហោតិ អនុទ្ធតោ អនុន្នឡោ អចបលោ អមុខរោ អវិកិណ្ណវាចោ



ទារុកម្មិកគហបតី ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ទានក្នុងត្រកូលខ្ញុំព្រះអង្គតែងឱ្យ បពិត្រព្រះអង្គដ៏ចំរើន តែថាទាននោះ ខ្ញុំព្រះអង្គឱ្យចំពោះតែពួកភិក្ខុ ដែលជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គ ប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ប្រព្រឹត្តបំសុកូលិកធុតង្គ ជាព្រះអរហន្ត ឬភិក្ខុដែលដល់នូវអរហត្តមគ្គប៉ុណ្ណោះ ។ ម្នាលគហបតី ខ្លួនអ្នក ជាគ្រហស្ថជាអ្នកបរិភោគកាម នៅគ្រប់គ្រងនូវដំណេកដ៏ចង្អៀតដោយកូនប្រពន្ធ ប្រើប្រាស់នូវខ្លឹមចន្ទន៍ដ៏ល្អិត ទ្រទ្រង់នូវកម្រងផ្កា គ្រឿងក្រអូបនិងគ្រឿងលាប ត្រេកអរនូវមាសនិងប្រាក់ កម្រនឹងដឹងថាពួកនេះ ភិក្ខុទាំងនេះ ជាព្រះអរហន្ត ឬ ភិក្ខុទាំងនេះ បានដល់នូវអរហត្តមគ្គនេះបានហើយ ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តអារញ្ញិកធុតង្គ ប៉ុន្តែមានចិត្តរាយមាយ ជាអ្នកលើកកំពស់ មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានសំដីផ្តេសផ្តាស ជាអ្នកភ្លេចស្មារតី មិនមានសម្បជញ្ញៈ មិនមានចិត្តតាំងមាំ មានចិត្តវិលវល់ មានឥន្ទ្រិយជាប្រក្រតី កាលបើយ៉ាងនេះ ភិក្ខុនោះគួរគេតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តអារញ្ញិកធុតង្គ ប៉ុន្តែជាអ្នកមានចិត្តមិនរាយមាយ ជាអ្នកមិនលើកកំពស់ មិនមានចិត្តឃ្លេងឃ្លោង មិនមានមាត់រឹង មិនមានវាចាផ្តេសផ្តាស

ឧបដ្ឋិតស្សតិ សម្បជានោ សមាហិតោ ឯកគ្គចិត្តោ សំវុតិន្ទ្រិយោ ឯវំ សោ តេនង្គេន បាសំសោ ។ គាមន្តវិហារី ចេបិ គហបតិ ភិក្ខុ ហោតិ ទុដ្ឋោ ។បេ។ ឯវំ សោ តេនង្គេន គារយ្ហោ ។ គាមន្តវិហារី ចេបិ គហបតិ ភិក្ខុ ហោតិ អទុដ្ឋោ ។បេ។ ឯវំ សោ តេនង្គេន បាសំសោ ។ បិណ្ឌបាតិកោ ចេបិ គហបតិ ភិក្ខុ ហោតិ ទុដ្ឋោ ។បេ។ ឯវំ សោ តេនង្គេន គារយ្ហោ ។ បិណ្ឌបាតិកោ ចេបិ គហបតិ ភិក្ខុ ហោតិ អទុដ្ឋោ ។បេ។ ឯវំ សោ តេនង្គេន បាសំសោ ។ នេមន្តនិកោ ចេបិ គហបតិ ភិក្ខុ ហោតិ ទុដ្ឋោ ។បេ។ ឯវំ សោ តេនង្គេន គារយ្ហោ ។ នេមន្តនិកោ ចេបិ គហបតិ ភិក្ខុ ហោតិ អទុដ្ឋោ ។បេ។ ឯវំ សោ តេនង្គេន បាសំសោ ។



មានស្មារតីខ្ជាប់ខ្ជួន មានសម្បជញ្ញៈ មានចិត្តដំកល់មាំ មានចិត្តមូលតែ ១ ជាអ្នកសង្រួមឥន្ទ្រិយ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរសរសើរដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកនៅក្នុងសេនាសនៈជិតស្រុក ប៉ុន្តែជាអ្នកមានចិត្តកាយខាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកនៅក្នុងសេនាសនៈជិតស្រុក ប៉ុន្តែជាអ្នកមានចិត្តមិនកាយខាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរសរសើរដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ប៉ុន្តែជាអ្នកមានចិត្តកាយខាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ប៉ុន្តែជាអ្នកមានចិត្តមិនកាយខាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរសរសើរដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកទទួលនិមន្តគេ ប៉ុន្តែជាអ្នកមានចិត្តកាយខាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកទទួលនិមន្តគេ ប៉ុន្តែជាអ្នកមិនមានចិត្តកាយខាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរសរសើរដោយហេតុនោះបាន ។

បំសុកូលិកោ ចេបិ គហបតិ ភិក្ខុ ហោតិ ឧទ្ធតោ ៗបេៗ ឯវំ សោ តេនង្គេន គារយ្ហោ បំសុកូលិកោ ចេបិ គហបតិ ភិក្ខុ ហោតិ អនុទ្ធតោ ៗបេៗ ឯវំ សោ តេនង្គេន បាសំសោ ។ គហបតិចីវរកោ ចេបិ គហបតិ ភិក្ខុ ហោតិ ឧទ្ធតោ ឧន្នឡោ ចបលោ មុខរោ វិកិណ្ណវាចោ មុដ្ឋស្សតិ អសម្បជានោ អសមាហិតោ វិព្ភន្តចិត្តោ បាកតិន្ទ្រិយោ ឯវំ សោ តេនង្គេន គារយ្ហោ ។ គហបតិចីវរកោ ចេបិ គហបតិ ភិក្ខុ ហោតិ អនុទ្ធតោ អនុន្នឡោ អចបលោ អមុខរោ អវិកិណ្ណវាចោ ឧបដ្ឋិតស្សតិ សម្បជានោ សមាហិតោ ឯកគ្គចិត្តោ សំវុតិន្ទ្រិយោ ឯវំ សោ តេនង្គេន បាសំសោ ។ ឥង្ឃ ត្វំ គហបតិ សង្ឃេ ទានំ ទេហិ សង្ឃេ តេ ទានំ ទទតោ ចិត្តំ បសីទិស្សតិ សោ ត្វំ បសន្នចិត្តោ



ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តបំសុកូលិកង្គ ប៉ុន្តែជាអ្នកមានចិត្តរាយមាយ ។ បេ ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តបំសុកូលិកង្គ ប៉ុន្តែជាអ្នកមិនមានចិត្តរាយមាយ ។ បេ ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរសរសើរដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តនូវគហបតិចីវរ ប៉ុន្តែជាអ្នកមានចិត្តរាយមាយ ជាអ្នកលើកកំពស់ មានចិត្តឃ្មើងឃ្មោង មានមាត់រឹង មានសំដីផ្ដេសផ្ដាស ជាអ្នកភ្លេចភ្លាំងស្មារតី មិនមានសម្បជញ្ញៈ មានចិត្តមិនខ្ជាប់ខ្ជួន មានចិត្តវិលវល់ មានឥន្ទ្រិយជាប្រក្រតី កាលបើយ៉ាងនេះ ភិក្ខុនោះ គួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តនូវគហបតិចីវរ ប៉ុន្តែជាអ្នកមិនមានចិត្តរាយមាយ មិនលើកកំពស់ មិនមានចិត្តឃ្មើងឃ្មោង មិនមានមាត់រឹង មិនមានសំដីផ្ដេសផ្ដាស មានស្មារតីខ្ជាប់ខ្ជួន មានសម្បជញ្ញៈ មានចិត្តដំកល់មាំ មានចិត្តមូលតែមួយ ជាអ្នកសង្រួមឥន្ទ្រិយ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរសរសើរដោយហេតុនោះបាន ។ ម្នាលគហបតី អញ្ជើញអ្នកឲ្យទានចំពោះសង្ឃវិញ កាលបើអ្នកឲ្យទានចំពោះសង្ឃហើយ ចិត្តនឹងជ្រះថ្លា លុះអ្នកនោះមានចិត្តជ្រះថ្លាហើយ

កាយស្ស ភេទា បរម្មរណា សុគតិំ សគ្គំ លោកំ ឧបបជ្ជិស្សសីតិ ។ ឯសាហំ ភន្តេ អជ្ជតគ្គេ សាវេជ្ជ ជាតានិ ឆស្សាមីតិ ។

(៦០) ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ ។ តេន ខោ បន សមយេន សម្ពហុលា ថេរា ភិក្ខូ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា មណ្ឌលមាឡេ សន្និសិន្នា សន្និបតិតា អភិធម្មកថំ កថេន្តិ ។ តត្រ សុទំ អាយស្មា ចិត្តោ ហត្ថិសារិបុត្តោ ថេរានំ ភិក្ខូនំ អភិធម្មកថំ កថេន្តានំ អន្តរន្តរា កថំ ឱបាតេតិ ។ អថខោ អាយស្មា មហាកោដ្ឋិកោ អាយស្មន្តំ ចិត្តំ ហត្ថិសារិបុត្តំ ឯតទវោច(១) អាយស្មា ចិត្តោ ហត្ថិសារិបុត្តោ ថេរានំ ភិក្ខូនំ អភិធម្មកថំ កថេន្តានំ អន្តរន្តរា កថំ ឱបាតេតិ(២) យាវ កថាបរិយោសានំ អាយស្មា ចិត្តោ ហត្ថិសារិបុត្តោ អាគមេតូតិ ។ ឯវំ វុត្តេ អាយស្មតោ ចិត្តស្ស ហត្ថិសារិបុត្តស្ស សហាយកា ភិក្ខូ អាយស្មន្តំ មហាកោដ្ឋិកំ ឯតទវោចុំ

១ ៖ ឯក្ខរ មតិ ទិស្សតិ ។ ២ ឱ. ម. ឱបាតេសិ ។



ព្រោះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក ទារុកម្មិកគហបតីក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ចាប់ដើមអំពីថ្ងៃនេះទៅ ខ្ញុំព្រះអង្គមិនដឹង នឹងនាំចេញការសេព្យវិញ ។

(៦០) សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ សម័យនោះឯង ពួកភិក្ខុជាថេរៈច្រើនរូប ត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាក្រោយភត្ត ហើយអង្គុយប្រជុំគ្នានិយាយអភិធម្មកថា ក្នុងរោងមូល (មណ្ឌលសាលា) ។ បានឮថា បណ្តាពួកភិក្ខុទាំងនោះ ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុ កាលដែលពួកភិក្ខុជាថេរៈ កំពុងនិយាយអភិធម្មកថា ក៏និយាយកាត់ពាក្យក្នុងចន្លោះៗ លំដាប់នោះ ព្រះមហាកោដ្ឋិកៈដ៏មានអាយុ បាននិយាយនឹងព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុយ៉ាងនេះថា ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុ កាលដែលពួកភិក្ខុជាថេរៈ កំពុងនិយាយអភិធម្មកថា បែរជានិយាយកាត់ពាក្យក្នុងចន្លោះ ៗ ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុ សូមបង្អង់ចាំចប់អភិធម្មកថាសិន ។ កាលបើព្រះមហាកោដ្ឋិកៈដ៏មានអាយុនិយាយយ៉ាងនេះហើយ ពួកភិក្ខុជាសំឡាញ់របស់ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុ ក៏បាននិយាយនឹងព្រះមហាកោដ្ឋិកៈដ៏មានអាយុយ៉ាងនេះថា

អាយស្មា មហាកោដ្ឋិកោ អាយស្មន្តំ ចិត្តំ ហត្ថិសារីបុត្តំ អបសាទេតិ បណ្ឌិតោ អាយស្មា ចិត្តោ ហត្ថិសារីបុត្តោ បហោតិ អាយស្មា ចិត្តោ ហត្ថិសារីបុត្តោ ចេភនំ ភិក្ខូនំ អភិធម្មកថំ កថេតុន្តិ ។ ទុជ្ជានំ ខោ ឯតំ អាវុសោ បរស្ស ចេតោបរិយាយំ អជានន្តេហិ ។ ឥធាវុសោ ឯកច្ចោ បុគ្គលោ តាវទេវ សោរតសោរតោ ហោតិ និវាតនិវាតោ ហោតិ ឧបសន្តុបសន្តោ ហោតិ យាវ សត្ថារំ ឧបនិស្សាយ វិហរតិ អញ្ញតរំ វា គរុដ្ឋានិយំ សព្រហ្មចារឹ ។ យតោ ច ខោ សោ វបកស្សតេវ សត្ថារា វបកស្សតិ គរុដ្ឋានិយេហិ សព្រហ្មចារីហិ សោ សំសដ្ឋោ វិហរតិ ភិក្ខូហិ ភិក្ខុនីហិ ឧបាសកេហិ ឧបាសិកាហិ រញ្ញោ រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ តស្ស សំសដ្ឋស្ស វិស្សដ្ឋស្ស បាកដស្ស ភស្សមនុយុត្តស្ស វិហរតោ រាគោ ចិត្តំ អនុទ្ធំសេតិ សោ រាគានុទ្ធំសិតេន ចិត្តេន សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។



ព្រះមហាកោដ្ឋិកៈដ៏មានអាយុ មិនសមបើហាមឃាត់ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុសោះ (ព្រោះ) ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុ ជាអ្នកប្រាជ្ញ ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុ អាចសំដែងនូវអភិធម្មកថា ជាមួយនឹងពួកភិក្ខុជាប្រាកដ ។ ព្រះមហាកោដ្ឋិកៈដ៏មានអាយុ បាននិយាយថា ម្នាលអាវុសោទាំងឡាយ ពួកជនដែលមិនដឹងនូវវារៈនៃចិត្តរបស់ជនដទៃ ក្រនឹងដឹងបាន ។ ម្នាលអាវុសោទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ កាលនៅអាស្រ័យនឹងគ្រូ ឬសព្រហ្មចារី គួរជាទីគោរពណាមួយនៅឡើយ រមែងជាអ្នកស្ងួតបូតណាស់ ជាអ្នករាបទាបណាស់ ជាអ្នកស្រងត់ស្រងំណាស់ ។ លុះកាលណាភិក្ខុនោះ ចេញអំពីគ្រូ ចេញអំពីពួកសព្រហ្មចារី គួរជាទីគោរព ភិក្ខុនោះក៏ត្រឡប់ជានៅច្រឡូកច្រឡំ ដោយពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ព្រះរាជា ពួកអាមាត្យធំនៃព្រះរាជា ពួកតិរ្ថិយ នឹងពួកសាវ័កនៃតិរ្ថិយវិញ កាលដែលភិក្ខុនោះ នៅច្រឡូកច្រឡំ លះបង់ (ការយាមល្អ) មានឥន្ទ្រិយជាប្រក្រតី គឺមិនសង្រួមឥន្ទ្រិយ ខ្វល់ខ្វាយតែនិយាយពាក្យឥតន័យ រាគៈក៏គ្របសង្កត់ចិត្ត លុះភិក្ខុនោះ ត្រូវរាគៈគ្របសង្កត់ចិត្តហើយ រមែងលាចាកសិក្ខា វិលត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ។

សេយ្យថាបិ អាវុសោ គោណោ កិដ្ឋាទោ ទាមេន វា ពទ្ធោ វជេ វា រុទ្ធោ យោ នុ ខោ អាវុសោ ឯវំ វទេយ្យ ន ទានាយំ គោណោ កិដ្ឋាទោ បុនទេវ កិដ្ឋំ ឱតរិស្សតីតិ សម្មា នុ ខោ សោ អាវុសោ វទមានោ វទេយ្យាតិ ។ នោ ហិទំ អាវុសោ ឋានញ្ហេតំ អាវុសោ វិជ្ជតិ យំ សោ គោណោ កិដ្ឋាទោ ទាមំ វា ឆេត្វា វជំ វា ភិន្ទិត្វា អថ បុនទេវ កិដ្ឋំ ឱតរេយ្យាតិ ។ ឯវមេវ ខោ អាវុសោ ឥធេកច្ចោ បុគ្គលោ តាវទេវ សោរតសោរតោ ហោតិ និវាតនិវាតោ ហោតិ ឧបសន្តុបសន្តោ ហោតិ យាវ សត្ថារំ ឧបនិស្សាយ វិហរតិ អញ្ញតរំ វា គរុដ្ឋានិយំ សព្រហ្មចារឹ ។ យតោ ច ខោ សោ វូបកស្សតោ សត្ថារា វូបកស្សតិ គរុដ្ឋានិយេហិ សព្រហ្មចារីហិ សោ សំសដ្ឋោ វិហរតិ ភិក្ខូហិ ភិក្ខុនីហិ ឧបាសកេហិ ឧបាសិកាហិ



ម្នាលអាវុសោទាំងឡាយ ដូចជាគោ (ឈ្មោល) ស៊ីសំណាប គេចងទុកដោយខ្សែ ឬគេក្រៀកទុកក្នុងក្រោល ម្នាលអាវុសោទាំងឡាយ បើបុគ្គលណា គប្បីនិយាយយ៉ាងនេះថា គោ (ឈ្មោល) ស៊ីសំណាបនេះ មុខជាមិនហ៊ានចុះ (ស៊ី) សំណាប ក្នុងកាលខាងមុខទៀតឡើយ តើអាវុសោទាំងឡាយ តើបុគ្គលនោះ ឈ្មោះថា គប្បីនិយាយសមតាមហេតុឬទេ ។ ពួកភិក្ខុតបថា ម្នាលអាវុសោ មិនសមតាមហេតុទេ ម្នាលអាវុសោ ព្រោះថាហេតុនុ៎ះ រមែងមាន ត្រង់ដែលគោឈ្មោលស៊ីសំណាបនោះ មុខជាផ្តាច់ខ្សែ ឬ ទំលាយក្រោល ហើយចុះ (ស៊ី) សំណាប ក្នុងកាលជាខាងក្រោយវិញទៀត ។ ព្រះមហាកោដ្ឋិតៈដ៏មានអាយុពោលថា ម្នាលអាវុសោទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ក៏យ៉ាងនឹងនោះដែរ កាលនៅអាស្រ័យនឹងគ្រូ ឬសព្រហ្មចារី អ្នកជាទីគោរពណាមួយនៅឡើយ រមែងជាអ្នកស្លូតបូតណាស់ ជាអ្នកសភាពរាបទាបណាស់ ជាអ្នកស្រគត់ស្រគំណាស់ ។ លុះកាលណាភិក្ខុនោះ ចេញអំពីគ្រូ ចេញអំពីពួកសព្រហ្មចារី អ្នកជាទីគោរព ភិក្ខុនោះ ក៏ត្រឡប់ជានៅច្របូកច្របល់ ដោយពួកភិក្ខុ ភិក្ខុនី ពួកឧបាសក ឧបាសិកា

រញ្ញា រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ តស្ស សំសដ្ឋស្ស វិស្សដ្ឋស្ស បាកតស្ស ភស្សមនុយុត្តស្ស វិហរតោ រាគោ ចិត្តំ អនុទ្ធំសេតិ សោ រាគានុទ្ធំសិតេន ចិត្តេន សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ ឥធ បនាវុសោ ឯកច្ចោ បុគ្គលោ វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ សោ លាភិម្ហិ បឋមស្ស ឈានស្សាតិ សំសដ្ឋោ វិហរតិ ភិក្ខូហិ ។បេ។ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ សេយ្យថាបិ អាវុសោ ចាតុម្មហាបថេ ថុល្លផុសិតកោ ទេវោ វស្សន្តោ រជំ អន្តរធាបេយ្យ ចិក្ខល្លំ បាតុភាវេយ្យ យោ នុ ខោ អាវុសោ ឯវំ វទេយ្យ នទានិ អមុស្មឹ ចាតុម្មហាបថេ បុនទេវ រជោ បាតុភវិស្សតីតិ សម្មា នុ ខោ សោ អាវុសោ វទមានោ វទេយ្យាតិ ។ នោ ហិទំ អាវុសោ ឋានញ្ហេតំ អាវុសោ វិជ្ជតិ យំ អមុស្មឹ ចាតុម្មហាបថេ មនុស្សា វា អតិក្កមេយ្យុំ គោបសូ វា អតិក្កមេយ្យុំ វាតាតបោ វា សិនេហគតំ បរិយាទិយេយ្យ អថ បុនទេវ រជោ បាតុភវេយ្យាតិ ។



ព្រះរាជា អាមាត្យធំរបស់ព្រះរាជា ពួកតិរ្ថិយ និងសាវកនៃតិរ្ថិយវិញ កាលដែលភិក្ខុនោះ នៅច្រឡូកច្របល់ លះបង់អាចារយាទល្អ មានឥន្ទ្រិយជាប្រក្រតី ខ្វល់ខ្វាយ តែនិយាយពាក្យទ្រើយទ្រឹង រាគៈក៏គ្របសង្កត់ចិត្ត លុះភិក្ខុនោះ ត្រូវរាគៈគ្របសង្កត់ចិត្តហើយ រមែងលាខ្លួនសិក្ខាវិលត្រឡប់ទៅកាន់ភេទជាគ្រហស្ថវិញ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានចូលកាន់បឋមជ្ឈាន បុគ្គលនោះ គិតថា អញជាអ្នកបានបឋមជ្ឈានដូច្នេះ ហើយនៅច្រឡូកច្របល់ ដោយពួកភិក្ខុ ។បេ។ រមែងលាខ្លួនសិក្ខាវិលត្រឡប់ទៅកាន់ភេទជាគ្រហស្ថវិញ ។ ម្នាលអាវុសោទាំងឡាយ ដូចភ្លៀងធំមានដំណក់ទឹកធំៗ បង្អុរចុះមកក្នុងផ្លូវធំ ៤ បំបាត់បង់នូវធូលី ធ្វើភក់ឲ្យកើតប្រាកដឡើង ម្នាលអាវុសោទាំងឡាយ បើបុគ្គលណា គប្បីនិយាយយ៉ាងនេះថា ធូលីនឹងមិនមានប្រាកដក្នុងផ្លូវធំ ៤ នោះ ក្នុងកាលឥឡូវនេះទៀតឡើយ តើអាវុសោទាំងឡាយ តើបុគ្គលនោះ ឈ្មោះថា គប្បីនិយាយសមគួរដោយហេតុឬទេ ។ ពួកភិក្ខុតបថា ម្នាលអាវុសោ មិនសមគួរដោយហេតុទេ ម្នាលអាវុសោ ព្រោះថា ហេតុនុ៎ះរមែងមាន គឺពួកមនុស្ស គប្បីដើរកាត់ ឬពួកគោនិងសត្វចិញ្ចឹមដើរកាត់ ខ្យល់ ឬ កំដៅថ្ងៃ គប្បីបក់ផាត់បង់ជាតិជ្រាយរីងរះបាន ក្នុងផ្លូវធំ ៤ នោះ កាលបើដូច្នេះ ធូលីនឹងកើតមានប្រាកដវិញ ។

ឯវមេវ ខោ អាវុសោ ឥធេកច្ចោ បុគ្គលោ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ សោ លាភិម្ហិ បឋមស្ស ឈានស្សាតិ សំសដ្ឋោ វិហរតិ ភិក្ខូហិ ។ បេ ។ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ ឥធ បនាវុសោ ឯកច្ចោ បុគ្គលោ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សោ លាភិម្ហិ ទុតិយស្ស ឈានស្សាតិ សំសដ្ឋោ វិហរតិ ភិក្ខូហិ ។ បេ ។ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ សេយ្យថាបិ អាវុសោ គាមស្ស វា និគមស្ស វា អវិទូរេ មហន្តំ តឡាកំ តត្ថ ថុល្លផុសិតកោ ទេវោ វុដ្ឋោ សិប្បិសម្ពុកម្បិ សក្ខរកឋលម្បិ អន្តរធាបេយ្យ យោ នុ ខោ អាវុសោ ឯវំ វទេយ្យ ន ទានិ អមុស្មឹ តឡាកេ បុនបិ សិប្បិសម្ពុកា វា សក្ខរកឋលា វា បាតុភវិស្សន្តីតិ សម្មា នុ ខោ សោ អាវុសោ វទមានោ វទេយ្យាតិ ។



ព្រះមហាកោដ្ឋិតៈដ៏មានអាយុពោលថា ម្នាលអាវុសោទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ក៏យ៉ាងនោះដែរ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានចូលកាន់បឋមជ្ឈាន បុគ្គលនោះ គិតថា អាត្មាអញបានបឋមជ្ឈានដូច្នេះ ហើយនៅច្រឡូកច្រឡំ ដោយពួកភិក្ខុ ។បេ។ រមែងលានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ។បេ។ បានចូលកាន់ទុតិយជ្ឈាន បុគ្គលនោះ គិតថា អាត្មាអញបានទុតិយជ្ឈានដូច្នេះ ហើយនៅច្រឡូកច្រឡំ ដោយពួកភិក្ខុ ។បេ។ រមែងលានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ។ ម្នាលអាវុសោទាំងឡាយ ដូចជាស្រះមួយធំ ជិតស្រុក ឬ និគម ផ្គរជាភ្លៀងដែលមានដំណក់ធំៗ ក៏បង្អុរចុះមកក្នុងស្រះនោះ ញ៉ាំងខ្យងក្រំ ក្រួសនិងអំបែងឲ្យសាបសូន្យទៅ ម្នាលអាវុសោទាំងឡាយ បើបុគ្គលណា គប្បីនិយាយយ៉ាងនេះថា ខ្យងក្រំ ឬ ក្រួសអំបែង នឹងមិនមានប្រាកដ ក្នុងស្រះឯណោះ ក្នុងកាលដទៃទៀតទេ ម្នាលអាវុសោទាំងឡាយ តើបុគ្គលនោះឈ្មោះថា គប្បីនិយាយសមគួរដែរឬទេ ។

នោ ហេតំ អាវុសោ ឋានញ្ញេតំ អាវុសោ វិជ្ជតិ យំ អមុស្មិំ តឡាកេ មនុស្សា វា បិវេយ្យុំ គោបសូ វា បិវេយ្យុំ វាតាតបោ វា សិនេហគតំ បរិយាទិយេយ្យ អថ បុនទេវ សិប្បិសម្ពុកាបិ សក្ខរកឋលាបិ បាតុភវេយ្យុន្តិ ។ ឯវមេវ ខោ អាវុសោ ឥធេកច្ចោ បុគ្គលោ វិតក្កវិចារានំ វូបសមា ។បេ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សោ លាភិម្ហិ ទុតិយស្ស ឈានស្សាតិ សំសដ្ឋោ វិហរតិ ភិក្ខូហិ ។បេ។ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ ឥធ បនាវុសោ ឯកច្ចោ បុគ្គលោ បីតិយា ច វិរាគា ។បេ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សោ លាភិម្ហិ តតិយស្ស ឈានស្សាតិ សំសដ្ឋោ វិហរតិ ភិក្ខូហិ ។បេ។ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ សេយ្យថាបិ អាវុសោ បុរិសំ បណីតភោជនំ ភុត្តាវី អភិទោសិកំ ភោជនំ នច្ឆាទេយ្យ យោ នុ ខោ អាវុសោ ឯវំ វទេយ្យ ន ទានិ អមុំ បុរិសំ បុនទេវ ភោជនំ ឆាទេស្សតីតិ សម្មា នុ ខោ សោ អាវុសោ វទមានោ វទេយ្យាតិ ។



គួរពិតឬ តបថា ម្នាលអាវុសោ មិនសមតាមហេតុទេ ម្នាលអាវុសោ ព្រោះថា ហេតុនុ៎ះ រមែងមានពិត ពួកមនុស្សគង់ផឹក ឬពួកគោពពែគង់ផឹក ខ្យល់ ឬ កំដៅថ្ងៃ គង់បក់ផាត់នូវជាតិជ្រាយអស់ទៅបាន ក្នុងស្រះនោះ កាលបើដូច្នោះ ខ្យងក្រំក្តី ក្រួសនិងអំបែងក្តី នឹងមានប្រាកដឡើងវិញ ។ ព្រះមហាកោដ្ឋិកៈមានអាយុពោលថា ម្នាលអាវុសោទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ក៏យ៉ាងនោះដែរ ព្រោះរម្ងាប់នូវវិតក្កៈ និងវិចារៈ ។បេ។ បានចូលកាន់ទុតិយជ្ឈាន បុគ្គលនោះគិតថា អាត្មាអញបាននូវទុតិយជ្ឈានដូច្នេះ ហើយទៅច្រឡូកច្រឡំ ដោយពួកភិក្ខុ ។បេ។ រមែងលានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ព្រោះប្រាសចាកបីតិផង ។បេ។ បានចូលកាន់តតិយជ្ឈាន បុគ្គលនោះគិតថា អាត្មាអញបាននូវតតិយជ្ឈានដូច្នេះ ហើយទៅច្រឡូកច្រឡំ ដោយពួកភិក្ខុ ។បេ។ រមែងលានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលអាវុសោទាំងឡាយ ដូចបុរសដែលឆ្អែតបរិភោគភោជនដ៏ថ្លៃថ្លាហើយ រមែងមិនគាប់ចិត្ត នឹងភោជនដែលផ្អូម ម្នាលអាវុសោទាំងឡាយ បើបុគ្គលណា គប្បីនិយាយយ៉ាងនេះថា បុរសឯណោះ នឹងមិនគាប់ចិត្តចំពោះភោជនថ្មីទៀតឡើយ ម្នាលអាវុសោទាំងឡាយ តើបុគ្គលនោះ ឈ្មោះថា គប្បីនិយាយសមតាមហេតុឬទេ ។

នោ ហេតំ អាវុសោ(១) អមុញ្ហាវុសោ បុរិសំ បណីត-
ភោជនំ ភុត្តាវិំ យាវស្ស សា ឱជា កាយេ ឋស្សតិ
តាវ ន អញ្ញំ ភោជនំ ឆាទេស្សតិ យតោ ច ខ្វស្ស
សា ឱជា អន្តរធាយិស្សតិ អថ បុនទេវ តំ ភោជនំ
ឆាទេយ្យាតិ ។ ឯវមេវ ខោ អាវុសោ ឥធេកច្ចោ
បុគ្គលោ បីតិយា ច វិរាគា ។បេ។ តតិយំ ឈានំ
ឧបសម្បជ្ជ វិហរតិ សោ លាភិម្ហិ តតិយស្ស
ឈានស្សាតិ សំសដ្ឋោ វិហរតិ ភិក្ខូហិ ។បេ។ សិក្ខំ
បច្ចក្ខាយ ហីនាយាវត្តតិ ។ ឥធ បនាវុសោ ឯកច្ចោ
បុគ្គលោ សុខស្ស ច បហានា ទុក្ខស្ស ច បហានា
។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ សោ លាភិម្ហិ
ចតុត្ថស្ស ឈានស្សាតិ សំសដ្ឋោ វិហរតិ ភិក្ខូហិ
។បេ។ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ សេយ្យថាបិ
អាវុសោ បព្ពតសង្ខេបេ ឧទករហទោ និវាតោ
វិគតូមិកោ យោ នុ ខោ អាវុសោ ឯវំ វទេយ្យ

១ ឱ. ម. ឯត្ថន្តរេ ហិទំ ហោតិ អាវុសោ វិត្ថិតិ ទិស្សតិ ។



ពួកភិក្ខុតបថា ម្នាលអាវុសោ មិនសមតាមហេតុទេ ម្នាលអាវុសោ
ព្រោះថា បុរសឯណោះ ដែលឆ្អែតបរិភោគភោជនដ៏ថ្លៃថ្លាហើយ បើ
ឱជារបស់ភោជនដ៏ថ្លៃថ្លានោះ នឹងឋិតនៅក្នុងកាយត្រឹមណា គឺនឹង
មិនគាប់ចិត្ត ចំពោះភោជនដទៃ ត្រឹមណោះ លុះកាលណា ឱជារបស់
ភោជនដ៏ថ្លៃថ្លានោះ សាបសូន្យទៅ ទើបនឹងគាប់ចិត្តចំពោះភោជន
ប៉ីទៀតមិនខាន ។ ព្រះមហាកោដ្ឋិតៈដ៏មានអាយុ ពោលថា ម្នាល
អាវុសោទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ គឺយ៉ាងនោះដែរ ព្រោះ
ប្រាសចាកបីតិផង ។បេ។ បានចូលកាន់តតិយជ្ឈាន បុគ្គលនោះ
គិតថា អាត្មាអញបាននូវតតិយជ្ឈានដូច្នេះ ហើយនៅច្របូកច្របល់
ដោយពួកភិក្ខុ ។បេ។ រមែងលានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទ
ថោកទាបវិញ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលខ្លះ
ក្នុងលោកនេះ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ។បេ។
បានចូលកាន់ចតុត្ថជ្ឈាន បុគ្គលនោះគិតថា អាត្មាអញបាននូវចតុត្ថជ្ឈាន
ដូច្នេះ ហើយនៅច្របូកច្របល់ដោយពួកភិក្ខុ ។បេ។ រមែងលា
នូវសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលអាវុសោទាំង
ឡាយ ដូចជាអន្លង់ទឹក ក្នុងចន្លោះភ្នំ ជាអន្លង់ទឹកប្រាសចាក
ខ្យល់ ប្រាសចាករលក បើបុគ្គលណា គប្បីនិយាយយ៉ាងនេះថា

ឋានំ អមុស្មិំ ឧទករហទេ បុនទេវ ឩមិ ជាតុ ភវិស្សតីតិ សម្មា នុ ខោ សោ អាវុសោ វទមានោ វទេយ្យាតិ ។ នោ ហិទំ អាវុសោ ឋានញ្ហេតំ អាវុសោ វិជ្ជតិ យា បុរត្ថិមាយ ទិសាយ អាគច្ឆេយ្យ ភុសា វាតវុដ្ឋិ សា តស្មឹ ឧទករហទេ ឩមឹ ជនេយ្យ យា បច្ឆិមាយ ទិសាយ អាគច្ឆេយ្យ ។បេ។ យា ឧត្តរាយ ទិសាយ អាគច្ឆេយ្យ ទក្ខិណាយ ទិសាយ អាគច្ឆេយ្យ ភុសា វាតវុដ្ឋិ សា តស្មឹ ឧទករហទេ ឩមឹ ជនេយ្យាតិ ។ ឯវមេវ ខោ អាវុសោ ឥធេកច្ចោ បុគ្គលោ សុខស្ស ច បហានា ទុក្ខស្ស ច បហានា ។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ សោ លាភិម្ហិ ចតុត្ថស្ស ឈានស្សាតិ សំសដ្ឋោ វិហរតិ ភិក្ខូហិ ។បេ។ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ ឥធ បនាវុសោ ឯកច្ចោ បុគ្គលោ សព្វនិមិត្តានំ អមនសិការា អនិមិត្តំ ចេតោសមាធឹ ឧបសម្បជ្ជ វិហរតិ



ឥឡូវនេះ រលកនឹងមិនមានប្រាកដ ក្នុងអន្លង់ទឹកឯណោះទៀតទេ ម្នាលអាវុសោទាំងឡាយ តើបុគ្គលនោះ ឈ្មោះថា ពោលនិយាយសមតាមហេតុឬទេ ។ ពួកភិក្ខុតបថា ម្នាលអាវុសោ មិនសមតាមហេតុទេ ម្នាលអាវុសោ ព្រោះថា ហេតុនុ៎ះ រមែងមាន គឺខ្យល់ព្យុះធំទាំងណា បក់ផាត់មកអំពីទិសខាងកើត ខ្យល់ព្យុះធំទាំងនោះ គង់ធ្វើរលកឲ្យកើតមានក្នុងអន្លង់ទឹកនោះបាន ខ្យល់ព្យុះធំទាំងណា បក់ផាត់មកអំពីទិសខាងលិច ។ បេ ។ ខ្យល់ព្យុះធំទាំងណា បក់ផាត់មកអំពីទិសខាងជើង ខ្យល់ព្យុះធំទាំងណា បក់ផាត់មកអំពីទិសខាងត្បូង ខ្យល់ព្យុះធំទាំងនោះ គង់ធ្វើឲ្យរលកកើតមានក្នុងអន្លង់ទឹកនោះបាន ។ ព្រះមហាកោដ្ឋិកៈដ៏មានអាយុពោលថា ម្នាលអាវុសោទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ គឺយ៉ាងនោះឯង ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ។ បេ ។ បានចូលកាន់ចតុត្ថជ្ឈាន បុគ្គលនោះគិតថា អាត្មាអញបាននូវចតុត្ថជ្ឈានដូច្នេះ ហើយទៅច្រឡូកច្រឡំដោយពួកភិក្ខុ ។ បេ ។ រមែងលាខ្លួនសិក្ខា វិលត្រឡប់ទៅកាន់ភេទជាគហដ្ឋវិញ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងពួង បានចូលកាន់ចេតោសមាធិ ដែលមិនមាននិមិត្ត

សោ លាភិម្ហិ អនិមិត្តស្ស ចេតោសមាធិស្សាតិ សំសដ្ឋោ វិហរតិ ភិក្ខូហិ ភិក្ខុនីហិ ឧបាសកេហិ ឧបាសិកាហិ រញ្ញា រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ តស្ស សំសដ្ឋស្ស វិស្សដ្ឋស្ស បាកដស្ស ភស្សមនុយុត្តស្ស វិហរតោ រាគោ ចិត្តំ អនុទ្ធំសេតិ សោ រាគានុទ្ធំសិតេន ចិត្តេន សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ សេយ្យថាបិ អាវុសោ រាជា វា រាជមហាមត្តោ វា ចតុរង្គិនិយា សេនាយ អទ្ធានមគ្គប្បដិបន្នោ អញ្ញតរស្មឹ វនសណ្ឌេ ឯករត្តឹ វាសំ ឧបគច្ឆេយ្យ តត្រ ហត្ថិសទ្ទេន អស្សសទ្ទេន រថសទ្ទេន បត្តិសទ្ទេន ភេរិបណវសង្ខតិណវនិន្នាទសទ្ទេន ចីរិកាសទ្ទោ អន្តរធាយេយ្យ យោ នុ ខោ ឯវំ វទេយ្យ នទានិ អមុស្មឹ វនសណ្ឌេ បុនេវ ចីរិកាសទ្ទោ បាតុភវិស្សតីតិ សម្មា នុ ខោ សោ អាវុសោ វទមានោ វទេយ្យាតិ ។ នោ ហេតំ អាវុសោ ឋានញ្ហេតំ អាវុសោ វិជ្ជតិ យំ សោ រាជា វា រាជមហាមត្តោ វា តម្ហា វនសណ្ឌា បក្កមេយ្យ



បុគ្គលនោះតែងគិតថា អញជាអ្នកបាននូវចេតោសមាធិ ដែលមិនមាននិមិត្តដូច្នេះ ហើយនៅច្រឡូកច្រឡំដោយពួកភិក្ខុ ភិក្ខុនី ពួកឧបាសក ឧបាសិកា ព្រះរាជា រាជាមហាមាត្យរបស់ព្រះរាជា ពួកតិរ្ថិយ និងសាវ័កនៃតិរ្ថិយ កាលបើបុគ្គលនោះ នៅច្រឡូកច្រឡំ លះបង់ (ការយោចល្អ) មានឥន្ទ្រិយជាប្រក្រតី ខ្វល់ខ្វាយតែការនិយាយពាក្យឥតប្រយោជន៍ រាគៈរមែងគ្របសង្កត់ចិត្ត លុះបុគ្គលនោះ ត្រូវរាគៈគ្របសង្កត់ចិត្តហើយ រមែងលាសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលអាវុសោទាំងឡាយ ដូចជាព្រះរាជាក្តី រាជាមហាមាត្យរបស់ព្រះរាជាក្តី ដើរទៅកាន់ផ្លូវឆ្ងាយ ដោយចតុរង្គសេនា ហើយចូលទៅស្នាក់នៅក្នុងដងព្រៃណាមួយ អស់រាត្រីមួយ សំឡេងរឹតគ្រឹតគ្រេងដោយស្នូរដំរី ស្នូរសេះ ស្នូររថ ស្នូរពលថ្មើរជើង ស្នូរគងគោនៃស្គរធំ ស្គរតូច ស័ង្ខនិងតិណវ ក៏បាត់សូន្យទៅក្នុងដងព្រៃនោះ បើបុគ្គលណា គប្បីនិយាយយ៉ាងនេះថា ឥឡូវនេះ សំឡេងរឹតគ្រឹតគ្រេងនឹងមិនមានប្រាកដ ក្នុងដងព្រៃឯណោះទៀតឡើយ ម្នាលអាវុសោទាំងឡាយ បុគ្គលនោះ ឈ្មោះថាគប្បីនិយាយសមគួរដែរឬទេ ។ ពួកភិក្ខុតបថា ម្នាលអាវុសោ មិនសមគួរទេ ម្នាលអាវុសោ ព្រោះថា ហេតុនុ៎ះ រមែងមាន គឺស្តេចនោះក្តី រាជាមហាមាត្យរបស់ស្តេចនោះក្តី ចុះចាកចេញចាកដងព្រៃនោះទៅ

អថ បុនទេវ ចីរិឡិកាសទ្ទោ បាតុភវេយ្យាតិ ។ ឯវមេវ ខោ អាវុសោ ឥធេកច្ចោ បុគ្គលោ សព្វនិមិត្តានំ អមនសិការា អនិមិត្តំ ចេតោសមាធិំ ឧបសម្បជ្ជ វិហរតិ សោ លាភិម្ហិ អនិមិត្តស្ស ចេតោសមាធិស្សាតិ សំសដ្ឋោ វិហរតិ ភិក្ខូហិ ភិក្ខុនីហិ ឧបាសកេហិ ឧបាសិកាហិ រញ្ញា រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ តស្ស សំសដ្ឋស្ស វិស្សដ្ឋស្ស បាកតស្ស ភស្សមនុយុត្តស្ស វិហរតោ រាគោ ចិត្តំ អនុទ្ធំសេតិ សោ រាគានុទ្ធំសិតេន ចិត្តេន សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតីតិ ។ អថខោ អាយស្មា ចិត្តោ ហត្ថិសារីបុត្តោ អបរេន សមយេន សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិ ។ អថខោ ចិត្តស្ស ហត្ថិសារីបុត្តស្ស សហាយកា ភិក្ខូ យេនាយស្មា មហាកោដ្ឋិកោ តេនុបសង្កមិំសុ ឧបសង្កមិត្វា អាយស្មន្តំ មហាកោដ្ឋិកំ ឯតទវោចុំ



វេលានោះ សំឡេងនៃគ្រឹតគ្រេង គប្បីមានប្រាកដឡើងវិញ ។ ព្រះមហា-កោដ្ឋិកៈដ៏មានអាយុពោលថា ម្នាលអាវុសោទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ក៏យ៉ាងនោះដែរ ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងពួង បានចូលកាន់ចេតោសមាធិ ដែលមិនមាននិមិត្ត បុគ្គលនោះគិតថា អញជាអ្នកបាននូវចេតោសមាធិ ដែលមិនមាននិមិត្តដូច្នេះ ហើយនៅច្រឡូកច្រឡំដោយពួកភិក្ខុ ភិក្ខុនី ពួកឧបាសក ឧបាសិកា ព្រះរាជា អាមាត្យធំរបស់ព្រះរាជា ពួកតិរ្ថិយ ពួកសាវ័កនៃតិរ្ថិយវិញ កាលដែលបុគ្គលនោះ នៅច្រឡូកច្រឡំ លះបង់ (មារយាទល្អ) មានឥន្ទ្រិយជាប្រក្រតី ខ្វល់ខ្វាយតែការនិយាយពាក្យឥតប្រយោជន៍ រាគៈរមែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះ លុះរាគៈគ្របសង្កត់ចិត្តហើយ ក៏រមែងលានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទជាគ្រហស្ថវិញ ។ គ្រាសម័យជាខាងក្រោយមក ចិត្តហត្ថិសារីបុត្តដ៏មានអាយុ បានលានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទជាគ្រហស្ថវិញ ។ លំដាប់នោះ ពួកភិក្ខុជាសំឡាញ់របស់ចិត្តហត្ថិសារីបុត្ត បានចូលទៅរកព្រះមហាកោដ្ឋិកៈដ៏មានអាយុ លុះចូលទៅដល់ហើយ បានសួរព្រះមហាកោដ្ឋិកៈដ៏មានអាយុយ៉ាងនេះថា

កឹ នុ ខោ អាយស្មតា មហាកោដ្ឋិកេន ចិត្តោ ហត្ថិសារីបុត្តោ ចេតសា ចេតោ បរិច្ច វិទិតោ ឥមាសញ្ច ឥមាសញ្ច វិហារសមាបត្តីនំ ចិត្តោ ហត្ថិសារីបុត្តោ លាភី អថ ច បន សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សតីតិ ឧទាហុ ទេវតា ឯតមត្ថំ អារោចេសុំ ចិត្តោ ភន្តេ ហត្ថិសារីបុត្តោ ឥមាសញ្ច ឥមាសញ្ច វិហារសមាបត្តីនំ លាភី អថ ច បន សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សតីតិ ។ ចេតសា ចេតោ បរិច្ច វិទិតោ មេ អាវុសោ ចិត្តោ ហត្ថិសារីបុត្តោ ឥមាសញ្ច ឥមាសញ្ច វិហារសមាបត្តីនំ លាភី អថ ច បន សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សតីតិ ទេវតាបិ មេ ឯតមត្ថំ អារោចេសុំ ចិត្តោ ភន្តេ ហត្ថិសារីបុត្តោ ឥមាសញ្ច ឥមាសញ្ច វិហារសមាបត្តីនំ លាភី អថ ច បន សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សតីតិ ។



ព្រះមហាកោដ្ឋិកៈដ៏មានអាយុ បានសង្កេតមើលចិត្តរបស់ចិត្តហត្ថិសារីបុត្ត ដោយចិត្តរបស់ខ្លួន ហើយដឹងច្បាស់ថា ចិត្តហត្ថិសារីបុត្ត ជាអ្នកបាននូវវិហារសមាបត្តិទាំងឡាយនេះផង នេះផង តែបើទុកជាដូច្នោះ ក៏គង់លានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទជាគ្រហស្ថវិញដូច្នេះឬ ឬក៏ពួកទេវតាប្រាប់សេចក្តីនុ៎ះថា បពិត្រព្រះករុណាដ៏ចំរើន ចិត្តហត្ថិសារីបុត្ត ជាអ្នកបាននូវវិហារសមាបត្តិទាំងឡាយនេះផង នេះផង តែបើទុកជាដូច្នោះ ក៏គង់លានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទជាគ្រហស្ថវិញ ។ ព្រះមហាកោដ្ឋិកៈដ៏មានអាយុ តបថា ម្នាលអាវុសោ ខ្ញុំបានសង្កេតមើលចិត្ត (របស់ចិត្តហត្ថិសារីបុត្ត) ដោយចិត្តរបស់ខ្លួន ហើយដឹងច្បាស់ថា ចិត្តហត្ថិសារីបុត្ត ជាអ្នកបាននូវវិហារសមាបត្តិទាំងឡាយនេះផង នេះផង តែបើទុកជាដូច្នោះ ក៏គង់លានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទជាគ្រហស្ថវិញ ទាំងពួកទេវតា ក៏បានប្រាប់សេចក្តីនេះដល់ខ្ញុំថា បពិត្រព្រះករុណាដ៏ចំរើន ចិត្តហត្ថិសារីបុត្ត ជាអ្នកបាននូវវិហារសមាបត្តិទាំងឡាយនេះផង នេះផង តែបើទុកជាដូច្នោះ ក៏គង់លានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទជាគ្រហស្ថវិញ ។

អថខោ ចិត្តស្ស ហត្ថិសារិបុត្តស្ស សហាយកា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ចិត្តោ ភន្តេ ហត្ថិសារិបុត្តោ ឥមាសញ្ច ឥមាសញ្ច វិហារសមាបត្តីនំ លាភី អថ ច បន សិក្ខំ បច្ចក្ខាយ ហីនាយាវត្តោតិ ។ ន ភិក្ខវេ ចិត្តោ ចិរំ សរិស្សតិ នេក្ខម្មស្សាតិ ។ អថខោ ចិត្តោ ហត្ថិសារិបុត្តោ ន ចិរស្សេវ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិ ។ អថខោ អាយស្មា ចិត្តោ ហត្ថិសារិបុត្តោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ន ចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ



លំដាប់នោះ ពួកភិក្ខុជាសំឡាញ់របស់ចិត្តហត្ថិសារីបុត្ត បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះពួកភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរស្រេចហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ចិត្តហត្ថិសារីបុត្ត ជាអ្នកបានវិហារសមាបត្តិទាំងឡាយនេះផង នេះផង តែបើទុកជាដូច្នោះ ក៏គង់លាចាកសិក្ខាវិលត្រឡប់ទៅកាន់ភេទគ្រហស្ថវិញ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចិត្តហត្ថិសារីបុត្ត មិនយូរប៉ុន្មានទេ នឹងនឹករលឹកដល់នេក្ខម្មគុណវិញ ។ គ្រានោះឯង ចិត្តហត្ថិសារីបុត្ត មិនយូរប៉ុន្មាន ក៏បានកោរសក់ កោរពុកមាត់ ស្លៀកដណ្ដប់សំពត់កាសាវៈ ចេញចាកផ្ទះចូលកាន់ផ្នួស ។ លំដាប់នោះ ព្រះចិត្តហត្ថិ-សារីបុត្តដ៏មានអាយុ ចៀសចេញចាកពួកទៅនៅតែម្នាក់ឯង មិនមានសេចក្ដីប្រមាទ មានព្យាយាមជាគ្រឿងដុតបំផ្លាញកិលេស មានចិត្តស្ទុះទៅកាន់ព្រះនិព្វាន ពួកកុលបុត្ត ចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ

តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា ចិត្តោ ហត្ថិសារីបុត្តោ អរហតំ អហោសីតិ ។

(៦១) ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ ។ តេន ខោ បន សមយេន សម្ពហុលានំ ថេរានំ ភិក្ខូនំ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តានំ មណ្ឌលមាឡេ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ បារាយនេ មេត្តេយ្យបញ្ហេ

យោ ឧភន្តេ[១] វិទិត្វាន មជ្ឈេ មន្តា ន លិម្បតិ
តំ ព្រូមិ មហាបុរិសោតិ សោធ សិព្វនិមច្ចគាតិ ។

១ ម. ឧភោន្តេ ។



ដើម្បីប្រយោជន៍ផលអនុត្តរធម៌ណា មិនយូរប៉ុន្មាន លោកក៏បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវអនុត្តរធម៌ដែលមានព្រហ្មចរិយធម៌ជាទីបំផុតនោះដោយប្រាជ្ញាដ៏ខ្ពង់ខ្ពស់របស់ខ្លួនឯង ក្នុងបច្ចុប្បន្នក៏បានដឹងច្បាស់ថា ជាតិរបស់អាត្មាអញ អស់ហើយ មគ្គព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចដែលត្រូវធ្វើ អាត្មាអញបានធ្វើស្រេចហើយ កិច្ចដទៃក្រៅអំពីសោឡសកិច្ចនេះមិនមានឡើយ ។ មានសេចក្តីសរសើរជាបណ្តាព្រះអរហន្តទាំងឡាយ ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុក៏បានជាព្រះអរហន្តមួយអង្គដែរ ។

(៦១) សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ សម័យនោះឯង ពួកភិក្ខុជាថេរៈច្រើនរូប ត្រឡប់មកពីបិណ្ឌបាត ក្នុងវេលាក្រោយភត្ត ហើយអង្គុយប្រជុំគ្នាក្នុងរោងសម្រាប់សម្រាកកាយ ក៏កើតសំដីជាចន្លោះនេះឡើងថា ម្នាលអាវុសោទាំងឡាយ ពាក្យនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ ក្នុងប្រស្នានៃមេត្តេយ្យមាណព ត្រង់ពាក្យថា

បុគ្គលណាដឹងនូវចំណែកទាំងពីរ ដោយប្រាជ្ញា មិន
ជាប់ជំពាក់ក្នុងកណ្តាល តថាគតហៅបុគ្គលនោះថាជា
មហាបុរស មហាបុរសនោះ បានកន្លងផុត តណ្ហាជាតិ
ជាគ្រឿងចាក់ស្រែះ ក្នុងលោកនេះបានហើយ ។

កតមោ នុ ខោ អាវុសោ ឯកោ អន្តោ កតមោ ទុតិយោ អន្តោ កឹ មជ្ឈេ កា សិព្វនីតិ ។

ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ថេរេ ភិក្ខូ ឯតទវោច ផស្សោ ខោ អាវុសោ ឯកោ អន្តោ ផស្សសមុទយោ ទុតិយោ អន្តោ ផស្សនិរោធោ មជ្ឈេ តណ្ហា សិព្វនី តណ្ហា ហិ នំ សិព្វតិ តស្ស តស្សេវ អភិនិព្វត្តិយា ឯត្តាវតា ខោ អាវុសោ ភិក្ខុ អភិញ្ញេយ្យំ អភិជានាតិ បរិញ្ញេយ្យំ បរិជានាតិ អភិញ្ញេយ្យំ អភិជានន្តោ បរិញ្ញេយ្យំ បរិជានន្តោ ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតីតិ ។



ម្នាលអាវុសោទាំងឡាយ ចុះចំណែកទី ១ តើដូចម្តេច ចំណែកទី ២ តើដូចម្តេច អ្វីជាកណ្តាល ធម្មជាតិជាគ្រឿងដាក់ស្រេះតើដូចម្តេច ។ កាលបើភិក្ខុទាំងនោះ និយាយយ៉ាងនេះហើយ ភិក្ខុមួយរូបទៀត បាននិយាយនឹងភិក្ខុទាំងឡាយ ជាថេរៈដូច្នេះថា បពិត្រលោកដ៏មានអាយុទាំងឡាយ ផស្សៈ(១)ឈ្មោះជាចំណែកទី ១ ផស្សសមុទយៈ (២)ឈ្មោះជាចំណែកទី ២ ផស្សនិរោធ(៣) ឈ្មោះជាកណ្តាល តណ្ហាឈ្មោះជាជាគ្រឿងដាក់ស្រេះ ព្រោះថា តណ្ហាតែងតែដាក់ស្រេះនូវផស្សៈទាំងនោះ ដើម្បីឲ្យកើតអត្តភាពនោះៗ បពិត្រលោកដ៏មានអាយុទាំងឡាយ ដោយហេតុប៉ុណ្ណេះឯង ។ ភិក្ខុដឹងច្បាស់អភិញ្ញេយ្យធម៌(៤) កំណត់ដឹងបរិញ្ញេយ្យធម៌(៥) កាលបើដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ហើយ ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។

---

១ សំដៅយកអត្តភាពដែលកើតដោយសំណាចផស្សៈ (បានខាងអត្តភាពជាបច្ចុប្បន្ន) ។ ២ សំដៅយកអត្តភាពជាអនាគត ដែលកើតអំពីបច្ច័យគឺកម្មនិងផស្សៈដែលបុគ្គលធ្វើហើយក្នុងអត្តភាពនេះ ។ ៣ សំដៅយកព្រះនិព្វាន ។ ៤ បានខាងចតុសច្ចធម៌ដែលបុគ្គល គប្បីដឹងច្បាស់ ។ ៥ បានខាងលោកិយសច្ច ២ប្រការ គឺទុក្ខសច្ច ១ សមុទយសច្ច ១ ដែលបុគ្គលគប្បីកំណត់ដោយសំណាចញាណនិងបហានបរិញ្ញា ។ អដ្ឋកថា ។

ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ថេរេ ភិក្ខូ ឯតទវោច អតីតំ ខោ អាវុសោ ឯកោ អន្តោ អនាគតំ ទុតិយោ អន្តោ បច្ចុប្បន្នំ មជ្ឈេ តណ្ហា សិព្វិនី តណ្ហា ហិ នំ សិព្វតិ តស្ស តស្សេវ ភវស្ស អភិនិព្វត្តិយា ឯត្តាវតា ខោ អាវុសោ ភិក្ខុ អភិញ្ញេយ្យំ អភិជានាតិ បរិញ្ញេយ្យំ បរិជានាតិ អភិញ្ញេយ្យំ អភិជានន្តោ បរិញ្ញេយ្យំ បរិជានន្តោ ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតីតិ ។

ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ថេរេ ភិក្ខូ ឯតទវោច សុខា អាវុសោ វេទនា ឯកោ អន្តោ ទុក្ខា វេទនា ទុតិយោ អន្តោ អទុក្ខមសុខា វេទនា មជ្ឈេ តណ្ហា សិព្វិនី តណ្ហា ហិ នំ សិព្វតិ តស្ស តស្សេវ ភវស្ស អភិនិព្វត្តិយា



កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ភិក្ខុមួយរូបទៀតបាននិយាយនឹងភិក្ខុទាំងឡាយជាថេរៈដូច្នេះថា បពិត្រលោកដ៏មានអាយុទាំងឡាយ អតីតក្ខន្ធ(១) ឈ្មោះថាចំណែកទី ១ អនាគតក្ខន្ធ(២) ឈ្មោះថា ចំណែកទី ២ បច្ចុប្បន្នក្ខន្ធ(៣) ជាកណ្តាល តណ្ហាជាគ្រឿងដេរចាក់ស្រេះ ព្រោះថា តណ្ហាដែលដេរចាក់ស្រេះនូវខន្ធទាំងនោះ ដើម្បីឲ្យកើតភពនោះៗ បពិត្រលោកដ៏មានអាយុទាំងឡាយ ដោយហេតុប៉ុណ្ណេះឯង ភិក្ខុដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ កាលបើដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ហើយ ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។

កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ភិក្ខុមួយរូបទៀត បាននិយាយនឹងភិក្ខុទាំងឡាយ ជាថេរៈ ដូច្នេះថា បពិត្រលោកដ៏មានអាយុទាំងឡាយ សុខវេទនាឈ្មោះថាចំណែកទី ១ ទុក្ខវេទនាឈ្មោះថាចំណែកទី ២ អទុក្ខមសុខវេទនា ជាកណ្តាល តណ្ហាជាគ្រឿងដេរចាក់ស្រេះ ព្រោះថា តណ្ហាដែលដេរចាក់ស្រេះនូវវេទនាទាំងនោះ ដើម្បីឲ្យកើតភពនោះៗ

---

១-២-៣ បទទាំងបីនេះមានសេចក្តីប្រៀបធៀបដោយក្រណាត់ ៣ ផ្ទាំង កាលបើត្រូវការនឹងដេរភ្ជាប់គ្នានឹងខ្សែ លុះដេរភ្ជាប់ហើយ ក្រណាត់ ៣ ក៏ភ្ជាប់ត្រង់កន្លែងទាំង ៣ យ៉ាងណា មិញ អតីតក្ខន្ធ អនាគតក្ខន្ធ បច្ចុប្បន្នក្ខន្ធ ក៏ភ្ជាប់គ្នានឹងក្រណាត់ ៣ យ៉ាងនោះដែរ តណ្ហាក៏ដូចគ្នានឹងខ្សែ ព្រោះតណ្ហាដែលចាក់ស្រេះអតីតក្ខន្ធភ្ជាប់នឹងបច្ចុប្បន្នក្ខន្ធ ចាក់ស្រេះបច្ចុប្បន្នក្ខន្ធភ្ជាប់នឹងអនាគតក្ខន្ធ កាលបើតណ្ហារលត់ហើយ ខន្ធទាំងនោះក៏ឈ្មោះថាលែងជាប់ដែរ ដូចជាក្រណាត់ទាំង ៣ កាលបើខ្សែដាច់ហើយ ក៏ធ្លាក់ចុះក្នុងកន្លែងទាំង ៣ ។ អដ្ឋកថា ។

ឯត្តាវតា ខោ អាវុសោ ភិក្ខុ អភិញ្ញេយ្យំ អភិជានាតិ
បរិញ្ញេយ្យំ បរិជានាតិ អភិញ្ញេយ្យំ អភិជានន្តោ
បរិញ្ញេយ្យំ បរិជានន្តោ ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ
ហោតីតិ ។

ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ថេរេ ភិក្ខូ ឯតទវោច
នាមំ ខោ អាវុសោ ឯកោ អន្តោ រូបំ ទុតិយោ អន្តោ
វិញ្ញាណំ មជ្ឈេ តណ្ហា សិព្វនី តណ្ហា ហិ នំ សិព្វតិ
តស្ស តស្សេវ ភវស្ស អភិនិព្វត្តិយា ឯត្តាវតា ខោ
អាវុសោ ភិក្ខុ អភិញ្ញេយ្យំ អភិជានាតិ បរិញ្ញេយ្យំ
បរិជានាតិ អភិញ្ញេយ្យំ អភិជានន្តោ បរិញ្ញេយ្យំ
បរិជានន្តោ ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតីតិ ។

ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ថេរេ ភិក្ខូ ឯតទវោច ឆ
ខោ អាវុសោ អជ្ឈត្តិកានិ អាយតនានិ ឯកោ អន្តោ



បពិត្រលោកដ៏មានអាយុទាំងឡាយ ដោយហេតុប៉ុណ្ណេះឯង ទើបភិក្ខុដឹង
ច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ កាលបើដឹងច្បាស់អភិ-
ញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ហើយ ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខ
ក្នុងបច្ចុប្បន្នបាន ។

កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ភិក្ខុមួយរូបទៀត បាន
និយាយនឹងភិក្ខុទាំងឡាយ ជាថេរៈដូច្នេះថា បពិត្រលោកដ៏មានអាយុទាំង
ឡាយ នាមឈ្មោះថាចំណែកទី ១ រូប ឈ្មោះថាចំណែកទី ២ វិញ្ញាណ(១)
ជាកណ្តាល តណ្ហាជាគ្រឿងដោតក្រែស ព្រោះថា តណ្ហាតែងដោតក្រែស
នូវធម៌ទាំងនោះ ដើម្បីឲ្យកើតភពនោះ ៗ បពិត្រលោកដ៏មានអាយុទាំង
ឡាយ ដោយហេតុប៉ុណ្ណេះឯងហើយ ទើបភិក្ខុដឹងច្បាស់អភិញ្ញេយ្យធម៌
កំណត់ដឹងបរិញ្ញេយ្យធម៌ កាលបើដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹង
បរិញ្ញេយ្យធម៌ហើយ ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។

កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ភិក្ខុមួយរូបទៀត
បាននិយាយនឹងភិក្ខុទាំងឡាយ ជាថេរៈ ដូច្នេះថា បពិត្រលោកដ៏មាន
អាយុទាំងឡាយ អាយតនៈខាងក្នុង ៦ ឈ្មោះថា ចំណែកទី ១

---

១ បដិសន្ធិវិញ្ញាណក្តី វិញ្ញាណដ៏សេសក្តី ឈ្មោះថា ធម៌ជាចំណែកត្រង់កណ្តាល
នៃនាមនិងរូប ព្រោះវិញ្ញាណកើតឡើងដោយអាស្រ័យ ធម៌នាមនិងរូប ។

ឆ ពាហិរានិ អាយតនានិ ទុតិយោ អន្តោ វិញ្ញាណំ មជ្ឈេ តណ្ហា សិព្វនី តណ្ហា ហិ នំ សិព្វតិ តស្ស តស្សេវ ភវស្ស អភិនិព្វត្តិយា ឯត្តាវតា ខោ អាវុសោ ភិក្ខុ អភិញ្ញេយ្យំ អភិជានាតិ បរិញ្ញេយ្យំ បរិជានាតិ អភិញ្ញេយ្យំ អភិជានន្តោ បរិញ្ញេយ្យំ បរិជានន្តោ ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតីតិ ។

ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ថេរេ ភិក្ខូ ឯតទវោច សក្កាយោ ខោ អាវុសោ ឯកោ អន្តោ សក្កាយសមុទយោ ទុតិយោ អន្តោ សក្កាយនិរោធោ មជ្ឈេ តណ្ហា សិព្វនី តណ្ហា ហិ នំ សិព្វតិ តស្ស តស្សេវ ភវស្ស អភិនិព្វត្តិយា



អាយតនៈខាងក្រៅ ៦ ឈ្មោះថាចំណែកទី ២ វិញ្ញាណ(២) ជាកណ្តាល តណ្ហាជាគ្រឿងចាក់ស្រេះ ព្រោះថា តណ្ហាតែងចាក់ស្រេះនូវអាយតនៈទាំងនោះ ដើម្បីឲ្យកើតភពនោះ ៗ បពិត្រលោកដ៏មានអាយុទាំងឡាយ ដោយហេតុប៉ុណ្ណេះឯងហើយ ទើបភិក្ខុដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ កាលបើដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ហើយ ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។

កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ភិក្ខុមួយរូបទៀត បាននិយាយនឹងភិក្ខុទាំងឡាយ ជាថេរៈ ដូច្នេះថា បពិត្រលោកដ៏មានអាយុទាំងឡាយ សក្កាយៈ(១) ឈ្មោះថាចំណែកទី ១ សក្កាយសមុទយៈ(២) ឈ្មោះថាចំណែកទី ២ សក្កាយនិរោធ(៣) ជាកណ្តាល តណ្ហាជាគ្រឿងចាក់ស្រេះ ព្រោះថា តណ្ហាតែងចាក់ស្រេះនូវសក្កាយៈទាំងនោះ ដើម្បីឲ្យកើតភពនោះៗ

---

២ សំដៅយកកម្មវិញ្ញាណ ។ ម្យ៉ាងទៀត បណ្ដាអាយតនៈខាងក្នុងទាំងប្រាំមួយ ក្រៅពីមនះ គឺត្រឹមតែវិញ្ញាណ ៥ ពួក ក៏ឈ្មោះថាជាគន្ធិ ចំណែកក្រឹតកណ្តាលទាំងអស់ ព្រោះមនាយតនៈ ជាខន្ធគឺរូបយកកម្ម ។ បើក្នុងបទនេះ សំដៅយកអស់វិញ្ញាណ ក៏ឈ្មោះថា ជាកណ្តាលដែរ ព្រោះសន្តានអាស្រ័យនឹងអាយតនៈខាងក្នុង ។ អដ្ឋកថា ។

១ ខន្ធដែលប្រព្រឹត្តទៅក្នុងភពទាំង ៣ ។ ២ សមុទយសច្ច ។ ៣ និរោធសច្ច ។ អដ្ឋកថា ។

ឯត្តាវតា ខោ អាវុសោ ភិក្ខុ អភិញ្ញេយ្យំ អភិជានាតិ បរិញ្ញេយ្យំ បរិជានាតិ អភិញ្ញេយ្យំ អភិជានិត្វា បរិញ្ញេយ្យំ បរិជានិត្វា ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតីតិ ។

ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ថេរេ ភិក្ខូ ឯតទវោច ព្យាកតំ ខោ អាវុសោ អម្ហេហិ សព្វេហេវ យថាសកំ បដិភាណំ អាយាមាវុសោ យេន ភគវា តេនុបសង្កមិស្សាម ឧបសង្កមិត្វា ភគវតោ ឯតមត្ថំ អារោចេស្សាម យថា នោ ភគវា ព្យាករិស្សតិ តថា នំ ធារេយ្យាមាតិ(១) ។ ឯវមាវុសោតិ ខោ ថេរា ភិក្ខូ តស្ស ភិក្ខុនោ បច្ចស្សោសុំ ។ អថខោ ថេរា ភិក្ខូ យេន ភគវា តេនុបសង្កមិំសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិំសុ ។ ឯកមន្តំ និសិន្នា ខោ ថេរា ភិក្ខូ យាវតកោ អហោសិ សព្វេហេវ សទ្ធិំ កថាសល្លាបោ តំ សព្វំ ភគវតោ អារោចេសុំ កស្ស នុ ខោ ភន្តេ សុភាសិតន្តិ ។

១ ម. ធារេស្សាមាតិ ។



បពិត្រលោកដ៏មានអាយុទាំងឡាយ ដោយហេតុប៉ុណ្ណេះឯងហើយ ទើបភិក្ខុដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ កាលបើដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ហើយ ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។

កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ភិក្ខុមួយរូបទៀត បាននិយាយនឹងភិក្ខុទាំងឡាយ ជាថេរៈ ដូច្នេះថា បពិត្រលោកដ៏មានអាយុទាំងឡាយ ពួកយើងទាំងអស់គ្នា ព្យាករតាមសេចក្តីយល់នៃរៀងខ្លួនៗ បពិត្រលោកដ៏មានអាយុទាំងឡាយ មកពួកយើងនឹងចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ នឹងក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ នឹងបានព្រះដ៏មានព្រះភាគព្យាករដល់យើងយ៉ាងណា យើងនឹងចាំទុកនូវសេចក្តីនុ៎ះយ៉ាងនោះ ។ ភិក្ខុទាំងឡាយ ជាថេរៈ បានទទួលពាក្យភិក្ខុនោះថា អើអាវុសោ ។ គ្រានោះ ភិក្ខុទាំងឡាយ ជាថេរៈ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងឡាយជាថេរៈ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលសេចក្តីទាំងប៉ុន្មាន ដែលខ្លួនបានចរចា ជាមួយនឹងភិក្ខុទាំងអស់នោះ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុណានិយាយត្រូវ ។

សព្វេសំ វោ ភិក្ខវេ សុភាសិតំ បរិយាយេន អបិ ច យំ មយា សន្ធាយ ភាសិតំ បារាយនេ មេត្តេយ្យបញ្ហេ

យោ ឧភន្តេ វិទិត្វាន មជ្ឈេ មន្តា ន លិប្បតិ
តំ ព្រូមិ មហាបុរិសោ សោធ សិព្វិនិមច្ចគាតិ ។

តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ផស្សោ ខោ ភិក្ខវេ ឯកោ អន្តោ ផស្សសមុទយោ ទុតិយោ អន្តោ ផស្សនិរោធោ មជ្ឈេ តណ្ហា សិព្វិនី តណ្ហា ហិ នំ សិព្វតិ តស្ស តស្សេវ ភវស្ស អភិនិព្វត្តិយា ឯត្តាវតា ខោ ភិក្ខវេ ភិក្ខុ អភិញ្ញេយ្យំ អភិជានាតិ បរិញ្ញេយ្យំ បរិជានាតិ អភិញ្ញេយ្យំ អភិជានន្តោ បរិញ្ញេយ្យំ បរិជានន្តោ ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ហោតីតិ ។



ម្នាលភិក្ខុទាំងឡាយ អ្នកទាំងអស់គ្នា និយាយត្រូវតាមបរិយាយ ដែលតថាគតសំដែង ក្នុងប្រស្នានៃមេត្តេយ្យមាណព ត្រង់បារាយនវគ្គថា

បុគ្គលណាដឹងនូវចំណែកទាំងពីរ ដោយប្រាជ្ញា មិន
ជាប់ជំពាក់ក្នុងកណ្តាល តថាគតហៅបុគ្គលនោះ ថា
ជាមហាបុរស មហាបុរសនោះ បានកន្លងផុតនូវតណ្ហា
ជាគ្រឿងចាក់ស្រែះ ក្នុងលោកនេះចេញបានហើយ ។

អ្នកទាំងឡាយ ចូរស្តាប់ធ្វើទុកក្នុងចិត្តនូវហេតុនោះឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងឡាយ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគបានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ផស្សៈឈ្មោះជាចំណែកទី ១ ផស្សសមុទយៈឈ្មោះជាចំណែកទី ២ ផស្សនិរោធ ឈ្មោះជាកណ្តាល តណ្ហាជាគ្រឿងចាក់ស្រែះ ព្រោះថា តណ្ហាតែងចាក់ស្រែះនូវផស្សៈទាំងនោះ ដើម្បីឲ្យកើតភពនោះៗ ម្នាលភិក្ខុទាំងឡាយ ដោយហេតុប៉ុណ្ណេះឯង ទើបភិក្ខុដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ កាលបើដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ហើយ ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។

[៦២] ឯកំ សមយំ ភគវា កោសលេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន ទណ្ឌកប្បកំ នាម កោសលានំ និគមោ តទវសរិ ។ អថ ខោ ភគវា មគ្គា ឱក្កម្ម អញ្ញតរស្មឹ រុក្ខមូលេ បញ្ញត្តេ អាសនេ និសីទិ ។ តេ ភិក្ខូ ទណ្ឌកប្បកំ បវិសឹសុ អាវសថំ បរិយេសិតុំ ។ អថ ខោ អាយស្មា អានន្ទោ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ យេន អចិរវតី នទី តេនុបសង្កមិ គត្តានិ បរិសិញ្ចិតុំ អចិរវតិយា នទិយា គត្តានិ បរិសិញ្ចិត្វា បច្ចុត្តរិត្វា ឯកចីវរោ អដ្ឋាសិ គត្តានិ បុព្វាបយមានោ(១) ។ អថ ខោ អញ្ញតរោ ភិក្ខុ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ ឯតទវោច កិន្នុ ខោ អាវុសោ អានន្ទ សព្វំ ចេតសោ សមន្នាហរិត្វា នុ ខោ ទេវទត្តោ ភគវតា ព្យាកតោ អាបាយិកោ ទេវទត្តោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោតិ ឧទាហុ កេនចិទេវ បរិយាយេនាតិ ។ ឯវំ ខោ បនេតំ អាវុសោ ភគវតា ព្យាកតន្តិ ។

១ ឱ. ម. គត្តានិ បុព្វាបយមានោតិ ទិស្សតិ ។



(៦២) សម័យមួយ ព្រះដ៏មានព្រះភាគ ត្រាច់ទៅកាន់ចារិកក្នុងដែនកោសល ជាមួយនឹងភិក្ខុសង្ឃដ៏ច្រើន ចូលទៅដល់និគមឈ្មោះទណ្ឌកប្បកៈរបស់ពួកអ្នកដែនកោសល ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញពីផ្លូវហើយ ទៅគង់លើអាសនៈដែលគេក្រាលថ្វាយ ទៀបគល់ឈើមួយដើម ។ ភិក្ខុទាំងនោះ ចូលទៅកាន់និគមឈ្មោះទណ្ឌកប្បកៈ ដើម្បីស្វែងរកទីសំណាក់ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ក៏ស្ដេចទៅស្ទឹងអចិរវតី ជាមួយនឹងពួកភិក្ខុដ៏ច្រើន ដើម្បីស្រោចស្រពខ្លួនក្នុងស្ទឹងអចិរវតី លុះស្រោចស្រពខ្លួនរួចហើយ ក៏ឡើងមក មានតែចីវរមួយ ហើយឈរផ្ញើខ្លួនឲ្យស្ងួតដូចកាលមុន ។ ស្រាប់តែ មានភិក្ខុមួយរូប ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះអានន្ទដ៏មានអាយុយ៉ាងនេះថា បពិត្រអានន្ទដ៏មានអាយុ ព្រះដ៏មានព្រះភាគ ទ្រង់ពិចារណាហេតុទាំងអស់ ដោយព្រះហឫទ័យ ហើយព្យាករទេវទត្តថា ទេវទត្តជាអ្នកកើតក្នុងអបាយ ទៅនរក តាំងនៅអស់ ១ កប្ប រកកែមិនកើត ឬហ្ន៎ ឬថា ដោយហេតុណាមួយទេ ។ ម្នាលអាវុសោ ដំណើរនុ៎ះ ព្រះដ៏មានព្រះភាគ ទ្រង់ព្យាករហើយយ៉ាងនុ៎ះមែន ។

អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ សម្ពហុលេហិ ភិក្ខូហិ សទ្ធិំ យេន អចិរវតី នទី តេនុបសង្កមឹ គត្តានិ បរិសិញ្ចិតុំ អចិរវតិយា នទិយា គត្តានិ បរិសិញ្ចិត្វា បច្ចុត្តរិត្វា ឯកចីវរោ អដ្ឋាសិំ គត្តានិ បុព្វាបយមានោ ។ អថខោ ភន្តេ អញ្ញតរោ ភិក្ខុ យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ ឯតទវោច កិន្នុ ខោ អាវុសោ អានន្ទ សព្វំ ចេតសា សមន្នាហរិត្វា នុ ខោ ទេវទត្តោ ភគវតា ព្យាកតោ អាបាយិកោ ទេវទត្តោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោតិ ឧទាហុ កេនចិទេវ បរិយាយេនាតិ ។

ឯវំ វុត្តេ អហំ ភន្តេ តំ ភិក្ខុំ ឯតទវោចំ ឯវំ ខោ បនេតំ អាវុសោ ភគវតា ព្យាកតន្តិ ។



គ្រានោះ ព្រះអានន្ទដ៏មានអាយុ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គព្រមទាំងភិក្ខុសង្ឃជាច្រើន ចុះទៅក្នុងស្ទឹងអចិរវតី ដើម្បីស្រោចស្រពខ្លួនក្នុងស្ទឹងអចិរវតី លុះស្រោចស្រពខ្លួនរួចហើយ ក៏ឡើងមកមានតែចីវរមួយ ហើយឈរធ្វើខ្លួនឲ្យប្រាកដដូចជាកាលមុន ។ បពិត្រព្រះអង្គដ៏ចំរើន លំដាប់នោះ មានភិក្ខុមួយរូបចូលទៅរកខ្ញុំព្រះអង្គ លុះចូលទៅដល់ហើយ ក៏និយាយនឹងខ្ញុំព្រះអង្គដូច្នេះថា បពិត្រអានន្ទដ៏មានអាយុ ព្រះដ៏មានព្រះភាគ ទ្រង់ប្រមូលហេតុទាំងអស់ ដោយព្រះហឫទ័យ ហើយព្យាករទេវទត្តថា ទេវទត្តជាអ្នកកើតក្នុងអបាយ ទៅនរក តាំងនៅអស់ ១ កប្ប រកកែមិនកើតទេ ឬថាកែបាន ដោយហេតុណាមួយដែរ ។

កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបាននិយាយនឹងភិក្ខុនោះ ដូច្នេះថា ម្នាលអាវុសោ ហេតុនុ៎ះ ព្រះដ៏មានព្រះភាគ ទ្រង់ព្យាករយ៉ាងនោះដែរ ។

សោ ច ខោ អានន្ទ ភិក្ខុ នវោ ភវិស្សតិ អចិរ-ប្បព្វជិតោ ថេរោ វា បន ពាលោ អព្យត្តោ តេសំ ហិ នាម យំ មយា ឯកំសេន ព្យាកតំ តត្ថ ទ្វេជ្ឈំ អាបជ្ជិស្សតិ នាហំ អានន្ទ អញ្ញំ ឯកបុគ្គលំបិ សមនុបស្សាមិ យោ ឯវំ មយា សព្វំ ចេតសោ សមន្នាហរិត្វា ព្យាកតោ យថយិទំ ទេវទត្តោ ។ យាវ-កីវញ្ចាហំ អានន្ទ ទេវទត្តស្ស វាលគ្គកោដិនិត្តុទ-នមត្តម្បិ សុក្កំ ធម្មំ អទ្ទសំ នេវ តាវាហំ ទេវទត្តំ ព្យាកាសឹ អាបាយិកោ ទេវទត្តោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោតិ ។ យតោ ច ខោ អហំ អានន្ទ ទេវទត្តស្ស វាលគ្គកោដិនិត្តុទនមត្តម្បិ សុក្កំ ធម្មំ ន អទ្ទសំ អថាហំ តំ ទេវទត្តំ ព្យាកាសឹ អាបាយិកោ ទេវទត្តោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោតិ ។ សេយ្យថាបិ អានន្ទ គូថកូបោ សាធិកោ បោរិសោ បូរោ គូថស្ស សមតិត្តិកោ តត្រ បុរិសោ សសីសកោ និមុគ្គោ អស្ស



ម្នាលអានន្ទ ភិក្ខុនោះ ជាភិក្ខុថ្មី ទើបតែនឹងបួសក្តី ជាថេរៈល្ងង់ មិនឈ្លាសវៃក្តី ពាក្យណាដែលតថាគត ព្យាករដោយចំណែកមួយ ភិក្ខុនោះនឹងមិនដល់នូវចំណែកពីរ ក្នុងពាក្យនោះឡើយ ម្នាលអានន្ទ តថាគតមិនដែលឃើញបុគ្គលដទៃ សូម្បីម្នាក់ដែលតថាគតរំពឹងនូវហេតុទាំងអស់ដោយចិត្ត ហើយព្យាករដូចជាភិក្ខុ ទេវទត្តនេះទេ ។ ម្នាលអានន្ទ តថាគតបានឃើញធម៌ស របស់ទេវទត្ត ត្រឹមតែចាក់ដោយចុងចំផុតនៃរោមបាន ដរាបណា តថាគតក៏មិនព្យាករ ភិក្ខុទេវទត្តថា ទេវទត្តជាអ្នកកើតក្នុងអបាយ នៅនរក តាំងនៅអស់ ១ កប្ប កែមិនកើត ដរាបនោះ ម្នាលអានន្ទ កាលណាបើតថាគត មិនបានឃើញធម៌សរបស់ទេវទត្ត ត្រឹមតែចាក់ដោយចុងចំផុតនៃរោមបាន តថាគតព្យាករទេវទត្តនោះថា ភិក្ខុទេវទត្ត ជាអ្នកកើតក្នុងអបាយ នៅនរក តាំងនៅអស់ ១ កប្ប កែមិនបាន ក្នុងកាលនោះ ។ ម្នាលអានន្ទ រណ្តៅលាមក ដែលមានជំរៅជាង ១ ព្យាម ពេញ ដោយលាមកប្រៀបស្មើមាត់ មានបុរសលិចចុះទៅទាំងក្បាល ក្នុងរណ្តៅលាមកនោះ

តស្ស កោចិទេវ បុរិសោ ឧបគច្ឆេយ្យ(១) អត្ថកាមោ ហិតកាមោ យោគក្ខេមកាមោ តម្ហា គូថកូបា ឧទ្ធរិតុកាមោ សោ តំ គូថកូបំ សមន្តានុបរិគន្ត្វា ន បស្សេយ្យ តស្ស បុរិសស្ស កេសគ្គកោដិនិត្តុទ្ទនមត្តម្បិ គូថេន អមក្ខិតំ យត្ថ តំ គហេត្វា ឧទ្ធរេយ្យ ឯវមេវ ខោ អហំ អានន្ទ យតោ ទេវទត្តស្ស កេសគ្គកោដិនិត្តុទ្ទនមត្តម្បិ សុក្កំ ធម្មំ ន អទ្ធសំ អថាហំ ទេវទត្តំ ព្យាកាសិំ អាបាយិកោ ទេវទត្តោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោតិ សចេ ត្វំ អានន្ទ សុណេយ្យាសិ តថាគតស្ស បុរិសិន្ទ្រិយញាណានិ វិភជន្តស្សាតិ(២) ។ ឯតស្ស ភគវា កាលោ ឯតស្ស សុគត កាលោ យំ ភគវា បុរិសិន្ទ្រិយញាណានិ វិភជេយ្យ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហានន្ទ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។

១ ម. ឧបគច្ឆេយ្យ ។ ២ ម. វិភជិស្សាមីតិ ។



បុរសណាមួយជាអ្នកប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីចំរើន ប្រាថ្នាដើម្បីក្សេមចាកយោគៈ ដល់បុរសនោះ ប្រាថ្នានឹងស្រង់ចេញពីរណ្តៅលាមកនោះ ក៏ដើរចូលមកកាន់បុរសនោះ ឯបុរសនោះ ដើរក្រឡឹងជុំវិញរណ្តៅលាមកនោះហើយ មិនឃើញសរីរប្រទេសរបស់បុរសនោះដែលត្រឹមតែចាក់ដោយចុងចំផុតនៃរោម ដែលមិនប្រឡាក់ដោយលាមក ដែលគួរនឹងចាប់ស្រង់បុរសនោះឡើងបាន យ៉ាងណាមិញ ម្នាលអានន្ទ តថាគតមិនបានឃើញធម៌សរបស់ទេវទត្ត ត្រឹមតែចាក់ដោយចុងចំផុតនៃរោមបានក្នុងកាលណា តថាគតព្យាករទេវទត្តថា ភិក្ខុទេវទត្តជាអ្នកកើតក្នុងអបាយ ទៅនរក ឋិតនៅអស់ ១ កប្ប កែមិនកើត ក្នុងកាលនោះក៏យ៉ាងនោះឯង ម្នាលអានន្ទ បើដូច្នោះ អ្នកគាប់ចិត្តឲ្យ ត្រូវស្តាប់ តថាគតចែកនូវបុរិសិន្ទ្រិយញាណ(១) បពិត្រព្រះអង្គមានព្រះភាគ កាលនេះជាកាលគួរ បពិត្រព្រះសុគត កាលនេះ ជាកាលគួរ សូមព្រះដ៏មានព្រះភាគ ចែកនូវបុរិសិន្ទ្រិយញាណ ពួកភិក្ខុស្តាប់ព្រះដ៏មានព្រះភាគហើយ នឹងចងចាំទុក ។ ម្នាលអានន្ទ បើដូច្នោះ អ្នកចូរស្តាប់ ធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។

១ សេចក្តីដឹងនូវឥន្ទ្រិយរបស់បុរស [illegible] ។

ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច ឥធាហំ អានន្ទ ឯកច្ចំ បុគ្គលំ(១) ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមស្ស ខោ បុគ្គលស្ស វិជ្ជមានា កុសលាបិ ធម្មា អកុសលាបិ ធម្មាតិ តមេនំ អបរេន សមយេន ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមស្ស ខោ បុគ្គលស្ស កុសលា ធម្មា អន្តរហិតា អកុសលា ធម្មា សម្មុខីភូតា អត្ថិ ច ខ្វស្ស កុសលមូលំ អសមុច្ឆិន្នំ តម្ហា តស្ស កុសលាកុសលំ បាតុភវិស្សតិ ឯវមយំ បុគ្គលោ អាយតឹ អបរិហានធម្មោ ភវិស្សតីតិ សេយ្យថាបិ អានន្ទ ពីជានិ អខណ្ឌានិ អបូតីនិ អវាតាតបហតានិ សារាទានិ សុខសយិតានិ សុខេត្តេ សុបរិកម្មកតាយ ភូមិយា និក្ខិត្តានិ ជានេយ្យាសិ ត្វំ អានន្ទ ឥមានិ ពីជានិ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សន្តីតិ ។

១ ឯកច្ចស្ស បុគ្គលស្ស ឥច្ចេកច្ចេ ។



ព្រះអានន្ទដ៏មានអាយុ បានទទួលព្រះពុទ្ធដីកានៃព្រះសម្ពុទ្ធដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ ។ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយរបស់បុគ្គលនោះបាត់ទៅ អកុសលធម៌កើតឡើងដ៏ប្រាកដ តែបុគ្គលនោះមិនទាន់មិនរំលើងកុសលមូលទេ ព្រោះហេតុនោះ កុសលនឹងកុសលរបស់បុគ្គលនោះនឹងកើតឡើងដ៏ប្រាកដវិញ បុគ្គលនេះ នឹងមានធម៌មិនសាបសូន្យតទៅទៀត ដោយប្រការយ៉ាងនេះ ម្នាលអានន្ទ ដូចពូជទាំងឡាយដែលមិនដាច់ មិនស្អុយ មិនត្រូវខ្យល់និងកំដៅថ្ងៃប្រហារ មានបណ្ដុលល្អ គេទុកដាក់ដោយល្អ ហើយគេសាបព្រោះលើទីដែលភ្ជួររាស់ដោយស្រួលបួល ក្នុងស្រែល្អ ម្នាលអានន្ទ អ្នកត្រូវដឹងថា ពូជទាំងនេះនឹងដល់នូវការដុះ លូតលាស់ឡើងធំ ទូលំទូលាយបានឬទេ ។

ឯវំ ភន្តេ ។ ឯវមេវ ខោ អហំ អានន្ទ ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមស្ស ខោ បុគ្គលស្ស វិជ្ជមានា កុសលាបិ ធម្មា អកុសលាបិ ធម្មាតិ តមេនំ អបរេន សមយេន ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមស្ស ខោ បុគ្គលស្ស កុសលា ធម្មា អន្តរហិតា អកុសលា ធម្មា សម្មុខីភូតា អត្ថិ ច ខ្វស្ស កុសលមូលំ អសមុច្ឆិន្នំ កម្ហា តស្ស កុសលា កុសលំ បាតុភវិស្សតិ ឯវមយំ បុគ្គលោ អាយតឹ អបរិហានធម្មោ ភវិស្សតីតិ ឯវម្បិ ខោ អានន្ទ តថាគតស្ស បុរិសបុគ្គលោ ចេតសា ចេតោ(១) បរិច្ច វិទិតោ ហោតិ ឯវម្បិ ខោ អានន្ទ តថាគតស្ស បុរិសិន្ទ្រិយញ្ញាណំ ចេតសា ចេតោ(២) បរិច្ច វិទិតំ ហោតិ ឯវម្បិ ខោ អានន្ទ តថាគតស្ស អាយតឹ ធម្មសមុប្បាទោ ចេតសា ចេតោ(៣) បរិច្ច វិទិតោ ហោតិ ឥធ បនាហំ អានន្ទ ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ

១-២-៣ ចិតេ បាលិ ឥតិបាឋោ ទិស្ស ។



ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ តថាគត កំណត់ដឹងនូវចិត្ត របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយ របស់បុគ្គលនេះ បាត់សូន្យទៅ អកុសលធម៌ទាំងឡាយ កើតឡើងប្រាកដ តែបុគ្គលនោះ មិនបានដាច់រំលើង កុសលមូលទេ ហេតុនោះ កុសលនឹងកុសល របស់បុគ្គលនោះ នឹងកើតប្រាកដវិញបាន បុគ្គលនេះ នឹងមានធម៌ មិនសាបសូន្យតទៅទៀត ដោយប្រការយ៉ាងនេះ ក៏យ៉ាងនោះឯង ម្នាលអានន្ទ បុរសបុគ្គលដែលតថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ បុរិសិន្ទ្រិយញ្ញាណដែលតថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ សេចក្តីកើតឡើងនៃធម៌តទៅ ដែលតថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា

ឥមស្ស ខោ បុគ្គលស្ស វិជ្ជមានា កុសលាបិ ធម្មា អកុសលាបិ ធម្មាតិ តមេនំ អបរេន សមយេន ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមស្ស ខោ បុគ្គលស្ស អកុសលា ធម្មា អន្តរហិតា កុសលា ធម្មា សម្មុខីភូតា អត្ថិ ច ខ្វស្ស អកុសលមូលំ អសមុច្ឆិន្នំ តម្ហា តស្ស កុសលាកុសលំ បាតុភវិស្សតិ ឯវមយំ បុគ្គលោ អាយតឹ បរិហានធម្មោ ភវិស្សតីតិ សេយ្យថាបិ អានន្ទ ពីជានិ អខណ្ឌានិ អបូតីនិ អវាតាតបហតានិ សារាទានិ(១) សុខសយិតានិ បុថុសិលាយ និក្ខិត្តានិ ជានេយ្យាសិ ត្វំ អានន្ទ ឥមានិ ពីជានិ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សន្តីតិ ។ នោ ហេតំ ភន្តេ ។ ឯវមេវ ខោ អហំ អានន្ទ ឥធេកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមស្ស ខោ បុគ្គលស្ស វិជ្ជមានា កុសលាបិ ធម្មា អកុសលាបិ ធម្មាតិ តមេនំ អបរេន សមយេន ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ

១ ម. ឱ. សារទានិ ។



កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា អកុសលធម៌ទាំងឡាយរបស់បុគ្គលនេះ បាត់សូន្យទៅ កុសលធម៌ទាំងឡាយ កើតឡើងប្រាកដ តែបុគ្គលនោះមិនបានកាត់រំលើងកុសលមូលទេ ព្រោះហេតុនោះ កុសលនឹងអកុសលរបស់បុគ្គលនោះ នឹងកើតប្រាកដ បុគ្គលនេះ នឹងមានធម៌សាបសូន្យ តទៅទៀត ដោយប្រការយ៉ាងនេះ ម្នាលអានន្ទ ដូចពូជទាំងឡាយ ដែលមិនដាច់ មិនស្អុយ មិនត្រូវខ្យល់នឹងកំដៅថ្ងៃប្រហារ មានខ្លឹមនៅល្អ គេទុកដាក់ដោយស្រួល តែគេសាបព្រោះលើថ្មក្រាស់ ម្នាលអានន្ទ អ្នកត្រូវដឹងថា ពូជទាំងនេះ មិនងាយនឹងដុះលូតលាស់ឡើង ទទឹងគ្រាលបានឡើយ ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគត កំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា

ឥមស្ស ខោ បុគ្គលស្ស អកុសលា ធម្មា អន្តរហិតា កុសលា ធម្មា សម្មុខីភូតា អត្ថិ ច ខ្វស្ស អកុសលមូលំ អសមុច្ឆិន្នំ តម្ហា តស្ស កុសលា-កុសលំ បាតុភវិស្សតិ ឯវមយំ បុគ្គលោ អាយតឹ បរិហានធម្មោ ភវិស្សតីតិ ឯវម្បិ ខោ អានន្ទ តថាគតស្ស បុរិសបុគ្គលោ ចេតសា ចេតោ បរិច្ច វិទិតោ ហោតិ ឯវម្បិ ខោ អានន្ទ តថាគតស្ស បុរិសិន្ទ្រិយញាណំ ចេតសា ចេតោ បរិច្ច វិទិតំ ហោតិ ឯវម្បិ ខោ អានន្ទ តថាគតស្ស អាយតឹ ធម្មសមុប្បាទោ ចេតសា ចេតោ បរិច្ច វិទិតោ ហោតិ ឥធ បនាហំ អានន្ទ ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមស្ស ខោ បុគ្គលស្ស វិជ្ជមានា កុសលាបិ ធម្មា អកុសលាបិ ធម្មាតិ តមេនំ អបរេន សមយេន ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ នត្ថិ ឥមស្ស បុគ្គលស្ស វាលគ្គកោដិនិត្តុទនមត្តោបិ សុក្កោ ធម្មោ



អកុសលធម៌ទាំងឡាយរបស់បុគ្គលនេះ បាត់សូន្យទៅ កុសលធម៌ទាំងឡាយ កើតឡើងប្រាកដវិញបាន ចំណែកបុគ្គលនោះ មិនបានដាច់រំលើងអកុសលមូលទេ ព្រោះហេតុនោះ កុសលនិងអកុសលរបស់បុគ្គលនោះ នឹងកើតប្រាកដវិញបាន បុគ្គលនេះ នឹងមានធម៌សាបសូន្យតទៅទៀត យ៉ាងនេះ ក៏យ៉ាងនោះឯង ម្នាលអានន្ទ បុរសបុគ្គលដែលតថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ បុរិសិន្ទ្រិយ-ញាណ ដែលតថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ សេចក្តីកើតឡើងនៃធម៌តទៅ ដែលតថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា ធម៌សរបស់បុគ្គលនេះ សូម្បីល្មមត្រឹមតែចាក់ដោយចុងចំពុកនៃរោមបាន មិនមានឡើយ

សមន្នាគតាយំ បុគ្គលោ ឯកន្តកាឡកេហិ អកុសលេហិ ធម្មេហិ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជិស្សតីតិ សេយ្យថាបិ អានន្ទ ពីជានិ ខណ្ឌានិ បូតីនិ វាតាតបហតានិ សុក្ខេត្តេ សុបរិកម្មកតាយ ភូមិយា និក្ខិត្តានិ ជានេយ្យាសិ ត្វំ អានន្ទ នយិមានិ ពីជានិ វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជិស្សន្តីតិ ។ ឯវំ ភន្តេ ។ ឯវមេវ ខោ អហំ អានន្ទ ឥធេកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមស្ស ខោ បុគ្គលស្ស វិជ្ជមានា កុសលាបិ ធម្មា អកុសលាបិ ធម្មាតិ តមេនំ អបរេន សមយេន ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ នត្ថិ ឥមស្ស បុគ្គលស្ស វាលគ្គកោដិនិត្តុទនមត្តោបិ សុក្កោ ធម្មោ សមន្នាគតាយំ បុគ្គលោ ឯកន្តកាឡកេហិ អកុសលេហិ ធម្មេហិ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជិស្សតីតិ ឯវម្បិ ខោ អានន្ទ តថាគតស្ស បុរិសបុគ្គលោ ចេតសា ចេតោ បរិច្ច វិទិតោ ហោតិ ។



បុគ្គលនេះ ប្រកបដោយអកុសលធម៌ទាំងឡាយ ដែលមានពណ៌ខ្មៅសុទ្ធ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងចូលទៅកាន់អបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលអានន្ទ ដូចពូជទាំងឡាយដែលដាច់ ស្អុយ ត្រូវខ្យល់និងកំដៅថ្ងៃប្រហារ ហើយគេសាបព្រោះលើដី ដែលគេភ្ជួររាស់ដោយល្អ ក្នុងស្រែល្អ ម្នាលអានន្ទ អ្នកត្រូវដឹងថា ពូជទាំងនេះនឹងមិនដុះលូតលាស់ចំរើនធំធាត់បានទេ ឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា ធម៌ស របស់បុគ្គលនេះ សូម្បីល្មមត្រឹមតែចាក់ដោយចុងចំផុតនៃរោមចាមរ មិនមានឡើយ បុគ្គលនេះ ប្រកបដោយអកុសលធម៌ទាំងឡាយ ដែលមានពណ៌ខ្មៅសុទ្ធ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងចូលទៅកាន់អបាយ ទុគ្គតិ វិនិបាត នរក យ៉ាងនោះឯង ម្នាលអានន្ទ បុរសបុគ្គល តថាគតកំណត់ដឹងដោយចិត្តយ៉ាងនេះផង

ឯវម្បិ ខោ អានន្ទ តថាគតស្ស បុរិសិន្ទ្រិយញាណំ ចេតសា ចេតោ បរិច្ច វិទិតំ ហោតិ ឯវម្បិ ខោ អានន្ទ តថាគតស្ស អាយតឹ ធម្មសមុប្បាទោ ចេតសា ចេតោ បរិច្ច វិទិតោ ហោតីតិ ។

ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សក្កា នុ ខោ ភន្តេ ឥមេសំ តិណ្ណំ បុគ្គលានំ អបរេបិ តយោ បុគ្គលា សប្បដិភាគា បញ្ញាបេតុន្តិ ។ សក្កានន្ទាតិ ភគវា ឯតទវោច ឥធាហំ អានន្ទ ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមស្ស ខោ បុគ្គលស្ស វិជ្ជមានា កុសលាបិ ធម្មា អកុសលាបិ ធម្មាតិ តមេនំ អបរេន សមយេន ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមស្ស ខោ បុគ្គលស្ស កុសលា ធម្មា អន្តរហិតា អកុសលា ធម្មា សម្មុខីភូតា អត្ថិ ច ខ្វស្ស កុសលមូលំ អសមុច្ឆិន្នំ តម្បិ សព្វេន សព្វំ សមុគ្ឃាតំ គច្ឆតិ ឯវមយំ បុគ្គលោ អាយតឹ បរិហានធម្មោ ភវិស្សតីតិ



ម្នាលអានន្ទ បុរិសិន្ទ្រិយញ្ញាណ តថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ សេចក្តីកើតឡើងនៃធម៌តទៅ តថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ។

កាលបើ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គអាចបញ្ញត្តបុគ្គល ៣ ពួកក្រៅពីបុគ្គល ៣ ពួកនេះឲ្យមានចំណែកស្មើគ្នាបាន ឬទេ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ តថាគតអាចបញ្ញត្តបាន ហើយទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយរបស់បុគ្គលនេះ បាត់សូន្យទៅ អកុសលធម៌ទាំងឡាយ កើតឡើងប្រាកដ តែបុគ្គលនោះ មិនបានគាស់រំលើងកុសលមូលទេ ឯកុសលមូលនោះ ដល់នូវការរលើងឡើងដោយប្រការទាំងពួង បុគ្គលនេះ នឹងមានធម៌សាបសូន្យតទៅទៀត យ៉ាងនេះ

សេយ្យថាបិ អានន្ទ អង្គារកំ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ បុថុសិលាយ និក្ខិត្តំ ជានេយ្យាសិ ត្វំ អានន្ទ នយិទំ អង្គារកំ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សតីតិ ។ ឯវំ ភន្តេ ។ សេយ្យថាបិ វា បនានន្ទ សាយណ្ហសមយេ សុរិយេ ឱគច្ឆន្តេ ជានេយ្យាសិ ត្វំ អានន្ទ អាលោកោ អន្តរធាយិស្សតិ អន្ធការោ បាតុភវិស្សតីតិ ។ ឯវំ ភន្តេ ។ សេយ្យថាបិ វា បនានន្ទ អភិទោសអឌ្ឍរត្តំ ភត្តកាលសមយេ ជានេយ្យាសិ ត្វំ អានន្ទ អាលោកោ អន្តរហិតោ អន្ធការោ បាតុភូតោតិ ។ ឯវំ ភន្តេ ។ ឯវមេវ ខោ អហំ អានន្ទ ឥធេកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមស្ស ខោ បុគ្គលស្ស វិជ្ជមានា កុសលាបិ ធម្មា អកុសលាបិ ធម្មាតិ តមេនំ អបរេន សមយេន ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមស្ស ខោ បុគ្គលស្ស កុសលា ធម្មា អន្តរហិតា អកុសលា ធម្មា សម្មុខីភូតា



ម្នាលអានន្ទ ដូចរងើកភ្លើងទាំងឡាយកំពុងឆេះ រន្ទាលច្រាលឆ្អៅ ដែលគេដាក់លើផែនថ្មដ៏ក្រាស់ ម្នាលអានន្ទ អ្នកត្រូវដឹងថា រងើកភ្លើងទាំងនេះ នឹងមិនដល់នូវការចំរើនលូតលាស់ធំទូលាយឡើយ ឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ មួយទៀត ដូចព្រះអាទិត្យលិច ក្នុងសាយណ្ហសម័យ ម្នាលអានន្ទ អ្នកត្រូវដឹងថា ពន្លឺនឹងបាត់សូន្យទៅ ងងឹតនឹងកើតប្រាកដបានឡើង ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ ពុំនោះសោត ដូចសម័យ ភត្តកាល ចំពាក់កណ្ដាលយប់ ម្នាលអានន្ទ អ្នកត្រូវដឹងថា ពន្លឺបាត់ទៅ ងងឹតកើតប្រាកដបានឡើង ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយរបស់បុគ្គលនេះ បាត់សូន្យទៅ អកុសលធម៌ទាំងឡាយ កើតប្រាកដ

អត្ថិ ច ខ្វស្ស កុសលមូលំ អសមុច្ឆិន្នំ តម្បិ សព្វេន សព្វំ សមុគ្ឃាតំ គច្ឆតិ ឯវមយំ បុគ្គលោ អាយតឹ បរិហានធម្មោ ភវិស្សតីតិ ឯវម្បិ ខោ អានន្ទ តថាគតស្ស បុរិសបុគ្គលោ ចេតសា ចេតោ បរិច្ច វិទិតោ ហោតិ ឯវម្បិ ខោ អានន្ទ តថាគតស្ស បុរិសិន្ទ្រិយញ្ញាណំ ចេតសា ចេតោ បរិច្ច វិទិតំ ហោតិ ឯវម្បិ ខោ អានន្ទ តថាគតស្ស អាយតឹ ធម្មសមុប្បាទោ ចេតសា ចេតោ បរិច្ច វិទិតោ ហោតិ ។ ឥធ បនាហំ អានន្ទ ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមស្ស ខោ បុគ្គលស្ស វិជ្ជមានា កុសលាបិ ធម្មា អកុសលាបិ ធម្មាតិ តមេនំ អបរេន សមយេន ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមស្ស ខោ បុគ្គលស្ស អកុសលា ធម្មា អន្តរហិតា កុសលា ធម្មា សម្មុខីភូតា អត្ថិ ច ខ្វស្ស អកុសលមូលំ អសមុច្ឆិន្នំ តម្បិ សព្វេន សព្វំ សមុគ្ឃាតំ គច្ឆតិ



តែបុគ្គលនោះ មិនទាន់គាស់រំលើងកុសលមូលទេ កុសលមូលនោះ ដល់នូវការរំលើកឡើង ដោយប្រការទាំងពួង បុគ្គលនេះ នឹងមានធម៌សាបសូន្យតទៅទៀត ដោយប្រការយ៉ាងនេះ គឺយ៉ាងនេះឯង ម្នាលអានន្ទ បុរិសបុគ្គល តថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ បុរិសិន្ទ្រិយញ្ញាណ តថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ សេចក្តីកើតឡើងនៃធម៌តទៅ តថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្ត របស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា អកុសលធម៌ទាំងឡាយរបស់បុគ្គលនេះ បាត់សូន្យទៅ កុសលធម៌ទាំងឡាយកើតប្រាកដ តែបុគ្គលនោះ មិនទាន់គាស់រំលើងអកុសលមូលទេ អកុសលមូលនោះ ដល់នូវការរំលើកឡើង ដោយប្រការទាំងពួង

ឯវមយំ បុគ្គលោ អាយតិំ អបរិហានធម្មោ ភវិស្សតីតិ សេយ្យថាបិ អានន្ទ អង្គារានិ អាទិត្តានិ សម្បជ្ជលិតានិ សជោតិភូតានិ សុក្ខេ តិណបុញ្ជេ វា កដ្ឋបុញ្ជេ វា និក្ខិត្តានិ ជានេយ្យាសិ ត្វំ អានន្ទ ឥមានិ អង្គារានិ វុឌ្ឍឹ វិរូឡ្ហឹ វេបុល្លំ អាបជ្ជិស្សន្តីតិ ។ ឯវំ ភន្តេ ។ សេយ្យថាបិ វា បនានន្ទ រត្តិយា បច្ចូសសមយេ សុរិយេ ឧគ្គច្ឆន្តេ ជានេយ្យាសិ ត្វំ អានន្ទ អន្ធការោ អន្តរធាយិស្សតិ អាលោកោ បាតុភវិស្សតីតិ ។ ឯវំ ភន្តេ ។ សេយ្យថាបិ វា បនានន្ទ អភិទោសមជ្ឈន្តិកេ ភត្តកាលសមយេ ជានេយ្យាសិ ត្វំ អានន្ទ អន្ធការោ អន្តរហិតោ អាលោកោ បាតុភូតោតិ ។ ឯវំ ភន្តេ ។ ឯវមេវ ខោ អហំ អានន្ទ ឥធេកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមស្ស ខោ បុគ្គលស្ស វិជ្ជមានា កុសលាបិ ធម្មា អកុសលាបិ ធម្មាតិ តមេនំ អបរេន សមយេន ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ



បុគ្គលនេះ នឹងមានធម៌មិនបានសាបសូន្យតទៅទៀតយ៉ាងនេះ ម្នាលអានន្ទ ដូចរងើកភ្លើងទាំងឡាយ ដែលឆេះឆួល ព្រោលផ្លោ ហើយបុគ្គលដាក់លើគំនរស្មៅក្តី គំនរឧសក្តី ដែលស្ងួត ម្នាលអានន្ទ អ្នកត្រូវដឹងថា រងើកភ្លើងទាំងនេះ នឹងដល់នូវការចំរើន ដុះដាលធំទូលាយបានឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ មួយទៀត ដូចព្រះអាទិត្យរះឡើង ក្នុងបច្ចូសសម័យនៃរាត្រី ម្នាលអានន្ទ អ្នកត្រូវដឹងថា ងងឹតនឹងបាត់ទៅ ពន្លឺនឹងកើតប្រាកដឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ ពុំនោះសោត ដូចសម័យកណ្តាល ពេលថ្ងៃត្រង់ជាក់ ម្នាលអានន្ទ អ្នកត្រូវដឹងថា ងងឹតបាត់ទៅ ពន្លឺកើតប្រាកដឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្ត របស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា

ឥមស្ស ខោ បុគ្គលស្ស អកុសលា ធម្មា អន្តរហិតា កុសលា ធម្មា សម្មុខីភូតា អត្ថិ ច ខ្វស្ស អកុសលមូលំ អសមុច្ឆិន្នំ តម្បិ សព្វេន សព្វំ សមុគ្ឃាតំ គច្ឆតិ ឯវាយំ បុគ្គលោ អាយតឹ អបរិហានធម្មោ ភវិស្សតីតិ ឯវម្បិ ខោ អានន្ទ តថាគតស្ស បុរិសបុគ្គលោ ចេតសា ចេតោ បរិច្ច វិទិតោ ហោតិ ឯវម្បិ ខោ អានន្ទ តថាគតស្ស បុរិសិន្ទ្រិយញ្ញាណំ ចេតសា ចេតោ បរិច្ច វិទិតំ ហោតិ ឯវម្បិ ខោ អានន្ទ តថាគតស្ស អាយតឹ ធម្មសមុប្បាទោ ចេតសា ចេតោ បរិច្ច វិទិតោ ហោតិ ឥធ បនាហំ អានន្ទ ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមស្ស ខោ បុគ្គលស្ស វិជ្ជមានា កុសលាបិ ធម្មា អកុសលាបិ ធម្មាតិ តមេនំ អបរេន សមយេន ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ នត្ថិ ឥមស្ស បុគ្គលស្ស វាលគ្គកោដិនិត្តុទនមត្តោបិ អកុសលោ ធម្មោ



អកុសលធម៌តាំងឡាយ របស់បុគ្គលនេះ សាបសូន្យទៅ កុសលធម៌តាំងឡាយកើតប្រាកដ តែបុគ្គលនោះ មិនទាន់ដកនូវអកុសល-មូលទេ អកុសលមូលនោះ ដល់នូវការដកឡើង ដោយប្រការទាំងពួង បុគ្គលនេះ នឹងមានធម៌មិនសាបសូន្យទៅទៀត យ៉ាងនេះក៏យ៉ាងនោះឯង ម្នាលអានន្ទ បុរសបុគ្គល តថាគត កំណត់ដឹងដោយចិត្ត យ៉ាងនេះផង ម្នាលអានន្ទ បុរិសិន្ទ្រិយញ្ញាណ តថាគតកំណត់ដឹងដោយចិត្ត យ៉ាងនេះផង ម្នាលអានន្ទ សេចក្តីកើតឡើងនៃធម៌តទៅ តថាគត កំណត់ដឹងដោយចិត្ត យ៉ាងនេះផង ម្នាលអានន្ទ តថាគត កំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌តាំងឡាយក្តី អកុសលធម៌តាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគត កំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា អកុសលធម៌របស់បុគ្គលនេះ ត្រឹមតែចាក់ដោយចុងចំបុក នៃរោមបាន មិនមានឡើយ

សមន្នាគតាយំ បុគ្គលោ ឯកន្តសុក្កេហិ អនវជ្ជេហិ ធម្មេហិ ទិដ្ឋេវ ធម្មេ បរិនិព្វាយិស្សតីតិ សេយ្យថាបិ អានន្ទ អង្គារានិ សីតានិ និព្វុតានិ សុក្ខេ តិណបុញ្ជេ វា កដ្ឋបុញ្ជេ វា និក្ខិត្តានិ ជានេយ្យាសិ ត្វំ អានន្ទ ឥមានិ អង្គារានិ វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជិស្សន្តីតិ ។ នោ ហេតំ ភន្តេ ។ ឯវមេវ ខោ អហំ អានន្ទ ឥធេកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមស្ស ខោ បុគ្គលស្ស វិជ្ជមានា កុសលាបិ ធម្មា អកុសលាបិ ធម្មាតិ តមេនំ អបរេន សមយេន ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ នត្ថិ ឥមស្ស បុគ្គលស្ស វាលគ្គកោដិនិត្តុទនមត្តោបិ អកុសលោ ធម្មោ សមន្នាគតាយំ បុគ្គលោ ឯកន្តសុក្កេហិ អនវជ្ជេហិ ធម្មេហិ ទិដ្ឋេវ ធម្មេ បរិនិព្វាយិស្សតីតិ ឯវម្បិ ខោ អានន្ទ តថាគតស្ស បុរិសបុគ្គលោ ចេតសា ចេតោ បរិច្ច វិទិតោ ហោតិ



បុគ្គលនេះ ជាអ្នកប្រកបដោយធម៌ទាំងឡាយ ដែលគ្មានទោស មានចំណែកសសុទ្ធ នឹងបរិនិព្វាន ក្នុងបច្ចុប្បន្ន ម្នាលអានន្ទ ដូចរងើកភ្លើងទាំងឡាយ ដែលរលត់ត្រជាក់ បុគ្គលដាក់លើគំនរស្មៅ ឬគំនរអុសដ៏ស្ងួត ម្នាលអានន្ទ អ្នកត្រូវដឹងថា រងើកភ្លើងទាំងនេះ មិនដល់នូវការចំរើន រាលដាលឡើងធំទូលាយទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ ។ សម័យក្រោយទៀត តថាគត កំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា អកុសលធម៌របស់បុគ្គលនេះ ត្រឹមតែចាក់ដោយចុងចំផុត នៃរោមមិនមានឡើយ បុគ្គលនេះ ប្រកបដោយធម៌ទាំងឡាយ ដែលមិនមានទោស មានចំណែកសសុទ្ធ នឹងបរិនិព្វាន ក្នុងបច្ចុប្បន្នដូច្នោះឯង ម្នាលអានន្ទ បុរសបុគ្គល តថាគតកំណត់ដឹងដោយចិត្ត យ៉ាងនេះផង

ឯវម្បិ ខោ អានន្ទ តថាគតស្ស បុរិសិន្ទ្រិយញាណំ ចេតសា ចេតោ បរិច្ច វិទិតំ ហោតិ ឯវម្បិ ខោ អានន្ទ តថាគតស្ស អាយតឹ ធម្មសមុប្បាទោ ចេតសា ចេតោ បរិច្ច វិទិតោ ហោតិ ។ តត្រានន្ទ យេ តេ បុរិមា តយោ បុគ្គលា តេសំ តិណ្ណំ បុគ្គលានំ ឯកោ អបរិហានធម្មោ ឯកោ បរិហានធម្មោ ឯកោ អាបាយិកោ នេរយិកោ តត្រានន្ទ យេមេ បច្ឆិមា តយោ បុគ្គលា ឥមេសំ តិណ្ណំ បុគ្គលានំ ឯកោ អបរិហានធម្មោ ឯកោ បរិហានធម្មោ ឯកោ បរិនិព្វានធម្មោតិ ។

(៦៣) និព្វេធិកបរិយាយំ វោ ភិក្ខវេ ធម្មបរិយាយំ ទេសេស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច សោ ភិក្ខវេ និព្វេធិកបរិយាយោ ធម្មបរិយាយោ ។ កាមា ភិក្ខវេ វេទិតព្វា



ម្នាលអានន្ទ បុរិសិន្ទ្រិយញ្ញាណ តថាគត កំណត់ដឹងដោយចិត្តយ៉ាងនេះឯង ម្នាលអានន្ទ សេចក្តីកើតឡើងនៃធម៌តទៅ តថាគត កំណត់ដឹង ដោយចិត្តយ៉ាងនេះឯង ។ ម្នាលអានន្ទ បណ្តាបុគ្គលទាំងនោះ បុគ្គល ៣ នាក់ដើមណា បណ្តាបុគ្គលទាំង ៣ នោះ បុគ្គលមួយមានធម៌មិនសាបសូន្យ បុគ្គលមួយមានធម៌សាបសូន្យ បុគ្គលមួយកើតក្នុងអបាយ នៅនរក ម្នាលអានន្ទ បណ្តាបុគ្គលទាំងនោះ បុគ្គល ៣ នាក់ចុងណា បណ្តាបុគ្គលទាំង ៣ នេះ បុគ្គលមួយមានសភាពមិនសាបសូន្យ បុគ្គលមួយមានសភាពសាបសូន្យ បុគ្គលមួយមានសភាពបរិនិព្វាន ។

(៦៣) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវនិព្វេធិក-បរិយាយ (ហេតុដែលទំលាយនូវលោភក្ខន្ធជាដើម ដែលបុគ្គលមិនបានទំលាយ) ជាធម្មបរិយាយ ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់ ធ្វើទុកក្នុងចិត្តនូវបរិយាយនោះ ឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ បានទទួលព្រះពុទ្ធដីកា ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ និព្វេធិកបរិយាយ ជាធម្មបរិយាយនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាមទាំងឡាយ បុគ្គលគប្បីដឹង

កាមានំ និទានសម្ភវោ វេទិតព្វោ កាមានំ វេមត្តតា វេទិតព្វា កាមានំ វិបាកោ វេទិតព្វោ កាមនិរោធោ វេទិតព្វោ កាមនិរោធគាមិនីបដិបទា វេទិតព្វា ។ វេទនា ភិក្ខវេ វេទិតព្វា វេទនានំ និទានសម្ភវោ វេទិតព្វោ វេទនានំ វេមត្តតា វេទិតព្វា វេទនានំ វិបាកោ វេទិតព្វោ វេទនានិរោធោ វេទិតព្វោ វេទនានិរោធគាមិនីបដិបទា វេទិតព្វា ។ សញ្ញា ភិក្ខវេ វេទិតព្វា សញ្ញានំ និទានសម្ភវោ វេទិតព្វោ សញ្ញានំ វេមត្តតា វេទិតព្វា សញ្ញានំ វិបាកោ វេទិតព្វោ សញ្ញានិរោធោ វេទិតព្វោ សញ្ញានិរោធគាមិនីបដិបទា វេទិតព្វា ។ អាសវា ភិក្ខវេ វេទិតព្វា អាសវានំ និទានសម្ភវោ វេទិតព្វោ អាសវានំ វេមត្តតា វេទិតព្វា អាសវានំ វិបាកោ វេទិតព្វោ



ហេតុនាំឲ្យកើតកាមទាំងឡាយ បុគ្គលគប្បីដឹង សេចក្ដីប្លែកគ្នានៃកាមទាំងឡាយ បុគ្គលគប្បីដឹង វិបាកនៃកាមទាំងឡាយ បុគ្គលគប្បីដឹង សេចក្ដីរលត់កាម បុគ្គលគប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្ដីរលត់កាម បុគ្គលគប្បីដឹង ។ ម្នាលភិក្ខុទាំងឡាយ វេទនាទាំងឡាយ បុគ្គលគប្បីដឹង ហេតុនាំឲ្យកើតវេទនាទាំងឡាយ បុគ្គលគប្បីដឹង សេចក្ដីប្លែកគ្នានៃវេទនាទាំងឡាយ បុគ្គលគប្បីដឹង វិបាកនៃវេទនាទាំងឡាយ បុគ្គលគប្បីដឹង សេចក្ដីរលត់វេទនា បុគ្គលគប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្ដីរលត់វេទនា បុគ្គលគប្បីដឹង ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាទាំងឡាយ បុគ្គលគប្បីដឹង ហេតុនាំឲ្យកើតសញ្ញាទាំងឡាយ បុគ្គលគប្បីដឹង សេចក្ដីប្លែកគ្នានៃសញ្ញាទាំងឡាយ បុគ្គលគប្បីដឹង វិបាករបស់សញ្ញាទាំងឡាយ បុគ្គលគប្បីដឹង សេចក្ដីរលត់សញ្ញា បុគ្គលគប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្ដីរលត់សញ្ញា បុគ្គលគប្បីដឹង ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ បុគ្គលគប្បីដឹង ហេតុនាំឲ្យកើតអាសវៈទាំងឡាយ បុគ្គលគប្បីដឹង សេចក្ដីប្លែកគ្នានៃអាសវៈទាំងឡាយ បុគ្គលគប្បីដឹង វិបាករបស់អាសវៈទាំងឡាយ បុគ្គលគប្បីដឹង

អាសវនិរោធោ វេទិតព្វោ អាសវនិរោធគាមិនីបដិបទា វេទិតព្វា ។ កម្មំ ភិក្ខវេ វេទិតព្វំ កម្មានំ និទាន-សម្ភវោ វេទិតព្វោ កម្មានំ វេមត្តតា វេទិតព្វា កម្មានំ វិបាកោ វេទិតព្វោ កម្មនិរោធោ វេទិតព្វោ កម្មនិរោធ-គាមិនីបដិបទា វេទិតព្វា ។ ទុក្ខំ ភិក្ខវេ វេទិតព្វំ ទុក្ខស្ស និទានសម្ភវោ វេទិតព្វោ ទុក្ខស្ស វេមត្តតា វេទិតព្វា ទុក្ខស្ស វិបាកោ វេទិតព្វោ ទុក្ខនិរោធោ វេទិតព្វោ ទុក្ខនិរោធគាមិនីបដិបទា វេទិតព្វា ។

កាមា ភិក្ខវេ វេទិតព្វា កាមានំ និទានសម្ភវោ វេទិតព្វោ កាមានំ វេមត្តតា វេទិតព្វា កាមានំ វិបាកោ វេទិតព្វោ កាមនិរោធោ វេទិតព្វោ កាមនិរោធគាមិនី-បដិបទា វេទិតព្វាតិ ឥតិ យំ តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ បញ្ចិមេ ភិក្ខវេ កាមគុណា ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសំហិតា



សេចក្តីរលត់អាសវៈ បុគ្គលគប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្តីរលត់អាសវៈ បុគ្គលគប្បីដឹង ។ ម្នាលភិក្ខុទាំងឡាយ កម្មបុគ្គលគប្បីដឹង ហេតុនាំឲ្យកើតកម្មទាំងឡាយ បុគ្គលគប្បីដឹង សេចក្តីប្លែកគ្នានៃកម្មទាំងឡាយ បុគ្គលគប្បីដឹង វិបាករបស់កម្មទាំងឡាយ បុគ្គលគប្បីដឹង សេចក្តីរលត់កម្ម បុគ្គលគប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្តីរលត់កម្ម បុគ្គលគប្បីដឹង ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខបុគ្គលគប្បីដឹង ហេតុនាំឲ្យកើតទុក្ខ បុគ្គលគប្បីដឹង សេចក្តីប្លែកគ្នានៃទុក្ខ បុគ្គលគប្បីដឹង វិបាករបស់ទុក្ខ បុគ្គលគប្បីដឹង សេចក្តីរលត់ទុក្ខ បុគ្គលគប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្តីរលត់ទុក្ខ បុគ្គលគប្បីដឹង ។

ម្នាលភិក្ខុទាំងឡាយ កាមទាំងឡាយ បុគ្គលគប្បីដឹង ហេតុនាំឲ្យកើតកាមទាំងឡាយ បុគ្គលគប្បីដឹង សេចក្តីប្លែកគ្នានៃកាមទាំងឡាយ បុគ្គលគប្បីដឹង វិបាករបស់កាមទាំងឡាយ បុគ្គលគប្បីដឹង សេចក្តីរលត់កាម បុគ្គលគប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្តីរលត់កាម បុគ្គលគប្បីដឹង ពាក្យដែលតថាគតសំដែងហើយដូច្នេះ ពាក្យនុ៎ះ តថាគតសំដែងហើយ ព្រោះអាស្រ័យអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាមគុណនេះមាន ៥ គឺ រូបទាំងឡាយ ដែលបុគ្គលគួរដឹងច្បាស់ដោយចក្ខុ ជារូបគួរប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម

រជនីយា សោតវិញ្ញេយ្យា សទ្ទា ។បេ។ ឃាន-វិញ្ញេយ្យា គន្ធា ជិវ្ហាវិញ្ញេយ្យា រសា កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសំហិតា រជនីយា ។ អបិ ច ខោ ភិក្ខវេ នេតេ កាមា កាមគុណា នាមេតេ(១) អរិយស្ស វិនយេ វុច្ចន្តិ ។

សង្កប្បរាគោ បុរិសស្ស កាមោ
នេតេ កាមា យានិ ចិត្រានិ លោកេ
សង្កប្បរាគោ បុរិសស្ស កាមោ
តិដ្ឋន្តិ ចិត្រានិ តថេវ លោកេ
អថេត្ថ ធីរា វិនយន្តិ ឆន្ទន្តិ ។

កតមោ ច ភិក្ខវេ កាមានំ និទានសម្ភវោ ។ ផស្សោ ភិក្ខវេ កាមានំ និទានសម្ភវោ ។ កតមា ច ភិក្ខវេ កាមានំ វេមត្តតា ។ អញ្ញោ ភិក្ខវេ កាមោ រូបេសុ អញ្ញោ កាមោ

១ ម. ឱ. កាមគុណា នាម នេតេ កាមា ។



ជាទីតាំងនៃសេចក្តីត្រេកអរ ១ សំឡេងទាំងឡាយ ដែលបុគ្គលគួរដឹងច្បាស់ដោយត្រចៀក ។បេ។ ក្លិនទាំងឡាយ ដែលបុគ្គលគួរដឹងច្បាស់ដោយច្រមុះ រសទាំងឡាយ ដែលបុគ្គលគួរដឹងច្បាស់ ដោយអណ្តាត ផ្សព្វៈទាំងឡាយ ដែលបុគ្គលគួរដឹងច្បាស់ដោយកាយ គួរប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាទីតាំងនៃសេចក្តីត្រេកអរ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងនុ៎ះ មិនមែនកាមទេ ធម៌ទាំងនុ៎ះហៅថា កាមគុណ ក្នុងវិន័យនៃអរិយៈ ។

សេចក្តីត្រេកអរកើតឡើង ដោយសំណាបការត្រិះរិះ ជាកាម
របស់បុរស អារម្មណ៍ដ៏វិចិត្រ ក្នុងលោក មិនមែនកាមទេ
សេចក្តីត្រេកអរកើតឡើង ដោយសំណាបការត្រិះរិះ ជាកាម
របស់បុរស អារម្មណ៍ដ៏វិចិត្រទាំងឡាយ តែងឋិតនៅក្នុង
លោក ដោយប្រការដូច្នោះ តែអ្នកប្រាជ្ញទាំងឡាយ រមែង
កំចាត់បង់នូវសេចក្តីពេញចិត្ត ក្នុងអារម្មណ៍ទាំងឡាយនុ៎ះចេញ ។

ម្នាលភិក្ខុទាំងឡាយ ចុះហេតុនាំឲ្យកើតកាមទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ផស្សៈជាហេតុនាំឲ្យកើតកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីប្លែកគ្នានៃកាមទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាមក្នុងរូបទាំងឡាយ ដោយឡែក

សទ្ទេសុ អញ្ញោ កាមោ គន្ធេសុ អញ្ញោ កាមោ រសេសុ អញ្ញោ កាមោ ផោដ្ឋព្វេសុ ។ អយំ វុច្ចតិ ភិក្ខវេ កាមានំ វេមត្តតា ។ កតមោ ច ភិក្ខវេ កាមានំ វិបាកោ ។ យំ ខោ ភិក្ខវេ កាមយមានោ តជ្ជំ តជ្ជំ អត្តភាវំ អភិនិព្វត្តេតិ បុញ្ញភាគិយំ វា អបុញ្ញភាគិយំ វា អយំ វុច្ចតិ ភិក្ខវេ កាមានំ វិបាកោ ។ កតមោ ច ភិក្ខវេ កាមនិរោធោ ។ ផស្សនិរោធា ភិក្ខវេ កាមនិរោធោ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ កាមនិរោធគាមិនីបដិបទា សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ យតោ ច ខោ ភិក្ខវេ អរិយសាវកោ ឯវំ កាមេ បជានាតិ ឯវំ កាមានំ និទានសម្ភវំ បជានាតិ ឯវំ កាមានំ វេមត្តតំ បជានាតិ ឯវំ កាមានំ វិបាកំ បជានាតិ ឯវំ កាមនិរោធំ បជានាតិ ឯវំ កាមនិរោធគាមិនីបដិបទំ បជានាតិ



កាមក្នុងសំឡេងទាំងឡាយ ដោយឡែក កាមក្នុងក្លិនទាំងឡាយ ដោយឡែក កាមក្នុងរសទាំងឡាយ ដោយឡែក កាមក្នុងផោដ្ឋព្វៈទាំងឡាយ ដោយឡែក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីប្លែកគ្នានៃកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះវិបាករបស់កាមទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលប្រាថ្នានូវអារម្មណ៍ណា ញុំាងអត្តភាពដែលកើតអំពីអារម្មណ៍នោះៗ ជាចំណែកបុណ្យក្តី ចំណែកបាបក្តី ឲ្យកើតឡើង ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិបាករបស់កាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់កាម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីរលត់កាម ព្រោះរលត់ផស្សៈ ។ មគ្គដ៏ប្រសើរប្រកបដោយអង្គ៨ នេះឯង ជាបដិបទាដំណើរទៅកាន់សេចក្តីរលត់កាម គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបើ អរិយសាវក ដឹងច្បាស់នូវកាមទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវហេតុនាំឲ្យកើតកាមទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្លែកគ្នា នៃកាមទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវវិបាករបស់កាមទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់កាមយ៉ាងនេះ ដឹងច្បាស់នូវបដិបទាដំណើរទៅកាន់សេចក្តីរលត់កាមយ៉ាងនេះហើយ

សោ ឥមំ និព្វេធិកំ ព្រហ្មចរិយំ បជានាតិ កាមនិរោធំ ។ កាមា ភិក្ខវេ វេទិតព្វា ។បេ។ កាមនិរោធគាមិនីបដិបទា វេទិតព្វាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

វេទនា ភិក្ខវេ វេទិតព្វា ។បេ។ វេទនានិរោធគាមិនីបដិបទា វេទិតព្វាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ តិស្សោ ឥមា ភិក្ខវេ វេទនា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ កតមោ ច ភិក្ខវេ វេទនានំ និទានសម្ភវោ ។ ផស្សោ ភិក្ខវេ វេទនានំ និទានសម្ភវោ ។ កតមា ច ភិក្ខវេ វេទនានំ វេមត្តតា ។ អត្ថិ ភិក្ខវេ សាមិសា សុខា វេទនា អត្ថិ និរាមិសា សុខា វេទនា អត្ថិ សាមិសា ទុក្ខា វេទនា អត្ថិ និរាមិសា ទុក្ខា វេទនា អត្ថិ សាមិសា អទុក្ខមសុខា វេទនា អត្ថិ និរាមិសា អទុក្ខមសុខា វេទនា ។



អរិយសាវ័កនោះតែងដឹងច្បាស់នូវព្រហ្មចរិយធម៌ដែលជាគ្រឿងទំលុះទំលាយ (នូវកិលេសមានលោភៈជាដើម) នេះថាជាសេចក្តីរលត់កាម ។ ម្នាលភិក្ខុទាំងឡាយ កាមទាំងឡាយ បុគ្គលគប្បីដឹង ។បេ។ បដិបទាជាដំណើរទៅកាន់សេចក្តីរលត់កាម បុគ្គលគប្បីដឹង ពាក្យណាដែលតថាគតសំដែងហើយដូច្នេះ ពាក្យនុ៎ះ តថាគតសំដែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ វេទនាទាំងឡាយ បុគ្គលគប្បីដឹង ។បេ។ បដិបទាជាដំណើរទៅកាន់សេចក្តីរលត់វេទនា បុគ្គលគប្បីដឹង គឺពាក្យដែលតថាគតសំដែងហើយ ដូច្នេះនុ៎ះ ពាក្យនុ៎ះ តថាគតសំដែងហើយ ព្រោះអាស្រ័យអ្វី ។ ម្នាលភិក្ខុទាំងឡាយ វេទនានេះ មាន ៣ យ៉ាងគឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនាំឲ្យកើតវេទនាទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ផស្សៈជាហេតុនាំឲ្យកើតវេទនាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីផ្សេងគ្នានៃវេទនាទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សុខវេទនា ប្រកបដោយអាមិសៈក៏មាន សុខវេទនា មិនប្រកបដោយអាមិសៈក៏មាន ទុក្ខវេទនា ប្រកបដោយអាមិសៈក៏មាន ទុក្ខវេទនា មិនប្រកបដោយអាមិសៈក៏មាន អទុក្ខមសុខវេទនា ប្រកបដោយអាមិសៈក៏មាន អទុក្ខមសុខវេទនា មិនប្រកបដោយអាមិសៈក៏មាន ។

អយំ វុច្ចតិ ភិក្ខវេ កម្មានំ វេមត្តតា ។ កតមោ ច ភិក្ខវេ កម្មានំ វិបាកោ ។ យំ ខោ ភិក្ខវេ វេទយមានោ តជ្ជំ តជ្ជំ អត្តភាវំ អភិនិព្វត្តេតិ បុញ្ញភាគិយំ វា អបុញ្ញភាគិយំ វា អយំ វុច្ចតិ ភិក្ខវេ កម្មានំ វិបាកោ ។ កតមោ ច ភិក្ខវេ កម្មនិរោធោ ។ ផស្សនិរោធា ភិក្ខវេ កម្មនិរោធោ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ កម្មនិរោធគាមិនីបដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ យតោ ខោ ភិក្ខវេ អរិយសាវកោ ឯវំ កម្មំ បជានាតិ ឯវំ កម្មានំ និទានសម្ភវំ បជានាតិ ឯវំ កម្មានំ វេមត្តតំ បជានាតិ ឯវំ កម្មានំ វិបាកំ បជានាតិ ឯវំ កម្មនិរោធំ បជានាតិ ឯវំ កម្មនិរោធគាមិនីបដិបទំ បជានាតិ សោ ឥមំ និព្វេធិកំ ព្រហ្មចរិយំ បជានាតិ កម្មនិរោធំ ។



ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីផ្សេងគ្នានៃកម្មទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះវិបាករបស់កម្មទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គល ទទួលត្រូវផលនូវកម្មណា រមែងញុំាងអត្តភាព ដែលកើតអំពីកម្មនោះ ៗ ជាចំណែកបុណ្យក្តី ចំណែកបាបក្តី ឲ្យកើតឡើង ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិបាករបស់កម្មទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់កម្ម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីរលត់កម្ម ព្រោះរលត់ផស្សៈ ។ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាបដិបទា ជាដំណើរទៅកាន់សេចក្តីរលត់កម្ម គឺសម្មាទិដ្ឋិ ១ ។បេ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលណាអរិយសាវក ដឹងច្បាស់នូវកម្មយ៉ាងនេះ ដឹងច្បាស់នូវហេតុនាំឲ្យកើតកម្មទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីផ្សេងគ្នា នៃកម្មទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវវិបាក របស់កម្មទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់កម្មយ៉ាងនេះ ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់សេចក្តីរលត់កម្មយ៉ាងនេះហើយ អរិយសាវកនោះ ក៏ដឹងច្បាស់នូវព្រហ្មចរិយធម៌ ដែលជាគ្រឿងទំលុះទំលាយនេះ ថាជាសេចក្តីរលត់កម្ម ។

វេទនា ភិក្ខវេ វេទិតព្វា ។បេ។ វេទនានិរោធគាមិនី-
បដិបទា វេទិតព្វាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ
បដិច្ច វុត្តំ ។

សញ្ញា ភិក្ខវេ វេទិតព្វា ។បេ។ សញ្ញានិរោធ-
គាមិនីបដិបទា វេទិតព្វាតិ ឥតិ ខោ បនេតំ វុត្តំ
កិញ្ចេតំ បដិច្ច វុត្តំ ។ ឆយិមា ភិក្ខវេ សញ្ញា
រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា
ផោដ្ឋព្វសញ្ញា ធម្មសញ្ញា ។ កតមោ ច ភិក្ខវេ
សញ្ញានំ និទានសម្ភវោ ។ ផស្សោ ភិក្ខវេ សញ្ញានំ
និទានសម្ភវោ ។ កតមា ច ភិក្ខវេ សញ្ញានំ
វេមត្តតា ។ អញ្ញា ភិក្ខវេ សញ្ញា រូបេសុ អញ្ញា
សញ្ញា សទ្ទេសុ អញ្ញា សញ្ញា គន្ធេសុ អញ្ញា សញ្ញា
រសេសុ អញ្ញា សញ្ញា ផោដ្ឋព្វេសុ អញ្ញា សញ្ញា
ធម្មេសុ ។ អយំ វុច្ចតិ ភិក្ខវេ សញ្ញានំ វេមត្តតា ។



ម្នាលភិក្ខុទាំងឡាយ វេទនាទាំងឡាយ បុគ្គលគប្បីដឹង ។បេ។ បដិបទា
ជាដំណើរទៅកាន់សេចក្ដីរលត់វេទនា បុគ្គលគប្បីដឹង ពាក្យណាដែល
តថាគតសំដែងហើយដូច្នេះ ពាក្យនុ៎ះ តថាគតសំដែងហើយ ព្រោះ
អាស្រ័យហេតុនេះឯង ។

ម្នាលភិក្ខុទាំងឡាយ សញ្ញាទាំងឡាយ បុគ្គលគប្បីដឹង ។បេ។ បដិបទា
ជាដំណើរទៅកាន់សេចក្ដីរលត់សញ្ញា បុគ្គលគប្បីដឹង ពាក្យដែលតថាគត
សំដែងហើយ ដូច្នេះនុ៎ះ ពាក្យនុ៎ះ តថាគតសំដែងហើយ ព្រោះអាស្រ័យអ្វី ។
ម្នាលភិក្ខុទាំងឡាយ សញ្ញានេះមាន ៦ យ៉ាង គឺរូបសញ្ញា ១ សទ្ទសញ្ញា ១
គន្ធសញ្ញា ១ រសសញ្ញា ១ ផោដ្ឋព្វសញ្ញា ១ ធម្មសញ្ញា ១ ។
ម្នាលភិក្ខុទាំងឡាយ ចុះហេតុនាំឲ្យកើតសញ្ញាទាំងឡាយ តើដូចម្ដេច ។
ម្នាលភិក្ខុទាំងឡាយ ផស្សៈជាហេតុនាំឲ្យកើតសញ្ញាទាំងឡាយ ។
ម្នាលភិក្ខុទាំងឡាយ ចុះសេចក្ដីប្លែកគ្នានៃសញ្ញាទាំងឡាយ តើដូចម្ដេច ។
ម្នាលភិក្ខុទាំងឡាយ សញ្ញាក្នុងរូបទាំងឡាយ ដោយឡែក សញ្ញា
ក្នុងសំឡេងទាំងឡាយ ដោយឡែក សញ្ញាក្នុងក្លិនទាំងឡាយ ដោយ
ឡែក សញ្ញាក្នុងរសទាំងឡាយ ដោយឡែក សញ្ញាក្នុងផោដ្ឋព្វៈ
ទាំងឡាយ ដោយឡែក សញ្ញាក្នុងធម៌ទាំងឡាយ ដោយឡែក ។
ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្ដីប្លែកគ្នានៃសញ្ញាទាំងឡាយ ។

កតមោ ច ភិក្ខវេ សញ្ញានំ វិបាកោ ។ វោហារ-វេបក្កាហំ ភិក្ខវេ សញ្ញា វទាមិ យថា យថា នំ សញ្ជានាតិ តថា តថា វោហរតិ ឯវំ សញ្ញី អហោសិន្តិ ។ អយំ វុច្ចតិ ភិក្ខវេ សញ្ញានំ វិបាកោ ។ កតមោ ច ភិក្ខវេ សញ្ញានិរោធោ ។ ផស្សនិរោធា ភិក្ខវេ សញ្ញានិរោធោ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សញ្ញានិរោធគាមិនីបដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ យតោ ច ខោ ភិក្ខវេ អរិយសាវកោ ឯវំ សញ្ញា បជានាតិ ឯវំ សញ្ញានំ និទានសម្ភវំ បជានាតិ ឯវំ សញ្ញានំ វេមត្តតំ បជានាតិ ឯវំ សញ្ញានំ វិបាកំ បជានាតិ ឯវំ សញ្ញានិរោធំ បជានាតិ ឯវំ សញ្ញានិរោធគាមិនី-បដិបទំ បជានាតិ សោ ឥមំ និព្វេធិកំ ព្រហ្មចរិយំ បជានាតិ សញ្ញានិរោធំ ។ សញ្ញា ភិក្ខវេ វេទិតព្វា ។ បេ ។ សញ្ញានិរោធគាមិនីបដិបទា វេទិតព្វាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។



ម្នាលភិក្ខុទាំងឡាយ ចុះវិបាកនៃសញ្ញាទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតហៅសញ្ញាទាំងឡាយថា មានវោហារជាវិបាក បុគ្គលចាំបានយ៉ាងណា ៗ និយាយយ៉ាងនោះ ៗ ថា ខ្ញុំជាអ្នកមានសេចក្តីសំគាល់យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាវិបាករបស់សញ្ញាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់សញ្ញា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីរលត់សញ្ញាព្រោះរលត់ផស្សៈ ។ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាបដិបទាដំណើរទៅកាន់សេចក្តីរលត់សញ្ញា គឺសម្មាទិដ្ឋិ ១ ។បេ។ សម្មា-សមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបើ អរិយសាវកដឹងច្បាស់នូវសញ្ញាទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវហេតុនាំឲ្យកើតសញ្ញាទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្លែកគ្នានៃសញ្ញាទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវវិបាករបស់សញ្ញាទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់សញ្ញាយ៉ាងនេះ ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់សេចក្តីរលត់សញ្ញាយ៉ាងនេះហើយ អរិយសាវកនោះ ក៏ដឹងច្បាស់នូវព្រហ្មចរិយធម៌ ជាគ្រឿងទំលុះទំលាយនេះ ថាជាសេចក្តីរលត់សញ្ញា ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាទាំងឡាយ បុគ្គលគប្បីដឹង ។បេ។ បដិបទា ជាដំណើរទៅកាន់សេចក្តីរលត់សញ្ញា បុគ្គលគប្បីដឹង ពាក្យណាដែលតថាគតសំដែងហើយដូច្នេះ ពាក្យនុ៎ះ តថាគតសំដែង ព្រោះអាស្រ័យហេតុនេះឯង ។

អាសវា ភិក្ខវេ វេទិតព្វា ។បេ។ អាសវនិរោធគាមិនីបដិបទា វេទិតព្វាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ តយោមេ ភិក្ខវេ អាសវា កាមាសវោ ភវាសវោ អវិជ្ជាសវោ ។ កតមោ ច ភិក្ខវេ អាសវានំ និទានសម្ភវោ ។ អវិជ្ជា ភិក្ខវេ អាសវានំ និទានសម្ភវោ ។ កតមា ច ភិក្ខវេ អាសវានំ វេមត្តតា ។ អត្ថិ ភិក្ខវេ អាសវា និរយគមនិយា អត្ថិ អាសវា តិរច្ឆានយោនិគមនិយា អត្ថិ អាសវា បេត្តិវិសយគមនិយា អត្ថិ អាសវា មនុស្សលោកគមនិយា អត្ថិ អាសវា ទេវលោកគមនិយា ។ អយំ វុច្ចតិ ភិក្ខវេ អាសវានំ វេមត្តតា ។ កតមោ ច ភិក្ខវេ អាសវានំ វិបាកោ ។ យំ ខោ ភិក្ខវេ អវិជ្ជាគតោ តជ្ជំ តជ្ជំ អត្តភាវំ អភិនិព្វត្តេតិ បុញ្ញភាគិយំ វា អបុញ្ញភាគិយំ វា អយំ វុច្ចតិ ភិក្ខវេ អាសវានំ វិបាកោ ។



ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ បុគ្គលគប្បីដឹង ។បេ។ បដិបទាជាដំណើរទៅកាន់សេចក្តីរលត់អាសវៈ បុគ្គលគប្បីដឹង ពាក្យដែលតថាគតសំដែងហើយដូច្នេះ ពាក្យនុ៎ះ តថាគតសំដែង ព្រោះអាស្រ័យអ្វី ។ ម្នាលភិក្ខុទាំងឡាយ អាសវៈនេះមាន ៣ យ៉ាង គឺកាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនាំឲ្យកើតអាសវៈទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អវិជ្ជា ជាហេតុនាំឲ្យកើតអាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីប្លែកគ្នានៃអាសវៈទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ នាំសត្វឲ្យទៅនរកក៏មាន អាសវៈទាំងឡាយ នាំសត្វឲ្យទៅកាន់កំណើតតិរច្ឆានក៏មាន អាសវៈទាំងឡាយ នាំសត្វឲ្យទៅកាន់បិត្តិវិស័យក៏មាន អាសវៈទាំងឡាយ នាំសត្វឲ្យទៅមនុស្សលោកក៏មាន អាសវៈទាំងឡាយនាំសត្វឲ្យទៅទេវលោកក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីប្លែកគ្នានៃអាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ វិបាករបស់អាសវៈទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលុះក្នុងអវិជ្ជាណា ញុំាងអត្តភាព ដែលកើតអំពីអវិជ្ជានោះៗ ជាចំណែកបុណ្យក្តី ចំណែកបាបក្តី ឲ្យកើតឡើង ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិបាករបស់អាសវៈទាំងឡាយ ។

កតមោ ច ភិក្ខវេ អាសវនិរោធោ ។ អវិជ្ជានិរោធា ភិក្ខវេ អាសវនិរោធោ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ អាសវនិរោធគាមិនីបដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ យតោ ច ខោ ភិក្ខវេ អរិយសាវកោ ឯវំ អាសវេ បជានាតិ ឯវំ អាសវានំ និទានសម្ភវំ បជានាតិ ឯវំ អាសវានំ វេមត្តំ បជានាតិ ឯវំ អាសវានំ វិបាកំ បជានាតិ ឯវំ អាសវនិរោធំ បជានាតិ ឯវំ អាសវនិរោធគាមិនិំ បដិបទំ បជានាតិ សោ ឥមំ និព្វេធិកំ ព្រហ្មចរិយំ បជានាតិ អាសវនិរោធំ ។ អាសវា ភិក្ខវេ វេទិតព្វា ។បេ។ អាសវនិរោធគាមិនីបដិបទា វេទិតព្វាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

កម្មំ ភិក្ខវេ វេទិតព្វំ ។បេ។ កម្មនិរោធគាមិនីបដិបទា វេទិតព្វាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។



ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់អាសវៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីរលត់អាសវៈ ព្រោះរលត់អវិជ្ជា ។ មគ្គដ៏ប្រសើរ ប្រកបដោយអង្គ ៨ នេះឯង ជាបដិបទាដំណើរទៅកាន់សេចក្តីរលត់អាសវៈ គឺសម្មាទិដ្ឋិ ១ ។បេ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវក ដឹងច្បាស់នូវអាសវៈទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវហេតុនាំឲ្យកើតអាសវៈទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្លែកគ្នានៃអាសវៈទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវផលរបស់អាសវៈទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់អាសវៈយ៉ាងនេះ ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់សេចក្តីរលត់អាសវៈយ៉ាងនេះហើយ អរិយសាវកនោះ ក៏ដឹងច្បាស់នូវព្រហ្មចរិយធម៌ ជាគ្រឿងទំលុះទំលាយនេះ ថាជាសេចក្តីរលត់អាសវៈ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ បុគ្គលគប្បីដឹង ។បេ។ បដិបទាជាដំណើរទៅកាន់សេចក្តីរលត់អាសវៈ បុគ្គលគប្បីដឹង ពាក្យណាដែលតថាគតសំដែងហើយ ដូច្នេះ ពាក្យនុ៎ះ តថាគតសំដែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។

ម្នាលភិក្ខុទាំងឡាយ កម្មបុគ្គលគប្បីដឹង ។បេ។ បដិបទាជាដំណើរទៅកាន់សេចក្តីរលត់កម្ម បុគ្គលគប្បីដឹង គឺពាក្យដែលតថាគតសំដែងហើយដូច្នេះនុ៎ះ ពាក្យនុ៎ះ តថាគតសំដែងហើយ ព្រោះអាស្រ័យអ្វី ។

ចេតនាហំ ភិក្ខវេ កម្មំ វទាមិ ចេតយិត្វា កម្មំ ករោតិ កាយេន វាចាយ មនសា ។ កតមោ ច ភិក្ខវេ កម្មានំ និទានសម្ភវោ ។ ផស្សោ ភិក្ខវេ កម្មានំ និទានសម្ភវោ ។ កតមា ច ភិក្ខវេ កម្មានំ វេមត្តតា ។ អត្ថិ ភិក្ខវេ កម្មំ និរយវេទនិយំ អត្ថិ កម្មំ តិរច្ឆានយោនិវេទនិយំ អត្ថិ កម្មំ បេត្តិវិសយវេទនិយំ អត្ថិ កម្មំ មនុស្សលោកវេទនិយំ អត្ថិ កម្មំ ទេវលោកវេទនិយំ ។ អយំ វុច្ចតិ ភិក្ខវេ កម្មានំ វេមត្តតា ។ កតមោ ច ភិក្ខវេ កម្មានំ វិបាកោ ។ តិវិធាហំ ភិក្ខវេ កម្មានំ វិបាកំ វទាមិ ទិដ្ឋេវ ធម្មេ ឧបបជ្ជេ វា អបរេ វា បរិយាយេ ។ អយំ វុច្ចតិ ភិក្ខវេ កម្មានំ វិបាកោ ។ កតមោ ច ភិក្ខវេ កម្មនិរោធោ ។ ផស្សនិរោធា ភិក្ខវេ កម្មនិរោធោ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ



ម្នាលភិក្ខុទាំងឡាយ តថាគតហៅចេតនា ថាជាកម្ម ព្រោះបុគ្គលគិតហើយ ទើបធ្វើកម្មដោយកាយ វាចា ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុដែលនាំឲ្យកើតកម្មទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ផស្សៈជាហេតុនាំឲ្យកើតកម្មទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីផ្សេងគ្នានៃកម្មទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កម្មនាំឲ្យទទួលផល ក្នុងនរកក៏មាន កម្មនាំឲ្យទទួលផល ក្នុងកំណើតតិរច្ឆានក៏មាន កម្មនាំឲ្យទទួលផល ក្នុងបិត្តិវិស័យក៏មាន កម្មនាំឲ្យទទួលផល ក្នុងមនុស្សលោកក៏មាន កម្មនាំឲ្យទទួលផល ក្នុងទេវលោកក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីផ្សេងគ្នានៃកម្មទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះវិបាករបស់កម្មទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវវិបាករបស់កម្មទាំងឡាយ ថាមាន ៣ ប្រការ គឺវិបាករបស់កម្ម ក្នុងបច្ចុប្បន្ន ១ វិបាករបស់កម្ម ក្នុងអត្តភាពបន្ទាប់ ១ វិបាករបស់កម្ម ក្នុងអត្តភាពជាលំដាប់ៗទៅ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិបាករបស់កម្មទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់កម្ម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីរលត់កម្ម ព្រោះរលត់ផស្សៈ ។ មគ្គដ៏ប្រសើរ ប្រកបដោយអង្គ ៨ នេះឯង

ទុក្ខនិរោធគាមិនីបដិបទា សេយ្យថីទំ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ យតោ ច ខោ ភិក្ខវេ អរិយសាវកោ ឯវំ ទុក្ខំ បជានាតិ ឯវំ ទុក្ខស្ស និទានសម្ភវំ បជានាតិ ឯវំ ទុក្ខស្ស វេមត្តតំ បជានាតិ ឯវំ ទុក្ខស្ស វិបាកំ បជានាតិ ឯវំ ទុក្ខនិរោធំ បជានាតិ ឯវំ ទុក្ខនិរោធគាមិនិបដិបទំ បជានាតិ សោ ឥមំ និព្ពេធិកំ ព្រហ្មចរិយំ បជានាតិ ទុក្ខនិរោធំ ។ ទុក្ខំ ភិក្ខវេ វេទិតព្វំ ។បេ។ ទុក្ខនិរោធគាមិនីបដិបទា វេទិតព្វាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ទុក្ខំ ភិក្ខវេ វេទិតព្វំ ទុក្ខស្ស និទានសម្ភវោ វេទិតព្វោ ទុក្ខស្ស វេមត្តតា វេទិតព្វា ទុក្ខស្ស វិបាកោ វេទិតព្វោ ទុក្ខនិរោធោ វេទិតព្វោ ទុក្ខនិរោធគាមិនីបដិបទា វេទិតព្វាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។



ជាបដិបទាជាដំណើរទៅកាន់សេចក្តីរលត់កម្ម គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវក ដឹងច្បាស់នូវកម្ម យ៉ាងនេះ ដឹងច្បាស់នូវហេតុនាំឲ្យកើតកម្មទាំងឡាយ យ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្លែកគ្នា នៃកម្មទាំងឡាយ យ៉ាងនេះ ដឹងច្បាស់នូវវិបាករបស់កម្មទាំងឡាយ យ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់កម្ម យ៉ាងនេះ ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់សេចក្តីរលត់កម្មយ៉ាងនេះហើយ អរិយសាវកនោះ ក៏ដឹងច្បាស់នូវព្រហ្មចរិយធម៌ ជាគ្រឿងទំលុះទំលាយ នេះថាជាសេចក្តីរលត់កម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មបុគ្គលគប្បីដឹង ។បេ។ បដិបទាជាដំណើរទៅកាន់សេចក្តីរលត់កម្ម បុគ្គលគប្បីដឹង ពាក្យណា ដែលតថាគតសំដែងហើយដូច្នេះ ពាក្យនុ៎ះ តថាគតសំដែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខបុគ្គលគប្បីដឹង ហេតុនាំឲ្យកើតទុក្ខ បុគ្គលគប្បីដឹង សេចក្តីប្លែកគ្នានៃទុក្ខ បុគ្គលគប្បីដឹង វិបាករបស់ទុក្ខ បុគ្គលគប្បីដឹង ។ សេចក្តីរលត់ទុក្ខ បុគ្គលគប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្តីរលត់ទុក្ខ បុគ្គលគប្បីដឹង ពាក្យដែលតថាគតសំដែងហើយដូច្នេះ៎ ពាក្យនុ៎ះ តថាគតសំដែងហើយ ព្រោះអាស្រ័យអ្វី ។

ជាតិបិ ទុក្ខា ជរាបិ ទុក្ខា ព្យាធិបិ ទុក្ខោ(១) មរណម្បិ ទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសាបិ ទុក្ខា យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ។ កតមោ ច ភិក្ខវេ ទុក្ខស្ស និទានសម្ភវោ ។ តណ្ហា ភិក្ខវេ ទុក្ខស្ស និទានសម្ភវោ ។ កតមា ច ភិក្ខវេ ទុក្ខស្ស វេមត្តតា ។ អត្ថិ ភិក្ខវេ ទុក្ខំ អធិមត្តំ អត្ថិ បរិត្តំ អត្ថិ ទន្ធវិរាគិ អត្ថិ ខិប្បវិរាគិ ។ អយំ វុច្ចតិ ភិក្ខវេ ទុក្ខស្ស វេមត្តតា ។ កតមោ ច ភិក្ខវេ ទុក្ខស្ស វិបាកោ ។ ឥធ ភិក្ខវេ ឯកច្ចោ យេន ទុក្ខេន អភិភូតោ បរិយាទិន្នចិត្តោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ យេន វា បន ទុក្ខេន អភិភូតោ បរិយាទិន្នចិត្តោ ពហិទ្ធា បរិយេដ្ឋឹ អាបជ្ជតិ កោ(២) ឯកបទំ ទ្វិបទំ ជានាតិ ឥមស្ស ទុក្ខស្ស និរោធាយាតិ ។

(១) អញ្ញេ បោត្ថកេ ព្យាធិបិ ទុក្ខាតិ ទិស្សតិ ។ ២ ម. កោ ៩ ។



ជាតិក៏ជាទុក្ខ ជរាក៏ជាទុក្ខ ព្យាធិក៏ជាទុក្ខ មរណៈក៏ជាទុក្ខ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈក៏ជាទុក្ខ បុគ្គលប្រាថ្នារបស់ណា ហើយមិនបាននូវរបស់នោះ ក៏ជាទុក្ខ បើនិយាយដោយរួម ឧបាទានក្ខន្ធទាំង ៥ ក៏ជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនាំឲ្យកើតទុក្ខ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាជាហេតុនាំឲ្យកើតទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីប្លែកគ្នានៃទុក្ខ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខយ៉ាងខ្លាំង ក៏មាន ទុក្ខយ៉ាងស្រាល ក៏មាន ទុក្ខក្រសាយ ក៏មាន ទុក្ខឆាប់សាយ ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីប្លែកគ្នានៃទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះវិបាករបស់ទុក្ខ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មានទុក្ខគ្របសង្កត់ មានទុក្ខរួបរឹតចិត្តហើយ រមែងសោយសោក លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងវង្វាន់ មួយទៀត បុគ្គលមានទុក្ខគ្របសង្កត់ មានទុក្ខរួបរឹតចិត្តហើយ តែងដល់នូវការស្វែងរកហេតុខាងក្រៅព្រោះទុក្ខសាសនាថា បុគ្គលណាម្នាក់ ដឹង ( មន្តគាថា ) តែមួយបទ ឬពីរបទ ដើម្បីរលត់ទុក្ខនេះបាន ។

សម្មោហវេបក្កំ វាហំ ភិក្ខវេ ទុក្ខំ វទាមិ បរិយេ-
ដ្ឋិវេបក្កំ វា ។ អយំ វុច្ចតិ ភិក្ខវេ ទុក្ខស្ស វិបាកោ ។
កតមោ ច ភិក្ខវេ ទុក្ខនិរោធោ ។ តណ្ហានិរោធោ
ភិក្ខវេ ទុក្ខនិរោធោ ។ អយមេវ អរិយោ អដ្ឋង្គិកោ
មគ្គោ ទុក្ខនិរោធគាមិនីបដិបទា សេយ្យថីទំ សម្មាទិដ្ឋិ
។បេ។ សម្មាសមាធិ ។ យតោ ខោ ភិក្ខវេ
អរិយសាវកោ ឯវំ ទុក្ខំ បជានាតិ ឯវំ ទុក្ខស្ស
និទានសម្ភវំ បជានាតិ ឯវំ ទុក្ខស្ស វេមត្តតំ
បជានាតិ ឯវំ ទុក្ខវិបាកំ បជានាតិ ឯវំ ទុក្ខនិរោធំ
បជានាតិ ឯវំ ទុក្ខនិរោធគាមិនីបដិបទំ បជានាតិ
សោ ឥមំ និព្វេធិកំ ព្រហ្មចរិយំ បជានាតិ
ទុក្ខនិរោធំ ។ ទុក្ខំ ភិក្ខវេ វេទិតព្វំ ទុក្ខស្ស
និទានសម្ភវោ វេទិតព្វោ ទុក្ខស្ស វេមត្តតា
វេទិតព្វា ទុក្ខស្ស វិបាកោ វេទិតព្វោ ទុក្ខនិរោធោ
វេទិតព្វោ ទុក្ខនិរោធគាមិនីបដិបទា វេទិតព្វាតិ
ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។



ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវទុក្ខថា មានសេចក្តីវង្វេងវង្វាន់
ជាវិបាក ឬការស្វែងរក ជាវិបាក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា
វិបាករបស់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់ទុក្ខ តើដូចម្តេច ។
ម្នាលភិក្ខុទាំងឡាយ សេចក្តីរលត់ទុក្ខ ព្រោះរលត់តណ្ហា ។
មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាបដិបទាដំណើរទៅកាន់
សេចក្តីរលត់ទុក្ខ គឺសម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ។ ម្នាល
ភិក្ខុទាំងឡាយ កាលបើអរិយសាវក ដឹងច្បាស់នូវទុក្ខយ៉ាងនេះ ដឹង
ច្បាស់នូវហេតុនាំឲ្យកើតទុក្ខយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីផ្សេងគ្នានៃ
ទុក្ខយ៉ាងនេះ ដឹងច្បាស់នូវវិបាករបស់ទុក្ខយ៉ាងនេះ ដឹងច្បាស់នូវសេចក្តី
រលត់ទុក្ខយ៉ាងនេះ ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់សេចក្តី
រលត់ទុក្ខយ៉ាងនេះហើយ អរិយសាវកនោះក៏ដឹងច្បាស់នូវព្រហ្មចរិយធម៌
ជាគ្រឿងទំលុះទំលាយនេះ ថាជាសេចក្តីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ
ទុក្ខ បុគ្គលគប្បីដឹង ហេតុនាំឲ្យកើតទុក្ខ បុគ្គលគប្បីដឹង សេចក្តីផ្សេង
គ្នានៃទុក្ខ បុគ្គលគប្បីដឹង វិបាករបស់ទុក្ខ បុគ្គលគប្បីដឹង សេចក្តី
រលត់ទុក្ខ បុគ្គលគប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្តីរលត់ទុក្ខ
បុគ្គលគប្បីដឹង ពាក្យណា ដែលតថាគតសំដែងហើយដូច្នេះ ពាក្យ
នុះ តថាគតសំដែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។

អយំ ខោ សោ ភិក្ខវេ និព្វេធិកបរិយាយោ ធម្មបរិយាយោតិ ។

(៦៤) ឆយិមានិ ភិក្ខវេ តថាគតស្ស តថាគតពលានិ យេហិ ពលេហិ សមន្នាគតោ តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ កតមានិ ឆ ។ ឥធ ភិក្ខវេ តថាគតោ ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ យថាភូតំ បជានាតិ យម្បិ ភិក្ខវេ តថាគតោ ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ យថាភូតំ បជានាតិ ឥទម្បិ ភិក្ខវេ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។

បុន ចបរំ ភិក្ខវេ តថាគតោ អតីតានាគតបច្ចុប្បន្នានំ កម្មសមាទានានំ ឋានសោ ហេតុសោ វិបាកំ យថាភូតំ បជានាតិ



ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថា និព្វេធិកបរិយាយ ឈ្មោះថា ធម្មបរិយាយ ។

(៦៤) ម្នាលភិក្ខុទាំងឡាយ តថាគតពលៈ របស់ព្រះតថាគតនេះ មាន ៦ ដែលព្រះតថាគត បានប្រកបដោយពលៈហើយ ប្ដេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិសទ្យ ញុំាងព្រហ្មចក្រ (ចក្រដ៏ប្រសើរ) ឲ្យប្រព្រឹត្តទៅ ។ តថាគតពលៈ ៦ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតក្នុងលោកនេះ ដឹងច្បាស់ជាក់លាក់នូវហេតុ តាមហេតុពិត ដឹងច្បាស់ជាក់លាក់នូវអំពើ មិនមែនជាហេតុ តាមអំពើមិនមែនជាហេតុពិត ម្នាលភិក្ខុទាំងឡាយ ត្រង់ព្រះតថាគត ដឹងច្បាស់ជាក់លាក់នូវហេតុ តាមហេតុពិត ដឹងច្បាស់ជាក់លាក់នូវអំពើ មិនមែនជាហេតុ តាមអំពើមិនមែនជាហេតុពិត ម្នាលភិក្ខុទាំងឡាយ នេះ តថាគតពលៈរបស់ព្រះតថាគត ដែលព្រះតថាគតបានអាស្រ័យពលៈ ហើយប្ដេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិសទ្យ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគត ដឹងច្បាស់ជាក់លាក់នូវវិបាករបស់កុសលកម្មនិងអកុសលកម្ម ដែលសត្វបានធ្វើហើយ ទាំងអតីត ទាំងអនាគតនិងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុ

យម្បិ ភិក្ខវេ តថាគតោ អតីតានាគតប្បច្ចុប្បន្នានំ កម្មសមាទានានំ ឋានសោ ហេតុសោ វិបាកំ យថាភូតំ បជានាតិ ឥទម្បិ ភិក្ខវេ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។

បុន ចបរំ ភិក្ខវេ តថាគតោ ឈានវិមោក្ខសមាធិសមាបត្តីនំ សង្កិលេសំ វោទានំ វុដ្ឋានំ យថាភូតំ បជានាតិ យម្បិ ភិក្ខវេ តថាគតោ ។ បេ ។ ឥទម្បិ ភិក្ខវេ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។

បុន ចបរំ ភិក្ខវេ តថាគតោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ



ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ដឹងច្បាស់ជាក់លាក់នូវវិបាករបស់កុសលកម្មនិងអកុសលកម្មដែលសត្វបានធ្វើហើយ ទាំងអតីតទាំងអនាគតនិងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពលៈរបស់ព្រះតថាគត ដែលព្រះតថាគតបានអាស្រ័យពលៈហើយ ប្ដេជ្ញានូវឋានៈដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិសទ្យ ញ៉ាំងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគត ដឹងច្បាស់ជាក់លាក់នូវសេចក្ដីសៅហ្មង សេចក្ដីផូរផង់ និងការចេញចាកឈាន វិមោក្ខ សមាធិ និងសមាបត្តិ (១) ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពលៈរបស់ព្រះតថាគត ដែលព្រះតថាគតបានអាស្រ័យពលៈហើយប្ដេជ្ញានូវឋានៈដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិសទ្យ ញ៉ាំងព្រហ្មចក្រ ឲ្យប្រព្រឹត្តទៅ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតរលឹកឃើញនូវបុព្វេនិវាសៈជាច្រើនប្រការ គឺរលឹកឃើញ ១ ជាតិ ២ ជាតិ ។ បេ ។ រលឹកឃើញនូវបុព្វេនិវាសៈ ជាច្រើនប្រការ ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេសដូច្នេះ

---

១ បានដល់ឈានទាំង ៤ វិមោក្ខទាំង ៨ សមាធិទាំង ៣ និងអនុបុព្វសមាបត្តិទាំង ៩ ។ អដ្ឋកថា ។

យម្បិ ភិក្ខវេ តថាគតោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។បេ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ឥទម្បិ ភិក្ខវេ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។

បុន ចបរំ ភិក្ខវេ តថាគតោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។បេ។ យថាកម្មូបគេ សត្តេ បជានាតិ យម្បិ ភិក្ខវេ តថាគតោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។បេ។ យថាកម្មូបគេ សត្តេ បជានាតិ ឥទម្បិ ភិក្ខវេ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។



ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត រលឹកឃើញនូវបុព្វេនិវាសៈ ជាច្រើនប្រការ គឺរលឹកបាន ១ ជាតិ ២ ជាតិ ។បេ។ រលឹកឃើញនូវបុព្វេនិវាសៈ ជាច្រើនប្រការ ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេសដូច្នេះ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពលៈរបស់ព្រះតថាគត ដែលព្រះតថាគតបានអាស្រ័យពលៈហើយ ប្តេជ្ញានូវឋានដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ្យ ញុំាងព្រហ្មចក្រ ឲ្យប្រព្រឹត្តទៅ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតមានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងនូវចក្ខុរបស់មនុស្សធម្មតា ។បេ។ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងនូវចក្ខុរបស់មនុស្សធម្មតា ។បេ។ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពលៈរបស់ព្រះតថាគត ដែលព្រះតថាគតបានអាស្រ័យពលៈហើយប្តេជ្ញានូវឋានដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ្យ ញុំាងព្រហ្មចក្រ ឲ្យប្រព្រឹត្តទៅ ។

បុន ចបរំ ភិក្ខវេ តថាគតោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ យម្បិ ភិក្ខវេ តថាគតោ អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឥទម្បិ ភិក្ខវេ តថាគតស្ស តថាគតពលំ ហោតិ យំ ពលំ អាគម្ម តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ ឥមានិ ខោ ភិក្ខវេ ទស តថាគតស្ស តថាគតពលានិ យេហិ ពលេហិ សមន្នាគតោ តថាគតោ អាសភណ្ឋានំ បដិជានាតិ បរិសាសុ សីហនាទំ នទតិ ព្រហ្មចក្កំ បវត្តេតិ ។ តត្រ ចេ ភិក្ខវេ បរេ តថាគតំ ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ យថាភូតំ ញាណេន ឧបសង្កមិត្វា បញ្ហំ បុច្ឆន្តិ យថា យថា ភិក្ខវេ តថាគតស្ស ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ យថាភូតំ ញាណំ វិទិតំ



ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ធ្វើឲ្យជាក់ច្បាស់សម្រេច ។ បេ ។ ព្រោះអស់អាសវៈទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពលៈ របស់ព្រះតថាគត ដែលព្រះតថាគតបានអាស្រ័យពលៈហើយ ប្តេជ្ញានូវឋានដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពលៈរបស់ព្រះតថាគត ទាំង ១០ ប្រការនេះ ដែលព្រះតថាគតបានប្រកបដោយពលៈហើយ ប្តេជ្ញានូវឋានដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រ ឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ បើជនទាំងឡាយដទៃ ចូលមករកព្រះតថាគតហើយសួរប្រស្នា ត្រង់ការដឹងជាក់លាក់នូវហេតុ តាមហេតុផល នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផល ម្នាលភិក្ខុទាំងឡាយ ញាណដែលព្រះតថាគត ដឹងជាក់លាក់នូវហេតុ តាមហេតុផល នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផល យ៉ាងណា ៗ

តថា តថា តេសំ តថាគតោ ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ យថាភូតំ ញាណេន បញ្ហំ បុដ្ឋោ ព្យាករោតិ ។ តត្រ ចេ ភិក្ខវេ បរេ តថាគតំ អតីតានាគតបច្ចុប្បន្នានំ កម្មសមាទានានំ ឋានសោ ហេតុសោ វិបាកំ យថាភូតំ ញាណេន ឧបសង្កមិត្វា បញ្ហំ បុច្ឆន្តិ យថា យថា ភិក្ខវេ តថាគតស្ស អតីតានាគតបច្ចុប្បន្នានំ កម្មសមាទានានំ ឋានសោ ហេតុសោ វិបាកំ យថាភូតំ ញាណំ វិទិតំ តថា តថា តេសំ តថាគតោ អតីតានាគតបច្ចុប្បន្នានំ កម្មសមាទានានំ ឋានសោ ហេតុសោ វិបាកំ យថាភូតំ ញាណេន បញ្ហំ បុដ្ឋោ ព្យាករោតិ ។ តត្រ ចេ ភិក្ខវេ បរេ តថាគតំ ឈានវិមោក្ខសមាធិ-សមាបត្តីនំ សង្កិលេសំ វោទានំ វុដ្ឋានំ យថាភូតំ ញាណេន ឧបសង្កមិត្វា បញ្ហំ បុច្ឆន្តិ



ព្រះតថាគត ក៏ឆ្លើយដោះប្រស្នាដែលពួកជនទាំងនោះសួរហើយ តាមការដឹងជាក់លាក់នូវហេតុ តាមហេតុផង នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផង យ៉ាងនោះៗ បាន ។ ម្នាលភិក្ខុទាំងឡាយ បើជនទាំងឡាយដទៃ ចូលមករកព្រះតថាគត ហើយសួរប្រស្នាត្រង់ការដឹងជាក់លាក់នូវវិបាករបស់កុសលកម្មនិងអកុសលកម្ម ដែលសត្វធ្វើហើយ ទាំងអតីត ទាំងអនាគតនិងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុ ម្នាលភិក្ខុទាំងឡាយ ញាណដែលព្រះតថាគត ដឹងជាក់លាក់ នូវវិបាករបស់កុសលនិងអកុសលដែលសត្វធ្វើហើយ ទាំងអតីត ទាំងអនាគតនិងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុយ៉ាងណា ៗ ព្រះតថាគត ក៏ឆ្លើយដោះប្រស្នាដែលពួកជនទាំងនោះ សួរហើយដោយការដឹងជាក់លាក់នូវវិបាករបស់កុសលកម្មនិងអកុសលកម្ម ដែលសត្វធ្វើហើយ ទាំងអតីត ទាំងអនាគតនិងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុយ៉ាងនោះៗ បាន ។ ម្នាលភិក្ខុទាំងឡាយ បើជនទាំងឡាយដទៃ ចូលមករកព្រះតថាគតហើយសួរប្រស្នា ត្រង់ការដឹងជាក់លាក់ នូវសេចក្តីសៅហ្មង សេចក្តីផូរផង់ និងការចេញចាកឈាន វិមោក្ខ សមាធិ និងសមាបត្តិ

យថា យថា ភិក្ខវេ តថាគតស្ស ឈានវិមោក្ខសមាធិសមាបត្តីនំ សង្កិលេសំ វោទានំ វុដ្ឋានំ យថាភូតំ ញាណំ វិទិតំ តថា តថា តេសំ តថាគតោ ឈានវិមោក្ខសមាធិសមាបត្តីនំ សង្កិលេសំ វោទានំ វុដ្ឋានំ យថាភូតំ ញាណេន បញ្ហំ បុដ្ឋោ ព្យាករោតិ ។ តត្រ ចេ ភិក្ខវេ បរេ តថាគតំ បុព្វេនិវាសានុស្សតិំ យថាភូតំ ញាណេន ឧបសង្កមិត្វា បញ្ហំ បុច្ឆន្តិ យថា យថា ភិក្ខវេ តថាគតស្ស បុព្វេនិវាសានុស្សតិ យថាភូតំ ញាណំ វិទិតំ តថា តថា តេសំ តថាគតោ បុព្វេនិវាសានុស្សតិំ យថាភូតំ ញាណេន បញ្ហំ បុដ្ឋោ ព្យាករោតិ ។ តត្រ ចេ ភិក្ខវេ បរេ តថាគតំ សត្តានំ ចុតូបបាតំ យថាភូតំ ញាណេន ឧបសង្កមិត្វា បញ្ហំ បុច្ឆន្តិ យថា យថា ភិក្ខវេ តថាគតស្ស សត្តានំ ចុតូបបាតំ យថាភូតំ ញាណំ វិទិតំ តថា តថា តេសំ តថាគតោ សត្តានំ ចុតូបបាតំ យថាភូតំ ញាណេន បញ្ហំ បុដ្ឋោ ព្យាករោតិ ។



ម្នាលភិក្ខុទាំងឡាយ ញាណដែលព្រះតថាគត ដឹងជាក់លាក់នូវសេចក្តីសៅហ្មង សេចក្តីផូរផង់ និងការចេញចាកឈាន វិមោក្ខ សមាធិនិងសមាបត្តិយ៉ាងណា ៗ ព្រះតថាគត ក៏ឆ្លើយដោះប្រស្នា ដែលពួកជនទាំងនោះសួរហើយ ដោយការដឹងជាក់លាក់នូវសេចក្តីសៅហ្មង សេចក្តីផូរផង់និងការចេញចាកឈាន វិមោក្ខ សមាធិ និងសមាបត្តិយ៉ាងនោះៗបាន ។ ម្នាលភិក្ខុទាំងឡាយ បើជនទាំងឡាយដទៃ ចូលមករកព្រះតថាគត ហើយសួរប្រស្នា ត្រង់ការដឹងជាក់លាក់នូវបុព្វេនិវាសានុស្សតិ ម្នាលភិក្ខុទាំងឡាយ ញាណដែលព្រះតថាគត ដឹងជាក់លាក់នូវបុព្វេនិវាសានុស្សតិយ៉ាងណា ៗ តថាគតក៏ឆ្លើយដោះប្រស្នា ដែលពួកជនទាំងនោះ សួរហើយ តាមការដឹងជាក់លាក់នូវបុព្វេនិវាសានុស្សតិយ៉ាងនោះៗបាន ។ ម្នាលភិក្ខុទាំងឡាយ បើជនទាំងឡាយដទៃ ចូលមករកព្រះតថាគត ហើយសួរប្រស្នា ត្រង់ការដឹងជាក់លាក់ នូវចុតិនិងបដិសន្ធិរបស់សត្វទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ញាណដែលព្រះតថាគត ដឹងជាក់លាក់ នូវចុតិនិងបដិសន្ធិរបស់សត្វទាំងឡាយយ៉ាងណា ៗ ព្រះតថាគត ក៏ឆ្លើយដោះប្រស្នាដែលពួកជនទាំងនោះសួរហើយ ដោយការដឹងជាក់លាក់ នូវចុតិនិងបដិសន្ធិរបស់សត្វទាំងឡាយ យ៉ាងនោះៗបាន ។

តត្រ ចេ ភិក្ខវេ បរេ តថាគតំ អាសវានំ ខយំ យថាភូតំ ញាណេន ឧបសង្កមិត្វា បញ្ហំ បុច្ឆន្តិ យថា យថា ភិក្ខវេ តថាគតស្ស អាសវានំ ខយំ យថាភូតំ ញាណំ វិទិតំ តថា តថា តេសំ តថាគតោ អាសវានំ ខយំ យថាភូតំ ញាណេន បញ្ហំ បុដ្ឋោ ព្យាករោតិ ។ តត្រ ភិក្ខវេ យម្បិទំ ឋានញ្ច ឋានតោ អដ្ឋានញ្ច អដ្ឋានតោ យថាភូតំ ញាណំ តម្បិ សមាហិតស្ស វទាមិ នោ អសមាហិតស្ស ។ យម្បិទំ អតីតានាគត-បច្ចុប្បន្នានំ កម្មសមាទានានំ ឋានសោ ហេតុសោ វិបាកំ យថាភូតំ ញាណំ តម្បិ សមាហិតស្ស វទាមិ នោ អសមាហិតស្ស ។ យម្បិទំ ភិក្ខវេ ឈានវិមោក្ខសមាធិសមាបត្តីនំ សង្កិលេសំ វោទានំ វុដ្ឋានំ យថាភូតំ ញាណំ តម្បិ សមាហិតស្ស វទាមិ



ម្នាលភិក្ខុទាំងឡាយ បើជនទាំងឡាយដទៃ ចូលមកគាល់ព្រះតថាគត ហើយសួរប្រស្នា ត្រង់ការដឹងច្បាស់ នូវសេចក្តីអស់ទៅនៃអាសវៈទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ញាណដែលព្រះតថាគត ដឹងច្បាស់នូវសេចក្តីអស់ទៅនៃអាសវៈទាំងឡាយយ៉ាងណាៗ ព្រះតថាគត ក៏ឆ្លើយដោះប្រស្នាដែលពួកជនទាំងនោះ សួរហើយតាមការដឹងច្បាស់ នូវសេចក្តីអស់ទៅនៃអាសវៈទាំងឡាយ យ៉ាងនោះៗបាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោល នូវការដឹងច្បាស់នូវហេតុ តាមហេតុផង នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផងនោះ ថាជារបស់បុគ្គលដែលមានចិត្តតាំងមាំ មិនមែនរបស់បុគ្គល ដែលមានចិត្តមិនតាំងមាំទេ ។ តថាគតពោលនូវការដឹងច្បាស់ នូវវិបាករបស់កុសលកម្ម នឹងអកុសលកម្មដែលសន្សំធ្វើហើយ ទាំងអតីតទាំងអនាគតនឹងបច្ចុប្បន្នតាមបច្ច័យ តាមហេតុនោះ ថាជារបស់បុគ្គលដែលមានចិត្តតាំងមាំ មិនមែនរបស់បុគ្គលដែលមានចិត្តមិនតាំងមាំទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការដឹងច្បាស់នូវសេចក្តីសៅហ្មង សេចក្តីផូរផង់នឹងការចេញចាកឈានវិមោក្ខ សមាធិនឹងសមាបត្តិនោះ ថាជារបស់បុគ្គលដែលមានចិត្តតាំងមាំ

នោ អសមាហិតស្ស ។ យម្បិទំ ភិក្ខវេ បុព្វេនិវា-
សានុស្សតិ យថាភូតំ ញាណំ តម្បិ សមាហិតស្ស
ហោតិ នោ អសមាហិតស្ស ។ យម្បិទំ សត្តានំ
ចុតូបបាតេ យថាភូតំ ញាណំ តម្បិ សមាហិតស្ស
ហោតិ នោ អសមាហិតស្ស ។ យម្បិទំ អាសវានំ
ខយេ យថាភូតំ ញាណំ តម្បិ សមាហិតស្ស
ហោតិ នោ អសមាហិតស្ស ។ ឥតិ ខោ ភិក្ខវេ
សមាធិ មគ្គោ អសមាធិ កុម្មគ្គោតិ ។

មហាវគ្គោ បឋមោ ។

## តស្សុទ្ទានំ

សោណោ ផគ្គុណោ ឆឡាភិជាតិយោ
អាសវា ទារុកម្មេន បញ្ច ចស្សេ
ចិត្តហាយំ ទុតកំ ឆព្វេជំ
ជ ឥមា ពលេន វត្តាតិ ។



មិនមែនរបស់បុគ្គលដែលមានចិត្តមិនតាំងមាំទេ ។ ម្នាលភិក្ខុទាំងឡាយ
តថាគតពោលនូវការដឹងជាក់លាក់ នូវបុព្វេនិវាសានុស្សតិនោះ ជាជា
របស់បុគ្គលដែលមានចិត្តតាំងមាំ មិនមែនរបស់បុគ្គលដែលមានចិត្តមិន
តាំងមាំទេ ។ តថាគត ពោលនូវការដឹងជាក់លាក់នូវចុតិនិងឧបប-
ត្តិរបស់សត្វទាំងឡាយនោះ ជាជារបស់បុគ្គលដែលមានចិត្តតាំងមាំ
មិនមែនរបស់បុគ្គលដែលមានចិត្តមិនតាំងមាំទេ ។ តថាគតពោលនូវ
ការដឹងជាក់លាក់នូវសេចក្តីអស់ទៅ នៃអាសវៈទាំងឡាយនោះ ជាជា
របស់បុគ្គលដែលមានចិត្តតាំងមាំ មិនមែនរបស់បុគ្គលដែលមានចិត្តមិន
តាំងមាំទេ ។ ម្នាលភិក្ខុទាំងឡាយ សមាធិ ជាផ្លូវត្រូវ អសមាធិ
ជាផ្លូវខុស ដូចបានសំដែងមកហើយ ។

ចប់ មហាវគ្គ ទី ៥ ។

## ឧទ្ទាននៃមហាវគ្គនោះគឺ

និយាយអំពីរឿងព្រះថេរៈ ឈ្មោះសោណៈ ១ ព្រះថេរៈ
ឈ្មោះផគ្គុណៈ ១ អភិជាតិ ៦ យ៉ាង ១ អាសវៈទាំងឡាយ ១
រឿងទារុកម្មិកៈជាអ្នកធ្វើការក្នុងព្រៃ ១ ចិត្តហត្ថិសារីបុត្ត ១
មេត្តេយ្យបញ្ហាក្នុងបារាយនវគ្គ ១ ព្រះអានន្ទ ចុះទៅជម្រះខ្លួន
ក្នុងទឹកស្ទឹងអចិរវតី ១ និព្វេធិកបរិយាយ ១ ពលៈ ៦ យ៉ាង ១ ។

(៦៥) ឆ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ អនាគាមិផលំ សច្ឆិកាតុំ ។ កតមេ ឆ ។ អស្សទ្ធិយំ អហិរិកំ អនោត្តប្បំ កោសជ្ជំ មុដ្ឋស្សច្ចំ ទុប្បញ្ញតំ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ អប្បហាយ អភព្វោ អនាគាមិផលំ សច្ឆិកាតុំ ។ ឆ ភិក្ខវេ ធម្មេ បហាយ ភព្វោ អនាគាមិផលំ សច្ឆិកាតុំ ។ កតមេ ឆ ។ អស្សទ្ធិយំ អហិរិកំ អនោត្តប្បំ កោសជ្ជំ មុដ្ឋស្សច្ចំ ទុប្បញ្ញតំ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ បហាយ ភព្វោ អនាគាមិផលំ សច្ឆិកាតុន្តិ ។

(៦៦) ឆ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ អរហត្តំ សច្ឆិកាតុំ ។ កតមេ ឆ ។ ថីនំ មិទ្ធំ ឧទ្ធច្ចំ កុក្កុច្ចំ អស្សទ្ធិយំ បមាទំ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ អប្បហាយ



(៦៥) ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៦ យ៉ាង មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលបានឡើយ ។ ធម៌ ៦ យ៉ាង គឺអ្វីខ្លះ ។ គឺសេចក្តីមិនជឿ ១ មិនខ្មាសបាប ១ មិនខ្លាចបាប ១ ខ្ជិលច្រអូស ១ ភ្លេចស្មារតី ១ អប្បឥតប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៦ យ៉ាងនេះឯង មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផលបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាង គួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផលបាន ។ ធម៌ ៦ យ៉ាង គឺអ្វីខ្លះ ។ គឺសេចក្តីមិនជឿ ១ មិនខ្មាសបាប ១ មិនខ្លាចបាប ១ ខ្ជិលច្រអូស ១ ភ្លេចស្មារតី ១ អប្បឥតប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាងនេះឯង ទើបគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលបាន ។

(៦៦) ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៦ យ៉ាង មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលទេ ។ ធម៌ ៦ យ៉ាង គឺអ្វីខ្លះ ។ គឺសេចក្តីច្រអូសចិត្ត ១ សេចក្តីច្រអូសកាយ ១ សេចក្តីរាយមាយចិត្ត ១ សេចក្តីសៅសោកចិត្ត ១ សេចក្តីមិនជឿ ១ សេចក្តីធ្វេសប្រហែស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៦ យ៉ាងនេះឯង

អភព្វោ អរហត្តំ សច្ឆិកាតុំ ។ ឆ ភិក្ខវេ ធម្មេ បហាយ ភព្វោ អរហត្តំ សច្ឆិកាតុំ ។ កតមេ ឆ ថីនំ មិទ្ធំ ឧទ្ធច្ចំ កុក្កុច្ចំ អស្សទ្ធិយំ បមាទំ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ បហាយ ភព្វោ អរហត្តំ សច្ឆិកាតុន្តិ ។

[២៧] សោ វត ភិក្ខវេ ភិក្ខុ បាបមិត្តោ បាបសហាយោ បាបសម្បវង្កោ បាបមិត្តេ សេវមានោ ភជមានោ បយិរុបាសមានោ តេសញ្ច ទិដ្ឋានុគតឹ អាបជ្ជមានោ អភិសមាចារិកំ ធម្មំ បរិបូរេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ អភិសមាចារិកំ ធម្មំ អបរិបូរេត្វា សេក្ខធម្មំ បរិបូរេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សេក្ខធម្មំ អបរិបូរេត្វា សីលានិ បរិបូរេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សីលានិ អបរិបូរេត្វា កាមរាគំ វា រូបរាគំ វា អរូបរាគំ វា បជហិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វត ភិក្ខវេ ភិក្ខុ កល្យាណមិត្តោ កល្យាណសហាយោ



មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាង ទើបគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តបាន ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសេចក្តីច្រអូសចិត្ត ១ សេចក្តីច្រអូសកាយ ១ សេចក្តីរាយមាយចិត្ត ១ សេចក្តីស្តាយសល់ចិត្ត ១ សេចក្តីមិនជឿ ១ សេចក្តីធ្វេសប្រហែស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់នូវធម៌ ៦ យ៉ាងនេះឯង ទើបគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តបាន ។

(២៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯងមានមិត្តអាក្រក់ មានសំឡាញ់អាក្រក់ ថែរទាក់ទងតែបុគ្គលអាក្រក់ សេពគប់ ចូលទៅអង្គុយជិតនូវមិត្តអាក្រក់ យកតម្រាប់តម្រាតាមពួកមិត្តអាក្រក់ទាំងនោះ នឹងបំពេញអភិសមាចារិកធម៌ ឲ្យបរិបូណ៌បាន ហេតុនេះមិនដែលមានឡើយ ។ បើមិនបានបំពេញអភិសមាចារិកធម៌ ឲ្យបរិបូណ៌ហើយ នឹងបំពេញសេក្ខធម៌ ឲ្យបរិបូណ៌បាន ហេតុនេះមិនដែលមានទេ ។ បើមិនបានបំពេញសេក្ខធម៌ ឲ្យបរិបូណ៌ហើយ នឹងបំពេញសីលទាំងឡាយ ឲ្យបរិបូណ៌បាន ហេតុនេះមិនដែលមានទេ ។ បើមិនបានបំពេញសីលទាំងឡាយឲ្យបរិបូណ៌បានទេ នឹងលះបង់កាមរាគ ឬរូបរាគ ឬអរូបរាគបាន ហេតុនេះក៏មិនដែលមានទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ មានមិត្តល្អ មានសំឡាញ់ល្អ

កល្យាណសម្បវង្កោ កល្យាណមិត្តេ សេវមានោ ភជមានោ បយិរុបាសមានោ តេសញ្ច ទិដ្ឋានុគតឹ អាបជ្ជមានោ អភិសមាចារិកំ ធម្មំ បរិបូរេស្សតីតិ ឋានមេតំ វិជ្ជតិ ។ អភិសមាចារិកំ ធម្មំ បរិបូរេត្វា សេក្ខធម្មំ បរិបូរេស្សតីតិ ឋានមេតំ វិជ្ជតិ ។ សេក្ខធម្មំ បរិបូរេត្វា សីលានិ បរិបូរេស្សតីតិ ឋានមេតំ វិជ្ជតិ ។ សីលានិ បរិបូរេត្វា កាមរាគំ វា រូបរាគំ វា អរូបរាគំ វា បជហិស្សតីតិ ឋានមេតំ វិជ្ជតីតិ ។

(៦៨) សោ វត ភិក្ខវេ ភិក្ខុ សង្គណិការាមោ សង្គណិការតោ សង្គណិការាមតំ អនុយុត្តោ គណារាមោ គណរតោ គណារាមតំ អនុយុត្តោ ឯកោ បវិវេកោ អភិរមិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ ឯកោ បវិវេកោ អនភិរមន្តោ ចិត្តស្ស និមិត្តំ គហេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ ចិត្តស្ស និមិត្តំ អគ្គណ្ហន្តោ សម្មាទិដ្ឋឹ បរិបូរេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សម្មាទិដ្ឋឹ អបរិបូរេត្វា សម្មាសមាធឹ បរិបូរេស្សតីតិ នេតំ ឋានំ វិជ្ជតិ ។



ដែលទៅគប់រកនឹងមិត្តល្អ សេពគប់ ចូលទៅអង្គុយជិតចំពោះពួកមិត្តល្អ ហើយក៏យកតម្រាប់តម្រាតាមពួកមិត្តល្អទាំងនោះ នឹងបំពេញអភិសមាចារិកធម៌ ឲ្យបរិបូណ៌បាន ហេតុនេះរមែងមានមែន ។ បើបានបំពេញអភិសមាចារិកធម៌ ឲ្យបរិបូណ៌ហើយ នឹងបំពេញសេក្ខធម៌ ឲ្យបរិបូណ៌បានទៀត ហេតុនេះរមែងមានមែន ។ បើបានបំពេញសេក្ខធម៌ហើយ នឹងបំពេញសីលទាំងឡាយបានទៀត ហេតុនេះរមែងមានមែន ។ បើបានបំពេញសីលទាំងឡាយហើយ នឹងលះបង់កាមរាគៈ រូបរាគៈ ឬក៏អរូបរាគៈចេញបាន ហេតុនេះរមែងមានមែន ។

(៦៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ជាអ្នករីករាយ ក្នុងការប្រឡូកប្រឡំដោយពួក ត្រេកអរក្នុងការប្រឡូកប្រឡំដោយពួក ប្រកបសេចក្តីត្រេកអរ ក្នុងការប្រឡូកប្រឡំដោយពួក រីករាយក្នុងពួក ត្រេកអរក្នុងពួក ប្រកបសេចក្តីត្រេកអរក្នុងពួកហើយ ត្រេកអរក្នុងវិវេកតែម្នាក់ឯងបាន ហេតុនេះមិនដែលមានឡើយ ។ កាលបើមិនត្រេកអរក្នុងវិវេកតែម្នាក់ឯង នឹងទទួលយកនិមិត្តនៃចិត្តបាន ហេតុនេះមិនដែលមានឡើយ ។ កាលបើមិនទទួលយកនិមិត្តនៃចិត្តហើយ នឹងបំពេញសម្មាទិដ្ឋិបាន ហេតុនេះមិនដែលមានឡើយ ។ លុះមិនបានបំពេញសម្មាទិដ្ឋិហើយ នឹងបំពេញសម្មាសមាធិបាន ហេតុនេះមិនដែលមានឡើយ ។

សម្មាសមាធឹ អបរិបូរេត្វា សញ្ញោជនានិ បជហិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សញ្ញោជនានិ អប្បហាយ និព្វានំ សច្ឆិករិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វត ភិក្ខវេ ភិក្ខុ ន សង្គណិការាមោ ន សង្គណិករតោ ន សង្គណិការាមតំ អនុយុត្តោ ន គណារាមោ ន គណរតោ ន គណារាមតំ អនុយុត្តោ ឯកោ បវិវេកេ អភិរមិស្សតីតិ ឋានមេតំ វិជ្ជតិ ។ ឯកោ បវិវេកេ អភិរមន្តោ ចិត្តស្ស និមិត្តំ គហេស្សតីតិ ឋានមេតំ វិជ្ជតិ ។ ចិត្តស្ស និមិត្តំ គណ្ហន្តោ សម្មាទិដ្ឋឹ បរិបូរេស្សតីតិ ឋានមេតំ វិជ្ជតិ ។ សម្មាទិដ្ឋឹ បរិបូរេត្វា សម្មាសមាធឹ បរិបូរេស្សតីតិ ឋានមេតំ វិជ្ជតិ ។ សម្មាសមាធឹ បរិបូរេត្វា សញ្ញោជនានិ បជហិស្សតីតិ ឋានមេតំ វិជ្ជតិ ។ សញ្ញោជនានិ បហាយ និព្វានំ សច្ឆិករិស្សតីតិ ឋានមេតំ វិជ្ជតីតិ ។

(៦៩) អដ្ឋមោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា



បើមិនបំពេញសម្មាសមាធិហើយ នឹងលះបង់សញ្ញោជនៈទាំងឡាយបាន ហេតុនេះមិនដែលមានឡើយ ។ បើមិនលះបង់សញ្ញោជនៈទាំងឡាយហើយ នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានបាន ហេតុនេះមិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចាល់តែភិក្ខុនោះ មិនរីករាយក្នុងការប្រជុំប្រចល់ដោយពួក មិនត្រេកអរក្នុងការប្រជុំប្រចល់ដោយពួក មិនប្រកបសេចក្តីត្រេកអរ ក្នុងការប្រជុំប្រចល់ដោយពួក មិនរីករាយក្នុងពួក មិនត្រេកអរក្នុងពួក មិនប្រកបសេចក្តីរីករាយ ក្នុងពួកហើយ ត្រេកអរក្នុងទីវិវេកតែម្នាក់ឯងបាន ហេតុនេះទើបមានមែន ។ កាលបើត្រេកអរក្នុងទីវិវេកតែម្នាក់ឯងហើយ នឹងទទួលយកនិមិត្តនៃចិត្តបាន ហេតុនេះទើបមានមែន ។ កាលបើទទួលយកនិមិត្តនៃចិត្តហើយ នឹងបំពេញសម្មាទិដ្ឋិបាន ហេតុនេះទើបមានមែន ។ បើបំពេញសម្មាទិដ្ឋិហើយ នឹងបំពេញសម្មាសមាធិបានទៀត ហេតុនេះទើបមានមែន ។ បើបំពេញសម្មាសមាធិហើយ នឹងលះបង់សញ្ញោជនៈទាំងឡាយបាន ហេតុនេះទើបមានមែន ។ លះបង់សញ្ញោជនៈទាំងឡាយហើយ នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានបាន ហេតុនេះទើបមានមែន ។

(៦៩) គ្រានោះ ទេវតាមួយអង្គ កាលបើកន្លងបឋមយាមកន្លងទៅហើយ មានរស្មី ញុំាងវត្តជេតពនជុំវិញទាំងអស់ ឲ្យភ្លឺស្វាង

យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ ឯតទវោច ឆយិមេ ភន្តេ ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ ឆ ។ សត្ថុគារវតា ធម្មគារវតា សង្ឃគារវតា សិក្ខាគារវតា សោវចស្សតា កល្យាណមិត្តតា ។ ឥមេ ខោ ភន្តេ ឆ ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តីតិ ។ ឥទមវោច សា ទេវតា ។ សមនុញ្ញោ សត្ថា អហោសិ ។ អថខោ សា ទេវតា សមនុញ្ញោ មេ សត្ថាតិ ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយិ ។ អថខោ ភគវា តស្សា រត្តិយា អច្ចយេន ភិក្ខូ អាមន្តេសិ ឥមំ ភិក្ខវេ រត្តឹ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា



ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចឈរនៅក្នុងទីដ៏សមគួរ ។ លុះទេវតានោះឈរក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៦ យ៉ាងនេះប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៦ យ៉ាងដូចម្តេចខ្លះ ។ គឺសេចក្តីគោរពក្នុងព្រះសាស្តា ១ សេចក្តីគោរពក្នុងព្រះធម៌ ១ សេចក្តីគោរពក្នុងព្រះសង្ឃ ១ សេចក្តីគោរពក្នុងសិក្ខា ១ ភាពជាអ្នកប្រដៅងាយ ១ ភាពជាអ្នកមានមិត្តល្អ ១ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៦ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ទេវតានោះបានក្រាបទូលពាក្យនេះហើយ ។ ព្រះសាស្តាទ្រង់សព្វព្រះទ័យ ។ គ្រានោះ ទេវតានោះ បានដឹងថា ព្រះសាស្តាសព្វព្រះទ័យនឹងអញហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគធ្វើប្រទក្សិណ ហើយបាត់ក្នុងទីនោះឯង ។ លំដាប់ពីនោះមក ព្រះដ៏មានព្រះភាគ កាលដែលរាត្រីនោះ កន្លងទៅហើយ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ យប់មិញមានទេវតាមួយរូប កាលដែលរាត្រីបឋមយាម កន្លងទៅហើយ មានរស្មីដ៏ល្អ ធ្វើវត្តជេតពនជុំវិញទាំងអស់ ឲ្យភ្លឺស្វាង

យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ ភិក្ខវេ សា ទេវតា មំ ឯតទវោច ឆយិមេ ភន្តេ ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ ឆ ។ សត្ថុគារវតា ធម្មគារវតា សង្ឃគារវតា សិក្ខាគារវតា សោវចស្សតា កល្យាណមិត្តតា ។ ឥមេ ខោ ភន្តេ ឆ ធម្មា ភិក្ខុនោ អបរិហានាយ សំវត្តន្តីតិ ។ ឥទមវោច ភិក្ខវេ សា ទេវតា ឥទំ វត្វា មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។ ឯវំ វុត្តេ អាយស្មា សារីបុត្តោ ភគវន្តំ អភិវាទេត្វា ឯតទវោច ឥមស្ស ខោ អហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមិ ។ ឥធ ភន្តេ ភិក្ខុ អត្តនា ច សត្ថុគារវោ ហោតិ សត្ថុគារវតាយ ច វណ្ណវាទី



ហើយចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ក្រាបថ្វាយបង្គំតថាគត ហើយឈរក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះទេវតានោះឈរក្នុងទីដ៏សមគួរហើយ បាននិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៦ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ គឺសេចក្តីគោរពក្នុងព្រះសាស្តា ១ សេចក្តីគោរពក្នុងព្រះធម៌ ១ សេចក្តីគោរពក្នុងព្រះសង្ឃ ១ សេចក្តីគោរពក្នុងសិក្ខា ១ ភាពជាអ្នកប្រដៅងាយ ១ ភាពជាអ្នកមានមិត្តល្អ ១ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ ៦ យ៉ាងនេះឯង ប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ទេវតានោះបាននិយាយយ៉ាងនេះ លុះនិយាយពាក្យនេះចប់ហើយ ក៏ថ្វាយបង្គំតថាគតធ្វើប្រទក្សិណហើយបាត់ក្នុងទីនោះ ។ កាលបើព្រះសាស្តា ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះសារីបុត្តដ៏មានអាយុ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គយល់សេចក្តីអធិប្បាយនៃធម៌ ដែលព្រះដ៏មានព្រះភាគសំដែងដោយបំប្រួញនេះ ដោយសេចក្តីពិស្តារយ៉ាងនេះបាន ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុក្នុងសាសនានេះ ជាអ្នកគោរពក្នុងព្រះសាស្តា ដោយខ្លួនឯងផង ជាអ្នកនិយាយសរសើរគុណនៃសេចក្តីគោរព ក្នុងព្រះសាស្តាផង

យេ ចញ្ញេ ភិក្ខូ ន សត្ថុគារវា តេ ច សត្ថុគារវតាយ សមាទបេតិ យេ ចញ្ញេ ភិក្ខូ សត្ថុគារវា តេសញ្ច វណ្ណំ ភណតិ ភូតំ តច្ឆំ កាលេន ។ អត្តនា ច ធម្មគារវោ ហោតិ ។បេ។ សង្ឃគារវោ ហោតិ សិក្ខាគារវោ ហោតិ សុវចោ ហោតិ ។បេ។ កល្យាណមិត្តោ ហោតិ កល្យាណមិត្តតាយ ច វណ្ណវាទី យេ ចញ្ញេ ភិក្ខូ ន កល្យាណមិត្តា តេ ច កល្យាណមិត្តតាយ សមាទបេតិ យេ ចញ្ញេ ភិក្ខូ កល្យាណមិត្តា តេសញ្ច វណ្ណំ ភណតិ ភូតំ តច្ឆំ កាលេន ។ ឥមស្ស ខោ អហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមីតិ ។ សាធុ សាធុ សារីបុត្ត សាធុ ខោ ត្វំ សារីបុត្ត ឥមស្ស មយា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាសិ ។



ពួកភិក្ខុណា មិនគោរពក្នុងព្រះសាស្តាទេ ក៏ដឹកនាំពួកភិក្ខុនោះឲ្យគោរពក្នុងព្រះសាស្តាផង ។ ពួកភិក្ខុណា ជាអ្នកគោរពក្នុងព្រះសាស្តាស្រាប់ ក៏និយាយសរសើរគុណរបស់ពួកភិក្ខុនោះ ដែលមានពិតប្រាកដ តាមកាលគួរផង ។ ជាអ្នកគោរពក្នុងព្រះធម៌ ដោយខ្លួនឯងផង ។បេ។ ជាអ្នកគោរពក្នុងព្រះសង្ឃ ជាអ្នកគោរពក្នុងសិក្ខា ជាអ្នកប្រដៅងាយ ។បេ។ ជាអ្នកមានមិត្តល្អ និយាយសរសើរគុណ នៃការមានមិត្តល្អផង ពួកភិក្ខុណាជាអ្នកមិនមានមិត្តល្អទេ ក៏ដឹកនាំពួកភិក្ខុទាំងនោះ ឲ្យមានមិត្តល្អផង ពួកភិក្ខុណា ជាអ្នកមានមិត្តល្អស្រាប់ហើយ ក៏និយាយសរសើរគុណរបស់ពួកភិក្ខុនោះ ដែលមានពិតប្រាកដ តាមកាលដ៏គួរផង ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គយល់ច្បាស់ នូវសេចក្តីអធិប្បាយនៃធម៌ ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងដោយបំប្រួញនេះ ដោយសេចក្តីពិស្តារយ៉ាងនេះបាន ។ ម្នាលសារីបុត្ត ត្រូវហើយ ត្រូវហើយ ម្នាលសារីបុត្ត អ្នកបានយល់ច្បាស់ នូវសេចក្តីអធិប្បាយនៃធម៌ ដែលតថាគតសំដែងដោយបំប្រួញនេះ ដោយសេចក្តីពិស្តារយ៉ាងនេះបាន ប្រពៃណាស់ ។

ឥធ សារីបុត្ត ភិក្ខុ អត្តនា ច សត្ថុគារវោ ហោតិ សត្ថុគារវតាយ ច វណ្ណវាទី យេ ចញ្ញេ ភិក្ខូ ន សត្ថុគារវា តេ ច សត្ថុគារវតាយ សមាទបេតិ យេ ចញ្ញេ ភិក្ខូ សត្ថុគារវា តេសញ្ច វណ្ណំ ភណតិ ភូតំ តច្ឆំ កាលេន ។ អត្តនា ច ធម្មគារវោ ហោតិ ។ បេ ។ សង្ឃគារវោ ហោតិ សិក្ខាគារវោ ហោតិ សុវចោ ហោតិ ។ បេ ។ កល្យាណមិត្តោ ហោតិ កល្យាណមិត្តតាយ ច វណ្ណវាទី យេ ចញ្ញេ ភិក្ខូ ន កល្យាណមិត្តា តេ ច កល្យាណមិត្តតាយ សមាទបេតិ យេ ចញ្ញេ ភិក្ខូ កល្យាណមិត្តា តេសញ្ច វណ្ណំ ភណតិ ភូតំ តច្ឆំ កាលេន ។ ឥមស្ស ខោ សារីបុត្ត មយា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថោ ទដ្ឋព្វោតិ ។

(៧០) សោ វត ភិក្ខវេ ភិក្ខុ ន សន្តេន សមាធិនា ន បណីតេន ន បដិប្បស្សទ្ធិលទ្ធេន ន ឯកោទិភាវាធិគតេន អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភវិស្សតិ ឯកោបិ ហុត្វា ពហុធា ភវិស្សតិ



ម្នាលសារីបុត្ត ភិក្ខុក្នុងសាសនានេះ ជាអ្នកគោរពក្នុងសាស្តា ដោយខ្លួនឯងផង និយាយសរសើរគុណ នៃសេចក្តីគោរពក្នុងសាស្តាផង បើពួកភិក្ខុណា មិនគោរពក្នុងសាស្តាទេ ក៏ដឹកនាំពួកភិក្ខុទាំងនោះ ឲ្យគោរពក្នុងសាស្តាផង បើពួកភិក្ខុណាគោរពក្នុងសាស្តាស្រាប់ហើយ ក៏និយាយសរសើរគុណរបស់ពួកភិក្ខុទាំងនោះ ដែលមានពិតប្រាកដ តាមកាលគួរផង ជាអ្នកគោរពក្នុងធម៌ ដោយខ្លួនឯងផង ។បេ។ ជាអ្នកគោរពក្នុងសង្ឃ ជាអ្នកគោរពក្នុងសិក្ខា ជាអ្នកប្រដៅងាយ ។បេ។ ជាអ្នកមានមិត្តល្អ ជាអ្នកសរសើរគុណ នៃការមានមិត្តល្អផង បើពួកភិក្ខុណា ជាអ្នកឥតមិត្តល្អទេ ក៏បបួលពួកភិក្ខុទាំងនោះ ឲ្យមានមិត្តល្អផង បើភិក្ខុណា ជាអ្នកមានមិត្តល្អស្រាប់ហើយ ក៏និយាយសរសើរគុណ របស់ពួកភិក្ខុទាំងនោះ ដែលមានពិតប្រាកដ តាមកាលគួរផង ។ ម្នាលសារីបុត្ត សេចក្តីអធិប្បាយនៃធម៌ ដែលតថាគតសំដែងបំប្រួញនេះ អ្នកគួរយល់ដោយសេចក្តីពិស្តារ យ៉ាងនេះចុះ ។

(៧០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមិនមានសមាធិ ដ៏ស្ងប់ស្ងាត់ មិនមានសមាធិដ៏ឧត្តម មិនបាននូវបដិប្បស្សទ្ធិ មិនដល់នូវឯកោទិភាព ហើយនឹងបាននូវឫទ្ធិវិធៈច្រើនប្រការ មនុស្សម្នាក់ធ្វើឲ្យទៅជាច្រើនអ្នកបាន

ពហុធាបិ ហុត្វា ឯកោ ហោតិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ(១) នេតំ ឋានំ វិជ្ជតិ ។ ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណិស្សតិ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ចាតិ នេតំ ឋានំ វិជ្ជតិ ។ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានិស្សតិ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានិស្សតិ ។ បេ ។ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរិស្សតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សិស្សតិ ។ បេ ។ យថាកម្មូបគេ សត្តេ បជានិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។

១ វត្តេស្សតីតិ បាឋោ យុត្តោ ។



ជាមនុស្សច្រើននាក់ ធ្វើខ្លួនទៅជាមនុស្សម្នាក់បាន ។ បេ ។ នឹងធ្វើអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយរហូតដល់ព្រហ្មលោកបាន ហេតុនេះមិនមានឡើយ ។ បុគ្គលនោះនឹងស្តាប់ឮនូវសំឡេងទាំង ២ពួក គឺជាសំឡេងទេវតា នឹងសំឡេងមនុស្ស ឆ្ងាយក្តី ជិតក្តី ដោយសោតធាតុ ដូចជាទិព្វដ៏បរិសុទ្ធ កន្លងហួសសោតធាតុជារបស់មនុស្សធម្មតាបាន ហេតុនេះមិនមានឡើយ ។ កំណត់ដឹងនូវចិត្ត របស់សត្វទាំងឡាយដទៃ របស់បុគ្គលទាំងឡាយដទៃ ដោយចិត្តរបស់ខ្លួនបាន គឺចិត្តដែលប្រកបដោយរាគៈក្តី ក៏ដឹងថា ចិត្តប្រកបដោយរាគៈ ។ បេ ។ ចិត្តមិនទាន់ផុតចាកកិលេសក្តី ក៏ដឹងថា ចិត្តមិនទាន់ផុតចាកកិលេស ហេតុនេះមិនមានឡើយ ។ រលឹកឃើញនូវបុព្វេនិវាសៈ គឺលំនៅចាស់ៗ ដែលសត្វអាស្រ័យនៅក្នុងកាលមុនដ៏ច្រើនប្រការ គឺរលឹកឃើញមួយជាតិ ពីរជាតិ ។ បេ ។ រលឹកឃើញនូវបុព្វេនិវាសៈ មានប្រការដ៏ច្រើន ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ហេតុនេះមិនមានឡើយ ។ មានចក្ខុដ៏បរិសុទ្ធ ដូចជាទិព្វ កន្លងចក្ខុរបស់មនុស្សធម្មតា ឃើញនូវពួកសត្វ ។ បេ ។ ដឹងនូវពួកសត្វ ដែលប្រព្រឹត្តទៅ តាមកម្មរបស់ខ្លួន ហេតុនេះមិនមានឡើយ ។

ការសកំ ខយា ៗបេៗ សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។

សោ វត ភិក្ខវេ ភិក្ខុ សន្តេន សមាធិនា បណីតេន បដិប្បស្សទ្ធិលទ្ធេន ឯកោទិភាវាធិគតេន អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភវិស្សតិ ៗបេៗ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេស្សតីតិ ឋានមេតំ វិជ្ជតិ ។ ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្ត-មានុសិកាយ ឧភោ សទ្ទេ សុណិស្សតិ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ចាតិ ឋានមេតំ វិជ្ជតិ ។ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានិស្សតិ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានិស្សតិ ៗបេៗ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានិស្សតីតិ ឋានមេតំ វិជ្ជតិ ។ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរិស្សតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ៗបេៗ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរិស្សតីតិ



ព្រោះអស់អាសវៈទាំងឡាយ ៗបេៗ ធ្វើឲ្យជាក់ច្បាស់ ចូលដល់ ហេតុនេះ មិនមានឡើយ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមានសមាធិដ៏ល្អិត ដ៏ឧត្តម បាននូវបដិប្បស្សទ្ធិ បានដល់នូវឯកោទិភាព បាននូវឥទ្ធិវិធៈច្រើនប្រការ ៗបេៗ នឹងធ្វើអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយ រហូតដល់ព្រហ្មលោកបាន ហេតុនេះទើបមាន ។ អាចឮនូវសំឡេងទាំងពីរពួក គឺសំឡេងទេវតា ១ សំឡេងមនុស្ស ១ ទោះនៅឆ្ងាយក្តី ជិតក្តី ដោយសោតធាតុ ដូចជាទិព្វដ៏បរិសុទ្ធ កន្លងសោតធាតុរបស់មនុស្សធម្មតា ហេតុនេះទើបមាន អាចកំណត់ដឹងនូវចិត្តរបស់សត្វទាំងឡាយដទៃ របស់បុគ្គលទាំងឡាយដទៃ ដោយចិត្តរបស់ខ្លួនបាន គឺចិត្តដែលប្រកបដោយរាគៈក្តី ក៏ដឹងថា ចិត្តប្រកបដោយរាគៈ ៗបេៗ ចិត្តដែលមិនទាន់រួចស្រឡះក្តី ក៏ដឹងថា ចិត្តមិនទាន់រួចស្រឡះ ហេតុនេះទើបមាន ។ រលឹកឃើញនូវបុព្វេនិវាសៈ មានប្រការដ៏ច្រើន គឺរលឹកឃើញមួយជាតិ ពីរជាតិ ៗបេៗ រលឹកឃើញនូវបុព្វេនិវាសៈ មានប្រការដ៏ច្រើន ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ

ឋានមេតំ វិជ្ជតិ ។ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សិស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានិស្សតីតិ ឋានមេតំ វិជ្ជតិ ។ អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតីតិ ឋានមេតំ វិជ្ជតីតិ ។

(៧១) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ តត្រ តត្រេវ សក្ខិភព្វតំ បាបុណិតុំ សតិ សតិ អាយតនេ ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ ឥមេ ហានភាគិយា ធម្មាតិ យថាភូតំ នប្បជានាតិ ឥមេ ឋិតិភាគិយា(១) ធម្មាតិ យថាភូតំ នប្បជានាតិ ឥមេ វិសេសភាគិយា ធម្មាតិ យថាភូតំ នប្បជានាតិ ឥមេ និព្វេធភាគិយា ធម្មាតិ យថាភូតំ នប្បជានាតិ អសក្កច្ចការី ច ហោតិ អសប្បាយការី ច ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ តត្រ តត្រេវ សក្ខិភព្វតំ បាបុណិតុំ សតិ សតិ អាយតនេ ។

១ ម. ឋិតិភាគិយា ។



ហេតុនេះទើបមាន ។ ភិក្ខុនោះ មានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធកន្លងចក្ខុរបស់មនុស្សធម្មតា តែងឃើញពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកថយ ខ្ពង់ខ្ពស់ សម្បុរល្អ សម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់ នូវពួកសត្វដែលប្រព្រឹត្តទៅ តាមកម្មរបស់ខ្លួន ហេតុនេះទើបមាន ។ ធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ មិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ហេតុនេះទើបមាន ។

(៧២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង កាលបើមានហេតុ មិនគួរដើម្បីដល់នូវសេចក្តីជាក់ច្បាស់ ក្នុងគុណវិសេសនោះៗ ទេ ។ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនដឹងច្បាស់តាមពិតថា នេះពួកធម៌ជាចំណែកនៃសេចក្តីសាបសូន្យ ១ មិនដឹងច្បាស់តាមពិតថា នេះពួកធម៌ជាចំណែកនៃការតាំងនៅ ១ មិនដឹងច្បាស់តាមពិតថា នេះពួកធម៌ជាចំណែកដ៏វិសេស ១ មិនដឹងច្បាស់តាមពិតថា នេះពួកធម៌ជាចំណែកនៃសេចក្តីធ្លុះធ្លាយ ១ ជាអ្នកមិនធ្វើដោយសេចក្តីគោរព ១ ជាអ្នកមិនធ្វើសេចក្តីសប្បាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង កាលបើមានហេតុ មិនគួរដល់នូវសេចក្តីជាក់ច្បាស់ ក្នុងគុណវិសេសនោះៗ ទេ ។

ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ តត្រ តត្រេវ សក្ខិភព្វតំ បាបុណិតុំ សតិ សតិ អាយតនេ ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ ឥមេ ហានភាគិយា ធម្មាតិ យថាភូតំ បជានាតិ ឥមេ ឋិតិភាគិយា ធម្មាតិ យថាភូតំ បជានាតិ ឥមេ វិសេសភាគិយា ធម្មាតិ យថាភូតំ បជានាតិ ឥមេ និព្វេធភាគិយា ធម្មាតិ យថាភូតំ បជានាតិ សក្កច្ចការី ច ហោតិ សប្បាយការី ច ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ តត្រ តត្រេវ សក្ខិភព្វតំ បាបុណិតុំ សតិ សតិ អាយតនេតិ ។

(៧២) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ សមាធិស្មឹ ពលតំ បាបុណិតុំ ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ ន សមាធិស្ស សមាបត្តិកុសលោ ហោតិ ន សមាធិស្ស ឋិតិកុសលោ ហោតិ ន សមាធិស្ស វុដ្ឋានកុសលោ ហោតិ អសក្កច្ចការី ច ហោតិ អសាតច្ចការី ច អសប្បាយការី ច ។



ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង កាលបើមានហេតុ គួរដើម្បីដល់នូវសេចក្តីជាក់ច្បាស់ ក្នុងគុណវិសេសនោះៗ បាន ។ ធម៌ ៦ យ៉ាងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះដឹងច្បាស់តាមពិតថា នេះពួកធម៌ជាចំណែកនៃសេចក្តីសាបសូន្យ ១ ដឹងច្បាស់តាមពិតថា នេះពួកធម៌ជាចំណែកនៃការតាំងនៅ ១ ដឹងច្បាស់តាមពិតថា នេះពួកធម៌ជាចំណែកនៃវិសេស ១ ដឹងច្បាស់តាមពិតថា នេះពួកធម៌ជាចំណែកនៃសេចក្តីធ្លុះធ្លាយ ១ ជាអ្នកធ្វើដោយសេចក្តីគោរព ១ ជាអ្នកធ្វើសេចក្តីសប្បាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង កាលបើមានហេតុ គួរដើម្បីដល់នូវសេចក្តីជាក់ច្បាស់ ក្នុងគុណវិសេសនោះៗ បាន ។

(៧២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង មិនគួរដើម្បីដល់នូវភាព ជាអ្នកមានកំឡាំងក្នុងសមាធិ ។ ធម៌ ៦ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនឈ្លាសក្នុងការចូលសមាធិ ១ មិនឈ្លាសក្នុងការតាំងនៅក្នុងសមាធិ ១ មិនឈ្លាសក្នុងការចេញចាកសមាធិ ១ មិនធ្វើនូវសេចក្តីគោរព ១ មិនធ្វើរឿយៗ ១ មិនធ្វើសេចក្តីសប្បាយ ១ ។

ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ សមាធិស្មឹ ពលតំ បាបុណិតុំ ។

ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ សមាធិស្មឹ ពលតំ បាបុណិតុំ ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ សមាធិស្ស សមាបត្តិកុសលោ ហោតិ សមាធិស្ស ឋិតិកុសលោ ហោតិ សមាធិស្ស វុដ្ឋានកុសលោ ហោតិ សក្កច្ចការី ច ហោតិ សាតច្ចការី ច សប្បាយការី ច ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ សមាធិស្មឹ ពលតំ បាបុណិតុន្តិ ។

(៧៣) ឆ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតុំ ។ កតមេ ឆ ។ កាមច្ឆន្ទំ ព្យាបាទំ ថីនមិទ្ធំ ឧទ្ធច្ចកុក្កុច្ចំ វិចិកិច្ឆំ កាមេសុ ខោ បនស្ស អាទីនវោ ន យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋោ ហោតិ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ អប្បហាយ អភព្វោ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតុំ ។



ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកមិនគួរដើម្បីដល់នូវភាពជាអ្នកមានកំឡាំងក្នុងសមាធិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរដើម្បីដល់នូវភាពជាអ្នកមានកំឡាំងក្នុងសមាធិ។ ធម៌ ៦ យ៉ាងតើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកឈ្លាសក្នុងការចូលសមាធិ ១ ឈ្លាសក្នុងការតាំងនៅក្នុងសមាធិ ១ ឈ្លាសក្នុងការចេញចាកសមាធិ ១ ធ្វើនូវសេចក្តីគោរព ១ ធ្វើរឿយៗ ១ ធ្វើសេចក្តីសប្បាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកគួរដើម្បីដល់នូវភាពជាអ្នកមានកំឡាំងក្នុងសមាធិ ។

(៧៣) ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៦ យ៉ាង ជាអ្នកមិនគួរបាននូវបឋមជ្ឈាន ។ ធម៌ ៦ យ៉ាងតើដូចម្តេច ។ គឺកាមច្ឆន្ទៈ ១ ព្យាបាទៈ ១ ថីនមិទ្ធៈ ១ ឧទ្ធច្ចកុក្កុច្ចៈ ១ វិចិកិច្ឆា ១ ទោសក្នុងកាមទាំងឡាយ បុគ្គលនោះ មិនបានពិចារណាឲ្យឃើញច្បាស់ ដោយប្រាជ្ញារបស់ខ្លួន តាមពិត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានលះបង់ធម៌ ៦ យ៉ាងនេះឯង ជាអ្នកមិនគួរបាននូវបឋមជ្ឈានឡើយ ។

ឆ ភិក្ខវេ ធម្មេ បហាយ ភព្វោ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតុំ ។ កតមេ ឆ ។ កាមច្ឆន្ទំ ព្យាបាទំ ថីនមិទ្ធំ ឧទ្ធច្ចកុក្កុច្ចំ វិចិកិច្ឆំ កាមេសុ ខោ បនស្ស អាទីនវោ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋោ ហោតិ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ បហាយ ភព្វោ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតុន្តិ ។

(៧៦) ឆ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតុំ ។ កតមេ ឆ ។ កាមវិតក្កំ ព្យាបាទវិតក្កំ វិហឹសាវិតក្កំ កាមសញ្ញំ ព្យាបាទសញ្ញំ វិហឹសាសញ្ញំ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ អប្បហាយ អភព្វោ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតុំ ។

ឆ ភិក្ខវេ ធម្មេ បហាយ ភព្វោ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតុំ ។ កតមេ ឆ ។ កាមវិតក្កំ ព្យាបាទវិតក្កំ



ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាង ទើបជាអ្នកគួរបាននូវបឋមជ្ឈាន ។ ធម៌ ៦ យ៉ាង តើដូចម្តេច ។ គឺ កាមច្ឆន្ទៈ ១ ព្យាបាទ ១ ថីនមិទ្ធៈ ១ ឧទ្ធច្ចកុក្កុច្ចៈ ១ វិចិកិច្ឆា ១ ទោសក្នុងកាមទាំងឡាយ បុគ្គលនោះ ពិចារណាឃើញដោយប្រាជ្ញាល្អ ទួន តាមពិត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាង នេះឯង ទើបជាអ្នកគួរបាននូវបឋមជ្ឈាន ។

(៧៦) ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៦ យ៉ាង ជាអ្នកមិនគួរបាននូវបឋមជ្ឈាន ។ ធម៌ ៦ យ៉ាង តើដូចម្តេច ។ គឺកាមវិតក្កៈ ១ ព្យាបាទវិតក្កៈ ១ វិហឹសាវិតក្កៈ ១ កាមសញ្ញា ១ ព្យាបាទសញ្ញា ១ វិហឹសាសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៦ យ៉ាងនេះឯង ជាអ្នកមិនគួរបាននូវបឋមជ្ឈានទេ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាង ទើបជាអ្នកគួរបាននូវបឋមជ្ឈាន ។ ៦ យ៉ាងតើដូចម្តេច ។ គឺកាមវិតក្កៈ ១ ព្យាបាទវិតក្កៈ ១

វិហិំសាវិតក្កំ កាមសញ្ញំ ព្យាបាទសញ្ញំ វិហិំសាសញ្ញំ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ បហាយ ភព្វោ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតុន្តិ ។

ទេវតាវគ្គោ តតិយោ ។

## តស្សុទ្ទានំ

អនាគាមិ អរហំ មិត្តា ទេវតា
សតិសក្ខិពលំ តំ ឈានំ អបរេ ទុវេតិ ។



វិហិំសាវិតក្កៈ ១ កាមសញ្ញា ១ ព្យាបាទសញ្ញា ១ វិហិំសាសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់នូវធម៌ ៦ យ៉ាងនេះឯង ទើបជាអ្នកគួរ ចូលបឋមជ្ឈាន ។

ចប់ ទេវតាវគ្គទី ៣ ។

## ឧទ្ទាននៃទេវតាវគ្គនោះគឺ

និយាយអំពីអនាគាមិបុគ្គល ១ ព្រះអរហន្ត ១
មិត្ត ១ ទេវតា ១ ការបើតាមហេតុ មិនគួរដល់
នូវសមាធិជាក់ច្បាស់ ១ កំឡាំង ( ក្នុងសមាធិ ) ១
បឋមជ្ឈាន ១ ឈាន ៦ ដទៃទៀត ១ ។

## អរហត្តវគ្គោ

(៧៥) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ទិដ្ឋេវ ធម្មេ ទុក្ខំ វិហរតិ សវិឃាតំ សឧបាយាសំ សបរិឡាហំ កាយស្ស ភេទា បរម្មរណា ទុគ្គតិ បាដិកង្ខា ។ កតមេហិ ឆហិ ។ កាមវិតក្កេន ព្យាបាទវិតក្កេន វិហឹសាវិតក្កេន កាមសញ្ញាយ ព្យាបាទសញ្ញាយ វិហឹសាសញ្ញាយ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ទិដ្ឋេវ ធម្មេ ទុក្ខំ វិហរតិ សវិឃាតំ សឧបាយាសំ សបរិឡាហំ កាយស្ស ភេទា បរម្មរណា ទុគ្គតិ បាដិកង្ខា ។

ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ទិដ្ឋេវ ធម្មេ សុខំ វិហរតិ អវិឃាតំ អនុបាយាសំ អបរិឡាហំ កាយស្ស ភេទា បរម្មរណា សុគតិ បាដិកង្ខា ។ កតមេហិ ឆហិ ។ នេក្ខម្មវិតក្កេន អព្យាបាទវិតក្កេន អវិហឹសាវិតក្កេន នេក្ខម្មសញ្ញាយ អព្យាបាទសញ្ញាយ

## អរហត្តវគ្គ

(៧៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង តែងនៅជាទុក្ខ ប្រកបដោយសេចក្តីលំបាកចង្អៀតចង្អល់ ក្តៅក្រហាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅហើយ ទៅកើតក្នុងទុគ្គតិ ។ ធម៌ ៦ យ៉ាងតើដូចម្តេច ។ គឺកាមវិតក្កៈ ១ ព្យាបាទវិតក្កៈ ១ វិហឹសាវិតក្កៈ ១ កាមសញ្ញា ១ ព្យាបាទសញ្ញា ១ វិហឹសាសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង តែងនៅជាទុក្ខ ប្រកបដោយសេចក្តីលំបាកប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅហើយ ទៅកើតក្នុងទុគ្គតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង តែងនៅជាសុខ មិនមានសេចក្តីលំបាក មិនចង្អៀតចង្អល់ មិនក្តៅក្រហាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅហើយ តែងមានសុគតិជាទីសង្ឃឹម ។ ធម៌ ៦ យ៉ាង តើដូចម្តេច ។ គឺ នេក្ខម្មវិតក្កៈ ១ អព្យាបាទវិតក្កៈ ១ អវិហឹសាវិតក្កៈ ១ នេក្ខម្មសញ្ញា ១ អព្យាបាទសញ្ញា ១

អាទីនវសញ្ញាយ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ទិដ្ឋេវ ធម្មេ សុខំ វិហរតិ អវិឃាតំ អនុបាយាសំ អបរិឡាហំ កាយស្ស ភេទា បរម្មរណា សុគតិ បាដិកង្ខាតិ ។

(៧៦) ឆ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ អរហត្តំ សច្ឆិកាតុំ ។ កតមេ ឆ ។ មានំ ឱមានំ អតិមានំ អធិមានំ ថម្ភំ អតិនិបាតំ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ អប្បហាយ អភព្វោ អរហត្តំ សច្ឆិកាតុំ ។

ឆ ភិក្ខវេ ធម្មេ បហាយ ភព្វោ អរហត្តំ សច្ឆិកាតុំ ។ កតមេ ឆ ។ មានំ ឱមានំ អតិមានំ អធិមានំ ថម្ភំ អតិនិបាតំ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ បហាយ ភព្វោ អរហត្តំ សច្ឆិកាតុន្តិ ។



អាទីនវសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង រមែងនៅជាសុខ មិនមានសេចក្តីលំបាក មិនចង្អៀតចង្អល់ មិនក្តៅក្រហាយ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងមានសុគតិជាទីសង្ឃឹម ។

(៧៦) ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៦ យ៉ាង ជាអ្នកមិនគួរធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសេចក្តីប្រកាន់ ដោយការជាតិជាដើម ១ សេចក្តីប្រកាន់ថា អញថោកទាប ១ សេចក្តីប្រកាន់ថា ខ្ពង់ខ្ពស់ ១ សេចក្តីប្រកាន់ថា លើសលុប ១ រឹងត្អឹង ១ សេចក្តីប្រកាន់ថា អញថោកថយជាងគេ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ទាំង ៦ យ៉ាងនេះឯង ជាអ្នកមិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តទេ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាង ជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តបាន ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសេចក្តីប្រកាន់ ដោយការជាតិជាដើម ១ សេចក្តីប្រកាន់ថា ថោកទាប ១ សេចក្តីប្រកាន់ថា ខ្ពង់ខ្ពស់ ១ សេចក្តីប្រកាន់ថា លើសលុប ១ រឹងត្អឹង ១ សេចក្តីប្រកាន់ថា ថោកថយជាងគេ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាងនេះឯង ទើបគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តបាន ។

(៧៧) ឆ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ ឧត្តរិមនុស្សធម្មា អលមរិយញាណទស្សនវិសេសំ សច្ឆិកាតុំ ។ កតមេ ឆ ។ មុដ្ឋស្សច្ចំ អសម្បជញ្ញំ ឥន្ទ្រិយេសុ អគុត្តទ្វារតំ ភោជនេ អមត្តញ្ញុតំ កុហនំ លបនំ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ អប្បហាយ អភព្វោ ឧត្តរិមនុស្សធម្មា អលមរិយញាណទស្សនវិសេសំ សច្ឆិកាតុំ ។

ឆ ភិក្ខវេ ធម្មេ បហាយ ភព្វោ ឧត្តរិមនុស្សធម្មា អលមរិយញាណទស្សនវិសេសំ សច្ឆិកាតុំ ។ កតមេ ឆ ។ មុដ្ឋស្សច្ចំ អសម្បជញ្ញំ ឥន្ទ្រិយេសុ អគុត្តទ្វារតំ ភោជនេ អមត្តញ្ញុតំ កុហនំ លបនំ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ បហាយ ភព្វោ ឧត្តរិមនុស្សធម្មា អលមរិយញាណទស្សនវិសេសំ សច្ឆិកាតុន្តិ ។

(៧៨) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ទិដ្ឋេវ ធម្មេ សុខសោមនស្សពហុលោ វិហរតិ យោនិ ចស្ស អារទ្ធា ហោតិ អាសវានំ ខយាយ ។



(៧៧) ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះធម៌ ៦ យ៉ាង ជាអ្នកមិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស គឺញាណទស្សនៈដ៏ឧត្តម លើសមនុស្សធម៌ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺភ្លេចស្មារតី ១ មិនដឹងខ្លួន ១ មានទ្វារមិនបានគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ ១ មិនដឹងប្រមាណ ក្នុងភោជន ១ និយាយកុហក ១ និយាយលើកដាក់ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនលះបង់ធម៌ ៦ យ៉ាងនេះឯង ជាអ្នកមិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេសគឺញាណទស្សនៈ ដ៏ឧត្តម លើសមនុស្សធម៌ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលលះធម៌ ៦ យ៉ាង ជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស គឺញាណទស្សនៈ ដ៏ឧត្តមលើសមនុស្សធម៌ ។ ធម៌ ៦ យ៉ាងតើអ្វីខ្លះ ។ គឺភ្លេចស្មារតី ១ មិនដឹងខ្លួន ១ មានទ្វារមិនបានគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ១ មិនដឹងប្រមាណក្នុងភោជន ១ និយាយកុហក ១ និយាយលើកដាក់ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាងនេះឯង ទើបជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស គឺញាណទស្សនៈដ៏ឧត្តម លើសមនុស្សធម៌បាន ។

(៧៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកមានសុខនិងសោមនស្ស ដ៏ច្រើនក្នុងបច្ចុប្បន្ន ទាំងហេតុប្រព្រឹត្តទៅ ដើម្បីអស់អាសវៈទាំងឡាយ ក៏ភិក្ខុនោះបានប្រារព្ធហើយ ។

កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ ធម្មារាមោ ហោតិ ភាវនារាមោ ហោតិ បហានារាមោ ហោតិ បវិវេការាមោ ហោតិ អព្យាបជ្ឈារាមោ ហោតិ និប្បបញ្ចារាមោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ទិដ្ឋេវ ធម្មេ សុខសោមនស្សពហុលោ វិហរតិ យោនិ ចស្ស អារទ្ធា ហោតិ អាសវានំ ខយាយាតិ ។

[៧៩] ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ អនធិគតំ វា កុសលំ ធម្មំ អធិគន្តុំ អធិគតំ វា កុសលំ ធម្មំ ផាតិកាតុំ ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ ន អាយកុសលោ ហោតិ ន អបាយកុសលោ ហោតិ ន ឧបាយកុសលោ ហោតិ អនធិគតានំ កុសលានំ ធម្មានំ អធិគមាយ ន ឆន្ទំ ជនេតិ អធិគតេ កុសលេ ធម្មេ ន សារក្ខតិ សាតច្ចកិរិយាយ ន សម្បាទេតិ ។



ធម៌ ៦ យ៉ាងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកត្រេកអរក្នុងធម៌ ១ ត្រេកអរក្នុងភាវនា ១ ត្រេកអរក្នុងការលះ ១ ត្រេកអរក្នុងវិវេក ១ ត្រេកអរក្នុងអព្យាបាទ ១ ត្រេកអរក្នុងធម៌ មិនធ្វើដំណើរឲ្យយឺតយូរ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកមានសុខនឹងសោមនស្សដ៏ច្រើន ក្នុងបច្ចុប្បន្ន ទាំងហេតុប្រព្រឹត្តទៅ ដើម្បីអស់អាសវៈទាំងឡាយ ភិក្ខុនោះបានប្រារព្ធហើយ ។

(៧៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកមិនគួរ ដើម្បីបាននូវកុសលធម៌ដែលខ្លួនមិនទាន់បាន ឬ ដើម្បីធ្វើកុសលធម៌ដែលខ្លួនបានរួចហើយ ឲ្យផ្សាយចេញទៅ ។ ធម៌ ៦ យ៉ាងតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនឈ្លាសក្នុងសេចក្តីចំរើន ១ មិនឈ្លាសក្នុងសេចក្តីវិនាស ១ មិនឈ្លាសក្នុងឧបាយ ១ មិនញុំាងសេចក្តីពេញចិត្តឲ្យកើតឡើង ដើម្បីបាននូវកុសលធម៌ទាំងឡាយ ដែលខ្លួនមិនទាន់បាន ១ មិនរក្សានូវកុសលធម៌ទាំងឡាយ ដែលខ្លួនបានហើយ ១ មិនញុំាងកុសលធម៌ឲ្យដល់ព្រម ដោយការធ្វើរឿយៗ ១ ។

ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ អនធិគតំ វា កុសលំ ធម្មំ អធិគន្តុំ អធិគតំ វា កុសលំ ធម្មំ ផាតិកាតុំ ។

ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ អនធិគតំ វា កុសលំ ធម្មំ អធិគន្តុំ អធិគតំ វា កុសលំ ធម្មំ ផាតិកាតុំ ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ អាយកុសលោ ច ហោតិ អបាយកុសលោ ច ហោតិ ឧបាយកុសលោ ច ហោតិ អនធិគតានំ កុសលានំ ធម្មានំ អធិគមាយ ឆន្ទំ ជនេតិ អធិគតេ កុសលេ ធម្មេ សារក្ខតិ សាតច្ចកិរិយាយ សម្បាទេតិ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ អនធិគតំ វា កុសលំ ធម្មំ អធិគន្តុំ អធិគតំ វា កុសលំ ធម្មំ ផាតិកាតុន្តិ ។

(៨០) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ន ចិរស្សេវ មហន្តំ(១) វេបុល្លត្តំ បាបុណាតិ ធម្មេសុ ។

១ ឱ, ម. មហត្តំ ។



ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកមិនគួរ ដើម្បីបាននូវកុសលធម៌ ដែលខ្លួនមិនទាន់បាន ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរដើម្បី បាននូវកុសលធម៌ ដែលខ្លួនមិនទាន់បាន ឬ ដើម្បីធ្វើនូវកុសលធម៌ ដែលខ្លួនបានហើយ ឲ្យផ្សាយចេញទៅ ។ ធម៌ ៦ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកឈ្លាសក្នុងសេចក្តីចំរើន ១ ឈ្លាសក្នុងសេចក្តីវិនាស ១ ឈ្លាសក្នុងឧបាយ ១ ញុំាងសេចក្តីពេញចិត្តឲ្យកើតឡើង ដើម្បីបាននូវកុសលធម៌ទាំងឡាយ ដែលខ្លួនមិនទាន់បាន ១ រក្សាកុសលធម៌ទាំងឡាយ ដែលខ្លួនបានហើយ ១ ញុំាងកុសលឲ្យដល់ព្រម ដោយកិរិយាធ្វើរឿយ ៗ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកគួរដើម្បី បាននូវកុសលធម៌ ដែលខ្លួនមិនទាន់បាន ឬ ដើម្បីធ្វើនូវធម៌ ដែលខ្លួនបានហើយ ឲ្យផ្សាយចេញទៅ ។

(៨០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង មិនយូរប៉ុន្មាន គង់ដល់នូវភាពជាធំ ទូលំទូលាយ ក្នុងធម៌ទាំងឡាយ ។

កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ អាលោកពហុលោ ច ហោតិ យោគពហុលោ ច ហោតិ(១) វីរិយពហុលោ ច ហោតិ សន្តុដ្ឋិពហុលោ ច អនិក្ខិត្តធុរោ ច កុសលេសុ ធម្មេសុ ឧត្តរិញ្ច បតារេតិ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ន ចិរស្សេវ មហត្តំ វេបុល្លត្តំ បាបុណាតិ ធម្មេសូតិ ។

(៨១) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ឆហិ ។ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុ មិច្ឆាចារី ហោតិ មុសាវាទី ហោតិ បាបិច្ឆោ ច មិច្ឆាទិដ្ឋិ ច ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។

ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ ឆហិ ។ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ អប្បិច្ឆោ ច សម្មាទិដ្ឋិ ច ។

១ ម. ហាគិនិ ឥត្ថិ ។



ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះជាអ្នកមានពន្លឺ គឺញាណដ៏ច្រើន ១ មានព្យាយាមដ៏ច្រើន ១ មានសេចក្តីត្រេកអរដ៏ច្រើន ១ មានសន្តោសដ៏ច្រើន ១ មិនលះធុរៈពោលគឺកុសលធម៌ ១ ញុំាងចិត្តឲ្យឆ្លងទៅកាន់គុណខាងលើ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង មិនយូរប៉ុន្មាន តែងបានដល់នូវភាពជាធំទូលំទូលាយ ក្នុងធម៌ទាំងឡាយ ។

(៨១) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាង តែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកសម្លាប់សត្វ ១ កាន់យកទ្រព្យ ដែលគេមិនបានឲ្យ ១ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ពោលពាក្យកុហក ១ មានសេចក្តីប្រាថ្នាលាមក ១ មានទិដ្ឋិខុស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង តែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាង តែងទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកវៀរចាកការសម្លាប់ ១ វៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឲ្យ ១ វៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ វៀរចាកការនិយាយកុហក ១ មានសេចក្តីប្រាថ្នាតិច ១ មានទិដ្ឋិត្រូវ ១ ។

ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

(៩២) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ឆហិ ។ មុសាវាទី ហោតិ បិសុណាវាចោ ហោតិ ផរុសាវាចោ[១] ហោតិ សម្ផប្បលាបី ហោតិ លុទ្ធោ ច បគព្ភោ ច ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។

ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ ឆហិ ។ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្ប-លាបា បដិវិរតោ ហោតិ អលុទ្ធោ ច អប្បគព្ភោ ច ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

(៩៣) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ អភព្វោ ភិក្ខុ អគ្គំ ធម្មំ អរហត្តំ សច្ឆិកាតុំ ។ កតមេហិ ឆហិ ។

---

១ ឱ. ម. បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុមិច្ឆាចារី ហោតិ មុសាវាទី ហោតិ ។



ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង តែងទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

(៩២) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាង តែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ធម៌ ៦ យ៉ាង តើដូចម្ដេច ។ គឺបុគ្គលជាអ្នកនិយាយកុហក ១ និយាយញុះញង់ ១ និយាយអាក្រក់ ១ និយាយឥតប្រយោជន៍ ១ កាចអាក្រក់ ១ ឃ្លើសឃ្លង់ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង តែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាង តែងទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ធម៌ ៦ យ៉ាង តើដូចម្ដេច ។ គឺបុគ្គលជាអ្នកវៀរចាកការនិយាយកុហក ១ វៀរចាកការនិយាយញុះញង់ ១ វៀរចាកការនិយាយអាក្រក់ ១ វៀរចាកការនិយាយឥតប្រយោជន៍ ១ មិនកាចអាក្រក់ ១ មិនឃ្លើសឃ្លង់ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង តែងទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

(៩៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកមិនគួរ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ជាធម៌ដ៏ខ្ពង់ខ្ពស់ ។ ធម៌ ៦ យ៉ាង តើដូចម្ដេច ។

ឥធ ភិក្ខវេ ភិក្ខុ អស្សទ្ធោ ហោតិ អហិរិកោ ហោតិ អនោត្តប្បី ហោតិ កុសីតោ ហោតិ ទុប្បញ្ញោ ហោតិ កាយេ ច ជីវិតេ ច សាបេក្ខោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ អគ្គំ ធម្មំ អរហត្តំ សច្ឆិកាតុំ ។

ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ អគ្គំ ធម្មំ អរហត្តំ សច្ឆិកាតុំ ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ សទ្ធោ ហោតិ ហិរិមា ហោតិ ឱត្តប្បី ហោតិ អារទ្ធវិរិយោ ហោតិ បញ្ញវា ហោតិ កាយេ ច ជីវិតេ ច អនបេក្ខោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ អគ្គំ ធម្មំ អរហត្តំ សច្ឆិកាតុន្តិ ។

(៨៦) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតស្ស ភិក្ខុនោ យា រត្តិ វា ទិវសោ វា អាគច្ឆតិ ហានិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ មហិច្ឆោ ហោតិ វិឃាតវា



ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនមានសទ្ធា ១ មិនខ្មាសបាប ១ មិនខ្លាចក្រែងនឹងបាប ១ ខ្ជិលច្រអូស ១ អប្បឥតប្រាជ្ញា ១ មានសេចក្តីអាឡោះអាល័យ ក្នុងកាយនិងជីវិត ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកមិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ជាធម៌ដ៏ខ្ពង់ខ្ពស់ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ជាធម៌ដ៏ខ្ពង់ខ្ពស់ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ១ មានសេចក្តីខ្មាសបាប ១ មានសេចក្តីខ្លាចបាប ១ ប្រារព្ធព្យាយាម ១ មានប្រាជ្ញា ១ មិនអាឡោះអាល័យ ក្នុងកាយនិងជីវិត ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ជាធម៌ដ៏ខ្ពង់ខ្ពស់ ។

(៨៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង យប់ក្តី ថ្ងៃក្តី រមែងមានមក ឯសេចក្តីសាបសូន្យ ក្នុងកុសលធម៌ទាំងឡាយ ដែលកើតឡើងប្រាកដ សេចក្តីចំរើនមិនមានឡើយ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីប្រាថ្នាច្រើន មានសេចក្តីចង្អៀតចង្អល់

អសន្តុដ្ឋោ ឥតរីតរចីវរបិណ្ឌបាតសេនាសនគិលានប្ប-
ច្ចយភេសជ្ជបរិក្ខារេន អសទ្ធោ ហោតិ ទុស្សីលោ
ហោតិ កុសីតោ ហោតិ មុដ្ឋស្សតិ ហោតិ ទុប្បញ្ញោ
ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ
សមន្នាគតស្ស ភិក្ខុនោ យា រត្តិ វា ទិវសោ វា
អាគច្ឆតិ ហានិយេវ បាដិកង្ខា កុសលេសុ
ធម្មេសុ នោ វុឌ្ឍិ ។

ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតស្ស ភិក្ខុនោ យា
រត្តិ វា ទិវសោ វា អាគច្ឆតិ វុឌ្ឍិយេវ បាដិកង្ខា
កុសលេសុ ធម្មេសុ នោ បរិហានិ ។ កតមេហិ
ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ ន មហិច្ឆោ ហោតិ
ន វិឃាតវា សន្តុដ្ឋោ ឥតរីតរចីវរបិណ្ឌបាតសេនា-
សនគិលានប្បច្ចយភេសជ្ជបរិក្ខារេន សទ្ធោ ហោតិ
សីលវា ហោតិ អារទ្ធវិរិយោ ហោតិ សតិមា ហោតិ



មិនសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយ-
ភេសជ្ជបរិក្ខារ តាមមាន តាមបាន ១ មិនមានសទ្ធា ១ ទ្រុស្តសីល ១
ខ្ជិលច្រអូស ១ ភ្លេចស្មារតី ១ អប្បឥតប្រាជ្ញា ១ ។ ម្នាលភិក្ខុ
ទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង យប់ក្តី ថ្ងៃក្តី រមែង
មានមក ឯសេចក្តីសាបសូន្យ គឺកុសលធម៌ទាំងឡាយ តែងកើតឡើង
ប្រាកដ សេចក្តីចំរើនមិនមានឡើយ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង យប់ក្តី ថ្ងៃក្តី
រមែងមានមក ឯសេចក្តីចំរើនគឺកុសលធម៌ទាំងឡាយ តែងកើតឡើង
ប្រាកដ សេចក្តីសាបសូន្យមិនមានឡើយ ។ ធម៌ ៦ យ៉ាង តើដូចម្តេច ។
ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនមានសេចក្តី
ប្រាថ្នាច្រើន មិនមានសេចក្តីចង្អៀតចង្អល់ សន្តោសដោយចីវរ បិណ្ឌបាត
សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន ១
ជាអ្នកមានសទ្ធា ១ មានសីល ១ ប្រារព្ធសេចក្តីព្យាយាម ១ មានស្មារតី ១

បញ្ញវា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតស្ស ភិក្ខុនោ យា រត្តិ វា ទិវសោ វា អាគច្ឆតិ វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានីតិ ។

អរហន្តវគ្គោ តតិយោ ។

តស្សុទ្ទានំ

ទុក្ខំ អរហត្តំ ឧត្តរិ ច   សុខំ អធិគមេន ច
មហាត្តុយចរិយេ   អត្តទត្តញ្ញា រត្តិយាតិ ។



មានប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងនេះ ឯង យប់ក្តី ថ្ងៃក្តី វិលវិលមក ឯសេចក្តីចំរើនក្នុងកុសលធម៌ទាំងឡាយ តែងកើតឡើងប្រាកដ សេចក្តីសាបសូន្យមិនមានឡើយ ។

ចប់ អរហន្តវគ្គទី៣ ។

ឧទ្ទាននៃអរហន្តវគ្គនោះគឺ

និយាយពីការនៅជាទុក្ខ ១ មិនគួរធ្វើឲ្យជាក់ច្បាស់អរហត្ត ១ ឧត្តរិមនុស្សធម៌ ១ សុខនឹងសោមនស្សដ៏ច្រើន ១ ការត្រាស់ដឹង និងមិនត្រាស់ដឹង ១ ដល់នូវការជាធំ ១ ការទៅកើតក្នុងនរកតាមលោក មិនគួរធ្វើឲ្យជាក់ច្បាស់នូវឧត្តរិមនុស្សធម៌ នឹងគួរធ្វើឲ្យជាក់ច្បាស់នូវឧត្តរិមនុស្សធម៌ ១ យប់នឹងថ្ងៃ វិលវិលមក ១ ។

## សីតិវគ្គោ

(៨៥) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ អនុត្តរំ សីតិភាវំ សច្ឆិកាតុំ ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ យស្មិំ សមយេ ចិត្តំ និគ្គហេតព្វំ តស្មិំ សមយេ ចិត្តំ ន និគ្គណ្ហាតិ យស្មិំ សមយេ ចិត្តំ បគ្គហេតព្វំ តស្មិំ សមយេ ចិត្តំ ន បគ្គណ្ហាតិ យស្មិំ សមយេ ចិត្តំ សម្បហំសិតព្វំ តស្មិំ សមយេ ចិត្តំ ន សម្បហំសេតិ យស្មិំ សមយេ ចិត្តំ អជ្ឈុបេក្ខិតព្វំ តស្មិំ សមយេ ចិត្តំ ន អជ្ឈុបេក្ខតិ ហីនាធិមុត្តិកោ ច ហោតិ សក្កាយាភិរតោ ច ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ អនុត្តរំ សីតិភាវំ សច្ឆិកាតុំ ។

ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ អនុត្តរំ សីតិភាវំ សច្ឆិកាតុំ ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ យស្មិំ សមយេ ចិត្តំ និគ្គហេតព្វំ

## សីតិវគ្គ

[៨៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកមិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសេចក្ដីត្រជាក់ចិត្ត ដ៏ប្រសើរបាន ។ ធម៌ ៦ យ៉ាងតើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចិត្តដែលគួរសង្កត់សង្កិន ក្នុងវេលាណា មិនសង្កត់សង្កិនចិត្ត ក្នុងវេលានោះ ១ ចិត្តដែលគួរផ្គងឡើង ក្នុងវេលាណា មិនផ្គងចិត្តឡើង ក្នុងវេលានោះ ១ ចិត្តដែលគួរធ្វើឲ្យរីករាយ ក្នុងវេលាណា មិនធ្វើចិត្តឲ្យរីករាយ ក្នុងវេលានោះ ១ ចិត្តដែលគួរធ្វើឲ្យព្រងើយ ក្នុងវេលាណា មិនធ្វើចិត្តឲ្យព្រងើយ ក្នុងវេលានោះ ១ ជាអ្នកស្ទុះទៅរកធម៌ថោកទាប ១ ត្រេកអរនឹងកាយរបស់ខ្លួន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកមិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសេចក្ដីត្រជាក់ចិត្ត ដ៏ប្រសើរបាន ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវសេចក្ដីត្រជាក់ចិត្ត ដ៏ប្រសើរ ។ ធម៌ ៦ យ៉ាង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចិត្តដែលគួរសង្កត់សង្កិន ក្នុងវេលាណា

តស្មឹ សមយេ ចិត្តំ និគ្គណ្ហាតិ យស្មឹ សមយេ ចិត្តំ បគ្គហេតព្វំ តស្មឹ សមយេ ចិត្តំ បគ្គណ្ហាតិ យស្មឹ សមយេ ចិត្តំ សម្បហំសិតព្វំ តស្មឹ សមយេ ចិត្តំ សម្បហំសេតិ យស្មឹ សមយេ ចិត្តំ អជ្ឈុបេក្ខិតព្វំ តស្មឹ សមយេ ចិត្តំ អជ្ឈុបេក្ខតិ បណីតាធិមុត្តិកោ ច ហោតិ និព្វានាភិរតោ ច ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ អនុត្តរំ សីតិភាវំ សច្ឆិកាតុំ ។

(៨៦) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ អភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។ កតមេហិ ឆហិ ។ កម្មាវរណតាយ សមន្នាគតោ ហោតិ កិលេសាវរណតាយ សមន្នាគតោ ហោតិ វិបាកាវរណតាយ សមន្នាគតោ ហោតិ អស្សទ្ធោ ច ហោតិ អច្ឆន្ទិកោ ច ទុប្បញ្ញោ ច ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ



ក៏សង្កត់សង្កិនចិត្ត ក្នុងវេលានោះ ១ ចិត្តដែលគួរផ្គងឡើង ក្នុងវេលាណា ក៏ផ្គងចិត្តឡើង ក្នុងវេលានោះ ១ ចិត្តដែលគួរធ្វើឲ្យរីករាយ ក្នុងវេលាណា ក៏ធ្វើចិត្តឲ្យរីករាយ ក្នុងវេលានោះ ១ ចិត្តដែលគួរធ្វើឲ្យព្រងើយ ក្នុងវេលាណា ក៏ធ្វើចិត្តឲ្យព្រងើយក្នុងវេលានោះ ១ ជាអ្នកស្ទុះទៅក្នុងធម៌ដ៏ថ្លៃថ្លា ១ ត្រេកអរ ក្នុងព្រះនិព្វាន ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសេចក្តីត្រជាក់ចិត្ត ដ៏ប្រសើរ ។

(៨៦) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាង បើទុកជាកំពុងស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីចុះកាន់និយាម គឺ មគ្គដ៏ទៀង ក្នុងកុសលធម៌ទាំងឡាយ ។ ធម៌ ៦ យ៉ាង តើដូចម្តេច ។ គឺបុគ្គលជាអ្នកប្រកបដោយការកាត់គឺកម្ម(១) ១ ប្រកបដោយការកាត់ គឺកិលេស(២) ១ ប្រកបដោយការកាត់គឺវិបាក(៣) ១ មិនមានសទ្ធា ១ មិនពេញចិត្តនឹងធម៌ ១ ឥតប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង បើទុកជាកំពុងស្តាប់ព្រះសទ្ធម្ម

---

១ អនន្តរិយកម្មទាំង ៥ ។ ២ និយតមិច្ឆាទិដ្ឋិ ។ ៣ សត្វបដិសន្ធិដោយអកុសលវិបាក ឬ សត្វបដិសន្ធិជាអហេតុកកំណើត ទោះកើតជាមនុស្ស, ខ្វាក់, ថ្លង់, ឆ្កួតជាដើម ព្រោះអកុសលវិបាកទាំងឡាយ ។ អដ្ឋកថា ។

អភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។

ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ ភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។ កតមេហិ ឆហិ ។ ន កម្មាវរណតាយ សមន្នាគតោ ហោតិ ន កិលេសាវរណតាយ សមន្នាគតោ ហោតិ ន វិបាកាវរណតាយ សមន្នាគតោ ហោតិ សទ្ធោ ច ហោតិ ឆន្ទិកោ ច បញ្ញវា ច ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ ភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តន្តិ ។

(៨៧) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ អភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។ កតមេហិ ឆហិ ។ មាតា ជីវិតា វោរោបិតា ហោតិ បិតា ជីវិតា វោរោបិតោ ហោតិ អរហា ជីវិតា វោរោបិតោ ហោតិ តថាគតស្ស ទុដ្ឋេន ចិត្តេន លោហិតំ ឧប្បាទិតំ ហោតិ សង្ឃោ ភិន្នោ ហោតិ



ក៏មិនគួរដើម្បីចុះកាន់និយាមដ៏ទៀង ក្នុងកុសលធម៌ទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាង បើបានស្តាប់ព្រះសទ្ធម្ម ជាអ្នកគួរ ដើម្បីចុះកាន់និយាមដ៏ទៀង ក្នុងកុសលធម៌ទាំងឡាយ ។ ធម៌ ៦ យ៉ាង តើដូចម្តេច ។ គឺបុគ្គលជាអ្នកមិនប្រកបដោយការរាំងនូវកម្ម ១ មិនប្រកបដោយការរាំងនូវកិលេស ១ មិនប្រកបដោយការរាំងនូវវិបាក ១ មានសទ្ធា ១ ពេញចិត្តនឹងកុសលធម៌ ១ មានប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង កាលបើបានស្តាប់នូវព្រះសទ្ធម្ម ជាអ្នកគួរដើម្បីចុះកាន់និយាមដ៏ទៀង ក្នុងកុសលធម៌ទាំងឡាយ ។

(៨៧) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាង បើទុកជាកំពុងស្តាប់ព្រះសទ្ធម្ម ក៏ជាអ្នកមិនគួរដើម្បីចុះកាន់និយាមដ៏ទៀង ក្នុងកុសលធម៌ទាំងឡាយ ។ ធម៌ ៦ យ៉ាង តើដូចម្តេច ។ គឺបុគ្គលជាអ្នកផ្តាច់ផ្តិលជីវិតមាតា ១ ផ្តាច់ផ្តិលជីវិតបិតា ១ ផ្តាច់ផ្តិលជីវិតអរហន្ត ១ មានចិត្តប្រទូស្តចំពោះព្រះតថាគត ធ្វើលោហិតឲ្យពោរពងឡើង ១ បំបែកសង្ឃ ១

ទុប្បញ្ញោ ហោតិ ជឡោ ឯឡមូគោ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ អភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។

ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ ភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។ កតមេហិ ឆហិ ។ ន មាតា ជីវិតា វោរោបិតា ហោតិ ន បិតា ជីវិតា វោរោបិតោ ហោតិ ន អរហា ជីវិតា វោរោបិតោ ហោតិ ន តថាគតស្ស ទុដ្ឋេន ចិត្តេន លោហិតំ ឧប្បាទិតំ ហោតិ ន សង្ឃោ ភិន្នោ ហោតិ បញ្ញវា ហោតិ អជឡោ អនេឡមូគោ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ ភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តន្តិ ។

(៨៨) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ អភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។ កតមេហិ ឆហិ ។



អប់ប្រាជ្ញា ខ្លៅលេលា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង បើទុកជាកំពុងស្តាប់ព្រះសទ្ធម្ម ក៏ជាអ្នកមិនគួរដើម្បីចុះកាន់និយាមដ៏ប្រពៃ គឺកុសលធម៌ទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាង កាលបើបានស្តាប់ព្រះសទ្ធម្មហើយ ជាអ្នកគួរដើម្បីចុះកាន់និយាមដ៏ប្រពៃ គឺកុសលធម៌ទាំងឡាយ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលជាអ្នកមិនផ្តាច់ផ្តិលជីវិតមាតា ១ មិនផ្តាច់ផ្តិលជីវិតបិតា ១ មិនផ្តាច់ផ្តិលជីវិតអរហន្ត ១ មិនមានចិត្តប្រទូស្តចំពោះព្រះតថាគត ធ្វើលោហិតឲ្យពោរពងឡើង ១ មិនបំបែកសង្ឃ ១ មានប្រាជ្ញា មិនខ្លៅលេលា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង កាលបើបានស្តាប់ព្រះសទ្ធម្មហើយ ជាអ្នកគួរដើម្បីចុះកាន់និយាមដ៏ប្រពៃ គឺកុសលធម៌ទាំងឡាយ ។

(៨៨) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាង បើទុកជាកំពុងស្តាប់ព្រះសទ្ធម្ម ក៏ជាអ្នកមិនគួរ ដើម្បីចុះកាន់និយាមដ៏ប្រពៃ គឺកុសលធម៌ទាំងឡាយ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។

តថាគតប្បវេទិតេ ធម្មវិនយេ ទេសិយមានេ ន សុស្សូសតិ ន សោតំ ឱទហតិ ន អញ្ញាចិត្តំ ឧបដ្ឋបេតិ អនត្ថំ គណ្ហាតិ អត្ថំ រិញ្ចតិ អននុលោមិកាយ ខន្តិយា សមន្នាគតោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ អភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។

ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ ភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ ។ កតមេហិ ឆហិ ។ តថាគតប្បវេទិតេ ធម្មវិនយេ ទេសិយមានេ សុស្សូសតិ សោតំ ឱទហតិ អញ្ញាចិត្តំ ឧបដ្ឋបេតិ អត្ថំ គណ្ហាតិ អនត្ថំ រិញ្ចតិ អនុលោមិកាយ ខន្តិយា សមន្នាគតោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ សុណន្តោបិ សទ្ធម្មំ ភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តន្តិ ។



គឺកាលបើធម្មវិន័យ ដែលព្រះតថាគតប្រកាសសំដែង បុគ្គលមិនស្តាប់ដោយគោរព ១ មិនប្រុងត្រចៀកស្តាប់ ១ មិនតាំងចិត្តស្តាប់ឲ្យបានដឹង ១ កាន់យកតែអំពើឥតប្រយោជន៍ ១ លះបង់ប្រយោជន៍ចោល ១ ប្រកបដោយខន្តិ ដ៏មិនសមគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង បើទុកជាកំពុងស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីចុះកាន់និយាម ដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាង កាលបើបានស្តាប់ព្រះសទ្ធម្មជាអ្នកគួរ ដើម្បីចុះកាន់និយាមដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺកាលបើធម្មវិន័យ ដែលព្រះតថាគតទ្រង់ប្រកាសសំដែង បុគ្គលស្តាប់ដោយគោរព ១ ប្រុងត្រចៀកស្តាប់ ១ តាំងចិត្តប្រុងស្តាប់ឲ្យដឹង ១ កាន់យកនូវប្រយោជន៍ ១ លះបង់នូវតែអំពើមិនជាប្រយោជន៍ ១ ប្រកបដោយខន្តិដ៏សមគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង កាលបើបានស្តាប់ព្រះសទ្ធម្ម ជាអ្នកគួរ ដើម្បីចុះកាន់និយាមដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយ ។

(៨៩) ឆ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ ទិដ្ឋិសម្បទំ សច្ឆិកាតុំ ។ កតមេ ឆ ។ សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ អបាយគមនិយំ រាគំ អបាយគមនិយំ ទោសំ អបាយគមនិយំ មោហំ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ អប្បហាយ អភព្វោ ទិដ្ឋិសម្បទំ សច្ឆិកាតុំ ។

ឆ ភិក្ខវេ ធម្មេ បហាយ ភព្វោ ទិដ្ឋិសម្បទំ សច្ឆិកាតុំ ។ កតមេ ឆ ។ សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ អបាយគមនិយំ រាគំ អបាយគមនិយំ ទោសំ អបាយគមនិយំ មោហំ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ បហាយ ភព្វោ ទិដ្ឋិសម្បទំ សច្ឆិកាតុន្តិ ។

(៩០) ឆយិមេ ភិក្ខវេ ធម្មា ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស បហីនា ។ កតមេ ឆ ។ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ អបាយគមនិយោ រាគោ



(៨៩) ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានលះធម៌ ៦ យ៉ាង ជាអ្នកមិនគួរ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវទិដ្ឋិសម្បទា (សោតាបត្តិមគ្គ) បានឡើយ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ រាគៈជាហេតុនាំឲ្យទៅកាន់អបាយ ១ ទោសៈជាហេតុនាំឲ្យទៅកាន់អបាយ ១ មោហៈជាហេតុនាំឲ្យទៅកាន់អបាយ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានលះធម៌ទាំង ៦ យ៉ាងនេះទេ មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវទិដ្ឋិសម្បទាបានឡើយ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលលះធម៌ ៦ យ៉ាងបាន ទើបគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវទិដ្ឋិសម្បទា ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ រាគៈជាហេតុនាំឲ្យទៅកាន់អបាយ ១ ទោសៈជាហេតុនាំឲ្យទៅកាន់អបាយ ១ មោហៈជាហេតុនាំឲ្យទៅកាន់អបាយ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះធម៌ ៦ យ៉ាងនេះបានហើយ ទើបគួរធ្វើឲ្យជាក់ច្បាស់នូវទិដ្ឋិសម្បទាបាន ។

(៩០) ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ទើបលះធម៌ ៦ យ៉ាងនេះបាន ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ រាគៈជាហេតុនាំឲ្យទៅកាន់អបាយ ១

អបាយគមនិយោ ទោសោ អបាយគមនិយោ មោហោ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មា ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស បហីនាតិ ។

(៤១) ឆ ភិក្ខវេ ធម្មេ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ ឧប្បាទេតុំ ។ កតមេ ឆ ។ សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ អបាយគមនិយំ រាគំ អបាយគមនិយំ ទោសំ អបាយគមនិយំ មោហំ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ ឧប្បាទេតុន្តិ ។

(៤២) ឆយិមានិ ភិក្ខវេ អភព្វដ្ឋានានិ ។ កតមានិ ឆ ។ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ សត្ថរិ អគារវោ វិហរិតុំ អប្បតិស្សោ អភព្វោ ទិដ្ឋិ-សម្បន្នោ បុគ្គលោ ធម្មេ អគារវោ វិហរិតុំ អប្បតិស្សោ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ សង្ឃេ អគារវោ វិហរិតុំ អប្បតិស្សោ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ សិក្ខាយ អគារវោ វិហរិតុំ អប្បតិស្សោ អភព្វោ



ទោសៈជាហេតុនាំឲ្យទៅកាន់អបាយ ១ មោហៈជាហេតុនាំឲ្យទៅកាន់អបាយ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ទើបលះធម៌ទាំង ៦ យ៉ាងនេះបាន ។

(៤១) ម្នាលភិក្ខុទាំងឡាយ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរធ្វើធម៌ ៦ យ៉ាង ឲ្យកើតឡើងទេ ។ ធម៌ ៦ យ៉ាង តើដូចម្តេច ។ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ រាគៈជាហេតុនាំឲ្យទៅកាន់អបាយ ១ ទោសៈជាហេតុនាំឲ្យទៅកាន់អបាយ ១ មោហៈជាហេតុនាំឲ្យទៅកាន់អបាយ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរធ្វើធម៌ ៦ យ៉ាងនេះ ឲ្យកើតឡើងបានទេ ។

(៤២) ម្នាលភិក្ខុទាំងឡាយ អភព្វដ្ឋាន (ហេតុដែលមិនគួរ) នេះមាន ៦ យ៉ាង ។ ធម៌ ៦ យ៉ាង តើដូចម្តេច ។ គឺបុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរ មិនគោរព មិនកោតក្រែងចំពោះព្រះសាស្តា ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរ មិនគោរព មិនកោតក្រែងចំពោះព្រះធម៌ ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរ មិនគោរព មិនកោតក្រែងចំពោះសង្ឃ ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរ មិនគោរព មិនកោតក្រែងចំពោះសិក្ខា ១

ទិដ្ឋិសម្បន្នោ បុគ្គលោ អនាគមនីយវត្ថុំ បច្ចាគន្តុំ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ អដ្ឋមំ ភវំ និព្វត្តេតុំ ។ ឥមានិ ខោ ភិក្ខវេ ឆ អភព្វដ្ឋានានីតិ ។

(៩៣) ឆយិមានិ ភិក្ខវេ អភព្វដ្ឋានានិ ។ កតមានិ ឆ ។ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ កញ្ចិ សង្ខារំ និច្ចតោ ឧបគន្តុំ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ កញ្ចិ សង្ខារំ សុខតោ ឧបគន្តុំ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ កញ្ចិ ធម្មំ អត្តតោ ឧបគន្តុំ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ អនន្តរិយកម្មំ កាតុំ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ កោតុហលមង្គលេន សុទ្ធឹ បច្ចាគន្តុំ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសិតុំ ។ ឥមានិ ខោ ភិក្ខវេ ឆ អភព្វដ្ឋានានីតិ ។

(៩៤) ឆយិមានិ ភិក្ខវេ អភព្វដ្ឋានានិ ។ កតមានិ ឆ ។ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ មាតរំ ជីវិតា វោរោបេតុំ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ បិតរំ ជីវិតា វោរោបេតុំ អភព្វោ



បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរដើម្បីត្រឡប់ មកកាន់ហេតុដែលខ្លួនមិនគប្បីប្រែ(១)កាន់ ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិមិនគួរញុំាងភពជាគំរប់ ៨ ឲ្យកើត (២) ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលមិនគួរនេះ មាន ៦ យ៉ាងដូច្នេះ ។

(៩៣) ម្នាលភិក្ខុទាំងឡាយ ហេតុមិនគួរនេះមាន៦យ៉ាង ។ ៦ យ៉ាងតើដូចម្តេច ។ គឺបុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរប្រកាន់សង្ខារណាមួយ ជាទៀង ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរប្រកាន់សង្ខារណាមួយ ជាសុខ ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរប្រកាន់ធម៌ណាមួយ ជាខ្លួន ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរធ្វើនូវអនន្តរិយកម្ម ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរត្រឡប់ទៅកាន់សេចក្តីបរិសុទ្ធិ ដោយមង្គលភ្ញាក់ផ្អើល ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅព្រះពុទ្ធសាសនានេះ ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលមិនគួរនេះ មាន ៦ យ៉ាងនេះឯង ។

(៩៤) ម្នាលភិក្ខុទាំងឡាយ ហេតុដែលមិនគួរនេះ មាន ៦ យ៉ាង ។ ៦ យ៉ាង តើដូចម្តេច ។ គឺបុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរផ្តាច់ផ្តិលជីវិតមាតា ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរផ្តាច់ផ្តិលជីវិតបិតា ១

---

១ ហេតុដែលខ្លួនមិនគួរប្រកាន់នេះ គឺឈ្មោះនៃទិដ្ឋិ ៦២ ប្រការ ។

២ មិនចាប់បដិសន្ធិជាគំរប់ ៨ ក្នុងកាមាវចរភពទៀតទេ ។ អដ្ឋកថា ។

ទិដ្ឋិសម្បន្នោ បុគ្គលោ អរហន្តំ ជីវិតា វោរោបេតុំ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ តថាគតស្ស ទុដ្ឋេន ចិត្តេន លោហិតំ ឧប្បាទេតុំ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ សង្ឃំ ភិន្ទិតុំ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ អញ្ញំ សត្ថារំ ឧទ្ទិសិតុំ ។ ឥមានិ ខោ ភិក្ខវេ ឆ អភព្វដ្ឋានានីតិ ។

(៩៥) ឆយិមានិ ភិក្ខវេ អភព្វដ្ឋានានិ ។ កតមានិ ឆ ។ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ សយំកតំ សុខទុក្ខំ បច្ចាគន្តុំ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ បរកតំ សុខទុក្ខំ បច្ចាគន្តុំ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ សយំកតញ្ច បរកតញ្ច សុខទុក្ខំ បច្ចាគន្តុំ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ អសយំការំ(១) អធិច្ចសមុប្បន្នំ សុខទុក្ខំ បច្ចាគន្តុំ អភព្វោ ទិដ្ឋិសម្បន្នោ បុគ្គលោ អបរការំ អធិច្ចសមុប្បន្នំ សុខទុក្ខំ បច្ចាគន្តុំ អភព្វោ

១ ម. អសយំការំ (អបរំការំ) ។



បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរផ្តាច់ជីវិតព្រះអរហន្ត ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរញុំាងលោហិតរបស់ព្រះតថាគត ឲ្យពុះពងដោយចិត្តប្រទូស្ត ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរបំបែកសង្ឃ ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរប្រកាន់នូវសាស្តាដទៃ ១ ម្នាលភិក្ខុទាំងឡាយ ហេតុដែលមិនគួរនេះមាន ៦ យ៉ាងនេះឯង ។

(៩៥) ម្នាលភិក្ខុទាំងឡាយ ហេតុដែលមិនគួរ នេះមាន ៦ យ៉ាង ។ ៦ យ៉ាងតើដូចម្តេច ។ គឺបុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរត្រឡប់មកកាន់សុខនិងទុក្ខ ដែលខ្លួនធ្វើដោយខ្លួនឯង ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរត្រឡប់មកកាន់សុខនិងទុក្ខ ដែលបុគ្គលដទៃធ្វើ ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរត្រឡប់មកកាន់សុខនិងទុក្ខ ដែលខ្លួនឯងធ្វើផង ដែលបុគ្គលដទៃធ្វើផង ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរត្រឡប់មកកាន់សុខនិងទុក្ខដែលកើតឡើង ដោយមិនអាស្រ័យហេតុ មិនជាអំពើ ដែលខ្លួនឯងធ្វើ ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរត្រឡប់មកកាន់សុខនិងទុក្ខ ដែលកើតឡើង ដោយមិនអាស្រ័យហេតុ មិនមែនជាអំពើដែលបុគ្គលដទៃធ្វើ ១

ទិដ្ឋិសម្បន្នោ បុគ្គលោ អសយំការំ អបរការំ អធិច្ចសមុប្បន្នំ សុខទុក្ខំ បច្ចាគន្តុំ ។ តំ កិស្ស ហេតុ ។ តថាហិស្ស ភិក្ខវេ ទិដ្ឋិសម្បន្នស្ស បុគ្គលស្ស ហេតុ ច សុទិដ្ឋោ ហេតុសមុប្បន្នា ច ធម្មា ។ ឥមានិ ខោ ភិក្ខវេ ឆ អភព្វដ្ឋានានីតិ ។

សីតិវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ

សីតិ ភព្វោ អាវរណា   សុស្សូសា បដ្ឋេតិ
បហាតព្វំ បហីនា ទេ   ឧប្បាទេតព្វំ សត្ថរិ
តាញុ សង្ខារំ មាតរិ   សយំការេន បញ្ចតិ ។



បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរត្រឡប់មកកាន់សុខនិងទុក្ខ ដែលកើតឡើង ដោយមិនអាស្រ័យហេតុ មិនមែនជាអំពើ ដែលខ្លួនឯងធ្វើផង មិនមែនជាអំពើ ដែលបុគ្គលដទៃធ្វើផង ១ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិនោះ ឃើញច្បាស់លាស់នូវហេតុផង នូវធម៌កើតអំពីហេតុផង ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលមិនគួរនេះមាន ៦ យ៉ាងប៉ុណ្ណេះឯង ។

ចប់ សីតិវគ្គទី ៤ ។

## ឧទ្ទាននៃសីតិវគ្គនោះគឺ

និយាយអំពីភិក្ខុ មិនគួរធ្វើឲ្យជាក់ច្បាស់នូវសេចក្តីត្រជាក់ ១
គួរធ្វើឲ្យជាក់ច្បាស់នូវសេចក្តីត្រជាក់ ១ គ្រឿងរាំង ១ ស្តាប់
ដោយគោរព ១ បុគ្គលត្រូវលះបង់ធម៌ ៦ យ៉ាង ១ បុគ្គលលះ
បង់ធម៌ ៦ យ៉ាងហើយ ១ មិនគួរធ្វើធម៌ ៦ យ៉ាងឲ្យ
កើតឡើង ១ គោរពក្នុងព្រះសាស្តា ១ មិនគួរប្រកាន់
សង្ខារណាមួយ ១ មិនគួរ ផ្តាច់ជីវិតមាតា
ជាដើម ១ មិនគួរប្រកាន់សុខទុក្ខ ដោយការធ្វើខ្លួនឯង ១ ។

(៩៦) ឆន្នំ ភិក្ខវេ បាតុភាវោ ទុល្លភោ លោកស្មឹ ។ កតមេសំ ឆន្នំ ។ តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស បាតុភាវោ ទុល្លភោ លោកស្មឹ តថាគតប្បវេទិតស្ស ធម្មវិនយស្ស ទេសេតា បុគ្គលោ ទុល្លភោ លោកស្មឹ អរិយាយតនេ បច្ចាជាតោ ទុល្លភោ លោកស្មឹ ឥន្ទ្រិយានំ អវេកល្លតា ទុល្លភា លោកស្មឹ អជឡតា អនេឡមូគតា ទុល្លភា លោកស្មឹ កុសលធម្មច្ឆន្ទោ ទុល្លភោ លោកស្មឹ ។ ឥមេសំ ខោ ភិក្ខវេ ឆន្នំ បាតុភាវោ ទុល្លភោ លោកស្មិន្តិ ។

(៩៧) ឆយិមេ ភិក្ខវេ អានិសំសា សោតាបត្តិផលសច្ឆិកិរិយាយ ។ កតមេ ឆ ។ សទ្ធម្មនិយតោ ហោតិ អបរិហានធម្មោ ហោតិ បរិយន្តកតស្ស ទុក្ខំ ន ហោតិ



(៩៦) ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសភាវៈ ៦ យ៉ាងគឺ បុគ្គលបានដោយក្រ ក្នុងលោក។ ៦ យ៉ាងតើអ្វីខ្លះ ។ គឺការកើតឡើងនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ បុគ្គលបានដោយក្រ ក្នុងលោក ១ បុគ្គលជាអ្នកសំដែងធម្មវិន័យ ដែលព្រះតថាគតបានប្រកាសហើយ បុគ្គលបានដោយក្រ ក្នុងលោក ១ សត្វត្រឡប់មកកើត ក្នុងប្រទេសជាទីនៅនៃអរិយៈជន បុគ្គលបានដោយក្រ ក្នុងលោក ១ ការមិនខ្វះខាតនៃឥន្ទ្រិយទាំងឡាយ បុគ្គលបានដោយក្រ ក្នុងលោក ១ ភាពនៃបុគ្គលមិនលេលាមិនគ បុគ្គលបានដោយក្រក្នុងលោក ១ សេចក្ដីពេញចិត្ត ក្នុងកុសលធម៌ បុគ្គលបានដោយក្រ ក្នុងលោក ១ ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសភាវៈ ៦ យ៉ាងនេះ បុគ្គលបានដោយក្រ ក្នុងលោក ។

(៩៧) ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃកិរិយាធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលនេះ មាន ៦ យ៉ាង ។ ៦ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលជាអ្នកទៀងត្រង់ ក្នុងព្រះសទ្ធម្ម ១ មានធម៌មិនសាបសូន្យ ១ សេចក្ដីទុក្ខ មិនមានដល់បុគ្គល អ្នកធ្វើនូវព្រះនិព្វាន ជាទីបំផុតទុក្ខ ១

អសាធារណេន ញាណេន សមន្នាគតោ ហោតិ ហេតុ ចស្ស សុទិដ្ឋោ ហេតុសមុប្បន្នា ច ធម្មា ។ ឥមេ ខោ ភិក្ខវេ ឆ អានិសំសា សោតាបត្តិផលសច្ឆិកិរិយាយាតិ ។

(៩៨) សោ វត ភិក្ខវេ ភិក្ខុ កញ្ចិ សង្ខារំ និច្ចតោ សមនុបស្សន្តោ អនុលោមិកាយ ខន្តិយា សមន្នាគតោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ អនុលោមិកាយ ខន្តិយា អសមន្នាគតោ សម្មត្តនិយាមំ ឱក្កមិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សម្មត្តនិយាមំ អនោក្កមមានោ សោតាបត្តិផលំ វា សកទាគាមិផលំ វា អនាគាមិផលំ វា អរហត្តំ វា សច្ឆិករិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោ វត ភិក្ខវេ ភិក្ខុ សព្វសង្ខារេ អនិច្ចតោ សមនុបស្សន្តោ អនុលោមិកាយ ខន្តិយា សមន្នាគតោ ភវិស្សតីតិ ឋានមេតំ វិជ្ជតិ ។ អនុលោមិកាយ ខន្តិយា សមន្នាគតោ សម្មត្តនិយាមំ ឱក្កមិស្សតីតិ ឋានមេតំ វិជ្ជតិ ។



ប្រកបដោយញាណមិនទូទៅ (ដល់បុថុជ្ជនទាំងឡាយ) ១ ហេតុដែលបុគ្គលនោះឃើញដោយប្រពៃ ១ ធម៌ទាំងឡាយកើតឡើងអំពីហេតុ ១ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃកិរិយាធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល មាន ៦ យ៉ាងនេះឯង ។

(៩៨) ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះពិចារណានូវសង្ខារណាមួយ ថាទៀង នឹងប្រកបដោយអនុលោមិកខន្តិបាន ហេតុនេះមិនដែលមានឡើយ ។ ភិក្ខុមិនប្រកបដោយអនុលោមិកខន្តិ នឹងឈានចុះកាន់និយាមដ៏ប្រពៃបាន ហេតុនេះមិនដែលមានឡើយ ។ កាលភិក្ខុមិនឈានចុះកាន់និយាមដ៏ប្រពៃ នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឬសកទាគាមិផល អនាគាមិផល ឬអរហត្តបាន ហេតុនេះមិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ ពិចារណានូវសង្ខារទាំងពួង ថាមិនទៀង នឹងប្រកបដោយអនុលោមិកខន្តិបាន ហេតុនេះរមែងមាន ។ ភិក្ខុប្រកបដោយអនុលោមិកខន្តិហើយ នឹងឈានចុះកាន់និយាមដ៏ប្រពៃបាន ហេតុនេះរមែងមាន ។

សម្មត្តនិយាមំ ឱក្កមមានោ សោតាបត្តិផលំ វា សកទាគាមិផលំ វា អនាគាមិផលំ វា អរហត្តំ វា សច្ឆិករិស្សតីតិ ឋានមេតំ វិជ្ជតីតិ ។

(៩៩) សោ វត ភិក្ខវេ ភិក្ខុ កញ្ចិ សង្ខារំ សុខតោ សមនុបស្សន្តោ ។បេ។ សព្វសង្ខារេ ទុក្ខតោ សមនុបស្សន្តោ ។បេ។

(១០០) សោ វត ភិក្ខវេ ភិក្ខុ កញ្ចិ ធម្មំ អត្តតោ សមនុបស្សន្តោ ។បេ។ សព្វធម្មេ អនត្តតោ សមនុបស្សន្តោ ។បេ។

(១០១) សោ វត ភិក្ខវេ ភិក្ខុ និព្វានំ ទុក្ខតោ សមនុបស្សន្តោ អនុលោមិកាយ ខន្តិយា សមន្នាគតោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ អនុលោមិកាយ ខន្តិយា អសមន្នាគតោ សម្មត្តនិយាមំ ឱក្កមិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សម្មត្តនិយាមំ អនោក្កមមានោ សោតាបត្តិផលំ វា សកទាគាមិផលំ វា អនាគាមិផលំ វា អរហត្តំ(១) វា សច្ឆិករិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។

១ ម. អរហត្តផលំ ។



ភិក្ខុឈានចុះកាន់និយាមដ៏ប្រពៃហើយ នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឬសកទាគាមិផល អនាគាមិផល ឬក៏អរហត្តផលបាន ហេតុនេះ រមែងមាន ។

(៩៩) ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ ពិចារណានូវសង្ខារណាមួយថា សុខ ។បេ។ កាលពិចារណានូវសង្ខារទាំងពួងថា ទុក្ខ ។បេ។

(១០០) ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ ពិចារណានូវធម៌ណាមួយថា ជាខ្លួន ។បេ។ កាលពិចារណានូវធម៌ទាំងពួង ថា មិនមែនខ្លួន ។បេ។

(១០១) ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ ពិចារណានូវព្រះនិព្វានថា ជាទុក្ខ នឹងប្រកបដោយអនុលោមិកខន្តិបាន ហេតុនេះ មិនដែលមានឡើយ ។ ភិក្ខុមិនប្រកបដោយអនុលោមិកខន្តិហើយ នឹងឈានចុះកាន់និយាមដ៏ប្រពៃបាន ហេតុនេះ មិនដែលមានឡើយ ។ ភិក្ខុមិនឈានចុះកាន់និយាមដ៏ប្រពៃហើយ នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឬសកទាគាមិផល អនាគាមិផល ឬក៏អរហត្តផលបាន ហេតុនេះ មិនដែលមានឡើយ ។

សោ វត ភិក្ខវេ ភិក្ខុ និព្វានំ សុខតោ សមនុបស្សន្តោ អនុលោមិកាយ ខន្តិយា សមន្នាគតោ ភវិស្សតីតិ ឋានមេតំ វិជ្ជតិ ។ អនុលោមិកាយ ខន្តិយា សមន្នាគតោ សម្មត្តនិយាមំ ឱក្កមិស្សតីតិ ឋានមេតំ វិជ្ជតិ ។ សម្មត្តនិយាមំ ឱក្កមមានោ សោតាបត្តិផលំ វា សកទាគាមិផលំ វា អនាគាមិផលំ វា អរហត្តំ វា សច្ឆិករិស្សតីតិ ឋានមេតំ វិជ្ជតីតិ ។

(១០៦) ឆ ភិក្ខវេ អានិសំសេ សម្បស្សមានេន អលមេវ ភិក្ខុនា សព្វសង្ខារេសុ អនោធឹ ករិត្វា អនិច្ចសញ្ញំ ឧបដ្ឋាបេតុំ ។ កតមេ ឆ ។ សព្វសង្ខារា ច(១) អនវដ្ឋិតតោ ខាយិស្សន្តិ សព្វលោកេ ច មេ មនោ នាភិរមិស្សតិ សព្វលោកា ច មេ មនោ វុដ្ឋហិស្សតិ និព្វានបោណញ្ច មេ មានសំ ភវិស្សតិ សញ្ញោជនា ច មេ បហានំ គច្ឆន្តិ បរមេន ច សាមញ្ញេន សមន្នាគតោ ភវិស្សាមីតិ ។ ឥមេ ខោ ភិក្ខវេ ឆ អានិសំសេ សម្បស្សមានេន អលមេវ ភិក្ខុនា សព្វសង្ខារេសុ អនោធឹ ករិត្វា អនិច្ចសញ្ញំ ឧបដ្ឋាបេតុន្តិ ។

---
១ ឱ. ម. ឯត្តុប បេតិ បទំ ។



ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ ពិចារណាឃើញព្រះនិព្វានថា ជាសុខ នឹងប្រកបដោយអនុលោមិកខន្តិបាន ហេតុនេះ រមែងមាន ។ ភិក្ខុប្រកបដោយអនុលោមិកខន្តិហើយ នឹងឈានចុះកាន់និយាមដ៏ប្រពៃបាន ហេតុនេះ រមែងមាន ។ ភិក្ខុឈានចុះកាន់និយាមដ៏ប្រពៃហើយ នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឬសកទាគាមិផល អនាគាមិផល ឬអរហត្តបាន ហេតុនេះ រមែងមាន ។

(១០៦) ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឃើញនូវអានិសង្ស ទាំង ៦ យ៉ាង គួរធ្វើមិនឲ្យមានខណ្ឌដែន ក្នុងសង្ខារទាំងពួង ហើយដំកល់នូវសេចក្តីសំគាល់ថា មិនទៀង ។ ៦ យ៉ាង តើដូចម្តេច ។ គឺសង្ខារទាំងឡាយទាំងពួង នឹងប្រាកដថា ជារបស់មិនតាំងនៅខ្ជាប់ខ្ជួនបាន ១ ចិត្តអាត្មាអញនឹងមិនត្រេកអរ ក្នុងលោកទាំងពួង ១ ចិត្តអាត្មាអញ នឹងចេញចាកលោកទាំងពួង ១ ចិត្តឈមទៅរកព្រះនិព្វាន នឹងមានដល់អាត្មាអញ ១ សំយោជនៈទាំងឡាយ របស់អាត្មាអញ នឹងដល់នូវការលះបង់ ១ អាត្មាអញ នឹងប្រកបដោយភាពនៃខ្លួន ជាសមណៈដ៏ឧត្តម ១ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុ ឃើញនូវអានិសង្ស ៦ យ៉ាងនេះឯង គួរធ្វើមិនឲ្យមានខណ្ឌដែន ក្នុងសង្ខារទាំងពួង ហើយដំកល់នូវសេចក្តីសំគាល់ថា មិនទៀង ។

(១០៣) ឆ ភិក្ខវេ អានិសំសេ សម្បស្សមានេន អលមេវ ភិក្ខុនា សព្វសង្ខារេសុ អនោធឹ ករិត្វា ទុក្ខសញ្ញំ ឧបដ្ឋបេតុំ ។ កតមេ ឆ ។ សព្វសង្ខារេសុ ច មេ និព្វិទសញ្ញា បច្ចុបដ្ឋិតា ភវិស្សតិ សេយ្យថាបិ ឧក្ខិត្តាសិកេ វធកេ សព្វលោកា ច មេ មនោ វុដ្ឋហិស្សតិ និព្វានេ ច សន្តិទស្សាវី(១) ភវិស្សាមិ អនុសយា ច មេ សមុគ្ឃាតំ គច្ឆិស្សន្តិ(២) កិច្ចការី ច ភវិស្សាមិ សត្ថា ច បរិចិណ្ណោ ភវិស្សតិ មេត្តាយនាតិ ។ ឥមេ ខោ ភិក្ខវេ ឆ អានិសំសេ សម្បស្សមានេន អលមេវ ភិក្ខុនា សព្វសង្ខារេសុ អនោធឹ ករិត្វា ទុក្ខសញ្ញំ ឧបដ្ឋបេតុន្តិ ។

(១០៤) ឆ ភិក្ខវេ អានិសំសេ សម្បស្សមានេន អលមេវ ភិក្ខុនា សព្វធម្មេសុ អនោធឹ ករិត្វា អនត្តសញ្ញំ ឧបដ្ឋបេតុំ ។ កតមេ ឆ ។ សព្វលោកេ ច អតម្មយោ ភវិស្សាមិ អហំការា ច មេ ឧបរុជ្ឈិស្សន្តិ

១ ម. សន្តទស្សាវី ។ ២ ម. គច្ឆន្តិ ។



(១០៣) ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឃើញនូវអានិសង្សទាំង ៦ យ៉ាង គួរធ្វើមិនឲ្យមានសេចក្តីដែន ក្នុងសង្ខារទាំងពួង ហើយដំកល់នូវសេចក្តីសំគាល់ថា ជាទុក្ខ ។ ៦ យ៉ាងតើអ្វីខ្លះ ។ គឺសេចក្តីសំគាល់ក្នុងការរលត់ចាកសង្ខារទាំងពួង នឹងតាំងឡើងប្រាកដដល់អាត្មាអញ ដូចឃាតកដែលលើកដាវឡើង ១ ចិត្តអាត្មាអញ នឹងចេញចាកលោកទាំងពួង ១ អាត្មាអញជាអ្នកឃើញនូវសេចក្តីស្ងប់រម្ងាប់ ក្នុងព្រះនិព្វាន ១ អនុស័យធម៌ទាំងឡាយ របស់អាត្មាអញ នឹងដល់នូវការគាស់រំលើង ១ អាត្មាអញនឹងជាអ្នកធ្វើនូវកិច្ចការ ១ ព្រះសាស្តា អាត្មាអញនឹងជាអ្នកបំរើ ប្រកបដោយមេត្តា ១ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឃើញនូវអានិសង្សទាំង ៦ យ៉ាងនេះឯង គួរធ្វើមិនឲ្យមានសេចក្តីដែន ក្នុងសង្ខារទាំងពួង ហើយដំកល់នូវសេចក្តីសំគាល់ថា ជាទុក្ខ ។

(១០៤) ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឃើញនូវអានិសង្សទាំង៦យ៉ាង គួរធ្វើមិនឲ្យមានសេចក្តីដែន ក្នុងធម៌ទាំងពួង ហើយដំកល់នូវសេចក្តីសំគាល់ថា អនត្ត ។ ៦ យ៉ាងតើអ្វីខ្លះ ។ គឺអាត្មាអញនឹងមិនមានតណ្ហាៈ (តណ្ហាទិដ្ឋិ) ក្នុងលោកទាំងពួង ១ ពួកអហំការទិដ្ឋិរបស់អាត្មាអញ នឹងរលត់ទៅ ១

មមង្ការា ច មេ ឧបរុជ្ឈិស្សន្តិ អសាធារណេន ច ញាណេន សមន្នាគតោ ភវិស្សាមិ ហេតុ ច មេ សុទិដ្ឋោ ភវិស្សតិ ហេតុសមុប្បន្នា ច ធម្មា ។ ឥមេ ខោ ភិក្ខវេ ឆ អានិសំសេ សម្បស្សមានេន អលមេវ ភិក្ខុនា សព្វធម្មេសុ អនោធឹ ករិត្វា អនត្តសញ្ញំ ឧបដ្ឋាបេតុន្តិ ។

(១០៥) តយោមេ ភិក្ខវេ ភវា បហាតព្វា តីសុ សិក្ខាសុ សិក្ខិតព្វំ ។ កតមេ តយោ ភវា បហាតព្វា ។ កាមភវោ រូបភវោ អរូបភវោ ។ ឥមេ តយោ ភវា បហាតព្វា ។ កតមាសុ តីសុ សិក្ខាសុ សិក្ខិតព្វំ ។ អធិសីលសិក្ខាយ អធិចិត្តសិក្ខាយ អធិបញ្ញាសិក្ខាយ ។ ឥមាសុ តីសុ សិក្ខាសុ សិក្ខិតព្វំ ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ ឥមេ តយោ ភវា បហីនា ហោន្តិ ឥមាសុ ច តីសុ សិក្ខាសុ សិក្ខិតសិក្ខោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អច្ឆេជ្ជិ តណ្ហំ វិវត្តយិ សញ្ញោជនំ សម្មា មានាភិសមយា អន្តមកាសិ ទុក្ខស្សាតិ ។



ពួកមមង្ការតណ្ហារបស់អាត្មាអញ នឹងរលត់ទៅ១ អាត្មាអញ ជាអ្នកប្រកបដោយញាណមិនទូទៅ១ ហេតុ អាត្មាអញនឹងឃើញដោយប្រពៃ១ ធម៌ទាំងឡាយ កើតឡើងអំពីហេតុ១ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឃើញអានិសង្សទាំង ៦ យ៉ាងនេះឯង គួរធ្វើមិនឲ្យមានខណ្ឌដែន ក្នុងធម៌ទាំងពួង ហើយដំកល់នូវសេចក្តីសំគាល់ថា អនត្តា ។

(១០៥) ម្នាលភិក្ខុទាំងឡាយ ភព ៣ នេះ បុគ្គលគួរលះ ហើយគួរសិក្សាក្នុងសិក្ខាទាំង ៣ ។ ភព ៣ ដែលបុគ្គលគួរលះ តើដូចម្តេច ។ គឺកាមភព១ រូបភព១ អរូបភព១ ។ ភព ៣ យ៉ាងនេះ បុគ្គលគួរលះបង់ចេញ ។ សិក្ខា ៣ ដែលបុគ្គលគួរសិក្សា តើដូចម្តេច ។ គឺអធិសីលសិក្ខា១ អធិចិត្តសិក្ខា១ អធិបញ្ញាសិក្ខា១ ។ បុគ្គលគួរសិក្សា ក្នុងសិក្ខាទាំង ៣ នេះ ។ ម្នាលភិក្ខុទាំងឡាយ ភពទាំង ៣ នេះ ជាភពដែលភិក្ខុលះបង់ហើយផង ភិក្ខុជាអ្នកមានសិក្ខាសិក្សាហើយ ក្នុងសិក្ខាទាំងឡាយ ៣ នេះផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុអ្នកបានកាត់នូវតណ្ហា ស្រាយនូវសញ្ញោជនៈ ធ្វើនូវទីបំផុតនៃទុក្ខ ព្រោះត្រាស់ដឹងនូវមានះដោយប្រពៃ ។

(១០៦) តិស្សោ ឥមា ភិក្ខវេ តណ្ហា បហាតព្វា តយោ ច មានា ។ កតមា តិស្សោ តណ្ហា បហាតព្វា ។ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។ ឥមា តិស្សោ តណ្ហា បហាតព្វា ។ កតមេ តយោ មានា(១) ។ មានោ ឱមានោ អតិមានោ ។ ឥមេ តយោ មានា ។ យតោ ខោ ភិក្ខវេ ភិក្ខុនោ ឥមា តិស្សោ តណ្ហា បហីនា ហោន្តិ ឥមេ ច តយោ មានា ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អច្ឆេច្ឆិ តណ្ហំ វិវត្តយិ សញ្ញោជនំ សម្មា មានាភិសមយា អន្តមកាសិ ទុក្ខស្សាតិ ។

អានិសំសវគ្គោ បឋមោ ។

## ឧទ្ទានំ

បាតុភាវោ អានិសំសោ អនិច្ចំ ទុក្ខមនត្តតោ
និព្វានំ តយោ អនោធិសំ
វុត្តា ភវា តណ្ហាយ តេ ទសាតិ ។

ទុតិយបណ្ណាសកោ និដ្ឋិតោ ។

១ ម. ម. មានា បហាតព្វា ។



(១០៦) ម្នាលភិក្ខុទាំងឡាយ តណ្ហា ៣ នេះបុគ្គលគួរលះ ទាំងមានះ ៣ បុគ្គលក៏គួរលះដែរ ។ តណ្ហា ៣ ដែលបុគ្គលគួរលះ តើដូចម្តេច ។ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ តណ្ហាទាំង ៣ នេះ បុគ្គលគួរលះ ។ មានះ ៣ តើដូចម្តេច ។ គឺមានះ ១ ឱមានះ ១ អតិមានះ ១ ។ នេះមានះ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ កាលណាតណ្ហាទាំង ៣ នេះ ភិក្ខុលះហើយ មានះទាំង ៣ នេះឈ្មោះថា ភិក្ខុលះហើយដែរ ។ ម្នាលភិក្ខុទាំងឡាយ នេះទើបហៅថា ភិក្ខុអ្នកកាត់បង់នូវតណ្ហា ផ្ដាច់ រលាស់ចោលនូវសញ្ញោជនៈ ធ្វើនូវទីបំផុតនៃទុក្ខ ព្រោះត្រាស់ដឹងនូវមានះដោយប្រពៃ ។

ចប់ អានិសំសវគ្គ ទី៥ ។

## ឧទ្ទាននៃអានិសំសវគ្គនោះគឺ

និយាយអំពីការកើតប្រាកដ ១ អានិសង្ស ១
អនិច្ចសញ្ញា ១ ទុក្ខសញ្ញា ១ អនត្តសញ្ញា ១ ព្រះ
និព្វាន ១ មានះ ៣ មិនធ្វើនូវការកំណត់ ១ ភព
ទាំងឡាយ ១ តណ្ហា ១ ទាំងអស់ត្រូវជា ១០ ។

ចប់ ទុតិយបណ្ណាសក ។

## បណ្ណាសកាសង្គហិតោ វគ្គោ

### តិកវគ្គោ

(១០៧) តយោ មេ ភិក្ខវេ ធម្មា ។ កតមេ តយោ ។ រាគោ ទោសោ មោហោ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មា ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ តយោ ធម្មា ភាវេតព្វា ។ កតមេ តយោ ។ រាគស្ស បហានាយ អសុភា ភាវេតព្វា ទោសស្ស បហានាយ មេត្តា ភាវេតព្វា មោហស្ស បហានាយ បញ្ញា ភាវេតព្វា ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ ឥមេ តយោ ធម្មា ភាវេតព្វាតិ ។

(១០៨) តយោមេ ភិក្ខវេ ធម្មា ។ កតមេ តយោ ។ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មា ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ តយោ ធម្មា ភាវេតព្វា ។ កតមេ តយោ ។ កាយទុច្ចរិតស្ស បហានាយ កាយសុចរិតំ ភាវេតព្វំ វចីទុច្ចរិតស្ស បហានាយ វចីសុចរិតំ ភាវេតព្វំ មនោទុច្ចរិតស្ស បហានាយ មនោសុចរិតំ ភាវេតព្វំ ។

## បណ្ណាសកាសង្គហិតវគ្គ

### តិកវគ្គ

(១០៧) ម្នាលភិក្ខុទាំងឡាយធម៌ទាំងឡាយនេះ មាន ៣ យ៉ាង ។ ៣ យ៉ាងតើដូចម្តេច ។ គឺរាគៈ ១ ទោសៈ ១ មោហៈ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលត្រូវចំរើនធម៌ ៣ ប្រការ ដើម្បីលះធម៌ ៣ ប្រការនេះចេញ ។ ធម៌ ៣ ប្រការតើដូចម្តេច ។ គឺបុគ្គលត្រូវចំរើនអសុភ ដើម្បីលះរាគៈ ១ ត្រូវចំរើនមេត្តា ដើម្បីលះទោសៈ ១ ត្រូវចំរើនបញ្ញា ដើម្បីលះមោហៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលត្រូវចំរើនធម៌ទាំង ៣ នេះ ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

(១០៨) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មាន ៣ យ៉ាង ។ ៣ យ៉ាងតើដូចម្តេច ។ គឺកាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៣ យ៉ាង បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាង នេះចេញ ។ ៣ យ៉ាងតើដូចម្តេច ។ គឺបុគ្គលត្រូវចំរើនកាយសុចរិត ដើម្បីលះកាយទុច្ចរិតចេញ ១ ត្រូវចំរើនវចីសុចរិត ដើម្បីលះវចីទុច្ចរិតចេញ ១ ត្រូវចំរើនមនោសុចរិត ដើម្បីលះមនោទុច្ចរិតចេញ ១ ។

ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ ឥមេ តយោ ធម្មា ភាវេតព្វាតិ ។

(១០៩) តយោមេ ភិក្ខវេ ធម្មា ។ កតមេ តយោ ។ កាមវិតក្កោ ព្យាបាទវិតក្កោ វិហឹសាវិតក្កោ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មា ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ ឥមេ តយោ ធម្មា ភាវេតព្វា ។ កតមេ តយោ ។ កាមវិតក្កស្ស បហានាយ នេក្ខម្មវិតក្កោ ភាវេតព្វោ ព្យាបាទវិតក្កស្ស បហានាយ អព្យាបាទវិតក្កោ ភាវេតព្វោ វិហឹសាវិតក្កស្ស បហានាយ អវិហឹសាវិតក្កោ ភាវេតព្វោ ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ ឥមេ តយោ ធម្មា ភាវេតព្វាតិ ។

(១១០) តយោមេ ភិក្ខវេ ធម្មា ។ កតមេ តយោ ។ កាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មា ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ តយោ ធម្មា ភាវេតព្វា ។ កតមេ តយោ ។



ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

(១០៩) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មាន ៣ យ៉ាង ។ ៣ យ៉ាងតើអ្វីខ្លះ ។ គឺកាមវិតក្កៈ ១ ព្យាបាទវិតក្កៈ ១ វិហឹសាវិតក្កៈ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។ ៣ យ៉ាងតើអ្វីខ្លះ ។ គឺបុគ្គលត្រូវចំរើននេក្ខម្មវិតក្កៈ ដើម្បីលះកាមវិតក្កៈចេញ ១ ត្រូវចំរើនអព្យាបាទវិតក្កៈ ដើម្បីលះព្យាបាទវិតក្កៈចេញ ១ ត្រូវចំរើនអវិហឹសាវិតក្កៈ ដើម្បីលះវិហឹសាវិតក្កៈចេញ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

(១១០) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មាន ៣ យ៉ាង ។ ៣ យ៉ាងតើអ្វីខ្លះ ។ គឺកាមសញ្ញា ១ ព្យាបាទសញ្ញា ១ វិហឹសាសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។ ៣ យ៉ាងតើអ្វីខ្លះ ។

កាមសញ្ញាយ បហានាយ នេក្ខម្មសញ្ញា ភាវេតព្វា ព្យាបាទសញ្ញាយ បហានាយ អព្យាបាទសញ្ញា ភាវេតព្វា វិហឹសាសញ្ញាយ បហានាយ អវិហឹសាសញ្ញា ភាវេតព្វា ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ ឥមេ តយោ ធម្មា ភាវេតព្វាតិ ។

(១១១) តយោមេ ភិក្ខវេ ធម្មា ។ កតមេ តយោ ។ កាមធាតុ ព្យាបាទធាតុ វិហឹសាធាតុ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មា ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ តយោ ធម្មា ភាវេតព្វា ។ កតមេ តយោ ។ កាមធាតុយា បហានាយ នេក្ខម្មធាតុ ភាវេតព្វា ព្យាបាទធាតុយា បហានាយ អព្យាបាទធាតុ ភាវេតព្វា វិហឹសាធាតុយា បហានាយ អវិហឹសាធាតុ ភាវេតព្វា ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ ឥមេ តយោ ធម្មា ភាវេតព្វាតិ ។

(១១២) តយោមេ ភិក្ខវេ ធម្មា ។ កតមេ តយោ ។ អស្សាទទិដ្ឋិ អត្តានុទិដ្ឋិ មិច្ឆាទិដ្ឋិ ។



គឺបុគ្គលត្រូវចំរើននេក្ខម្មសញ្ញា ដើម្បីលះកាមសញ្ញា ១ ត្រូវចំរើនអព្យាបាទសញ្ញា ដើម្បីលះព្យាបាទសញ្ញា ១ ត្រូវចំរើនអវិហឹសាសញ្ញា ដើម្បីលះវិហឹសាសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។

(១១១) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ ៣ យ៉ាង ។ ៣ យ៉ាង តើដូចម្តេច ។ គឺកាមធាតុ ១ ព្យាបាទធាតុ ១ វិហឹសាធាតុ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាង បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។ ៣ យ៉ាងតើដូចម្តេច ។ គឺបុគ្គលត្រូវចំរើននេក្ខម្មធាតុ ដើម្បីលះកាមធាតុ ១ ត្រូវចំរើនអព្យាបាទធាតុ ដើម្បីលះព្យាបាទធាតុ ១ ត្រូវចំរើនអវិហឹសាធាតុ ដើម្បីលះវិហឹសាធាតុ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

(១១២) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មាន ៣ យ៉ាង។ ៣ យ៉ាង តើដូចម្តេច។ គឺអស្សាទទិដ្ឋិ (យល់ថាសប្បាយទៀង) ១ អត្តានុទិដ្ឋិ(*) ១ មិច្ឆាទិដ្ឋិ ១ ។

---

* បានដល់សក្កាយទិដ្ឋិ ២០ ប្រការ ដែលមានស្រាយទុក ។ អដ្ឋកថា ។

ឥមេ ខោ ភិក្ខវេ តយោ ធម្មា ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ តយោ ធម្មា ភាវេតព្វា ។ កតមេ តយោ ។ សស្សតទិដ្ឋិយា បហានាយ អនិច្ចសញ្ញា ភាវេតព្វា អត្តានុទិដ្ឋិយា បហានាយ អនត្តសញ្ញា ភាវេតព្វា មិច្ឆាទិដ្ឋិយា បហានាយ សម្មាទិដ្ឋិ ភាវេតព្វា ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ ឥមេ តយោ ធម្មា ភាវេតព្វាតិ ។

(១១៣) តយោមេ ភិក្ខវេ ធម្មា ។ កតមេ តយោ ។ អរតិ វិហិំសា អធម្មចរិយា ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មា ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ តយោ ធម្មា ភាវេតព្វា ។ កតមេ តយោ ។ អរតិយា បហានាយ មុទិតា ភាវេតព្វា វិហិំសាយ បហានាយ អវិហិំសា ភាវេតព្វា អធម្មចរិយាយ បហានាយ ធម្មចរិយា ភាវេតព្វា ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ ឥមេ តយោ ធម្មា ភាវេតព្វាតិ ។



ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាង បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលត្រូវចំរើន អនិច្ចសញ្ញា ដើម្បីលះសស្សតទិដ្ឋិ ១ ត្រូវចំរើនអនត្តសញ្ញា ដើម្បីលះអត្តានុទិដ្ឋិ ១ ត្រូវចំរើនសម្មាទិដ្ឋិ ដើម្បីលះមិច្ឆាទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

(១១៣) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មាន ៣ យ៉ាង ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺអរតិ (សេចក្ដីមិនត្រេកអរ) ១ វិហិំសា (ការបៀតបៀន) ១ អធម្មចរិយា (ការមិនប្រព្រឹត្តធម៌) ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ទាំងឡាយ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាង បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលត្រូវចំរើន មុទិតា ដើម្បីលះអរតិ ១ ត្រូវចំរើនអវិហិំសា ដើម្បីលះវិហិំសា ១ ត្រូវចំរើនធម្មចរិយា ដើម្បីលះអធម្មចរិយា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៣ យ៉ាងនេះ បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

(១០៦) តយោមេ ភិក្ខវេ ធម្មា ។ កតមេ តយោ អសន្តុដ្ឋិតា អសម្បជញ្ញំ មហិច្ឆតា ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មា ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ តយោ ធម្មា ភាវេតព្វា ។ កតមេ តយោ ។ អសន្តុដ្ឋិតាយ បហានាយ សន្តុដ្ឋិតា ភាវេតព្វា អសម្បជញ្ញស្ស បហានាយ សម្បជញ្ញំ ភាវេតព្វំ មហិច្ឆតាយ បហានាយ អប្បិច្ឆតា ភាវេតព្វា ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ ឥមេ តយោ ធម្មា ភាវេតព្វាតិ ។

(១០៧) តយោមេ ភិក្ខវេ ធម្មា ។ កតមេ តយោ ។ ទោវចស្សតា បាបមិត្តតា ចេតសោ វិក្ខេបោ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មា ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ តយោ ធម្មា ភាវេតព្វា ។ កតមេ តយោ ។ ទោវចស្សតាយ បហានាយ សោវចស្សតា ភាវេតព្វា បាបមិត្តតាយ បហានាយ កល្យាណមិត្តតា ភាវេតព្វា



(១០៦) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មាន ៣ យ៉ាង ។ ៣ យ៉ាង តើដូចម្តេច ។ គឺអសន្តុដ្ឋិតា (សេចក្តីមិនសន្តោស) ១ អសម្បជញ្ញៈ (មិនដឹងខ្លួន) ១ មហិច្ឆតា (សេចក្តីប្រាថ្នាច្រើន) ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាង បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។ ៣ យ៉ាង តើដូចម្តេច ។ គឺបុគ្គលត្រូវចំរើនសន្តុដ្ឋិតា ដើម្បីលះអសន្តុដ្ឋិតា ១ ត្រូវចំរើន សម្បជញ្ញៈ ដើម្បីលះអសម្បជញ្ញៈ ១ ត្រូវចំរើន អប្បិច្ឆតា ដើម្បីលះមហិច្ឆតា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

(១០៧) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មាន ៣ យ៉ាង ។ ធម៌ ៣ យ៉ាង តើដូចម្តេច ។ គឺទោវចស្សតា (ភាពនៃបុគ្គលជាអ្នកប្រដៅបានដោយក្រ) ១ បាបមិត្តតា (ភាពនៃបុគ្គលជាអ្នកមានមិត្រអាក្រក់) ១ សេចក្តីរវើរវាយចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាង បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។ ៣ យ៉ាង តើដូចម្តេច ។ គឺបុគ្គលត្រូវចំរើនសោវចស្សតា (ភាពនៃបុគ្គលជាអ្នកប្រដៅបានដោយងាយ) ដើម្បីលះទោវចស្សតា ១ ត្រូវចំរើនកល្យាណមិត្តតា ដើម្បីលះបាបមិត្តតា ១

ចេតសោ វិក្ខេបស្ស បហានាយ អានាបានស្សតិ ភាវេតព្វា ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ ឥមេ តយោ ធម្មា ភាវេតព្វាតិ ។

(១១៦) តយោ មេ ភិក្ខវេ ធម្មា ។ កតមេ តយោ ។ ឧទ្ធច្ចំ អសំវរោ បមាទោ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មា ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ តយោ ធម្មា ភាវេតព្វា ។ កតមេ តយោ ។ ឧទ្ធច្ចស្ស បហានាយ សមថោ ភាវេតព្វោ អសំវរស្ស បហានាយ សំវរោ ភាវេតព្វោ បមាទស្ស បហានាយ អប្បមាទោ ភាវេតព្វោ ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ ធម្មានំ បហានាយ ឥមេ តយោ ធម្មា ភាវេតព្វាតិ ។

និដ្ឋិតោ ទុតិយោ ។

## តស្សុទ្ទានំ

អកុសលទុច្ចរិតវិតក្កា- សញ្ញា ធាតូតិ វុច្ចតិ
អស្សាទអរតិ តុដ្ឋិ ទុវេ ច ឧទ្ធច្ចេន វគ្គោតិ ។



ត្រូវចំរើនអានាបានស្សតិ ដើម្បីលះសេចក្តីរាយមាយចិត្ត១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

(១១៦) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មាន ៣ យ៉ាង ។ ៣ យ៉ាង តើដូចម្តេច ។ គឺឧទ្ធច្ចៈ (សេចក្តីរាយមាយ)១ អសំវរៈ (សេចក្តីមិនសង្រួម)១ បមាទៈ (សេចក្តីធ្វេសប្រហែស)១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាង បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។ ៣ យ៉ាង តើដូចម្តេច ។ គឺបុគ្គលត្រូវចំរើនសមថៈ ដើម្បីលះឧទ្ធច្ចៈ១ ត្រូវចំរើនសំវរៈ ដើម្បីលះអសំវរៈ១ ត្រូវចំរើនអប្បមាទៈ ដើម្បីលះបមាទៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចំរើន ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

ចប់ វគ្គ ។

## ឧទ្ទាននៃវគ្គនោះគឺ

និយាយអំពីអកុសល ១ ទុច្ចរិត ១ វិតក្កៈ ១ សញ្ញា ១ ធាតុ ១
អស្សាទទិដ្ឋិ ១ អរតិ ១ តុដ្ឋិពីរលើក១ ឧទ្ធច្ចៈ ១ ។

## វគ្គសង្គហិតា សុត្តន្តា

(១១៧) ឆ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ កាយេ កាយានុបស្សី វិហរិតុំ ។ កតមេ ឆ ។ កម្មារាមតំ ភស្សារាមតំ និទ្ទារាមតំ សង្គណិការាមតំ ឥន្ទ្រិយេសុ អគុត្តទ្វារតំ ភោជនេ អមត្តញ្ញុតំ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ អប្បហាយ អភព្វោ កាយេ កាយានុបស្សី វិហរិតុំ ។

(១១៨) ឆ ភិក្ខវេ ធម្មេ បហាយ ភព្វោ កាយេ កាយានុបស្សី វិហរិតុំ ។ កតមេ ឆ ។ កម្មារាមតំ ភស្សារាមតំ និទ្ទារាមតំ សង្គណិការាមតំ ឥន្ទ្រិយេសុ គុត្តទ្វារតំ ភោជនេ មត្តញ្ញុតំ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ បហាយ ភព្វោ កាយេ កាយានុបស្សី វិហរិតុន្តិ ។

## វគ្គសង្គហិតសុត្តន្ត

(១១៧) ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះធម៌ ៦ យ៉ាងចេញទេ ជាអ្នកមិនគួរពិចារណាឃើញកាយ ក្នុងកាយ ។ ៦ យ៉ាង តើអ្វីខ្លះ ? គឺសេចក្តីត្រេកអរក្នុងការងារ ១ សេចក្តីត្រេកអរក្នុងនិយាយពាក្យ ១ សេចក្តីត្រេកអរក្នុងការដេក ១ សេចក្តីត្រេកអរក្នុងការប្រឡូកប្រឡំ ដោយពួកគណៈ ១ សេចក្តីមិនសង្រួមទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ១ សេចក្តីមិនដឹងប្រមាណ ក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះធម៌ ៦ យ៉ាងនេះចេញទេ ជាអ្នកមិនគួរពិចារណាឃើញកាយ ក្នុងកាយឡើយ ។

(១១៨) ម្នាលភិក្ខុទាំងឡាយ បុគ្គលលះធម៌ ៦ យ៉ាងចេញ ជាអ្នកគួរពិចារណាឃើញកាយ ក្នុងកាយ ។ ៦ យ៉ាង តើអ្វីខ្លះ ? គឺសេចក្តីត្រេកអរក្នុងការងារ ១ សេចក្តីត្រេកអរក្នុងនិយាយពាក្យ ១ សេចក្តីត្រេកអរក្នុងការដេក ១ សេចក្តីត្រេកអរក្នុងការប្រឡូកប្រឡំ ដោយពួកគណៈ ១ សេចក្តីមិនសង្រួមទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ១ សេចក្តីមិនដឹងប្រមាណ ក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះធម៌ ៦ យ៉ាងនេះចេញ ជាអ្នកគួរពិចារណាឃើញកាយ ក្នុងកាយបាន ។

(១១៩) ឆ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ អជ្ឈត្តំ កាយេ កាយានុបស្សី វិហរិតុំ ។បេ។ ពហិទ្ធា កាយេ... អជ្ឈត្តពហិទ្ធា កាយេ...

(១២០) ឆ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ វេទនាសុ វេទនានុបស្សី វិហរិតុំ ។បេ។ អជ្ឈត្តំ វេទនាសុ... ពហិទ្ធា វេទនាសុ... អជ្ឈត្តពហិទ្ធា វេទនាសុ...

(១២១) ឆ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ ចិត្តេ ចិត្តានុបស្សី វិហរិតុំ ។បេ។ អជ្ឈត្តំ ចិត្តេ... ពហិទ្ធា ចិត្តេ... អជ្ឈត្តពហិទ្ធា ចិត្តេ...

(១២២) ឆ ភិក្ខវេ ធម្មេ អប្បហាយ អភព្វោ ធម្មេសុ ធម្មានុបស្សី វិហរិតុំ ។បេ។ អជ្ឈត្តំ ធម្មេសុ... ពហិទ្ធា ធម្មេសុ... អជ្ឈត្តពហិទ្ធា ធម្មេសុ ធម្មានុបស្សី វិហរិតុំ ។ កតមេ ឆ ។ កម្មារាមតំ ភស្សារាមតំ និទ្ទារាមតំ សង្គណិការាមតំ



(១១៩) ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះធម៌ ៦ យ៉ាង ជាអ្នកមិនគួរពិចារណាឃើញកាយ ក្នុងកាយជាខាងក្នុង ។បេ។ ក្នុងកាយខាងក្រៅ... ក្នុងកាយ ទាំងខាងក្នុង ទាំងខាងក្រៅ...

(១២០) ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះធម៌ ៦ យ៉ាង ជាអ្នកមិនគួរពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយ ។បេ។ ក្នុងវេទនាទាំងឡាយ ជាខាងក្នុង... ក្នុងវេទនាទាំងឡាយ ជាខាងក្រៅ... ក្នុងវេទនាទាំងឡាយ ទាំងខាងក្នុងទាំងខាងក្រៅ...

(១២១) ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះធម៌ ៦ យ៉ាង ជាអ្នកមិនគួរពិចារណាឃើញចិត្ត ក្នុងចិត្ត ។បេ។ ក្នុងចិត្តជាខាងក្នុង... ក្នុងចិត្តជាខាងក្រៅ ក្នុងចិត្តទាំងខាងក្នុង ទាំងខាងក្រៅ...

(១២២) ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះធម៌ ៦ យ៉ាង មិនគួរពិចារណាឃើញធម៌ ក្នុងធម៌ទាំងឡាយ ។បេ។ ក្នុងធម៌ទាំងឡាយជាខាងក្នុង... ក្នុងធម៌ទាំងឡាយ ជាខាងក្រៅ... ពិចារណាឃើញធម៌ ក្នុងធម៌ទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅ ។ ធម៌ ៦ យ៉ាង តើដូចម្តេច ។ គឺសេចក្តីត្រេកអរក្នុងការងារ ១ សេចក្តីត្រេកអរក្នុងតិរច្ឆានកថា ១ សេចក្តីត្រេកអរក្នុងការដេក ១ សេចក្តីត្រេកអរក្នុងការច្រឡូកច្រឡំ ដោយពួកគណៈ ១

ឥន្ទ្រិយេសុ អគុត្តទ្វារំ ភោជនេ អមត្តញ្ញុំ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ អប្បហាយ អភព្វោ អជ្ឈត្តពហិទ្ធា ធម្មេសុ ធម្មានុបស្សី វិហរិតុំ ។

(១៦៣) ឆ ភិក្ខវេ ធម្មេ បហាយ ភព្វោ អជ្ឈត្តពហិទ្ធា ធម្មេសុ ធម្មានុបស្សី វិហរិតុំ ។ កតមេ ឆ ។ កម្មារាមតំ ។ បេ ។ ភោជនេ អមត្តញ្ញុំ ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មេ បហាយ ភព្វោ អជ្ឈត្តពហិទ្ធា ធម្មេសុ ធម្មានុបស្សី វិហរិតុន្តិ ។

(១៦៤) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ តបុស្សោ គហបតិ តថាគតេ និដ្ឋង្គតោ អមតទ្ទសោ អមតំ សច្ឆិកត្វា ឥរិយតិ ។ កតមេហិ ឆហិ ។ ពុទ្ធេ អវេច្ចប្បសាទេន ធម្មេ អវេច្ចប្បសាទេន សង្ឃេ អវេច្ចប្បសាទេន អរិយេន សីលេន អរិយេន ញាណេន អរិយាយ វិមុត្តិយា ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ តបុស្សោ គហបតិ តថាគតេ និដ្ឋង្គតោ អមតទ្ទសោ អមតំ សច្ឆិកត្វា ឥរិយតីតិ ។



សេចក្តីមិនសង្រួមទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ១ សេចក្តីមិនដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះធម៌ ៦ យ៉ាងនេះហើយ ជាអ្នកមិនគួរពិចារណាឃើញធម៌ ក្នុងធម៌ទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅឡើយ ។

(១៦៣) ម្នាលភិក្ខុទាំងឡាយ បុគ្គលលះធម៌ ៦ យ៉ាងបានហើយ ជាអ្នកគួរពិចារណាឃើញធម៌ ក្នុងធម៌ទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅ ។ ៦ យ៉ាង តើដូចម្តេច ។ គឺសេចក្តីត្រេកអរក្នុងការងារ ១ ។ បេ ។ មិនដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះធម៌ ៦ យ៉ាងនេះបាន ជាអ្នកគួរពិចារណាឃើញធម៌ ក្នុងធម៌ទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅ ។

(១៦៤) ម្នាលភិក្ខុទាំងឡាយ តបុស្សគហបតីប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកអស់សង្ស័យ ក្នុងព្រះតថាគត ជាអ្នកឃើញអមតធម៌ ហើយធ្វើឲ្យជាក់ច្បាស់នូវអមតធម៌ ។ ៦ យ៉ាង តើដូចម្តេច ។ គឺសេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះពុទ្ធ ១ សេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះធម៌ ១ សេចក្តីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះសង្ឃ ១ សីលដ៏ប្រសើរ ១ ញាណដ៏ប្រសើរ ១ វិមុត្តិដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ តបុស្សគហបតីប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកអស់សង្ស័យក្នុងព្រះតថាគត ជាអ្នកឃើញអមតធម៌ ហើយធ្វើឲ្យជាក់ច្បាស់នូវអមតធម៌ ។

(១២៩) ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភល្លិកោ គហបតិ សុទត្តោ គហបតិ អនាថបិណ្ឌិកោ ចិត្តោ គហបតិ មច្ឆិកាសណ្ឌិកោ ហត្ថកោ អាឡវកោ មហានាមោ សក្កោ ឧគ្គោ គហបតិ វេសាលិកោ ឧគ្គតោ គហបតិ សូរោ អម្ពដ្ឋោ ជីវកោ កោមារភច្ចោ នកុលបិតា គហបតិ តវកណ្ណិកោ គហបតិ បូរណោ គហបតិ ឥសិទត្តោ គហបតិ សន្ធានោ គហបតិ វិជយោ គហបតិ វជ្ជិយមហិតោ គហបតិ មេណ្ឌកោ គហបតិ វាសេដ្ឋោ ឧបាសកោ អរិដ្ឋោ ឧបាសកោ សារគ្គោ ឧបាសកោ តថាគតេ និដ្ឋង្គតោ អមតទ្ទសោ អមតំ សច្ឆិកត្វា ឥរិយតិ ។ កតមេហិ ឆហិ ។ ពុទ្ធេ អវេច្ចប្បសាទេន ធម្មេ អវេច្ចប្បសាទេន សង្ឃេ អវេច្ចប្បសាទេន អរិយេន សីលេន អរិយេន ញាណេន អរិយាយ វិមុត្តិយា ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ សារគ្គោ ឧបាសកោ តថាគតេ និដ្ឋង្គតោ អមតទ្ទសោ អមតំ សច្ឆិកត្វា ឥរិយតីតិ ។



(១២៩) ម្នាលភិក្ខុទាំងឡាយ ភល្លិកគហបតី ១ សុទត្តគហបតីអនាថបិណ្ឌិក ១ ចិត្តគហបតី នៅក្នុង មច្ឆិកាសណ្ឌៈ ១ ហត្ថកអាឡវកៈ ១ មហានាមសក្កៈ ១ ឧគ្គគហបតី នៅក្នុងក្រុងវេសាលី ១ ឧគ្គតគហបតី ១ សូរអម្ពដ្ឋ ១ ជីវកកោមារភច្ច ១ នកុលបិតាគហបតី ១ តវកណ្ណិកគហបតី ១ បូរណគហបតី ១ ឥសិទត្តគហបតី ១ សន្ធានគហបតី ១ វិជយគហបតី ១ វជ្ជិយមហិតគហបតី ១ មេណ្ឌកគហបតី ១ វាសេដ្ឋឧបាសក ១ អរិដ្ឋឧបាសក ១ សារគ្គឧបាសក ១ សុទ្ធតែប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកអស់សេចក្ដីសង្ស័យក្នុងព្រះតថាគត ជាអ្នកឃើញអមតធម៌ ហើយធ្វើឲ្យជាក់ច្បាស់នូវអមតធម៌ ។ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះពុទ្ធ ១ សេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះធម៌ ១ សេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះសង្ឃ ១ សីលដ៏ប្រសើរ ១ ញាណដ៏ប្រសើរ ១ វិមុត្តិដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ សារគ្គឧបាសក ប្រកបដោយធម៌ទាំង ៦ យ៉ាងនេះ ជាអ្នកអស់សេចក្ដីសង្ស័យក្នុងព្រះតថាគត ឃើញអមតធម៌ ហើយធ្វើឲ្យជាក់ច្បាស់នូវអមតធម៌ ។

(១៦៦) រាគស្ស ភិក្ខវេ អភិញ្ញាយ ឆ ធម្មា ភាវេតព្វា ។ កតមេ ឆ ។ ទស្សនានុត្តរិយំ សវនានុត្តរិយំ លាភានុត្តរិយំ សិក្ខានុត្តរិយំ បារិចរិយានុត្តរិយំ អនុស្សតានុត្តរិយំ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ ឆ ធម្មា ភាវេតព្វាតិ ។

(១៦៧) រាគស្ស ភិក្ខវេ អភិញ្ញាយ ឆ ធម្មា ភាវេតព្វា ។ កតមេ ឆ ។ ពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ សីលានុស្សតិ ចាគានុស្សតិ ទេវតានុស្សតិ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ ឆ ធម្មា ភាវេតព្វាតិ ។

(១៦៨) រាគស្ស ភិក្ខវេ អភិញ្ញាយ ឆ ធម្មា ភាវេតព្វា ។ កតមេ ឆ ។ អនិច្ចសញ្ញា អនិច្ចេ ទុក្ខសញ្ញា ទុក្ខេ អនត្តសញ្ញា បហានសញ្ញា វិរាគសញ្ញា និរោធសញ្ញា ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ ឆ ធម្មា ភាវេតព្វាតិ ។



(១៦៦) ម្នាលភិក្ខុទាំងឡាយ បុគ្គលគួរតែចំរើនធម៌ ៦ ប្រការ ដើម្បីឲ្យបានដឹងច្បាស់នូវរាគៈ ។ ៦ ប្រការតើអ្វីខ្លះ ។ គឺការឃើញដ៏ប្រសើរ ១ ការស្តាប់ដ៏ប្រសើរ ១ ការបានដ៏ប្រសើរ ១ ការរៀនដ៏ប្រសើរ ១ ការបម្រើដ៏ប្រសើរ ១ ការរលឹកដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៦ ប្រការនេះ បុគ្គលគួរតែចំរើន ដើម្បីឲ្យបានដឹងច្បាស់នូវរាគៈ ។

(១៦៧) ម្នាលភិក្ខុទាំងឡាយ បុគ្គលគួរតែចំរើនធម៌ ៦ ប្រការ ដើម្បីឲ្យបានដឹងច្បាស់នូវរាគៈ ។ ៦ ប្រការតើអ្វីខ្លះ ។ គឺពុទ្ធានុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ សីលានុស្សតិ ១ ចាគានុស្សតិ ១ ទេវតានុស្សតិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៦ ប្រការនេះ បុគ្គលគួរតែចំរើន ដើម្បីឲ្យបានដឹងច្បាស់នូវរាគៈ ។

(១៦៨) ម្នាលភិក្ខុទាំងឡាយ ធម៌ ៦ ប្រការ បុគ្គលគួរតែចំរើន ដើម្បីឲ្យបានដឹងច្បាស់នូវរាគៈ ។ ៦ ប្រការតើអ្វីខ្លះ ។ គឺសេចក្តីសំគាល់ថាមិនទៀង ក្នុងរបស់មិនទៀង ១ សេចក្តីសំគាល់ថាជាទុក្ខ ក្នុងរបស់ជាទុក្ខ ១ សេចក្តីសំគាល់ថាមិនមែនជារបស់ខ្លួន ១ សេចក្តីសំគាល់ក្នុងការលះ ១ សេចក្តីសំគាល់ក្នុងការប្រាសចាកតម្រេក ១ សេចក្តីសំគាល់ក្នុងការរលត់ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៦ ប្រការនេះ បុគ្គលគួរតែចំរើន ដើម្បីឲ្យបានដឹងច្បាស់នូវរាគៈ ។

(៦៤៩) រាគស្ស ភិក្ខវេ បរិញ្ញាយ ។បេ។ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ ឥមេ ឆ ធម្មា ភាវេតព្វា ។បេ។

(៦៥០) ទោសស្ស មោហស្ស កោធស្ស ឧបនាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ ។បេ។ ឥមេ ខោ ភិក្ខវេ ឆ ធម្មា ភាវេតព្វាតិ ។ ឥទមវោច ភគវា ។ អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ឆក្កនិបាតោ និដ្ឋិតោ ។



(៦៤៩) ម្នាលភិក្ខុទាំងឡាយ ដើម្បីកំណត់ដឹងនូវរាគៈ ។បេ។ ធម៌ ៦ យ៉ាងនេះ បុគ្គលគួរតែចំរើន ដើម្បីឲ្យអស់ហើយ លះបង់អស់ទៅ ស្ងប់ទៅ ប្រាសចាក រលត់ កំចាត់ចេញ រលាស់ចេញ ។បេ។

(៦៥០) ដើម្បីដឹងច្បាស់ កំណត់ដឹង អស់ហើយ លះអស់ទៅ ស្ងប់ទៅ ប្រាសចាក រលត់ កំចាត់ចេញ រលាស់ចេញ នូវទោសៈ មោហៈ ក្រោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ ។បេ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៦ ប្រការនេះឯង បុគ្គលគួរតែចំរើន ។ លុះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សូត្រនេះ ចប់ហើយ ភិក្ខុទាំងនោះ មានចិត្តរីករាយ ត្រេកអរ នឹងភាសិតរបស់ព្រះដ៏មានព្រះភាគ ។

ចប់ ឆក្កនិបាត ។

បិដកនេះស្កេនដោយ ឧបាសក សោម ទ្បើយ